គ្រួសជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ភាសាសង្គម

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៨ ខែមករា លេខ ១ ព.ស. ២៤៨៨ គ.ស. ១៩៤៦



ភ័ទ្រសុនីយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា		*ទំព័រ*
— ដំណាងជា	ព្រះធម្មាលីវង្ស សូរ - ហាយ . . .	៣
— ដំណាងមើលមិនឃើញ	ឃុនបណ្ឌាធុរ៍ក្ស ប៊ូ - ប៊ូ . . .	១៩
— បញ្ហាសង្ខាតក ភាគទី ៤ (តមក) . . .	បណ្ឌិតមហា ឈឹម - ស៊ីមន៍ . . .	២៤
ផ្នែកអក្សរសាស្ត្រ		
— ពេជ្រព្រះរាជា	លោក ស៊ីន - ហ៊ាន	៣៤
— រឿងភ្នំសំពៅនៅខែត្រចាត់ដំបង	អ្នកស្រី សារិះយ៉ាន	៤៥
— រឿងសាមកុក (តមក)	ឧកញ៉ា ខូ - ភន	៥៣
— ដំណាំងតាមខ្សល់ក្នុងកន្ត្រារ: (តទៅ) . .	លោក ផេង - ត្រីវ៉ា	៦០
— រឿងបល្ល័ង្កទិព្យ (តមក)	លោក ភ័ឃ - ប៊ុក	៧១
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ . .	លោក ជាម - តិន	៧៨
កំណាត់ទំនឹកប្រវត្តិការណ៍		
— ពិធីអនុស្សាវរីយ៍មហាសន្និបាតលើកទី ១២ នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ ១៩៥៦.	ពុទ្ធសាសនបណ្ឌិត្យ	៨៩

មួយឆ្នាំមាន ១២ សៀវភៅ — ដំណៃ្លជាវ ២៣០រ,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE: *Page*

— Jayakatha	*Vén. SO-HAY*	*3*
— Tout ce qui se trouve trop près n'est pas visible	*M. BOU-PO*	*19*
— Pannasajataka-vol. 4 (suite.) .	*M. CHHIM-SOUM*	*24*

PARTIE LITTERAIRE:

— Conte "Le Diamant du Raja"..	*M. SIN-HEAN*	*34*
— Historique du Phnom-Sampeou	*Mme SRIN-SARIS-YANN* .	*45*
— Histoire de SAMKOK (suite). .	*Oknha NOU-KAN*.	*53*
— Le souffle du désert (suite) .	*M. PHENG-CHRIV* . . .	*60*
— Les trente deux récits du TRONE (suite)	*M. RAY BUC*.	*71*
— Activités de la Commission des Moeurs et Coutumes.	*M. CHAP-PIN*	*78*

NOTES ET CHRONIQUES:

—Réunion annuelle des dignitaires religieux pour l'année 1936 . .	*Institut Bouddhique*	*89*

Prix d'abonnement annuel (comprenant 12 numéros) 2308.00

ជ័យកថា

ព្រះឧត្តមលិខិត ស្សរ - ហាយ ក្រុមដំនុំព្រះត្រៃបិដក

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

វេលានេះ សូមសំដែងអំពីពាក្យថា "ជ័យ" ដូចសេចក្តីអធិប្បាយតាមចារីតនីតិអដ្ឋកថា តទៅនេះ ។

ពាក្យ "ជ័យ" ប្រែថា "ការឈ្នះឬជំនះ" ផ្ទុយគ្នា នឹងពាក្យ "បរាជ័យ" ដែលប្រែថា "ចាញ់" ។ អ្នកខ្វះដោយចូលចិត្តខុស យកពាក្យ "អបរាជ័យ" មកប្រែនិយាយក្នុងន័យប្រយោគថា "ចាញ់" ទៅវិញ តាមដែលពិតនោះ "អបរាជ័យ" ប្រែថា "មិនចាញ់" បានសេចក្តីថា "ឈ្នះ" ដូចជាពាក្យថា "ជ័យ" ដែរ ។ ដំណើរនេះ សូមចាំទុកជាគំ ថា ជ័យ "ការឈ្នះ" បរាជ័យ "ការចាញ់" អបរាជ័យ "មិនចាញ់តែឈ្នះ" ។

ពួកបុថុជ្ជនភាគច្រើន សុទ្ធតែត្រូវការចង់បានទទួលជ័យជំនះ មិនមាននរណាមួយបដិសេធចោលទទួលជ័យជំនះឡើយ ។ ការឈ្នះមានច្រើន

យ៉ាងគឺ ឈ្នះដោយចំចាំង, ដោយគោគសម្បត្តិ, ដោយល្បែងភ្នាល់ មានបៀកៅជាដើម ។ អ្នកដែលចុះស្មាមកងចំចាំង ឬកងការភ្នាល់ សុទ្ធតែត្រូវការចង់ឈ្នះគេជាជាងាប ខំរកឧបាយកលដើម្បីឲ្យបានតែងាងឈ្នះ ។

គួប្រហាងប្រដែងគាំងពីម្ខាក់ម្ខាងទៀងទៅ សុទ្ធតែប្រឹងប្រែងដោយកម្លាំងកាយទឹងកម្លាំងប្រាជ្ញា ប្រកួតដណ្តើមយកជ័យជំនះគាំងអស់គ្នា តែការឈ្នះនោះមានតែមួយ, បើអ្នកម្ខាងយកជ័យបាន, អ្នកម្ខាងក៏ត្រូវបាននូវបរាជ័យ គឺថា បើអ្នកឈ្នះមាន, អ្នកចាញ់ក៏មាន, បើមិនមានអ្នកឈ្នះ, អ្នកចាញ់ក៏មិនមានដែរ ។

មនុស្សគាត់ច្រើនដែលត្រូវការចង់បាននូវជ័យជំនះនោះ ព្រោះការឈ្នះរមែងបានកិត្តិសព្ទសរសើរញាតិផង បានសិទ្ធិអំណាចតេជះបរិបូណ៌ខ្ពង់ខ្ពស់ គាំងលាភយសសក្តិចំរើនរុងរឿងផង ។ ការឈ្នះរបស់ប្រជាជនក្នុងលោកនេះជាសភាវៈមិនទៀង តែងអណ្តែត តែងធ្លាក់ទៅលើពួកជនឯណោះម្តងឯណោះម្តង ឥតមានបឋមទៅកងពួកជនមួយៗជាទៀងប្រាកដឡើយ គឺថាជួនកាលជ័យជំនះទៅលើអ្នកនោះ, ជួនកាលមកនៅលើអ្នកនេះ ស្រេចទឹងឥទ្ធិពលរបស់មនុស្ស, បើអ្នកណាមានឥទ្ធិពលខ្លាំងពូកែជាង អ្នកនោះក៏ត្រូវបាននូវជ័យជំនះ, បើអ្នកណាមានឥទ្ធិពលខ្សោយជាង អ្នកនោះក៏ត្រូវបាននូវបរាជ័យ គឺការចាញ់ ។

ក្នុងព្រះពុទ្ធសាសនា ក៏មានគោលបំណងកងការឈ្នះ និយមយកជ័យជំនះនេះដែរ ប៉ុន្តែមិនមែនជ័យជំនះ ដូចជាជ័យជំនះរបស់ប្រជាជន

ក្នុងលោកនេះឡើយ ។ ព្រោះហេតុនោះពាក្យថា "ជ័យ" ដែលប្រែថា "ការឈ្នះប្លុងនេះ" នេះ គួរចែកចេញជា ២ យ៉ាងគឺ៖

១— ពហិជ័យ ការឈ្នះខាងក្រៅ

២— អង្គោជ័យ ការឈ្នះខាងក្នុង ។

អធិប្បាយពង្រីកសេចក្តី

១— ការឈ្នះខាងក្រៅ, ការឈ្នះខាងក្រៅសំដៅយកការឈ្នះអ្នកដទៃដោយល្បួងកាល់ក្តី ដោយការប្រឡងក្តី ដោយការប្បាំងក្តី ឬដោយហេតុណាមួយក្តី ។ ការឈ្នះនេះជាករណីយកិច្ចក្នុងផ្លូវលោក ដែលប្រជាជនត្រូវការចង់បានពន់ពេកណាស់ ។ ពួកជនដែលឈ្នះអ្វីមួយ ដូចគាលឈ្នះដោយផ្លូវសុចរិត, ដូចគាលដោយផ្លូវទុច្ចរិត ។ បើឈ្នះដោយផ្លូវសុចរិត ក៏ពប់ថាជាការប្រសើរគ្រាន់បើក្នុងផ្លូវព្រះពុទ្ធសាសនា, បើឈ្នះដោយផ្លូវទុច្ចរិត ឈ្មោះថាជាអំពើអាក្រក់ថ្លៃថ្លៃបេង, អ្នកដែលឈ្នះដោយផ្លូវទុច្ចរិតនោះ ក៏អាចដឹងខ្លួនថាទុច្ចរិតដែរ ប៉ុន្តែចេះតែធ្វើទាំងបំពាន ។ ការឈ្នះខាងក្រៅនេះ គឺឈ្នះមនុស្សផងគ្នា គេពប់ថាជាឧត្តមគតិកងផ្លូវលោកមួយដែរ តែមិនមែនជាស្ថាពរជាប់មាំមួនយូរតទៅឡើយ តែងត្រូវប្រែប្រួលទៅវិញជាធម្មតា ។

ការឈ្នះខឹងការចាញ់នេះ ឈ្នះថាជាអំពើត្រឡប់ត្រឡិន មិនមែននាំឲ្យមានសន្តិភាពទេ ដោយហេតុថា ការឈ្នះខាងក្រៅនេះ កាលបើអ្នកណាបានហើយ អ្នកនោះត្រូវខំប្រឹងប្រែងរក្សាទុកនូវជំនះរបស់ខ្លួន

ដោយប្រយ័ត្នជាទីបំផុត ។ ការរក្សាខ្លួនឲ្យរួចផុតនូវជ័យជំនះនោះសោត កំនាំមកនូវសេចក្តីទុក្ខព្រួយភ័យផ្សេងៗយ៉ាងក្រៃលែងណាស់ទៅទៀត ។

អ្នកណាប្រាថ្នាចង់បានជ័យជំនះខាងក្រៅ អ្នកនោះរមែងទទួលទុក្ខលំបាកគ្រោះថ្នាក់ខាតបង់ជាច្រើនប្រការណាស់ គឺថាអ្នកដែលបានឈ្នះជ័យជំនះឈ្មោះថាប្រមូលមកនូវសេចក្តីទុក្ខភ័យ ។ អ្នកឈ្នះតែងបានឈ្នះការតុំគួនអំពីអ្នកចាញ់ ចំណែកខាងអ្នកចាញ់ ក៏រមែងដេកក្តៅក្រហាយជានិច្ច ។ ការឈ្នះនឹងចាញ់នេះ ឃើញថាសុទ្ធតែជាផ្លូវនាំមកនូវទុក្ខទោស ។

ពាក្យថា "ការឈ្នះ, ការចាញ់នៃមនុស្សទាំងគ្នា" ដូចអធិប្បាយមកនេះ ឈ្មោះថាជាអំពើខាងក្រៅក្របខ័ណ្ឌនៃព្រះពុទ្ធសាសនា គឺអំពើមិនប្រកបដោយគុណធម៌តាមផ្លូវព្រះពុទ្ធសាសនាឡើយ ។

๒.— ការឈ្នះខាងក្នុង, ការឈ្នះខាងក្នុងសំដៅយកជំនះកិលេសខ្លួនឯង ដែលមាននៅក្នុងខ្លួនរបស់យើងគ្រប់គ្នា ។ ការឈ្នះខាងក្នុងនេះ ត្រូវតាមគោលបំណងនៃព្រះពុទ្ធសាសនា ដែលតែងនិយមសរសើរជាទីបំផុត ថាជាកិច្ចប្រសើរជាងការអ្វីៗទាំងអស់ ។ កិលេសដែលមាននៅក្នុងខ្លួនសន្តានរបស់បុថុជ្ជនមានច្រើនយ៉ាង តែបើកប់ដោយខ្លឹមាន ๓ យ៉ាងគឺ លោភៈ ๑ ទោសៈ ๑ មោហៈ ๑ ។ កិលេសទាំង ๓ យ៉ាងនេះ ទុកជាឫសគល់នៃកិលេសឯទៀតៗ, អ្នកដែលមានចក្ខុល្អ ប្រកបដោយញាណគតិ ទំញ៉ាយាមលះបង់នូវកិលេស ๓ យ៉ាងនេះ មិនបណ្តាយឲ្យខ្លួនទៅជាទាសកាតនៃកិលេសដែលតាចគ្រប

សង្កត់ញាំញីបាន ទំរ្រឹងតស៊ូដោយកុសលធម៌ជាច្រើនយ៉ាង មានការធ្វើទានក្សាសីលជាដើម, ទំរ្រឹងប្រតិបត្តិធម៌ដើម្បីបង្ក្រាបនូវកិលេសក្នុងខ្លួន ដរាបណាលំតែឈ្នះមិនឲ្យមានកិលេសគាំងនោះ ករកើតឡើងគ្របសង្កត់ខ្លួនឯងនៅតែបាន ។ ការឈ្នះកិលេសនេះឈ្មោះថាជាជ័យជំនះដ៏ប្រសើរចំផុត ចាត់ជាចរិយាល្អក្នុងផ្លូវធម៌ដោយពិត សមដូចព្រះពុទ្ធភាសិតថា

អត្តាហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា

ប៉ុណ្ណោះជាដើម ត្រែចថា "ការឈ្នះខ្លួនឯងជាការប្រសើរ ប៉ែកខាងពួកជនដែលឈ្នះគ្រាន់តែនេះ (តុំប្រសើរឡើយ) ព្រោះថាការឈ្នះខ្លួនឯងនោះ កាលបើយើងឈ្នះរបរហើយ មិនអាចនឹងត្រឡប់ចាញ់វិញបានទេ ទោះបីមនុស្សក្តី ទេវតាក្តី ព្រហ្មក្តី មារក្តី ក៏ដណ្តើមយកជ័យជំនះអំពីខ្លួនយើងវិញពុំបានឡើយ" ។

យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ សវេ សង្គាមជុត្តមោ

សេចក្តីថា "ជនណាឈ្នះពួកមនុស្ស ក្នុងសង្គ្រាមតាន់នាក់ក៏ដោយ ចំណែកខាងបុគ្គលនោះ ឈ្នះខ្លួនឯងតែម្នាក់បានឈ្មោះថាជាបុគ្គលដ៏ខ្ពស់ជាងអ្នកឈ្នះក្នុងសង្គ្រាម" ។

អធិប្បាយការឈ្នះខ្លួនឯង

ការឈ្នះខ្លួនឯងជាការប្រសើរជាងការឈ្នះអ្នកដទៃ, ពុទ្ធភាសិតនេះ

ចំគ្នីសេចក្តីឲ្យរៀបរៀញថា ការឈ្នះខ្លួនឯងទើបល្អ, ការចាញ់ខ្លួនឯងមិនល្អឡើយ ។

ពាក្យថា "ខ្លួនឯង" នេះបាលីហៅថា "អត្តា" ប្រែថា "ខ្លួនឬចិត្ត" សំស្ក្រឹតថា "អាត្ម័ន" ក្រាយទៅជាអាត្មា គឺបានដល់ចិត្ត ចេតសិកដែលមាននៅកន្លែងកាយរបស់មនុស្ស-សត្វ ។ មនុស្សពាំងអស់កន្លែងលោកនេះ តែងតែមានធម្មជាតិគឺកំណើតនៃធម៌មួយដែលជាតួនាមឥតមានរូបកាយពណ៌សម្បុរ ហើយមិនអាចមើលឃើញច្បាស់ដោយមំស-ចក្ខុទេ តែបើមិនបានខ្លួនសង្កត់សង្កិនក៏អាចនាំកាយឲ្យវិនាស, កាលបើគេបានខ្លួនឲ្យបានបានល្អហើយ គឺរមែងនាំមកនូវសេចក្តីសុខចំរើនដោយពិត ។ ធម្មជាតិនោះឯង គឺចិត្តនឹងចេតសិក ត្រង់នឹងពាក្យខ្មែរយើងថា "ខ្លួន" ។ សំដីដែលនិយាយថា "ខ្លួន" នេះជាប្រធាននៃកិច្ចការពាំងខាងល្អពាំងខាងអាក្រក់, កាលបើបុគ្គលប្រព្រឹត្តល្អក៏ព្រោះខ្លួនដែលបានបានល្អ គឺថាខ្លួនហ្នឹងឯងជាបច្ច័យនាំឲ្យបុគ្គលធ្វើល្អ, កាលបើខ្លួនយើងប្រកបដោយកិលេសគ្រោតគ្រាតខ្លាំង ឈ្មោះថាយើងមានខ្លួនអាក្រក់, កាលបើខ្លួនអាក្រក់ក៏រមែងដឹកនាំការយាត្រាឲ្យធ្លាក់អាក្រក់ផ្សេងៗ មានការសម្លាប់សត្វ, លួចប្លន់ឥតគេជាដើម ។

ពាក្យថា "ឈ្នះខ្លួនឯង" សំដៅយកការប្រយ័ត្ន, ការទប់ឬកាត់ខ្លួនមិនឲ្យខ្លួនលុះទៅកន្លែងអំណាចនៃកិលេសមានលោភៈជាដើមបាន, មួយទៀត ការឈ្នះខ្លួនឯងនេះ ដោយវិធីយ៉ាងសង្ខេបមាន ២ យ៉ាង គឺសញ្ញាមវិធី បានដល់ការសង្រួមប្រយ័ត្នទ្វារអារម្មណ៍ពាំងខាងក្នុងពាំងខាង

ត្រៃ មិនបណ្តាយឲ្យបាបធម៌ចាំងឡាយមានអកិដ្ឋា ឬ លោកៈ ជាដើមគ្របសង្កត់ចិត្តរបស់យើងបាន ១, ទីម៉ិរិធី បានដល់ការខ្ជាន់ពត់គម្រើចិត្ត, គាបចិត្ត, ខន់ឥតញ៉ចិត្តមិនបណ្តាយឲ្យចិត្តសេពគប់នូវអារម្មណ៍មិនល្អ ធ្វើចិត្តឲ្យបិតនៅក្នុងអំណាចនៃបញ្ញា គឺវិបស្សនាបញ្ញារហូតទាល់តែបានមគ្គផលនិព្វាន ១ ។

ការខ្ជាន់ខ្ជួនបានដោយវិធីពីរយ៉ាង មិនឲ្យចិត្តលុះលង់ដោយអំណាចកិលេសដូចអធិប្បាយមកនេះ ឈ្មោះថា "ឈ្នះខ្ជួនឯង" ។ ការផ្ទុសច្រវែកបណ្តែតបណ្តាយឲ្យចិត្តត្រាច់ឆ្ពោះទៅតាមទំនើង ឥតមានការច្រៀតច្រក់ទល់ ឈ្មោះថា "ចាញ់ខ្ជួនឯង" ។ ការឈ្នះខ្ជួនឯងលោកពន្យល់ថា ជាការប្រសើរ ដោយហេតុថា ជំនះនោះជាជំនះឈ្នះពុម មិនត្រឡប់ចាញ់វិញឡើយ ។ កាលបើបុគ្គលមានជ័យជំនះឈ្នះកិលេសចាំងត្រៃតត្រៃត កណ្តាល ស្ងិត អស់រលីងចាកខន្ធសន្តានហើយ ឈ្មោះថាជាអ្នកបានដល់នូវព្រះនិព្វាន, ឈ្មោះថាជាអ្នកឈ្នះពុមតទៅ ឥតមានអ្នកណាមួយដណ្តើមយកជ័យជំនះនោះឲ្យត្រឡប់ទៅជាចាញ់វិញបានឡើយ, ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធខន់សរសើរថា "ការឈ្នះខ្ជួនឯងជាការប្រសើរ" ដូចបរិយាយមកនេះ ។

ព្រះសម្មាសម្ពុទ្ធខន់សំដែងធម៌ទេសនាចុងជាគោល ដើម្បីឲ្យប្រជាជនប្រតិបត្តិយកជ័យជំនះ ខាងក្នុងសន្តានដូចពុទ្ធការិតកថាគម្ពីរធម្មបទខុទ្ទកនិកាយ ដែលបានដំកល់ចុងក្នុងបទខាងដើមថា

អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

ប្រែថា "បុគ្គលគប្បីឈ្នះខ្មាំងមនុស្សក្រោធដោយសេចក្តីមិនក្រោធ, គប្បីឈ្នះខ្មាំងមនុស្សមិនល្អ ដោយសេចក្តីល្អ, គប្បីឈ្នះខ្មាំងមនុស្សកំណាញ់ដោយការឲ្យ, គប្បីឈ្នះខ្មាំងមនុស្សអ្នកនិយាយមិនពិតដោយពាក្យពិត" ។

ពុទ្ធភាសិតនេះ សំដែងអំពីវិធីយកជ័យជំនះ ប្លែកវិធីផ្សេងៗ ដែលអាចញែកចេញជា ៤ អត្ថបទ ដូចសេចក្តីអធិប្បាយចំពោះអត្ថបទមួយៗ តទៅនេះ ៖

១— ឈ្នះខ្មាំងមនុស្សក្រោធដោយសេចក្តីមិនក្រោធ ជាន សេចក្តីថា "មិនតបតដោយកាយវាចាចិត្ត គឺមិនព្រមឲ្យចិត្តកម្រើកក្រែវក្រោធទៅរកមនុស្សអ្នកក្រោធ" ។ ធម្មតាសេចក្តីក្រែវក្រោធខុកដូចជាភ្លើង, ឯការអត់ធន់តស៊ូចំពោះភ្លើងនោះខុកដូចជាទឹកសម្រាប់លត់ ។ ចំណែកខាងទឹកច្រែងតែឈ្នះភ្លើងជាជាងបន្តោះហេតុនោះ ការទប់ចិត្តមិនក្រែវក្រោធរបស់ខ្លួនឯងជាន មិនឲ្យតបតឆ្លើយទៅរកបុគ្គលអ្នកក្រោធ ឈ្មោះថាជាអ្នកឈ្នះខ្មាំងបុគ្គលអ្នកក្រោធផងឈ្នះខ្មាំងភ្លើងកិលេស គឺសេចក្តីក្រោធរបស់ខ្លួនផង;

២— ឈ្នះមនុស្សមិនល្អដោយសេចក្តីល្អ សេចក្តីថា មនុស្សមិនល្អនោះ សំដៅយកមនុស្សអ្នកប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត គឺជាមនុស្សទ្រុស្តសីល ឬជាមនុស្សអន្ធពាល ។ កាលបើត្រូវការ

ចង់ឈ្នះមនុស្សអន្ធពាលនោះ ត្រូវផ្ចាញ់ដោយ១ចាយដ៏ល្អរបស់ខ្លួន គឺតាំងខ្លួនឲ្យជាអ្នកប្រព្រឹត្តសុចរិត, មានសីលធម៌, មានកល្យាណធម៌ ដើម្បីយោសនាបង្ហាញឲ្យបានស់ដល់មនុស្សអាក្រក់អន្ធពាលឲ្យរឿយ។ ។ ការប្រព្រឹត្តល្អទៅរកមនុស្សអាក្រក់ដូច្នេះ ឈ្មោះថាជាវិធីសម្រាប់ផ្ចាញ់មួយដ៏ប្រសើរបំផុតក្នុងវាងមនុស្សសប្បុរសនឹងអសប្បុរស តាំងឈ្មោះថាជា១ភ្ជុមគតិនៃពុទ្ធបរិស័ទអ្នកមានទន្ទិធម៌ក្នុងព្រះពុទ្ធសាសនាផង ។

๓- ឈ្នះមនុស្សកំណាញ់ដោយការឲ្យ សេចក្តីថា មនុស្សកំណាញ់ គឺមនុស្សដែលស្ងួតស្ងាញលាក់លៀមទ្រព្យសម្បត្តិមិនបរិច្ចាគជួយបំពេញកិច្ចណាមួយ ចំពោះបុគ្គលមានមាតាបិតាឬបព្វជិតអ្នកមានសីលធម៌ជាដើម ឬចំពោះសាសនា ជាមនុស្សធ្ងន់ដោយលោភៈ ច្រើនតិតយើញតែគឺមសេចក្តីសុខរបស់ខ្លួនក្នុងបច្ចុប្បន្នតែប៉ុណ្ណោះ ។ កាលបើត្រូវការផ្ចាញ់មនុស្សកំណាញ់នោះ គប្បីផ្ចាញ់ដោយការឲ្យ ។ ព្រោះការឲ្យ ជា១ចាយមួយដែលផ្ចុយគ្នាទឹងសេចក្តីកំណាញ់, ការឲ្យទុកជាកិច្ចដ៏ប្រសើរ ដែលគប្បីបង្ហាញឲ្យឃើញច្បាស់នូវសេចក្តីល្អរបស់ខ្លួនដល់អ្នកផងទៀត ដើម្បីបន្ថែនាំអ្នកដែលកំណាញ់នោះឲ្យយល់ឃើញទោសនៃសេចក្តីកំណាញ់ ឬ នាំឲ្យមានសេចក្តីរង្កៀសដល់ខ្លួន ព្រោះហេតុនោះការបរិច្ចាគឲ្យដោយផ្លូវខ្លាយ លោកពាប់ថាជាគ្រឿងសួចខឹកចិត្តដ៏ប្រសើរ ។

๔- ឈ្នះមនុស្សអ្នកនិយាយមិនពិតដោយពាក្យពិត សេចក្តីថា មនុស្សអ្នកពោលពាក្យមិនពិត គឺមនុស្សដែលចូលចិត្តតែ

និយាយកុហកកូតកវ ឬអួតអាង់លើកដំកើងខ្លួនឯង ដោយអាង់ហេតុផល
ទាញទាហរណ៍ដើម្បីឲ្យគេជឿតាមសំដីខ្លួន, ឲ្យគេគោតខ្លាច, ឲ្យគេ
សរសើរ ភាសាចាលីថា "អត្តុក្កំសិ បរវម្ភី" ប្រែថា "បុគ្គលអ្នកបួលចិត្ត
តែខាង់លើកខ្លួនឯង ចន្ទះបង្អាប់អ្នកដទៃ" ។ មនុស្សថែបនេះ ច្រើន
តែនិយាយបន្ទ្រឹង់ជាន ពុំសូវមានពាក្យសំដីពិតទេ ។ កាលបើត្រូវការ
ផ្ដាញ់មនុស្សដែលពោលពាក្យមិនពិតនោះ គប្បីផ្ដាញ់ដោយការនិយាយ
ពាក្យពិតទៅវិញ គឺពាក្យដែលខឿងចាត់, ពាក្យដែលមានប្រយោជន៍
ប្រកបដោយទុត្តមគតិ ជាពាក្យមានហេតុផល មានខ្លឹមសារពិតប្រាកដ ។

សេចក្ដីអធិប្បាយមកនេះប្អូបម្រមៅឃើញថា "មនុស្សល្អ ច្រើន
តែឈ្នះមនុស្សអាក្រក់ ឬ អំពើល្អឈ្នះអំពើអាក្រក់" ដំណើរនេះគួរតាំង
ជាបញ្ហាទុក ដើម្បីផ្ទៀងសេចក្ដីអធិប្បាយដល់លោកអ្នកមានប្រាជ្ញាគ្រាន់
នឹងដោះស្រាយតទៅ ៖

មនុស្សម្នាក់មានចិត្តអាក្រក់ធាប់ខឹងកាចក្រៃក្រៃគាធ, មនុស្សម្នាក់
ទៀតមានចិត្តល្អមិនធាប់ក្រៃក្រៃគាធ ។ មនុស្សដែលមានចិត្តកាចក្រៃ
ក្រៃគាធនោះ អាចប្រទូស្តបៀតបៀនមនុស្សស្លូតរហូតដល់ក្ស័យជីវិតក៏បាន
ធ្វើឲ្យលំបាកខ្លុកវេទនាក៏បាន ហេតុអ្វីបានជានិយាយថា មនុស្សល្អឈ្នះ
មនុស្សអាក្រក់? មួយទៀតមនុស្សម្នាក់ ជាអ្នកប្រព្រឹត្តធ្វើចោរកម្ម,
មនុស្សម្នាក់ទៀតជាអ្នករកខ្លួលបានដោយសម្មាអាជីវៈ ។ បើអ្នកប្រកប
ដោយសម្មាអាជីវៈ ចេះតែអត់ធន់ចំពោះមនុស្សអ្នកប្រព្រឹត្តចោរកម្មនោះ
មុខជាអ្នកប្រព្រឹត្តចោរកម្មនោះ លួចប្លន់យកទ្រព្យសម្បត្តិអស់ពុំខានមែន

ឬ? មួយទៀតមនុស្សម្នាក់ជាអ្នកកំណាញ់ស្តិចស្តួញ, មនុស្សម្នាក់ទៀតជាអ្នកមានចិត្តទូលាយក្នុងការឲ្យ ។ មនុស្សកំណាញ់មុខជានឹងចេះតែសុំយកទ្រព្យសម្បត្តិអំពីអ្នកចិត្តទូលាយអស់ពុំខានមែនឬ? មួយវិញទៀត មនុស្សម្នាក់ជាអ្នកកុហកបោកប្រាស, មនុស្សម្នាក់ជាអ្នកស្មោះត្រង់ ។ មើលទៅមុខជានឹងត្រូវមនុស្សកុហកបោកប្រាសនោះបញ្ឆោតយកទ្រព្យសម្បត្តិ អំពីអ្នកស្មោះត្រង់អស់មិនលែងមែនឬ?

បញ្ហាទាំងនេះ សូមលោកអ្នកពិចារណា ហើយដោះស្រាយតាមសមត្ថភាពតទៅផងចុះ ចំណែកយើងអ្នកនិពន្ធនេះ សូមធ្វើយដោះស្រាយជូនទុកជាមុនដោយសង្ខេបដូចតទៅនេះ ៖

មនុស្សល្អនឹងមនុស្សអាក្រក់, កាលបើយើងពិចារណាដោយគ្រោតគ្រាតក៏យើញថា មនុស្សអាក្រក់ឈ្នះមនុស្សល្អពិតមែន, តែបើពិចារណាឲ្យល្អិតម៉ដ្ឋចត់ក៏អាចយើញថា មនុស្សអាក្រក់មិនឈ្នះមនុស្សល្អបានឡើយ ។ ព្រោះថាមនុស្សអាក្រក់បើទុកជាឈ្នះមនុស្សល្អក៏ឈ្នះដោយសារតែកម្លាំងកាយប៉ុណ្ណោះ បើតាមពាក្យថ្មីដែលគេនិយាយថា "ឈ្នះដោយកម្លាំងបាយ" ។ ការឈ្នះដោយកម្លាំងអន្ធពាលនេះមិនបានបិតថេរយូរអង្វែងតទៅទេ ទីបំផុតត្រូវតែឡប់ចាញ់វិញដោយធាប់រហ័សពុំខាន ។ ការឈ្នះតាមផ្លូវបស់ព្រះពុទ្ធសាសនា ដែលលោកពាប់ថាជាគោលធម៌ដ៏ប្រសើរនោះ គឺឈ្នះដោយចិត្តបរិសុទ្ធ, ដោយទប្រាយថ្លាជាដើម្បីប្រសើរសម្រាប់ខ្លួនគ្រប់ៗគ្នា គឺឈ្នះកិលេសក្នុងសន្តានរបស់ខ្លួន ដោយការអត់ធ្មត់, ដោយការខ្ជាន ហ្មត់ហាត់, ដុសខាត់

ចិត្តឲ្យស្អាតចាកកំលេសទាំងឡាយមានលោភៈ ទោសៈ ជាដើម តាល់តែចិត្តបានបរបៃបល្អ រហូតដល់បានមគ្គផលនិព្វាន ដូច្នេះទើបឈ្មោះថាជាការឈ្នះដ៏ប្រសើរបំផុត មិនត្រឡប់ចាញ់វិញឡើយ ។ មួយទៀត ការគាត់សេចក្តីឲ្យដឹងថា "មនុស្សខាងណាចាញ់, ខាងណាឈ្នះ" នោះត្រូវពិនិត្យមើលមគិភាគច្រើនទើភាគតិចនៃប្រជាជន តើមនុស្សអាក្រក់ធំមនុស្សល្អ មានមហាជនពេញចិត្តខាងណាច្រើនជាង? បើតាមសេចក្តីពិត មនុស្សភាគៈច្រើនតែងស្រឡាញ់ពេញចិត្តមនុស្សល្អ, រើសរកមនុស្សល្អជាដរាប, ទាំងវង្កតិចាលក៏ត្រូវការស្រឡាញ់តែមនុស្សល្អ, ដួយយកអាសាកាន់ជើងមនុស្សល្អ, ការពារមនុស្សល្អ, តែងជាត់ទោសខណ្ឌកម្ចត់ខ្លាដល់មនុស្សអាក្រក់ ដូចយើងក៏បានឃើញស្រាប់មកហើយ ។

ព្រះពុទ្ធសាសនាមិនឱ្យមយកការឈ្នះដោយកម្លាំងកាយ ឬកម្លាំងអាវុធដែលជាអំពើទុច្ចរិតទេ ព្រោះថាការឈ្នះដូច្នោះជាការណកម្មអាក្រក់ក្រៃលែងពេកណាស់ ដូចយ៉ាងសង្គ្រាមដែលកើតឡើង អាចនាំឲ្យវិនាសខូចខាតដ៏វិតមនុស្សសត្វគ្មានសម្បត្តិ មិនមែនតិចឡើយ ទំរាំតែទើងដឹងចាញ់ឈ្នះ ។ ពួកអ្នកចាញ់ក៏ខូចខាតឥស្សរភាព, ពួកអ្នកឈ្នះ ទោះបីមានកិត្តិស័ព្ទ ថាជាអ្នកឈ្នះពិតមែន តែត្រូវបានទទួលពៀរវេរាទុក្ខមកវិញពុំខាន ព្រោះអ្នកចាញ់នោះ ក៏មានៈសេចក្តីឈឺចាប់ក្នុងចិត្តឥតឧបមា តែងមានចិត្តអាឃាដចង់តម្អពៀរ ចំពោះអ្នកឈ្នះ ដោយការគុំគួនជាខ្លាំងទៅរកអ្នកឈ្នះ ។ កាលបើមានចិត្តចងពៀរយ៉ាងនេះ

តើតឿនេធ៌មម្ចាស់សូម្បីបាត់ទៅដូចម្តេចកើត សមដូចព្រះពុទ្ធគាសិតថា

យេ រោ ឧបនយ្ហន្តិ រោ តេសំ ន សម្មតិ សេចក្តីថា "ពួកជនណាចងតឿខុង តឿរបស់ជនពួកនោះមិនស្ងប់រម្ងាប់ទៅបានឡើយ" ។

សេចក្តីនេះបំភ្លឺឱ្យឃើញច្បាស់ថា "កាលបើតឿរនៅមានដល់គ្នានឹងគ្នា សេចក្តីសុខសប្បាយវែងឆ្ងាយក៏កើតមិនបាន" ។

ចំណែកខាងអ្នកឈ្នះក៏ចេះតែមានទុក្ខ - ភ័យ ព្រួយជានិច្ចចំពោះបរបក្ស, ទើបឯខាងអ្នកចាញ់ក៏ចេះតែស្វែងរកឧកាសដើម្បីតស៊ូដណ្តើមយកជ័យជំនះមកវិញ ម្ល៉ោះហើយក៏ត្រូវរៀបចំតែមិនឈប់ជានិច្ច ។

ការឈ្នះនឹងការចាញ់នេះ, កាលបើធំដូនជាន់ណាឃើញដូច្នេះហើយ រមែងមិនត្រូវការចង់បានទូវការឈ្នះអំពីអ្នកដទៃឡើយ, តែងតែចំណែងស្វែងរកសន្តិភាព គឺធ្វើសម្រេចដើម្បីបន្ធូរបន្ថយទូវកិលេសមានលោភៈជាដើមរបស់ខ្លួន យកជ័យជំនះតែចំពោះខ្លួនមិនបាច់ប្រណាំងប្រជែងយកជ័យអំពីគេឡើយ នោះទើបនាំមកទូវសេចក្តីសុខសន្តិភាពគ្រប់គ្រាយបថដោយពិតប្រាកដ សមដូចព្រះពុទ្ធគាសិតថា:

ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ

សេចក្តីថា "បុគ្គលលុះតែលះបង់ចោលទូវជ័យនឹងបរាជ័យ គឺការឈ្នះនឹងការចាញ់ចេញបាន ទើបស្ងប់រម្ងាប់ដេកនៅជាសុខ" ។

ពិតណាស់ សេចក្តីស្ងប់នេះជាសុខដ៏ប្រសើរបំផុត ជាឯហេតុដទៃ

ពាំងអស់ដែលមានឡើងនោះ មិនមែនកើតមកអំពីការលះបង់មនុស្សនឹងមនុស្សផងគ្នាឡើយ ព្រោះការឈ្នះមនុស្សផងគ្នានោះ គ្រាន់តែជាការយកប្រៀបគ្នាប៉ុណ្ណោះ មិនមែនបានសេចក្តីស្ងប់ចិត្ត ដែលកើតអំពីការឈ្នះនោះទេ ។ អ្នកឈ្នះគេព្រោះហេតុតែបរិបូណ៌ដោយកម្លាំងកាយឬកម្លាំងអាវុធ, អ្នកចាញ់គេ ក៏ព្រោះតែខ្វះកម្លាំងកាយកងអាវុធប៉ុណ្ណោះ ។ សេចក្តីស្ងប់តែងកើតមាន ព្រោះការគេចរេះចេញចាកពួកគណៈផង, ព្រោះចិត្តដែលច្បាស់ចាកកិលេសផង មិនមែនកើតឡើងអំពីបុគ្គលអ្នកឈ្នះនឹងអ្នកចាញ់ឡើយ ។ អ្នកពាំងពីរ គឺអ្នកឈ្នះនឹងអ្នកចាញ់សុទ្ធតែជាអ្នកបណ្តុះបណ្តាលឲ្យកើតទុក្ខភ័យពៀរវេរដល់គ្នានឹងគ្នា តុំមែននាំឲ្យកើតសេចក្តីស្ងប់ឡើយ ។

ការឈ្នះចាញ់នៃមនុស្សផងគ្នានេះ កាលបើពិចារណាក៏អាចឃើញច្បាស់ថា សុទ្ធតែជាអំពើដែលគួរលះបង់ចោលឲ្យស្រឡះមិនគួរច្បាច្បាច់បានឡើយ មិនគួរចង់ជួបប្រទះសោះ ។ តាមមារយាទរបស់ចិត្តបុថុជ្ជន ច្រើនតែប៉ុនប៉ងច្បាច់ច្បាដើម្បីជ័យជំនះលើគេពាំងអស់ ឥតមានខណៈមួយច្បាច់ច្បាយកត្រង់ការចាញ់គេឡើយ ។ ប៉ុន្តែការចាញ់គេនោះបើខ្លួនជាមិនមានអ្នកច្បាច់ពិតមែន តែអាចកើតមានឡើងជាធម្មតា ។ អ្នកចង់ឈ្នះគេ ត្រូវប់ជាចាញ់គេក៏មាន, អ្នកធ្លាប់ចាញ់គេត្រូវប់ជៀសឈ្នះគេក៏មាន ព្រោះហេតុនោះការឈ្នះចាញ់របស់មនុស្សផងគ្នានេះសុទ្ធតែជាទោស ជាសត្រូវនាំមកនូវសេចក្តីចង្អៀតទុក្ខភ័យវិនាសហិនហោចជាពន្លឹកមហិមា ។

កល្យាណជនចាំងឡាយ! កាលបើត្រូវការចង់បានសេចក្តីសុខក្សេមក្សាន្តដ៏ធំទូលាយ ត្រូវលះបង់នូវជ័យនឹងបាជ័យឲ្យដិះស្រឡះ ទើបឈ្នះសេចក្តីទុក្ខបាន ។

អស់តណ្ហាឈ្នះសេចក្តីទុក្ខ

សេចក្តីថ្លាថ្នូរ, ការអន្ទះសា, ការសង្ឃឹមសង្ឃែរប្រកាន់ចង់ឈ្នះគេ ចាំងអស់នេះហៅថា "តណ្ហា" ។ បើយើងនៅមានតណ្ហាជាប់ជាមួយណា, យើងក៏នៅមានសេចក្តីទុក្ខគ្រប់យ៉ាងជាប់ជាមួយនោះ, បើយើងអស់តណ្ហា, យើងក៏ឈ្នះសេចក្តីទុក្ខចាំងពួងដែរ, សមដូចព្រះគាថាក្នុងធម្មបទខុទ្ទកនិកាយថា: តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ 'ការអស់ទៅនៃតណ្ហារមែងឈ្នះនូវទុក្ខចាំងពួង" ។

ព្រះគាថានេះ បំភ្លឺសេចក្តីឲ្យឃើញថា "សេចក្តីទុក្ខគ្រប់យ៉ាងគឺទុក្ខអំពីសេចក្តីចាស់គ្រាំគ្រាក្តី, ទុក្ខអំពីការឈឺចាប់ក្តី, ទុក្ខអំពីសេចក្តីស្លាប់ព្រាត់ប្រាសក្តី, ទុក្ខអំពីបម្រាំងពាំងដល់ក្តី សុទ្ធតែកើតអំពីកិលេសចាំងអស់" ។ ឯកិលេសដែលជាឫសគល់នៃកិលេសឯទៀតៗនោះបានដល់លោភៈ ការជាប់ដំពាក់ក្នុងអារម្មណ៍មិនចេះឆ្អែតស្កប់ស្កល់, ទោសៈ ការខឹងត្រូវក្រោធចំពោះសត្វ ឬ សង្ខារ, មោហៈ ការវង្វេងភ័ន្តច្រឡំ ។ កិលេសចាំងនេះលោកហៅថាប្រកបពាកិលេស គឺជាដែនកើតនៃកិលេសចាំងឡាយមានតណ្ហាជាដើម ដែលជាបច្ច័យនាំសត្វឲ្យចំសុះពន្ធនៈស្វែងរកនូវអារម្មណ៍ផ្សេងៗ, កាលបើស្វែងរកបានក៏អរសប្បាយ, កាលបើស្វែង

រកមិនបាន ក៏កើតទុក្ខទោមនស្សក្តៅក្រហាយចិត្ត ជាហេតុនាំឲ្យច្រណែនច្រវែងដេញដើងគ្នាក្នុងការស្វែងរក ។

បុគ្គលដែលមានតំលេសគ្រាសក្នុងសន្តានស្វែងរកមុនដំបូងដោយផ្លូវសុចរិតក៏មាន, ទុច្ចរិតក៏មាន, លុះគាលជាខាងក្រោយមក គាលបើស្វែងរកដោយផ្លូវសុចរិតមិនបាន ទ្វារអារម្មណ៍ដូចបំណង ក៏ស្វែងរកផ្លូវទុច្ចរិតមានការប្រើឧបាយដោយសម្ងាត់ក៏មាន ដោយការប្រព្រឹត្តបំពានបំពេញមុខក៏មាន តាមតែប្រទះគិតយកឲ្យតែខាងបានប្រយោជន៍មកខ្លួនឬត្រកូលខ្លួន ទោះបីបះពាល់សិទ្ធិរបស់អ្នកណាមួយក៏ឥតគោតញញើតឡើយ ។ ការស្វែងរកនោះ, បើចេះតែប្រព្រឹត្តទៅដោយស្រួលល្អ មិនមានអ្នកណាមួយហ៊ានជំទាស់ទេ ក៏ឈ្មោះថាមានកំពូបានផលល្អ យូរអង្វែងតទៅ ។ ការប្រព្រឹត្តស្វែងរករបស់បុគ្គលអ្នកមានតំលេសគ្រាស់នោះ គាលបើចេះតែរកធំទូលាយ, ឫទ្ធិអំណាចក៏កើតមានឡើងដោយលំដាប់ ។ គាលបើឫទ្ធិអំណាចមានបរិបូណ៌ហើយ, ការប្រព្រឹត្តរំលោភឈ្លានពានជិះជាន់លើមនុស្សផងគ្នាក៏កាន់តែមានឡើងឥតឈប់ឈរឡើយ, ម្ល៉ះហើយ ការប្រព្រឹត្តរំលោភដោយហេតុតែចង់បានសុខដ៏ធំទូលាយមកលើខ្លួនម្នាក់ ។ នោះក៏រមែងប៉ះពាល់ដំពប់ទៅលើសិទ្ធិអ្នកណាមួយក្នុងថ្ងៃណាមួយពុំខាន ។

ផយកថា ចប់

ជីវតោ ភាមើលមិនឃើញ[1]

ឃុនបណ្ណានុរក្ស ប៊ុ - ប៊ុ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

សំនួរ – យើងច្រើនតែសំគាល់ឃើញថា ខ្លួនយើងល្អសព្វគ្រប់ គាំងអស់ រឥតខ្វះកន្លះសោះ ចុះហេតុអ្វីបានជាអ្នកដទៃគេនៅតែយល់ឃើញថា យើងនៅមានសេចក្តីអាក្រក់ខ្លះ រឿងនេះ ព្រោះហេតុផលដូចម្តេច ?

ចម្លើយ – ព្រោះយើងនៅជិតខ្លួនឯងពេកណាស់ ឋានជាត្រួតត្រាមើលខ្លួនមិនសព្វគ្រប់ សូម្បីតែនាំតែមើលមុខខ្លួនឯងក៏មិនឃើញផង បើចង់ឃើញ ត្រូវយកកញ្ចក់មកធ្លុះមើល បើចង់ឲ្យឃើញខាងក្រោយទៀត ត្រូវដែមកញ្ចក់ ១ ទៀត ។ ចំណែកអ្នកដទៃមើលឃើញខ្លួនយើងច្បាស់ណាស់ ព្រោះគេខ្លួវធ្វាយឃ្លាតពីខ្លួនយើង មានឧកាសពិនិត្យមើលច្បាស់លាស់ ។ ឯអ្នកដទៃនោះ ក៏មិនឃើញខ្លួនឯងច្បាស់ ដូចជាយើងមិនឃើញខ្លួនយើងដែរ ។

យើងមិនសូវយកចិត្តទុកដាក់ក្នុងសេចក្តីប្រព្រឹត្តិរបស់យើង ដោយការទុស្សាហ៍ត្រួតត្រាមើល ដូចជាយើងគ្មានកញ្ចក់ធ្លុះមុខ យើងត្រួតត្រាដោយការសមគំនិតនឹងខ្លួនឯងច្រើនពេក ឋានជាយើងមើលមិនឃើញសេចក្តីអាក្រក់របស់យើង ដូចជាយើងធ្លុះកញ្ចក់ហើយ ប៉ុន្តែយកកញ្ចក់

---

១ ប្រែចាកច្បាប់ធម្មចក្ស ព. ស. ២៤៩១ ។

មកជាក់ផ្ទាប់ជាប់ខ្លឹងសាច់មុខតែម្តង ឬកញ្ចក់នោះនៅឆ្ងាយពីមុខយើងពេក
ក៏ឥតមើលឃើញអ្វីសោះ ហាក់ដូចជាមិនបានឆ្លុះកញ្ចក់ដែរ លុះតែជាក់
កញ្ចក់ឲ្យឆ្ងាយល្មមប្រមាណ ទើបឆ្លុះឃើញមុខច្បាស់ ។ ការត្រួតត្រា
មើលសេចក្តីប្រព្រឹត្តិរបស់ខ្លួនក៏យ៉ាងនោះដែរ បើត្រួតត្រាមើលដោយសម
គំនិតតែខាងខ្លួនឯងពេកទៅ ក៏ដូចជាឆ្លុះកញ្ចក់យកមកជាក់ខួបមុខតែម្តង
ឬជាក់ឆ្ងាយពីខ្លួនពេកឥតឃើញអ្វីសោះ ។ ហេតុនេះ ត្រូវត្រួតត្រាមើល
ខ្លួនឯងដោយមិនចូលដៃនឹងខ្លួនឯង ទើបបានឃើញសេចក្តីល្អអាក្រក់
ពិតប្រាកដ ដូចឆ្លុះកញ្ចក់ជាក់ពីមុខឲ្យឆ្ងាយល្មម ។ សរុបសេចក្តីថា
ការដែលអ្នកជវៃមើលឃើញសេចក្តីអាក្រក់របស់យើង ច្រើនជាងយើង
ឃើញខ្លួនឯងនោះ ដោយមានហេតុ ២ ប្រការ គឺយើងនៅជិតខ្លួនឯង
ហួសពេក ១ យើងច្រើនតែសមគំនិតនឹងខ្លួនឯងពេក ១ ។

មានបម្រើយមប ៉ាងទៀតថា ឋានជាយ៉ាងនោះ ព្រោះមានហេតុផល
៤ ប្រការគឺ ព្រោះសេចក្តីនិយមចូលចិត្តផ្សេងគ្នា ១ ព្រោះយើងមាន
សេចក្តីឃើញសមគំនិតតែខាងខ្លួនឯង ១ ព្រោះយើងធ្វើខុសដោយមិន
ដឹងខ្លួន ១ ព្រោះសេចក្តីល្អដែលយើងមាននោះ មិនជាទីចូលចិត្តរបស់
អ្នកជវៃ ១ ។

ត្រង់ប្រការទី ១ ដែលថា ព្រោះសេចក្តីនិយមចូលចិត្តផ្សេងគ្នានោះ
គឺមានបញ្ជាប់របស់ធម្មតាថា ជាតាបិព្ពិ ចិត្តរមែងផ្សេងៗគ្នា កាលបើចិត្ត
ផ្សេងគ្នាហើយ សេចក្តីនិយមចូលចិត្តក៏ផ្សេងគ្នាដែរ កាលបើសេចក្តី
និយមចូលចិត្តផ្សេងគ្នាហើយ សេចក្តីយល់ឃើញរហូតដល់ការធ្វើក៏ផ្សេង

គ្នាដែរ ។ បើមនុស្សមានច្រើនប៉ុន្មាន គំនិតសេចក្តីនិយមចូលចិត្ត, សេចក្តីយល់ឃើញ, ឧដ្ឋការធ្វើ ក៏ចេះតែបែកខ្វែកផ្សែក ។ គ្នាទៅប៉ុណ្ណោះ ដែលនឹងឲ្យត្រូវគ្នាគ្រប់គ្នាតែងណាស់ ។ រួមសេចក្តីថា អ្នកណានិយមយ៉ាងណា ក៏ចូលចិត្តយ៉ាងនោះ ។ អ្នកណានិយមក្នុងខ្លួន ក៏ប្រកាន់យកខ្លួនជាធំ (អត្តាធិបតេយ្យ) ។ អ្នកណានិយមក្នុងលោក ក៏ប្រកាន់យកលោកជាធំ (លោកាធិបតេយ្យ) ។ អ្នកណានិយមក្នុងធម៌ ក៏ប្រកាន់យកធម៌ជាធំ (ធម្មាធិបតេយ្យ) ។ សេចក្តីនិយមផ្សេងគ្នានេះ មានរឿងក្នុងព្រះសុត្តន្តបិដកជាគាថាវណ៌ថា គ្រាមួយ ព្រះរាជាច្រើនព្រះអង្គកើតជជែកគាស់ខែងខ្វែងគំនិតគ្នា អង្គមួយយល់ឃើញថា ល្អ ។ អង្គមួយយល់ឃើញថាសំឡេងល្អ ។ អង្គមួយយល់ឃើញថាក្លិនល្អ ។ អង្គមួយយល់ឃើញថារសល្អ ។ អង្គមួយយល់ឃើញថាផោដ្ឋព្វៈល្អ ។ អង្គមួយយល់ឃើញថាធម្មារម្មណ៍ល្អ ។ មានសេចក្តីយល់ឃើញមិនចុះសម្រុងគ្នាដូច្នេះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "មហាបពិត្រទាំងឡាយ ! រឿងនេះប្រកាន់យកសេចក្តីចូលចិត្តជាប្រមាណ គឺថា បើអ្នកណាចូលចិត្តយ៉ាងណា យ៉ាងនោះហើយជាសេចក្តីល្អរបស់អ្នកនោះ, ដូច្នេះ ។ យើងចូលចិត្តទៅម្យ៉ាង អ្នកដទៃចូលចិត្តទៅម្យ៉ាង របស់ដែលយើងចូលចិត្ត គេមែរជាមិនចូលចិត្តវិញ របស់ដែលយើងយល់ឃើញថាល្អ គេមែរថាជាមិនល្អវិញ គឺថាយើងប្លែរបស់នៃយើងអាត្រកំនោះឯង ។

ត្រង់ប្រការទី ២ ដែលថា ព្រោះយើងមានសេចក្តីយល់ឃើញសមគំនិតតែខាងខ្លួនឯងនោះ គឺកាលគំនិត, សេចក្តីនិយម, សេចក្តីយល់

ឃើញ, សេចក្តីគាប់ចិត្តនឹងការធ្វើផ្សងគ្នា មានឡើងហើយ សេចក្តី
ឃល់ឃើញថាខ្លួនត្រូវក៏មានឡើងដែរ ហើយនឹកជានិច្ចថា យើងល្អ
សព្វគ្រប់ទាំងអស់ អ្នកដទៃមិនអាចប្រៀបផ្ទឹមនឹងយើងបានឡើយ សូម្បី
យើងទើងខុសសែនខុស ក៏នៅតែនឹកថាខ្លួនត្រូវជាដរាប សូម្បីយើងខូច
ក្រៃលែងខូច ក៏នៅតែនឹកថាខ្លួនល្អជានិច្ច ព្រោះទោសគឺមានៈនឹងនិដ្ឋ
នោះមកបិទបាំង ទើបធ្វើឲ្យយើងមើលមិនឃើញសេចក្តីខ្វះខាតរបស់
ខ្លួន ។ សេចក្តីល្អដែលយើងប្រកាន់យកនេះត្រូវតែអ្នកដទៃសំឡឹងមើល
ទើបនឹងដឹងថាខូចបន់ត្រង់ណាបាន ។ យើងចេះតែនឹកថា យើងល្អ
ពេញទី ប៉ុន្តែសេចក្តីអាក្រក់ដែលជ្រៀតជ្រែកនៅក្នុងចន្លោះខ្លួនយើងនោះ
នឹងកើតប្រាកដក្នុងភ្នែករបស់អ្នកដទៃមិនខាន ។ ព្រះដ៏មានព្រះភាគ
បានត្រាស់ព្រះគាថាទុកក្នុងធម្មបទ ដើម្បីនឹងចង្អុលប្រាប់រឿងនេះថា
សុទុស្សុំ វជ្ជមញ្ញេសំ ទោសរបស់អ្នកដទៃឃើញបានងាយ អត្តនោ
បន ទុទ្ទសំ ចំណែកទោសរបស់ខ្លួនឯងឃើញបានក្រ បរេសំ
ហិ សោ វជ្ជានិ ឱបុនាតិ យថា ភុសំ ព្រោះថា គេរវែងបាចសាច
ទោសទាំងឡាយដល់ជនពួកដទៃ ដូចមនុស្សបាចអង្កាមដូច្នោះ អត្តនោ
បន ឆាទេតិ តែថា រវែងបិទបាំងទោសរបស់ខ្លួនទុក កលិវ កិតវា
សឋោ ដូចជានាយព្រានបិទបាំងកាយដោយស្លឹងបិទបាំងដូច្នោះ ។

ត្រង់ប្រការទី ៣ ដែលថា ព្រោះគេធ្វើការខុសដោយមិនដឹងខ្លួន
នោះ គឺកន្លងកាលយើងមានសេចក្តីល្អហើយ យើងស្រាវឆ្លៀតក្លែតក្លែនក្លេច

ខ្ញុំកន្ធរសេចក្តីល្អរបស់យើងដ្រលពេកទៅ (ច្រមាច) ទាល់តែជាហេតុ
ឲ្យធ្វើអំពើអាក្រក់ដោយមិនដឹងខ្លួន ទាំងកំពុងតែធ្វើអាក្រក់ដូច្នោះ ក៏មិន
ដឹងថាយើងធ្វើអាក្រក់ផង ចេះតែច្រកាន់ថាយើងធ្វើល្អត្រឹមត្រូវជានិច្ច
ដោយអំណាចមោហៈមកគ្របសង្កត់ ទើបធ្វើឲ្យយើងវង្វេងដូចស្រែរាំង
សុក ។ សេចក្តីអាក្រក់ដូច្នោះយើងសំឡឹងមើលមិនឃើញ ប៉ុន្តែទឹង
ត្រូវកើតមានច្បាកដក្នុងក្នែកបស់អ្នកដទៃ គឺអ្នកដទៃគេមើលកំហុសរបស់
យើងឃើញច្បាស់ណាស់ ។

ត្រង់ច្រការ ៤ ដែលថា ព្រោះសេចក្តីល្អរបស់យើងមាន តែមិនជា
ទីចូលចិត្តរបស់អ្នកដទៃនោះ គឺសេចក្តីល្អរបស់យើងមានមែនហ៊ាយ បើ
ពុកជាត្រឹមត្រូវតាមសេចក្តីនិយមរបស់គេក៏ដោយ គេក៏នៅតែត្រូវការចង់
ឲ្យយើងរិះសេរះច្រឌិនឡើងជាងមុននោះទៅទៀត ។ ចំណែកសេចក្តីល្អ
ដែលគេចូលចិត្តនោះ យើងមិនចាន់មាននៅឡើយ ចាន់ជាគេឃើញថា
យើងមិនចាន់ល្អដល់កម្រិតទេ គឺថានៅតែមានអាក្រក់មិនចានឡើយ ។

មួយទៀត មនុស្សគ្រប់រូបនឹងឲ្យល្អត្រមសព្វគ្រប់ចាំងអស់ឥតខ្ចះ
កន្ទះនោះរកមិនចានទេ តែងមានល្អខ្ចះ អាក្រក់ខ្ចះជាធម្មតា ប៉ុន្តែអ្នកដទៃ
ទៅសំឡឹងយកតែត្រង់ចំណែកអាក្រក់ ត្រង់ចំណែកល្អមិនចានសំឡឹង
មើលផងទេ ចានជាឃើញថា យើងនៅមានសេចក្តីអាក្រក់ខ្ចះមិនចាន ។

បញ្ញាសជាតក

ភាគទី ៤

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាជាលីជាន់ខ្ពស់ ចាត់ឡប្រែហើយតិចខ្លះផ្សេងផ្ដាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតគឺ ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

វេដ្ឋង្គុលីភជាតក ទី ២០

លោកអាចារ្យ ឈឹម-ណាក ប្រែតាមលី

ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

ខ្ញុំបានស្ដាប់មកយ៉ាងនេះថា សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់សម្រេចសម្រាន្តព្រះវិហារបឋ ក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋ ទៀបក្រុងសាវត្ថី ។

សម័យនោះឯង ព្រះចុតបសេនទិកោសល ទ្រង់សោយរាជ្យក្នុងនគរនោះ; ព្រះអង្គប្រកបដោយទសពិធរាជធម៌ រក្សាមហាជនដោយសង្គហធម៌ទាំង ៤ យ៉ាង មានព្រះពលទាន ព្រះពលទ្រព្យជាដើម, ទ្រង់មិនប្រើអាការៈកំហែងធ្វើទោសលក់ដៃ ទ័ណ្ឌមិនមានប្រហារដោយគ្រឿងសស្ត្រាវុធឡើយ ។ ព្រះអង្គតែងនាំគ្រឿងសក្ការបូជាមានកម្រងផ្កាទំងគ្រឿងក្រអូបជាដើម ទ្រង់ស្ដេចទៅកាន់វត្តជេតពន ដើម្បីស្ដាប់ធម៌

ទេសនា ក្នុងសាយណ្ហសម័យជានិច្ច ។ មានកាលសម័យថ្ងៃមួយ ព្រះដ៏មានបុណ្យ ទ្រង់តើនចាកសយនាក្នុងបច្ចូសសម័យ ទ្រង់ប្រមើលមើលដោយពុទ្ធចក្ខុ ឃើញពួកជនដែលមានឧបនិស្ស័យគួរត្រាស់ដឹងនូវមគ្គផលនៅក្នុងទីឆ្ងាយ, ទើបព្រះអង្គទ្រង់ធ្វើសរីរកិច្ចរួចស្រេចស្តេចប្រដាប់ជាត្រចីវរ ទ្រង់ពុទ្ធដំណើរទៅក្នុងទីនោះ, សំដែងធម៌ប្រោសជនអ្នកមានឧបនិស្ស័យនោះឲ្យបានដល់ក្នុងសោតាបត្តិផល ។ ជួនជាពេលនោះ ព្រះចុតូបបសេនទេរកោសលព្រមទាំងបរិពារ ឲ្យពង់រើកាន់គ្រឿងសក្ការបូជា មានគ្រឿងក្រអូបនឹងកម្រងផ្កាជាដើម ស្តេចទៅកាន់វត្តជេតពន ដើម្បីស្តាប់ធម៌ ក្នុងសាយណ្ហសម័យ; កាលទ្រង់មិនឃើញព្រះតថាគត ក៏មានព្រះរាជហឫទ័យក្តុកក្តួលរំជួលជាខ្លាំងពេកមនស្សត្រាស់ថា ឧហ្ម៎! វត្តជេតពនសាបសូន្យហើយតើ, ទាំងបំណងរបស់អាត្មាអញក៏ជាប់មិនបានសម្រេចដែរ ។ ព្រះរាជាត្រាស់យ៉ាងនេះហើយក៏តើតរឭងដំណើរសេចក្តីក្តៅក្រហាយស្តាយព្រះពុទ្ធា, ទ្រង់បូជាចំពោះពុទ្ធសាសនៈ ដោយគ្រឿងសក្ការៈមានទៀនធូបគ្រឿងក្រអូបនឹងកម្រងផ្កា ហើយទ្រង់ត្រឡប់ចូលមកកាន់ក្រុងសាវត្ថីវិញភ្លាម ។ រំលោភគ្រីយប់នោះ ព្រះអង្គជ្រុំមិនស្តាប់តេញមួយយប់ ទើបមានព្រះរាជទ្ធាវត្រាស់ហៅអាមាត្យនឹងព្រាហ្មណ៍គហបតីទាំងឡាយ មកហើយត្រាស់ពិភាក្សាថា ម្នាលអ្នកដ៏ចំរើនទាំងឡាយ, ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលគង់នៅជាប់ជានិច្ចក្នុងកន្លែងណាមួយ។ ទេ, បើពួកវេនេយ្យសត្វអ្នកមានឧបនិស្ស័យគួរព្រះអង្គដឹកនាំបាន នៅក្នុងទីណា, ព្រះអង្គតែងធ្វើពុទ្ធដំណើរទៅក្នុងទីនោះ។ ព្រោះ

ព្រះអង្គមានព្រហ្មវិហារ គឺសេចក្តីអាណិតអាសូរចំពោះសត្វទាំងនោះជាបរិបូរ, ឯព្រះពុទ្ធជាម្ចាស់នៃយើង ក៏ដូច្នោះដែរ; ចំណែកខាងយើងចង់តែចូលទៅអង្គុយជិតព្រះតនៃត្រែជាទីបំផុត ប៉ុន្តែបើព្រះដ៏មានព្រះភាគស្តេចមានពុទ្ធដំណើរទៅកន្លែណាមួយ ទ្រង់ផ្តាច់វត្តរបស់យើងដើម្បីប្រយោជន៍ពួកជនដទៃ, គួរតែយើងសូមឲ្យព្រះដ៏មានព្រះភាគអនុញ្ញាតដើម្បីទិងកសាងព្រះចេដិយមួយអង្គជាព្រះរូបស្មង ។ ពួកឥស្សរជនទាំងអស់ មានអាមាត្យជាដើម បានស្តាប់ព្រះរាជឧង្ការរហើយ ក៏មានចិត្តរីករាយ ក្រាបបង្គំទូលស្នងព្រះរាជឧង្ការទៅវិញថា បពិត្រព្រះរាជសម្ភារ, ព្រះរាជតម្រិះដែលព្រះអង្គទ្រង់ឈ្វេងយល់នេះប្រៃពៃពេកណាស់ ទីដ៏បានជាប្រយោជន៍ដល់សត្វសត្វទូទៅក្នុងព្រះនគរ អស់កាលជាយូរអង្វែង, ឯទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ក៏ទីដ៏បានកសាងព្រះចេដិយតាមតំណាងរឿងៗខ្លួនដោយសារព្រះអង្គផង ។ លុះដល់វេលាព្រឹកឡើង ព្រះរាជាត្រាស់ហៅពួកឥស្សរជនមានអាមាត្យជាដើម ឲ្យមកជួបជុំគ្នាក្នុងវេលាថ្ងៃរសៀល ឲ្យកាន់យកគ្រឿងសក្ការៈផ្សេងៗ មានផ្ការម្រងទឹងគ្រឿងក្រអូបជាដើម ស្តេចទៅកាន់វត្តជេតពនចូលទៅរកព្រះដ៏មានព្រះភាគ, លុះចូលទៅដល់ ទ្រង់ថ្វាយបង្គំ ហើយទ្រង់គង់ក្នុងទីដ៏សមគួរ ។ ព្រះចុតុបសេនទិកោសល ទ្រង់គង់នៅក្នុងទីដ៏សមគួរហើយ ទ្រង់មានព្រះរាជឧង្ការចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន, ពីថ្ងៃម្សិលមិញ បណ្តាជនក្នុងក្រុងសាវត្ថី មកឯវត្តជេតពននេះ ពុំបានឃើញព្រះដ៏មានព្រះភាគ ក៏តើតសេចក្តីក្តៅក្រហាយ

ត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ដោយគិតថា "នុ៎ះ! វត្តដេតពន សាបសូន្យ
ហើយតើ; បពិត្រព្រះអង្គដ៏ចំរើន, ព្រោះហេតុនោះសូមព្រះអង្គទ្រង់
អនុញ្ញាតនូវការកសាងព្រះបដិមាដល់ខ្ញុំព្រះអង្គ ដើម្បីអនុគ្រោះដល់សត្វ-
លោក, ប្រសិនបើព្រះដ៏មានព្រះភាគព្រះអង្គព្រមអនុញ្ញាតឲ្យ, ខ្ញុំព្រះអង្គ
ទាំងឡាយ ជាអ្នកមានសទ្ធានឹងកសាងព្រះបដិមា ដម្កល់ទុកជាទីគោរព
ស្ដង់ព្រះអង្គតទៅ"។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះសណ្ដាប់ព្រះពាជនុង្ការ
នោះហើយ ទ្រង់ត្រាស់ថា បពិត្រមហាពាជ, ប្រពៃហើយ, ស្រួលហើយ,
សូមព្រះអង្គធ្វើព្រះបដិមាចុះ, តថាគតអនុញ្ញាតឲ្យតាមព្រះពាជបំណង។
ព្រះពាជាបសេនទិកោសល ទ្រង់ព្រះសវនាការព្រះពុទ្ធដីកាព្រះតថាគត
ហើយ ក៏មានព្រះពាជហប្ញទ័យផ្អែមស្ដប់ស្ដល់ ដោយព្រះបីតិជ្រះថ្លា លើក
ព្រះហត្ថាថ្វាយបង្គំទូលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគ ហើយគង់នៅ
ស្ដាប់ធម្មទេសនាដរាបដល់ចប់ ទើបក្រាបថ្វាយបង្គំលាព្រះសាស្ដានាំ
ពួកពាជបរិពារចូលទៅគាន់ព្រះពាជបុរីវិញ។ ព្រឹកឡើង ទ្រង់ត្រាស់ឲ្យ
ហៅពួកជាងឈើមក ទ្រង់ត្រាស់ព្រះពាជបញ្ជាឲ្យជាងនោះសាងព្រះ
បដិមាដោយទ្វីមចន្ទន៍[1] មានកំពស់ប្រាំថ្នាក់ទ្រនិច។ កាលបើកិច្ចកសាងព្រះ
បដិមានោះសម្រេចហើយ, ទ្រង់ឲ្យលាបលនវិលេចនពណ៌ដ៏វិចិត្រ ឲ្យ
ដូចជាតួអង្គព្រះសម្មាសម្ពុទ្ធ ដែលមានព្រះដ៏វិតពិតប្រាកដ; ទើបព្រះ
អង្គទ្រង់ចាត់ឲ្យធ្វើមណ្ឌបដ៏វិចិត្រដោយរតនវត្ថុផ្សេងៗ។ ហើយទ្រង់ឲ្យ
និមន្តព្រះពុទ្ធបដិមាមកគង់លើសីហាសនៈ កណ្ដាលមណ្ឌបនោះ ទ្រង់ធ្វើ

---

១ ក្នុងសៀវភៅដំណាលពុទ្ធចេតិយ មានសេចក្ដីបន្ថែមសេចក្ដីរឿងនេះថា ទាស់តែងបែបបទដទៃ។

សក្ការបូជាជាមហាឡាភៈច្រើនប្រការ ។ លំដាប់ពីនោះមក ព្រះពុទ្ធ
ទ្រង់ស្តេចទៅឯវត្តជាមួយនឹងពួកភពជបរិវារ ថ្វាយបង្គំព្រះដ៏មានព្រះភាគ
ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន, ការកសាងព្រះពុទ្ធបដិមា
សម្រេចហើយ, ប្រសិនបើព្រះដ៏មានបុណ្យទ្រង់ទតឃើញ ប្រហែល
ជាទ្រង់តេញព្រះពាដប្អូរច្រើនណាស់ ។ សម្តេចព្រះដ៏មានព្រះភាគជា
ម្ចាស់ ទ្រង់ទទួលដោយតុណ្ហីភាព ។

ដល់ថ្ងៃស្អែកឡើង ព្រះបរមគ្រូ មានពួកភិក្ខុចោមរោមជាបរិវារ
ទ្រង់ពុទ្ធដំណើរចូលទៅកាន់ភពនិវេសន៍, ទ្រង់សំដៅទៅគង់កន្លែងដែល
ព្រះពុទ្ធបដិមាគង់នៅ ។ ខណៈនោះព្រះពុទ្ធបដិមា បានឃើញព្រះ
បរមគ្រូហើយ ក៏ហាក់ដូចជាមានព្រះចិត្តគិតថា "អាត្មាអញមិនគួរបើ
អង្គុយលើអាសនៈខ្ពស់ថែបនេះសោះ ព្រោះព្រះសម្មាសម្ពុទ្ធដែលមាន
ព្រះជីវិត ព្រះអង្គទ្រង់ធរមាយុនៅឡើយ" ហើយក៏ប្រែបរៀប
ចុះចាកសីហាសនៈជាវិការៈនៃកែវ៧ប្រការ ។ លំដាប់នោះ ព្រះ
បរមសាស្តា ទ្រង់ទតឃើញព្រះបដិមាមានអាការៈដូច្នោះ ក៏ព្រះដ៏
ទ្រង់យសទ្រង់លាព្រះហស្តខាងស្តាំ ដ៏ល្អទុកាស ខន់ល្អខ្ចាស់ដូចជា
ប្រមោយដំរីឰភវ័ណ្ណ ភឃាត់ថា ម្នាលអាវុសោ, អ្នកចូរអង្គុយចុះ, អ្នក
កុំចុះចាកអាសនៈឡើយ, មិនយូរប៉ុន្មានទេតថាគតនឹងបរិនិព្វាន, ម្នាល
អាវុសោ, ចូរអ្នកថែរក្សាសាសនាតថាគតឲ្យបានគ្រប់ចំនួន៥០០០វស្សា
ដើម្បីប្រយោជន៍ដល់សត្វលោក ។ ព្រះពុទ្ធបដិមានោះ ក៏ហាក់ដូចជា
ចេះស្តាប់ព្រះពុទ្ធដីកា ថយទៅគង់លើអាសនៈដូចដើមវិញ ។ គ្រានោះ

ពួកមហាជន មានព្រះរាជាជាប្រមុខ ឃើញហេតុជាទីអស្ចារ្យដូច្នោះ ក៏ថ្វាយដីវិតដល់សាសនា ហើយយកសំពត់ធ្វើទង់ជាច្រើនពាន់ ជោតគ្រប់ទីដ៏ឋនសំពោធរោងព្រាត ។ ព្រះបាទបសេនទិកោសលថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ គ្រាស់ព្រះឰជបុច្ឆា សួរអំពីអានិសង្សនៃការកសាងព្រះពុទ្ធបដិមាចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន, នរជនណាមួយ ទោះជាបុរសឬជាស្ត្រីដែលបានកសាងព្រះពុទ្ធបដិមា តើនរជននោះត្រូវបានអានិសង្សដូចម្តេច? ព្រះដ៏មានជោគទ្រង់បានសវនាការព្រះពាជបុច្ឆានោះហើយ ទើបបើកព្រះឧស្ណមានពណ៌ក្រហមពុំដូចសំពត់កម្ពល គ្រាស់ព្រះពុទ្ធដីកាចំពោះព្រះពាជាថា បពិត្រមហារាជ, នរជនណាមួយ ទោះជាបុរសឬជាស្ត្រី ដែលមានសទ្ធាបានកសាងព្រះពុទ្ធបដិមា អំពីដ៏ស្អិតក្តី ថ្មក្តី ដែកក្តី ស្ពាន់ក្តី ឈើក្តី សំណក្តី កែវក្តី ច្រក់ក្តី មាសក្តី ភក់ក្តី ស្បែងក្តី គួរជាគំនូរក្តី បណ្តាបេះតាំងអស់នោះ ណាមួយ, នរជននោះឯង ទំនឹងត្រូវបានផលានិសង្សច្រើន; បពិត្រមហារាជ, ព្រះពុទ្ធបដិមា បិតនៅក្នុងលោកដរាបណាសត្វលោកឈ្មោះថាមិនសូន្យចាកព្រះពុទ្ធដរាបនោះ ពាំងបាននូវគ្រឿងទីពឹងក្នុងសាសនាទៀត; បុគ្គលណាមួយ បានកសាងព្រះពុទ្ធបដិមាបុគ្គលនោះ រមែងមានសេចក្តីសុខក្នុងលោកខាងមុខ, បើតាំងសេចក្តីប្រាថ្នាយ៉ាងណា ក៏ទំនងបានសំរេចនូវផលតាមសេចក្តីប្រាថ្នាយ៉ាងនោះ; បពិត្រមហារាជ, កាលពីមុន ពោធិសត្វបានធ្វើនូវកុសល តិចតួចតែធ្វើម្រាមព្រះហស្តមួយរបស់ព្រះបដិមាដែលកំបុតឲ្យគាំងនៅដាប្រក្រតីដូច

ដើមវិញ ហើយបូជានូវគ្រឿងបន្ទះបន្ទប់ប៉ុណ្ណោះ, ដោយអំណាចផលនោះ ព្រះពោធិសត្វបានសោយសម្បត្តិទិព្វក្នុងឋានសួគ៌ តាមសេចក្តីប្រាថ្នា, លុះច្យុតចាកទេវលោកនោះមកបានជាស្តេចឯកភាជ្យក្នុងជម្ពូទ្វីបទៀត; តទៅនោះមក ព្រះពោធិសត្វ បានគង់ព្រះពោធិមណ្ឌល កំចាត់បង់ពួកពលមារ ដែលមកចោមរោមព័ទ្ធជុំវិញ ហើយទ្រង់បានត្រាស់សព្វញ្ញុតញ្ញាណជាព្រះពុទ្ធប្រាកដឡើងក្នុងលោក ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ព្រះពុទ្ធដីកាតែប៉ុណ្ណោះ ក៏ទ្រង់គង់ស្ងៀមពាល់តែព្រះបាទបសេនទិកោសល ក្រាបទូលសូមឲ្យព្រះអង្គនាំអតីតនិទានមកសំដែង ទើបព្រះអង្គទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា :

អតីតេ កិរ អមរវតិយា នាម នគរេ ឯកោ ពាណិជោ កុលកទ្ទុកុមារោ នាម បដិវសតិ ។ បានឮរឿងកាលពីដើមកថា កាលដែលកន្លងទៅហើយ នៅក្នុងនគរអមរវតី មានពាណិជម្នាក់ ឈ្មោះកុលកទ្ទុកុមារ ។ សម័យមួយ កុលកទ្ទុកុមារនោះបានបររទេះទៅកាន់នគរឯទៀត ជាមួយនឹងពួកពាណិជប្រហែល ១ ពាន់នាក់ ដើម្បីជួញដូរ ។ កាលដែលកុលកទ្ទុពោធិសត្វ កំពុងបររទេះទៅ ក៏ស្រាប់តែបានប្រទះឃើញព្រះពុទ្ធបដិមាមួយព្រះអង្គ ដែលគេកសាងពីដីស្អិត ក្នុងអាកាសដែលតាំងនៅកណ្តាលផ្លូវ ។ ព្រះពុទ្ធបដិមានោះ ជាក់ស្តែងព្រះហស្តមួយ ដោយត្រង់ទឹកភ្លៀង ។ ពោធិសត្វបានឃើញហើយ ក៏ថ្វាយបង្គំព្រះបដិមានោះ បានប្រថាប់ដីស្អិតលាយនឹងប្រេងល្ង តាមព្រះហស្តព្រះពុទ្ធបដិមាឲ្យពេញបរិបូណ៌ដូចដើមវិញ ។ ពោធិសត្វនោះ បានបូជាដោយគ្រឿង

សក្ការៈ តាំងឡាយ មានខៀនធូប ទឹងផ្កាកម្រងជាដើម ហើយបានយកច្រាក់ ៨ កហាបណៈ មកប្រគល់ឲ្យទាសីម្នាក់ជាអ្នករក្សាព្រះពុទ្ធរូបនោះ ដើម្បីជាជម្រៃគ្រឿងយ័ញ្ញផង ដើម្បីជាជម្រៃគ្រឿងបូជា មានខៀនធូប គ្រឿងក្រអូបទឹងផ្កាកម្រងជាដើមផង, ទើបប្រណម្យអញ្ជលីតាំងសេចក្តីប្រាថ្នាយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន, ដោយអានិសង្សនៃការកសាងព្រះមហស្ពនេះ ដល់ទៅអនាគត សូមកុំឲ្យស្ត្រីតាំងឡាយតាំងពួងមានមកក្នុងទីចំពោះមុខខ្ញុំឡើយ, ហើយខ្ញុំសូមឲ្យបានជាព្រះពុទ្ធប្រាកដក្នុងលោក ។ ចាប់ដើមតាំងពីនោះមក ពលក្តី សត្រូវក្តី ដោយហោចទៅ សូម្បីតែសត្វពស់ដែលមានពិស ក៏មិនហ៊ានទៅចំពីមុខព្រោធិសត្វនោះឡើយ ។ ព្រោធិសត្វទៅជាសុទ្ធដកឋដល់អស់ជន្មាយុ ច្យុតចាកអត្តភាពជាមនុស្សនោះទៅ បានទៅកើតក្នុងទេវលោកសោយសម្បត្តិទិព្វ សម័យនោះ ពួកអាសុរតាំងអស់ ឥតហ៊ានគ្រេកម្រើលចំមុខព្រោធិសត្វ សត្វនោះឡើយ ។ លុះច្យុតចាកស្ថានសួគ៌នោះមក បានមកចាប់បដិសន្ធិក្នុងផ្ទៃនៃអគ្គមហេសីព្រះបាទពារាណសី ។ ចំណែកខាងពួកទេវតាចំនួន ១ ពាន់ជាបរិវារ ក៏ច្យុតមកចាប់បដិសន្ធិ ក្នុងផ្ទៃកំរីយានៃអាមាត្យតាំងឡាយក្នុងនគរនោះដែរ ។ ព្រះអគ្គមហេសីនោះ លុះគ្រប់គត់ខែសមាសហើយ ក៏ប្រសូតិព្រះពជបុត្តប្រកបដោយបុញ្ញលក្ខណៈ ។ ចំណែកខាងកំរីយានៃអាមាត្យតាំងឡាយក៏សម្រាលបុត្តក្នុងថ្ងៃនោះដែរ ។

ព្រះបរមពោធិសត្វ ទ្រង់ចំរើនថ្កុំថ្កើងរុងរឿងដោយពួកកុមារជាបរិវារ ទ្រង់មានពួកកុមារហែហមចោមរោមជានិច្ច ។ ព្រះអង្គមានបុណ្យ

អានុភាពអស្ចារ្យចំឡែក ទោះបីសេះឬដំរីឯណាដែលកាចសាហាវគេ ខ្លួនានពុំបាន, ដំរីឬសេះនោះ គ្រាន់តែឃើញព្រះពោធិសត្វ ចង្អុលដោយម្រាមព្រះហស្តមួយប៉ុណ្ណោះ ក៏ត្រាមត្រាបចុះឥតមានពុតអំណាចរឹងរូសសោះ ព្រោះហេតុដូច្នោះបានជា ព្រះរាជវង្សានុវង្សទ្រង់ថ្វាយព្រះនាមព្រះពោធិសត្វនោះថា វដ្ដង្គុលិរាជកុមារ ។ លុះអំណើះអំពីព្រះវរៈជបិតាទៅ ព្រះពោធិសត្វទ្រង់បានសោយរាជសម្បត្តិ ក្នុងនគរមេសព្រះអង្គដោយទសពិធរាជធម៌ ។ ទ្រង់រក្សាប្រជាជនដោយសង្គហវត្ថុ៤យ៉ាង ពុំបានបៀតបៀនដោយអាជ្ញាឡើយ ។ ព្រះពោធិសត្វអង្គនោះជាធម្មិករាជ ទ្រង់ចំណាយព្រះរាជទ្រព្យសាងសាលាទាន៦ន្លង ហើយទ្រង់ព្រះរាជទាន មហាទាន៦សែនកហាបណៈរាល់ៗ៧ថ្ងៃ ។ ព្រះអង្គពុំដែលសម្ងាប់សត្វចំបាត់ជីវិតឡើយ ដោយហោចទៅ សូម្បីតែញុំងឈាមមនុស្សសត្វដទៃឲ្យស្រក់ចុះត្រឹមតែរុយតូចមួយស្ទឹងខ្ចែត ក៏ពុំដែលផង ។ ទ្រង់ពុំដែលកាន់យកវត្ថុដែលម្ចាស់គេមិនបានឲ្យដោយកាយឬដោយវាចា សូម្បីតែមួយកាកកណិកឡើយ ។ ពុំដែលឆ្នៀងព្រះនេត្រខុសប្រពន្ធអ្នកដទៃ ដោយសេចក្តីតម្រេកបន្តិចបន្តួចឡើយ ។ ពុំដែលបញ្ឆោតព្រះរាជទ្រព្យមិនពិត សូម្បីតែបន្តិចបន្តួចចំពោះអ្នកដទៃឡើយ ។ ពុំដែលសោយសុរាចាំង៥ប្រការ ចំពោះសុរាត្រង់ប្រការណាមួយសោះឡើយ ។

កាលនោះ ព្រះរាជាចាំង១០ព្រះអង្គនៅក្នុងជម្ពូទ្វីប បានជ្រាបនូវគុណានុភាពព្រះមហាក្សត្រហើយ បានរួមគំនិតប្រជុំប្រឹក្សាគ្នាថា ពួក

យើងនឹងទៅច្បាំងដណ្តើមយកពលសម្បត្តិរបស់ស្តេចវដ្តគ្គិលីនោះ ឲ្យបានដោយងាយ ដូចជារបេះផ្កាឈូកដែលជាប់នៅទឹងខន ។

ព្រះពជាតាំងអស់នោះ លុះប្រជុំព្រមព្រៀងគ្នាស្រេច ទើបស្តេចចាត់ការរៀបចតុរង្គអង្គសេនា មានចំនួនពួកពលសកលយោធា ១៨ អក្ខោកិនី ចេញសំដៅទៅក្រុងពារាណសី ។ លុះលើកទ័ពទៅដល់ពាក់កណ្តាលផ្លូវ ក៏សារសេរព្រះពជសារបញ្ជូនទូតម្នាក់ឲ្យនាំយកទៅ ថ្វាយវដ្តគ្គិលីពជ ។ សេចក្តីក្នុងព្រះពជសារនោះយ៉ាងនេះថា អ្នកក្រុងពារាណសីព្រមឲ្យពជ-សម្បត្តិដល់យើង ឬមួយចង់ច្បាំងជាមួយនឹងយើង? បើចង់យ៉ាងណា ចូរធ្វើយ៉ាងនោះចុះ ។ ពជទូតចូលទៅក្នុងក្រុងពារាណសីហើយឈរនៅនាព្រះពជលាន ។ មានអាមាត្យម្នាក់ឃើញពជទូតនោះហើយ ក៏ទៅក្រាបបង្គំទូលព្រះមហាសត្វ ។ ព្រះអង្គទ្រង់ត្រាស់ឲ្យហៅពជទូតនោះចូលមកសួរពត្តមាន ។ ពជទូតក៏ចូលទៅថ្វាយព្រះពជសារ ។ ព្រះពជាទ្រង់ទតសព្វគ្រប់សេចក្តី ក៏មានព្រះពជហឫទ័យក្លៀវក្លាដូចជាពជសីហ៍ ឥតមានសេចក្តីញាប់ញ័រព្រឺព្រឺរោមសូម្បី ១ សរសៃឡើយ ហើយទ្រង់ព្រះសម្រួលត្រាស់សួរពជទូតនោះវិញថា ស្តេចតាំងអស់នោះចំនួនប៉ុន្មាន, មានពួកពលចំនួនប៉ុន្មាន, ដែលមកបំណងនឹងធ្វើសង្គ្រាមជាមួយយើងនេះ? ពជទូតក្រាបទូលថា ស្តេចតាំងអស់ចំនួន ១០១ ព្រះអង្គ, មានពលចំនួន ១៨ អក្ខោកិនី បានមកត្រៀមចាំជាស្រេច ។ (មានត)



ពេទ្យព្រះរាជា

លោក សុិន-ប៉ាន ប្រែរៀបរៀង

លោក យ៉ូរ៉ូ-អ៊ុំ ពិនិត្យកែសម្រួល

អ្នកស្រឡាញ់ធម៌គឺជាអ្នកល្អ

ក្នុងសម័យដ៏កន្ទុំដ៏យូរហើយ នៅប្រទេសឥណ្ឌា មាននគរមួយ ឈ្មោះពារាណសី ជានគរដ៏ធំស្តុកស្តម្ភ, ព្រះមហាក្សត្រគ្រប់គ្រងនគរនេះ ទ្រង់ព្រះនាម "ព្រះធម្មបតីរាជា" ទ្រង់មានព្រះរាជធីតា ៣ ព្រះអង្គ តែគ្មានព្រះរាជបុត្រជារដ្ឋទាយាទទេ ។ បណ្តាព្រះរាជធីតាទាំង ៣ ព្រះអង្គនោះ អង្គបង្អស់ព្រះនាម "សុភាទេវី" អង្គកណ្តាលព្រះនាម "ស្រីឧសា" អង្គប្អូនបំផុតព្រះនាម "កល្យាណី" ព្រះរាជធីតាប្អូនទាំងនេះមានសរីរៈរាងកាយល្អត្រៃលែង សមនឹងព្រះនាមរបស់ព្រះនាង ។

ប្រជាជនក្នុងនគរពារាណសី មានសេចក្តីសុខក្សេមក្សាន្តគ្រប់គ្នា ព្រោះព្រះបាទធម្មបតីរាជាទ្រង់គ្រប់គ្រងនគរតាមទសពិធរាជធម៌ ទើបខេត្តខ័ណ្ឌសីមារបស់ព្រះអង្គត្រជាក់ត្រជុំជាសុខស្តាវ លុះតមកកាលព្រះរាជធីតាទាំង ៣ ព្រះអង្គ មានវ័យសមគួរល្មមនឹងអភិសេកឲ្យមានព្រះស្វាមីហើយ ព្រះអង្គក៏ទ្រង់ហៅហោរាព្រឹទ្ធាមាត្យមកថ្វៃក្សា កាលហោរាព្រឹទ្ធាមាត្យទាំងឡាយមកដល់ហើយ ព្រះអង្គក៏មានព្រះបន្ទូលថា:

"ខ្ញុំចង់ដឹងថា ក្នុងដែនចាំងអស់របស់យើងនេះ តើមានវង្ស្តបុរសដែលសមគួរនឹងអភិសេកជាមួយនឹងធីតារបស់យើងឬទេ? ដូច្នេះសូមលោកចាំងឡាយជ្រើសរើសរកមកឲ្យយើង បើបុត្រក្សត្រចាំងឡាយដ៏សមគួរមិនមានទេ ក៏សូមឲ្យលោកចាត់រកបុត្រវេស្សពស្តេអ្នកដំនួញក្នុងដែនរបស់យើងឬអំពីដែនដទៃក៏បាន សូមឲ្យពួកលោកទទួលការក្នុងការណ៍នេះ ដោយយកចិត្តទុកដាក់" ។

ពួកព្រឹទ្ធាមាត្យ ទទួលព្រះពរដបញ្ជាព្រះមហាក្សត្រ ហើយក៏ប្រឹក្សាគ្នា, បណ្តាអាមាត្យនឹងខុនណាចាំងឡាយ មានខុនណាងអ្នកធំ ១ រូប ឲ្យយោបល់ថា

"នគរពោធណាស៍ មានសេចក្តីរុងរឿងមកជាយូរអង្វែងឆ្នាំហើយ ដោយសារបុណ្យសម្ភារចារិតនៃព្រះមហាក្សត្រទ្រង់មានព្រះពរជ្ញាទ័យទ្រង់ធម៌ មានព្រះគុណាទិគុណ ទ្រង់ប្រកបដោយទសពិធរាជធម៌ប្រចាំព្រះអង្គ ដូច្នេះសូមឲ្យអស់លោកពិនិត្យមើលឲ្យល្អិតល្អន់" ។

ខុនណាងអ្នកធំ ១ រូបទៀតឲ្យយោបល់ថា

"ដើម្បីសេចក្តីសុខដល់ព្រះរាជា នឹងប្រជាជនចាំងពួង សូមឲ្យស៊ើបសួរជ្រើសរើសរកចំពោះតែអ្នកដែលមានគុណពិសេស, មិនចាំបាច់តែព្រះរាជបុត្រព្រះមហាក្សត្រទេ ទោះជាជាតិស្តេស្តុកណាក៏ដោយ ឲ្យតែមានសតិបញ្ញាឈ្វាសវៃនឹងមានគុណធម៌ដ៏ពិសេស ដែលសមគួរនឹងគ្រប់គ្រងនគរជាតំណអំពីព្រះធម្មបតិរាជាក្សត្រវេស្សយើងបាន" ។

កាលប្រជុំព្រមគ្នាជាឯកច្ឆន្ទហើយ ក៏ជ្រើសរើសបានខុនណាងអ្នក

ធំ ៣ រូបសំពាប់ឲ្យចេញទៅស៊ើបរកបុរសក្នុងដើម្បីឲ្យជាគូនឹងពជបុត្រី, ខុន ណាងអ្នកធំតាំង ៣ រូបនោះ ឈ្មោះចាលិត ១ សុទស្សនៈ ១ ទលិត ១ តាំង ៣ នេះជាអ្នកមានច្បាស់ជាវៀងវៃ មានសមត្ថភាពអង់អាចជាប់ធ្វើការគាង ព្រះនេត្រព្រះកាណាវបស់ព្រះធម្មបតីពជាមកជាយូរហើយ ។

ទើងថ្ងៃអំពីព្រះអង្គម្ចាស់ក្សត្រីតាំង ៣ ព្រះអង្គវិញ, កាលព្រះពជា ចានទ្រង់ប្រគល់ការជើសរើសស្វាមីដើម្បីពជបុត្រីស្រេចហើយ ក៏ស្តេច ទៅព្រះពជដំណាក់ ទ្រង់ដួបព្រះពជធីតាតាំង ៣ ហើយត្រាស់ប្តាប់ រឿងការវិវាទដែលព្រះអង្គចានទ្រង់ធ្វើឲ្យព្រះធីតាតាំង ៣ ព្រះអង្គជាបហេតុ ការណ៍រៀងៗខ្លួន ។

ព្រះពជធីតាតាំង ៣ ព្រះអង្គមានសេចក្តីអៀនខ្មាស់តាមវិស័យក្សត្រី ដែលមានស័ក្តិខ្ពស់, ព្រះនាងបងគ្រាបបង្គំទូលព្រះពជបិតាថា:

"បពិត្រព្រះពជបិតា ខ្ញុំម្ចាស់ជាព្រះពជបុត្រីរបស់ព្រះអង្គ ព្រះអង្គ ជាព្រះបិតា ទ្រង់ព្រះករុណាគុណដល់ខ្ញុំម្ចាស់ជាបុត្រី តម្រូនឹងរកវត្ថុ ឯណាក្នុងលោកមកប្រៀបឲ្យស្មើបាន, កាលបើព្រះអង្គមានព្រះពជបំ-ណងយ៉ាងណា ខ្ញុំម្ចាស់ក៏មិនអាចនឹងបដិសេធបោលនូវព្រះពជបំណង នោះឡើយ" ទូលព្រះពជបិតាហើយ ព្រះនាងបងក៏គង់នៅស្ងៀម ។

ព្រះធម្មបតីពជាទ្រង់លាន់ព្រះឆ្មៃ ដោយព្រះទ័យជឿកាយយ៉ាង ក្រៃលែង កាលបើព្រះពជធីតារបស់ព្រះអង្គមានចិត្តប្រកបដោយគុណ ធម៌ គឺសេចក្តីកតញ្ញូកតវេទី ដឹងគុណតាំងនៅក្នុងព្រះពជទ្រព្យយ៉ាង នេះហើយ ទើបទ្រង់ត្រាស់សួរដល់ព្រះពជធីតាបួនតាំងពីរតទៅទៀត

"នែបុត្រីសំឡាញ់! បិតាបានស្តាប់ពាក្យបង្គំនាងហើយ ក្រែងជាបិតានាងត្រែកអរហើយ បានទទួលប្រតិបត្តិតាមបំណងរបស់បិតា, ចុះបុត្រីចាំងពីរៀបៗ តើនឹងមានការខឹងគាស់យ៉ាងណាដែរឬទេ?" ។

ព្រះនាងស្រីទេសានឹងព្រះនាងកល្យាណីជ្រប់ព្រះកន្ត្រក ព្រះពជបិតាក៏គាស់សួរថែមទៀត:

"យ៉ាងដូចម្តេចទៅបុត្រីសំឡាញ់ចាំងពីរ, នាងមិនមានសេចក្តីត្រែកអរទេឬ?" ។

ទត្តិយានីចាំងពីរព្រះអង្គងើបព្រះកន្ត្រកឡើងហើយក្រាបបង្គំទូលតបព្រះពជបិតាថា:

"ខ្ញុំម្ចាស់ត្រែកអរ, ក្រែលើព្រះពជបិតាមានព្រះពជបំណងយ៉ាងណា ខ្ញុំម្ចាស់ក៏ពុំហ៊ានទទឹងគាស់ចាំងអស់" ។

ព្រះធម្មបតីពជាទ្រង់សោមនស្សយ៉ាងក្រៃលែង; តាំងអំពីនោះមកទ្រង់ក៏រង់ចាំមើលពួកអាមាត្យធំៗ ចាំង ៣ នាក់ដែលចេញទៅស៊ើបអង្កេតកេបុរសវ័ត្ត មកធ្វើជាព្រះពជសុនិសាដោយព្រះទ័យដ៏រួសរាន់ ។

ចាប់តាំងអំពីថ្ងៃជាដំបូង, អាមាត្យចាំង ៣ នាក់គ្នាដើរតាមផ្លូវចេញអំពីក្រុងពារាណសី ដរាបដល់ផ្លូវមួយបែកជាបី ឆ្ងាយពីក្រុងពារាណសីក៏បញ្ឈប់សេះប្រឹក្សាគ្នា:

"លោកចាំងពីរយល់ឃើញប្រការណាល្អជាង? យើងនឹងរួមគ្នាទៅតាន់ប្រទេសនីមួយៗ ចាំង ៣ នាក់ ឬនឹងបំបែកផ្លូវគ្នាទៅ តើបប្រពៃ?

បើយើងចំបែកគ្នាទៅ ហើយបានជួបប្រសព្វគ្នាក្នុងស្រុកណា យើងត្រូវរៀបត្រឡប់មកជួបគ្នានៅទីនេះ ក្នុងរយៈពេល ៦ ខែខាងមុខទៀត" ។

អមាត្យធំឈ្មោះចាលិត ជាអ្នកឱ្យយោបល់ដល់អមាត្យសុទស្សនៈ ទើបអមាត្យទុលិត, ដូច្នេះហើយទាំង ៣ នាក់ក៏យល់ស្របគ្នាទើបចំបែកផ្លូវគ្នាចេញទៅនៅខាងក្រោយពេល ដែលបានណាត់គ្នារួចហើយ ។ ចាលិតអមាត្យជាអ្នកចាស់ជាងគេស្គាត់ដំនាក់ញូវិជ្ជាផ្សេងៗ មកតាំងអំពីនៅកម្មោះ ជាអ្នកដឹងដល់ចិត្តថ្លើមមនុស្សណាដែលស្មោះត្រង់ រឿបរៀបឬមនុស្សលួងខ្លៅ, ក៏ឡើងជិះសេះបរកាត់តម្រង់ទៅកាន់ក្រុងវេសាលី ដែលជាប្រទេសមួយនៅឆ្ងាយអំពីនគរពោណាសី ។ ក្រុងវេសាលីមានកូមិប្លែកៗ មានកំផ្លាច្រើន, ទេសភាពក្រុងកំពុងតែប្រជាប់តាក់តែងទៅដោយគោមក្តៅដ៏ធំធាត់ខ្លួនទៅ ហាក់ដូចជាមានការធ្វើបុណ្យទូន្មានគរ ។ ចាលិតអមាត្យទើបចូលទៅសួរបុរសម្នាក់ថា:

"ម្ចាលលោកដ៏ចំរើន, ការដោតទង់ជាតិ ទឹងប្រជាប់តាក់តែងទៅដោយគោមក្តៅខ្លួនទៅទាំងព្រឹនគរយ៉ាងនេះ តើដើម្បីធ្វើពិធីអ្វី? ព្រោះខ្ញុំទើបទឹងមកអំពីឆ្ងាយមិនបានទឹងរឿងរ៉ាវនេះសោះ សូមលោកមេត្តាប្រាប់ខ្ញុំឲ្យបានដឹងផង" ។

បុរសដែលត្រូវគេសួរឃើញអាការៈរបស់អមាត្យចាលិតមានសេចក្តីគួរសំពោង ក៏សើចហើយតបថា:

"លោកវង្វៀតតែទៅក្នុងឆ្ងាយទើបមិនដឹងថា ក្នុង ៧ ថ្ងៃខាងមុខនេះ ព្រះពាធាទឹងធ្វើពិធីបូជាយ័ញ្ញយ៉ាងធំឡាក ក្នុងកោងពិធីមុខព្រះពាធាំង,

ពិធីនេះមិនបានធ្វើមកអស់រៀលច្រើនឆ្នាំហើយ, ការបូជាយ័ញ្ញត្រូវច្រើនសត្វរស់ៗ ជាចំនួនច្រើន, បុណ្យទាំងនេះយូរៗ មានឡើងម្តង គេធ្វើក្នុងពេលដែលស្រុកទេសកើតអាកេរមិនមានសន្តិសុខ" ។

ចាលិតអមាត្យទើបចុះអំពីខ្នងសេះ ដោយសេចក្តីធ្ងឿនធ្ងល់ក្នុងចិត្ត ព្រោះមិនធ្លាប់បានឮបានដឹងអំពីវិធីបូជាយ័ញ្ញ ដោយសត្វរស់ៗ ដែលថ្លែងផ្សងអំពីពិធីដទៃៗ ដែលធ្លាប់បានឃើញមកក្នុងក្រុងពាកណសី ព្រមទាំងធ្ងល់ថា តើការបូជាយ័ញ្ញដោយសត្វរស់ទោះនឹងធ្វើដោយប្រការដូចម្តេច? កាលមានសេចក្តីសង្ស័យដូច្នោះហើយក៏អត់សង្កត់ចិត្តមិនបានទើបសួរទៀត :

"សូមលោកមេត្តាប្រាប់ខ្ញុំឲ្យបានដឹងបន្ថែមតទៅទៀត ការបូជាយ័ញ្ញដែលពាក់ព័ន្ធជាពិធីដ៏សំខាន់ត្រូវប្រើសត្វរស់ៗ នោះ តើកើតអំពីអ្វីដែលជាដើមហេតុ ហើយត្រូវប្រើសត្វអស់ប៉ុន្មាន?" ។

ឯណៈដែលចាលិតអមាត្យកំពុងតែសួរ អំពីការធ្វើពិធីបូជាយ័ញ្ញចំពោះបុរសនោះ ក៏ស្រាប់តែមានមាណពម្នាក់ដើរសេះសត្រង់ចូលមកបញ្ឈប់សេះហើយចុះមកសម្តែងសួរដោយអាការនុនលំទោនមានលំនាំជាឥតួរសើរតួរកែកយ :

"លោកដ៏ចំរើន, សូមមេត្តាប្រាប់ឲ្យខ្ញុំបានដឹងផង តើប៉ុន្មានថ្ងៃទៀតព្រះពជានឹងធ្វើពិធីបូជាយ័ញ្ញ?" ។

បុរសនោះតបថា "មាណព, ៣ ថ្ងៃទៀត លោកនឹងបានឃើញពិធីធំដុំដែលយូរៗ មានធ្វើម្តង គេបង្អង់ចាំឲ្យតែដល់ថ្ងៃ ១៥ កើតដែល

ព្រះចន្ទរះពេញវង់ ជាថ្ងៃដែលព្រះឥសូរទ្រង់រីករាយព្រះទ័យ ថ្ងៃនោះ ព្រះរាជាទន្លែងដ៏ប្រោសប្រទានឲ្យធ្វើពិធីនេះហើយ" ។ មាណពឆ្លក់ក្បាលហើយអង្គុយស្ងៀមមិននិយាយអ្វីតទៅទៀត ។

បុរសនោះទើបឆាកបែរមុខមកនិយាយនឹងបាលិតអាមាត្យ :

" ការបូជាយ័ញ្ញដែលនឹងធ្វើក្នុងថ្ងៃដូចពោលមកនេះ គឺព្រោះព្រះជាតារបស់ព្រះរាជាទន្លែងប្រឈួនជាខ្លាំងក្នុងគ្រានេះ ព្រមទាំងកើតមានអាកេរផ្សេងៗគឺ សំបូរក្នុងស្រែមិនល្អតសល់ស្អាប់អស់រលីងព្រោះគ្មានទឹក; ការកំណាចក្លៀងនេះនាំឲ្យកើតរោគរបាក្បាលពួកទាំងស្រុក, ព្រះរាជាបានទ្រង់សួរទៅពួករោហក និងពួកព្រាហ្មណ៍ ។ ឥសូរជនទាំងនេះ សឹងតែយល់ឃើញស្របគ្នាហើយក្រាបទូលថា. " ព្រះឥសូរជាម្ចាស់ទ្រង់ពិរោធ ទើបបានបណ្តាលឲ្យក្លៀងកាំងនឹងកើតមានរោគរបាក្បា, ត្រូវតែរកតំណែបួងសួងខ្ពើមទាំងឡាយនឹងព្រះឥសូរ ទើបហេតុអាកេទាំងឡាយនឹងបន្ធូរបន្ថយស្រាលស្តើងទៅបាន" ។

អាមាត្យបាលិតបានស្តាប់ពាក្យអធិប្បាយអំពីវិធីបួងសួង ដោយបូជាយ័ញ្ញហើយ ក៏ចង់ឃើញពិធីនោះយ៉ាងម៉ៃក្រៃលែង ទើបអរគុណបុរសនោះហើយក៏លាទៅវិញទីស្នាក់តទៅ. ដំណើរដើរតាមផ្លូវទៅមិនយូរប៉ុន្មាន ក៏បានដល់ព្រះរាជវាំងនៃព្រះម្ចាស់ផែនដីនៃនគរវេសាលី បានឃើញពេធពិធីធំៗយ៉ាងមហិមា ក៏ប្រញាប់ស្រួតដើរដឹកសេះចូលទៅមើលជិត ។ មើលទៅខាងក្នុងឃើញមានដើរគ្រានក្តៀងធំៗ ដែលកដោយអដ្ឋ ព្រមទាំងឧសសួតប្រុងប្រៀបខ្ទុកសម្រាប់ដុត បន្ទាប់អំពីដើរគ្រាន

ក្នុងឆ្នាំ ។ នោះទៅ មានក្មេងកសិករបានយកអំពីខែនីមួយ ។ ខែនោះ មានហ៊ុនសៀតគ្រឿងសស្ត្រាវុធជាវាលំពែងគ្រប់បែប មើលទៅគួរឲ្យខ្លាចពន់ពេក អំពីចន្លោះខែនោះទៅមានក្រមុំសត្វធំ ។ សត្វដែលនៅក្នុងក្រមុំនោះមាន សេះ, គោ, ក្របី, ពពែ, កែះ ឮសូរតែសំឡេងយំអឺងកងខ្ទរទៅពាំងបរិវេណពេញពិធី, សត្វខ្លះក៏ដេកលក់ស៊ីប់ ខ្លះស៊ីស្មៅ ខ្លះក៏ឈរស្ងៀមសម្លឹងមើលទៅខាងក្រៅ ។

ចៅលិតអមាត្យពប់សត្វពាំងនោះទៅឃើញប្រមាណជាងពាន់សត្វ ក៏នឹកចំឡែកក្នុងចិត្តចំពោះពិធីនេះ ដែលខ្លួនមិនធ្លាប់បានឃើញពីដើមមក សោះ ។ ខណៈដែលចៅលិតអមាត្យកំពុងឈរមើលដោយសេចក្តីស្ងប់ស្ងៀងនោះ មានបុរសម្នាក់មកកេះគាត់ពីខាងក្រោយ គាត់ងាកមើលទៅឃើញមាណពតូចម្នាក់ដែលបានជួបអម្បាញ់មិញម្តងមកហើយ ទើបគាត់សន្ធឹងនឹងបុរសនោះ ។

មាណពតូចនោះឆក់ក្បាលធ្វើគារវកិច្ចហើយប្រស្រ័យ ដោយកិរិយាមិនសូវរីករាយ :

"លោកដ៏មានអាយុ លោកចូលចិត្តក្នុងពិធីបូជាយ័ញ្ញរបស់ព្រះកជាឬ? តើលោកមានការដឹងយ៉ាងដូចម្តេចខ្លះក្នុងពិធីនេះ? ។

អមាត្យចៅលិត ឃើញអាការរបស់មាណពតូចដូច្នោះហើយ ក៏ពិនិត្យមើលឃើញសត្វពាងកាយរបស់គេទៅឃើញបានថា ជាបុរសកម្ងោះ ១ រូបល្អឆើត ដោយតែងកាយប្លែកអំពីអ្នកស្រុកនេះ ស្ពាយជាវសមស្ងួនស្រស់បស់គួរមើល ទើបយល់បានថា គេមិនមែនជាអ្នកស្រុក

នេះដោយពិតជាកង, អាកប្បកិរិយារបស់គេនុនលំពោនបន្តូនខ្លួនក្នុង
ខណៈដែលចរចា, ជាលិតអមាត្យទើបតបថា:

" ខ្ញុំដឹងប្លាស់មកតាំងអំពីដំបូង ដោយបានឃើញការតាក់តែងធំ
ជាតិខ្លួនៗទាំងព្រះនគរ លុះចាលបានសាកសួរអ្នកស្រុកដឹងនូវកិច្ចការធ្វើ
ពិធីហើយ ខ្ញុំជាមនុស្សតាងប្រទេស មិនធ្លាប់បានឃើញពិធីដូច្នេះ
ក្នុងខណាមកអំពីមុនសោះឡើយ ទើបខ្ញុំចង់ឃើញការធ្វើពិធីនេះឲ្យជាក់
ប្លាស់ធំនៃក្នក តើលោកឃើញពិធីនេះប្លែកយ៉ាងដូចម្តេចខ្លះ? " ។

មាណពងើបមើលទៅខាងក្រង់ទាំងសត្វនោះមុន ទើបបែរមុខមក
និយាយថា:

" ខ្ញុំមិនឃើញថា ពិធីនេះជាពិធីប្លែកគួរមើលគួរសរសើរសោះទេ
ព្រោះសត្វទាំងឡាយ ដែលគេនាំមកទាំងខ្លុកទៅដីនេះ ធំតែត្រូវគេ
សម្លាប់សាច់ស្បែករបស់ពួកវាត្រូវព្រះអគ្គីឆាបនេះខ្ចោចទៅជាផ្សងផែះ
តុំខាន តើធំកើតប្រយោជន៍អ្វីដោយការបូជាបែបនេះ? ពេតរបក្សារបស់
អ្នកស្រុកធំតែការប្រឈួនខែព្រះអគ្គិម្ចាស់ក្សត្រីមិនមែនវិនាសទៅ ព្រោះ
តែការបូជាយញ្ញបែបនេះទេ ការយល់ឃើញរបស់ខ្ញុំដូច្នេះឯង " ។

ជាលិតអមាត្យ ជានស្តាប់ពាក្យរបស់មាណព តំយល់ឃើញថាជា
ពាក្យពិត តែក្នុងចិត្តនៅគិតថាជាពិធីបូជាយញ្ញនេះជាប្រពៃណីដែលអ្នក
នគរនេះធ្លាប់ធ្វើធំតបត្តិមក ឯមាណពអ្នកនិយាយមិនមែនជាអ្នកស្រុក
នេះ ព្រោះធម្មតាមនុស្សក្រៅប្រទេសតែងមានគំនិតផ្ទុយគ្នា តែពាក្យ
របស់មាណពនោះអាចជាស់សតិគាត់ជានខ្លះទើបសួរមាណពថា:

"ចុះលោកបានជ្រាបច្បាស់ដូចេ្នះហើយឬ ថាការបើធ្វើពិធីបូជាយ៉ាញ្ញ
ទៅហើយ អាការប្រឈួនៃម្ចាស់ក្បែរនឹងពេលវេលាក្បាលឯងមិនវិនាស?" ។

មាណពឆ័ក្សាលតំនាបតបថា "ខ្ញុំបានដឹងរឿងសេសជាឯងនេះទៅ
ទៀត? ព្រោះហេតុនេះ ខ្ញុំទើបនិយាយថាការធ្វើពិធីបូជាយ៉ាញ្ញានេះ មិន
សម្រេចប្រយោជន៍អ្វីក្រៅអំពីការបង្កឲ្យកើតសេចក្តីទុក្ខវេទនាធំការតក់
ស្លុតដល់មនុស្សជូចជាខ្ញុំនេះ" និយាយបណ្តើរលើកដៃចង្អុលទៅត្រង់ចំ
ដែលគេធ្វើទុកក្នុងពេលពិធីដែលមានគ្នាទើបហូរមកកាន់តំនរក្បើង "លោក
មើលចំឯណោះ? តើលោកមានសេចក្តីយល់ឃើញដូចម្តេច?" ។

អមាត្យឫសិតបានស្តាប់ពាក្យមាណពហើយ ក៏ទឹកឮល់ថា ហេតុអ្វី
បានជាថា ពិធីនេះធ្វើឲ្យកើតនូវសេចក្តីតក់ស្លុតធំទុក្ខវេទនាដល់មាណព?
តែលុះដល់សម្លឹងមើលតាមដៃដែលមាណពចង្អុលទៅ ក៏ផ្ទាស់ទឹកមុខ
តបថា:

"ខ្ញុំយល់ថា ជាកន្ទែងដែលគេធ្វើសម្រាប់ឲ្យទឹកហូរមកកាន់តំនរ
ក្បើង" ។

—មិនមែនទេ! សេចក្តីចូលចិត្តរបស់លោកយ៉ាងនេះមិនត្រូវសោះ
សេចក្តីពិត ទារនេះគេធ្វើទុកបំរុងចាំដល់វេលាណាដែលគេនាំសត្វស្រស់ ។
មកជាក់លើទែនរៀបរួចហើយ គេក៏អារកសត្វនោះឲ្យឈាមហូរចាញ់
ចេញចាកចំពងឆ្អឹកទៅក្នុងទារនេះ ទារនេះក៏គឺទារឈាមនោះឯង មិនមែន
ទេរបង្អួរទឹកទេ ខ្ញុំឃើញថាគួរស្រប់ស្រែងចាំងជាអំពើអាក្រក់ខ្លាំងណាស់ ។

អាមាត្យថ្មាលិតស្តាប់ពាក្យមាណពដែលនិយាយអំពីនារីយ៉ាមហើយ
គាលគំចារណាទៅតាមពាក្យនោះ ក៏កើតមានសេចក្តីស្រឡាំងកាំង
សម្លាប់សត្វខ្លែត :

"អើមាណព សូមអ្នកទុកឧកាសខំនេរគ្រាន់ជានសន្ធានធីនខ្ញុំខ្លែត
ព្រោះខ្ញុំទើបនឹងមកដល់ខនរនេះក្នុងថ្ងៃនេះឯង មិនទាន់កេីស្នាក់ជាន
នៅឡើយ ខ្ញុំមិនដឹងជានឹងទៅស្នាក់នៅទីណាទេ ខណៈនេះពេលក៏ជិត
ដល់ថ្ងៃត្រង់ហើយ ខ្ញុំចង់រកទីស្នាក់សម្រាកឲ្យជានសម្រេចជាមុនសិន" ។

មាណពទើបអញ្ជើញអមាត្យថ្មាលិត :

" បើលោកមិននរង្គៀសទេ សូមអញ្ជើញទៅស្នាក់ជាមួយនឹងខ្ញុំចុះ
ព្រោះខ្ញុំជានជួលផ្ទះមួយទៅទីបរវែលផ្សារ មិនឆ្ងាយអំពីព្រះពជកំងនេះ
ប៉ុន្មាន" ។

អមាត្យខ្លាចចិត្តមាណពពន់ពេកទើបតបថា :

"ក្រែងជាការលំបាកដល់លោកនឹងពួកមិត្ត ឬមនុស្សដទៃដែលមក
ជាមួយនឹងលោកទេដឹង ! បើដូច្នេះសូមកុំលោកព្រួយចុះ គ្រាន់តែប្រាប់
ខ្ញុំអំពីទីស្នាក់ដែលលួមរកជានទៅទីដទៃ ខ្ញុំអរគុណណាស់ហើយ" ។

" មិនមាននរណាទេលោក ! ខ្ញុំនៅតែម្នាក់ឯង, ទាំងផ្ទះស្នាក់ខ្ញុំក៏
ជួលយកមានបន្ទប់នៅសល់ទៀត គួរនៅដោយសប្បាយ ផ្ទះសំណាក់
នោះតាំងនៅក្បែរមាត់ទឹក, ខ្ញុំកំពុងចង់ជានមិត្តម្នាក់ ក៏ទើបជួលជានមក
ជួបនឹងលោក ខ្ញុំអរណាស់" ។

(មានត)

រឿងភ្នំសំពៅនៅខេត្តបាត់ដំបង

និង

រឿងភ្នំម្ភាយនឹងក្មួនៅវៀតណាមខាងត្បូង

ជារឿងព្រេង

អ្នកស្រីពេជ្រ-សល់ ហៅសារ៉ះយ៉ាន

រៀបរៀបរៀង

រឿងភ្នំសំពៅនៅខេត្តបាត់ដំបង

ភ្នំសំពៅនៅខេត្តបាត់ដំបងក្នុងប្រទេសកម្ពុជាយើងនេះ មានរឿងព្រេងដំណាលថា ក្នុងកាលកន្លងទៅយូរហើយ មានព្រះមហាក្សត្រមួយអង្គព្រះនាម រាជកុល សោយរាជ្យនៅប្រទេសកម្ពុជា ។ ព្រះបាទរាជកុលទ្រង់សព្វព្រះរាជហឫទ័យនឹងស្រីម្នាក់ឈ្មោះនាង សុវណ្ណមសា នាងនេះជាកូនអ្នកក្រីក្រទេ ប៉ុន្តែនាងមានរូបឆោមល័ក្ខិសមល្អណាស់ នាងចិញ្ចឹមសត្វក្រពើមួយ ដែលមានវិជ្ជីក្បាហាន ធ្វាតវាងវៃណាស់ គោះបីនឹងប្រែឲ្យធ្វើអ្វីក៏បានតាំងអស់ ។ ក្រពើនោះមានខ្លួនធំលើសប្រមាណ នាងឲ្យឈ្មោះអាធន់ ។ តាមដំណាលថា នាងសុវណ្ណមសាដើរសុំបានពងសត្វមួយយកមកពុក តែនាងមិនស្គាល់ជាពងសត្វអ្វីទេ ប៉ុន្តែលុះដល់ថ្ងៃខែនឹងញាស់ ស្រាប់តែឃើញចេញកូនក្រពើមក ។ នាងក៏ចេះតែអាណិតនិងចិញ្ចឹមថែរក្សាដោយពេញចិត្តណាស់ ក្រពើនោះទៀតសោត ក៏ឃ្លាតពីក្រពើតាំងពួន ចេះស្អាប់ចង្អាប់នាងដូចជាមនុស្សស្នេហាជា ។

ឯព្រះបាទពាជកុល លុះបានឮសុវណ្ណមសាមកជាគូស្នេហាហើយ
មិនយូរប៉ុន្មានក៏មានព្រះឱយពុំសូវស្នំគ្រោះ ដោយខ្លាំព្រះចិត្តឃើញ
ថា នឹងលើកនាងជាអគ្គមហេសីពេញទីពុំបាន ព្រោះនាងជាកូស្តីមាន
ហានៈពុំស្មើ ពុំសមនឹងរៀបអភិសេកជាឯកអគ្គមហេសីសោះ ។ លុះខ្លាំ
គិតដូច្នេះហើយ ខ្លាំស្តេចទៅគ្រាបទូលព្រះវរពាជបិតាមាតា ។ ក៏ខ្លាំ
យល់តាមហើយចាត់ឱ្យស៊ើបសួរកូស៊ីឯណាដែលមានពូជពង្សត្រកូល
ខ្ពង់ខ្ពស់ ដើម្បីនឹងរៀបអភិសេកជាមួយនឹងព្រះពាជបុត្រារបស់ព្រះអង្គ ។
យូរបន្តិចមក ឮដំណឹងថា នៅស្រុកចន្ទបុរី មានស្តេចមួយព្រះអង្គ មាន
ព្រះពាជបុត្រីមួយព្រះនាមនាង រំសាយសក់ ព្រោះនាងមានសក់ចិញ្ចូ
ចង់ច្រាច្នាអ្វីក៏បានដូចចិត្ត ។ គឺនាងគ្រាន់តែច្បូតសក់ទៅចង់ឱ្យទឹកសមុទ្រ
ខះទៅជាដីគោកក៏បាន ចាំឱ្យដីគោកក្លាយទៅជាទឹកសមុទ្រក៏បាន ។
ទើបមាតាបិតាព្រះបាទពាជកុល ប្រើសេនាឱ្យនាំសារទៅថ្វាយស្តេចក្រុង
ចន្ទបុរី ដើម្បីដណ្តឹងនាងនោះតាមច្បាប់ប្រពៃណី ។ ស្តេចក្រុងចន្ទបុរីក៏
ពុំខ្លាំយល់ទាស់ឡើយ ខ្លាំក៏បង្គាប់ឱ្យលើកបណ្ណាការមក ។ សេនា
បានទទួលព្រះពាជឧត្តារ ហើយត្រាបបង្គំលាត្រឡប់មកត្រាបទូលព្រះវរ
ពាជមាតាបិតានៃព្រះបាទពាជកុលសព្វគ្រប់តាមដំណើរនោះ ព្រះបាទ
ពាជកុលខ្លាំបានព្រះសណ្តាប់ដូច្នោះ ក៏មានព្រះឱយសោមនស្សជា
ពន់ពេក ទើបខ្លាំត្រាស់បង្គាប់រៀបចំគ្រឿងបណ្ណាការយ៉ាងខ្ពង់ខ្ពស់
ក្នុងសំពៅ ដើម្បីធ្វើដំណើរចេញទៅកាន់ក្រុងចន្ទបុរី ។

ចំណែកនាងសុវណ្ណមសាចុនដឹងដំណឹងនេះគាលណា កំកើតចិត្តក្តៅគ្រហាយខ្លាំងណាស់ ទើបប្រើគ្រតើឲ្យទៅតាមកល់សំពៅនោះឲ្យលិចវិនាសអន្តរាយ កុំឲ្យព្រះចាខពជកុលចុនទៅដួចនឹងនាងរំសាយសក់ ។ គ្រតើនោះក៏ប្រើចុនដួចចិត្តទៀត ក៏ចោះពួយកន្ទឹកលឿនដួចព្រួញ លុះដឹតដល់ទៅសំពៅព្រះចាខពជកុល ។ ខ្ទង់គ្រឡេកឃើញអាចន់ កំខ្ទង់មានព្រះបន្ទូលយ៉ាងខ្លាំង ។ ច្រាប់ថា ៖

– នែអាចន់ អញទេ កុំមកធ្វើផ្តេសផ្តាស!

អាចន់ឆ្លើយទៅវិញថា ៖

– ស៊ីចុាយអ្នកណា យកអាសាអ្នកនោះ ។

ពួកពលគ្រឡេកឃើញគ្រតើធំសំបើម ក៏ភ័យស្រែកនោះឡោពេញទាំងសំពៅ ខ្លះចោះត្រឡាច រៅ ខ្ទង់មាន់ ខ្ទង់ទាឲ្យអាចន់ឈប់ស៊ី ដើម្បីឲ្យឃ្លាតឆ្ងាយអំពីសំពៅ តែអាចន់ពុំខ្វល់ស៊ីសោះ ។ ព្រះចាខពជកុលក៏ប្លងសួងអស់ទៅតាសូមឲ្យលោកជួយឲ្យផុតពីគ្រោះថ្នាក់ ។

ដោយបុណ្យចារមីព្រះអគ្គ សេចក្តីប្លងសួងនេះ ក៏ដំណួលទៅដល់ព្រះឥន្ទ្រាធិរាជ ។ ក៏ប្រើបំរើឲ្យទៅច្រាប់នាងរំសាយសក់ក្លាម ។ នាងរំសាយសក់ក៏ប្លូតព្រះកេសីឲ្យទឹកសមុទ្រខ្ទះរើទៅជាដីទាំងអស់ ។ ឯគ្រតើក៏ជាប់ក្នុងដីនោះដែរ តែមុននឹងស្លាប់ គ្រតើនោះគោះកន្ទុយផងរកដង្ហើមផង ទាល់តែជាច់ខ្យល់ស្លាប់ ។ តួខ្លួនគ្រតើក៏ក្លាយទៅជាភ្នំមួយធំ ហៅ ភ្នំក្រពើ ទាល់តែដល់សព្វថ្ងៃនេះ ។ ត្រង់កន្ទែងគ្រតើគោះកន្ទុយនឹងត្រង់ច្រមុះគ្រតើ ក៏ក្លាយទៅជាបឹងទាំងពីរទៅដល់សព្វថ្ងៃ

នេះដែរ ហៅ បឹងភក្ដួយក្រពើ ទឹង បឹងប្រមុំក្រពើ ។ ឯសំពៅ
នោះក៏ក្លាយទៅជាភ្នំមានពាងជាសំពៅសុទ្ធ ហៅ ភ្នំសំពៅ តែផ្នែងបន្តិច
ព្រោះលោកចោកខ្ទាំងណា សំទៅពេលដែលអាធន់ដឹតទៅដល់សំពៅ ។
ក្តោងសំពៅក៏សន្តកឆ្ងាក់ទៅក្នុងទឹក ហើយក្លាយទៅជាភ្នំមួយហៅ ភ្នំ
ក្តោងសំពៅ ពាល់សព្វថ្ងៃនេះ ។

ព្រះបាទពាជកុល លុះសម្តែងក្លាយទៅជាដី ក៏ប្រែពួកពលឲ្យជញ្ជូន
ចែងចាប់ច្រែងាំងពួនដើរទៅកាន់ក្រុងចន្ទបុរី ដើម្បីរៀបអភិសេកជាមួយ
ទឹងនាងរំសាយសក់តាមប្រពៃណីទៅ ។ កន្លែងដែលនាងប្លុតសក់នោះ
ក៏ក្លាយទៅជាភ្នំមួយនៅខាងត្បូងភ្នំសំពៅ ហៅ ភ្នំរំសាយសក់ ទៅ
ដល់សព្វថ្ងៃ ។

លុះរៀបអភិសេកស្រេចហើយ ព្រះបាទពាជកុល ទ្រង់នាំនាង
រំសាយសក់ជាអគ្គមហេសី ព្រមទាំងពលសេនាជាច្រើនត្រឡប់ទៅកាន់
ពាជបុរីវិញ ។ ព្រះអង្គទ្រង់គង់លើដំរីជាមួយនឹងភរិយាមានពលហែហម
មកជាច្រើន ។ មកដល់ពាក់កណ្តាលផ្លូវទ្រង់ក្រឡេកទៅឃើញភ្នំសំពៅ
ភ្នំក្រពើ ទ្រង់នឹកខោមនស្សជាខ្លាំងនឹងនាងសុវណ្ណមសា ថាព្រោះតែភ
ចិត្តអាក្រក់ចាន់ជាឲ្យគេស្លាប់វិនាសអស់យ៉ាងនេះ ។ ព្រះអង្គក៏ទ្រង់ប្រើ
ឲ្យសេនាទៅចាប់នាងសុវណ្ណមសាមកសម្លាប់ចោល សេនាក៏ធ្វើតាមព្រះ
ពាជបញ្ជាចាប់នាងសុវណ្ណមសាមកកាត់ក្បាលសងសឹកវិញ ចោលទៅតើត
ជាភ្នំមួយ ហៅ ភ្នំសងក្បាល នៅដិតស្រុកមង្គលបុរីសព្វថ្ងៃនេះ ប៉ុន្តែ

ពាក្យអ្នកស្រុកហៅភ្នាយទៅជា ភ្នំសង្កែក្បាង ទៅវិញ ។ មានវាលមួយ
នៅជិតភ្នំនោះ សព្វថ្ងៃហៅ វាលបិណ្ឌោះពោះ ព្រោះតួកសេនាចំញ្ជាំ
ពោះរៀនខាងចោលនៅទីនោះ; ឯរយានីរបស់ខាង សេនាបានអាត្រែវែង
ចោលទៅកើតជាភ្នំមួយទៀត ហៅ ភ្នំក្រពាយនាង ហៅភ្នាយ ។ មក
ទៀតទៅជា ភ្នំបន្ទាយនាង ។

ចំណែកព្រះបាទកដកុល នឹងព្រះអគ្គមហេសីយាងចូលទៅថ្វាយ
បង្គំព្រះវរកដមាតាបិតាវិញ ក៏យាងទ្រង់គង់នៅជាសុខសាន្តរៀងមក
ដរាបទៅ ។

រឿងភ្នំភ្នាយនឹងភ្នំកូន

បើគាលណាគេធ្វើដំណើរតាំ "ចាន់មីជួត" ទៅ "និនហ្វា" គេនឹងឃើញរូបភាពថ្មកងជាមនុស្សពីរកូននៅលើកំពូលភ្នំមួយ ដែលយួនហៅថា "ភ្នំភ្នាយពីរកូន" ។

ភ្នំនេះមានរឿងព្រៃងដំណាលថា កាលនោះមានបុរសក្មេងម្នាក់អាយុ
ប្រមាណជា ១៧ ឆ្នាំ គំរប់នឹងឆ្នាំថ្មី ។ បុរសនេះចេះតែមានចិត្តចង់ចាន
ប្រពន្ធ ការតែក្តីនេះក៏កាន់តែជុះថ្ងៅសឡើងមួយថ្ងៃបន្តិច ។ ពាល់តែបុរស
នោះគ្មាត់ចាន ក៏រកហោរម្នាក់ដែលជំនាញឲ្យមកទាយរកគូព្រែងឲ្យ ។

កាលពីបុរាណ គ្រូហោរច្រើនតែចេះការឲ្យ ហើយជាអ្នកគណិត-
សាស្ត្រផងដើម្បីនឹងគន់គូរមើលពេលវេលាទៅអនាគត ។ លុះគន់គូរទៅ
ឃើញការចំណែកក្នុងអនាគតនៃបុរសក្មេងនេះ ហោរក៏ស្មានថាខ្លួនច្រឡំ

លេខ ឬកំពូនមានស្មារតីរីករលាចវិត តាត់មិនព្រមឆាយឲ្យបុរសនោះសោះ តែដោយបុរសនោះបង្ខិំពេក តាត់ក៏ច្រាប់ថា "ទុកូនអើយ! ទំនាយគេខ្ពង់នេះដូចជាផ្លែកណាស់ លេខឆ្លើយថាតូព្រៃងអ្នក តឹប្អូនស្រីអ្នកនេះឯង ហើយអ្នកនឹងបានត្រែបន្ទូរសេចក្តីស្នេហាមួយយ៉ាងធំបំផុត" ។

លុះបានស្តាប់សំដីហោរាសាណា បុរសឆ្លើយទៅវិញថា ៖ "ខ្ញុំមិនជឿទេ, ប៉ុន្តែចិត្តខ្ញុំត្រែវការស្នេហានឹងអ្នកដទៃត្រែវិញ" ថាតែប៉ុណ្ណោះ បុរសក៏រត់ចេញពីមុខហោរទៅ ទឹកក្តៅចិត្តថា ចុះហោរចំកួតនេះនិយាយអ្វីដូច្នេះ ។ លុះដល់ទៅផ្ទះឃើញមុខប្អូនស្រី, បុរសចេះតែមួម៉ៅក្តៅត្រែហាយ ។ ច្រាំឆ្នាំត្រែយមកឥពុកម្តាយ ក៏ស្លាប់ចោលអស់ បុរសកំព្រានៅជាមួយប្អូនស្រី រកបានព្រែកខ្វះល្ងាច រងទុក្ខវេទនាជាមួយគ្នាជាអនេក ។ ប៉ុន្តែកាលណាបុរសនឹកដល់ពាក្យហោរាយ ក៏តែងចិត្តស្អប់ខ្ពើមប្អូនស្រីរៃត្រែពេក ។

ថ្ងៃមួយ ដោយមានមានៈទឹងកសនារបស់ខ្លួន បុរសពុំចង់ទុកឲ្យការអាក្រែក់នេះបានសម្រែច ។ គិតហើយប្រុសកន្ត្រាក់ពូថៅដោយដៃម្ខាង ទាញប្អូនស្រីដោយដៃម្ខាងនាំចូលទៅកន្លែងមួយជ្រៅ ។ ឯប្អូនស្រីសោតដោយពុំបានដឹងខ្លួន ស្មានថាបងធ្វើលេង ចេះតែសើចហើយបណ្តោយឲ្យបងអូសរហូតដល់កន្លែងព្រៃជ្រៅងងឹត ដែលមានពន្លឺព្រះចូលតាមតែចន្លោះស្លឹកឈើ ។ បុរសយកពូថៅសំពងក្បាលប្អូនបុង្គ ហើយដោយអំណាចកំយេនឹងប្រព្រឹត្តអំពើឃាដកម្មផង ដោយអាណិតប្អូនផង ដោយឃើញប្អូនដេកស្តូកនៅដីគ្មានស្មារតីផង បុរសតក់ស្លុតខ្លាំងណាស់ ទំស្លុះតក់

ចេញពីវៃលែងដាក់ក្រោយ គិតតែរត់ឲ្យខាងតែបានឆ្ងាយគាល់តែអស់ដើង ទៅទៀតពុំបួច ។

ក្រោយអំពីពេលអាសន្នធំនោះមក បុរសក៏បានសេចក្តីក្សេមក្សាន្ត ហាក់ដូចជាបានបំរះរួចអំពីចំណងអ្វីមួយ ឬដូចជាបានដោះស្រាយបញ្ហាមួយដែលមានន័យដល់ទៅពីរ ឬថាដូចជារត់រួចអំពីចំណោមមនុស្សដែលមានចិត្តសាវកន្ទ្រើស ។ ពីរបីឆ្នាំក្រោយមក បុរសក៏រៀបការនឹងស្រីម្នាក់ដែលខ្លួនពេញចិត្ត នាងនោះមានពងពាក់ពួច ទឹកដមក្អែកនាងធ្វើឲ្យគេសំគាល់បានថា នាងជាមនុស្សស្លូតត្រង់ គ្មានពុតអាក្រក់ ។ បុរសនឹកថា " តែប៉ុណ្ណោះហើយអញឆ្ងាយពីពាក្យហោរាយថ្កាកដ " ។

បុរសនឹងប្រពន្ធស្រឡាញ់គ្នាណាស់ ប្រពន្ធយល់អធ្យាស្រ័យប្តី ។ យកអាសរប្រពន្ធ មិនដែលមានរឿងកកស្អុកអ្វីឡើយ ។ លុះដល់បុរសមានកូន ហើយកូននោះចេះដើរចេះស្តី ក្នុងគ្រួសារបុរសក៏កាន់តែមានការសប្បាយច្រើនឡើងទៀត ។ ប្រពន្ធនៅតែជួរមើលថែទាំធ្វើអ្វីៗ កុំឲ្យតែប្តីខាស់ចិត្ត ឯប្តីទៀតសោត តែកាលណាធ្វើការងារហើយ ចូលចិត្តមកលបបញ្ជាក់ប្រពន្ធលេង ថ្ងៃមួយនាងព្រពន្ធស្រាយក្នងសក់លាងសំអាតសក់ ហើយដោយសក់នៅទទឹក នាងក៏មិនប្រញាប់ទំនឹងបួងសក់ទៅវិញ ពុតសំដៅឲ្យសក់ស្ងួតសិន ។ នៅពេលនោះបុរសប្តីត្រឡប់មកផ្ទះវិញ ហើយអង្គុយលេងទំនឹងប្រពន្ធ ។ ជារទេសកាលអ្វីក៏នាំចិត្តនាងឲ្យប្រញាប់ប្រមូលសក់ឡើងបួង លើកឆុតអំពីកញ្ចឹងក ។ ប្តីក្រឡេកក្អែកទៅឃើញស្នាមនៅក្បាលខាងក្រោយ ស្រាប់តែដូចជាមាន


ខ្យល់កំបុតត្បូងកំណាចមួយមកគ្រប់បុរសស្មើតែបាត់ស្មារតី អ្នកនឹកឃើញប្អូនដែលអ្នកបានចង់សម្លាប់ បុរសសុះខ្យល់ចាប់ដៃប្រពន្ធស្ទុះចាំងញ័រចម្រៃបបាយ "អ្នកណាធ្វើឲ្យអូនមានស្នាមត្រង់ហ្នឹង?" ប្រពន្ធដោយតុំបានដឹងរឿងអ្វី ក៏និយាយរឿងភ័ន្តវិដែលនាងចាំស្រេចស្រួលប្រាប់ប្តីថា: "នៅពេលដែលនាងត្រូវបួសសន្ទប់ ពួកចោរបានរើសនាងទៅ ហើយយកទៅលក់ឲ្យគេ ដល់នាងធំដឹងក្តីកាលណាទៀត នាងនៅតែនឹកខ្លឹងនឹងបង ដោយនាងមិនយល់ថាហេតុអ្វីបានជាចង់សម្លាប់នាងដូច្នេះ" ។

ចំណែកបុរសជាប្តី ដែលខ្លួលសំដីនាងមួយម៉ាត់ៗ ដូចជាខ្លួលមុខកាំបិត ទោះជាអ្នកខំប្រឹងនឹងសេចក្តីពិតយ៉ាងណា ក៏អ្នកនៅតែមានចិត្តតក់ស្លុត ព្រមទាំងឃើញរាល់សនាដែលអ្នកដៀសពុំរួចមកតាមទាន់អ្នកវង្វេងស្មារតីដូចជាមនុស្សស្រវឹង តែអ្នកខំខប់ចិត្តមិនធ្វើឲ្យប្រពន្ធដឹងហើយក៏ដើរចេញពីផ្ទះទៅទាំងក្រៀមក្រំ ដូចជាមនុស្សកែលចរិត ។

លុះព្រលប់ប្រពន្ធចាំប្តីបាត់ទៅ។ មិនឃើញត្រឡប់មកផ្ទះវិញ នាងពក្សូនដើរតាមរកប្តី នាងឡើងទៅអង្គុយលើភ្នំមើលទៅឆ្ងាយគ្រប់ទិសឃើញប្តី តែមួយថ្ងៃជាមួយថ្ងៃ នាងចាំបាត់។ ពាលែតរូបនាងនឹងក្លូនក្លាយទៅជាថ្មទៅលើភ្នំនោះ, អ្នកស្រុកទើបហៅភ្នំនោះថា "ភ្នំម្ដាយនឹងកូន" ។

ឧកញ៉ាវិបុលរាជសេនា ន្ធូ-កន ប្រែរៀបរៀង

(តមក)



ស៊ីឡុងធ្វើយទូលថា ខ្ញុំបាទនឹងសុំយកអាសា ទៅចាប់ខ្លួនជាន់លៀងមកឲ្យបាន ។ ចូឆូក៏ប្រគល់ទាហានឲ្យស៊ីឡុងលើកចេញទៅ តតាំងចាំជាន់នឹងជាន់លៀងបាន ២០ ភ្លេត ស៊ីឡុងធនកម្លាំងនឹងជាន់លៀងមិនបានក៏ថយត្រឡប់មកចូលបន្ទាយវិញ ។ បណ្តាទាហានយើញដូច្នោះក៏តូចចិត្តគ្រប់គ្នា ទូលពេលព្រលប់យប់ឯនឹតខ័ពពាំងសងខាងក៏ប្រុងរក្សាបន្ទាយរៀងខ្លួន ។ ចូឆូប្រឹក្សានឹងសេនាទាហានពាំងពួនថាខ្លួនណានឹងអាចតទល់កម្លាំងនឹងជាន់លៀងបាន ។ ស៊ីឡុងថាខ្ញុំបាទយល់យើញតែគួនអ៊ូ ១ មានកម្លាំងខ្លាំងពូកែអាចតចាំងនឹងជាន់លៀងបាន ។ ចូឆូថាបើយើងនឹងឲ្យទៅហៅគួនអ៊ូមកធ្វើការគ្រានេះ បើគួនអ៊ូចាំងមានជ័យក៏នឹងដោះដៃទៅពីយើងជាអសារ ។ ស៊ីឡុងធ្វើយថា ខ្ញុំបាទយល់យើញ

ថាឡៅពីទៅអស្រ័យទៅនឹងអ្នកនៅ ដើម្បីនឹងឲ្យបានសេចក្តីសម្រាប់សេនាគាហានអ្នកនៅម្នាក់នេះបាន អ្នកនៅដឹងក៏នឹងសម្រាប់ឡៅពីជាប្រាកដ បើឡៅពីអស់ជីវិតកាលណា គួនអ៊ូក៏អស់ប្រាថ្នានឹងទៅវត មុខជាបានមកផ្ទើកម្ចាំងៈនាងនឹងយើងតទៅ ។ ឫដូចយល់ឃើញគ្រកំរៃគាហានទៅហៅគួនអ៊ូជាប្រញាប់ គាហានក៏ចូលទៅប្រាប់គួនអ៊ូថា មហាឧបរាជឲ្យអញ្ជើញលោកទៅឯតង់ខ័ត ។ គួនអ៊ូបានស្តាប់ក៏រៀបខ្លួនចូលទៅដល់មាត់ទ្វារតំនាប់បង់ថ្ងៃតាំង ២ ថា ឥឡូវមហាឧបរាជឲ្យមកហៅឲ្យទៅធ្វើការសឹកសង្គ្រាម ។ បង់ថ្ងៃតាំង ២ ក៏ធ្វើយតបភ្លាមថា ប្អូនទៅធ្វើការឲ្យមានជ័យជំនះឈ្នះសត្រូវចុះ តែឲ្យទំស្តាប់ដំណឹងជាបង់ប្រុសអ្នកនៅឯណា ។ គួនអ៊ូក៏តំនាប់លាបង់ថ្ងៃចេញមក យកសេះសឹកថាវាជាដំនិះ គួនអ៊ូក៏ឡើងជិះកាន់ដាវនាំគាហានប្រមែល ១០ នាក់ចេញមកគ្រា បរស្រួតទៅដល់បន្ទាយចូលួ ។ គ្រឡែកឃើញគួនអ៊ូទៅដល់ ក៏មានសេចក្តីត្រេកអរណាស់និយាយថា ងាន់លៀងសេនាអ្នកនៅមានថ្វីដៃខ្លាំងពូកែ សម្រាប់សុង់ហៀនទឹងឆុយសុកស្ងាប់ទៅហើយ យើងនៅទើបឲ្យទៅកអ្នកប្រាថ្នាដើម្បីនឹងឲ្យជួយលៃលកចូលចប្បាំងទឹងងាន់លៀងសង់សឹកវិញ ។ គួនអ៊ូធ្វើយថា ខ្ញុំបាទនឹងសុំចេញទៅមើលកលការសិន ។ ចូលួក៏នាំគួនអ៊ូឡើងទៅលើកុំ ខ្លួនគ្រឡែកឃើញងាន់លៀងលើកគាហានចេញមកជិតមុខបន្ទាយ ចូលួក៏និយាយប្រាប់គួនអ៊ូថា អ្នកមើលទៅចុះ ដែលជិះសេះចាំង៉ត្រែវគាយានោះឈ្មោះងាន់លៀងជានាយគាហានខ័ពមុខ ។ គួនអ៊ូថា ងាន់លៀងនោះខ្ញុំបាទនឹងតស៊ូបាន លោកកុំតែក្តៅឡើយ

ខ្ញុំបាទនឹងទៅកាត់ក្បាលជាន់លៀងយកមកជូនលោកឲ្យបាន ។ ចូតូ
ក៏និយាយទៅគួនអ៊ូថា អ្នកកុំអាលប្រមាទមើលងាយជាន់លៀងនោះ
ឡើយ ។ គួនអ៊ូថាខ្ញុំបាទក៏មានថ្វីដៃខ្លះដែរ បានជាហ៊ានសុំយកអាសា
ទៅកាត់ក្បាលជាន់លៀងមកជូនលោក ព្រោះឃើញថាមិនជាការក្រ
លំបាកប៉ុន្មាន ។បមាដូចយកចង្កឹះចាប់ដុំសាច់បរិភោគ ។

តៀវលៀវបានស្តាប់ពាក្យនិយាយតបទៅគួនអ៊ូថា ឯធម្មតាការសឹក
សង្គ្រាមនោះ បើនឹងនិយាយការអ្វីដល់មេទ័ពមេកង ចូរប្រមាណការ
នោះឲ្យខ្មៀងពាត់ប្រាកដសិនសឹមនិយាយ ។ គួនអ៊ូថា "អ្នកកុំព្រួយ
រំលឹកខ្ញុំឡើយ" ហើយក៏លាចូតូឡើងសេះបំផាយពុះពាហានជាន់លៀង
ចូលទៅ, ឯពាហានជាន់លៀងមិនទាន់ដឹងខ្លួន លុះឃើញគួនអ៊ូបំផាយ
សេះទំលុះចូលមក ក៏ភ័យតក់ស្លុតពាំងអស់គ្នាទាំងគ្នាស្ទុះរត់ខ្ចាត់ខ្ចាយចេញ
ទៅជាច្រើន ។ គួនអ៊ូក៏បរសេះបំផាយចូលទៅដោយកំឡាំងដ៏រហ័ស
ដូចនឹងបរទំគិចនឹងសេះជាន់លៀង។ ក្រឡេកឃើញសេនាមុខក្រហមប្លែក
ពុសពីពាហានធម្មតា, ក៏សំគាល់ថាប្រហែលគួនអ៊ូប្អូនទៀតពី ហៀប
នឹងហាមាត់ប្រាប់ដំណឹងពីទៀតពីតែប្រាប់មិនទាន់ ទ្រុលគួនអ៊ូលើកដាវ
ឡើងកាប់ក្បាលជាន់លៀងជាប់ដៃដួលក្ងាក់ទៅដី ។ ពាហានចូតូឃើញដូច្នោះ
ក៏ស្ទុះស្រែចូលទៅសំដៅកាប់ចាក់ ពាហានជាន់លៀងស្ទាប់ពាក្យជាច្រើន
ហើយរើសយកគ្រឿងសស្ត្រាវុធបានជាច្រើន ។ គួនអ៊ូក៏លើកយក
ក្បាលជាន់លៀងយួរចូលទៅជូនចូតូតែងបន្ទាយ ចូតូក្រឡេកឃើញទ្រុល

អំណរណាស់ សរសើរគួនអ៊ូថា ខ្លួនអ្នកនេះមិនមែនមាហានមនុស្សធម្មតា ដែលមានថ្លើដែរហ៊ាសដូច្នេះ សមជាមាហានទេពតា ។

គួនអ៊ីវចូតូថាដូច្នោះ កំភ្លែងបន្តោកខ្លួនថាថ្លើដែខ្ញុំបានប៉ុណ្ណេះគ្រាន់តែជាប្រមាណ ប្អូនខ្ញុំឈ្មោះតៀវហ៊ុយមានកំឡាំងថ្លើដែខ្លាំងពូកែលើសខ្ញុំបានទៅទៀត ខោះមាហានប៉ុន្មានរយម៉ឺនការពារនាយទ័ពដួចម្តេចក្តី តៀវហ៊ុយក៏អាចទំលុះពុះពារទៅកាត់ក្បាលយកមកបានដោយរហ័ស ឧបមាដូចគេចាប់យកកន្លែកួចនៅក្នុងឡាំង ។

ចូតូបានឮដូច្នោះក៏គិតញញើតខ្លាចថ្លើដែតៀវហ៊ុយ ទើបបង្គាប់ពួកមាហានឲ្យសរសេរអក្សរទុកក្នុងអាវគ្រប់គ្នាថា បើនរណាជួបប្រទះនឹងតៀវហ៊ុយក៏កុំអាលតស៊ូឲ្យវង់ស្តាប់កំឡាំងមើលសិន ។

ឯមាហានដាន់លៀង ក៏បែកខ្លាត់ខ្លាយរត់ទៅដល់កងទ័ពអ៊ូនសៀវ ហើយចូលទៅអធិប្បាយរឿងក៉ាវឲ្យអ្នួនសៀវស្តាប់គ្រប់ប្រការ, អ៊ូនសៀវបានឮដូច្នោះក៏ភ័យស្លុតចិត្ត ហើយគិតពិភាល់ថា ពីដើមមកមិនបានជ្រាបជាមាហានចូតូមុខក្រហមពុកមាត់វែង មានកំឡាំងខ្លាំងពូកែដូច្នេះសោះ ។ ឈើស៊ីវថាមាហានមុខក្រហមពុកមាត់វែងនោះ ខ្ញុំបានស្មានថា ជ្រាកជាគួនអ៊ីវអ្វីនេះឯង ឯអ្នកជាខែកមិនបានស្គាល់ជាជ្រាកជ ។ អ៊ូនសៀវបានស្តាប់ក៏ខឹងណាស់ និយាយជ្រាប់ឡៃព័ថា "ប្អូនអ្នកឯងចូលទៅធ្វើសេនាចូតូ ហើយមកសម្លាប់សេនាឯករបស់យើងស្លាប់ដូច្នេះ កំយើញថាអ្នកឯងជាពួកម៉ាកខាងចូតូ ក្លែងមកនៅទីឯយើងជាកលសឹក

យើងនឹងចិញ្ចឹមខុកក៏មិនបាន" អ្នកនេសាក៏បង្គាប់ភាហានឲ្យចាប់ខ្លៅពីនឹងយកទៅសម្លាប់ ។

ខ្លៅពីបានឮដូច្នោះក៏ភ័យណាស់ និយាយទៅអ្នកនេសាវិញថា ហេតុម្តេចលោកមកស្រាលតែចៀកស្តាប់តែពាក្យម្នាងដូច្នេះ សុំឲ្យលោកដាក់ម៉ែលឲ្យគួរសិន ខ្ញុំនឹងបង់ស្រុកទេសនឹងនិកសាកបុត្រកពោនូវអស់ស្ន្តែចក្បាលក្បាលតែបួលមកជ្រកកោននៅនឹងលោកតែខ្លួន១ ដោយហេតុបួនួលើកទ័ពមកធ្វើអន្តរាយ គួនអ្នកតែហ៊ុយបួនខ្ញុំបានតាំង ២ កាយ កំភ្លាត់ភ្លាយព្រាត់គ្នាទៅមិនដឹងជារស់ឬស្លាប់ សាបសូន្យដំណឹងសោះ, ដែលថាភាហានមុខក្រហមពុកមាត់វែងនោះ នឹងចំពោះមានតែគួនអ្នក ១ ក៏ខេតដ៏មានរូបអ្នកឯទៀតទៅខ្លះដែរ លោកបួរពិគ្រោះពិចារណាឲ្យធួនថៃទៅសិន ។

អ្នកនេសាវិនោះជាមនុស្សមិនមានចារកម៉ាំមួន លុះបានស្តាប់សំដីខ្លៅពីអធិប្បាយក៏រសាយកំហឹង តែឲ្យប់ក្រែងខឹងនឹងឈើសីវិញថា "ខ្ញុំជាមនុស្សកំប្សតក្រាជ្ញា កែងមកបរាញ៉ុះញ្ជាន់ឲ្យយើងសម្លាប់ខ្លៅពីដូច្នេះមិនគួរសោះ" ថាហើយក៏ក្រែករៀង ហៅខ្លៅពីទៅបរិភោគអាហារ ពិគ្រោះគ្នានឹងលើកទ័ពទៅកំចាត់បួនួ ។

ប៊ុនធីវែងក៏បអ្នកនេសាវិថា សេនាបួនួដែលសម្លាប់ឆាន់លៀងនោះ ខ្ញុំបាននឹងសុំយកអសាចេញទៅបង្ហាងនឹងបួនួនឯទៀត ។ អ្នកនេសាវិឮហើយក៏ធ្វើយទទួល ព្រោះឃើញប៊ុនធីវមានកម្លាំងច្រើនខ្លាំង ៦ ហត្ថ មុខភ្លៅដូចសម្បុរខ្មាឃ្មុំ ចាំងមានថ្លើដៃខ្លាំងពូកែសមគួរនឹងតតាំងបង្ហាងនឹង

សេនាបួនគូបាន ដើមមានភ្ញាក់ថា "អ្នកទាំងនេះលួចយកអាសាចេញទៅគ្រានេះ យើងមានសេចក្តីត្រេកអរណាស់" ហើយអ្នកនៅវត្តក៏ប្រគល់ថាហានឲ្យប៊ុនធីវ ១០ ម៉ឺន ចាត់សុខតែពួកចំបាំងឲ្យប៊ុនធីវលើកតួងនេះហងហោតស្ងើចចិត្តបួន ។

ឈើស៊ីវដំណាងអ្នកនៅថា បួនគូនោះជាមនុស្សចេះគិតល្អិតល្អណាស់ មានដំណើរដំនះដូច្នេះហើយក៏មានចិត្តគំរើប ដែលលោកគិតស្រាលឲ្យប៊ុនធីវលើកតួងនេះទៅនោះ ខ្លាចបួនគូដឹងលើកថាហានមកចាំស្កាត់ក្រយក្រោយក្តាលទ្លូវ ក៏ទំនងត្រូវច្បាំងការអស្ចារ្យទេ ។ អ្នកនៅវត្តហើយទាំងណាស់ គំហកដៅឈើស៊ីវថា អាមនុស្សកំណេរអ័ប្បវតគ្រាជា ឯតិតការឲ្យតែយើងបង្ក្រាត ។ ឈើស៊ីវមិនចាន់ធ្វើយទៀតថាម្តេច គេចក្រោកដើរទៅខាងក្រៅហើយក៏ដកដង្ហើមធំ និយាយកណ្តាលទីប្រជុំថាហានថា អ្នកចាំងឡាយជានាយទំពនាយកងរាល់គ្នា មើនាយទៅហ្វាយយើងគិតការចាន់សម្រេច យើងចាំងឡាយក៏ចាន់រួចពីសេចក្តីស្លាប់ មើទៅហ្វាយនាយយើងមិនត្រមស្តាប់ទីប្រឹក្សា ធ្វើការប្រមាថមើលងាយដល់បួនគូដូច្នេះ យើងក៏យល់ថាគង់ទំនងច្បាំងការ នរណា ។ ដួយរំលឹកពន្យល់ក៏ចេះដឿ ប្តេជ្ញាប់ អ្នកចាំងឡាយទាំងយកសាកអស្ចារ្យមកចោលទុកនៅទីនេះជាច្រកដហើយ ។ តាំងពីថ្ងៃនោះមកឈើស៊ីវក៏ធ្វើជាឈឺមិនចាន់ទៅមករកអ្នកនៅវដ្តយប្រឹក្សាពិគ្រោះសោះ ។ ក្នុងខណៈនោះ អ្នកនៅវក៏ចង្អុលចាត់ចែងឲ្យប៊ុនធីវលើកទ័ពទៅ ។

ខ្លះពីក៏និយាយទាំងអ្នកនៅថា ខ្ញុំមកទៅជ្រកកោនទាំងលោកក៏ចាន

សេចក្តីសុខ លោកមានគុណូបការធំធ្ងំជាច្រើន ឥឡូវខ្ញុំសុំយកអាសាទៅជាមួយនឹងប៊ុនធីវ ដើម្បីជាឥតបស្នងសងគុណលោក ប្រការ១ នឹងបានស៊ើបមើលឲ្យដឹងឃើញថា តាហានមុខក្រហមពុកមាត់វែងនោះ ប្រាកដជាគួនអ៊ូ ឬ អ្នកឯណាឯទៀតទេ ។ អ្នកសៀវបានស្តាប់ដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់ និយាយនឹងប៊ុនធីវថា ឡៅពីជាមនុស្សមានសតិបញ្ញា យើងនឹងឲ្យចេញទៅជាមួយនឹងអ្នក ដើម្បីនឹងបានជួយគ្នាគិតការធ្វើសង្គ្រាមតនឹងបួច ។ ប៊ុនធីវតបថា ឡៅពីជាមនុស្សមានដំរេះគ្រប់មែនហើយ តែនៅខ្លាចថ្លើដែបួច ដែលលោកនឹងឲ្យឡៅពីទៅជាមួយនឹងខ្ញុំនោះ ខ្ញុំនឹងបែងរំលែកតាហាន ៣ ម៉ឺនឲ្យឡៅពីលើកទៅជាកងមួយផ្សេង ។ អ្នកសៀវយល់ឃើញត្រូវក៏ប្រគល់តាហាន ៣ ម៉ឺនឲ្យឡៅពីលើកចេញទៅជាកងក្រោយ ។ លុះបានឫក្សជោគល្អ ប៊ុនធីវក៏លាអ្នកសៀវលើកទ័ពចេញទៅជាកងមុខ ធ្វើដំណើរហានហោទៅ, តែឡៅពីចេញចាកទីនៅមិនទាន់ធ្វើដំណើរ ។

ខណៈកាលបួចមានជ័យជំនះនោះ ក៏មានចិត្តត្រេកអរសប្បាយតែងបុតហ្មាយស្តីគុណចំណាប់របស់គួនអ៊ូ បួលទៅគ្រាបទូលព្រះចៅហៀនតេ។ ឲ្យដឹងជាបសេចក្តីក៏មានព្រះទ័យសោមនស្សពន់ប្រមាណ ទើបឲ្យដឹងព្រះកឋាននាគ្រាសម្រាប់ងារ តាំងគួនអ៊ូជា ហាក់ស៊ីតែងហៅ តីមន្ត្រីមានយសខ្ពស់ធំក្នុងព្រះចៅហៀនតេ, បំរើក៏ទទួលយកគ្រាតាំងនោះទៅប្រគល់ឲ្យគួនអ៊ូ។ ទទួលបំរើសេះបួលមកប្រាប់បួចថា ឥឡូវអ្នកសៀវប្រើប៊ុនធីវឲ្យលើកតាហានមកប្រហែល ១០ ម៉ឺនធ្វើដំណើរហានហោ ។ (មានត)

លោក ផេង-ជ្រៃ សាស្ត្រាចារ្យនៅសាលាគរុជ្ជាភ្នំពេញ

ប្រែពីភាសាចាវ៉ាំងមកជាភាសាខ្មែរ

(តមក)

អ៊ីស្មាអ៊ីលធ្វើយថា:

– ព្រះតេជៈគុណវរសេនីយ៍ឯក! ខ្ញុំបាទបានដឹងតែមួយយ៉ាង អំពីបទពាណិជ្ជកម្មប៉ុណ្ណោះ គឺថាជាតិអឺរ៉ុបចេះរៀបចំ ហើយប្រសប់ជាងយើងជាតិអាហ្វ្រិកខ្លាំងណាស់ ។ សូមព្រះតេជៈព្រះគុណពិចារណាមើលនូវការអន្តរាយក្នុងផ្លូវគមនាគមន៍របស់យើងដែលមានពួកវិលុម្បក: ពួនស្កាត់ចាំប្លន់ពួកឈ្មួញជានិច្ច ។ នៅបណ្តាពួកមេឈ្មួញទាំងនោះ បច្ចុប្បន្នតែរបស់យើងតែងនឹងមានអ្នកបន្តនិយាយការណ៍ ដែលធ្លាប់ប្រសប់មានការទាក់ទងនឹងជាតិអឺរ៉ុប ហើយមានគំនិតច្បាស់ជាងអ្នកនៅភូមិ នឹងពួកបរទេសទៀត ។

« ផ្លូវណាដែលគ្មានវិលុម្បកកម្ម ហើយដំរីក៏មានជាប់បន្តគ្នាដើរកាន់តែលឿនដែរ ។ ការជំនួលផលិតផល អីវ៉ាន់របស់ជាតិអឺរ៉ុប នឹងការទិញដូរទំនិញអ្នកស្រុកអាយក៏នឹងមិនសូវយូរដូចសព្វថ្ងៃនេះ ត្រូវគិតទុកបីឆ្នាំមុនឱ្យហើយជាស្រេច រាងការធ្វើដំណើរតាមប៊ូលីនឹងការត្រឡប់មកវិញរបស់មេឈ្មួញម្នាក់ ។

លោកវរសេនីយ៍ឯក ទ្រង់គិតយូរ ។ រីឯខាងពាណិជ្ជកម្ម លោក

មិនចេះសោះ ។ លោកចេញមកពីសាលានាយខាហានជាន់ចាស់ដែលមានការបង្ហាត់តែអំពីកិច្ចសង្គ្រាម ជាការតយុទ្ធត្រូវមានជាវយ៉ាងមុត ត្រូវបណ្តើរទ័ពឬត្រូវពាក់ស្រោមដៃឲ្យស្អាត ដើរពីមុខកងអនុសេនាធំ ។ លោកនេះមិនយល់អំពីសង្គ្រាមឥឡូវ គឺសង្គ្រាមខាងសេដ្ឋកិច្ចខ្លាំងជាងសង្គ្រាមនៅឯសមរភូមិ ។

ប្រាកដមែនហើយលោកអនុសេនីយ៍ឯកនេះផ្ទាស់យោបល់ចាំងអស់ដោយកាន់តែទំនើបថ្មី ។ មិនបាច់សង្ស័យឡើយ គឺប្រាកដជាមនុស្សក្បាលអាក្រក់ ។ លោកវរសេនីយ៍ឯកតាំងចាប់ផ្តើការយល់ហើយនិយាយថា:

– អើ! មែនហើយ អ៊ីរ៉ុប!... អាវ្យធម៌... លោកចូលចិត្តខាងណោះជាងអាណាចក្រតួគី... យើងមិនគាប់ចិត្ត ដោយថាខាងនាយខាហានបែបលោកនេះទេ!

កងទ័ពសោះ លោកវរសេនីយ៍ឯក ចាប់តាំងពីតស្វាសម្រាប់កាត់ក្រដាសបង្ហិលសេងចុះឡើង ហើយហាក់ដូចជាបញ្ជូនចិត្តទៅកាន់អារម្មណ៍ផ្សេងពីការសន្ទនាជាមួយនឹងអ៊ីស្មាអ៊ីល រួចស្រាប់តែបែរជាំងចំពោះអ្នកកំណើរហើយសួរយ៉ាងខ្លីថា:

– ហេតុអីបានជាលោកសម្លាប់រស្មីមេបន - អាប់ជាឡៃ នៅសម័យដែលគេប្រឆាំងនឹងធ្វើប្រតិបត្តិការតទល់នឹងពួកខ្ញុំលោ?

អ៊ីស្មាអ៊ីលសំឡឹងចំលោកវរសេនីយ៍ឯកគ្មានព្រិចភ្នែកតែឥតមានឆ្លើយ។

លោកមេទ័ពសួរទៀតថា:

– លោកមិនត្រូវយករឿងស្រីមកអាងដូចគេថាឡើយ ។

លោកមេទ័ពមានសេចក្តីសង្ឃឹមថា មុខជានឹងបានចម្លើយមួយមិនខាន អំពីអ៊ីស្មាអ៊ីល ទោះបីជាថាខេឫទ្ធលព្រម ចំដ្បិតតែចិត្តលោកបើងរំងូសគាចអាក្រក់ ក៏លោកនៅមានសេចក្តីគោរពចំពោះការក្លាហានដែរ លោកឃើញគំរោងបេះនាយតាហានតំឡោះ បរិបូណ៌ដោយការរឹងត្អឹងឥតញាប់ញ័រ ដោយសេចក្តីវិសារៈឥតខ្ចត់ អាការទាំងនេះមិនមែនជាមិនធ្វើឲ្យលោកមេទ័ពរំជួលឡើយ ។ លោកមានចំណងនឹងចង់ជួយសង្គ្រោះអ៊ីស្មាអ៊ីលដែរ ប៉ុន្តែរហស្សភាពនៃអ៊ីស្មាអ៊ីលនាំឲ្យលោកអនុ-សេនីយ៍ឯកមានគោរៈ ។

ឥឡូវបើអ៊ីស្មាអ៊ីលមិនព្រមធ្វើយទទួលសារភាពថា មរណភាពនៃរស្មីម គឺជាមូលហេតុមកពីការប្រជែងប្រឆាំងគ្នាបែកខាងកាមភគខ្លះទៀតមានមូលហេតុដទៃធ្វើឲ្យដៃគេកាន់អាវុធលើកឡើង ហើយការណ៍នេះងាយយល់ពេក គឺគ្មានអ្វីត្រៃពីរឿងនយោបាយឡើយ ។

អ៊ីស្មាអ៊ីលសម្លាប់រស្មីម ដើម្បីបំបាត់ការជំនួយដ៏ថ្លៃថ្លារបស់ជាតិតួរគី ។

រឿងនេះជាឧក្រិដ្ឋទោសយ៉ាងធ្ងន់ហួសព្រំដែនទាំងឡាយនៃមនុស្សធាតធម្មតា គេត្រូវទៅធ្វើយនៅចំពោះមុខតុលាការសង្គ្រាម ។

លោកមេទ័ពដ៏ឆ្លាស់ដោយការពិសោធន៍ថា ជាធម្មតា ការឃុំរបស់តុលាការសង្គ្រាមឥតមានមេត្តាករុណាឡើយ ហើយច្រើនតែមិនចាប់ហៅអ្នកទោសមកសួរផង ។

លោកមេទ័ពដកដង្ហើមធំ ហើយនិយាយថា:

អី លោកចេះតែចូលចិត្តនៅស្ងៀម . . . ការកុហករបស់លោក ឈ្មោះថា ការប្រមាថមើលងាយដល់ព្រះអាឡស់ . . . ។

ឥឡូវនេះ នៅចំពោះមុខនៃរាជសភាឥតកំណែរបស់អ៊ីស្មាអ៊ីល, លោកមេទ័ពឈប់សង្ស័យតទៅទៀត គឺកូនប្រុសនៃលោកតាកាំជ្រុងជាមានទោសខាងបទឧយោជ្ឈាយ ។ បើដូច្នេះ មិនត្រូវមានចិត្តអាណិតដល់អ្នកទោសឡើយ ។ ប៉ុន្តែ លោកអនុសេនីយ៍ឯកនៅតែធ្វើយ៉ាងព្រងើយ យ៉ាងរឹងត្អឹង ឥតខ្ចីត ។ គឺមិនមែនជាមិនស្គាយទេ ដែលលោកវរសេនីយ៍ឯកស្រែកហៅនាយទាហានរង្វិលចូលមក ហើយបង្គាប់ថា:

— លោកអនុសេនីយ៍.អ៊ីស្មាអ៊ីលបេន-អៃយ៉ាជ ត្រូវការនៅកន្លែងគុកឯនឹតបន្ទប់លេខ ២ ។

នាយទាហានវរគំនាប់ ហើយចាត់ការតាមបទបញ្ជាភ្លាម ។ មនុស្សប្លន់នាក់ ជាវរនៅពុងកាំភ្លើងមកដល់មួយរំពេច ។ គេនាំគ្នាឈរព័ទ្ធអ៊ីស្មាអ៊ីល ហើយតាមការបង្គាប់នៃនាយទាហានវរ គេបណ្តើរអនុសេនីយឯកជាបុត្រលោកតាអៃយ៉ាជសំដៅទៅគុកកន្លែងបន្ទាយ ។ ទ្វារគុកលេខ ២ បិទទៅវិញសូរគ្រាំង រក្សាទុកនូវគួរសង្ស័យរបស់នាងឡីឡានៅខាងក្នុង ។

បន្ទប់គុកលេខ ២ នេះ គឺជាបន្ទប់ដែលបំរុងសម្រាប់ឃុំទុកនូវនាយទាហានណាដែលគួរសង្ស័យត្រូវជំនុំដំរះ គឺជាបន្ទប់សម្រាប់ស្ងាប់!

*

* *

តាំងពីថ្ងៃដែលនាងមានចាន់សេចក្តីសុខ ដោយចាន់ជួបនឹងអ៊ុស្មាអ៊ុល ឡើយបេះតែស្រងូតស្រងាត់រឹងរៃ ទោះបីមានការថែរក្សាដ៏សុខុមរបស់ស្ត្រីជាមិត្តចាំងឡាយក៏ដោយ ។

នៅបណ្តាក្រុមស្រីជាបរិវារចាំងនោះ គេគ្រាន់តែដឹងថា អ៊ុស្មាអ៊ុលចេញទៅធ្វើសង្គ្រាម តែប៉ុណ្ណោះទុកជាការស្រេច ។ គ្មានអ្នកណាដឹងច្បាស់នូវព្រៃងវាសនារបស់គេទេ ។ ម្ល៉ោះហើយ ការសង្កេតសង្កៃតេបេះតែលុកលុយក្នុងសន្ធានៃនាងឡើយ ។

អ៊ុស្មាអ៊ុល គឺជាគូសង្សារឯករបស់នាង នាងមានចំណងយ៉ាងធំហើយតែមួយក្នុងជីវិតនាង ។ ឥឡូវស្រាប់តែធម្មតាមកចាំបែកនាងចេញចាំងតែក្តៅស្រស់ ។

ក្នុងវេលា តាំងពីប៉ុន្មានថ្ងៃមកហើយ នាងឡើងទៅអង្គុយច្រត់ដៃលើពនាហានសង់នៅលើដំបូលផ្ទះ ហើយចក្ខុនាងសំឡឹងទៅឆ្ងាយឯណោះ ត្រង់ចាកយណ៍ខ្សាច់ដែលបងស្រីនាង ដេកសម្រាកមិនត្រៀកត្រង់ពលកន្លាះ ដែលគូសង្សារបណ្តុលចិត្តរបស់នាង នៅឆ្ងាងមុខចំពអូដ្ឋដើរឆ្លងខ្សាច់ ។

តើសង្សាររបស់នាងសុខទុក្ខដូចម្តេច?

ឬហេតុបច្ចាមិត្តចាញ់ស្លាប់ហើយទេដឹង? សេចក្តីវិចិត្តនឹងរហាសកាពនេះធ្វើឲ្យនាងរឹងរឹតតែព្រួយឡើង ។ ឈាមក្នុងបេះដូងឡើងត្រជាក់កកដូចមនុស្សស្លាប់ ។ នាងដើរចុះឡើងចាំងស្រងូត តាមច្រកក្នុងផ្ទះដើម្បីស្វែងរកមុខប្រកបដោយចេនីកមេត្រីស្នេហា ប្រកបដោយការញញឹម

ត្រជាក់ គួរឲ្យខ្ពុកចិត្តខ្ពុកថ្លើម ។ ការណ៍កំប៉ុកកំប៉ុកមួយរយៈដំពូកនៃអាជីវៈ
ពាល់ថ្ម ចេះតែបណ្តាលឲ្យញាមានខ្សឹងក្នុងចិត្ត, ការណ៍ទាំងនេះជារឿង
ឥតប្រយោជន៍សោះ ប្រសិនបើនាងមិនបានរលឹកឃើញនូវអនុស្សាវរីយ៍
ដែលជាស្នេហាលនៃគូសង្សារបស់នាង ក្នុងការដង្ហើយហៅវក ។

ក្នុងសម័យដែលវិប្បលោភខ្លុកកំពុងញាំញីចន្ទសន្តាន ដូចជាទឹក
ជ្រោះដ៏ចត់ល្វីងបាញ់ចេញពីដួងហទយៈនៃនាង ខណៈនោះនាងនឹក
ឃើញសព្វ អំពីអនុស្សាវរីយ៍ជាអនិដ្ឋារម្មណ៍ក្នុងជីវិតរបស់នាង មរណ-
ភាពនៃលោកអាពុក, ការចាកចោលកូមិកំណើត, ការរងទុក្ខវេទនាតែ
ម្នាក់ឯងរបស់បងស្រីនៅកណ្តាលព្រៃ, ម្តាយត្រូវជាប់ជាឈ្លើយឥត
ដឹងដំណឹងសោះ ។ ម្ល៉ោះហើយ ការអាសោះទេះបុកុរុកដួងព្រលឹងនៃនាង
ត្រមុំព្រហ្មចារិយ៍នេះកាន់តែខ្លាំងឡើង ។

ថ្មាកដមែនហើយ គឺនាងមានដំទៀកក្នុងយុត្តិធម៌នៃព្រះអាឡស់
ប៉ុន្តែអនិដ្ឋារម្មណ៍ទាំងនោះដូចជាធំពេក ហួសកម្លាំងរបស់នាងដែលជា
ស្ត្រីមានអាយុទើបតែម្ភៃឆ្នាំ ។ ក្នុងរវាងអាយុត្រឹមប៉ុណ្ណេះដែលដីវភាព
កំពុងប្រកបដោយសេចក្តីត្រេកអរដូចជាផ្កាកំពុងរីករាងអារម្មណ៍ គឺជារបូរ
ដែលពួកស្ត្រីត្រមុំមានការខ្នះខ្នែងត្រឹមតែធ្វើខ្លួនឲ្យសប្បាយស្រួល ខឹង
ធ្វើដូចម្តេចឲ្យតែគេស្រឡាញ់ ចំណែកឯនាងត្រូវជាប់ជាយំទាំងយប់ទាំង
ថ្ងៃ ឥតសង្ឃឹមនឹងបានប្រទះដួចនូវសេចក្តីសប្បាយនឹងសេចក្តីសុខជាថ្មី
ឡើងវិញ ។

ក្នុងពេលដែលនាងកំពុងតែស្រងូតស្រងាត់ជាធម្មតា ដូចសព្វជន

រៀងមក ទោះបីព្រះអាទិត្យរះចាំងពន្លឺច្បាស់ក៏ដោយ ទោះបីសូរសំឡេងនៃ
ចក្រីចាំងឮយ៉ាងស្រែកយំអឺងអាប់ទឹងមេឃស្រឡះក៏ដោយ វត្ថុចាំងនេះ
ដូចជាមានភាពអាក្រក់ទៅវិញ ការណាចិត្តកើតទុក្ខ ។ ស្រាប់តែ
លោកតាឈៃយ៉ាជសួរនាងថា ។ លោកតាឈៃយ៉ាជញឹម ។ យកដៃអង្អែល
សក់ខន់ល្មើយរបស់នាងហើយប្រាប់ថា:

_ ខែមីនាង មានឥដ្ឋរម្មណ៍នៅឆ៊ងចាំនាង ។

រួចលោកចាប់ដៃនាងនាំដើរសន្សឹម ។ ទៅកន្លងបន្តុបមួយធំដែល
សម្រាប់ប្រែជាបណ្ណាល័យ ។

មានស្ត្រីម្នាក់ទទួរសំពត់ខ្មៅ ឈរនៅតាមុខបង្អួចមួយ គេអាចមើល
ឃើញមុខស្រីនោះ ដោយពន្លឺចាំងតាមរន្ធតូច ។ នៃសំពត់ ។

ឡើងប្រាប់ស្រែកថា:

_ ម៉ែ!

រួចនាងក្រមុំស្ទុះទៅកន្លងដៃនៃនាងចាឌីយ៉ា ដែលយំដោយប្រទះដួង
ទឹងសេចក្តីសុខ ។

គឺជាសេចក្តីស្រណោះស្រណោកមួយស្របក់ សូម្បីលោកតាឈៃ
យ៉ាជ ដែលជាបុរសតាពូជាប់មានការតាំសោធន៍ដ៏យូរអង្វែងក្នុងជីវិតមក
ហើយក៏អាចទប់អាត្មា មិនឲ្យញាប់ញ័រដល់ដួងវិញ្ញាណបាន ។

សេចក្តីរីករាយរបស់នាងកំសត់ចាឌីយ៉ា សំដែងអាការគួរឲ្យស្ងួត
ចិត្តដល់គេឯងពិតមែន ។ នាងស្មានតាំងពីយូរណាស់មកហើយថានាង
ឡើងក៏មានវាសនាអាក្រក់ដូចជាបងស្រីកំសត់ដែរ គឺថាកូនស្រីតាំងពីរ

មុខជាស្លាប់នាកណ្តាលភ្លៀងព្រៃមិនខាន ។ លុះគិតឃើញដូច្នោះ ហើយនាងម្តាយមានសេចក្តីទុក្ខព្រួយឥនទុបមា ស្ទើរតែនឹងវង្វេងស្មារតី ។ លុះទីបំផុត មានមួយថ្ងៃ នាងបានជួបតាម៉ាត្រុក ។ បានឲ្យដំណឹងអំពីកាសនានៃនាងឡីឡា ទើបនាងចាប៉ីយ៉ាអន់ព្រួយបន្តិច ។

លុះប៉ុន្មានថ្ងៃជាមួយនឹងគ្រោះមក ពួកការត្តូរតីបានយកអង្កែតយ៉ាងតឹងតឹងរួចហើយ ។ ខ្លួលស្គាល់ថាពួកអ្នកដើរទេសក្នុងកុលសម្ព័ន្ធនៃដែលយាងីគឺសុទ្ធតែពួកអ្នកជំនួញសុចរិត ឥតលាយឡំដោយពួកអ្នកនៅភូមិឡើយ ។ ហេតុដូច្នេះ មិនត្រូវខ្លាចអំពីការបះបោរ ។ ទើបគេសម្រេចថាត្រូវទុកអាព័ប់ពួកនេះឲ្យមានសេរីភាពចុះ ។

លុះរួចផុតពីគ្រោះថ្នាក់ជាអ្នកឈ្មួយវេលាណា នាងចាប៉ីយ៉ាស៊ើបសួរដំណឹងតាមមនុស្សអ្នកទៅក្នុងផ្ទះរបស់លោកតាកាអិដ្ឋ ។

ឥឡូវនេះ នាងទុបរឹតតែកួនស្រឡាំដើមទ្រូង ហើយមិនអាចដាក់ក្អែកចេញពីមុខនាងត្រឹមដែលនាងស្មានថា អស់បានជួបប្រទះហើយ ។ ការត្រែកអរកាលបំផុតគ្មានកើតមានពេញទាំងដួងហឫទ័យ ។

លោកតាអៃយ៉ាដឹងចិត្តនាងឡីឡាមិនខុស លោកដឹងច្បាស់ថា ការរីករាយនៃនាងដោយបានជួបម្តាយ ទំនងត្រឡប់អន់ថយទៅវិញ ព្រោះនាងនាំមានសេចក្តីស្តាយអាល័យ អំពីការចេញចាកផ្ទះដែលនាងធ្លាប់បានសុខពីដើមរៀងមក ។ លោកយល់បែបនេះឬមែលជាត្រូវ ?

លោកចូលមកជិតនាងឡីឡា យកដៃជាក់លើស្មាដូចជាឪពុក ហើយនិយាយដោយសុខសាកចាថា ;

– នែមីនាង ព្រះអាឡស់មានចំណងចង់ឲ្យនាង រៀបការនឹងកុលសម្ពន្ធ ជាតម្លាយនាងវិញ ។

នាងនារីបែរចំលោកតាអែយ៉ាដ ទាំងក្អែកក្រលួងរលេងរលោង ហើយនិយាយថា:

– ទុលោកម្ចាស់! ខ្ញុំម្ចាស់ត្រូវតែស្តាប់បង្គាប់ការស្ម័គ្រនៃព្រះអាឡស់ ប៉ុន្តែខ្ញុំម្ចាស់ទឹកមិនក្ងេចនូវអតីតវេលាដែលខ្ញុំម្ចាស់បានធ្វើឲ្យប្រព្រឹត្តទៅក្នុងគេហស្ថានជាទីគោរព ។

រួចនាងក្រមុំឈប់និយាយ ព្រោះមានការរំភើបយ៉ាងធំមកធ្វើឲ្យអួលដើមក ។ ក្អែកទាំងគូរបស់នាងក្តាំចាំងផ្ទេក។ ដោយជលនេត្រ ។

នាងចាប់និយាយឡើងខ្លែតទាំងត្រមិតត្រមក់។ ថា:

– ទុលោកម្ចាស់ថ្លៃខ្ញុំ បើអ៊ីស្មាអ៊ីលត្រឡប់មកវិញ សូមលោកប្រាប់គាត់ផងថា ខ្ញុំរលឹកគាត់រករបស់អ្វីប្រៀបគ្មាន ហើយខ្ញុំម្ចាស់បៀមនាំយកស្រមោលរូបដ៏ក្លាហានសប្បុរសរបស់គាត់ទុក ក្នុងកណ្តាលដួងព្រលឹងនៃខ្ញុំម្ចាស់ទៅជាមួយផង ។

ត្រង់ណេះត្រូវលើវេនលោកតាអែយ៉ាដម្តងវិញ លោកដឹងដួចជាមរណទុក្ខមកគៀបបេះដូងរបស់លោក ។ លោកដឹងតាំងពីយូរណាស់មកហើយ ថាកូនលោកមានការស្នេហាដ៏ធ្ងន់ចំពោះនាងក្រមុំ ហើយឥពុកកំសត់នេះមិនអាចខប់ខន់នឹងសេចក្តីព្រួយ ដោយនឹកដល់ភាសនារបស់កូនកំណេរលោក ។

អ៊ីស្មាអ៊ីល?

តើ គេដឹងជាវាស្លាប់ ឬរស់ពេលនេះ ! ប្រហែលពួកគ្រូតែលបចាំ ធ្វើទុក្ខតាមផ្លូវថ្នាកយណ៍ឯណាច់ ដែលទៅបន្ទាយកស្បែម៉ុតហើយទេដឹង ! ហើយទៅឯយមបន្ទាយឯណោះ មិនដឹងវាទទួលការធ្វើទុក្ខបុកម្នេញយ៉ាងណាមិនដឹងគេទម្លាក់ទោសមកលើវាយ៉ាងណា ដើម្បីផ្តន្ទាមកវែតពីវាមានសេចក្តីគោរពសច្ចវាចានឹងការពារខ្លួនវែតជាខ្លីស្រឡាញ់ ដែលអាចោរក្សត់ចង់ដណ្តើមយក ! ។

ហេតុដូច្នេះ សេចក្តីស្នេហាដ៏បរិសុទ្ធ ដ៏ជិតស្និតនៃនាងក្រមុំធ្វើឲ្យរំភើបដល់ចិត្តខាងក្នុងរបស់លោកតាកាអ៊ុង ក្នុងពេលដែលជ្រោតវាសនាមកកន្ត្រាក់យកនាងឡីឡាចេញពីផ្ទះ ហើយនាំនាងទៅកាន់អាជីវៈកណ្តាលវាលច្បាច់ ។ លោកតាសប្បុរសបេន-អៃយ៉ាងយល់ថា ពេលនេះខ្លួនលោកដូចជាគិតដល់នាងក្រមុំជាងសត្វជន ។ ការអាស្រ័យទៅនៃនាងក្រមុំព្រហ្មចារិយក្នុងផ្ទះ ហាក់ដូចជាបានសេចក្តីសុខគ្រាន់បើ ។ លោកវាប់ឃើញវាជាខ្លួច្ប កាលដែលវាទៅអណ្តែងទឹកជាមួយនឹងកូនស្រីកុយស្រីរបស់លោក ហើយលោកមានចិត្តពាប់អាណដូចគ្នាទាំងអស់ ឥតប្រែគាន់ ។ លោកដែលគេថ្នាប់ដឹងយូរមកហើយថាជាមនុស្សមិនញាប់ញ័រជាមនុស្សអាចសង្កត់ចិត្តខ្លួនបាន ឥឡូវត្រឡប់ទៅជារកកល់ខ្លប់ចិត្តមិនចង់កើត ។ លោកឈប់ការអួលអាក់ដែលឡើងមកត្រង់ចំពង់ក ហើយមានវាចាថា សូមការស្មើគ្នានៃព្រះអាឡស់សម្រេចចុះ !

រួចលោកលើកដៃជាក់លើក្បាលនាងឡីឡា ឱនម្តាយនាង ហើយលោកប្រកាប់ប្រសិទ្ធិឲ្យពរទាំងចិត្តទុក្ខព្រួយ ។

ឥឡូវនាងឡីឡាត្រូវវិលទៅដើរតាមគេពីដំរុំព្រឹកមួយទៅដំរុំព្រឹកមួយវិញ ។

ចម្ងាំងច្រែះតែកើតមាននៅតាមមាត់សមុទ្រនឹងខាងក្នុងកូមិកណ្ដាលបាកឃណ៌ខ្លាច់ ហើយសភាពធម្មជាតិក៏មិនខាន់ជាប្រែប្រួលណាស់ណានៅឡើយទេ ។ ប៉ុន្តែការផ្លាស់ប្ដូរប្រែប្រួលមានសភាពដ៏ធំចំពោះនាងឡីឡា ។ ដ៏វែកាតនាកណ្ដាលវ៉ាលប្រកបដោយសេរីភាព ដែលនាងធ្លាប់ប្រព្រឹត្តមកជាយូរអង្វែង ឥឡូវ ឥដ្ឋារម្មណ៍នេះ នាងមិនទទួលដូចពីមុនឡើយ ។ ដោយបាននទួលផលនូវនៃសេចក្ដីស្នេហារួចមកហើយ ក្រៅពីអនុស្សាវរីយ៍ចំពោះអ៊ីស្មាអ៊ីល នាងឥតមានសប្បាយនឹងអ្វីទាំងអស់ ។ ទីកន្លែងទាំងប៉ុន្មានគ្រាន់តែជាហេតុនាំឲ្យនាងកើតទុក្ខនឹងបាត់ការក្ដាហាន ។

កាលណានាងនាំហ្វូងពពែឲ្យស៊ីស្មៅ នាងតែងតែនឹកចាំងទុក្ខ ដល់រូបស្រមោលដ៏ថ្លៃថ្លាដែលបានដួនាងដើរកាត់តាមដើមគ្នោតនឹងផ្កាកូឡាបដើម ។ លុះការស្រមៃនេះរលុបបាត់ទៅ នាងនឹកដល់រូបស្រមោលនៃអ្នកដឹះសេះសបរមករកនាង ។

ឧបត្ថម្ភហេតុដើមដំបូងនៃការជួបប្រទះនឹងអ៊ីស្មាអ៊ីលត្រូវបាត់កើតឡើងក្នុងចិត្តទុក្ខព្រួយនៃនាងវិញម្ដងទៀត ។ នាងនឹកឃើញថា កាលនោះអ៊ីស្មាអ៊ីលស្លៀកពាក់បែបនេះ ត្រឹងអានេះបែបនេះ សូរសំដីអ៊ីស្មាអ៊ីលបែបឯណេះ នាងនឹកឃើញសព្វគ្រប់តែងតែណា ។

(មានត)

រឿងបល្ល័ង្កធំៗ សាមសិបពីររឿង

រឿងព្រេងតណ្ហៀ

លោកសមិន ម្ចាស់ជីវិតតែង

លោក រ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

និទានដែរបទេពធិម្មិតទី ១៦

មានកាលមួយថ្ងៃ ព្រះបាទកោដៈខ្ពង់ឡាងចូលទៅដឹតបល្ល័ង្កធំៗ, រូបទេពធិម្មិតទី ១៦ ក្រាបបង្គំទូលថា:

"បពិត្រ ព្រះបាទកោដៈ, ខ្ញុំលបង្គំសូមថ្វែងអំពីព្រះពរគុណសម្បត្តិដែលធ្វើឲ្យមហាពរវិក្រមាទិត្យ អាចគង់នៅលើបល្ល័ង្កធំៗនេះបាន សូមព្រះអង្គខ្ពង់ព្រះសណ្ដាប់!

មានព្រះមហាក្សត្រិយ៍មួយព្រះអង្គខ្ពង់ព្រះនាមចន្ទ្រសេខរៈ (Candraçekhara) មានមួយថ្ងៃស្ដេចគំពុងខ្ពង់គង់ប្រថាប់ក្នុងមហាសន្និបាតរដ្ឋមន្ត្រី, មានបរជាតិថ្នាអ្នករៀងម្នាក់ចូលមកក្រាបបង្គំគាល់ព្រះអង្គ ថ្វែងសរសើរអំពីព្រះពរកិត្តិគុណនៃព្រះបាទវិក្រមាទិត្យថា: "ព្រះបាទវិក្រមាទិត្យខ្ពង់ប្រកបដោយព្រះពរកិត្តិគុណសម្បត្តិគ្រប់យ៉ាង ព្រោះហេតុដូចនេះ អ្នកទាំងអស់ចូលទៅពុំនាក់អាស្រ័យនឹងព្រះអង្គ; ខ្ញុំជាទីជ្រកកោនខ្វះគុណសម្បត្តិគ្រប់យ៉ាង ព្រោះព្រះអង្គជាឧត្តមមនុស្សម្នាក់ ដែលមានព្រះប្ញាអាចបំពេញខ្វះគុណសម្បត្តិទាំងអស់បាន, ជាឯកមនុស្សមិនមានមនុស្សណាអាចយកមកប្រៀបធៀបនឹងព្រះអង្គបានឡើយ។

ព្រះបាទចន្ទូសេខរៈ កាលខ្ញុំព្រះសណ្ដាប់ទូវសេចក្ដីពណ៌នានៃអ្នកប្រៀង (សមដ្ឋបុរស Mévestrel) ខ្ញុំមានព្រះបន្ទូលទៅកាន់អ្នកប្រៀងថា "ម្នាលវាគកៈបុរស អ្នកឯងបានតាច់ទៅកាន់ប្រទេសជារច្រើន តើធ្លាប់បានឃើញបុគ្គលណាមានចរិយាល្អ ដូចព្រះបាទវិក្រមាទិត្យឬទេ ? វាគកៈបុរសក្រាបបង្គំទូលថា ខ្ញុំលព្រះបង្គំបានឃើញតែព្រះបាទវិក្រមាទិត្យ ដែលខ្ញុំមានព្រះគុណធម៌ច្រើនជាងគេ ។ ព្រះបាទចន្ទូសេខរៈ ខ្ញុំព្រះសណ្ដាប់ទូវសព្វវាចាធិប្បាយនៃវិញ្ញាជន អំពីព្រះគុណធម៌នៃព្រះបាទវិក្រមាទិត្យ ខ្ញុំមានព្រះពាជបំណងចង់ឲ្យមានព្រះគុណធម៌ដូចមហាពាជអង្គនោះដែរ ហើយខ្ញុំបួងសួងចំពោះទេវប្ញិ ។ ពេញព្រះពាជហ្ឫទ័យនឹងសម្បជសង្រ្គឹងនៃព្រះបាទចន្ទូសេខរៈ ក៏បានថ្វាយមកព្រះអង្គទូវអត្តភាព ហើយមានព្រះបន្ទូលថា "ក្នុងមួយថ្ងៃ សូមព្រះអង្គបូជាព្រះកាយព្រះអង្គចំពោះព្រះអគ្គី, ហើយរូបកាយនេះអស់ រៃទៅជារូបកាយមួយផ្សេងទៀត មានធម្មជាតិដ៏ឧត្តម ។ ក្រោយដែលបានមានព្រះបន្ទូលយ៉ាងនេះ ទេវប្ញិក៏បាត់ខ្លួនពីទីនោះទៅ ។ ព្រះបាទចន្ទូសេខរៈ ខ្ញុំក៏បានយកព្រះរូបព្រះអង្គទៅធ្វើព្រះពាជពលីកម្មរាល់ៗថ្ងៃ ហើយព្រះរូបព្រះអង្គទៅជាមានសម្ផស្សដ៏ទិព្យ ។ ដល់ខ្ញុំមានបុព្វសិទ្ធិជាអមតភាព, ខ្ញុំក៏មានព្រះគុណគ្រប់យ៉ាង ។

សមដ្ឋបុរសក៏បានក្រាបបង្គំទូល ចំពោះព្រះបាទវិក្រមាទិត្យទូវរឿងកំរៃនៃព្រះបាទចន្ទូសេខរៈ ។ ព្រះបាទវិក្រមាទិត្យក្រោយដែលបានខ្ញុំព្រះសណ្ដាប់ទូវវាចារបស់វាគកៈបុរស ខ្ញុំព្រះដម្រិះក្នុងព្រះ

ពាដប្ញាទ័យថា: "បើអ្នកណាបានធ្វើពលិកម្មដូចព្រះបាទចន្ទ្រសេខរៈ អ្នកនោះជាឧត្តមមនុស្ស ជាឯកបុគ្គលគួរជាទីគោរព គួរជាទីបូជា" ។ ដល់ទ្រង់ព្រះតម្រិះដូចនេះ ព្រះបាទវិក្រមាទិត្យទ្រង់ក៏បួងសួងចំពោះទេវប្ញទ្ធិ។ បញ្ចេញរូបមកចំពោះព្រះភ័ក្ត្រទ្រង់។ ក៏មានព្រះពាដឧង្ការទៅកាន់ទេវប្ញទ្ធិថា "សូមទេវប្ញទ្ធិឈប់លែងឲ្យព្រះបាទចន្ទ្រសេខរៈលោតទៅក្នុងព្រះអគ្គី ដើម្បីនឹងធ្វើរូបឲ្យបានប្រកបដោយអត្តភាព, សូមទេវប្ញទ្ធិប្រគល់ការៈដ៏ធ្ងន់នោះ គឺឲ្យខ្ញុំលោតទៅក្នុងព្រះអគ្គីវិញ, ហើយសូមប្រគល់ឲ្យអមតភាពនោះទៅព្រះបាទចន្ទ្រសេខរៈវិញ" ។ ទេវប្ញទ្ធិក៏យល់ព្រមតាមព្រះពាដចំណង ហើយហោះទៅឲ្យដំណឹងដល់ព្រះបាទចន្ទ្រសេខរៈថា តាំងពីថ្ងៃស្អែកនេះទៅទ្រង់មិនបាច់លោតទៅក្នុងព្រះអគ្គីទេ ការៈនេះគឺព្រះបាទវិក្រមាទិត្យទ្រង់ទទួលទៅហើយ, ព្រះអង្គចាំតែទទួលទូវអមតៈចុះ ហើយព្រះរូបព្រះអង្គប្រែជាអមតរូប គឺលែងចាស់-ឈឺ-ស្លាប់ តាំងពីថ្ងៃនេះតទៅ" ។

តាំងពីថ្ងៃនោះមក, ព្រះបាទវិក្រមាទិត្យទ្រង់តែងលោតទៅក្នុងព្រះអគ្គីពាល់ព្រឹក, ឯព្រះបាទចន្ទ្រសេខរៈចាំទទួលទូវអមតៈ។ រួបទេពនិមិត្តទី ១៦ ពោលដូច្នេះហើយ, ក៏ដាក់ទៅកព្រះបាទគោដៈ ហើយទូលថា បើទ្រង់មានកិច្ចការធ្វើពលិកម្មប្រែបនេះបាន សូមទ្រង់ស្តេចចូលទៅគង់លើបល្ល័ង្កទិព្វនេះចុះ ។ ព្រះបាទគោដៈទ្រង់យល់ថាកិច្ចនេះហួសវិស័យព្រះអង្គនឹងធ្វើបាន, ទ្រង់ក៏ថយចេញឆ្ងាយពីបល្ល័ង្កទិព្វ ពុំបានធ្វើពាដាកិសេកកង់ពេលនោះ ។

និទាននៃរូបទេពធីម្មិតទី ១៧

មានកាលថ្ងៃមួយ, ព្រះបាទកោដៈ ទ្រង់ខិតចូលទៅជិតបល្ល័ង្កខ្ញុំ ដើម្បីនឹងធ្វើពាក្យសេក ។ រូបទេពធីម្មិតទី ១៧ ក្រាបបង្គំទូលព្រះអង្គថា: សូមទ្រង់ព្រះមេត្តាប្រោស, ខ្ញុំលបង្កើនឯណានាព្រះពុទ្ធចរិយាដ៏ពិសេសនៃព្រះបាទវិក្រមាទិត្យដូចតទៅនេះ ៖

កន្លះជ្ឈកាលព្រះបាទវិក្រមាទិត្យ ទ្រង់សោយរាជសម្បត្តិនៅនគរអវន្តី ។ កន្លះពេលនោះពួកប្រជារាស្ត្រតាំងអស់ពេញចិត្តខាងការប្រព្រឹត្តនូវគុណធម៌ ដោយព្រះមហាក្សត្រិយ៍ ទ្រង់ទសពិធរាជធម៌ ។ ស្ត្រីស្គាល់តែប្តីរបស់ខ្លួនតាក់, គេលះបង់ចោលចាបអកុសល, គេពេញចិត្តខាងប្រតិបត្តិតាមបទបញ្ញត្តិច្បាប់, គេប្រព្រឹត្តតាមបទដែលបានចារឹកទុកក្នុងសាស្ត្រ:, គេគោរពក្បៀវ, ស្តាប់បង្គាប់ឪពុក មាតា-បិតា ព្រះមហាក្សត្រិយ៍ . . . ល . . . គេប្រព្រឹត្តតាមសីលធម៌ ដូចបានត្រាទុកក្នុងវិទ្យាសាស្ត្រនៃអត្តា (la science de l'âme suprême) បើពោលដោយសង្ខេប ប្រទេសតាំងអស់ក៏រុងរឿងដោយបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ ។ ព្រះបាទវិក្រមាទិត្យទ្រង់ទុកបម្រុងរក្សាជីវសត្វ, ធ្វើខណ្ឌកម្មពួកពាលសាមាន្យ តាមបទបញ្ញត្តិក្នុងខណ្ឌនីតិ (Dandaniti) (Dandaniti Code pénal) ហើយនឹងរាជនីតិ, (Rājāniti Code politique) ហើយទ្រង់សប្បាយព្រះរាជហ្ឫទ័យក្នុងរាជសម្បត្តិ បានប្រកបដោយសុភមង្គលត្រង់ប៉ង ។

មានមួយថ្ងៃនាយទ្វារ បានចូលមកក្រាបបង្គំទូលព្រះបាទវិក្រម-

ទៀតថា "បពិត្រព្រះអង្គដ៏ចំរើន មានជ្រូកព្រៃមួយធំសម្បើមអស្ចារ្យ មានរូបប៉ុនភ្នំដូចជាព្រះយមៈ (យមកជ) មកដល់, បានចូលទៅក្នុងគុម្ពោតឈើ ដែលជាទីកន្លែងព្រះអង្គម្ចាស់ធ្លាប់ស្តេចយាងទៅកំសាន្តព្រះកជប្បាទ័យ ។ ជ្រូកព្រៃនោះធ្វើឲ្យខូលព្រះបង្គំខ្លាចតក់ស្លុតពន់ប្រមាណ, ទាល់តែខូលព្រះបង្គំរត់ចេញពីព្រះកជុទ្យាន មកសូមពំនាក់អាស្រ័យនឹងព្រះអង្គ សូមទ្រង់ព្រះមេត្តាគ្រាស់បង្គាប់ឲ្យចាត់កងយោធាទៅដេញជ្រូកព្រៃនោះពីព្រះកជុទ្យាន ។

"កាលណាព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យនាយឧទ្យានចាស, ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះកជបំណងចង់យាងទៅប្រាញ់សត្វ, ទ្រង់ឡើងគង់លើព្រះទីនាំងហត្ថីតែមួយព្រះអង្គ ដើម្បីនឹងដេញជ្រូកព្រៃនោះចេញពីព្រះកជុទ្យាន ។ ដល់ព្រះបាទវិក្រមាទិត្យ ទ្រង់ស្តេចយាងចូលទៅក្នុងព្រះកជុទ្យាន ស្រាប់តែជ្រូកព្រៃនោះភ័យតក់ស្លុតឥតឧបមា, ក៏រត់ចេញពីទីនោះទៅ ។ ព្រះមហាក្សត្រិយ៍ទ្រង់ដេញតាមជ្រូកព្រៃ, កាត់តាមព្រៃជាច្រើនសង្កាត់ទើបយាងទៅដល់ព្រៃក្រាស់ធំមួយ ។ ទ្រង់ក៏ស្តេចដេញបែកតតាមពីក្រោយ ។ ដល់ជ្រូកព្រៃនោះទៅដល់មាត់ទ្វារគុហាភ្នំ ក៏យកថែងំលាយទ្វារធំនោះរត់ចូលទៅខាងក្នុង ។ ព្រះបាទវិក្រមាទិត្យទ្រង់ស្តេចយាងចុះពីព្រះទីនាំងហត្ថី ព្រះហស្តកាន់ព្រះខ័នហើយនឹងខែលចូលទៅក្នុងគុហានោះទៅ ។ គុហានោះមានទំហំធំពន់ពេក ដូចជាប្រទេសចាំងមួល ។ ទ្រង់ក៏បានស្វែងរកជ្រូកព្រៃគ្រប់ទិសទីតែមិនឃើញ ។ ទ្រង់ក៏គ្រាច់ទៅក្នុងគុហា, ស្រាប់តែទ្រង់ឃាន

ជួបប្រទះនឹងនគរមួយ ដែលខ្ញុំមិនដែលឃើញសោះឡើយ ។ ខ្ញុំ
បានទតទៅឃើញព្រះរូបព្រះនាគយក្ស ដែលមានអាកប្បកិរិយាដូចជា
ថ្លាយជង្គាយ នៅចាំមាត់ទ្វារនគរ ។ ខ្ញុំក៏បានថ្វែងព្រះបរិសុទ្ធ-
កថានឹងបណាមកថា ហើយខ្ញុំបានធ្វើព្រះពរប្រទក្សិណ ចំពោះ
ព្រះរូបព្រះនាគយក្សនោះ ហើយខ្ញុំគន់ប្រថាប់ដោយលើកព្រះហស្ត
ធ្វើអញ្ជលីកម្ម ។

ព្រះនាគយក្សខ្ញុំមានព្រះពរជ្រួតជ្រែយ សោមនស្សពន់ពេកដោយ
ព្រះបាទវិក្រមាទិត្យ ខ្ញុំបានគោរពនមស្សការជាំស្មោះស្ម័គ្រ ។ ខ្ញុំ
ក៏បានព្រះពរជានមកព្រះបាទវិក្រមាទិត្យ នូវវត្ថុដ៏ជាទិព្វពីរយ៉ាងគឺរស:
(Rasa) នឹងរសាយន: (Rasâyana) ដែលខ្ញុំបានពន្យល់អំពីរបៀបយក
ទៅប្រើ ព្រះនាគយក្សខ្ញុំមានព្រះបន្ទូលថា: បពិត្រមហាពាជ ចំពោះ
វត្ថុនេះដែលហៅថារស: របស់អ្វីដែលខ្ញុំព្រះតម្រិះទៅជល់ហើយ
នាំឲ្យត្រែកត្រអាលក្នុងសង្សារ ខ្ញុំអាចសម្រេចបានទៅតាមព្រះពរ
បំណងដោយសារវត្ថុនេះ ។ ចំណែកឯវត្ថុដ៏ទិព្វមួយទៀតដែលមានឈ្មោះ
ថារសាយន:នេះ បើខ្ញុំព្រះតម្រិះអំពីវត្ថុ គឺវត្ថុដែលមានសភាពខ្ពស់ជាង
ពិភពលោក; ខ្ញុំនឹងអាចសម្រេចទៅតាមព្រះពរបំណងទាំងអស់ ។

ព្រះបាទវិក្រមាទិត្យ ដល់ខ្ញុំបានវត្ថុដ៏ទិព្វទាំងពីរដោយព្រះពរ
អំណាចនៃព្រះនាគយក្ស ខ្ញុំក៏ចេញពីគុហា ។ ទ្វារនៃគុហានោះ
ក៏បិទជិតខ្ញុំក៏ក្តាប់ព្រះហស្តជាល់ទៅលើទ្វារនោះរបើក ហើយខ្ញុំក៏
យាងវិលត្រឡប់មកកាន់ព្រះពាជធានីវិញ ។ ទៅតាមផ្លូវ, ខ្ញុំបានជួប

ប្រទេសនឹងព្រាហ្មណ៍ពីរនាក់ជាឪពុកនឹងកូនប្រុសជាពួកវិញ្ញូជន ឲ្យចាប់ចេះដឹងសស្ត្រៈគាំងអស់, មានទុក្ខជាខ្លាំង ។ ក្រោយដែលទ្រង់ព្រះសណ្តាប់នូវរឿងរ៉ាវនៃព្រាហ្មណ៍គាំងពីរនាក់ ទ្រង់ក៏មានព្រះពាជហ្ហឫទ័យអាណិតអាសូរដល់ព្រាហ្មណ៍ដូចជាខ្លួនឯងបស់ព្រះអង្គ ហើយទ្រង់ព្រះពាជទានខ្លួវត្ថុដ៏ច្រើនគាំងពីរ គឺសេះនឹងរាយនៈទៅព្រាហ្មណ៍ ។

រួចខេតនិម្មិតទី ១៧ ទូលបន្ទូលថា: បពិត្រព្រះបាទកោជៈ: នេះហើយជាព្រះមហាវីរកាត ព្រះមហាសម្បុរសនៃព្រះបាទវិក្រមាទិត្យ បើទ្រង់មានព្រះបរិយាជ្ឈដូចព្រះបាទវិក្រមាទិត្យបែបនេះ, ទ្រង់អាចគង់ទៅលើបល្ល័ង្កទិព្វនេះបាន ។

ក្នុងពេលនោះ ព្រះបាទកោជៈក៏ទ្រង់មិនបានធ្វើពាងាកសេក ទ្រង់បានចេញពីបល្ល័ង្កទិព្វនេះទៅ ។ (មានត)

រស់នៅបែបណាទុកជាជាការរស់ប្រសើរ ?

២៤ – ក្នុងលោកនេះ អ្នកណារស់នៅតែមួយស្រែបក់ តែប្រកបដោយសម្បទាដែលមនុស្សលោកចូលចិត្ត គឺចំណេះវិជ្ជា, សេចក្តីអង់អាចក្លាហាន, ទ្រព្យសម្បត្តិ ទឹងគុណដ៏ប្រសើរគាំងឡាយ,អ្នកដឹងការណ៍នោះច្បាស់លាស់តែងពោលសរសើរជីវិតអ្នកនោះថាជាជីវិតដ៏ប្រសើរ; ឯសត្វក្អែករស់នៅបានយូរដោយគ្មានតែស៊ីចាយសល់អំពីគេធ្វើពលិកម្ម ចាត់ជារស់ពុំប្រសើរ ។

សកម្មភាពនៃក្រុមជំនុំនៀមទម្ងាប់ខ្មែរ

នៅពុទ្ធសាសនបណ្ឌិត្យ

បរិយាយពីល្បែងត្រុដិ

លោក ចាប-ពិន រៀបរៀង

ក្នុងនាមក្រុមជំនុំនៀមទម្ងាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ខ្ញុំសូមបរិយាយចំពោះល្បែងខ្មែរមួយចែប ហៅថា "ល្បែងត្រុដិ" ដែលអ្នកខែត្រសៀមកាប ទឹងបាត់ដំបងគេតែងលេងនៅរដូវចូលឆ្នាំខ្មែរកាលឆ្នាំ ។

រថាំគ្រាប់ចំពូកដែលមានពាំងកំពាំងច្រៀងពាំងក្ងេង ហៅតាមភាសាសំស្ក្រឹតថា "មហោស្រព" ។ មហោស្រពខ្មែរមានច្រើនចំពូក - មានស្លោន ស្លោនខោល ស្លោនយន្ត កំត្រុដិ កំស្នែងខន្ធាង ពាក់ផ្កាវែងជាដើម ។ ក្នុងទីនេះ សូមយកតែល្បែងត្រុដិមួយមកថ្លែងជាមុនសិន ដែលមុខសឹមថ្លែងពីល្បែងឯទៀត ដោយយើញថាល្បែងត្រុដិជាល្បែងខ្មែរតែខ្មែរយើង ក្រៅតែពីអ្នកខែត្រសៀមកាបទឹងអ្នកបាត់ដំបងចេញ ពុំសូវនរមាគេស្គាល់ទេ ។

ពាក្យថា ត្រុដិ ជាភាសាសំស្ក្រឹត វែប្រែថា "ការកាត់ផ្តាច់ គឺផ្តាច់ឆ្នាំមួយ ។" ឯល្បែងនេះបានជាបុពណាឲ្យឈ្មោះថា ល្បែងត្រុដិ ព្រោះជាល្បែងដែលគេត្រូវលេងចំពោះតែរដូវផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ។

តាមសេចក្តីឲ្យការណ៍របស់ព្រះតេជព្រះគុណ ព្រះវន្តែន ព្រះនាម អ៊ីវ - ឌួត មេគណខែត្របាត់ដំបងថា លោកបានដួបទឹងជនជាតិខ្មែរ នៅ

ស្រុកស្ទុំនេ ១ នាក់ឈ្មោះ ព្រឹម ឲ្យការណ៍ថា អ្នកស្រុកនោះ គេនៅ
រក្សាទំនៀមទម្លាប់ល្បែងត្រុដិល្អណាស់, ថាអ្នកស្រុកនោះ គេតែងលេង
ល្បែងនេះនៅវេលាចូលឆ្នាំពាល់ឆ្នាំ, ថាចាស់ ។ នៅស្រុកនោះដំណាល
ថា កាលព្រះមហាក្សត្រែវ្នែត្រែងពជ្យនៅអង្គរធំ វេលាជាប់ឆ្នាំចាស់ចូល
ឆ្នាំថ្មី ពួកត្រុដិតែ នៅលេងថ្វាយព្រះស័ព្ទសាធុការជាពាល់ឆ្នាំ, ព្រះ
មហាក្សត្រែតែងស្តេចចេញទ្រង់ព្រះតំណាក់ព្រះពជ-
ពានវង្វាន់ ទ្រង់ប្រោះទឹកព្រះពជពានតាមបរ ។

សេចក្តីឲ្យការណ៍នេះ ឃើញសមហេតុផល ព្រោះអ្នកខែត្រសៀម
ពេលសព្វថ្ងៃនេះនៅពាប់អានល្បែងត្រុដិណាស់ តែដឹងដល់ថ្ងៃចូលឆ្នាំពួក
អ្នកលេងល្បែងនេះ តែងត្រៀមគ្រឿងប្រដាប់លេងសព្វគ្រប់ ដល់ថ្ងៃ
ចូលឆ្នាំចេញលេងតាមភូមិស្រុក លុះដល់ថ្ងៃឡើងស័កទាំគ្នានៅលេង
ថ្វាយឯនតរវត្ត ជាទំនៀមរៀងពាល់ឆ្នាំ ។

ឯល្បែងត្រុដិមិនបានបឹតនៅខៀងតាត់ជាបែបមួយទេ ចេះតែផ្លាស់
ប្តូរទៅតាមកាលសម័យ តាំងគ្រឿងប្រដាប់សម្រាប់លេងនីមួយៗក្រៃ
កំមានថ្លៃក ។ គ្នា ទៅតាមខែត្រ តាមស្រុក តាមភូមិ ហើយគ្រឿង
ប្រដាប់នោះសោតក៏មានតិចច្រើនតាមវង់តូចវង់ធំ, វង់តូចគ្នាតិចគ្រឿង
ប្រដាប់តិច វង់ធំគ្នាច្រើនគ្រឿងប្រដាប់ច្រើន ។

ឯត្រដិវង់ធំមានអ្នកលេងច្រើន ចំនួន ៣២ នាក់ ទើបមានគ្រឿង
ប្រដាប់ច្រើន ដូចរៀបពាប់តទៅនេះ ៖

- ប្រុស ៣ នាក់ ជាអ្នកកាន់ដង្កៀកញ្ជាវ សម្រាប់បុកឲ្យឮធារៗ តាមចង្វាក់ស្គរ,
- ប្រុស ២ នាក់ ជាអ្នកកាន់ស្គរដែលហៅថាស្គរអាវ័ក្ស សម្រាប់ទះឲ្យឮខ្ទឹបៗ ខ្ទឹមៗតាមចង្វាក់ភ្លេង;
- ប្រុស ១ នាក់ ជាអ្នកកាន់ប៉ីពក សម្រាប់ផ្លុំតាមបទភ្លេង;
- ប្រុស ២ នាក់ ជាអ្នកកាន់ខ្លែ សម្រាប់កូតតាមបទភ្លេង;
- ប្រុស ៣ នាក់ ជាអ្នកកាន់ដង្កៀចឆ្នៃន៍ដំបែរ សម្រាប់បុកឲ្យឮរ៉ែៗ តាមចង្វាក់ស្គរ;
- ប្រុស ២ នាក់ ជាអ្នកពាក់ស្មៅន៍ប្រើសមែនខែនឬផ្កៅពត់ជាស្មៅន៍ប្រើសដើរក្រាយគេ សម្រាប់ឲ្យព្រានព្រៃចាំចាញ់;
- ប្រុស ៤ នាក់ ជាអ្នកពាក់ស្មៅន៍ខ្សាន់មែនខែនឬផ្កៅពត់ជាស្មៅន៍ខ្សាន់ដើរក្រាយគេ សម្រាប់ឲ្យព្រានព្រៃចាំចាញ់;
- ប្រុស ១ នាក់ ជាព្រានព្រៃឬយក្សចង់ចឆ្នៃន៍រ៉ូនដុំវិញចង្កេះដៃកាន់ធ្នូ សម្រាប់ចាំចាញ់ប្រើស ខឹងខ្សាន់;
- ប្រុស ៤ នាក់ ជាអ្នកទាំមុខ ដួតក្បាលក្រហម សម្រាប់ដើរនាំហ្វូង;

- ប្រុស ១ នាក់ ជាថ្មើរព្រៃជួតក្បាលក្រមា ស្លាយចាយកញ្ចប់ សម្រាប់ដើរមើលផ្លូវមុនព្រានព្រៃ;

ប្រុស ១នាក់ ជាអ្នកដើមបទ ពាក់គ្រឿងវែងដែលធ្វើពីខ្ទុំងស្លឹកដូង សម្រាប់ច្រៀងបើកបទឲ្យអ្នកលេងទាំងអស់គ្នាចាំច្រៀងបន្ទរតាម;

- ប្រុស ២ នាក់ ជាតួឯកស្លៀកសំពត់ចងក្បិនខ្លួនពាក់សង្វារក្បាលពាក់មកុដឬកញ្ចាំង មុខជាត់មេរ៉ាកាន់កន្ទុយក្អែកសម្រាប់ពាំនាំមុខគេ;

- ស្រី ២ នាក់ ជានាង ពាក់គ្រឿងវែង ក្បាលពាក់រៃស្លៀកសំពត់ហូលសំឡួយ ពាក់អាវបំពង់ខ្លីបង់កសំយុង សម្រាប់កំគួនធ្វើតួឯក;

- ប្រុស ២ នាក់ ជាអ្នកកាន់ដង់សន្ទូចប្រវែង ២ ម៉ែត្រ ចងថង់សំពត់ទៅចុង សម្រាប់ព្រាទៅកផ្ទះអ្នកស្រុកឲ្យម្ចាស់ផ្ទះជាក់សូត្រ អំបោះ ទឹងប្រាក់;

- ប្រុស ១ នាក់ ជាអាចារ្យ ស្លៀកពាក់ស ពាសស ស្លាយយាម សម្រាប់ឆ្លើមបើកពិធីលេងទឹងដើរមុខអ្នកលេង ចាំទទួលសូត្រអំបោះទឹងប្រាក់ ។

តាមទំនៀមអ្នកលេងត្រដិះទៅស្រុកតាគ្រាមទៃត្រូវបាត់ដំបង, មុនពេលលេងគេធ្វើពន្ធទេវតា ៣ ថ្នាក់ ដាក់ប៉ាយសី ១ គូ ស្វាធម ១ គូ

ពែ ១ ស្នឹត កញ្ចក់ រមៀត មេម៉ូ ស្វាចារ កន្ទោងចាយម្ហូបចំណី ទឹកអប់ ១ ដុំល អំបោះ ១ កម្រងៈ ខ្ទឹមមុខស្មាច់ ហើយឲ្យពួកអ្នកលេងតាំងប៉ុន្មានមកជួបជុំនៅមុខពន ។ ពួកអ្នកក្លែងកាន់តួនឹងក្លែងអង្គុយ ១ ជួរ, អ្នកកាន់តួនឹងប្រដាប់លេងផ្សេង ។ អង្គុយ ១ ជួរ, អាចារ្យអង្គុយចំកណ្តាលអុជទៀនធូបសូត្រចប្ងសួងវិសេនអាក្សអ្នកតា ។ ស្រែចកាលណាអាចារ្យលើកមុខស្មាច់ខ្ទឹងស្នែងប្រែសបំពាក់ឲ្យគ្រប់គ្នា ហើយចេញទៅក្រៅវង់ ។ លំដាប់ព័ទនេះ ពួកអ្នកលេងរៀបគណៈតាំងអស់គ្នាហើយ

ក្នុងកម្រែកច្រៀងឡើងថា:

ខ្ញុំសូមថ្វាយបង្គំ ហត្ថខ្ញុំប្រណម្យ ត្រៃរតនត្តៃយ

ទ្យ ! ព្រះគុណខ្ញុំហើយ ត្រៃរតនត្តៃយ សូមមានជោគជ័យ សេចក្តីក្សេមក្សាន្ត ។

អ្នកទួល ៗ ត្រមង់ថា:

ទ្យណានាងណា ! សេចក្តីក្សេមក្សាន្ត ។

ក្នុងពេលចប្ងសួងក្តី ពេលណា ៗ ក្តី, កាលពួកអ្នកច្រៀង ៗ ឡើង, ពួកអ្នកកាន់ដងកញ្ជ្រែងក៏ប្តូរកញ្ជ្រែងតាមចង្វាក់ស្មូរ, ចំណែកអ្នកកាន់ស្មូរក៏ទះតាមរយៈដែលគេកំណត់ គឺទ្រែបទ្រែម ត្រែទ្រែប ទ្រែបទ្រែម ជួនកាលយូរ ៗ គេបំភ្លៃម្តងត្រែងៗ ទ្រែប ៗ ទ្រែម ៗ ទ្រែប ទ្រែម ដូច្នេះ, គ្មានវិសេសជាងនេះទៀតទេ ។

កាលស្រែចពិធីពិការគេនាំគ្នាចេញលេងតទៅ ។

បើពេលលេងមានអ្នកស្រុកឲ្យទានវត្ថុប្លាក់កាសច្រើន, ក្រែយ

គេលេងពួកត្រុដំចាត់ការទិមន្តព្រះសង្ឃសូត្រមន្តប្រស់ទឹកឲ្យឥស្សាច,
ព្រឹកឡើងនិមន្តឆាន់ ។

បើបានវត្ថុតិចមិនល្មមធ្វើដូច្នោះបាន, ពួកត្រុដំប្រមូលវត្ថុទាំងឡាយ
មានអំបោះសូត្រជាដើមទៅប្រគេនព្រះសង្ឃឯវត្ត សូមឲ្យលោកប្រស់
ទឹកមាប់ចង្រៃ ។

យើងសែងខំនុកបៀងត្រុដំមកចរកែកុក្កគន្ធីនេះឲ្យ ដើម្បីបញ្ជាក់
ជូនអ្នកប្រវត្តិសាស្ត្រ ដែលត្រូវការសេចក្តីស្រាវជ្រាវដើមកំណើត
ល្ខោនេះ ។

ខំនុកបៀងត្រុដំនៅខែត្រសៀមកាប ដូចតទៅនេះ:

អ្នកដើមបទថា:

ត្រុដំនេះ អគ្គីត្រុដំអាយ ។
ត្រុដំលោកខៅហ្មាយ ប្រើខ្ញុំមកលេង ។

អ្នកទទួលថា:

ឧណាន៑ាងណា ! ប្រើខ្ញុំមកលេង ។

អ្នកដើមបទថា:

ជូះធំចម្ងាត់ ។ ជះណ្តើរកាំជ្រាក់ សមគាត់មានបុណ្យ ។

អ្នកទទួលថា:

ឧណាន៑ាងណា សាក៑ម៉ុមបង ។

អ្នកដើមបទថា.

នែ ! វ៉ីយកុំនោត ។ ជញ្ជាំងស្វឹកស្អាត គង់មានថ្នាំខ្ចាំង ។

អ្នកទទួលថា:

ក្រណាតាន់ណា ! តង់មានថ្នាំខ្លាំង ។

អ្នកដើមបទថា:

ប៉ានមួយថ្ងាវ តង់មានកម្លាំង

តាត់មានថ្នាំខ្លាំង មូរដាក់ដើង់ពាន ។

អ្នកទួលថា:

អាត:ឌីង់នាវ សាក៉ាម៉ុមបង ។

អ្នកដើមបទថា:

ត្រែបីស្នែងនប់ ស្នែងតុបចង្កា

ត្រែបីនរណា ចូលហ្វូងយើង់ហើយ ។

អ្នកទួលថា:

អាត:ឌីង់នាវ សាក៉ាម៉ុមបង ម៉ុមបង ម៉ុមបង ។

។ ល ។ ល ។

ខំនុកត្រែង់ត្រុដៃនៅខែត្រសៀមកបនៅមានច្រើនយ៉ាង់ទៀត ដែលស្រង់មកថ្វែង់ក្នុង់ទីនេះដោយសង្ខេបទេ ។

ឯខំនុកត្រែង់នៅខែត្រាត់ដំបង់ក៏មានច្រើនយ៉ាង់ដូចគ្នា តែស្រង់មកថ្វែង់ដោយសង្ខេប ដូចតទៅនេះ:

អ្នកដើមបទថា:

ត្រុដៃនេះ អង្គឺត្រុដៃអាយ។

ត្រុដៃលោកចៅហ្វាយ ខែត្រាត់ដំបង់

យើង់ខ្ញុំពាល់គ្នា ព្រួយចិត្តអឺង់កង់

ឮតែផ្លូវផង គ្មានភ្លៀង់ឡើយណា ។

អ្នកទួល ២ នាក់បន្តថា:

ឃោនៗឃោនៗ ទន្យាយលេចកូន

ក្បែរគុម្ពចែងម៉ែង រកគេដួយសែង

លេចស្នែងចង្រ្កឹង ។

អ្នកទូលទាំងអស់គ្នាបន្ទរថា:

អាត:ខីង៑ធារ អាក៉ាម៉ុមបង

អំបោះកម្រង បងដែកញ្ជារ ។

។ ល ។ ល ។

តាមធម្មតាអ្នកច្រៀងត្រូវ បើគេត្រូវការច្រៀងចូលឆ្នាំក៏គេច្រៀងតាមចំនុកដែលជាប់ច្រៀងហូរហែដូចពោលមកហើយ, បើគេត្រូវការច្រៀងយោសនាសាងវត្តក៏គេសរសើរឿងទាន មានចំនុកដូចតទៅនេះ:

អ្នកដើមបទថា:

លោកឪលោកម៉ែ! ខ្ញុំបាទសូមជាក់

ជ្រុតមានធុរៈ គិតសាងវិហារ ។

អ្នកទូលថា:

ឧណ្ហានាងណ្ហា! គិតសាងវិហារ ។

អ្នកដើមបទថា:

ថ្វាយដល់ព្រះសង្ឃ ដោយចិត្តសទ្ធា

កសាងវិហារ យកបុណ្យទៅមុខ ។

អ្នកទូលថា:

ឧណ្ហានាងណ្ហា! អ្នកថ្វាយអាជ្ញែន

មែនហើយ!ៗ ។

យើងសូមផ្តើការសង្កេតស្រាវជ្រាវរកដើមកំណើតល្បែងត្រុដិ លើអ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រ, ឯចំណែកយើងសន្និដ្ឋានថា ល្បែងត្រុដិពាក់ព័ន្ធដោយរឿងនិទានមួយក្នុងសាស្ត្រសុបិនដែលមានដំណាលថា:

"កាលពីព្រេងនាយ មានខេសរទេម្នាក់ឈ្មោះ ព្រាន ប៊ុន ប្រពន្ធ "ឈ្មោះនាង នមា" ។ រៀងមួយ ព្រាន ប៊ុន ចាញ់ចានស្តេច ប្រើស "មួយឈ្មោះនិគ្រោធម្រឹគ មានពេមភ្នំដូចមាស ស្មែងភ្នំដូចកែវ ។ "ព្រានប៊ុន យកស្បែកនិងស្មែងប្រើសនោះ ទៅថ្វាយព្រះរាជា។ ទ្រង់ "ព្រះរាជទានយសសក្តិជាចៅហ្វាយខែត្រ ។"

យើងសន្និដ្ឋានថា ដល់ព្រាន ប៊ុន បានធ្វើជាចៅហ្វាយខែត្របាន បង្កើតល្បែងត្រុដិនេះឡើង បានជាក្នុងផ្ទៃល្បែងនេះមានន័យ ២ យ៉ាង គួរឲ្យយើងសង្កេតហើយជឿបានថាប្រាកដជាព្រាន ប៊ុន នោះបង្កើតឡើងគឺព្រោះ :

- ន័យទី ១ ដំនុកច្រៀងត្រុដិតាំងប៉ុន្មាន នោះនៅខែត្រសៀមរាបក្តី ចាត់ដំបងក្តី សុទ្ធតែមានពាក្យមួយបទថា "ត្រុដិនេះ អង្គឺត្រុដិអាយ ត្រុដិលោកចៅហ្វាយ ប្រើខ្ញុំមកលេង" ដូច្នេះជាដរាប;

- ន័យទី ២ ល្បែងត្រុដិតាមតែនៅទីណាក៏ឥតមានលេងរឿងអ្វីវែងដូចល្ខោនទេ, មានតែលេងធ្វើព្រានព្រៃចាញ់ប្រើសដកយកស្មែងមកលក់ឲ្យអ្នកមើល ។ ឲ្យប្រាក់ទិវគ្គនានាដល់ពួកត្រុដិ ហើយយកអំបោះចងដៃពួកត្រុដិ យកវេទមន្តប្រស់ព្រំឲ្យពួកត្រុដិ ហើយពួកត្រុដិច្រៀងឲ្យតារអ្នកមើល ។

មួយទៀត យើងសន្និដ្ឋានថា ល្បែងត្រុដជាល្បែងខ្មែរសុទ្ធ មានដើមកំណើតនៅស្រុកខ្មែរ សម័យអង្គរ ព្រោះមានន័យគួរឲ្យដឿឃាន ២ យ៉ាង គឺ

– ន័យទី ១ អ្នកស្រុកសៀមកាបសត្វថ្ងៃនេះនៅពាប់អានល្បែងត្រុដណាស់ តែដឹងដល់ថ្ងៃចូលឆ្នាំ តែងត្រៀមប្រជាប់លេងសត្វគ្រប់ ដល់ថ្ងៃចូលឆ្នាំតែងចេញលេងតាមភូមិស្រុក, លុះដល់ថ្ងៃឡើងសក្តិតែងនាំគ្នាទៅលេងថ្វាយឯនតវត្តជាទំនៀមពាល់ឆ្នាំ;

– ន័យទី ២ ទំនុកច្រៀងត្រុដនាំងប៉ុន្មាន ទោះនៅខែត្រសៀមកាបក្តី ចាត់ដំបងក្តី សុទ្ធតែមានពាក្យមួយបទថា "ត្រុដនេះ អង្គឺត្រុដអាយ ត្រុដលោកទៅហ្វាយ ប្រើខ្ញុំមកលេង" ដូចគ្នាគ្រប់ស្រុក, សូម្បីស្រុកសុរ៉ិនដែលតាមឈ្មោះ ព្រឹម នៅស្រុកនោះឲ្យការណ៍ថា: ស្រុកសុរ៉ិនឯណោះពិតមែនតែចាននៅសៀមយូរហើយ ប៉ុន្តែសត្វថ្ងៃនេះនៅតែមានទំនុកច្រៀងមួយបទជាពាក្យខ្មែរសុទ្ធថា "ត្រុដនេះ អង្គឺត្រុដអាយ ត្រុដលោកទៅហ្វាយ ប្រើខ្ញុំមកលេង" ត្រូវគ្នាបេះបិទនឹងទំនុកមួយបទនៅស្រុកខ្មែរឯនេះដែរ ។

យើងសន្និដ្ឋានថា នៅប្រទេសកម្ពុជាយើងសម័យបុរាណមានល្បែងត្រុដពាសពេញព្រះពុទ្ធអាណាចក្រ, តែសត្វថ្ងៃនេះខែត្រឯទៀតៗល្បែងត្រុដសាបសូន្យរូបអស់លើងទៅហើយ សូម្បីតែឈ្មោះថាល្បែងត្រុដក៏ឥតមាននរណាស្គាល់ផង នៅតែខែត្រសៀមកាបជាទីត្រូវចាស់មួយខេ

មានល្បែងត្រុដិច្រើន, ក្រៅពីនេះ វាគ្រប់គ្រាន់មានដែរតែមិនច្រើនដូចសៀមរាប ដែលជាស្រុកកំណើតល្បែងនេះ ។

ដោយល្បែងត្រុដិ ជាល្បាំជំលួមួយគួរទស្សនា, យើងយល់ថាប្រទេសខ្មែរគួរតែរក្សាទុកកុំឲ្យបាត់បង់ ហើយគួរតែបង្កើតឡើងវិញម្តងល្បែងនេះឲ្យមានគ្រប់ខែគ្រឿងទាំងព្រះរាជអាណាចក្រកម្ពុជាផង ប៉ុន្តែពួកអ្នកលេងត្រុដិគួរព្រើសមេ្រកចំពាក់ឲ្យល្អសមរម្យឲ្យថ្លៃថ្នូរ ហើយឲ្យសមតាមសម័យបុរាណទំនើបចុងប្បន្នផង ដើម្បីញ៉ាំងអារម្មណ៍ខ្មែរឲ្យមានវឌ្ឍនភាពក្នុងលោកតទៅ ។

បំណាប់កើតមកជាមនុស្សត្រូវធ្វើទ្រុងក្រកូលរុងរឿង

២៦ – អ្នកណាកើតមកមិនបានលើករង្វែកូលខ្លួនឲ្យខ្ពស់ដូចទង់ជ័យលើកំពូលដងកើតទេ អ្នកនោះកើតមកម្ចងនឹងគេ តើបានប្រយោជន៍អ្វី? បានតែនាំតែបំផ្លាញរ៉ៃក្រឡៃនៃមាតាខ្លួនប៉ុណ្ណោះ ។

ក្នុងសង្ឃវដ្តដែលប្រព្រឹត្តកន្លងទៅនេះ នរណាមួយស្លាប់ហើយមិនកើតទៀត? ក្នុងលោកនេះ អ្នកណាឆ្លៀវឲ្យកើតសេចក្តីរុងរឿងក្នុងត្រកូលដោយវៃ្រលែង អ្នកនោះលោកពប់ថាកើតមកជាមនុស្សមែនទែន ។

ពិធីអនុស្សាវរីយ៍មហាសន្និបាតលើកទី ១២ នៃមន្ត្រីសង្ឃសំរាប់ឆ្នាំ ១៩៥៦ នៅមជ្ឈិមព្រះសទ្ធម្ម ក្នុងវត្តព្រះកែវមកុដ

របស់ពុទ្ធសាសនបណ្ឌិត្យ

ពិធីអនុស្សាវរីយ៍មហាសន្និបាតលើកទី ១២ នៃមន្ត្រីសង្ឃសំរាប់ឆ្នាំ ១៩៥៦ ដូចមានសេចក្តីរៀបរាប់តទៅនេះ ៖

នៅព្រឹកថ្ងៃទី ១០ មករា វេលាម៉ោង ៧ មានការជួបជុំព្រះសង្ឃនៅមជ្ឈិមព្រះសទ្ធម្មក្នុងវត្តព្រះកែវមកុដ ដែលត្រូវស្មាធ្យាយន័ចំរើនសត្តប្បការណ៍ ទ្វេសូត្រយប្រកបដោយកុសលចំពោះព្រះបិតរនៅចេតិយព្រះកែវមកុដ ។ នៅម៉ោង ៨ ទំនឹង ១៥ នាទី ឯកឧត្តមប្រធានវដ្ឋសភា, ឯកឧត្តមប្រធានក្រុមប្រឹក្សាព្រះពុទ្ធសាសនិកជន, គណៈរដ្ឋមន្ត្រី, រដ្ឋលេខាធិការក្រសួងធម្មការ, សមាជិកសភាតំណាងរាស្ត្រ, ឯកឧត្តមទេសាភិបាលក្រុង ព្រមទាំងឥស្សរជនជាពុទ្ធបរិស័ទច្រើនទៀត បានអញ្ជើញទៅដល់ចាំក្រាបថ្វាយបង្គំគាល់ព្រះគុណជាអម្ចាស់ជីវិតលើត្បូង នៅមុខព្រះហ៊ិរិព្រះកែវមកុដ ។

នៅម៉ោង ៨ ទំនឹង ៣០ នាទី ព្រះគុណជាអម្ចាស់ជីវិតលើត្បូងបានស្តេចយាងចេញពីព្រះបរមរាជវាំង ដោយមានអ្នកនាំកញ្ចុះកញ្ចាំងវរៈ-

វៀងជ័យ. សមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រិយ៍ ព្រមទាំងព្រះ
រាជបរិពារបានហែហមអមព្រះរាជដំណើរផង ។ ខៅពេលដែលព្រះនរបតី
ស្តេចយាងចុះពីព្រះទីនាំងរថយន្ត ឯកឧត្តម ខ្ញុំ-ប៉ាញ រដ្ឋលេខាធិការ
ក្រសួងធម្មការបានក្រាបថ្វាយបង្គំ ហើយប្រគេនសាតាំងពីរ ទឹងឯក-
ឧត្តមនាយករដ្ឋមន្ត្រីក្រាបថ្វាយបង្គំខៅទីនោះដែរ ។ បន្ទាប់មកក្រុមតួរ-
តន្ត្រីព្រះរាជទ្រព្យបានសម្តែងព្រះរាជាទីគោរព ហើយបន្ទឹបទលីលាជូន
ព្រះរាជដំណើរ ស្តេចយាងចូលខៅគាន់មន្ទីរព្រះសន្ទម្ន ដែលមានមន្ត្រី
សង្ឃទាំងឡាយគង់ខៅទំនោរ ។

ក្រោយដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ក្រាបថ្វាយ
បង្គំព្រះសង្ឃរួចហើយ ព្រះនរបតីទ្រង់មានព្រះរាជឧស្សាហ៍ទទួលព្រះអំណរ
ប្រសើយយ៉ាងជិតស្និទ្ធខៅរកមន្ត្រីសង្ឃ ដោយព្រះកត្តញ្ញូញឹមព្រមទាំង
ព្រះរាជហឫទ័យទ្រង់រីករាយយ៉ាងក្រៃលែង តមកឯកឧត្តម ខ្ញុំ-ប៉ាញ
រដ្ឋលេខាធិការក្រសួងធម្មការ អញ្ជើញចាប់ផ្តើមសុន្ទរកថាមានសេចក្តី
ដូចតខៅនេះ ៖

សូមព្រះតេជះដ៏កល់លើត្បូង
សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត
សូមទ្រង់ជ្រាបក្រាមល្អដ៏ធូលីព្រះបាទ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានទទួលខុសត្រូវព្រះរាជអំណរដ៏ជ្រាល
ជ្រៅ ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលបានស្តេចយាង

មកជាព្រះពាជាធិបតី ក្នុងឧកាសពិធីអនុសាវនៈមហាសន្និបាតមន្ត្រីសង្ឃ
ដ៏ ១២ សម្រាប់ឆ្នាំមមែនេះ ដោយមនោសញ្ចេតនាដ៏ឧត្តម ។

ក្នុងការៈជាដំបូងនេះ, ខ្ញុំលព្រះបង្គំជាខ្ញុំសូមព្រះពជ្ឈាន ព្រះបរម-
ពជវរៈកាសល្អង់ជូលិព្រះបាទ ដើម្បីប្រសើយទឹងព្រះមហាវេភន្តេរៈ
ទាំងឡាយ មានសម្តេចជាប្រធានដែលបានទិមន្តមកកាន់មហាសន្និបាត
នេះ ដោយបំណងទឹងឲ្យលជល់ព្រះសង្ឃទាំងឡាយឲ្យបានជ្រាបច្បាស់
នូវកិច្ចការសំខាន់ ។ ខាងពុទ្ធចក្រ ដែលជាប់ទាក់ទងនឹងអាណាចក្រក្នុង
កាលៈទេសៈនេះ ។

សូមថ្វាយបង្គំសម្តេចព្រមទាំងព្រះវេភន្តេរៈទាំងឡាយគ្រប់ព្រះអង្គ
ដោយគោរព ។

ខ្ញុំព្រះករុណាសូមទទួលអំណរគុណដ៏វៃលែង ចំពោះសម្តេច
ព្រមទាំងព្រះករុណាគ្រប់ព្រះអង្គដែលបានទិមន្តមកកាន់ព្រះពាធិអនុ-
សាវនៈមហាសន្និបាតនេះ ព្រោះការជួបជុំនេះ ពុកជាទស្សនាទុក្ខវិយៈ
មួយដ៏ប្រសើរ ដែលជាហេតុញ៉ាំងព្រះករុណាគ្រប់ព្រះអង្គឲ្យបានជ្រាប
ច្បាស់ នូវកិច្ចការទាំងពួងខាងពុទ្ធចក្រ ដែលទាក់ទងនឹងអាណាចក្រ ។

សម្តេច !

ព្រះករុណាគ្រប់ព្រះអង្គ !

ប្រទេសកម្ពុជា ដែលមានព្រះពុទ្ធសាសនាប្រតិស្ឋាននៅនេះ ពុក
ជាតំបូមួយប្រសើរផុត ព្រោះព្រះពុទ្ធបវរគ្រូចែងខ្ចាន់សត្វលោកឲ្យដើរ
ត្រង់ទៅរកសេចក្តីសុខស្ងាត់ គឺសន្តិភាព ដែលមនុស្សក្នុងសាកលនិយម

ពេញចិត្តគ្រប់គ្នា ព្រោះព្រះអង្គទ្រង់ប្រដៅសត្វ ទាំងយកកម្មផល ដែលសត្វធ្វើល្អអាក្រក់មកជាគោល ដូចព្រះកុណ្ឌគ្រប់ព្រះអង្គជ្រាបស្រាប់ហើយ ។ ខ្ញុំព្រះករុណាមានសេចក្តីសង្ឃឹមយ៉ាងមាំលើព្រះសង្ឃ ដែលជាសិស្សផ្ទាល់នៃព្រះពុទ្ធដ៏ឯកគ្រហស្ថថា ទីឆ៍ប្រកាន់យកសេចក្តីប្រតិបត្តិខាងសន្តិភាព តាមតម្រាយនៃព្រះពុទ្ធដែលព្រះអង្គបានគ្រាយទុកឲ្យដើរជាប្រាកដ ។

ដោយអាស្រ័យហេតុនេះហើយ បានជាព្រះពុទ្ធសាសនាមានអាយុឋិតនៅក្នុងសាកលលោក ដរាបមកដល់សត្វថ្ងៃនេះ ហើយផ្សាយឥទ្ធានុភាពរឹតសាយពេញសាកលលោកទាំងមូលរហូតដល់ជនជាតិអ៊ីរុបេ ដូចជាជាតិបាកាំង, អង់គ្លេស, អាមេរិកាំង, អូស្ត្រាលីជាដើម គេនិយមជឿតាមកាន់តែច្រើនឡើងហើយ ដោយគេយល់ថា ព្រះពុទ្ធសាសនា ជាសាសនាធ្វើមនុស្សឲ្យសប់សាត់ ប្រាសចាកការសង្កត់សង្កិនបៀតបៀនគ្នាទៅវិញទៅមក ដូចព្រះកុណ្ឌគ្រប់ព្រះអង្គជ្រាបស្រាប់ហើយ ។

លំដាប់តទៅនេះ ខ្ញុំព្រះករុណាសូមពិតទូលព្រះតេជព្រះគុណគ្រប់ព្រះអង្គ ឲ្យបានជ្រាបច្បាស់អំពីល្បឿនៃការសិក្សាប៉ែកខាងព្រះពុទ្ធសាសនា ដូចមានសេចក្តីតទៅនេះ ៖

១— អំពីសាលាបាលីវង់: សាលាបាលីវង់គ្រប់ខែត្តទឹងក្រុងមានចំនួន ៣៩៧សាលា ឯសិស្សនៃសាលានេះមានចំនួន ៤.៤៧៩រូប ។ ឥឡូវនេះ ក្រសួងធម្មការបានបង្កើនការសិក្សាគរុកោសល្យ សម្រាប់អប់រំពួកអាចារ្យបង្រៀនសាលាបាលីវង់ចាស់ចំនួន ៣០០ រូប ដើម្បីញុំាង

ការសិក្សានៅសាលានេះ ឲ្យមានរបៀបរៀបចំដែនល្អតាមប្រកាសក្រសួងធម្មការលេខ ៤.៥២៣ ចុះថ្ងៃ ២៣ តុលា ១៩៥៥ ។

២- អំពីពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត: ព្រះកុណាជាអម្ចាស់ដីវត្តលើភ្នំ ទ្រង់សព្វព្រះហឫទ័យ ព្រះបរមរាជានុញ្ញាតឲ្យកែប្រែសាលាបាលីជាន់ខ្ពស់ជាគ្រឹះស្ថានមធ្យមសិក្សា ហើយផ្លាស់នាមបញ្ជាត្តិនៃសាលានេះជា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត វិញ តាមសេចក្តីក្រាបបង្គំទូលស្នើនៃក្រសួងធម្មការ ។ សព្វថ្ងៃនេះកំពុងរីរាករមធ្យោបាយបង្កើតគ្រឹះស្ថានមធ្យមសិក្សាឲ្យបានចំនួន ៥ កន្លែងទៀត នៅទីប្រជុំជនវែតនានា ដើម្បីអនុគ្រោះដល់សិស្សដែលប្រឡងជាប់សាលាបាលីរួចហើយ គ្មានកន្លែងសម្រាប់រៀនបន្តវិជ្ជាទៀត ព្រោះគ្រឹះស្ថានមធ្យមសិក្សាបច្ចុប្បន្ននេះ ទទួលបន្ទុកសិស្សឲ្យចូលរៀនក្នុងមួយឆ្នាំ ។ បានត្រឹមតែ ១៥០ រូបប៉ុណ្ណោះ ហើយសិស្សដែលប្រឡងជាប់សាលាបាលីរួចក្នុងមួយឆ្នាំ ។ មានចំនួនដល់ទៅ ២ ពាន់ជាយរូប, ឃើញថាមិនមានតុល្យភាពសោះ ។

៣- អំពីមហាវិទ្យាល័យ: កាលក្នុងឆ្នាំ ១៩៥៥ គហបតី បេ - យាន ពាណិជនៅភ្នំពេញ បានធ្វើពិធីសម្ពោធរោងប្រគល់ជូនព្រះពុទ្ធជ្ជកិច្ចាល័យ ឬគ្រឹះស្ថាន ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុពុទ្ធជ ១ ខ្នង មានថ្នាក់ ៦ ។ គ្រឹះស្ថាននេះ គហបតី បេ - យាន បានកសាងចំណាយជនជាន់ជ្រួលខ្លួន សាងទុក្ខិសចំពោះព្រះពុទ្ធសាសនា ដោយមាន

សម្តេចព្រះទេបយុវរាជ កាលព្រះអង្គបិតនៅកន្លងសិរីរាជសម្បត្តិនៅឡើយ ទ្រង់មានព្រះរាជបញ្ជាឲ្យរាជរដ្ឋាភិបាលចំណាយដើរនេះ សម្រាប់សង់មហាវិទ្យាល័យ ឬនជាតណាតម្មការឬនសម្រេចសូមព្រះរាជានុញ្ញាតព្រះបរមនាមព្រះអង្គជាក់ថា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។ មិនតែប៉ុណ្ណោះសោត ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ បរិច្ចាគនូវព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ១ សែនរៀលទៀត ក្នុងការកសាងសាលានេះ ។

តមក, ព្រះអង្គទ្រង់ប្រោសព្រះរាជទានបន្ថែមទូរាប់អំណោយ ១ លាន ៥ សែនរៀល ដើម្បីកសាងនូវគ្រឹះស្ថានមហាវិទ្យាល័យ ១ ខ្នងទៀត ដែលកំពុងតែចាត់ការធ្វើសព្វថ្ងៃនេះ ។ មួយវិញទៀត មូលនិធិអាស៊ីបានសុំជួលជាបច្ចុប្បន្នក្នុងការកសាងគ្រឹះស្ថាននេះផង ។ ឯការសិក្សានៅមហាវិទ្យាល័យនេះ ប្រហែលជានឹងបានបើកបង្រៀនក្នុងរវាងឆ្នាំ ១៩៥៧ ឬ ១៩៥៨ ព្រោះក្បួនច្បាប់សម្រាប់បង្រៀននៅមហាវិទ្យាល័យ កំពុងមិនទាន់មាននៅឡើយផង ។

ដោយហេតុនេះហើយ ឬនជាព្រះរាជរដ្ឋាភិបាល ឬនចាត់ព្រះតេជព្រះគុណ ព្រះ ញាណ៉ាវ័ង្ស ហួត-តាត ជាអគ្គាធិការ នៃក្រុមអធិការដ្ឋាននិងជាក្រុមអភិបាលនៃគ្រឹះស្ថានសិក្សាបាលីខាងគណៈមហានិកាយ ឲ្យនិមន្តទៅកាន់ប្រទេសថៃចំនួន ២៩ ថ្ងៃ ពីថ្ងៃទី ៧ ធ្នូ ១៩៥៥ ដោយមានលោក យឹម-វ៉ែន ជាទីប្រឹក្សាបច្ចេកទេសទំនើលេខាធិការម្នាក់ ទៅអមជាមួយផង ដើម្បីពិនិត្យមើលការសិក្សាខាងធម្មវិន័យព្រះពុទ្ធសាសនាក្នុងប្រទេសនេះ ។

៤- អំពីសាលាធម្មវិន័យ: សាលានេះ កើតឡើងដោយព្រះ
ពជគ្រិត្យលេខ ២១៤ ចុះថ្ងៃ ២៨ សីហា ១៩៥០ មានគុណានុភាពអាច
ញុំាងសេចក្តីប្រតិបត្តិនៃពុទ្ធសាសនិក ឲ្យមានបែបតែមួយ ដើម្បីកំចាត់
បង់នូវការខាសខែងខ្វែងគំនិតគ្នាចំពោះធម៌វិន័យ ដើម្បីញុំាងព្រះពុទ្ធ-
សាសនា ឲ្យមានភាន្ទីរស្ទុំដ៏រុងរឿងទៅអនាគតជង ។

ព្រះគុណា គ្រប់ព្រះអង្គ! ការសិក្សាខៅប្រទេសកម្ពុជា ចែកជា ២
ប្រភេទ គឺប្រភេទទី ១ បានដល់ផ្លូវលោក គឺការសិក្សាខាងក្រសួង
សិក្សាធិការ, ខាងផ្លូវធម៌បានដល់សាលាបាលីនិងសាលាធម្មវិន័យ ។
ការសិក្សាទាំង ២ ប្រភេទនេះមានគុណានុភាពអាចកំចាត់បង់ នូវសេចក្តី
ល្ងង់ខ្លៅដែលដេកគប់ខៅក្នុងសន្តាន នៃប្រជាជនគ្រប់រូប ឬជាអលង្ការ
សម្រាប់តាក់តែងមនុស្សឲ្យខៅជាមនុស្សពេញលេញ ជាអ្នកមាន
សមត្ថភាពបំបួលិត្តដល់ការ ដើម្បីឲ្យបុគ្គលមានគុណធម៌ដ៏ល្អ ឲ្យដឹង
ខ្នួនច្បាស់ក្នុងការគ្រប់គ្រងដីវិត ទាំងដើម្បីត្រៀមឲ្យជាពលរដ្ឋដ៏ល្អ ជាកិច្ច
សម្រាប់អប់រំចិត្តយុវជន ឲ្យចេះដឹងច្រើនរើសសេចក្តីល្អទាំងពួង ។

ហេតុនេះ ការសិក្សា គួរចាត់ថាជាកិច្ចមួយ ប្រចាំជីវិតមនុស្សគ្រប់
រូប មិនថាស្ត្រីបុរសព្រះសង្ឃ ឬគ្រហស្ថឡើយ ។

ឯការសិក្សានោះ ត្រូវប្រែកថាដោយអង្គ ៣ គឺ:

១- បរិយាសិក្ខា បានដល់ការសិក្សាអប់រំផ្លូវកាយនិងផ្លូវចិត្ត
ឲ្យបានខៅជាអ្នកដឹងខុសត្រូវ តាំងខៅក្នុងសីលធម៌ដ៏ល្អ ដើម្បីជា

ឧបការណ៍ដឹកនាំឲ្យកើតសេចក្តីសុខសេចក្តីចំរើនដល់ខ្លួន ដល់គ្រួសារឬដល់សង្គម ។

២- ពុទ្ធិសិក្សា ជានដល់ការសិក្សាផ្លូវពិត្យា គឺចំណេះវិជ្ជាគ្រប់យ៉ាងដើម្បីឲ្យកើតសេចក្តីចេះដឹងឈ្លាសវៃ ក្នុងការប្រកបដីវិតកម្ម តួយ៉ាងដូចជាបង្រៀនវិជ្ជាផ្សេង ។ អក្សរសាស្ត្រ តារាសាស្ត្រ រហូតដល់វិទ្យាសាស្ត្រជាបំផុត ។

៣- ពលសិក្សា ជានដល់ការសិក្សាខាងផ្លូវកាយឬហាត់ឲ្យមានរាងកាយមាំមួនដើម្បីការពារពេតាព្យាធិពាំងពួង មានកំលាំងរឹងប៉ឹងល្អ ។

អត្ថនៃការសិក្សាទាំង ៣ ប្រការនេះ ជាគុណធម៌ដ៏ល្អឬវិសុទ្ធអារ្យប្រទេសពាំងឡាយ ទំាយមប្រការនំាយកថាជាគុណវិសេសរបស់ប្រទេសជាតិគេគ្រប់គ្នា ។

ដូច្នេះ សូមព្រះកុរណាគ្រប់ព្រះអង្គជាមន្ត្រីសង្ឃ ជួយទប្ទូលព្រះពុទ្ធសាសនា ដោយប្រើមធ្យោបាយរំលឹកជាស់តឿន ដល់ព្រះសង្ឃគ្រប់វត្ត ឲ្យចំយកព្រះទ័យទុកជាក់ចំរៀនសូត្រធម៌វិន័យប្រចំនព្រះអង្គឡើង ព្រោះធម្មវិន័យនេះហើយ ជាឫសគល់ព្រះពុទ្ធសាសនា ។

ក្នុងទីអវសានេះ, ខ្ញុំ [illegible]ព្រះបង្គំជាខ្ញុំសូមទទួលព្រះពរជ័យកុសលថ្វាយចំពោះព្រះកុរណាជាអម្ចាស់ដ៏វិតលើត្បូង ព្រមទាំងសម្តេចព្រះមហាក្សត្រិយានី សូមព្រះអង្គស្ថិតនៅជាសុខក្នុងសិរីរាជសម្បត្តិ អស់

កាលជាអង្វែងតទៅ, ១ ទៀត ខ្ញុំលព្រះបង្គំជាខ្ញុំ សូមទទួលនូវព្រះពរជ័យនេះ ថ្វាយសម្តេចព្រះទេពយុវរាជ ព្រមទាំងព្រះពរជ័យវង្សានុវង្ស សូមទ្រង់ប្រកបដោយសេចក្តីសុខចំរើនគ្រប់ប្រការ ។

សូមព្រះពុទ្ធសាសនារុងរឿងចំរើនឡើងជាលំដាប់ ។

សូមឲ្យប្រជាជនទឹងអស់លោកជាមន្ត្រី គ្រប់តំណែង តាំងនៅក្នុងសាមគ្គីធម្មិកូតវៃគ្នាកសាងមាតុប្រទេស ជាមួយសម្តេចព្រះទេពយុវរាជ ដែលព្រះអង្គជាបិតានៃឯកភាជ្យបរិបូណ៌ ចាប់ពីពេលនេះតទៅ ។

នៅពេលដែលចប់នូវសេចក្តីថ្លែងសុន្ទរកថានៃឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការហើយ ព្រះតេជព្រះគុណព្រះវន័ត្ត អ៊ុំ-ឌួត មេគណវត្តពោធិវ៌លវែតជាត់ដំបង និមន្តថ្លែងសុន្ទរកថាឆ្លើយតបវិញ មានសេចក្តីដូចតទៅនេះ ៖

សុន្ទរកថា

សូមថ្វាយព្រះពរបរមបពិត្រព្រះករុណាជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាប ។

អាត្មាភាព តាងនាមមន្ត្រីសង្ឃគ្រប់តំណែង ដែលបានទទួលមកកាន់អនុសំវច្ឆរៈមហាសន្និបាតជាតំរាប់ទី ១២ នេះ សូមព្រះពរជ័យព្រះបរមពជវរកោសថ្វាយព្រះពរជ័យ ដោយសេចក្តីគោរពដ៏ក្រៃលែងចំពោះព្រះពុទ្ធសាសនា ចំពោះព្រះករុណាជាអម្ចាស់ជីវិត ដោយសេចក្តីសង្ខេបថ្វាយដូចតទៅនេះ ៖

ពិធីបុណ្យអនុសំវច្ឆរៈមហាសន្និបាត ជាពិធីបុណ្យដែលពជវរដ្ឋ-

តំណាលបានរៀបចំធ្វើរៀងរាល់ឆ្នាំ ត្រាមព្រះពាជាធិបតីភាពនៃព្រះគុណ
ជាអម្ចាស់ដ៏វិតថាំងពីព្រះអង្គ ។ ពិធីបុណ្យនេះ មានទុកជាមប្រយោជន៍
យ៉ាងសំខាន់ក្នុងការប្រែស្រួយចាក់ទង្គិច រវាងពុទ្ធបរិស័ទ្ធ
ហើយជាពិសេសបំផុតក្នុងការណែនាំឲ្យព្រះសង្ឃកាន់ឡាយព្រម
ពាំងពុទ្ធបរិស័ទ្ធ ក្នុងព្រះពាជអាណាចក្រ ឲ្យយើញជាក់ស្តែង នូវ
សេចក្តីចំរុងចំរើននៃព្រះពុទ្ធសាសនា នូវតម្លៃពុទ្ធភាពនៃព្រះពុទ្ធសាសនា
ដែលវិតសាយទៅឆ្ងាយជាលំដាប់ ដោយសារព្រះពាជហឫទ័យដ៏ធំរបស់ព្រះ
ព្រះគុណជាអម្ចាស់ដ៏វិត ជាឯកអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។ សេចក្តីដូច
មានក្នុងសុន្ទរកថា ដែលឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ បានក្រាបបង្គំ
ទូលថ្វាយក្នុងពេលអម្បាញ់មិញនេះ ។

អាត្មាភាពសូមថ្លែងនូវសេចក្តីគោរពដ៏លើសលុបចំពោះ
ព្រះពុទ្ធសាសនា ទឹងសូមថ្លែងនូវសេចក្តីកតញ្ញូដ៏ស្មោះត្រង់ចំពោះព្រះ
គុណាធិគុណនៃព្រះគុណជាអម្ចាស់ដ៏វិត ចំពោះសម្តេចព្រះមហា-
ក្សត្រីយានី ព្រមទាំងសម្តេចព្រះឧបយុវរាជ ជាអតីតព្រះមហាវីរក្សត្រ
នៃប្រទេសកម្ពុជា ដោយប្រជាវិតប្រកាន់ខ្ជាប់តាមព្រះពុទ្ធសាសនា ទឹង
ព្រះពរជ័យបារមីនៃព្រះគុណជាអម្ចាស់ដ៏វិតគ្រប់ព្រះអង្គជាជាងប ។

នៅទីបញ្ចប់នេះ គុណនៃសីលធម៌ឯណា ដែលអាត្មាភាពរាល់រូប
ព្រមទាំងសិស្សានុសិស្ស ទាំងពុទ្ធបរិស័ទ្ធទាំងឡាយជាច្រើនវត្តនិមួយ ។
ក្នុងកម្ពុជរដ្ឋទាំងមូល ជានឬត្រឹមត្រូវតិបត្តិ ដ៏ត្រឹមត្រូវតាមសំណូនព្រះ
ពុទ្ធសាសនា សូមគុណសីលធម៌ដ៏ប្រសើរទាំងនោះ ជួយអភិបាលរក្សា

ព្រះករុណាជាអម្ចាស់ជីវិត សម្តេចព្រះមហាក្សត្រិយានីព្រមទាំងសម្តេចព្រះនរបយុវរាជ ខ្ញុំនឹងព្រះពរជារឿយៗនូវឥរិយាបថអត្តភាពសោភាគ្រប់ប្រការ សូមមានសិរីសួស្តីជ័យជំនះជានិច្ចរាល់ៗ សូមឲ្យប្រទេសកម្ពុជាដែលបានឯករាជ្យបរិបូណ៌ដែលបានចូលធ្វើជាសមាជិកពេញទី នៃអង្គការសហប្រជាជាតិហើយនេះ បានប្រកបដោយសន្តិភាព និងការរីកចម្រើនដ៏ប្រសើរសាន ។

ក្រោយដែលចប់សេចក្តីសុខទុក្ខរបស់ព្រះតេជព្រះគុណ ព្រះវន្តមេគណខេត្តបាត់ដំបងហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទទឹមានព្រះពរឧត្តុង្គចំពោះមន្ត្រីសង្ឃទាំងអស់ថា ៖

ខ្ញុំករុណាមានសេចក្តីត្រេកអរយ៉ាងក្រៃលែង ដែលខៅឧកាសនេះជាឧកាសមួយដ៏ក្រមណាស់ ដែលទាំងឲ្យខ្ញុំករុណាបានជួបព្រះតក្កថ្វាយបង្គំព្រះករុណាគ្រប់ព្រះអង្គជាមន្ត្រីសង្ឃខៅពេលនេះ ខ្ញុំករុណាសូមផ្ញើនូវការបើបាច់ថែរក្សាព្រះពុទ្ធសាសនាឲ្យបានរឿបរយល្អ ឲ្យសមតាមហានៈប្រទេសឯករាជ្យ ហើយសូមផ្តាំចំពោះគណៈជ្ជបាពុទ្ធបរិសទ្យ សូមឲ្យជួយជុំសាងតំព្រះពុទ្ធសាសនា ឲ្យតែតែមានវិរិយៈរឿងចំរើនតទៅមុខទៀត ខ្ញុំករុណាសូមប្រគេនពរសព្វសាធុការចំពោះព្រះករុណាគ្រប់ព្រះអង្គ សូមឲ្យបានជួបនូវសេចក្តីសុខចំរើនអស់កាលតរៃទៅ ។

ខៅពេលដែលចប់ព្រះពរឧត្តុង្គរបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងហើយ ព្រះសង្ឃទាំងអស់ក៏ទទឹមន្តស្មូធ្យាយនធម្មជ័យន្តោប្រសិទ្ធពរ ថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនូវជ័យមង្គលទាំងអស់ ។

កូនពេលដដែលនោះ ព្រះមហាក្សត្រិយ៍ទ្រង់សព្វព្រះពេជហឫទ័យ ទ្រង់ព្រះពេជសណ្តាប់ធម៌ព្រះសង្ឃនិមន្តមកពីលង្កាទ្វីប ព្រះនរបតីទ្រង់និមន្តព្រះសង្ឃចាំង ៣ ព្រះអង្គស្វាធ្យាយន៍ជាព្រះសណ្តាប់ដែលមានអត្ថរសខាងភាសាបាលី ដូចជាព្រះសង្ឃប្រទេសកម្ពុជាយើងដែរ ។

នៅម៉ោង ៩ ទឹង ៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងថ្វាយបង្គំលាព្រះសង្ឃ ស្តេចយាងចូលព្រះបរមរាជវាំងវិញ ដោយមានព្រះពេជបរិពារដដែលហែហមអមព្រះអង្គផង ។ ចំណែកឥស្សរជនទាំងអស់ក៏អញ្ជើញទៅកាន់ដំណែងរៀងខ្លួនវិញ ។ នៅម៉ោង ១០ ទឹង ៣០ នាទី ប្រគេនភត្តកង្ហរព្រះបរមនាម នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងដល់ព្រះសង្ឃចំពោះមុខវដ្ឋលេខាធិការកែសួនធម្មការ ព្រមទាំងមន្ត្រីកែសួនធម្មការ-ឧបាសក-ឧបាសិកានៅមហាកុដរាត្តឧណ្ហាលោម ។

កូនបែបណាសូម្បីអ្នកធំក៏គោរពដែរ?

៣០— កូនណា សូម្បីអ្នកធំទាំងឡាយក៏គោរពបូជាដែរ អ្នកប្រាជ្ញលោកវិលឹកពុកថា មាតាដែលពង្រៃនៃកូននោះ ជាមាតាដែលមានគុណធ្ងន់ បុគ្គលគួរគោរពកន្ទងមិនបាន ។

បញ្ចតន្ត្រៈ

ក្រុមជំនុំវិនិច្ឆ័យទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

តាន្តិសន្ទិយា

ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៨ លេខ ២ ខែកុម្ភៈ ព. ស. ២៤៩៨ គ. ស. ១៩៥៦



តម្រងសង្ខេប

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា		
— ការបួសក្នុងពុទ្ធសាសនា	លោកស្រី - អ៊ុំ	១០៣
— ការចំរើនទំនឹងការសោបសូន្យធម្មវិន័យក្នុងពុទ្ធសាសនា	ព្រះទេពសង្ឃ កឹម - ស្ងួរ	១១១
— សតិសម្បជញ្ញកថា	ព្រះជាឡាត់ សុង - ស៊ីវ	១១៨
— បញ្ញាសជាតក ភាគទី ៤ (តមក) ...	បណ្ឌិត្យមហា ឈឹម - ស៊ុមន៍ ...	១២៩
ផ្នែកអក្សរសាស្ត្រ		
— ទំនៀមទម្លាប់ស្ត្រីនៅស្រុកទីបេ	អ្នកស្រី សារិះយ៉ាន	១៤១
— សុភាសិតរាជនីតិ ពាក្យកាព្យ	អ្នកនាងញ៉ា នៅ	១៤៧
— ពេជ្រព្រះរាជា (តមក)	លោក ស៊ិន - ហ៊ាន	១៥៣
— ជឿងសាមកុក (តមក)	នាងញ៉ា ន្ហូ - កន	១៥៩
— ដំណឹងតាមខ្សល់ក្នុងកន្លែង: (ចប់) ..	លោក ផេង - ទ្រីវ	១៦៧
— ជឿងបល្ល័ង្កទិព្យ (តមក)	លោក ភ័ក - ប៊ុក	១៧២
កំណាត់ទឹនប្រែវត្តិការណ៍		
- ព្រះអនិច្ចធម្មនៃសម្តេចព្រះសង្ឃនាយក គណៈធម្មយុត្តិកនិកាយ	លោកប៉ូ - ប៊ូ	១៧៨

មួយឆ្នាំមាន ១២ លេខ — តំលៃជាវ ២៣០,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— L'ordination bouddhique . . .	*M. SREY-OU*	*103*
— Le progrès et la décadence du Bouddhisme	*Vén. KEM-TO*	*111*
— Satisampajannakatha	*Brah Balat SONG-SIV* . . .	*118*
— Pannasajataka vol. 4 (suite) .	*M. CHHIM-SOUM*	*129*

PARTIE LITTERAIRE:

— La coutume des femmes tibétaines	*Mme SRIN-SARIS-YANN* .	*141*
— Subhasitarajaniti (Poème) . .	*Oknha NEOU*	*147*
— Conte "Le Diamant du Raja" (suite)	*M. SIN-HEAN*	*153*
— Histoire de SAMKOK (suite). .	*Oknha NOU-KAN*	*159*
— Le souffle du désert (suite) .	*M. PHENG-CHRIV* . . .	*167*
— Les trente deux récits du TRONE (suite)	*M. RAY BUC*	*182*

NOTES ET CHRONIQUES:

— Décès du Chef de l'Ordre Dhammayuttikanikay	*M. BOU-PO*	*188*

Prix d'abonnement annuel (comprenant 12 numéros) 230$00

សេចក្តីថ្វាយសត្ចសាធុការពរ

សៀវភៅនេះទុំសថ្វាយដោយគោរពចំពោះព្រះរាជពិធីរាជាភិសេក

ខៅទុកាសដ៏ប្រកបដោយសិរីសួស្តីដ៏ឃមង្គលមហាប្រសើរក្នុង
ព្រះពុទ្ធសាសនានិងព្រះពុទ្ធចក្រកម្ពុជា ទិន ព្រះពុទ្ធសាសនាតាំងតាំងតុបម្រើនព្រះដន្ទវស្សា
ពីថ្ងៃទី ២ ដល់ទី ៤ មីនា ១៩៥៦ នៃព្រះគ្រិស្តសាសនាអម្ចាស់ដ៏វិសេសលើសលុប
ទីសម្តេចព្រះមហាក្សត្រីយានី ទ្រង់ឆ្លងឡើងសោយរាជសម្បត្តិ
ក្នុងព្រះរាជអាណាចក្រកម្ពុជា ដែលជាព្រះពុទ្ធសាសនាមានសក្តិណាស
ពីសេសសម្រាំង តំសម្តេចព្រះមហាក្សត្រីយានី បានទ្រង់ទទួលព្រះ
ពុទ្ធសាសនាដែរ ដើម្បីជានិមិត្តរួបជាវិច្ឆេទបំណុតនៃស្តេចខែ្មរ ដែលកន្លង
ពន្យារតាតាំងពីបុរាណកាលមក ពុំធ្លាប់មានព្រះក្សត្រីយានីព្រះអង្គ
ណាមួយ ឡើងគង់លើព្រះរាជបល្ល័ង្ក ជាមួយនឹងព្រះពុទ្ធសាសនា
ដូចជាសម្តេចព្រះមហាក្សត្រីយានីព្រះអង្គនេះឡើយ ហើយដែលជា
សុភមង្គលយ៉ាងក្រៃលែង បង្ហាញឱ្យឃើញជាច្បាស់ថារដ្ឋាភិបាលនេះ ជា
រដ្ឋាភិបាលប្រកបដោយភក្តីសាសនាប្រចេសកម្ពុជា ។

ពុទ្ធសាសនបណ្ឌិត្យ សូមថ្វាយចំពោះលោកឧត្តមក្រុមព្រះចាងវាំង
ព្រះអង្គ ខ្ញុំព្រះអាំង ៤ ប្រការ គឺអាយុ វណ្ណ សុខៈ ពលៈ សូមទ្រង់
គង់ខៅជាបរមសុខក្នុងសិរីភោគសម្បត្តិ ដើម្បីថែរក្សាប្រទេសជាតិ
ឱ្យបានសុខចម្រើនអស់កាលជាអង្វែងតទៅ ។

ពុទ្ធសាសនបណ្ឌិត្យ

ការបួសក្នុងពុទ្ធសាសនា

ស្រី-អ្ញិ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ការបួស ជាការណីយកិច្ច ប្រចាំជីវិតរបស់ពុទ្ធសាសនិកជនជាតិខ្មែរ ជាប់មកយូរកាលណាស់ហើយ ព្រោះការបួស ជាការផ្ចាស់ចិត្តគំនិត ដែលធ្លាប់ពយមាយ សាន់រ័ណ្ឌ ប្រប្លូកប្រប្រែទៅក្នុងរឿងលោក ឲ្យមកតាំងនៅក្នុងអាការស្ងប់ស្ងៀម ។

ការបួស បើបួសជាសាមណេរ ហៅថា បព្វជ្ជា បើបួសជាភិក្ខុ ហៅថា ឧបសម្បទា ។ ប្រពៃណីខ្មែរ កាលកុលបុត្តមានអាយុ ២០ ឆ្នាំ បរិបូណ៌ ដែលជាអាយុនៅក្នុងវ័យ: កាលជាអ្នកមានចិត្តឆ្ងន់ជ្រះ អាចអត់ធន់ចំពោះសេចក្តីស្រេកឃ្លានបាន ក៏ត្រៀមខ្លួនទទឹងបួស ប្រមែប្រមៀបគ្រឿងអដ្ឋបរិក្ខារគឺចីវរ, ស្បង់, សង្ឃាដី, ប៉ាត្រ, កាំបិត, ម្ជុល, ក្អែពន្ធចង្អេះ, តម្រងទឹក; ត្រៀមអដ្ឋបរិក្ខារចាំង ៨ យ៉ាងនេះ ទុកឲ្យគ្រប់គ្រាន់មុនបួសប្រមាណជា ១៥ ថ្ងៃ ឬ ១ ខែ ។

អ្នកគ្រប់គ្រងគឺមាតាបិតាជាដើម ត្រូវនាំកូនចៅដែលបម្រុងទទឹងបួស ទោះជើទុកឲ្យនៅទទឹងលោកគ្រូចៅអធិការ ដើម្បីរៀនហាត់វិធីបួសក្នុងកាលដ៏សមគួរ ។ បព្វជាបេក្ខ ឬ ឧបសម្បទាបេក្ខដែលចៅនៅរៀនហាត់

វិធីបួសនេះ ហៅថា ជាគិ កាលបើបានជានាគហើយ អ្នកត្រួតត្រង់ប្តអ្នកចំនុកបម្រុង ត្រូវហាមឃាត់នាគនោះ កុំឲ្យដើរលេងផ្តេសផ្តាសក្រែងមានរឿងហេតុកើតឡើង បណ្តាលឲ្យនាគនោះខានបួស ។

ពាក្យថា ជាគិ ប្រែថា "អ្នកប្រសើរ, អ្នកមិនធ្លាប់ជាប" បានសេចក្តីថា អ្នកបម្រុងនឹងបួស ជាមនុស្សប្រសើរ ជាមនុស្សមិនធ្លាប់អំពើជាប ។

ការបួសជាភិក្ខុ ត្រូវបួសក្នុងកេរ៉ាបោសថ ព្រោះកេរ៉ាបោសថនៅក្នុងដែនសីមា ។ ការបួសជាសង្ឃកម្មមួយ ត្រូវធ្វើក្នុងដែនសីមា ។

ពាក្យថា សីមា សំដៅយកវិនិត្រសម្រាប់កំណត់ឲ្យជាទីធ្វើការរបស់សង្ឃ, វត្តខ្លះមានសីមានៅជុំវិញកេរ៉ាបោសថ វត្តខ្លះមានសីមានៅប្រហែលជាវត្តជុំវិញ; ដំណើរនេះដើម្បីឲ្យដឹងថា វិនិត្រសង្ឃមាននៅត្រឹមណោះត្រឹមណោះ; ការធ្វើសង្ឃកម្មដូចការបួសជាដើម ត្រូវធ្វើក្នុងសីមាជាការចាំបាច់ ។

ការបួសសម្រេចនៅលើសង្ឃ, បើវត្តក្រឡត់លោកសង្ឃ ត្រូវមានដំនុំសង្ឃយ៉ាងតិចត្រឹម៥រូប, បើវត្តសម្បូរលោកសង្ឃ ត្រូវមានដំនុំសង្ឃយ៉ាងតិចត្រឹម ១០ រូប ហើយត្រូវមានព្រះថេរៈ ១ រូបជាព្រះឧបជ្ឈាយ៍ គឺជាប្រធានក្នុងការបំបួសកុលបុត្ត ទាំងជាអ្នកត្រួតត្រាមើលទោសកូនជំរបស់អ្នកបួស ហើយសង្ឃត្រូវសន្មតភិក្ខុ ១ រូប ឬ ២ រូប ឲ្យជាអ្នកសាកសួរអន្តរាយិកធម៌របស់អ្នកបួស ក្នុងកណ្តាលដំនុំសង្ឃថា "អ្នកមាន

ភេតឃ្មង់ បូស ស្រែង ហ៊ឹត ឆ្កួតជ្រូក ជាដើមដែរឬទេ" កាលបើសួរ
ពួកស្រែចហើយ ត្រាស់សួរតញ្ចុំ ក្នុងលំដាប់តទៅ; លុះចប់ញត្តិហើយ
ទើបព្រះទេវជញ្ញយ៍ប្រាប់អនុសាសនវិធី គឺប្រៀនប្រដៅអ្នកបួសថ្មីឲ្យដឹង
នូវកិច្ចខាងដើម គឺមុនដំបូងត្រូវដឹងនិស្ស័យគ្រឿងអស្រ័យរបស់បព្វជិត,
និស្ស័យនោះមាន ៤ យ៉ាង :

១— ត្រាប់ទៅបិណ្ឌបាត

២— ស្លៀកដណ្តប់សំពត់បង្សុកូល

៣— នៅដីតគល់ឈើ

៤— ឆាន់ប្តាំដែលត្រាំដោយទឹកនោមគោ[1] ។

និស្ស័យទាំង ៤ នេះ ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាត ក្នុងសម័យ
ដែលស្រុកទេសមិនសម្បូរដោយគ្រឿងប្រើប្រាស់ កំពុងកើតដុនដាប,
សម័យឥឡូវនេះ ស្រុកទេសបានចំរើនសម្បូរដោយលាភសក្ការៈ
តាមនៃតិក្ខកំប្រែប្រួលប្រព្រឹត្តទៅតាមសេចក្តីចំរើនរបស់ស្រុកទេសដែរ ។
ត្រង់បទថា ឲ្យតិក្ខស្លែងរកសំពត់បង្សុកូលដោយទឹកខ្មែងដែលគេចោល
លើគំនរអាចម៍ដី ឬតាមទីបាំនា មកធ្វើជាសំពត់សម្រាប់ស្លៀកដណ្តប់,

---

១ ប្រែចេញពីបទថា បូតិមុត្តៈ ដែលប្រែតាមប្រសព្ទថាទឹកនោមស្អុយ, ពាក្យនេះមិន
ចាត់ជាក់ជាទឹកនោមគ្មីទេ, អ្នកចេះរៀនថាទឹកនោមនុស្ស ម្ល៉ោះហើយកំនោមជាក់ដើងព្រាំផ្ទៃ
ស្រម៉ាកខ្លួនព្រៃជាដើម ធ្វើជាថ្នាំកែរោគ, តាមពិតសព្វវិញ្ញូតញាណក្នុងវិន័យបញ្ញត្តតឹងតែងណាស់ថា
ភិក្ខុឆាន់ចង្កាន់ឬទឹក សូម្បីលាយដោយភេម ឬសក់មនុស្សក៏ត្រូវអាបត្តិ ។ ចំពោះបទបូតិមុត្តៈនេះ
ក្នុងគម្ពីរបរមត្ថទីបនីអដ្ឋកថាខុទ្ទកនិកាយ អានកែពន្យល់ថា យំ កិញ្ចិ គោមុត្តំ ប្រែថាទឹក
នោមគោណាមួយ ។

សម័យនេះ សំពត់មានសាច់ល្អៗ ក៏ច្រើន ទាំងមានអ្នកមានសទ្ធា ជ្រះថ្លាក៏មានច្រើនដែរ ទើបអនុញ្ញាតឲ្យភិក្ខុប្រើប្រាស់សំពត់មានសាច់ ល្អៗបាន ។ ត្រង់បទថា ឲ្យភិក្ខុនៅជិតគល់ឈើ ឥឡូវនេះ វត្តអារាម មានច្រើនកុះករ ទើបអនុញ្ញាតឲ្យភិក្ខុនៅតាមវត្តបាន ។ ត្រង់បទថា ឲ្យឆាន់ថ្នាំដែលគ្រាំដោយទឹកនោមគោសម្រាប់តែពេលផ្សេងៗ សម័យនេះ មានមន្ទីរពេទ្យជាច្រើន សម្បូរដោយថ្នាំពេទ្យហើយ ទើបអនុញ្ញាតឲ្យ ភិក្ខុឆាន់ថ្នាំតាមវិធីពេទ្យបាន ។

លំដាប់តទៅ ព្រះឧបជ្ឈាយ៍គប្បីប្រាប់អករណីយកិច្ច គឺកិច្ចដែល អ្នកបួសមិនត្រូវធ្វើ, អករណីយកិច្ចនោះមាន ៤ យ៉ាង :

๑— មិនត្រូវសេពមេថុន

๒— មិនត្រូវលួចលាក់របស់គេ

๓— មិនត្រូវសម្លាប់សត្វ

๔—មិនត្រូវពោលអួតគុណវិសេសដែលមិនមានក្នុងខ្លួន។

កាលព្រះឧបជ្ឈាយ៍ បានប្រាប់និស្ស័យ ๖ ទី និងអករណីយកិច្ច ๔ ដូច ពោលមកដោយសង្ខេបនេះ ឈ្មោះថា បព្វជាអនុសាសនវិធីត្រឹមប៉ុណ្ណោះ ។ អ្នកបួសថ្មីក៏ប្រាថ្នាតម្រង់ភាពជាភិក្ខុក្នុងព្រះពុទ្ធសាសនា, អ្នកបួសថ្មីនោះ មានឈ្មោះថា ភិក្ខុ ព្រោះជាអ្នកសូម តឹងអ្នកទទួលទេយ្យមានអំពី ទាយក, មានឈ្មោះថា បព្វជិត ព្រោះជាអ្នកវៀរចាកអំពើមានទោស

ត្រង់យ៉ាង, មានន័យថា សមណ: ព្រោះជាអ្នកស្ងប់ស្ងាត់ គឺជាអ្នកវាយប់សេចក្តីអាក្រក់ ។

អ្នកដែលបានបួសហើយនេះ ឈ្មោះថាជាអ្នកជួយតម្រង់តាំងព្រះពុទ្ធសាសនាឲ្យបានត្រង់ ឲ្យបានចំរើនរុងរឿងជាស្ថាពរ ដរាបមកដល់សម័យបច្ចុប្បន្ននេះឯង ។

ប្រយោជន៍អដ្ឋបរិក្ខារ

បរិក្ខារ គ្រឿងប្រដាប់សម្រាប់ប្រើប្រាស់ របស់អ្នកបួសមាន ៨ យ៉ាង ដូចបានតំណាលមកហើយក្នុងខាងដើម, ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតគ្រឿងបរិក្ខារទាំង ៨ នេះ ដល់អ្នកបួស ដើម្បីទំនប្រើប្រាស់ រក្សាចិញ្ចឹមកាយ ទំនរក្សាចិញ្ចឹមដួងឲ្យបានស្រួលល្មម ។ លោកអ្នកបួសថ្មីអង្គខ្លះ ក្នុងសម័យនេះប្រហែលជាពុំទាន់យល់ប្រយោជន៍ នៃបរិក្ខារទាំង ៨ នេះដោយច្បាស់លាស់ទេ ហេតុនេះ ខ្ញុំសូមរៀបរាយអំពីប្រយោជន៍នៃបរិក្ខារទាំង ៨ នេះ ឲ្យយើញច្បាស់លាស់ឡើង តាមគោលបំណងនៃព្រះបរមគ្រូដែលទ្រង់អនុញ្ញាតទុកមក ។

បណ្តាបរិក្ខារទាំង ៨, បរិក្ខារមួយ ។ មានប្រយោជន៍ពីរ ។ ដូចសេចក្តីអធិប្បាយតទៅនេះ ៖

បិណ្ឌ, ស្បង់, សង្ឃាដិ មានប្រយោជន៍ ២ យ៉ាងគឺ កាយបរិហារ្យការរក្សាកាយ ឬ ការចិញ្ចឹមកាយ ១ កុប្បិបរិហារ្យ ការរក្សាដួង ឬការចិញ្ចឹមដួង ១ ។

កាលតថុស្ងៀតដណ្តប់ស្បង់ចីពរ ចេញដើរទៅក្នុងចន្លោះស្រុក, គ្រែចីវរនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមកាយ ។

កាលតថុដើរទៅក្នុងចន្លោះស្រុក ជួនជាស្រែកទឹក ហើយយកជាយចីវរត្រង់ទឹកធាន់ ឬក៏យកចីវរវេចផ្លែឈើតូចធំមានផ្លែស្វាយ ខ្នុរផ្លែល្មុតជាដើម ក្នុងកាលដែលទាយកគេប្រគេនមក, គ្រែចីវរនោះ ហៅថា កុប្បិបរិហារ្យ គ្រឿងរក្សាចិញ្ចឹមផ្លែ ។

ឬត្រូវ, កាលតថុយកថ្នាត្រដង់ទឹកស្រង់ ឬយកថ្នាត្រដង់ទឹកស្រោចត្រែះត្រីកុដិជាដើម, ថ្នាត្រនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមកាយ ។

កាលតថុយកថ្នាត្រទទួលអាហារគោជន ដែលទាយកប្រគេនមកដើម្បីឆាន់, ថ្នាត្រនោះ ហៅថា កុប្បិបរិហារ្យ គ្រឿងរក្សាចិញ្ចឹមផ្លែ ។

ក៏បីពុំ, កាលតថុយកកាំបិតមកកាប់កាត់ បិតសំរួច ធ្វើឈើស្ងួនសម្រាប់ចាក់ធ្មេញ ឬធ្វើធ្នើនវែង ដើងតាំង ដេងមុង ឬទឹងគាត់ហែកចីវរជាដើម, កាំបិតនោះ ហៅថា កាយបរិហារ្យ ជាគ្រឿងរក្សាចិញ្ចឹមកាយ ។

កាលតថុយកកាំបិតលួសសសកអំពៅតុវផ្លែដូង ចិតផ្លែស្វាយ ដើម្បីឆាន់ជាដើម, កាំបិតនោះ ហៅថា កុប្បិបរិហារ្យ ជាគ្រឿងរក្សាចិញ្ចឹមផ្លែ ។

ម្ជុល, កាលគិតយកម្ជុលដេរប៉ះស្បែងចំពាសង្ឃាដី ឬដោះបន្ទាដែលមុតដៃដើង, ម្ជុលនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមកាយឯង ។

កាលគិតយកម្ជុលចាក់ដោតទំចំណី មានទំផ្លែអាយជាដើម ឬចាក់ផ្លែឈើ ដើម្បីឆាន់, ម្ជុលនោះ ហៅថា កុប្បិបរិហារ្យ គ្រឿងរក្សាចិញ្ចឹមផ្លែ ។

វត្ថុពន្ធបង្អែះ, កាលគិតយកវត្ថុពន្ធ មកគ្រែកត់ឲ្យមាំ ហើយចេញដើរទៅក្នុងចន្ទោះស្រុក, វត្ថុពន្ធនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមកាយឯង ។

កាលគិតចេញដើរទៅក្នុងចន្ទោះស្រុក ហើយមានគាយកគេប្រគេនអំពៅច្រើនដើម គ្មានខ្សែរស្លាប់ទឹងចង់ កំយកវត្ថុពន្ធមកចងអំពៅជាបាច់នាំមកដើម្បីឆាន់, វត្ថុពន្ធនោះ ហៅថា កុប្បិបរិហារ្យ គ្រឿងរក្សាចិញ្ចឹមផ្លែ ។

ធម្មក្រែក (តម្រងទឹក), កាលគិតយកធម្មក្រែកដងទឹកស្រែ ឬដងទឹកស្រោចច្រោះត្រាំទឹកសេនាសនៈទឹងទឹលាងក្សរបរិវេណគុដិ ដើម្បីកុំឲ្យធូលីហុយឡើងជាដើម, ធម្មក្រែកនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមកាយឯង ។

កាលគិតយកធម្មក្រែកដងទឹកឆាន់ ឬយកធម្មក្រែកខ្ទប់ម្ជុលដាក់អង្គរ

អំបុកជាដើម សម្រាប់ទុកឆាន់, ឆមក្រែកនោះហៅថា កុប្បិបរិហារ្យ ត្រឿងរក្សាចិញ្ចឹមផ្ទៃ ។

បរិក្ខារទាំង ៨ យ៉ាងរបស់អ្នកបួស មានប្រយោជន៍ពីរ។ ដូចសេចក្តីអធិប្បាយមកដោយសង្ខេបត្រឹមប៉ុណ្ណេះ ។

សូមនិគមបរិក្ខារទាំង ៨ ចនៈជាគាថា ដើម្បីឲ្យងាយចាំដូចខាងក្រោមនេះ ៖

តិចីវរញ្ច បត្តោ ច វាសី ផ្លុនិ ច ឧទ្ធនំ
បរិស្សាវេន អដ្ឋេតេ យុត្តយោគស្ស ភិក្ខុនោ

(ប្រែ) បរិក្ខារទាំង ៨ នេះរបស់ភិក្ខុ អ្នកប្រកបព្យាយាម គឺត្រៃចីវរ, ផាត្រ, កាំបិត, ម្ជុល, វត្ថុតម្ងួចឆ្អែះ, ឆមក្រែក ។

មិនបង្ហោះញញួរទ្វិ គេមើលងាយ

៣១— សូម្បីសក្តទេវរាជ បើមិនបង្ហោះញញួរទ្វិយសស្តិឲ្យគេឃើញជាស់ទេ ក៏គេងជានត្ថុវការមើលងាយតឹមហាដែរ; បុគ្គលហ៊ានដើរកន្លងនូសដែលមានភ្លើងនៅខាងក្នុង, តែកាលណាភ្លើងនេះហើយ បុគ្គលមិនបកិនកន្លងឡើយ ។

មិនសាកសួរ មិនជានត្ថុវការរាប់រក

៣២— មន្ត្រីណាជារបាមួយព្រះរាជាហើយមិនហ៊ានសួរ មន្ត្រីនោះដាមនុស្សល្ងង់ខ្លៅ មិនតែប៉ុណ្ណោះទេ មន្ត្រីនោះគេងជានត្ថុវការមិនរាប់រក ព្រមទាំងជានត្ថុវការមើលងាយពីព្រះរាជាថែមទៀតផង ។

ការចំរើនធំនូវការសាបសូន្យធម្មារម្មណ៍យ

ក្នុងព្រះពុទ្ធសាសនា

ព្រះវេពសត្តា កិម - ភ្លីរ៉ា ចន្ទមង្គលោ

រៀបរៀង

ការចំរើនធំនូវការសាបសូន្យ នៃធម្មារម្មណ៍យក្នុងពុទ្ធសាសនា អាស្រ័យ
ហេតុដូចមានសេចក្តីអធិប្បាយតទៅនេះ ៖

ធម្មជាត ៣ យ៉ាងជាពន្លឺដែលអាចបំភ្លឺសត្វលោកឲ្យភ្លឺជាក់ច្បាស់ក្នុង
លោកទៅបាន អាស្រ័យដោយមិនមានត្រីធម៌មន្ទិលសៅហ្មង ចូលមក
បំពេញ ; ឯធម្មជាត ៣ យ៉ាងនោះគឺ :

១ — សុរិយមណ្ឌលំ មណ្ឌលព្រះអាទិត្យ

២ — បុណ្ណមចន្ទលំ មណ្ឌលព្រះចន្ទ ។

ព្រះអាទិត្យទាំងព្រះចន្ទទាំងពីរនេះ រមែងរះឡើងភ្លឺរុងរឿងបានតែ
តាមវេលា, គឺព្រះអាទិត្យរះឡើងភ្លឺរុងរឿងបានតែកន្លងវេលាថ្ងៃ ដល់វេលា
យប់ធំនឹងវិញ, ព្រះចន្ទរះឡើងភ្លឺរុងរឿងបានតែកន្លងវេលាយប់ ដល់វេលា
ថ្ងៃធំនឹងវិញ; ព្រះអាទិត្យទាំងព្រះចន្ទដែលអាចរះឡើងភ្លឺរុងរឿងបានតាម
វេលានោះសោតទៀត ព្រោះតែគ្មានសភាវៈក្លាដទៃចូលមកបៀតបៀន
ជ្រៀតជ្រែកបំពេញ ប្រសិនបើមានខ្យល់ព្យុះភ្លៀងផ្គរមេឃស្រែកប៉ុនអ័ព្ទ

បែកផ្សែងបង្អុរភ្លៀងធ្លាក់ចុះមកក្នុងវេលាណា ។ ស្តេចព្រះអាទិត្យនឹងព្រះចន្ទ
នោះឯង ក៏នាំសថាត់ទៅតាំងអស់ អាចញ៉ាំងលោកតាំងមូលឲ្យងងឹតសូន្យឈឹងទៅមួយរំពេចក្នុងវេលានោះពុំខាន ។

៣_ តថាគតប្បវេទិតំ ពុទ្ធរៃបង់ ពុទ្ធវចនៈ គឺធម៌នឹងវិន័យ
ដែលព្រះតថាគតបានត្រាស់ដឹងហើយទ្រង់សំដែងទុកមក, ពុទ្ធវចនៈនោះ
ជាពន្ធមួយរបស់សត្វលោក ។ អាចយកពន្ធគឺធម៌នឹងវិន័យនោះមកបញ្ជាំងផ្ទុំបំភ្លឺមើលហេតុពិតនឹងមិនពិត, មើលអំពើល្អនឹងអាក្រក់, ផ្ទុំពិនិត្យវាគុណនឹងទោស, ខុសនឹងត្រូវ គ្រប់យ៉ាង ឲ្យឃើញជាក់ច្បាស់ តាំងក្នុងបច្ចុប្បន្ន តាំងក្នុងបរលោក ហើយអាចញ៉ាំងចិត្តឲ្យងាកបែរចេញពីសេចក្តីយល់ខុសក្នុងហេតុដែលមិនពិត នឹងអំពើអាក្រក់ប្រកបដោយទោសនោះចោលចេញបាន ព្រមតាំងបានប្រតិបត្តិប្រព្រឹត្តកាន់យកតែហេតុដែលពិត នឹងអំពើដែលល្អប្រកបដោយគុណដើម្បីជាប្រយោជន៍ក្នុងលោកនេះនឹងលោកខាងមុខ ។ ពុទ្ធបរិស័ទដែលមានបញ្ញាចក្ខុយ៉ាងនេះ អាស្រ័យដោយពន្ធគឺធម៌នឹងវិន័យនេះឯង ។

ឯធម៌នឹងវិន័យ ដែលទន់ឯងអាចប្រតិស្ឋានតាំងទៅ បានសេចក្តីរុងរឿងអស់កាលជាយូរអង្វែងទៅបាន លុះតែអាស្រ័យដោយពួកពុទ្ធបរិស័ទតាំងបព្វជិតតាំងគ្រហស្ថជាអធិបតីក្នុងសង្គមនីមួយ ។ មិនត្រឹងើយកន្តើយបានប្រឹងជួយទប្ចក្ខម្ភកំទុកបំរុងផង តាំងកុលបុត្រអ្នករៀនសូត្រកំមានភ័ព្វ ការចេះដឹងជាច្រើន ហើយទំព្យាយាមបង្ហាត់បង្រៀនសិស្សានុសិស្សត ។

គ្នាផង ទំព្យាយាមរំលឹកជាស់តឿនណែនាំអ្នកដទៃឲ្យមានសេចក្តីប្រតិបត្តិ ប្រតិបត្តិតឹមត្រូវផង ទើបធម៌ទំនិរវិន័យរបស់ព្រះសម្មាសម្ពុទ្ធនោះទំនុរងរឿងបិតវេចិវាលៅបាន ។

មួយទៀត បុគ្គលជាធម្មកថិកក្តី មិនមែនជាធម្មកថិកក្តី មានសេចក្តីឃល់ខុស ប្រកបដោយមានះចចេសរឹងត្អឹង ហាមឃាត់សាសនារបស់ព្រះពុទ្ធ ឬជាអ្នកកំណាញ់ធម៌លះកំលៀមចំណេះវិជ្ជា មិនចង់ឲ្យអ្នកណាមួយគេចេះដឹងលើសខ្លួនឬស្មើនឹងខ្លួន ខ្លាចខាតលាភសក្ការៈរបស់ខ្លួនក្តី ជាអធម្មវាទី តោលទូរហេតុដែលមិនមែនជាធម៌ មិនមែនជាវិន័យថាជាធម៌ ថាជាវិន័យទៅវិញដូច្នេះក្តី បុគ្គលដែលបានឈ្មោះថាជាអ្នកចិទជ្ញាំងតទ្ទីតធម៌ទំនិរវិន័យរបស់ព្រះសម្មាសម្ពុទ្ធ ឲ្យស្រអាប់ជ្ញាត់តទ្ទីរស្មើ ជាអ្នកដឹកនាំមនុស្សទាំងពួងឲ្យវង្វេងក័ន្តគំនិតសំគាល់ខុសជាត្រូវ សំគាល់ត្រូវថាជាខុសវិញដោយច្រើន ដូចគ្នានឹងព្រះអាទិត្យព្រះចន្ទរះឡើងកំពុងមានរស្មីភ្លឺត្រចះល្អ បើមានសការៈជវៃ មានពពួកអសុរិន្ទជាដើម ចូលមកបៀតបៀនដណ្តើតដែកបិទជ្ញាំងព្រះអាទិត្យនឹងព្រះចន្ទ្រាលណាហើយ តទ្ទីរស្មីដែលកំពុងរុងរឿងល្អនោះ ក៏បែរទៅជាស្រអាប់ជ្ញាត់តទ្ទីរនាសសូន្យទៅមួយរំពេចក្នុងកាលនោះឯង, ឯធម៌ទំនិរវិន័យរបស់ព្រះសម្មាសម្ពុទ្ធ ក៏ដូច្នោះដែរ ។ រួមសេចក្តីដែលបានពណ៌នាមកថា ធម៌ទំនិរវិន័យដែលបានចំរើនរុងរឿងឡើង ឬវិនាសសាប

សូន្យទៅ ក៏ដោយសារតែពួកពុទ្ធបរិស័ទគាំងបព្វជិតគាំងគ្រហស្ថហ្នឹង
ឯង ។

មានពាក្យចោទសួរថា ពុទ្ធសាសនាគឺធម៌ដ៏វិនិច្ឆ័យ ដែលអាចរុងរឿងតាំងនៅអស់កាលជាអង្វែងទៅបាន អាស្រ័យដោយសារ បរិយត្តិ (ការរៀនសូត្រ) ជាឫសគល់ ឬក៏អាស្រ័យដោយសារ បដិបត្តិ (ការប្រតិបត្តិ) ជាឫសគល់ ? បញ្ហានេះ សូមទាញយករឿងដែលមានក្នុងគម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ មកធ្វើយបញ្ជាក់ថា មានភិក្ខុពីរពួកគឺភិក្ខុខាងបរិយត្តិមួយពួក, ភិក្ខុខាងប្រតិបត្តិកាន់ធុតង្គមួយពួក ។ មានបញ្ហាកើតឡើងដល់ភិក្ខុទាំងនោះថា បរិយត្តិ ជាឫសគល់នៃសាសនា ឬក៏ បដិបត្តិ ជាឫសគល់នៃសាសនា ? ពួកភិក្ខុខាងប្រតិបត្តិកាន់ធុតង្គធ្វើយឡើងថា បដិបត្តិ ជាឫសគល់នៃសាសនា ។ ឯពួកភិក្ខុខាងបរិយត្តិធ្វើយថា បរិយត្តិ ជាឫសគល់នៃសាសនា ។ ខណៈនោះ ព្រះថេរៈទាំងឡាយដែលគាំងនៅជាកណ្តាលប្រកាសឡើងថា យើងមិនទាន់ឃើញព្រមតាមពាក្យរបស់លោកទាំងសងខាងទេ សូមលោកទាំងឡាយលើកយកសូត្រជាភាសិតនៃព្រះដ៏ទ្រង់ស្មើមកពោលអាងផង ទើបបាន ។ លំដាប់នោះ ពួកភិក្ខុខាងបដិបត្តិកាន់ធុតង្គលើកយកសូត្រពីរអន្ទើមកពោលអាងថា តិមេ ប សុភទ្ទ ភិក្ខូ សម្មាបដិបត្តិ វិហរេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ អស្ស "ម្នាលសុភទ្ទៈ,

ប្រសិនបើតិក្ខុទាំងឡាយនេះ មានការប្រតិបត្តិដោយប្រពៃជាប្រក្រតី, លោក(នេះ)មិនតប្បីសូន្យចាកព្រះអរហន្តទាំងឡាយឡើយ" ។ បដិបត្តិ-
មូលកំ មហារាជ សត្ថុ សាសនំ បដិបត្តិយំ ធរន្តេ តិដ្ឋតិ "បពិត្រមហាក, សាសនារបស់ព្រះសាស្តាមានសេចក្តីប្រតិបត្តិជាប្រុសគល់ បិតនៅក្នុងបុគ្គលអ្នកចំរើនសេចក្តីប្រតិបត្តិ" ។ ឯពួកតិក្ខុទាំងបរិយត្តិ ក៏នាំយកសូត្រដូចខាងក្រោមនេះមកពោលអាងថា :

យាវ តិដ្ឋន្តិ សុត្តន្តា វិនយោ យាវ ទិប្បតិ
តាវ ទក្ខន្តិ អាលោកំ សុរិយេ អព្ភុដ្ឋិតេ យថា ។
សុត្តន្តេសុ អសន្តេសុ បមុដ្ឋេ វិនយម្ហិ ច
តមោ ភវិស្សតិ លោកស្ស សុរិយេ អដ្ឋង្គតេ យថា ។
សុត្តន្តេ វត្តមានេ សន្តេ បដិបត្តិ ហោតិ វត្តិតា
បដិបត្តិយំ ឋិតោ ធីរោ យោគក្ខេមា ន ធំសតីតិ ។

"ព្រះសូត្រទាំងឡាយឋិតនៅជាប់ណា, ព្រះវិន័យនៅរុងរឿងជាប់ណា, សត្វលោកក៏អាចនៅឃើញពន្លឺបានជាប់នោះ ដូចជាព្រះអាទិត្យដែលរះខ្ពស់ត្រដែតឡើង ដូច្នោះឯង ។ កាលបើព្រះសូត្រទាំងឡាយមិនមាន ទាំងព្រះវិន័យក៏តិក្ខក្នុងភ្លាមអស់ទៅហើយដែរ, ងងឹតអន្ធការក៏ធំធីកើតមានដល់សត្វលោក ដូចជាព្រះអាទិត្យដែលអស្តង្គតបាត់ពន្លឺ ដូច្នោះឯង ។ កាលបើតិក្ខុនៅរក្សាព្រះសូត្របាននៅឡើយ,

សេចក្តីប្រតិបត្តិ កំណើនថាជាគុណជាតិ ដែលកិកុនៅរក្សាបានដែរ; ជីវិតនៃអ្នកបិតនៅកន្លែងសេចក្តីប្រតិបត្តិ រមែងមិនខ្ជាត់ឃ្លាតចាកធម៌ជាដែនក្សេមចាកយោគៈឡើយ" ។

កាលពួកកិកុខាងបរិយន្តិ នាំយកព្រះសូត្រមកសំដែងតាមដូច្នេះហើយ, ពួកកិកុខាងប្រតិបត្តិកាន់ជុតង្គ កិយល់ស្រេចជាមួយគ្នាហើយនៅស្ងៀម ។ សេចក្តីនេះ អដ្ឋកថាចារ្យបានអធិប្បាយបន្ថែមដោយសេចក្តីប្រៀបធៀបចំភ្លឺថា ហ្វូងគោ ដែលមានសុទ្ធតែគោបាំងរយបាំងពាន់ កាលបើមិនមានមេគោជាសត្វរក្សាតំណាបវាលីនៅក្នុងហ្វូងគោបានោះផងទេ វង្សបវាលីឬពួកគោនោះឯង ក៏មុខជានឹងជាប់សូន្យទៅយ៉ាងណាមិញ; សាសនាក៏ដូច្នោះដែរ, ពោះបើមានកិកុច្រើនរូបដល់រយតាន់ក៏ដោយ បើសុទ្ធតែជាអ្នកប្រាព្ធនូវវិបស្សនាកម្មដ្ឋាន ជុតង្គរក្សាមូលនៅអស្រ័យក្នុងវៃព្រៃ, តែបើមិនមានកិកុអ្នកទ្រទ្រង់បរិយត្តិជាពហុទេឬ ក៏បរិយត្តិអន្តរធាននៅដោយហេតុណាមួយហើយ, ការចាក់ផ្លុះ ឬការត្រាស់ដឹងនូវអរិយមគ្គអរិយផល ក៏ពុំមានដែរ ព្រោះមិនមានបរិយត្តិជាបច្ច័យសម្រាប់ចម្រើនញាតឲ្យលាស់ចំភ្លឺនូវប្រតិបត្តិឲ្យត្រឹមត្រង់ទៅបាន ។ ន័យមួយទៀត លោកប្រៀបថា អក្សរដែលគេឆ្លាក់ក្តាប់នៅលើផ្ទាំងថ្ម ដើម្បីជាគ្រឿងសំគាល់ឲ្យដឹងនូវទីដែលមានផ្ទាំងកំណប់ទ្រព្យដែលគេកប់ទុក, ជាបណ្តា អក្សរទាំងនោះ នៅមិនទាន់លុបរលាយបាត់ទៅទេ; ជាបណ្តានោះ ផ្ទាំងកំណប់ទ្រព្យនោះ ឈ្មោះថាមិនទាន់វិនាសបាត់ទៅ

នៅឡើយ យ៉ាងណាមិញ; ឯសាសនានេះ ក៏យ៉ាងនោះឯង, បើបរិយត្តិ នៅមាន តែកុំទ្រេទ្រង់សិក្សារៀនសូត្រនៅឡើយ ឬមិនតាន់អន្តរធានដោយ ហេតុណាមួយទេ សាសនារបស់ព្រះសម្មាសម្ពុទ្ធក៏មិនតាន់អន្តរធាន សាបសូន្យទៅដែរ ព្រោះអាស្រ័យបរិយត្តិជាប្រមាណ គឺបរិយត្តិជាឫស គល់របស់សាសនាដូចបានពណ៌នាមកនេះឯង ។

បំណោទ ៨ យ៉ាង

បំណោទនេះអ្នកប្រាជ្ញតែងឡើងក្នុងរជ្ជកាលនៃព្រះបាទសម្តេចនរោត្តម ដែលនគរយើងភ្ជាក់ផ្អើលជាអាយ័តនៃបរទេស ។

១— ចាក់ទឹកដួង	អំផូងមួយពាន់
២— ការឈើឈ្នាន់	អន្លាន់អន្ទង
៣— ការបេង	រំលងសីមា
៤— កន្ទុយត្រីប្រា	មេនាងនាគ
៥— កន្ទុយត្រីដូក់	មេនាងកែវ
៦— អកកំពោរ	ប្រចាំបង់
៧— ចំពង់ឫស្សី	ប្រចាំរែក
៨— ក្បាលទំពែក	ក្អែកដុះជាក់ប៉ក់ ។

ស្រាយបំណោទទាំង ៨

ទី ១— ម៉ាស៊ីនទឹក, ទី ២— តំបាញ, ទី ៣— ខ្សែលួស, ទី ៤— ភស្ត្រាយកថ្នាលែងរើសពូជ, ទី ៥— ភស្ត្រាយកប្រពន្ធជាតិស្លេជ, ទី ៦— ស្ពោ ឲ្យមានគ្រាន់តែចាំកាំង, ទី ៧— នាម៉ឺនគ្រាន់តែជួសប្រយោជន៍ ឲ្យគេ, ទី ៨— អ្នកស្នេហាជាតិ តែឡើក ជាប់គុក នឹរទេស សម្លាប់ចោល ។

សតិសម្បជញ្ញកថា

ព្រះជាឃ្លាំងគ្មមលិទ្ធ សុង-ស៊ីរ៉ី វត្តលង្កា ភ្នំពេញ

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការ ចំពោះ*ព្រះភគវន្តមុនីអរហំ សម្មាសម្ពុទ្ធ*ព្រះអង្គ*នោះ* (*ត្រមាំង*ព្រះធម៌ *ទឹង*ព្រះសង្ឃ*ដោយគោរព*) ។

រលានេះ *អាត្មាភាព*សូម*សំដែង*នូវ*ធម៌*ដែល*មាន*ឧបការៈ*ច្រើន*ពី*រយ៉ាង* *គឺ* *សតិទឹងសម្បជញ្ញៈ* ។

*កិច្ចមិនាំងពី*ប្រែការនេះ *ព្រះសម្មាសម្ពុទ្ធ*ទ្រង់*សំដែង*យ៉ាង*ល្អិត*សុខុមពន់ពេក, បុគ្គលដែលជាប់ជំពាក់ខាក់ខន*ខ្ជាំង*ក្នុង*តាម ពុំ*ងាយ*ទឹង*ប្រតិបត្តិ*ឲ្យ*ពេញបរិបូណ៌*បាន*ទេ; តែ*ក្នុង*រលានេះ*ពោះ*បី*ធម៌*នេះ*ល្អិត*សុខុមដូច្នោះ *ក៏*សូម*សំដែង*ដែរ *ដើម្បី*ជា*ធម្មស្សវនាការ ចំពោះ*ពុទ្ធ-បរិស័ទ*តាំង*ឡាយ*ដូចតទៅនេះ ៖

*សូម*ផ្តើម*អធិប្បាយ*អំពី*លក្ខណៈ*បុគ្គលអ្នក*មាន*សតិសម្បជញ្ញៈ*ជា*មុន* ។

*ឯ*លក្ខណៈ*បុគ្គលអ្នក*មាន*សតិសម្បជញ្ញៈ *គឺ*បុគ្គលដែល*ប្រកប*ដោយ*សតិសម្បជញ្ញៈ *កាល*ទឹង*ឈាន*ទៅមុខ *ឬ*ឈាន*ថយ*ក្រោយ *ក៏*មាន*ស្មារតី*ដឹង*ខ្លួន*ថា "*ឥឡូវ*នេះ*អាត្មាអញ*កំពុង*ឈាន*ទៅមុខ, *កំពុង*ឈាន*ថយ*ក្រោយ" ។ *កាល*ទន*កាយ*ទៅមុខ*ក្តី *ផ្ទារ*កាយ*មក*ក្រោយ*ក្តី

ក្រឡេកមើលទៅមុខក្តី ទៅក្រោយក្តី ទៅធ្វេងក្តី ទៅស្តាំក្តីក៏មានស្មារតីដឹងខ្លួនថា "ឥឡូវនេះ អាត្មាអញកំពុងនុនកាយទៅមុខ, កំពុងផ្ងារកាយមកក្រោយ" ដូច្នេះដរាបដើម ។ សូម្បីកាលដែលទំនេរប្រើប្រាស់គ្រឿងបរិក្ខារទៀតក៏មានស្មារតីដឹងខ្លួនជានិច្ច ដូចគ្រឿងបរិក្ខារបស់បព្វជិត កាលដែលទំនេរប្រើប្រាស់ សង្ឃាដិ ឧត្តរាសង្គ, ចីវរ ក៏មានស្មារតីដឹងខ្លួនថា "ឥឡូវនេះ អាត្មាអញកំពុងប្រើ សង្ឃាដិ, ឧត្តរាសង្គ, ចីវរ" ។ កាលដែលទំនេរឆាន់បង្ហាន់ ឬឆាន់ទឹក ទំនេរទំពា ឬស្រូប, ហិត, លិទ្ធ, ភក្ស្យរបស់អ្វីៗ ក៏មានស្មារតីដឹងខ្លួនថា "ឥឡូវនេះ អាត្មាអញកំពុងឆាន់បង្ហាន់, ឆាន់ទឹក, ទំពា, ស្រូប, ហិត, លិទ្ធ, ភក្ស្យរបស់នោះៗ" ។ កាលដែលទំនេរបន្ទោបង់ឧច្চារៈ, បស្សាវៈ ក៏មានស្មារតីដឹងខ្លួនថា: "ឥឡូវនេះ អាត្មាអញកំពុងបន្ទោបង់ឧច្চារៈ, បស្សាវៈ" ។ កាលដេក, ដើរ, ឈរ, អង្គុយ, និយាយ, ស្តាប់ ក៏មានស្មារតីដឹងខ្លួនថា: "ឥឡូវនេះ អាត្មាអញកំពុងដេក, ដើរ, ឈរ, អង្គុយ, និយាយ, ស្តាប់" ។

កិកុយើញគ័យក្នុងវត្តសង្ឃារ រមែងប្រកបដោយសតិសម្បជញ្ញៈដូចសំដែងមកនេះ ។

អធិប្បាយអំពីសតិ

សតិ ជាធម៌សំខាន់បំផុត ទាំងធ្វើចិត្តឲ្យបរិសុទ្ធហ្មត់ចត់ល្អ, ព្រះសម្មុខ្ទ្ធសំដែងថា ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ

វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ
អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ

ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវដ៏ខ្លីតែម្នាក់ឯង ដើម្បីសេចក្តីបរិសុទ្ធិរបស់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកសស្តាយគ្រាន់ទ្រហោយំ នឹងសេចក្តីខ្សឹកខ្សួលទាំងឡាយ ដើម្បីរលត់នូវទុក្ខនឹងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង, ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ យទិទំ បត្តាទោ សតិបដ្ឋានា *ផ្លូវនោះគឺ សតិបដ្ឋាន ៤ ។ សតិបដ្ឋាន ៤ នោះគឺ :*

๑—កាយានុបស្សនាសតិបដ្ឋាន *ដំណើរសតិពិចារណាកាយជាអារម្មណ៍ ;*

๒—វេទនានុបស្សនាសតិបដ្ឋាន *ដំណើរសតិពិចារណាចិត្តជាអារម្មណ៍ ;*

๓—ចិត្តានុបស្សនាសតិបដ្ឋាន *ដំណើរសតិពិចារណាចិត្តជាអារម្មណ៍ ;*

๔—ធម្មានុបស្សនាសតិបដ្ឋាន *ដំណើរសតិពិចារណាធម៌ជាអារម្មណ៍ ។*

ឯវិធីដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រដៅឲ្យពិចារណានោះ មានន័យច្រើនជាអនេក, បើស្រង់យកតែចំណែកដែលជាចតុក្កាំង ๔ នោះមកសំដែង ក៏គឺពិចារណាឲ្យឃើញថា: "កាយនេះគ្រាន់តែជាកាយ, វេទនា

គ្រាន់តែជាវេទនា, ជាបុគ្គល, ជាតួខ្លួនទេ; គួរកុំប្រកាន់, កុំស្អប់, កុំស្រឡាញ់ឡើយ" ដូចច្នេះជាដើម ។

កាលបើកំពុងតាំងសតិកំណត់អារម្មណ៍ទាំង ៤ ប្រការ ដូចសំដែងមកនេះ, ចិត្តក៏ទំនឹងជាប់ទៅតែក្នុងកុសលធម៌ម្យ៉ាង; បើចិត្តជាប់ទៅក្នុងកុសលធម៌ហើយ ឧបក្កិលេសដែលជាអកុសលក៏រកឧកាសកើតឡើងពុំបាន, ចិត្តក៏ទំនឹងច្រាសចាកគ្រឿងសៅហ្មងតែងតែដល់នូវសេចក្តីជ្រះថ្លាជាខណៈ ដោយលំដាប់ទៅ ។

នេះជាសេចក្តីអធិប្បាយដោយសង្ខេបក្នុងពាក្យថាសតិ ។

អធិប្បាយអំពីសម្បជញ្ញៈ

សម្បជញ្ញៈ នោះចែកជា ៤ ប្រការគឺ:

๑— សាត្ថកសម្បជញ្ញៈ ដឹងហានៈមានប្រយោជន៍,

๒— សប្បាយសម្បជញ្ញៈ ដឹងហានៈជាទីសប្បាយ,

๓— គោចរសម្បជញ្ញៈ ដឹងហានៈជាទីគោចរ,

๔— អសម្មោហសម្បជញ្ញៈ ដឹងហានៈមានសេចក្តីមិនវង្វេង ។

សាត្ថកសម្បជញ្ញៈ = ដឹងហានៈមានប្រយោជន៍

តំណក់សាសនានេះ កាលបើគិតថាខ្លឹងទៅប្រទេសណា ក៏ពុំបានទៅដោយប្រញាប់ប្រញាល់តាមអំណាចចិត្តដែលគិតនោះទេ, តែងពិចារណាឲ្យដឹងថា ដែលអាត្មាអញទៅក្នុងវិនោះ តើទំនឹងមានប្រយោជន៍ឬទេ? បើឃើញថាមានប្រយោជន៍ គឺទំនឹងបានឃើញព្រះចេតិយ, ឃើញ

ពោធិព្រឹក្ស, ឃើញព្រះសង្ឃ, ឃើញមហាថេរ, ឃើញអសុភដែលមានចំនួនឲ្យតើតត្រៃលក្ខណ៍; លុះពិចារណាឃើញយ៉ាងនេះហើយទើបទៅ ។ បើពិចារណាទៅហើយឃើញថាមិនមានប្រយោជន៍ ក៏កាត់គំនិតចិត្តនោះចេញ, តុំបានទៅតាន់ទីដែលប្រាសចាកប្រយោជន៍នោះឡើយ ។ ឯការដែលបានឃើញព្រះចេតិយ, ឃើញពោធិព្រឹក្ស, ឃើញព្រះសង្ឃ, ឃើញមហាថេរ, ឃើញអសុកនោះឯង តែងជាបច្ច័យឲ្យចំរើនទៅសីលគុណ, សមាធិគុណ, បញ្ញាគុណ ។ បើបុគ្គលដែលមានឧបនិស្ស័យ បានសាងសន្សំមកពីបុព្វជាតិច្រើន, កាលបើបានឃើញវត្ថុដ៏ប្រសើរខាងនោះ ក៏កើតចិត្តប្រាថ្នាមានពុទ្ធគុណ, ធម្មគុណ, សង្ឃគុណជាអារម្មណ៍, លុះពិចារណាចិត្តប្រាថ្នានោះដោយឧបាយ: គឺកំណត់យកអស់ទៅនឹងសូន្យទៅហើយ, ក៏ច្រើនតែបានសម្រេចអរិយមគ្គ អរិយផលដោយលំដាប់ៗទៅ ។ បើបុគ្គលដែលពុំទាន់បានសាងសន្សំឧបនិស្ស័យធម៌ពីបុព្វជាតិមកទេ ក៏នឹងបានជាឧបនិស្ស័យទៅជាតិខាងមុខៗដែរ ។ ហេតុដូច្នេះ បានជាកិរិយាដែលមានប្រាថ្នា នឹងត្រេចទៅស្វែងរកប្រយោជន៍, មានថ្វាយបង្គំនូវព្រះចេតិយ ឬ ពោធិព្រឹក្សជាដើមនេះ ឈ្មោះថាសាត្ថកសម្បជញ្ញៈ ។

សប្បាយសម្បជញ្ញៈ = ដឹងហាន:ជាទីសប្បាយ

អធិប្បាយថា កិរិយាដែលប្រកបដោយសម្បជញ្ញៈ រមែងពិចារណារកដំណើរជាទីសប្បាយនឹងមិនសប្បាយជាមុនថា វេលាដែលអាត្មាអញទៅក្នុងទីនោះៗ តើនឹងបានអារម្មណ៍ជាទីសប្បាយឬទេ? បើឃើញថានឹង

យកអារម្មណ៍ឲ្យជាទីសប្បាយមិនបាន កំនឹងឈប់បង្អន់ ; លុះបានពេលដែលកើតអារម្មណ៍ជាទីសប្បាយទើបទៅ; យ៉ាងនេះជាដើម ឈ្មោះថាសប្បាយសម្បជញ្ញៈ ។

ដូចម្តេចដែលហៅថាដំណើរប្រកបដោយប្រយោជន៍ឲ្យកើតសេចក្តីសប្បាយ? ដំណើរដែលទៅមើលព្រះចេតិយឬពោធិព្រឹក្សជាដើម ហៅថាដំណើរប្រកបដោយប្រយោជន៍ឲ្យកើតសេចក្តីសប្បាយ ។ ប៉ុន្តែបើទីនោះមានបរិស័ទច្រើនទៅប្រជុំគ្នាដើម្បីធ្វើមហាបូជា, អស់មហាជនទាំងបុរសស្ត្រី ក៏សុទ្ធតែតាក់តែងកាយដោយគ្រឿងប្រដាប់យ៉ាងល្អល្អះ ដើរចាត់ទៅមក ។ ចិត្តរបស់តំណែដែលទៅកន្លែងមានសភាពដូច្នោះ រមែងជាប់ជំពាក់កន្លងផង់អារម្មណ៍, មានថ្នាំងថ្នាក់កន្លងអនិង្ហារម្មណ៍, រមែងកើតសេចក្តីអន្តរាយដល់ដីវិតព្រហ្មចរិយៈពុំខាន ។ ទីដែលមានសភាពដូច្នោះ ឈ្មោះថាជាទីមិនសប្បាយ, លុះតែទីដែលមិនមានសភាពដូច្នោះ ទើបឈ្មោះថាជាទីសប្បាយ ។

គោចរសម្បជញ្ញៈ = ដឹងហ៊ានៈជាទីគោចរ

អធិប្បាយថា បណ្តាកម្មដ្ឋានទាំង ៤០ លើកយកអាកាសកសិណនឹងអាលោកកសិណចេញ នៅ ៣៨, ក៏កម្មដ្ឋានទាំង ៣៨នោះ កាលតិក្ខុបានរៀនកម្មដ្ឋានណាមួយដែលមានអារម្មណ៍ជាទីគាប់ចិត្ត គឺសមគួរតាមចរិតហើយក៏កាន់យកកម្មដ្ឋាននោះជាអារម្មណ៍ គ្រប់វេលាដែលគោចរទៅកាន់ទីផ្សេង ។, តុំបានឲ្យចិត្តច្បាស់បាត់កម្មដ្ឋានឡើយ ។ ដំណើរដែលត្រចៀកយ៉ាងនេះ ហៅថា គោចរសម្បជញ្ញៈ ។

ដើម្បីទំនឹងសំដែងឲ្យដាក់ប្រាស់ខ្លួរគោចរសម្បជញ្ញៈនោះ ពុទ្ធបរិស័ត្តរួជ្រាបតាមន័យដែលលោកចែកជា ៤ យ៉ាងដូច្នេះ គឺ:

๑- ឯកច្ចោ ហរតិ ន បច្ចាហរតិ យោគាវចរដំពូកខ្លះ កាន់យកពុទ្ធានុស្សតិកម្មដ្ឋានជាអារម្មណ៍ បានតែពេលដែលត្រែចទៅ ត្រឡប់មកវិញមិនបាន ។

๒- ឯកច្ចោ បច្ចាហរតិ ន ហរតិ យោគាវចរដំពូកខ្លះ បានតែក្នុងពេលដែលត្រឡប់មក, ពេលដែលត្រែចទៅមិនបាន ។

๓- ឯកច្ចោ បន នេវ ហរតិ ន បច្ចាហរតិ យោគាវចរដំពូកខ្លះ មិនបានទាំងទៅ ទាំងមក ។

๔- ឯកច្ចោ ហរតិ ប បច្ចាហរតិ ប យោគាវចរដំពូកខ្លះ បានទាំងទៅ ទាំងមក ។

កាលបើយោគាវចរកាន់យកពុទ្ធានុស្សតិកម្មដ្ឋាន ជាទីសប្បាយហើយ ក៏ចំរើនត្រែចរំលងដែលគោចរទៅកាន់ទីផ្សេង ๆ ខ្លះឯង ហៅថា គោចរសម្បជញ្ញៈ ។

អសម្មោហសម្បជញ្ញៈ = ដឹងហ៊ាន:មានសេចក្តីមិនវង្វែង

អធិប្បាយថា: សេចក្តីមិនវង្វែងក្នុងតំរិយាបថទាំងឡាយ មានឈានទៅមុខជាដើម ហៅថាអសម្មោហសម្បជញ្ញៈ ។ បណ្ឌិតត្រូវជ្រាបសេចក្តីនោះយ៉ាងនេះថា ធម្មតាពួកហ៊ានជនវៃមិនវង្វែងតំរិយាបថទាំងឡាយមានឈានទៅមុខជាដើម គឺគ្រាន់តែដឹងថា អាត្មា

ឈានទៅមុខ ដំហានមុខអាត្មាអញថាបានឈានទៅហើយ ដូច្នេះប៉ុណ្ណោះ តុំបានដឹងវិសេសជាងនេះទៅទៀតឡើយ ។ ឯបណ្ដិតជនក្នុងព្រះពុទ្ធ-សាសនានេះ មិនវង្វេងដូច្នោះឡើយ គឺកាលបើមានចិត្តគិតថា អាត្មាអញទើឈានទៅមុខដូច្នេះហើយ រមែងនឹកឃើញថា: "ខ្ញុំ ឥឡូវនេះ ក៏យោធាតុ ញាំងឱ្យក្តៅឡើង គឺឡល់កំរើកហើយតើ!" ដូច្នេះជាមួយនឹងចិត្តដែលគិតថា "អញឈានទៅមុខ" នោះឯង, ហើយគិតទៅទៀតថា "ខ្ញុំ ឥឡូវនេះ ពាំងផ្ដើងដែលលោកសន្មត់ថា កាយនេះ កំពុងឈានទៅមុខដោយអំណាចកំរើកវាយោធាតុនឹងកិរិយាចិត្តហើយ" ។ គិតយ៉ាងនេះ គ្រប់ឥរិយាបថទាំង ៤ ។ តាមសេចក្តីក្នុងបរមត្ថថា ការដើរជារបស់ពួកធាតុ ការឈរក៏ជារបស់ពួកធាតុទាំងអស់ ។ ចិត្តដែលប្រព្រឹត្តទៅជាមួយនឹងរូបក្នុងចំណោមទាំងជាប់គ្នាដូចខ្សែទឹក ។

សេចក្តីនេះ សមដូចព្រះគាថាថា:

អញ្ញំ ឧប្បជ្ជតេ ចិត្តំ អញ្ញំ ចិត្តំ និរុជ្ឈតិ
អវិច្ចិមគ្គសន្តានោ ឧទិ្ធសោតោវ វត្តតិ ។

"ចិត្តដទៃកើតឡើង ចិត្តដទៃរលត់ទៅ ប្រៀបដូចខ្សែទឹកនទីដែលប្រព្រឹត្តជាប់ទៅតាមលំនាក" ។

សេចក្តីមិនវង្វេងក្នុងឥរិយាបថទាំងឡាយមានឈានទៅមុខជាដើមដូចអធិប្បាយមកហើយនេះ ឈ្មោះថា អសម្មោហសម្បជញ្ញៈ ។

បុគ្គលដែលប្រកបដោយសម្បជញ្ញៈដូច្នេះ ចិត្តរមែងជ្រះថ្លា មិនមានឧកាសឱ្យឧបក្កិលេសវុកពានចូលមកបាន ។

កាលបើបុគ្គលណាមិនមានសតិសម្បជញ្ញៈនេះហើយ បុគ្គលនោះតែងតែរសាត់អណ្តែតភ្ជាត់ភ្ជាក់ទៅក្នុងគំនរអកុសលធម៌ផ្សេង។ ក្បាយខ្លួនទៅជាបុគ្គលអាក្រក់, ជាបុគ្គលមានកំឡាំងខ្សោយ; សូម្បីតែលាភសក្ការៈក៏អាចសម្ងាប់បុគ្គលនោះបាន; ដូចពុទ្ធភាសិតមួយកន្លែងមានទៅក្នុងគម្ពីរសំយុត្តនិកាយថា:

ធិលំ វោ កទលិ ហន្តិ ធិលំ វេឡុំ ធិលំ នឡំ
សក្ការោ កាបុរិសំ ហន្តិ គព្ភោ អស្សតរឺ យថា ។

ផ្លែចេក តែងសម្ងាប់ដើមចេក, ផ្លែឫស្សី តែងសម្ងាប់ដើមឫស្សី, ផ្លែបបុស តែងសម្ងាប់ដើមបបុស, ឯសក្ការៈ តែងសម្ងាប់បុរសអាក្រក់ ដូចជាគភ៌សម្ងាប់មេសេះអស្សតរ ។

ន័យមួយទៀតថា: ជីវិមតកោ (ស្លាប់តាំងរស់) អាមកបូតិកោ (ស្អុយតាំងស្រស់), បានដល់បុគ្គលដែលមិនមានសតិសម្បជញ្ញៈនេះឯង។

ធម្មតាបុគ្គលមិនមានសតិសម្បជញ្ញៈ រមែងមានសេចក្តីប្រមាទជានិច្ច, កាលបើមានសេចក្តីប្រមាទដូច្នេះហើយ សូម្បីមានជីវិតរស់នៅក៏ឈ្មោះថាស្លាប់, ព្រោះស្លាប់សតិសម្បជញ្ញៈ; បានជាភាសិតនេះថា ជីវិមតកោ គឺស្លាប់តាំងរស់; បុគ្គលបែបនេះតែងតែប្រព្រឹត្តអំពើទុច្ចរិតផ្សេង។, បើប្រព្រឹត្តអំពើទុច្ចរិតដូច្នេះហើយ គេរំឭកឈ្មោះបុគ្គលនោះក៏អាក្រក់ ស្អុយផ្សាយទៅកាន់ទីប្រាសឱ្យល់ ទឹងបណ្តាយឱ្យល់ជានិច្ច, ឯ

គ្រោងកាយរបស់បុគ្គលនោះនៅស្រស់ខ្លះ តែមានក្លិនឈ្មោះស្អុយគ្រោះអាក្រក់ពុំប្រក្រតី, ជាន់ជាកាសិតនេះថា: អាមកប្បតិកោ គឺស្អុយទាំងស្រស់ ។

សតិនឹងសម្បជញ្ញៈទាំងពីរនេះ បើកើតឡើងព្រមគ្នាក្នុងវេលាមួយ, ក៏រើងតែតែខ្លាំងច្រើនឡើង អាចកំចាត់សត្រូវគឺកិលេសដែលជាមេធំគឺពន្ធៈ, ទោសៈ, មោហៈឲ្យអស់ទៅបាន; បើកិលេសទាំងនេះអស់ទៅហើយ ចិត្តក៏រមែងបរិសុទ្ធស្អាតជូរផង់ ពុកជាពុំទាន់ជាប់អស់ជាសមុច្ឆេទប្បហាន ក៏គង់ជាតទង្គប្បហាន; កាលបើជាតទង្គប្បហានរឿយ ។ ក៏អាចនឹងក្លាយជាសមុច្ឆេទប្បហានទៅបាន ។

ចិត្តនៃបុគ្គលដែលបានដុសខាត់រឿយ ។ រមែងស្អាតជូរផង់ដោយលំដាប់តាមទំនងនៃកុសលធម៌ ដែលជាគ្រឿងដុសខាត់នោះ ។, ដូចព្រាហ្មណ៍ម្នាក់ដែលធ្វើការកុសលបន្តិចម្តងៗ ជាលំដាប់ ដរាបដល់បានសម្រេចមគ្គផល ។ សូមនាំរឿងនោះមកសំដែង ជាឧទាហរណ៍ដូចតទៅនេះ ។ រឿងនោះមានសំដែងនៅក្នុងគម្ពីរខុទ្ទកនិកាយថា:

មានព្រាហ្មណ៍ម្នាក់បានធ្វើបុណ្យជាលំដាប់ ។ តាំងពីតិច ។ ដរាបដល់បានសម្រេចមគ្គផលជាទីបំផុត ។ មុនដំបូងបានឃើញទីដែលកិក្ខុ ១ រូបឈរឃ្លុំចីពរ, ទីនោះមិនស្អាតប្រឡាក់ដោយកាក់ធំធេងស្មៅ; ក៏ធ្វើឲ្យស្អាតឡើងបានដង្ហានដ៏ច្រាប់យកមកពោយពាយ រួចធ្វើជាកំពាំងគំរបថ្ម, ខាងក្រោយបំផុតបានសាងសាលា ១ ត្រង់ទីនោះ ។ លុះសង្ឃសាលានោះបានឱមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធានមកថ្វាយកត្តុ, ហើយក៏ក្រាបបង្គំទូលប្រវត្តិហេតុនៃការសាងសាលានោះតាំងពីខាងដើមជាលំដាប់

មក, រួចហើយវេរសាលានោះថ្វាយចំពោះសង្ឃមានព្រះពុទ្ធជាប្រធាន ។
កាលដែលព្រះបរមគ្រូនឹងទ្រង់អនុមោទនា ក៏ទ្រង់សំដែងគាថានេះថា :

អនុប្បុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។

"អ្នកមានប្រាជ្ញាគួរកំចាត់មន្ទិលរបស់ខ្លួនក្នុងខណៈ ។ បន្តិចម្តងៗ
ដោយលំដាប់គ្នា, ដូចជាងមាសដែលជម្រះស្នាមនៃមាសប្រាក់ដូច្នោះ" ។

ហេតុនេះ សប្បុរសទាំងឡាយគួរប្រតិបត្តិតាមពុទ្ធវចនេះគ្រប់ៗ
ប្រាណ ។

ពាក្យដែលខ្ញុំនាងឲ្យធ្វើចិត្តរបស់ខ្លួនឲ្យរួសរាន់ជាលំដាប់ ដកបដល់
បានសម្រេចអរហត្តជាទីបំផុត ដូចសំដែងមកនេះ ពាប់ថាជាពុទ្ធសាសនា
ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធពាល់ព្រះអង្គដែលបាន
ត្រាស់កន្លងកាលទាំងពួង តែងតែទ្រង់ប្រដៅដូច្នេះ ។

ធម៌ទេសនាដែលសំដែងមកកន្លងវេលានេះ សន្មត់ថាចប់ដោយ
សង្ខេបត្រឹមប៉ុណ្ណេះ ។

ដោយតេជះនៃធម្មទេសនានេះ បរិស័ទទាំងឡាយគ្រប់ជាន់ ដែល
បានប្រតិបត្តិតាមសាសនវិធី ត្រាមអធិបតេយ្យនៃព្រះសម្មាសម្ពុទ្ធ សូម
ឲ្យបានប្រកបដោយអនាតុរភាព (សេចក្តីមិនក្តៅក្រហាយ), ដើម្បីជា
ពលវត្ថុ ប្រកបកិច្ចសាសនា បានមគ្គាគិសម័យសមតាមអធ្យាស្រ័យ
វត្ថុចំណង់កុំបីឃ្លៀងឃ្លាត ឯរ ។

បញ្ញាសជាតក

ភាគទី ៤

បណ្ឌិតមហា ឈឺម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលទៅជាភេទបព្វជិតគឺ ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

រដ្ឋដ្ឋលីវជាតក ទី ២០

លោកអាចារ្យ ឈឺម-ណាក ប្រែពីបាលី

(ត-ដប់)

ព្រះមហាបុរសបានទ្រង់ព្រះសវនាការតាក្យនោះហើយ ក៏ត្រាស់ថា យើងនឹងធ្វើស្តេចត្រមាំងពលត្រាំងអស់នោះឲ្យវត់ទៅឯង ។ តតសម្លាប់ដោយគ្រឿងសស្ត្រាវុធណាមួយឡើយ ។

គ្រានោះ សហជាតអមាត្យទាំងឡាយដែលមានកំណើតថ្ងៃជាមួយនឹងព្រះពោធិសត្វ ក្រាបបង្គំទូលព្រះពោធិសត្វថា បពិត្រព្រះសម្មតិទេព, យើងខ្ញុំសូមបង្ក្រាំង, ទូលព្រះបង្គំជាខ្ញុំទាំងអស់ សុទ្ធតែជាអ្នកមានកំលាំងពលំ ជាវីរបុរសក្លៀវក្លាអង់អាចឈ្នះសត្រូវក្នុងសង្គ្រាម មិនជាអ្នកត្រឡប់វត់ថយក្រោយទេ, អាចញាំញីពួកសេនាបរស់ស្តេចជាខៃឲ្យខ្ចេចខ្ចីដូចផងធូលីបាន ដូចជាមហាគជេន្ទ្រឆាវ័ណ្ណ មិនមែនដូចដំរីសាម័ញ្ញឡើយ ខ្ញុំព្រះអង្គទាំងឡាយ សូមទទួលអាសាចាប់ស្តេចទាំង ១០១ ត្រមាំងយោងជាឲ្យត្រាតែបាន, សូមព្រះករុណាទ្រង់ព្រះរាជាទុញ្ញាត ។ ព្រះមហា-

សត្វមានព្រះភាគត្រាស់ថា "ណ្ហើយ, អ្នកចាំងឡាយកុំច្បាំងឡើយ, តែកើតច្បាំងហើយ មុខជាពួកស្តេច ๑๐๑ ទីធ៌ពួកពលចាំងអស់ខ្លះស្លាប់នាំមុខអស់មិនខាន សូម្បីតែអមាត្យម្នាក់ដែលរួចខ្លួន រត់ចាំដណ្តើមព័ន្ធអ្នកចាំងនោះស្លាប់ ទៅជ្រាបដល់កូនប្រពន្ធចាំងឡាយឯស្រុក ក៏គ្មានផង, ហេតុដូច្នេះ បងអ្នកចាំងអស់គ្នាឆ្លងទឹកបរិភោគបាយព្រឹកហើយស្លៀកពាក់តាក់តែងកាយ មកហែខ្ញុំទៅតាមដំណើរប្រក្រតី, ខ្ញុំដំរើលើខ្នងដំរី ទៅបង្អើលពួកស្តេច ๑๐๑ ព្រមចាំងពួកពលចាំងអស់ឲ្យរត់ខ្ចាត់ខ្ចាយ ដោយគ្រាន់តែចង្អុលដោយម្រាមដៃ ๑ ខ្ញុំមិនសម្លាប់ទេ, ណ្ហើយ, អ្នកចាំងឡាយកុំព្រួយបារម្ភណ៍ថ្វី ដល់ថ្ងៃស្អែកសឹមអ្នកចាំងអស់គ្នា មកហែខ្ញុំចេញទៅ" ទ្រង់មានព្រះភាគត្រាស់ដូច្នេះហើយ ក៏បញ្ជូនពួកអមាត្យឲ្យទៅកាន់ទីលំនៅរបស់ខ្លួនវិញ ។

លំដាប់នោះ កាលដែលរាត្រីភ្លឺច្បាស់ហើយ ព្រះពោធិសត្វទ្រង់ស្រង់ទ្រង់សោយព្រះស្នូយដែលមានរសជាតិឆ្ងាញ់ពីសារ ស្តេចទ្រង់គ្រឿងអលង្ការគ្រប់គ្រឿងស្រេច ស្តេចទៅប្រថាប់នៅនាព្រះភដ្ឋាន ទ្រង់ប្រជុំពួកអមាត្យចាំងអស់ ហើយទ្រង់តង់លើតដេន្ទូដែលជាភដ្ឋាសនៈប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង មានខ្សែដង្គួនខ្សែហាង ស្អិតស្អាងដោយមាស ជាដំរីដែលគេប្រើប្រាស់ដោយកន្លែងពេជដែលគេបង្ហាត់បានបទត្រឹមត្រូវ អាចញាំញីនូវសេនាដ៏ក្លៀវក្លារបស់ស្តេចដទៃបាន ទ្រង់មានពួកអមាត្យហែហមជោមជេមជាបរិវារ ដូចជាសក្កទេវរាជ ដែលមានពួកទេវតា ពួកស្រីអប្សរបរិវារកញ្ញា មានរូបយ៉ាងល្អ

ចំណាប់ ទឹង្សែជាទេតមហេសីតាំង ៤ ហែហមទៅដូច្នោះ ព្រះអង្គមាន
ពួកពលបរិវារ ដែលមានរូបកាយស្អាតៗ ជារាប់ចែន បក់ជាតំបែរដោយ
សុវណ្ណពាលវិជនី មានជនវិចិត្រដោយវត្ថុនានាផ្សេងៗ អ្នកខ្លះបើកឆ្នាំង
ស្លែត្រឹមតែវិចិត្រដោយកែវមណីមាសសុវណ្ណ, អ្នកខ្លះកាន់ខ្លឹកាន់ផ្លាំង
សំពត់, អ្នកខ្លះប្រគំដេញដំតូរ្យតន្ត្រី មានប្រការផ្សេងៗ, អ្នកខ្លះកាន់
ប្រដាប់ប្រដាជវែងៗ ផ្សេងៗ ជារាប់ចែនប្រការ, ហែព្រះពលាតាមព្រះ
ពលបវរណីដូចធម្មតាប្រក្រតី, ព្រះបរិទ្ធន៍ចេញទៅតាមទ្វារទាន់កើត,
ទ្រង់ទតឃើញសេនាវបស់ស្តេចជវែហើយ ត្រាស់ព្រះពលនុង្កាវសួរថា
បតុរង្គអង្គសេនាតាំង ៤ ពួក គឺសេនាដំរី សេនាសេះ សេនារថ សេនា
ថ្មើរជើង មកឡោមព័ទ្ធដុំវិញខ្លួនឯាញ់ ដ៏ល្អថ្កុំថ្កើងរុងរឿងដូចព្រះអាទិត្យ
តម្រៀបគ្នាជាជួរជាប់ប្រកិតតាមគ្រោយខ្នងគ្នា ដូចជារបៀបរលកនៃទឹក
ក្នុងសមុទ្រដុតវិស័យនឹងកប់បាន; សេនាគាហានច្រើនតាំងម្ល៉ឺននេះ តើ
ជាសេនាគាហានរបស់អ្នកណា? ។ អមាត្យតាំងឡាយបានស្តាប់ព្រះពល-
នុង្កាវនោះហើយ ក៏គ្រាបបង្គំទូលព្រះពោធិសត្វថា បពិត្រព្រះសម្មតិ-
ទេព ស្តេចតាំង ១០១ អង្គក្នុងជម្ពូទ្វីបនេះ មកដើម្បីច្បាំងជាមួយនឹង
យើង, សេនាគាហានជារាប់ចែនមានរបៀបដូចជារលកសាគរមិនដាច់ពី
គ្នានេះ ជាសេនាគាហានរបស់ស្តេចតាំងនោះ ។ ព្រះពោធិសត្វ ទ្រង់
ព្រះសណ្តាប់ពាក្យអមាត្យគ្រាបបង្គំទូលដូច្នោះហើយ ទើបត្រាស់ព្រះ
ពលនុង្កាវថា នែព្រះស្តេងតាំងឡាយ ចូរអ្នកពាល់គ្នា ទៅប្រាប់ស្តេច
តាំង ១០១ តាមពាក្យខ្ញុំថា បើស្តេចត្រៀបអង្គចង់ច្បាំងជាមួយនឹងខ្ញុំ ចូរ

ឡើងគង់ដំរីឱ្យត្រង់ ๆ អង្គុយចុះ, មិនតែប៉ុណ្ណោះ ទាំងពួកសេនាដំរី
ក៏ត្រូវឡើងជិះដំរី ពួកសេនាសេះ ក៏ត្រូវឡើងជិះសេះ, ពួកសេនារថ
ក៏ត្រូវឡើងជិះរថ ពួកអ្នកកាន់ទង់ជ័យកាន់ផ្លាំងសំពត់ ក៏ត្រូវលើកឡើង
តាមចំណាំចុះ, ពួកសេនាថ្មើរដើរទាំងនោះ ក៏ត្រូវប្រុងប្រៀបគ្រឿង
ក្រែ ខឹងកិច្ចការត្រង់យ៉ាង ដែលត្រូវធ្វើក្នុងសង្គ្រាមឱ្យរាប់ ๆ ភ្លាម ๆ
ឡើង ។ អមាត្យទាំងឡាយ ទៅថ្វាយដំណឹងដល់ពួកស្តេចទាំង ๑๐๑
តាមព្រះពាជនុង្ការនោះ សព្វគ្រប់ប្រការ ។ ព្រះពាគ្រប់ព្រះអង្គ ទ្រង់
ព្រះសណ្តាប់ពាក្យអមាត្យទាំងឡាយហើយ ក៏ទះព្រះហត្ថាសើចហាក
ក្លែក្លាំវាខ្លៀវខ្លាចក្រហឹងអឺងអាប់ ហាក់ដូចសំពួសន្ធឹកស្រុតទ្រុវផន
ប្រឋពី, ព្រះពាទាំងនោះ ព្រមទាំងសេនាបតីធំធំពួកមហាទាំងអស់
សុទ្ធសឹងប្រដាប់ដោយគ្រឿងក្រែដ៏ល្អស្រស់ថ្លៃថ្លា ហត្ថាកាន់លំពែង
កាន់ខែល កាន់អាវុធមានប្រការផ្សេង ๆ ឡើងដិះតាហណៈ តាមសមគួរ
ដល់ដំណែងរៀង ๆ ខ្លួន ។ កងទ័ពទាំងអស់គ្រវីលំពែងវែងស្មងក្រហ ទំង
ព្រះខាន់ផ្សេង ๆ មានពន្លឺភ្លឺផ្លេកពាសពេញទាំងអាកាស ដូចជាលជេរ-
ជាសដូចផ្លេកបន្ទោរជាច្រើនកោដិ ពួកដំរី ក៏បញ្ចេញកោញ្ចនាទជញ្ជួច
ក្រហឹង, ពួកសេះក៏កញ្ជ្រែវខ្លៀវខ្លារ ពួកពលថ្មើរដើរ ក៏ស្រែកសន្ធាប់;
សំឡេងគឹកកងនៃពួកជនទាំងនោះ ដូចជាសន្ធឹកខ្យល់ប្រល័យកប្ប ។
ស្តេចទាំង ๑๐๑ ឈរមុខសំដៅទៅរកព្រះពោធិសត្វ ដោយការប្រុង
ប្រយ័ត្នច្រើនសង្ឃឹតយកជ័យ ។

លំដាប់នោះ ដោយអានិសង្សវៃការកុសាងមានព្រះហស្តព្រះ

ពុទ្ធបដិមា ក៏ព្រះពោធិសត្វ គ្រាន់តែលើកព្រះហស្តមួយចង្កុលពួក
ស្តេចទឹងពួកពលទាំងនោះ ក៏ពួកពលដំរី ធ្លាក់ពីលើដំរី, ពួកពលសេះ
ធ្លាក់ពីលើសេះ, ពួកពលរថ ធ្លាក់ពីលើរថ, ពួកពលថ្មើរជើង ដែល
មានគ្រឿងក្រោះសៀតយ៉ាងជិតស្និទ្ធ ក៏រត់ខ្ចាត់ខ្ចាយទៅ, ពួកខ្លះដួល
ស្រេះជាប់នៅតែនឹង, ពួកខ្លះរត់ទៅដោយរហ័ស ពួកខ្លះចូលព្រៃភ្នំ,
ពួកខ្លះក៏ចូលទៅពួនសម្ងំនៅក្បែរមាត់ព្រៃក មាត់ស្ទឹងបឹងទន្លេនឹងមាត់
សមុទ្រ, ពួកខ្លះក៏របួតសំពត់រត់ទៅទាំងអាក្រាត ។ ព្រះមហាសត្វ
ឃើញជនទាំងនោះដល់នូវវិបរិតដូច្នោះ ក៏មានព្រះពាក្យប្តូរទ័យកាណិត
អាសូរ មានព្រះពាក្យតង្កាវថា នែអ្នកទាំងឡាយ! ចូរអ្នកពាល់គ្នាត្រេកត្រឡែង កុំភ័យឡើយ ។ ពួកស្តេចទាំងអស់នោះ ត្រេកត្រឡែងភ័យ
ខ្លាចស្ងាប់ ក៏អង្គុយថ្កុលម្យអញ្ជលី អង្វរកសូមថ្វាយគ្រឿងសក្ការៈ
ឧដ្ឋាកដសម្បត្តិ ព្រមទាំងកដធីតារបស់ខ្លួនដល់ព្រះពោធិសត្វ ។ ព្រះ
បាទវដ្ដគ្គុលាកដបរមពោធិសត្វ ក៏បានជាស្តេចឯកកដ្យក្នុងជម្ពូទ្វីប ទ្រង់
ទូន្មានប្រៀនប្រដៅស្តេចទាំងនោះ ហើយបញ្ជូនទៅកាន់រាជធានីរបស់ខ្លួន
ទាំងទ្វេរវិញ ។ ព្រះបាទវដ្ដគ្គុលាកដ ក៏ទ្រង់ស្តេចចូលទៅកាន់ព្រះពាជបុរី
របស់ព្រះអង្គ ព្រមទាំងបរិវារ ។ លំដាប់ពីនោះមក ពួកស្តេចទាំង ១០១
តែងបញ្ជូនគ្រឿងបណ្ណាការសួយសាអាករ មកថ្វាយព្រះបាទវដ្ដគ្គុលាកដ
នោះរៀងរាល់ឆ្នាំ ។ ព្រះមហាសត្វ តែងទ្រង់ព្រះពាជទាន ព្រះពាជទ្រព្យ
គ្រប់មុខរបស់ព្រះអង្គ ឲ្យជាទានដល់សមយោចកអ្នកកំសត់ទុគ្គតទីពាល់ក្រ

ទ្រង់សោយភត្តប្រកបដោយទសពិធភាជនទិព្វ ១០ ប្រការ ឥតមានព្រះភក្ត្រហប់ទ្រង់លំអៀងដោយអតតិណាមួយឡើយ ។

សម័យនោះ អាសនៈសក្កទេវភាជ ក៏សំដែងអាការៈត្កឹតត្កាយ។ឡើងដោយអានុភាពនៃសេចក្តីកតញ្ញូរបស់ព្រះមហាសត្វ ។ សក្កទេវភាជទ្រង់អាវជ្ជនាការពិចារណាដោយទិព្វចក្ខុឃើញហេតុនោះហើយ ទ្រង់ចុះពីទេវលោកមកភ្លាម ចូលមកកាន់សំណាក់ព្រះមហាសត្វ ទ្រង់ញ៉ាំងទិសឲ្យស្វាងរុងរឿងដូចជាព្រះអាទិត្យកំពុងរះឡើងនាគាលយ, បន្លឺញ្ជាសូរស្តីព្រៃនព្រាត ហើយទ្រង់ត្រាស់សួរព្រះមហាសត្វថា:

បុច្ឆាមិ តំ មហារាជ កិំ បុញ្ញំ បកតំ តយា
បុព្វេ បិ ភេន បុញ្ញេន លទ្ធោ តេ វិជយោ អយំ ។

"បពិត្រមហាភជាស្តេចធំ, ខ្ញុំសូមសួរព្រះអង្គ, កាលពីដើមព្រះអង្គបានធ្វើបុណ្យដូចម្តេច? ជ័យជំនះដែលព្រះអង្គបានឈ្នះដោយឥតមានសេចក្តីខ្នះខ្នែងក្នុងសង្គ្រាមប៉ុន្មាននេះ តើព្រះអង្គបានដោយបុញ្ញកម្មដូចម្តេច?" ។

ព្រះពោធិសត្វទ្រង់ព្រះសវនាការ ស្តាប់ព្រះពាក្យបុច្ឆារបស់ព្រះឥន្ទ្រាធិភាជនោះហើយ ទ្រង់មានព្រះហឫទ័យត្រេកអរសាទរ ទ្រង់មានជាតិសរញ្ញាណរលឹកនឹកឃើញព្រះជាតិរបស់ព្រះអង្គកន្លងកាលមុន ទើបទ្រង់សំដែងនូវបុព្វកម្មរបស់ព្រះអង្គថា:

ពាណិជ្ជោហំ បុរេ អាសឹ នាមកោ កុលភទ្ទកោ
គច្ឆាមិ តេន សទ្ធឹ សោ ធនេន ទាយំ ឯសតិ
ធិនុមេកាឯលឹ ទិស្វា ពុទ្ធរូបស្ស តាវទេ
អហំ តុដ្ឋបិត្តោ អាសឹ ន ទិស្សាមិ ចេតសា
មទ្ទិត្វា មត្តិកាសុទ្ធិ គុឡ្ហិយា អង្គុលឹ ករេ
តេន បុញ្ញានុភាវេន លទ្ធា មេ វិជយោ អយំ

- ‘‘បពិត្រសម្តេចសង្ឃនាយក, កាលពីមុន ខ្ញុំបាទកើតជាឈ្មួញឈ្មោះ កុលភទ្ទៈពាណិជ ជាទៅស្រែងកន្ត្រកយកទៅប្រាយដោយការជួញប្រែ ជាមួយនឹងពួកឈ្មួញអ្នកមានទ្រព្យផងគ្នា, គ្រានោះ ខ្ញុំបាទឃើញព្រះហស្ត១ របស់ព្រះពុទ្ធរូប១ ព្រះអង្គ ដែលរបេះជាច់ជាត់, ខ្ញុំក៏មានចិត្តត្រេកអរពុំអាចអត់សង្កត់ទប់ចិត្តបាន ទើបយកដីស្អិតដ៏ល្អ មកច្របាច់លាយដោយប្រេងល្អ ត្រមាមព្រះហស្តព្រះពុទ្ធរូបនោះឲ្យបានជាប្រក្រតីឡើងវិញ ដោយអានុភាពនៃបុណ្យដែលបានដួសដុលព្រះហស្តព្រះពុទ្ធរូបនោះ បានជាដល់មកជាតិនេះ ខ្ញុំមានជ័យជំនះឈ្នះសឹកសត្រូវ ដោយគ្រាន់តែលើកព្រះដៃចង្អុលៗដាច់នេះ ម្យ៉ាងទៀតទៅ ទោះបីស័ព្ទមិគពាជ ដ៏ការបសាហារក្តី ឬដំរីដ៏ក្លៀវក្លាពាំងពាន់ក្តី ពួកសេនាយោធាព្រមទាំងវាយនេប្រើនយ៉ាងណាក្តី បើហ៊ានឈរមុខឆ្ពោះត្រង់មកកន្លែងខ្ញុំ ដោយចំណងចង់ប្រកាន់ប្រឆាំងមានសេចក្តីខ្ពើមអន្តរាយ, ខ្ញុំគ្រាន់

តែលើកម្រាមដៃ ๑ ចង្អុលទៅ ក៏អាចការពារខ្លួនឲ្យរួចផុតអន្តរាយនោះបាន, សត្រូវទាំងប៉ុន្មានមានពាជសីហ៍ជាដើមនោះ ក៏នឹងភ្ញាក់ផ្អើលរត់រង្គាត់ទាំងព្រាត់ព្រាយខ្ចាត់ខ្ចាយអស់ទៅ ឬនឹងដួលផេកក្រាបនៅក្នុងតែនោះក៏សឹងមាន; ឋិតក្នុងសម្តេចសហស្សន័យទេវរាជិស្សរ, ដោយតេជៈបុណ្យដែលខ្ញុំបានដួសដុលម្រាមព្រះហស្តព្រះពុទ្ធរូបនោះ តទៅខាងអនាគត ខ្ញុំនឹងបានត្រាស់ជាព្រះពុទ្ធ ជាលោកនាយកឯតគ្មានពុំខាន" ។ ព្រះអង្គទ្រង់មានព្រះពាជក្សារ ចំពោះព្រះតន្ត្រីពាជដូច្នេះស្រេច ទើបស្តេចទ្រង់ប្រកាសជូនប្រាប់ដល់បណ្តាជនប្រុសស្រីទាំងឡាយថា ម្នាលអ្នកទាំងឡាយដ៏ចំរើន, មិនត្រឹមតែការកសាងព្រះពុទ្ធរូបប៉ុណ្ណោះទេ, ទាំងពុទ្ធបូជា ដែលអ្នកទាំងឡាយមានសទ្ធាជ្រះថ្លាបូជាចំពោះព្រះពុទ្ធហើយ សូម្បីបន្តិចបន្តួចសោះ ក៏គង់មានអានិសង្សច្រើនជាអនេក ។

សម្តេចព្រះវជិរញាណសក្កទេវពាជ ទ្រង់ព្រះសណ្តាប់ព្រះពាជក្សារព្រះចុងវជ្ជគ្គិលីពាជនោះហើយ ទ្រង់មានព្រះពាជហ្ឫទ័យប្រកបដោយសេចក្តីជ្រះថ្លាជាសោមនស្ស កាលទ្រង់គន់គំរើងដែងខ្លួនឲ្យព្រះចុងវជ្ជគ្គិលីជាមច្ចាស់ ទ្រង់សរសើរដូច្នេះថា:

សក្កោបមស្មិ ទេវិន្ទោ អាគតោស្មិ តវ សន្តិកេ
អនាគតេបិ សម្ពុទ្ធោ បាបុណិស្សសិ ភូបតិ
និសិន្នោ ពោធិមូលស្មិំ មារញ្ជេវ វិធំសនំ
បក្ខវិទ្ធបរិយន្តំ និក្កិលំសោ បរាជយិ

កិលេសកុន្ថមារញ្ច មច្ចុមារំ អសេសតោ
ទ្វិត្តិំស ឥរកេ សុញ្ញេ កវោសិ សគ្គំ ប្បរយិ
ធម្មមបាវោបេត្វាន អមត្តសគ្គេ ច បាបុណីតិ ។

"បពិត្រមហាបុរស, ខ្ញុំនខ្ញុំនេះ ជាសក្កទេវរាជ ជាធំជាងទេព្តាទាំងឡាយ បានមកគាន់សំណាក់ព្រះអង្គក្នុងកាលឥឡូវនេះ; បពិត្រព្រះម្ចាស់ដែនដី, ខ្ញុំព្រះអង្គមានសេចក្តីសង្ឃឹមថា តទៅក្នុងអនាគតកាលខាងមុខ ព្រះអង្គនឹងបានតំណែងព្រះពុទ្ធត្វមណ្ឌល កំចាត់បង់មារ-ធិបតីព្រមទាំងពលឲ្យបរាជ័យចាញ់តេជៈដៃ រត់ខ្ចាត់ខ្ចាយទៅឲ្យដល់កណ្តាប់ចក្រវាឡ ក្នុងកំចាត់បង់នូវកិលេសមារ ខន្ធមារ មច្ចុមារ មិនឲ្យមានសេសសល់, ក្នុងនឹងបានដល់នូវសម្មាសម្ពោធិញ្ញាណ បានត្រាស់ជាព្រះពុទ្ធ ក្នុងនឹងធ្វើនរកភាំង ៣២ រណ្តៅឲ្យសូន្យ ហើយក្នុងលើកឡើងនូវសត្តនិករ ដាក់ក្នុងសំពៅពោលតីធម៌ បើកបរសំដៅទៅដាល់ទុកក្នុងហានសួគ៌ គឺជាអម្តឹតមហានិព្វាន ជាប្រាកដពុំខាន" ។

សម្តេចសក្កទេវរាជ ត្រាស់សរសើរព្រះមហាសត្វដូច្នោះហើយ ក្នុងលាព្រះពោធិសត្វ ធ្វើនិវត្តនាការត្រឡប់ទៅគាន់ទេវលោក ជាទីនិវេសនដ្ឋានរបស់ព្រះអង្គវិញ ក្នុងខណៈនេះឯង ។

អង្គុសម្តេចព្រះបរមសាស្តាជាម្ចាស់ ក្នុងនាំព្រះធម្មទេសនានេះមកសំដែងហើយ កាលក្នុងសំដែងអានិសង្សនៃការកសាងព្រះពុទ្ធបដិមា ចំពោះព្រះភក្ត្របរមសុខុមាលក្នុងត្រាស់ជាបទព្រះគាថាថា:

សត្តក្ខត្តុំ ប ទេវិន្ទោ ទេវិន្ទដ្ឋមការយិ
អសីតិ ប សត្តក្ខត្តុំ បក្កាវត្តិសិរីរវោ

សេចក្តីកង់បទ ព្រះគាថានោះថា បុគ្គលអ្នកកសាង ព្រះពុទ្ធរូបនោះ ទើងបានជាព្រះឥន្ទ្រ ស្រេះយទេវសម្បត្តិដល់ ៧ ជាតិ, ចាំងបានជាសម្តេចបរមេចក្កពត្តិ មានសិរីសម្បត្តិដ៏ច្រើសើរដល់ ៨០ ជាតិឬ ១០០ ជាតិ ទើងបានជាស្តេចច្រើនសាជ ជាច្រើនអស្រេងយ្យជាតិរាប់ពុំបាន ។ មួយវិញទៀតបុគ្គលឯណា បានធ្វើបដិសង្ខរណកិច្ច ជួសជុលព្រះពុទ្ធរូបដែលមានអាយុវែកលែការដាប់របេះត្រើងកន្លែងណា ។ ក្តី ដោយត្រឹមតែដ៏ស្អិតមាំដ៏ប៉ុណ្ណោះ កំផលានិសង្សនៃការជួសជុលព្រះពុទ្ធរូបនោះ ជាអចិន្តេយ្យផលដុតវិស័យ ទើងគិតឲ្យដឹងកំណត់ថាប៉ុណ្ណោះប៉ុណ្ណោះបាន ។ បុគ្គលអ្នកកសាងព្រះពុទ្ធរូបមានសភាពដូច្នោះ ដោយមានបីតិសេចក្តីជ្រះថ្លាហើយ ផលអានិសង្សនោះក៏តេញបរិបូណ៌ អាចនាំបុគ្គលនោះឲ្យទៅឧប្បត្តិចាប់ជាតិកំណើតកើតក្នុងឋានសួគ៌ អស់កាលជាអង្វែងគ្រប់គ្នា ។ បុគ្គលអ្នកកសាងព្រះពុទ្ធរូបដោយដ៏ស្អិតវិចិត្រឲ្យជារបស់ថ្លៃថ្លា ឬគួរវាស្រចនាដោយផ្ងាំងសំពត់ ឬផ្ងាំងវត្ថុអ្វីដែលល្អមធ្វើបានក៏បុគ្គលអ្នកកសាងនោះ ត្រូវមានតេជះច្រើនគ្រប់គ្នា ដូចជាព្រះអាទិត្យ ដែលរះបា្រស់ច្បាសចាកមន្ទិលស្មៅហ្នឹងដូច្នោះ, បុគ្គលនោះ កាលមានជាតិជាមនុស្សវៃស្មៅដរាបដល់អស់ជីវិត រំលងខន្ធទៅកាន់បរលោកនាយ មិនដែលក្លាយជាតិកំណើតទៅកើតជានរកឬប្រែត មិនកើតក្នុងទុគ្គតិភព

មិនកើតជាតិច្ចានដែលមានពាងកាយធំ ឬ តូចយ៉ាងណាឡើយ ព្រោះ
ហេតុដែលបានកសាងកុសលគឺ សាងព្រះពុទ្ធរូបនោះឯង ។ ព្រះពុទ្ធរូប
នោះ បុគ្គលឯណាសាងហើយ ទោះបីតូចក្តីធំក្តី គួរជាគំនូរក្តីផលានិសង្ស
នោះ ក៏បានសម្រេចស្មើៗគ្នា តាមដោយកម្លាំងសទ្ធាសេចក្តីជ្រះថ្លា;
កន្លងចំណោមជនតាំង ៣ ពួកគឺ អ្នកដាំដើមគោធំព្រឹក្ស ១ ពួក អ្នកប្តេជ្ញា
ខ្លួនបួលបួសក្នុងព្រះពុទ្ធសាសនា ១ ពួក អ្នកកសាងព្រះពុទ្ធរូប ១ ពួក
នោះត្រូវបានផលអានិសង្សដូចគ្នា; បើច្បាច្ចាចន៍បានត្រាស់ជាព្រះពុទ្ធ,
ក៏ឥឡូវបានត្រាស់ជាច្បាកដតុំខាន ។ បុរសបុគ្គលណាមួយ កសាងព្រះ
ពុទ្ធរូប ដោយក្តុកដំរីក្តី ដោយស្មែងសត្វអ្វីៗក្តី ដោយថ្មសិលាក្តី
ដោយឥដ្ឋដាធម្មតាក្តី ទោះបីជួលគេកសាង ឬកសាងផ្ទាល់ខ្លួនឯង,
ក៏បុរសបុគ្គលនោះ អនុមោទនាតាំងតែតើតក្នុងពេលកាលអនាគត ឥឡូវ
បានសម្រេចនូវព្រះនិព្វានជាទីបំផុតនៃសេចក្តីទុក្ខ ក្នុងសំណាក់នៃព្រះ
អរិយមេត្តេយ្យសម្មាសម្ពុទ្ធ ឬបើច្បាច្ចាចន៍បានត្រាស់ជាព្រះពុទ្ធឡាល់ខ្លួន
ឯង, ក៏ច្បាកដជាទើបានត្រាស់ក្នុងកាលជាខាងក្រោយពុំខាន ។ ការ
អគ្គិសម្ពុចព្រះបរមសពិដ្ឋសាស្តាចារ្យ ទ្រង់ត្រាស់សំដែងធម្មទេសនា
ចប់សព្វគ្រប់ហើយ, មនុស្សនឹងទេវតាតាំងឡាយជារាប់ បានសម្រេច
មគ្គផលខ្លះៗផ្សេងៗពីគ្នា តាមសមគួរដល់ឧបនិស្ស័យបច្ច័យរៀងៗខ្លួន
ខ្លះបានសម្រេចដល់ត្រើសោតា សកិទាគា អនាគា អរហត្ត កំចាត់បង់នូវ
កិលេស ឥតមានសេសសល់នៅក្នុងខន្ធសន្តាន ដោយបានស្តាប់ធម្ម

ទេសនានេះ ។ សម្តេចព្រះបរមសាស្តាចារ្យជាម្ចាស់ ទ្រង់ត្រាស់សំដែង
ថ្វែងជាតកនេះចប់សព្វគ្រប់ហើយ ទ្រង់ជុំជាតកថា ពួកយោធាសេនា
ឥឡូវបស់ព្រះបាទវិដូដ្ឋភ្លើកជនាំងប៉ុន្មាន បានមកកើតជាពុទ្ធបរិសទ្យ
ចាំងអស់, ព្រះបាទវិដូដ្ឋភ្លើកជនោះ បានត្រាស់ជាព្រះសម្មាសម្ពុទ្ធ គឺអង្គ
តថាគតហ្នឹងឯង ។

ចប់ វិដូដ្ឋភ្លើកជាតក ទី ២០

ការខ្លាចនៃវត្ត ៤ យ៉ាង

១- ទឹកខ្លាចគេជន់ពុកជំកល់

២ ជាតិដែរដែកដុលខ្លាចដំរៅ

៣- ក្រញូងខ្លាចឆ្លើយកួចដូចស្មៅ

៤- ពួកខ្លាចគេទៅជាន់តែមឆ្អឹង ។

ធៀបនឹងមនុស្សខ្លាច ៤ ពួក

ទី ១- អ្នកមានចំណេះខ្លាចគេពុកៈស្រឡឹម

ទី ២- អ្នកធ្វើការងារខ្លាចគេប្រែគ្នានថ្ងៃ

ទី ៣- អ្នកជាន់ខ្ពស់ខ្លាចគេប្រឹក្សាធ្វើការខាងថោក

ទី ៤- អ្នកមានរឿងខ្លាចអ្នកឯទៃមកជាសំអាង ។

ផ្នែកអក្សរសាស្ត្រ

ទំនៀមទម្លាប់ស្ត្រីខ្មៅស្រុកឥណ្ឌា

អ្នកស្រី ពេជ្រ - សល់ ហៅ សារីះយ៉ាង ប្រែជា

អត្ថបទរបស់លោកអាលេក្សង់ទ្រី - ដាវីដ - ណែល

ក្នុងទស្សនាវដ្តីហ្វ្រង្ស - អាស៊ី

ពិតមែនតែខ្មៅស្រុកឥណ្ឌាមានជនជាតិស្បែកខ្មៅខ្មែរយើងច្រើនពាន់ពាន់នាក់ក៏ដោយ ប៉ុន្តែគេគង់អាចស្រាវជ្រាវរកទំនៀមទម្លាប់ជនជាតិឥណ្ឌានេះបានដោយអាស័យការសាកសួរអ្នកស្រុកឥណ្ឌា ដែលជាអ្នកពុំសូវគាន់រៀបរាប់ប៉ុន្មានទេមើលចុះ ។

ទោះជាយ៉ាងណាក៏ដោយ ជនជាតិឥណ្ឌានេះមិនមានទំនៀមទម្លាប់យង់ឃ្នងដូចខ្មៅស្រុកអាហ្វ្រិកទេ ព្រោះខ្មៅស្រុកអាហ្វ្រិកគេចាត់មនុស្សស្រីដូចជាសត្វធាតុ គេប្រើមនុស្សស្រីឲ្យធ្វើការធ្ងន់ៗ ចំណែកបុរសជាប្តីវិញទៅជាខ្មៅទំនេរលេងសប្បាយទៅវិញ ។

ជនជាតិឥណ្ឌាចាត់ស្ត្រីការពារជា "មនុស្សគោរពថ្កាកបំផុត" ដោយហេតុនេះហើយទើបស្រីៗជាតិឥណ្ឌាប្លាស់ប្តូរឲ្យបានកើតជាភេទបុរសក្នុងជាតិខាងមុខទៀត ព្រោះជនជាតិនេះជឿថាកាលស្លាប់ហើយនឹងកើតវិញ ដូចខ្មែរយើងដែរ ។ ប៉ុន្តែយើងមិនត្រូវចេះតែជឿទៅៗទេ ព្រោះគេបានសង្កេតឃើញស្ត្រីជាតិឥណ្ឌាតែងតែគាន់តំណែងមួយយ៉ាងមាំ ក្នុងគ្រួសារតែងការពារកិច្ចធ្ងន់ធ្ងរសង្គម ហើយមានសេរីភាពច្រើនណាស់ ។ ប្រហែល

មកពីស្ត្រីជាតិនេះមានមាឌទំ ហើយអាចធ្វើការធ្ងន់ៗបាន មិនចាំបាច់ពឹងកំឡាំងបុរសជាដំនួយទេដឹង ទើបបុរសផ្តល់ការងារធ្ងន់ៗឲ្យទៅស្ត្រីៗ ស្រីភស្ត្រជាតិទីបេអាចស្ថាយត់ភ្នំយ៉ាងធ្ងន់ហើយដើរឡើយបាន តោះជាបុរសជាតិអ៊ីរ៉ុបក៏ធន់មិនបានដល់ដែរ, ហើយជាស្ត្រីហ៊ានណាស់ផង ជួនកាលដើរលើកំតែម្នាក់ឯងដល់ទៅពាន់គីឡូម៉ែត្រក៏មាន ព្រោះស្ត្រីជាតិទីបេមិនញាញើតតែនឹងបុរសទេ ។

ពាសតែនៅស្រុកទីបេមិនមានច្បាប់ទម្លាប់ឲ្យត្រឹមត្រូវសោះ ។ បើមានស្តេចឬនាយកណាមួយបង្កើតច្បាប់មួយឡើង អ្នកស្រុកដែលនៅក្នុងអំណាចស្តេចនោះគោរពច្បាប់តែត្រឹមរាជ្យស្តេចនោះ ប៉ុន្តែច្បាប់នោះមិនមែនធ្វើសម្រាប់អ្នកនគរទេ ឃើញតែកត៏នគរយើងនឹងប្រទេសឯទៀត ។ អ្នកស្រុកទីបេគោរពតែទំនៀមទម្លាប់បេះដូចខ្លួន ដែលមានថ្លែកៗគ្នាទៅតាមជនបទ តាមវង្សត្រកូល និងតាមហានៈក្នុងសង្គម ។

ក្នុងលោកតាំងមូល គេស្គាល់ថាន រថស់ស្ត្រីជាតិនីមួយៗ នៅពេលដែលស្ត្រីនោះមានប្តី ។

នៅទីបេ ពេលរៀបកូនស្រីឲ្យមានប្តី ឪពុកម្តាយខាងស្ត្រីគ្មានត្រូវចែកទ្រព្យជាដើមទុនឲ្យកូនស្រីទេ ។ តែបុរសដែលចង់បានប្រពន្ធ ត្រូវជូន "ថ្លៃទឹកដោះ" ឲ្យទៅឪពុកម្តាយខាងស្ត្រី ដូចជាខ្មែរយើងដែរ ។ "ថ្លៃទឹកដោះ" នេះ ពុកជាថ្លៃបំណាច់ដែលបានចិញ្ចឹមកូនស្រីមកនោះ, ចំណែកខាងពួកអ៊ីរ៉ុបវិញ អ្នកមានកូនស្រីពិបាកនឹងរកជនជាន់ពុកឲ្យកូន

ស្រែនៅពេលមានប្តី ។ តាមទំនៀមនេះយើងយល់ថា អ្នកអ៊ីរ៉ូបដែលមានកូនស្រីដូចជាថៅកគេកណាស់ ដែលនៅទិញប្តីឲ្យកូនស្រីវិញ ។

នៅទីបេ ទំនៀមទាក់ទងនឹងប្រពន្ធត្រូវជូន ថ្កាក់-មាស-កែវ-កង ច្រើនតិចតាមជនជាតនៅឲ្យខាងស្រី ។ ប៉ុន្តែមិនមែនស្ត្រីដែលមានប្តីនោះមកនៅខាងប្តីតែម្ខាងទេ ។ កូនស្រីនៃអ្នកមានជនជាន មានយកគ្រាំងមាស-ពេជ្រ-គោ-ក្របី-សេះ ទឹងដីធ្លាមកជាមួយផង ព្រោះរបស់ទ្រព្យគ្រាំងអស់នេះ ជាកេរ្តិ៍មត៌កខាងស្រី ។ បើគាលណាមានរឿងការអ្វីឆ្គងលះគ្នា គឺនៅតែបានមកខាងស្ត្រីដដែល ។

នៅស្រុកទីបេ រៀបយកប្រពន្ធប្តី មានច្រើនយ៉ាងណាស់ : មានប្តីមួយប្រពន្ធមួយ - ប្តីមួយប្រពន្ធច្រើន - ស្រីមួយមានប្តីច្រើន ទំនឹងមានសេរីភាពក្នុងការសេពសម្ផស ។ ប៉ុន្តែគោះបីរបៀបគ្រប់ប៉ុន្មានយ៉ាងខាង លើនេះ គេចុកជាល្អគ្រាំងអស់ក៏ដោយ ជនជាតិទីបេភាគច្រើនបួលចិត្តតែមានប្តីមួយប្រពន្ធមួយ ។ ការយកប្រពន្ធច្រើន។ តែអ្នកមានគោតទ្រព្យគោះជាយ៉ាងណាក៏មិនដល់នៅមានធ្លុះចិញ្ចឹមស្រីដែរ ហើយជាតិនេះមិនចេះបង្ខាំងស្រីមិនឲ្យមានសេរីភាពទេ ។ ធម្មតាអ្នកមានសម្បត្តិ ច្រើនតែមានប្រពន្ធត្រឹមតែរ៉ូណោះ តម្រមានបីណាស់ ហើយស្មុគ្នាតែរៀបការពេញច្បាប់ផង ។

តាមធម្មតា នៅស្រុកជាច្រើន ខាងបូតាប្រទេស តែគាលណាប្រពន្ធប្តីមួយគ្មានកូន គេតែងតែយកប្រពន្ធទីពីរទៀត ព្រោះគេខ្លាចគ្មានអ្នកណាតបូជគេ ។ ម្យ៉ាងទៀត ការណ៍ដែលថ្វាយទ្រព្យសម្បត្តិឬថ្វាយ

ចង់ចាន់ចុណ្យស័ក្តិខ្ពស់ក្នុងសង្គម កំដាហេតុនាំឲ្យបុរសរកប្រពន្ធពី ២ ឬ ៣ ទៀតក៏មាន បើជាប្រពន្ធពី ១ អន់តែក ។ ក្នុងអាពាហ៍ពិពាហ៍, ជនជាតិនេះ មិនមែនថាគ្មានសេចក្តីស្រឡាញ់សោះទេ ប៉ុន្តែគេចុកជាការបន្ទាប់បន្សំ ។

ចំណែកឯស្ត្រីជាតិពីហេដែលយកប្តីច្រើនវិញ ជនបរទេសខ្លះយល់ថា គ្មានតែកុំឲ្យបែកខ្វែកមតិកប៉ុណ្ណោះ ព្រោះគេច្រើនតែយកប្តីក្នុងវង្សត្រកូលមួយៗ របស់គេ គឺថា បើស្ត្រីម្នាក់ការជាមួយទំនងប្រុសច្បង ក្នុងត្រកូលណាមួយ ស្ត្រីនោះត្រូវចុកខ្លួនជាប្រពន្ធរបស់ប្អូនថ្លៃប្រុសទាំងអស់ ហើយនៅពេលរៀបមង្គលការ គេចុះឈ្មោះប្តី ទឹងប្អូនប្រុសក្នុងបញ្ជីទាំងអស់ប្លែគ្នាតែយកឈ្មោះអ្នកទាំងអស់នោះមកពាប់ប្រាប់ ។ ក្នុងវិធីនេះសាម៉ីខ្លួនខាងស្រី ត្រូវកែងសេចក្តីរកយទំនងសេចក្តីស្មោះចំពោះឥតុកម្លាយក្មេកទឹងញាតិសន្តានដែលជាសាច់ថ្លៃទាំងប៉ុន្មាន ហើយទឹងពាប់រកដោយស្មើគ្នាចំពោះបុរសដែលត្រូវជាប្តីខ្លួនទាំងអស់ មិនត្រូវបង្ហាញឲ្យឃើញថាស្រឡាញ់ណាជាងណាទេ ។ តាមទម្លាប់ស្ត្រីនេះ ត្រូវមើលការខុសត្រូវលើទ្រព្យសម្បត្តិ របស់ប្តីទាំងពីរបីនាក់នោះ ហើយប្តីទាំងអស់ត្រូវប្រគល់ប្រាក់កាសដែលរកបានឲ្យប្រពន្ធតែមួយនេះដែរ ប្រពន្ធនេះត្រូវមើលការខុសត្រូវឲ្យប្តីទាំងអស់ ថែទាំកូនចៅ ហើយទឹងចាត់ប្រាក់កាសត្រូវចាយវាយព្រមទាំងត្រូវចុកជាក់ ។ ឯទំនៀមគឺត្រូវធ្វើដូច្នេះពិត, តែគេមិនសូវធ្វើតាមទេ ដូនកាលគេថាតែមាត់ស្រីក៏មាន ។ ប្អូនប្រុសខាងប្តីដែលត្រូវជាប្តីរបស់ប្រពន្ធបងប្រុសខ្លួននោះ ពុំសូវនៅជាមួយ

ទេ ។ មានតែបងប្រុសបង្អស់ទេ ដែលត្រូវនៅផ្ទះជាមួយប្រពន្ធ ។ ចំណែកប្អូនប្រុសពាក់កណ្តាលប៉ុន្មាន មួយទៅជួញដូរស្រែកធ្វើយ មួយទៀតទៅរកស៊ីនៅស្រុកចិន មួយទៀតទៅស្រុកភូមិន្ទ ហើយនៅ។ ទីនោះ សឹងតែជាទិច្ចកាលផង ។ ខ្លះទៀតនៅថែរក្សាក្តីអាណាព្យាបាលរបស់គ្នាសារ ដែលនៅឆ្ងាយពីផ្ទះឥតកម្លាយខ្លួន ។ បើសិនជាអ្នកអស់នោះរកស៊ីបានច្រើនត្រកំអំពីច្រើនជាងចំណាយរបស់គ្នាសារ អាចការប្រពន្ធត្រកំទៀតបាន ។

បើប្អូនប្រុសរបស់ប្តីមិនចង់យកប្រពន្ធរបស់បងទេ អាចនៅការប្រពន្ធត្រកំពីត្រកូលរបស់ខ្លួនបាន ប៉ុន្តែអ្នកនោះនឹងត្រូវបាត់អំណាចតាមតាមតិកាដ៏ឥតក ។

លើកតែអាពាហ៍ពិពាហ៍តាមធម្មតាចេញ ជនជាតិខ្មែរតែងប្រព្រឹត្តរួមសង្វាសនឹងគ្នាដោយសេរី តែគេមិនយល់ថាជាការអាក្រក់ទេ ។ ការរួមសង្វាសដោយសេរី មានច្រើនណាស់ទៅទីបេ ប៉ុន្តែចំពោះតែអ្នកជំនួញទេ ព្រោះជនពួកនេះ ច្រើនមានស្រីជាសមាជិកាមាំមួនណាស់ ។ ត្រកំអំពីជំនួយជាប្រយោជន៍នៃជំនួញរបស់ប្តី ស្ត្រីតាំងនេះចេះកាន់របរដំ។ ហើយរកទ្រាក់ទុកដោយខ្លួនឯងជាច្រើនរបស់ខ្លួនទៀត ។

ទោះជាគេដឹងថា ស្ត្រីចេះតែមានការត្រួតត្រាលនឹងបុរសឯទៀតត្រកំតីប្តីរបស់ខ្លួនយ៉ាងនេះក៏ដោយ ប្តីក៏មិនដែលបង្ខាំងប្រពន្ធទុកក្នុងផ្ទះទេ; ស្ត្រីស្រុកនោះដើរលេងខ្លួនឯង ទៅពុណ្យ ទៅខ្លួនគោជនាហារដោយសេរី ហើយនិយាយជាមួយនឹងបុរសដោយគ្មានញញើតអៀន

ខ្ញុំសង្ឃ ។ ក៏ប៉ុន្តែ ដល់មកសម័យឥឡូវនេះ ទោះស្រីមានសេរីភាពយ៉ាងនេះក៏ដោយ គង់នៅមានទំនៀមមួយទៀត ដែលស្រីស្រុកខ្មែរមិនដែលមានសេរីភាពសោះ គឺការរើសប្តីខ្លួនឯង ។

ទំនៀមផ្សំផ្គុំកូនចៅតាំងតែពីតូចៗ នៅស្រុកឥណ្ឌានឹងនៅស្រុកចិន ទំនៀមនេះមិនដែលមាននៅស្រុកខ្មែរទេ ។ ប៉ុន្តែឪពុកម្តាយខ្លះក៏ដាក់កូនចៅតែតាមចិត្តខ្លួន មិនសួរចិត្តកូនស្រីឡើយ ហើយកម្រនឹងមានកូនស្រីណាហ៊ានបង្ហើរចិត្តឪពុកម្តាយបានផង ។

ទំនៀមចាស់នេះ គេលែងគាន់ជាង ១០ ឆ្នាំមកហើយ ឥឡូវនេះគេមានតាំងហាមប្រាមទៀតផង ។

ទំនៀមនៅខ្មែរ មិនដូចទំនៀមនៅស្រុកឥណ្ឌាទេ នៅឥណ្ឌាយកគ្នាជាប្តីប្រពន្ធតែមួយ ។ រហូតអស់ជីវិត ឯនៅខ្មែរប្តីប្រពន្ធចង់លែងលះគ្នាក៏បាន ឲ្យតែនៅថ្ងៃដែលទោសនឹងការមិនសុខចិត្តមែបណាមួយ ប្រាប់មន្ត្រីណាដែលចាស់ជាងគេនៅក្នុងភូមិ ឬមន្ត្រីណាដែលបានមកជាសាក្សីក្នុងពេលរៀបមង្គលការ ។ អ្នកខ្លះតាក្យបណ្តឹងនេះ អាចកាត់សេចក្តីឲ្យបាន ហើយនឹងដំរះអំពីទ្រព្យសម្បត្តិថា ត្រូវបានទៅអ្នកណាឬអ្នកណាផង ។ អ្នកស្រុកខ្មែរមិនដែលឈ្លោះគ្នា ព្រោះរឿងប្រែប្រួលប្តីប្រពន្ធទេ ។ បើគេលះចង់ត្រពន្ធបាត់ទៅ ប្តីគ្រាន់តែទៅគាវឲ្យសងឪពុកម្តាយមកខ្លួនវិញ អំពីអ្នកសហាយប្រពន្ធខ្លួននោះ, ចំណែកខាងស្រីវិញ ក៏ទៅគាវប្រាប់ពីស្រីណាដែលលួចយកប្តីរបស់ខ្លួនខោះដែរ ។

សុភាសិតភាគ៨ដំណិត

ភាសាភាគ្យ

អ្នកឧកញ៉ាមហាវិនិច្ឆ័យ នៅ

រៀបរៀង

អារម្ភកថា

សុភាសិតនាមហៅភាគដំណិត

ជាកូនសំខួនចាស់បុកណាគិត　　ប្រៃពៃពិតសម្រាប់ថ្វាយកូនគ្រា ។
ដ៏ជាឥស្សរកេតម្ពុជ　　រំសុខថ្លៃរំសេរសុសម្ភ
ជាពំនឹងពឹងពាក់សរណា　　ពស្ត្រវង្ខជាបានសុខនិរុទ្ធភ័យ ។
តែច្បាប់កូនបុពណាជាពាក្យពាយ　　និយាយសារសំពួកច្បាប់តែទំយ
ដំណើរច្បាប់ក្រឹត្យក្រមដ៏ប្រៃពៃ　　ឥតមោះមៃមែនមានជាកូនមក ។
ទើបខ្ញុំរិះត្រែតត្រិះជាពាក្យជូន　　សំខួនកាត្យកិច្ចគិតលៃលក
ខុកតំណាតទៅជនរិះរក　　គ្រាន់នឹងយកមកមើលគិតរិះផ្សាន ។
រឿងនេះសម្តេចព្រះសុគន្ធា　　ព្រះឧបជ្ឈាយ៍ទន់ច្រៀងសព្រះពជគាន
ឲ្យដល់ខ្ញុំយកខុកជាប្រៃជាន　　គ្រាន់ខួនបានប្រៃជៅទូវអាត្មា ។
ដែលនឹងចូលធ្វើជាខ្ញុំព្រះបាទ　　សម្តេចកវីនាថឧត្តមឥស្សរ
គួរឲ្យចេះចំណេះសេរីគា　　សុសម្ភាសុចរិតដោយក្រឹត្យមើយ ។

អ្នកឧកញ៉ាមហាវិនិច្ឆ័យ នៅ
បានរៀបរៀង រឿងនេះ កាលនៅជាសុគន្ធរាជា ។

ភាគដ៏តំណាស្តីសុភាសិត

រាជនីតិ សត្តំ រញ្ជោ　　ទិដ្ឋធម្មត្ថសាធនំ
រុប្បតេ ពុទ្ធុរុត្តត្តំ　　បរំរដ្ឋរិមទ្ទនេ ។
ឧត្តារិ រតនគ្គយំ　　សុភាសិតំ បវក្ខាមិ
សុខាវហំបរមាទិ　　បញ្ញារុត្តិ រាជានំ ។

ខ្ញុំសូមបង្គំបីព្រះគុណ　　រតនត្រ័យជាមុនដោយសិរសំ
នឹងពោលភាសិតគិតលំអំ　　តតាំងលេខាវៀហារគាថ្យ ។
តម្រិះត្រិះខុកតាមតម្រា　　ភាជនីតិក្នុងភាជជាបថ
ដើម្បីក្តីសុខមិនដូនជាប　　កាត់ជាបជ្រាបបង់ពាជសត្រូវ ។
គ្រានេះនឹងចែងចាត់តាមក្បួន　　សំខួនសួនរបៀបតម្រូវ
តម្រាយអ្នកប្រាជ្ញពីមុនកូវ　　ឥឡូវក្លាយស័ព្ទចាប់ដួងថា ។
គម្ពីរភាជនីតិសាស្ត្រនេះ　　ខ្ញុំចែងតម្រិះពាជខ្ពស់ក្តីយោ
ដើម្បីចំរើនព្រះប្រាជ្ញា　　ចេះស្គាំណាចកង់វៃត្រដែន ។
កិរិយាញ៉ីញ៉ក់ពាជបរម៉ក្ស　　ចំជាក់ខ្ចប់ខ្ចាចាប់រយសែន
ដោយព្រះប្រាជ្ញាក្លាវៃខ្លួន　　ណាស់ណែនក្នុងដួងព្រះហ្ឫទ័យ ។
មួយបើចង់ជ្រាបខ្ញុំពាជការ　　ឯណាវៀហារប្រាជ្ញាវៃ
ឬជាអន់អាប់ពុំប្រៃ　　កុងន័យឲ្យស្តាប់ការចរចា ។
ចង់ដឹងអ្នកមានសីលវត្ត　　ប្រាកដប្រកបក្រិត្យកិរិយា
ឬជាខ្វះស្តីសីលសូន្យអសារ　　លោកថាមើលនាគាលនៅផង ។

ចង់ដឹងអ្នកស្អាតឬមិនស្អាត ប្រមាទខ្លួនធ្វេសធ្វើឲ្យហ្មង
មិនល្អិតគិតល្អដោយបំណង មើលនាំទុនធ្វើការងារ ។
ចង់ដឹងចរិតចិត្តសុភាព រឿងកបខាបខន់ធន់គាជារ
កតញ្ញូស្លាប់ដន្ទុមរណា មើលគ្រាគាលមានភ័យមកដល់ ។

ក្សត្រិយវង្សខ្ចីគួរលះ ស្រឡះចាកមនុស្សគ្មានយោបល់
ប្រកបគោសហេតុមិនមានផល មិនគួរដាក់ជាមាត្យា ។
បុរសប្រកបគោសជាំបី មានន័យសំដែងថ្លែងទុកថា
មួយមនុស្សច្រអូសមិនឧស្សាហ៍ មួយមានកិរិយាចិត្តអាក្រក់ ។
មួយមានគំនិតចិត្តខោតខ្វៃ មួយហៅមារយោងជាតិលាមក
មួយតែងធ្វើការឲ្យខូចធុក មួយជាំងំទុកគោសខ្លួនឯង ។

មួយមិនមានចិត្តគិតសន្ដោស ប្រសប់ជ្រាសសប្បុរសត្រប់តំណែង
មួយមិនក្លៀវក្លាអាចរវែង តាំងតែងតតបបញ្ចាមិត្ត ។
មហាក្សត្រិគួរគាត់លះបុរស ប្រកបគោសអស់ជាំបីពិត
មិនគួរចិញ្ចឹមខ្មៅជាប់ដិត គួរតែតកុំយកមកប្រើការ ។

មួយទៀតក្សត្រិយវង្ស បំរុងប្រជាកស្ដារដ្ឋា
គួរកុំតាំងមនុស្សខោសមុខ ជ្រាបពីប្រការទៀតនៅ ។
មួយមនុស្សវៃច័ណ្ឌចិត្ត ក៏ចាមិនល្អិតចិត្តរយោរយៅ
សំដីអាក្រក់តក់ម៉ក់នៅ មិនស្គាល់ពាក់ផ្លែនៅក្នុងខ្លួន ។
មួយមនុស្សរមែងកាច់កំនេត រះរេកហេតុគេទុកផ្លូវដួន

ទូលពិតញុះញង់ឲ្យខ្វែងគ្នួន
គំនុំគំនួនគ្នួនគោសា ។
មួយមនុស្សប្រកបដោយក្តីលោភ
ចិត្តល្មោភមិនល្មមងុតជ្រាបថ្នា
ខ្នះខ្នែងខ្វែងខំតាមចិត្តា
ហៅមហាលោភោគៀងគន្ធង ។
មួយមនុស្សមិនស្ងាត់កងធម្មសាត្រ
ប្រមាថមិនរៀនប្បាប់ខំនង
គោះទាំងពាងទឹកគ្នាំគ្នង
មិនអាចពាប់រង់រៀនឲ្យប្បាស់ ។
មួយមនុស្សអកតញ្ញូតា
រមិលគុណមហាកូនតាម្ចាស់
ដំណែងព្រះគុណគម្ចីគ្រាស់
ក្រឡាស់បំភ្លេចគេជាមិនគ្នាវ ។
មួយមនុស្សឃើញតែប្រយោជន៍ខ្លួន
មែនមួយចិនឃើញប្រយោជន៍គេ
មានម្ចាស់ជាដើមកំរេងសេ្ងួ
ពុំវេគ្នាខឹកវាតុដល់ ។
មួយមនុស្សក្រចាមុសាវ់ខ
កុហកបង់សៀតពាក្យឥតផល
ភូតព្រាងបញ្ឆៀងតាមយោបល់
មិនមានដំណល់ពាក្យសត្យា ។
ប្រាំពីរបទនេះជាគោសត្តិ
ពុទ្ធវិតប្រាកដកុំកង្វា
មិនគួរខ្ពើមតាំងជាឥស្សរ
សម្រេចកដការក្នុងផែនដី ។

ម្ភុទ្ទ្រមប្ញេសេរីកាមាត្យ

បើមិនទ្រឹះវត្តណាសសេចក្តី
វង្វេងវិលវល់ខ្វល់អប្រិយ
ហើយព្រះពក្តីខ្វែងមេត្តា ។
ប្រែប្រួលប្រាណាពាប់អានពុតព្រះទ័យ
រាំពាំតឹងដួយកដការ
តាំងពុតជាធំទីប្រឹក្សា
គោសរើប្រការប្រាកដមាន ។
មួយតឹអាត់តឥស្សរិយយស
ខ្ពង់ខ្ពស់ខឹងខាបខៅជាគ្នាន
គោះទាំងបរិវារពាប់រយលាន
ឱដ្ឋអន្តរធានបាត់បោះបង់ ។
មួយតឹវិនាសប្រយោជន៍ផល
វិលដល់មកដួចតាមចំណង់

ទីឆ៏ភ្លាត់ខ្លាត់បេញ្ចាចាកព្រះអង្គ
តរមែកត្រែកត្រឆ៏ក្រែវខាន ។
មួយទិវង្គតរលត់ខន្ធ
ទៅកាន់តើតទានរកឋាន
ប្រកបក្តីទុក្ខមិនសុខសាន្ត
ប្រមាណគាល់ផុតយថាកម្ម ។
ព្រោះហេតុជ្ឈឹតខោសតាំងបុរស
អាប់យសមិនយល់ក្តីសាំញ៉ាំ
មិនមានប្រាថ្នាការទុត្តម
ខើបនាំដូចន័យតាំងបីពិត ។
បញ្ចោមប្លោងជីមាត្យា
សេរីគាណាមួយធ្វើវិធ្វោតគិត
ច្បាជ្ញាវៃពងយោងតំនិត
ព្រះត្រីត្តសុចរិតប្រកបល្អ ។
ហើយស្តេចសម្រេចធ្វើជាធំ
ឧិយមកំណត់សមោសរ
ជាទីប្រឹក្សាការគ្រឹក្ត
ទីឆ៏កកើតគុណប៉ប្រការ ។
មួយតីទីឆ៏មានឥស្សរិយយស
ប្រសើរខ្ពង់ខ្ពស់យសស្តា
ចរិបូណ៌ត្រមត្រែងតាំងបរិវារ
ទទួលអនេកអនន្តវិស្រុត ។
មួយមានសម្បត្តិសម្បូរបុណ្យ
ទ្រព្យធនគោគតស្តុជាមហៃ
ប្រកបបុញ្ញវ័ទ្ធអតិវិឡ៏យ
អាស្រ័យយុត្តិបញ្ញាញាណ ។
មួយកាលសុរិណ្ណគតផុតជន្ម
ជាន់ទៅកើតទាសូគតិពីមាន
ស្វាយសុខនិរទុក្ខជាប្រធាន
ដោយទ្រង់មានញាណខ្ពង់ខ្ពស់រៃ ។
យំកិញ្ចោករតេភវោ
អមត្យោ អមាត្យណាមួយនៃ
ប្រព្រឹត្តសុចរិតឥតរមែរមៃ
ប្តុំប្រពៃពុទ្ធិតស្មោះ ។
សេចក្តីទាំងពីរនេះប្រាកដ
កំណាត់និយមមិនសូន្យស្មោះ
ទីឆ៏ជាប់ជិតដល់ម្ចាស់តាំងអស់
ព្រោះបរិសុទ្ធសមាគម ។
ហេតុនោះព្រះបេថមពិភព
តុគម្មទុស្សវេទ្យវិធ្វើធំ

ខឹងចាត់ប្រយោជន៍កងភាវម្យ គួរតែរសពសមអ្នកជ្រាជ្រុយ ។
ដែលមានបញ្ញាគ្រាយោបល់ ដឹងតស់បញ្ហាអត្ថតំនឹងឱ្យ
ខឹងមានប្រយោជន៍ផងវែងឆ្ងាយ សប្បាយសមបុណ្យសុវត្ថិ ។

កុលសីលោគុណោបេតំ អ្នកពុំធប្បាយស្រាយសេចក្តី
ឋានខ្ទែកេចញ្ចាំពីចាស៎ តាមខ័ឃលោកចែងសម្តែងថា ។
មហាក្សត្រដ៏ខ្ពង់ឥស្សរេត ម្ចុះកេតចមតិនពាជសីមា
ខឹងរើសរកជាគុណាការ កងខ័ពិភាក្សាក្តីកស្តែងផង ។
ទោះគួរតែឯតាំងកជបុរស ប្រកបគុណស្មោះមិនមានហ្មង
ជ្រាំពីរប្រការដោយខំនង មុពណាលោកចងជាក្បួនថា ។
ប្រការមួយប្រកបត្រកូលវង្ស ប្រការមួយបិតកងសីលាចារ
ប្រការមួយឱ្យមានពាក្យសត្យា មួយមានជ្រាជ្រៀវធ្វាសធ្ងុះ ។
ប្រការមួយទៀតឱ្យជ្រុកជ សូញ្ញាស្ងាត់ធម្មាតប្បាប់សព្វសុះ
មួយឱ្យពោលពាក្យមធុរស មួយទៀតមិនលុះអគតិបួន ។
ជ្រាំពីរបទនេះបើបុរស មានស្មោះរាបស៊ើខ្មោកកងខ្លួន
គួរខ្ពង់តាំងខ្ពុកឱ្យសមសួន មាំមួនកងខ័ពិភាក្សា ។
ន័យមួយគួរគាំងកជបុរស ប្រកបគុណស្មោះជ្រាំប្រការ
ឱ្យជាទាយឃ្មាំងចាំរក្សា កស្តែរកែវកងពិចិត្ររតន៍ ។
មួយតីប្រកបត្រកូលជាតិ មារយាទជាមនុស្សត្រង់ជ្រុកជ
ប្រការមួយជាន់ហាត់ព្យាមស្ងាត់ មិតចត់រក្សាទុកឱ្យល្អ ។

(មានត)

តេជ្ញាព្រះភជា

លោក ស៊ីង-ប៉ាង ប្រែរៀបរៀង

លោក ឃ្លូរ-អ៊ីង ពិនិត្យកែសម្រួល

(ត្រឡក)

អមាត្យបានឮមាណពអង្វរកវ កំត្រមទទួលពាក្យថានឹងទៅទៅ
ស្នាក់ផង, មាណពសំដែងសេចក្តីត្រេកអរហើយឡើងជិះសេះនាំមុខ,
អមាត្យបរសេះតាមក្រោយទៅ ។

កន្លងវេលាត្រឹមប៉ែនថ្ងៃនោះ មាណពអញ្ជើញអមាត្យរួមតុអាហារជា
មួយគ្នា កន្លងទីក្បែរមោត៌ឹកខាងក្រោយផ្ទះដែលមាណពជួលទៅ ។
អមាត្យបានស្តាំខ្មោលនឹងមាណពអស់រៀលជាយូរ កន្លងណៈនោះគាត់
ឮកថាគេជាបុរស ១ រូបមានចិត្តណះចេះចាំនឹងមានវិជ្ជាផ្សេង។ ត្រមាំង
ស្គាល់ទីកន្លែងស្រុកទេសជាដៃ។ ទៀត ដូច្នេះគួរសេនូនាថាណ្តើរ ទទួល
ទានអាហារបណ្តើរ; កន្លងកាលនោះអមាត្យចាប់ក្តីកនឹកយើញនូវពាក្យ
របស់មាណពដែលនិយាយអំពីវេលាថ្ងៃនៅកន្លងកេងពីធី ទើបសួរថា ៖

"មាណពសំឡាញ់ ! ខ្ញុំមិនគាន់អស់សង្ស័យទេវឡើយ ចំពោះ
ពាក្យរបស់លោកដែលនិយាយអំពីថ្ងៃមិញ បើលោកមិនចង្អៀតចង្អល់ចិត្ត
ទេ សូមលោកនិយាយប្រាប់ឲ្យខ្ញុំបានដឹងរឿងនោះខ្លះផង, ការដែលខ្ញុំ
ចង់ដឹងរឿងនេះ ដើម្បីជាគ្រឿងប្រដាប់ដល់សតិបញ្ញាខ្ញុំប៉ុណ្ណោះ" ។

"មិនអីទេ ! ខ្ញុំមិនទើសទាល់ចិត្តទេ កាលបើលោកចង់សួរអ្វីក៏សួរ
មកចុះ តែកុំសួរឲ្យដល់ភ្នាក់ប្រដាប់សតិបញ្ញារបស់លោកឡើយ ព្រោះ

ខ្ញុំនៅវ័យក្មេង ឋញ្ញាកំនុនថយ ម្តេចឡើយនឹងដឹងក្តី ។ ឲ្យល្អជាងលោក ដែលមានវ័យចាស់ជាងខ្ញុំ" មាណពនិយាយដំកបដោយអាការញញឹម ញញែមបង្ហាញឲ្យឃើញថាមិនមានសេចក្តីរង្កៀសក្នុងការសោកសួរបស់ អមាត្យឡើយ ។

អមាត្យថ្លាស់តបសេចក្តីអរគុណមាណពហើយ ទើបសួរ : "មាណពសំឡាញ់ ! លោកគំនាបជ្រាបហើយថាការបូជាយ័ញ្ញរបស់ ព្រះពាក្កនឹងគឺនេះត្រូវមានសំណែនដោយសត្វរស់ ។ ជាចំនួនច្រើន រាប់ថាជាពិធីចំបាច់មួយដែលត្រូវធ្វើជាប់ត ។ គ្នាមក ដកបដល់សព្វថ្ងៃ នេះ ដើម្បីវត្តបំណងមួយ គឺថ្លាថ្នាំនឹងកំចាត់បង្អាសសំអាតកេទភ័យ ដែលកើតឡើង ហើយកេទភ័យដែលកើតនោះ ទ្រង់វិនាសទៅដោយសារ ពិធីនេះ ចំណែកលោកត្រឡប់ជាយល់ឃើញថា ពិធីនេះឥតប្រយោជន៍ វិញ ទើបខ្ញុំចង់ដឹងចំពោះការយល់ឃើញរបស់លោកជាទីបំផុត" ។

មាណពអង្គុយស្តាប់អមាត្យសួរចាលតែចប់ ទើបថានគ្រាកឡើង ហើយដើរចេញទៅកាន់ទីមាត់ទឹកដោយអាការស្ងួតស្ងប់ ដកដង្ហើមធំ ងើយមុខឡើងសម្លឹងមើលវង់ព្រះចន្ទដែលមានរស្មីដ៏ស្រស់ខ្ចុម កណ្តាល អាកាស :ហើយទើបបែរមុខមកនិយាយនឹងអមាត្យ :

"សំឡាញ់ចាស់ ! មុនខ្ញុំនឹងថ្លាប់ខ្លួនវិការដ៏ធំរបស់ខ្ញុំ, ខ្ញុំត្រូវតែ ដំកបលោកថា ការចេះដឹងគឺនេះដែលកើតមានឡើងដល់ខ្ញុំ ដោយ ខ្ញុំបានទទួលសិទ្ធដល់ដួរមកកំពុងព្រះធម៌ដែលជាភាសាប្រៀនប្រែដោ

សាសនារបស់ព្រះសម្មាសម្ពុទ្ធម្ចាស់ ..." រួចមាណពសម្លឹងមើលមុខអមាត្យជាលិត ។

"ដូចម្តេច សាសនារបស់ព្រះសម្មាសម្ពុទ្ធម្ចាស់?" អមាត្យជាលិតសួរហើយសម្លឹងមើលមុខមាណព ដោយខ្លាចក្រែងមិនពេញចិត្ត ព្រោះពាក្យនេះគាត់មិនធ្លាប់ធ្លាប់បានដឹងបានឮវោហារិយាយដល់ឡើយ ។

"សំឡាញ់ចាស់! សាសនាឬពាក្យប្រៀនប្រដៅតាំងពីយ៉ាយតែងមានអ្នកគិតគាន់គ្នេរបានហើយនាំមកប្រៀនប្រដៅ ដែលយើងនិយមហៅថាសាស្តា ហើយពាក្យប្រដៅរបស់សាស្តានោះហៅថាសាសនា តែសាសនាដែលខ្ញុំកំពុងនិយាយដល់នេះជាសាសនារបស់ព្រះសម្មាសម្ពុទ្ធម្ចាស់, ព្រះអង្គបានត្រាស់ដឹងដោយអំណាចនៃការសូន្យចិត្តវៀរចាកកិលេសតាំងពីយ៉ាយ ដែលគ្មានអ្នកណាលះបាន, ហេតុនេះឯង ពាក្យប្រដៅរបស់ព្រះអង្គ ទើបជាធម្មិខ្ពស់ជាងពាក្យប្រដៅរបស់សាស្តាដទៃ ព្រោះព្រះអង្គបានត្រាស់ដឹងដោយប្រពៃ ទើបទទួលព្រះនាមថាព្រះសម្មាសម្ពុទ្ធម្ចាស់" ។

អមាត្យជាលិតមិនទាន់ចូលចិត្តច្បាស់នៅឡើយ គឺមិនដឹងថាព្រះសម្មាសម្ពុទ្ធម្ចាស់ មានគុណវិសេសដូចម្តេច, ពាក្យប្រដៅរបស់ព្រះអង្គដែលហៅថា ព្រះធម៌ដូចម្តេច, តាំងមិនបានដឹងថាព្រះសង្ឃសាវ័ករបស់ព្រះពុទ្ធម្ចាស់ មានទៅកន្លងនូវពាលសិក្ខាតែម្តង គាន់តែដឹងថាព្រះពាជាទ្រង់កាន់សាសនាព្រាហ្មណ៍ ទើបមិនបានទ្រង់លើកតំកើងពុទ្ធសាសនាឡើយ, ដូច្នោះការធ្វើពិធីផ្សេង ។ ក្នុងព្រះពាដំណាក់ ក៏ធ្វើ

ទៅតាមពិធីព្រាហ្មណ៍ទាំងអស់, អមាត្យជាលិតក៏ដូចគ្នា ជាន់ជាប់ហ្វឹកហាត់អប់រំផ្លូវផ្សេងៗមកតែក្នុងសាសនាព្រាហ្មណ៍ ទើបដឿក្នុងពាក្យប្រដៅរបស់ព្រាហ្មណ៍តែម្យ៉ាង, ព្រោះហេតុនោះទើបជាលិតអមាត្យសួរ:

"សូមលោកមេត្តាជ្រាបខ្ញុំឲ្យបានដឹងនូវពិធីយ័ញ្ញ ក្រៅអំពីពាក្យប្រដៅសិនចុះ, តើយ័ញ្ញឯណាដែលព្រះសម្មាសម្ពុទ្ធម្ចាស់ទ្រង់ឲ្យធ្វើ? យ័ញ្ញឯណាដែលគួរក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ?" ។

មាណពជាន់ស្តាប់ពាក្យសួរបស់អមាត្យជាលិតហើយ ក៏ដឹងភ្លាមថាបុរសជាអនេះមានការចេះដឹងដោយជាន់អប់រំអតែក្នុងសាសនាព្រាហ្មណ៍ប៉ុណ្ណោះ ចំណែកព្រះធម៌ដែលជ្រៅវិញ គាត់មិនមានការចេះដឹងឡើយ ទើបតបថា:

"លោកឲ្យខ្ញុំជ្រាបអំពីយ័ញ្ញរបស់ព្រះសម្មាសម្ពុទ្ធម្ចាស់នេះជាការល្អហើយ . . . សូមលោកតិះរិះមើលចុះ" មាណពនិយាយហើយងើយមើលមុខអមាត្យរួចសម្លឹងទៅឯអាកាស, ខណៈពេលនោះវេនព្រះចន្ទមានលក្ខណៈជិតពេញវង់ហើយ ទើបមាណពចង្អុលជ្រាប់ឲ្យសំឡាញ់ជាជាតូសខ្លួនាមើល:

"វេនព្រះចន្ទថ្ងៃនេះ ក៏ជិតពេញវង់ហើយ, ការត្រេកត្រអាយចិត្តរបស់ខ្ញុំក៏តែតាំងឡើង មិនយូរប៉ុន្មានព្រះពុទ្ធានៃនគរវេសាលីនេះក៏រៀបចំធ្វើពិធីយ័ញ្ញ, យ័ញ្ញរបស់ព្រះពុទ្ធានោះចាត់ថាលាមកអាក្រក់ជាការធ្វើដោយឥតដឹងសល់ . . . ខ្ញុំសូមអំពីយ័ញ្ញរបស់ព្រះសម្មាសម្ពុទ្ធម្ចាស់, ឯយ័ញ្ញរបស់ព្រះសម្មាសម្ពុទ្ធម្ចាស់ជាពិធីដ៏បរិសុទ្ធ ប្រសើរក្រៃអ្វី

ប្រៀបផ្ទឹមតុំបានឡើយ ព្រោះព្រះអង្គទ្រង់ឲ្យធ្វើយ័ញ្ញតែការសម្លាប់ដូចគ្នា តែការសម្លាប់នោះ គឺសម្លាប់របស់ដែលមាននៅកន្លែងខ្លួន ដែលចាត់ជាកិលេសដ៏លាមកអាក្រក់, សំឡាញ់ជក! សូមលោកមេត្តាឲ្យអភ័យទោសដល់ខ្ញុំៗ សូមតុកាសសួរលោកវិញ សូមលោកតបឲ្យខ្ញុំបានដឹងផង ដើម្បីជាផ្លូវដល់ការចម្អែលតឲ្យបេះខ្ញុំវិញបន្តិចចុះ" ។

អមាត្យថ្លាលិតរង៉ស្ងាប់ ដោយសេចក្តីពេញចិត្ត យូរៗញាក់មុខទួលម្តងៗ; មាណពទើបពោលតទៅ:

"រូបកាយរបស់លោកគឺរបស់ខ្ញុំគឺ រមែងជាទីស្រឡាញ់នៃយើងមិនមែនឬ?" ។

"មែន" អមាត្យថ្លាលិតទទួលពាក្យ ។

"អើ . . . :នែឯង សំឡាញ់ចាស់! សាសនារបស់ព្រះគោតមប្រៀដៅទុកយ៉ាងនេះ ព្រោះការដែលមានជីវិតរស់នៅជារបស់រកបានដោយកម្រ, ការសម្លាប់ជីវិតរបស់ខ្លួនឯង អ្នកមានប្រាជ្ញាតែងមិនប្រាថ្នា, ការសម្លាប់ជីវិតអ្នកដទៃ តែងកឲ្យកើតពៀរ, ឯពៀរនោះមានសេចក្តីសំគាល់ច្រើនយ៉ាង, ពៀរបានដល់ការអាឃាដរបស់អ្នកដែលត្រូវសម្លាប់ដូចការអាឃាដរបស់ញាតិមិត្រមានបងធំមិនប្អូនរបស់អ្នកដែលត្រូវសម្លាប់ជាដើម, ព្រោះអាស្រ័យពៀរទើបការសម្លាប់គ្នាមានឡើងរឿយៗ ដែលជាហេតុកឲ្យកើតបាប, ចុះលោកបូលចិត្តប្តេជ្ញាទទួលតាមពាក្យថាបាបនេះ?" ។

"ជូលចិត្តហើយសំឡាញ់! ចាបគឺដូលនៃអំពើអាក្រក់ដែលផ្តួយទឹងពាក្យថាបុណ្យ" អមាត្យចាលិតតបយ៉ាងជាក់លាក់ហើយត្រូវផង ដែលជាទីពេញចិត្តរបស់មាណពពន់ពេក, ទើបមាណពតបវិញ:

"ត្រូវហើយ សំឡាញ់ដ៏មានអាយុ! សេចក្តីវិភាយ ដែលកើតអំពីផលនៃបុណ្យ គឺជាផលដ៏បរិសុទ្ធនាំសេចក្តីសុខសប្បាយគាំងពួងមកឲ្យដល់ចិត្ត, ចំណែកចាបមានផលដ៏ក្តៅក្រហាយ, ព្រះសម្មាសម្ពុទ្ធមិនទ្រង់លើកតំកើងនូវការផ្តាច់ជីវិតទេ! គោរដាជីវិតរបស់សត្វតូចល្អិតក៏ដោយ ក៏ព្រះអង្គទ្រង់ហាមដាច់ខាត, លោកដ៏មានអាយុ! ការមិនសម្លាប់សត្វដែលមានជីវិត គឺជីវិតខ្លួនឯងនឹងទឹងជីវិតរបស់អ្នកដទៃ ហៅថាការគាន់សីល, ការគាន់មិនសម្លាប់ជីវិតនេះឯង ចាត់ថាសីល ក្នុងពួកសីល ៥ នៃពាក្យប្រដៅរបស់ព្រះគោតម ហើយជាសីលខ ដំបូង" ។

អមាត្យចាលិតមិនឆ្លាប់ស្តាប់ពាក្យបែបនេះ អំពីនរណា ។ ដល់ម្តងសោះ, ការដឹងខ្លួនក៏ផ្តើមមានឡើង ព្រោះចាងឮថាបុណ្យនាំសេចក្តីសុខមកឲ្យ ហើយចាបជារបស់មានផលដ៏ក្តៅក្រហាយ ទើបសួរតទៅ:

"សំឡាញ់! សូមលោកមេត្តាប្រាប់ខ្ញុំបន្ថែមតទៅទៀត, ធ្វើដូចម្តេចទើបចាត់ថាជាបុណ្យ ព្រោះខ្ញុំប្រាថ្នាចំពោះសេចក្តីសុខ ដែលកើតអំពីផលនៃបុណ្យ..." ។

(មានត)

កណ្ដាំ ២៣

ឧកញ៉ាវិបុលរាជសេនា ន្ធូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមក្កុកទុកជាបុរាណសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធំងបេះឧប៉ាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ចូឆូបានស្តាប់ដូច្នោះ កំពាត់ចែងយកគាហានកងគ្រែយលើតមកជាកងមុខ យកគាហានកងខាងមុខឲ្យត្រឡប់ទៅទៀតីគ្រែយ ហើយឲ្យនាំរនេះដែលធ្លុកស្បៀងអាហារបរទៅតីមុខកងខ្លាំង ។ លីយ៉ាយដំរាបសួរចូឆូថា ហេតុម្តេចបានជាមហាឧបាជឲ្យនាំយករនេះស្បៀងទៅជាក់តីមុខកងខ្លាំងវិញ ? ។ ចូឆូតបថា យើងលើកខ្លាំងទៅធ្វើសង្គ្រាមកាល់ដងយកស្បៀងអាហារទៅជាក់តីគ្រែយចេះតែបរាជ័យ, ម្តងណេះយើងឲ្យនាំខ្លាំងស្បៀងទៅជាក់តីមុខវិញ ។ លីយ៉ាយដំរាបសួរថា បើជាប្រទេះនឹងកងខ្លាំងអ្នួនសៀវគណ្ណាលផ្លូវ គាហានាំស្បៀងទាំងឡាយសុទ្ធតែមិនចំណានក្នុងការសង្គ្រាម នឹងមិនខ្លួចស្បៀងអាហារឬ ? ។ ចូឆូតបថា

"អ្នកកុំព្រួយចិត្តគិតអ្វីឡើយ ត្រង់ដែលទីធ៌ចានទីធ៌បង់ប្រការម្តេច តង់តែយូរទៅអ្នកទីធ៌ដឹងគំនិតរបស់យើងមិនខាន" ហើយចូឆូ ក៏ស្រូតបង្គំលើកតង់ទំពដល់កណ្តាលផ្លូវ ទំពមុខចូឆូដួចប្រទះទីធ៌ទំពប៊ុនធីវ ជានតតាំងច្បាំងគ្នាជាពន្ធឹក, តង់ឡាំលៀងនៃចូឆូដែលនាំស្បៀងអាហារទៅនោះ មិនប៊ុនប្រសប់ទីធ៌ច្បាំង ក៏បែកខ្ចាត់ខ្ចាយទៅតាំងស្បៀងអាហារអស់ ។ តាហានប៊ុនធីវ ក៏ចាប់ជានស្បៀងអាហារទីធ៌នឹងត្រីធ៌សស្ការុនជាច្រើន ។ ឯតង់ឡាំលៀងដែលបែកទៅនោះ ក៏នាំយកពតិមានមកដំកបចូឆូថា តាហានប៊ុនធីវវាយតាត់យកស្បៀងជានអស់ហើយ ទ្រុទីធ៌ស្រូតមកដំកបលោកមិនតាន់តារ ឥឡូវតាហានប៊ុនធីវលើកទ័ព្រួនចូលមក ។ ចូឆូជានស្តាប់ក៏មិនតបឆ្លើយថាអ្វីសោះ ខ្លួលត្រឡែកយើញរដ៌ងកុំនៅកែវផ្លូវ ក៏នាំតាហានតាំងពួនចូលទៅអែបនៅកែវរដ៌ងកុំនោះ ហើយឲ្យតាហានចុះពីលើសេះដោះក្រឹសចេញ តែតាហានដែលនៅជិតចូឆូនោះឲ្យតាន់អាវុធប្រចាំតារ ។ ឯតាហានចូឆូត្រឡែកយើញតាហានប៊ុនធីវលើកតាមមកជិតក៏ភ័យណាស់ បបួលគ្នាស្រែកដោះឡោថា ត្រូវតែថយទៅបន្ទាយវិញប៉ុនវែបវិញ ។

ស៊ុនហ៊ីរដ៌ងអធ្យាស្រ័យនៃចូឆូ លុះត្រឡែកយើញតាហានតង់ទំពត្រឡប់បែកខ្ចែកដូច្នោះ ក៏ហាមឃាត់ពួកតាំងនោះថា កុំឲ្យភ្លាត់ឆ្គួលធ្វើអ្វីតាខេះយើងជានតល់តារហើយ ។ ចូឆូជានឮស៊ុនហ៊ីរនិយាយដូច្នោះក៏ត្រេចិត្តណាស់អស់សំណើចហើយញាក់មុខឲ្យស៊ុនហ៊ីវ ។ ឯតាហានប៊ុនធីវលុះលើកតាមកយើញតង់ទំពចូឆូទៅដ៌ងកុំ មិនជានរៀចរយជាស្មួន

ខ្ញុំ ប៊ុនធីនឹងនាហានទាំងពួងក៏មានចិត្តកំរើកលើកគ្នាចូលវាយដណ្តើមយកសេះទឹងត្រីងសស្តាវុង ដែលជាក់ភាត់ភាយនៅក្បែរផ្លូវនោះ ។ ចូចួយល់ថាខ្លាចចំណាប់កិបត្តាប់ឲ្យគង់ខ្លួន ដែលពួនបង្កិបនោះចេញមកម្លាមខ្លួនប៊ុនធីវ៉ា ចូលចាប់សម្លាប់ពួកនាហានប៊ុនធីវ៉ា ក៏ពាខ្លាមកបង្កាំងតស៊ូជាពន្លឺត លុះឃើញថាកំឡាំងនឹងតទល់មិនបាន ក៏ញាក់សេះស្ទុះបំពានចំលាយខ្លួនចូចួដែលពួនោះចេញទៅតែម្នាក់ឯង ។ ចូចួនៅលើភ្នំក្រែកឡើកឃើញដូច្នោះក៏ស្រែកថា ប៊ុនធីវ៉ាសេនាឯកម្ចិនស្រីបំផ្លាយសេះរត់ទៅខាងណោះហើយ នរណានឹងយកអាសាចាប់ឲ្យយើងបាន? ។

ខ្លែវលៀវនឹងស៊ុឡង់ក៏ធ្វើយខ្លើងខ្លួលយកអាសា ហើយបំផ្លាយសេះតាមទៅ ប៊ុនធីងាកមកឃើញគាហានសេះ ២ បរដេញតាមមក ក៏យកធ្នូបាញ់ត្រឡប់មកវិញ ត្រូវកំពូលមក់ខ្លែវលៀវជាប់ធ្លាក់ពីលើក្បាលខ្លែវលៀវនឹងណាស់ក៏ពង្រីតសេះដេញចូលទៅមុខសេះស៊ុឡង់ បំណងនឹងចាប់ខ្លួនប៊ុនធីវ៉ាឲ្យបាន ប៊ុនធីវ៉ាបាញ់ថែម ១ ព្រួញមកទៀត ត្រូវកំផ្លង់ខ្លែវលៀវធ្លាក់ពីលើសេះ ប៊ុនធីវ៉ាក៏ងាកត្រឡប់មកទទឹងគាប់ខ្លែវលៀវ ខ្លួលស៊ុឡង់ស្ទុះទៅទាន់យកជារវង់ជាប៊ុនធីវ៉ាជាប់ ស៊ុឡង់នឹងប៊ុនធីវ៉ាក៏ប្រយុទ្ធគ្នាទៅវិញទៅមកបាន ៣០ ក្នុង ខ្លួលគាហានប៊ុនធីវ៉ាដែលទៅតាមក្រោយលើកពួនចូលមកជាច្រើន ស៊ុឡង់ឃើញទឹងថ្នាក់ការក៏នាំខ្លែវលៀវត្រឡប់ចេញមកវិញ ។ គួនអ៊ូឃើញដូច្នោះក៏បំផ្លាយសេះនាំគាហានច្រហែល ១១-១២ នាក់ស្ទាក់តាមទៅ ហើយស្រែកសន្ធាប់ថា អាសត្រូវបរសេះរត់ទៅណា? ប៊ុនធីវ៉ាឮច្បាស់ក៏ទឹងច្រឡាត

ចូលប្រយុទ្ធនឹងគួនអ៊ីបាន ៣ ក្លេង ប៉ុន្តែវាយលាំកំឡាំងនឹងខ្លាំងពុំបានគំបរ
សេះចេញត្រឡប់ទៅរកគង់ខ្លាំងវិញ គួនអ៊ីបរសេះសឹកថយដេញទៅ
ដោយថ្មើដើរលឿនរហ័សដល់ត្រើយទន្លេហង៍ហោ ទាន់សេះប៉ុន្តែវា គួនអ៊ី
កំលើកជាវគាប់ត្រូវប៉ុន្តែវាធ្លាក់ពីលើសេះស្លាប់ ។ ចូរឆ្លៀតលើកំពូលភ្នំ
ក្រឡេកឃើញ កំឱ្យទាហានដេញតាមសម្លាប់តែងវិញប៉ុន្តែវាស្លាប់ជាច្រើន
ទាហានដែលសល់ពីស្លាប់ក៏រត់បែកខ្ចាត់ខ្ចាយអស់ទៅ ស្បៀងនឹងគ្រឿង
សស្ត្រាវុធដែលមានទៅវិញនោះប៉ុន្មានក៏ឱ្យទាហានចូរឆ្ពាំងអស់ ។

ឯឡៅពីលើកទាហាន ៣ ម៉ឺន ជាខ្លាំពណ្តូនមកពីក្រោយប៉ុន្តែវា
ទៅមិនទាន់ឆ្ងាយខ្លះផង ទ្រុលជួបប្រទះនឹងទាហានប៉ុន្តែវាដែលបែកខ្ចែក
មកនិយាយប្រាប់ឡៅពីថា មានសេនាចូរម្នាក់មុខក្រហមពុកមាត់វែង
សម្លាប់ប៉ុន្តែវាស្លាប់ខ្លះទៅហើយ ។ ឡៅពីឮដូច្នោះក៏ភ័យស្ទុះចិត្ត
ខំបរសេះស្រួតទៅដល់មាត់ទន្លេជាយព្រៃ ក្រឡេកទៅឃើញកងខ្លាំង
ត្រើយម្ខាងស្គាល់ជាទាហានចូរ តែរកមើលមិនឃើញខ្លួនគួនអ៊ីសោះ
ឃើញតែទង់ដំយសរសេរឈ្មោះថាគួនអ៊ី ឡៅពីក៏មានចិត្តត្រេកអរ
ច្រើន តែកង់ចិត្តគិតថា "គួនអ៊ីប៉ុន្តែវាអញនៅ។ នោះទេឬ" ប្រឹងនឹងចាំ
មើលឱ្យឃើញខ្លួនគួនអ៊ី ទ្រុលទាហានចូរប្លុកធ្លងមក ឡៅពីក៏ភ័យ
ណាស់ទាំងទាហានខ្លួនឯងត្រាយមកវិញ ។

ឯទាហានប៉ុន្តែវាដែលបែកមកនោះមិញ ក៏នាំយកសេចក្តីទៅប្រាប់
កួតៀនឹងស៊ីមផួយថា ទាហានចូរម្នាក់មុខក្រហមពុកមាត់វែងឈ្មោះគួនអ៊ី
សម្លាប់ប៉ុន្តែវាស្លាប់ទៅខ្លះហើយ ។ កួតៀនឹងស៊ីមផួយក៏នាំរឿងនោះ

ទៅដំកបអ្នកនៅត្រង់ប្រការ ។ អ្នកនៅបានឮដូច្នោះខឹងណាស់ក៏ដេរ
ឡៅតីថា អាឡៅតំត្រចៀកយា ! ឯងកែងឲ្យប្អូនឯងមកសម្លាប់សេនាឯក
របស់យើងដល់ ២ នាក់ ។ ខ្ញុំលេឡៅតីចូលមកដល់ អ្នកនៅបង្គាប់ឲ្យ
ចាប់ឡៅតីទៅសម្លាប់ ។

ឡៅតីសួរថា ខ្ញុំបាទមានទោសទាស់នឹងអ្វីបានជាលោកឲ្យចាប់
ខ្លួនខ្ញុំបាទទៅសម្លាប់ដូច្នេះ ? ។ អ្នកនៅតបថា កាលគ្រាមុនយើងក៏
បានលើកទោសម្តងទៅហើយ តែឡូវនេះកែងឲ្យប្អូនរបស់ខ្លួនមកសម្លាប់
សេនាឯករបស់យើងស្លាប់ម្នាក់ទៀត ហេតុម្តេចខ្លួនថាមិនមានទោស ? ។
ឡៅតីថា "បើពុកជាដូច្នោះក្តី សូមឲ្យខ្ញុំបាទដំកបសេចក្តីឲ្យលោកជ្រាប
១ ខាន ចួចសឹមសម្លាប់ខ្ញុំបាទចុះ" ហើយដំកបថា "អំពីមុននោះ
ចួចមានចិត្តរង្កើសនឹងខ្ញុំបាទជាច្រើន តែនឹងសម្លាប់ខ្ញុំបាទចោលចេញ
តែឡូវនឹងថា ខ្ញុំបាទមកសំណាក់ជិតកោនទៅនឹងលោក ក៏ជាកំឡាំងគិតការនេះទៀត
ចួចក៏កែងប្រើគួនអ្នកមកសម្លាប់សេនាលោកចេញ បើលោកជ្រាបហើយ
គង់តែនឹងនឹងខ្ញុំបាទ ឧបមាដូចចួចខ្លួនឯងដែរ លោកឲ្យសម្លាប់ខ្ញុំបាទ
គួនអ្នកនោះក្រែងជាមិនបានដឹងថា ខ្ញុំបាទមកជ្រកកោននៅនឹងលោកទេ
តើបសុំបាកអាសាចួចមកសម្លាប់សេនាឯករបស់លោកចេញ បើខ្ញុំបាទមានសំបុត្រទៅជាប់គួនអ្នក ។ ដឹងហើយក៏ទឹងចូលមកគេខ្ញុំបាទ
ទឹងបានជួយមកធ្វើការជាកំឡាំងលោកតទៅ ដែលលោកឲ្យចសេនាឯក ២ នាក់នោះ ឧបមាបីដូចជាឲ្យចប្រើស ២ គួនទៅវិញ ។

អ្នកនៅបានស្តាប់ដូច្នោះ ក៏ត្រឡប់ចិត្តគិតឃើញត្រូវ មានអំណរ

ណាស់ ។ និយាយទៅទើនស៊ីមផ្ទួយកូនគៅថា "ខ្ញុំនអ្នកទាំង ២ គឺតគប់គ្នាមក ញុះញង់ប្រៃយើងសម្លាប់ខ្លួនឯង ដែលមានសតិបញ្ញាខៀនត្រង់ទើនដែនដ នោះ ម៉ខ្ញុស្សទាំងពួងដឹងព្រមហើយក៏ទើនតរហាទិញ្ញាដល់យើង" ថាហើយ គឺបណ្តែញស៊ីមផ្ទួយទើនកូនគៅចេញទៅ ហើយអញ្ជើញខ្លួនឯងមកអង្គុយ និយាយថា បើយើងបានគ្នូនអ៊ូមកទុក ក៏ទើនល្អជាងងាន់លៀងទើនប៉ុនណា ១០ សួនទៅទៀត ។ ខ្លួនឯងក៏ធ្វើសំបុត្រធ្វើទៅឲ្យគ្នូនអ៊ូហើយជូនទៅ ឲ្យអ្នូនសៀវមើល អ្នូនសៀវក៏ទទួលយកសំបុត្រនោះមកមើល ហើយចាត់ មនុស្សឲ្យនាំសំបុត្រទៅឲ្យគ្នូនអ៊ូនោះ តែមិនមាននរណាហ៊ានទទួលយក អាសារទៅឲ្យសោះ ។ វេលានោះ អ្នូនសៀវក៏ថយកងទ័ពត្រឡប់ទៅតាំង នៅតំបន់ប៊ូអៀង នាយទាហានក៏តាំងបន្ទាយរាយកងទ័ពចុះទៅ ចម្ងាយ ផ្លូវប្រហែល ៥០០ សិន (២០ គ ម.) ឲ្យត្រួតត្រាក្បាបន្ទាយទុកឲ្យមាំ មួនមិនខាន់ឲ្យចេញចាំងទើនកងទ័ពចូន ។

ឯចូនក៏ឲ្យតាំងបន្ទាយនៅតំបន់គួតរ លុះអ្នូនសៀវមិនលើតមកចាំង សោះ ចូនក៏ចាត់ឲ្យហៅហ្លួនត្រួតត្រាក្បាទាហានកងបន្ទាយ ចូនឯងក៏ នាំគ្នូនអ៊ូលើកកងទ័ពត្រឡប់ចូលទៅក្រុងហ៊ូតោវិញ លុះដល់ហើយក៏ឲ្យ តែងតុលៀងគោជនាហារ ឲ្យគ្នូនអ៊ូទើនសេនាទាហានទាំងពួងបរិភោគ ។ ចូនក៏និយាយទើនលីយ៉ាយថា ដែលយើងឲ្យកងខ្លាំលៀងលើករទៅជាកង មុខនោះ នរណាក៏មិនបានដឹងគំនិតយើងជាកល់សឹក បានជាអ្នកខ្លះមក និយាយទើនឥស់ទើនយើង មានតែស៊ុនហ៊ីម្នាក់ទេដែលអាចដឹងគំនិត យើងបាន ។ ទាហានទាំងពួងក៏សរសើរតម្កើងប្រាជ្ញាចូនថា លោកមាន

ច្រើនជាងនេះទៀតក៏មិនគួរ ។

ខណៈនោះ ខ្លួនមានបំរើសេះគាន់សំបុត្រមកពីគាវពជគាវមកជូនចូនចូថា ចោហនដែលឲ្យគេស្រុកយើងប្តឹងមកថា មានមេចោរ ២ នាក់ ឈ្មោះខ្លាវផេក ១ កុនៈតេ ១ លើកគ្នាកម៉ាតមកជាច្រើន ដើរកាតគ្នាធ្វើទុក្ខបុកម្នេញអាណាប្រជានុពស្រុកនេះអាណាចក្តយើងំ ចោហនលើកទាហានទៅបង្ក្រាបជាច្រើនគ្រា យើញលើសតំណាងនឹងការពាំបាន។ ជាបកសំបុត្រមកសុំកងទ័ពឲ្យលើកទៅជួយ ។

គួនអ៊ូឮដូច្នោះក៏ដឹកបចូនចូថា ដែលពួកចោរធ្វើទុក្ខប៉ែតប្រពឹត្តអាក្រក់ដូច្នេះ ខ្ញុំបាទសុំយកអាសាលើកទាហានទៅបាប់បាមឲ្យកបាបឲ្យបាន ។ ចូនចូឆ្លើយថា អ្នកទើបទើមកតែធ្វើការសង្គ្រាមកំពុងខ្សោយទៅទេ តុណចំណាយរបស់អ្នកដែលតាប់ប្រសើរកំរិតមិនទាន់បានខ្លួនស្នើសុំឲ្យអ្នក ដែលអ្នកនឹងសុំយកអាសាទៅបង្ក្រាបចោរវេលានេះទៀតក៏មិនគួរ ។ គួនអ៊ូឆ្លើយថា ខ្លួនខ្ញុំបាទនេះបើឈប់ទៅសឹមមិនធ្វើការសង្គ្រាមក៏រមែងឈឺស្អាត់ មហាឧបាជច្រមេត្តាបើកឲ្យខ្ញុំបាទចេញទៅធ្វើការសឹកចុះ ទើបទើនឹងបានសេចក្តីសប្បាយ ។ ចូនចូថា "បើអ្នកទើនឹងចង់ទៅធ្វើការសឹកក៏តាមចិត្តចុះ ដែលយើងថាដូច្នេះព្រោះមានចិត្តប្រណី" ហើយចូនចូក៏តែណាទាហានឲ្យគួនអ៊ូ ៩ ម៉ឺន ឲ្យអ៊ីកមនឹងនាក់ដឹនអមទៅ ៨ ដង ។ គួនអ៊ូ, អ៊ីកម, នាក់ដឹនក៏លាចូនចូលើកទ័ពចេញទៅ ។

ស៊ីនហុកចូលទៅដំកបចូនចូថា ដែលលោកប្រើឲ្យគួនអ៊ូលើកទ័ពចេញទៅនោះ ខ្ញុំបាទយល់ថា គួនអ៊ូនឹងស៊ើបសួរដំណឹងរកខ្លាំពី បើ

ដឹងថាឡៅតីនៅទីណាគួនអ៊ូមុខជានៅពុំខាន ។ ចូរឆ្លងបថា យើងបាន ជាបើកមាត់ព្រមឲ្យគេទៅហើយ ឥលូវនេះបើនឹងរំលែកក្យសំដីឲ្យហៅ ត្រឡប់មកវិញនោះ ឃើញថាមិនគួរសមសោះឡើយ, ដល់គេទៅមុខ យើងនឹងរំលងច្រើឲ្យទៅហើយ ។

ឯគួនអ៊ូកាលលើកទ័ពចេញទៅនោះ បានទៅដល់ស្រែកយីឡាំឲ្យ ចោះទ័ពចាប់ធ្វើបន្ទាយជាមាំមួន លុះគេលកណ្តាលអាធ្រត្រសូត កង ក្រវែលចាប់បានឈ្លើយ ២ នាក់ ឃុំនាំយកខ្លួនចូនគួនអ៊ូ។ ក្រឡេកឃើញ ស៊ុនខៀនក៏នឹកតែក្នុងចិត្តថា "ស៊ុនខៀនទៅនៅទីណាបានជាឲ្យគេចាប់ មកបាន" គួនអ៊ូក៏បណ្តេញមនុស្សពាំងអស់ឲ្យដើរទៅខាងក្រៅ ទើបឲ្យបំ សួរស៊ុនខៀនថា តាំងពីយើងបែកគ្នានឹងខ័ពចូរទៅគ្រានោះ យើងតាំង អស់គ្នាក៏ព្រាត់ប្រាស់និវាសទៅតែដោយខ្លួន ឥឡូវអ្នកមកនៅឯណា បានជាគេចាប់បាន ? ។

ស៊ុនខៀនតបថា កាលយើងបែកគ្នាទៅនោះក៏ព្រាត់ខ្លាត់ពីឡៅពី ខ្ញុំ មកអាស្រ័យនៅនឹងឡៅផែកក្នុងស្រែកយីឡាំ" រួចស៊ុនខៀនក៏សួរគួនអ៊ូ វិញថា ហេតុម្តេចបានជាអ្នកទៅនៅនឹងចូរ? ចុះបងថ្លៃអ្នកទាំង ២ នោះ ជាសុខសប្បាយតាមធម្មតាទេឬ? ។

(មានត)

លោក ផេង-ជ្រឿ សេរ្ដីចារឬនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាចាំងមកជាភាសាខ្មែរ

(ត-ចប់)

រួចតមក នាងនឹកឃើញកាលអ៊ីស្មាអ៊ីលយ៉ាងហាវហាន ហ៊ានសំឡាប់នាយចាហានរងតួរគេ ដើម្បីជួយការពារខ្លួននាង ហើយអ៊ីស្មាអ៊ីលចាប់ក្រែកនាងដើរសំដៅផ្ទះទុក កាលដែលអ៊ីស្មាអ៊ីលជញ្ជក់មាត់នាង។ មានតម្រែកក្នុងការដប់ថើបជាពន់ពេក ។ ទុរឿងខាងលើនេះ ឥឡូវផ្ទាយហើយ ។

* * *

ពួកមនុស្សទាំងគ្នាដើរតិច។ តាមផ្លូវទៅ ។ គឺដើរទ្រង់ទ្រាល ឡើងជួកខ្សាច់លើងណាលចាំងថ្ងៃត្រិច។ មើលជាច់កន្ទុយក្អែក ។ ឥឡូវពួកចាចក់ដួចជាខិតទៅជិតក្បែរប្រទេសដែលច្បាំងខ្លាំងតែនឹងរុកកាន់ហើយថ្មី។ ។ គេកាន់តែចូលទៅជិតមាត់សមុទ្រ ដែលមានភូមិជាប់បន្តគ្នាប្រកបដោយផ្ទះដំខានបូកណា ដំបូលកប ប្រក់កន្ទេល ប្រក់ស្លឹក ប្រក់ដីស្អិតគ្រាន់តែធ្នាដើរលើលាន់ឮសូរគ្រែបគ្រែប ។ ផ្ទះកន្លះបាំងនោះស្រុតរលំដោយទឹកភ្លៀង កំទេចកំទីរនៅប្រគរលើគ្នា ក្បែរខ្លួមថ្មី។ ដែលអ្នកស្រុកទើបនឹងធ្វើយ៉ាងប្រញាប់ឲ្យតែបានទៅ ។

ភូមិធំនេះ ត្រូវជាកន្លែងសមរស្មាន គឺជាទិតមដែលតាមាំព្រកអែលយោនបំណងនឹងមកលក់ទំនិញ ជាកន្លែងលក់រួចហើយបានចំណេញ

ច្រើនផង ។ តម្លៃវិនេះ ឃើញតែសេចក្តីទុក្ខទំនឹងសេចក្តីអន្តរាយ ។ ផ្ទះលក់ទំនិញតាំងឡាយដែលត្រូវតាំក្តៅធំកំពេចហើយនេះ រលំអស់រលីងផ្ទាន់ផ្ទង ត្រូវក្តៅភ្លេតរាជាគំនរឈើសុទ្ធតែធ្យូងដែលកណ្តៀរកំពុងស៊ុ ។ កន្លែងតែប៉ុន្មានម៉ោង អស់តាំងសំពត់អម្បោះ សំពត់សូត្រ សែកទំនឹងគ្រឿងប្រដាប់ប្រដាស្បៀងអាហារផ្សេង ។ នេះទៀតផ្ទះហើយមនុស្សដែលរស់រត់ស្រែកអំពាវនាវ យំសោកស្តាយទូវសម្បត្តិគ្រប់ដែលវិនាស ។

តម្លៃរួចបង់ហើយ នាងឡីឡាដេកមិនលក់ ចេះតែមមើរមមាល ។ នាងឃើញអ៊ីស្មាអ៊ីលដួលដេកស្ងាប់តណ្តាលទីវាល មានតស់ក្អែបពេមព័ទ្ធជុំវិញ ជួនកាលនាងឃើញគេនៅតណ្តាលសមរភូមិ ឮសពេញដោយមនុស្សស្ងាប់ រួចបន្តិចមកគេហាក់ដូចជាស្ងាប់ដែរ ប៉ុន្តែគេលោស្ទុះគ្រាកឡើង នាងឃើញខ្លួនគេប្រហោង ឈាមហូរចេញពីបេះដូង ។ រួចគេក៏គ្រឡប់ដួលផ្កាប់មុខទៅវិញ រំសែកហៅថា: ឡីឡា! ។

យល់សប្តិអាក្រក់នេះធ្វើឲ្យនាងភ្ញាក់ឡើងញ័រអស់តាំងខ្លួន ហើយកន្លងសំណាល់ពេលតាំងប៉ុន្មាន នាងមានតែសេចក្តីទុក្ខព្រួយរកទីបំផុតគ្មាន ។

មានព្រឹកមួយ ពួកចាចរក៏កំពុងតែប្រជុំប្រជៀប នឹងធ្វើដំណើរចេញចាកភូមិឃាជាយ៉ាដ នាងក្រមុំបានឃើញមនុស្សម្នាក់ដើរអួជបរតាមផ្លូវ ។ លុះមនុស្សនោះមកជិតនៅចម្ងាយតែបន្តិចតែប៉ុណ្ណោះ នាងឡីឡារំសែកដោយសប្បាយថា:

- តាឡីប!

គឺជាតាឡិបច្រែកដដែរ ។ គាត់នេះចេះតែដើរផ្តេសផ្តាស ដូចគាល គាត់ទៅនៅទឹងពួកអ្នកដើរទេស ជួយលក់ទំនិញ ជួយមើលថែសត្វ ពាហនៈឲ្យគេ យកតែបាយស៊ី ។ នាងក្រមុំសុះសំដៅដណ្តើលកុដិក។ ស្រែកហៅថា :

- ឡឺឡា !

លុះឲ្យសត្វជំនិះលុតជង្គង់រួចហើយ គាត់ក៏ចុះមកដី ។

នាងឡឺឡារៀបរាប់ច្បាប់តាឡិបអំពីព្រឹត្តិការណ៍ ដែលកើតមានទៅឯក្រុងតាស៊ី - កាកប៊ូលី ទាំងគ្រោយការចាកចោលរបស់គាត់ ។ តាឡិបក៏មិនសូវធ្វើឆ្ងល់ប៉ុន្មានគាត់និយាយថា :

- ខ្ញុំដឹងដែរ រឿងអស់នោះ ។ ឲ្យលុកឯកន្តារៈទាំងណឹងទាំងប៉ុន្មានមកច្បាប់ខ្ញុំគ្មានសល់ ។

នាងឡឺឡាអត់ទ្រាំពុំបាន ក៏សួរថា :

- ចុះតាដឹងឬទេ អ៊ីស្មាអ៊ីលដូចម្តេចទៅ ?

តាឡិបមុខឡើងខ្មៅ ហើយច្បាប់ថា :

- ល្អើយកុំតិត ! អ៊ីស្មាអ៊ីលចៅហ្វាយខ្ញុំ ជាប់ជាអ្នកទោសរបស់ជាតិតួរតើកឯបន្ទាយកស្បាម៉ុតហើយ។ លោកមានសេចក្តីអន្តរាយធំ . . . . ។

ភ្លាមដូច្នោះ ឡឺឡាឆេងឆោង ។ ដើម្បីកុំឲ្យដួល នាងសុះទៅគោងបង្អែរអូដ្ឋ ប៉ុន្តែការណ៍នេះក៏អន់ឡើយ ហើយបាត់ទៅញែកក្តាម តំនិតដែលគិតឃើញថា គួសន្សារដល់ទ្រព្យសេចក្តីអន្តរាយស្ងាប់ខ្លួន ធ្វើឲ្យនាងមានកំឡាំងក្លាហាន ។ នាងនិយាយដោយសំដីមឺងមាត់ថា.

— ត្រូវតែជួយសង្គ្រោះអ៊ីស្មាអ៊ីល ចូរយើងទៅឯបន្ទាយកស្សាម៉ុត ។

តាឡិបដែលជាមនុស្សមិនសូវខ្វាចស្ងាប់ សំឡឹងមុខនាងក្រមុំ គាត់ពិនិត្យទៅឃើញថាការសម្រេចនៃនាងឥតកែប្រែ រួចគាត់សំឡឹងមើលដើងមេឃម្តង ។ បើទៅតាមផ្លូវដែលគាត់ស្គាល់ ជនចំនួនតិចនឹងអាចទៅដល់បន្ទាយកស្សាម៉ុតដោយ ងាយ ហើយបានឆាប់ផង ។

តាឡិបឆ្លើយថា:

— គំនិតហ្នឹងល្អហើយ ! យើងចេញទៅយប់នេះ !

រួចគាត់ទៅធ្វើការរបស់លោកតាម៉ាត្រក ។

វេលាល្ងាច កាលដែលពួកចាកចរក៍ឈប់សម្រាក លុះពួកគេស្ងាត់ឈ្មោះចូលទៅសំឡឹងមើលម្ចាស់នាងកំពុងដេកលក់ ដោយមេត្តាចិត្តរួចត្រឡប់មកជួបនឹងតាឡិបវិញ ។ ជនចំនួនពីរធ្វើដំណើរចេញទៅដោយស្ងៀមស្ងាត់សំដៅបន្ទាយកស្សាម៉ុត ។

*

* *

រឿងបង្ហើយ

នាយទាហានវ័យក្មេង ចូលមកដោយស្ងៀមស្ងាត់ ក្នុងគុកបន្ទប់លេខ ២ ដែលគេដាក់លោកអន្ទុសេនីយឯក អ៊ីស្មាអ៊ីលបេន - អៃយ៉ាដ ។ នាយទាហានវ័យតំនាងដាក់ដើងពាំងពីរគ្រឹមគ្នាហើយច្រាបថា:

— លោកវរសេនីយឯកមានច្បាសាសន៍អញ្ជើញលោក ។

អ៊ីស្មាអ៊ីលក្រោកឡើងពាំងពាក្យ គេឥតសង្ស័យថានឹងបានរស់តទៅទៀតឡើយ ។ មុខគេច្រកបដោយការហត់ហៀវ អស់កំឡាំងនឹងសេចក្តី

ទុក្ខព្រួយជាពន់ពេក ប៉ុន្តែគេមានសេចក្តីសម្រេចយ៉ាងម៉ឺងម៉ាត់ ព្រមទទួលមរណភាពដោយក្លាហាន ។ ខ្ញុំ ប្រសិនបើគេបានឃើញមុខនាងឡាមុននឹងធ្វើដំណើរដ៏ធំនេះ ម្លេះសមនឹងស្រាកទុក្ខបានខ្លះ ។

នាងឡាគឺជាបុជ្ជា ជាការកែកយកក្នុងជីវភាពរបស់គេ នាងឡាមានចិត្តអម្រែតដែលអាចស្រាចចុះក្នុងដួងព្រលឹងរបស់គេ ។ ខ្ញុំ មិនត្រូវនឹកសោរឿងនេះ ព្រោះជាការសង្ឃឹមស្រមើស្រមៃឥតបានប្រយោជន៍ ។ ចំណែកនាងក្រមុំកំសត់គោតយ៉ាក មិនដឹងជាខ្លួញសោកយ៉ាងណាទេ នៅឯផ្ទះថ្ម កណ្តាលពពួកដើមគ្នោតស្ងឹកបៃតងនាក្រុងកាំស៊ី - ភាពប៊ូលី ។

* * *

"សេចក្តីស្នេហារបស់ស្ត្រី គឺជាម្ចប់នៃដើមឈើលើកលឿងច្បាប់ . . .

"ខុដើមគ្នោតលៃអើយ ! សូមដឹងច្បាប់ត្រង់ក្នែងកបំភ្លោច កុំសង្កត់ឲ្យធ្ងន់ពេកលើមួសនៃអ្នក . . ." ។

លុះចេញពីបន្ទប់ងងឹតមក អ៊ុស្មាអ៊ុលប៉ប្រិចភ្នែកដោយប្រទះនឹងពន្លឺថ្ងៃ ។ ព្រះអាទិត្យដែលតែងតែធ្វើត្រជាក់ឥតឈប់ឈរ ក្នងទីនេះគង់ចាំងរស្មីទៅលើទេសនាការខាងសេចក្តីស្លាប់ ។ សង្ស័យ? ភាយោបល់នាំយកសួរពេងដដែល ។ នៃគាំក្តៅពីទិសទក្សិណមក ។

គាហានបួននាក់ដើរពីក្រោយអ៊ុស្មាអ៊ុល ហើយនាយគាហានឯងជាអ្នកចាត់ការនាំបណ្តើរតាមច្រក រួចមកដល់កន្លែងយាម ក្នងទីបំផុត មកដល់ជើងជណ្តើរចង្អៀតមួយ ដែលនាំឡើងទៅលើថ្លាក់ប៉មជាន់ខ្ពស់នៃបន្ទាយទៅត្រង់កន្លែងនេះមានទង់ជាតិពណ៌ក្រហម ដើរក្បែរជ្រុង ភាយផ្លា

មាស របស់ជាតិសូតិ៍ពិបាកវិច ។ ត្រង់មន្ទីរនោះហើយដែលតុលាការចម្បាំងហៅកូនប្រុសនៃលោកតាកាអ៊ីដអែយ៉ាដមកដំនុំដំរះ ។

គឺជាបន្ទប់មួយដ៏ប្លែកឡូម ជញ្ជាំងថ្នេរ មានរូបព្រះចៅសុលតង់តាំងលំអនៅនោះ ។ មានទាយាទាហ៊ានប្រាំនាក់អង្គុយលើកៅអីដែលដាក់នៅតំខ្ពស់វិញតុឈើខ្មៅមួយធំ ។ លោកវ៉ាសេនីយហ្វាវ៉ឺន ជាមេទ័ពប្រចាំបន្ទាយជាអធិបតីនៃការដំនុំដំរះ លោកអង្គុយយ៉ាងស្រួលតែម្នាក់ឯងលើកៅអីស្អយ៉ាងត្រឹមត្រូវ ។ នៅខាងស្តាំទីងខាងធ្វេង មានលោកអនុសេនីយឯកពីរនាក់ជាចៅក្រមវិន ។ នៅចុងតុសងខាងមានអនុសេនីយគោម្នាក់គាន់ការជាក្រឡាបញ្ជី ម្នាក់ទៀតគាន់ការជាកុម្ម៉ង់ស្យារនៃរដ្ឋាភិបាលសម្រាប់សូត្រពាក្យកត់ចម្ងើយ ។ លុះអ្នកទោសចូលដល់នាយទាហានវ៉ែនទីងពួកទាហានថយចេញក្រៅ តាមសញ្ញារបស់លោកអធិបតី ។

អ៊ីស្មាអ៊ីលបេន អែយ៉ាដនៅតែម្នាក់ឯងឈរមុខចៅក្រម រួចសំនួរកំចាប់ផ្តើមឡើង ។ តាមការណ៍ពិត គេហៅមកសួរយកតែនាមទេ ចៅក្រមគ្រប់គ្នាមានការសម្រេចស្រេចអស់ហើយ ។ គេត្រូវធ្វើតាមបទបញ្ជានៃកុងស្តង់ទីណុប គឺសម្រេចទោសត្រូវបំបាត់ជីវិតមនុស្សនេះចោលចេញ ។

ចំណែកអ៊ីស្មាអ៊ីលបេន - អែយ៉ាដនៅតែគាន់អាតឃ្យកិរិយាស្ងៀមស្ងាត់ដដែល ។ គេព្រឺមជាតិសូតិ៍ហួតដល់មិនព្រមតវ៉ាដើម្បីការពារខ្លួនអំពីការចោទឲ្យបំពានគ្មានយុត្តិធម៌ ។

លុះយើញថាគ្មានយកចម្លើយអ្វីមួយបានពីអ្នកទោសនោះ ហើយ
គ្មានចំណាំនឹងបន្តសម័យប្រជុំទៀតទេ លោកវរសេនីយឯកជ្រាបនាយ
ទាហានដែលតាន់មុខជាវាជាក្រឡាបញ្ជីឲ្យសម្រែចសេចក្តី ។

ក្រឡាបញ្ជីនេះគឺជាទាហានចាស់ម្នាក់ ពូជអម្បូរជាន់ទាបដែល
អាពុកម្តាយធ្លាប់ធ្វើជាអ្នកបំរើរស់ពួកព្រះវង្សមានសម្បត្តិ ម្ល៉ោះហើយ
លោកនេះមានគំនុំតែម្យ៉ាងចំពោះកូននៃព្រះញាតិវង្សទាំងនោះ ទោះបីជា
អាប់ប្តូរគេក៏ដោយ ។ តែងរូបអ៊ីស្មាអ៊ីលជានាយទាហាន លោកនេះមិន
ចោទប្រកាន់កងបម្រុងឃុំសួរឃាងនឹងការក្បត់ប៉ុន្មានឡើយ ការណ៍ដែល
លោកចោទប្រកាន់នោះ ចំពោះតែងរូបអ៊ីស្មាអ៊ីលជាកូននៃលោកតាកាអ៊ុង
ប៉ុណ្ណោះ គឺជាវណ្ណៈនៃព្រះវង្សក្នុងសាសនាឥស្លាមដែលមានអាការទាង
ក្រែវជាអ្នកចុះចូល តែចិត្តទាងកងជាសត្រូវយ៉ាងមាំនឹងរង្គាកចាលតួរគេ ។
លោកស្តាយដែរ មិនគួរតាត់ទោសដ៏ធ្ងន់ដល់ប៉ុណ្ណោះឡើយ រួចលោក
សម្រែចសេចក្តីកងសាលក្រមថា អ៊ីស្មាអ៊ីលជាប់ទោសយ៉ាងធ្ងន់កងបម
ម្រុងឃុំសួរឃាងនឹងការក្បត់ ។ ហើយលោកនិយាយថា: ខ្ញុំតាត់ទោស
តែងរូបជាខ្ពស់បំផុត ចំពោះរូបអនុសេនីយឯកអ៊ីស្មាអ៊ីល បេន អៃយ៉ាជ ។

អ៊ីស្មាអ៊ីលខ្លៅតែស្ងៀម ស្តាប់ពាក្យគេដំនុំដំរះ ដូចជាស្តាប់សំរែក
ត្មែតត្រសែបទាំងគ្នា គ្មានយកចិត្តទុកដាក់ប្រឆងនឹងស្តាប់ប៉ុន្មាន ។ កងពេល
ដែលនាយទាហានអយ្យការចេះខ្យល់ កំពុងរកឫសនឹងគេ។ គិតតែនឹកខ្ពើ
ផ្ទះថ្នល់ មានជុតបង្គុយចន្ទល់ក្រស្នា ខ្លៅតាមច្បាប់ជែបដោយ
ក្សត្រក្បាច់រចនា, ខ្លាឃក្រាលថ្នែរ, កន្ទែងឆ្នូតទឹកព្រាចពាសដំត្រដាក់

ក្រុមស្តីបរិវារ ដែលសួរសំឡេងនាងឡឺឡាដ៏បរិសុទ្ធ យ៉ាងស្រួយស្រាប លាន់ឮឡើងក្នុងអាកាស មុខនាងស្រស់ច្បាស់ដែលអនុស្សាវរីយ៍អាចនាំរំលត់ខ្លះនៃសេចក្តីទុក្ខលំបាកជាខ្លួនឯង ។

ស្ករគំហកនៃលោកវរសេនីយ៍ឯកពញ្ជាក់គេអំពីការស្រឡែងយ៉ាងស្រួលនេះ:

– ខែ ! លោកឮលោកអនុសេនីយ៍ទោជាអយ្យការចាស្បុខេ ! លោកជាអ្នកក្បត់សាសន៍យើង ! លោកមិនសមធ្លាជានាយទាហានតួរគីឡើយ ! ។

ដោយឮសំដីនេះ អ៊ីស្មាអ៊ីលហាក់ដូចជាភ្ញាក់ចាកការព្រងើយកន្តើយ ។ គេងើបក្បាលឡើងភ្លាម សំឡឹងគេបង្ហាយដោយអាការមើលងាយចំពោះមនុស្សគំនប៉ុន្មានដែលធ្វើមុខងារជារបាំងក្រមខ្ចីខ្ចា ហើយគេស្រែកដោយសំឡេងយ៉ាងក្រអៅ ហោញដោយការក្រអឺតក្រទងជាតិនឹងសេចក្តីស្នេហាចំពោះមាតុភូមិថា:

– ខ្ញុំមិនមែនជាតិតួរគី ! ខ្ញុំជាជាតិអាល្ប៉ាន់ !

លោកវរសេនីយ៍ឯកស្ទុះគ្រាកឡើង ។ កំហឹងធ្វើមុខលោកដែលក្រហមស្រាប់ឲ្យរំងឹតតែក្រហមលើសលប់ទៅទៀត ។ លោកមានវាចាថា:

– អ៊ីស្មាអ៊ីលបេន - អៃយ៉ាដ ! លោកខើបតែបង្ហាញឲ្យយើញនូវការណ៍ដែលត្រូវតែឃុំឃាំងលោកទុកដល់មរណភាព ។ គុណការនឹងថយចេញដើម្បីសម្រេចនូវជាតវាសនារបស់លោក ។ ម្យ៉ាងទៀតលោកត្រូវបែយ័ត្នដល់យុត្តិធម៌នៃ . . . ។

លោកនិយាយមិនទាន់ចាំងផុតសេចក្តី ស្រាប់តែសូរកាំភ្លើងធំយ៉ាងអស្ចារ្យលាន់ឮស្ទើរកេរ្តែកចាំងបន្ទាយ ។ មានគ្រាប់បែកអ៊ីតាលីមួយធ្លាក់មកលើគ្រាបន្ទាយ ។

*

* *

ពួកទាហានភ្ញាក់ក្រោកឡើងចាំងអស់គ្នា ។ តើមានរឿងហេតុដូចម្តេច? សត្រូវមកជិតដល់ហើយឬ? គ្រាបន្ទប់បើកភ្លែត មានទាយទាហានម្នាក់ដែលទៅកងមន្ទីរចាត់ការធំចូលមកដល់ ប្រាប់ដំណឹងបែកញើសជាប ។ គេឈរស្រមៃតម្រៀបដើងគ្រឹមគ្នា ហើយហុចសំបុត្រជូនទៅលោកមេទ័ពកស្បាមុត ។

លោកហ្វារេឌីនចាប់នែតាភាក់ បែកសំបុត្រដែលផ្ញើមកពីប៉ុយ៉ូចាត់ការធំជាឧត្តមសេនីយ៍ហើយមើលភ្លាម។ ។ កងសំបុត្រនោះមានសេចក្តីដូចតទៅនេះ ៖

> ចប់ទឹងក្បាលវិតនៃបច្ចាមិត្តមិនបានទេ ។
> ត្រូវនាំទ័ពចេញឲ្យរហ័ស ។
>
> វ៉ាសេនីយ៍ឯក អ៊ុស្មាន-ប៊ី

លោកមេទ័ពហុចសារឲ្យទៅនាយទាហានឯទៀត។ មើលរួចលោកបង្គាប់អ្នកនាំសំបុត្រឲ្យរំលែតឡប់ទៅវិញ ។ លោកវ៉ាសេនីយ៍ឯកហៅនាយទាហានឆើងធំអ្នកយាមគ្រាឲ្យចូលមក ហើយនិយាយប្រាប់ ចង្អុល

ចំអ៊ីស្មាអ៊ីលថា: "មនុស្សនេះឈប់ធ្វើជានាយគាហានហើយ" ក្នុងពេលនោះលោកចោចបង្ហាប់ក្បាលសេសយមាស ដែលភ្ជាប់នៅលើស្មាជាយសស័ក្តិសញ្ញា ចេញអំពីឯកសណ្ឋាន គឺជាអ្នកគោសសាម័ញ្ញ រួចថ្កាប់ឲ្យគាហានពីរនាក់នាំគេបណ្តើរចេញទៅគ្រែក្រុង បើគេចង់វាត់ឲ្យថ្មាញ់ចោលភ្លាម ។

រួចលោកមេទ័ពបែរមកចំពោះនាយគាហានចាំងឡាយ ហើយស្រែកជារបៀបវរសេន៍យ៍ឯកត្តរតីថា:

– ឥឡូវនេះ ត្រូវដក ដោះខ្លួនចេញសិនរៀងខ្លួន!

អ៊ីស្មាអ៊ីល នៅជាចន្លោះគាហានពីរនាក់ ដើរចេញពីបន្លាយ ។ ជនចាំងបីគ្រាច់ដល់ផ្លូវមួយចង្អៀត ហើយប្រទះនឹងអ្នកស្រែកកិតក៏យតក់ស្លុតរត់ច្រាត់ ។

គាំភ្លើងថ្មាញ់ រកស្តាប់អ្វីពុំឮ ។ ពួកកងគាំភ្លើងធំបច្ចាមិត្តតួនទៅខាងគ្រែយកកូនកំដិតខាង ព័ទ្ធបន្លាយកស្បែមុត ហើយថ្មាញ់រះបន្លាយនឹងមិនត្រែយើស្បូវឡូដូចលាដូនុះ ។

អ៊ីស្មាអ៊ីលធ្វើវ៉ី មិនវល់អើពើអំពីគ្រាប់គាំភ្លើងនឹងអំបែងគ្រាប់បែកដែលរត់ជិតៗខ្លួន តាមកំពែងឮប្រឹងតែដើរដោយស្ងៀមស្ងាត់នាកណ្តាលគាហានតួរតីចាំងពីរធ្វើព្រងើយ ។

គាហានពីរនាក់នេះទំដើរញាប់ដើង លុះដល់ផ្លូវបែត អ៊ីស្មាអ៊ីលភ្ញាក់ផ្អើលគ្រាយ ។ គ្រាប់បែកមួយផ្ទុះឡើង លើកគេចោលទៅលើដីចំណែកចំណែកឮទ្រឹងអាចម៍ដីខ្ចាត់ខ្ចាយឡើង ខ្មាត់ទៅឯអាកាសធ្លាក់មេឃ ។

អ្នកកំឡោះដួលស្លុកស្លឹងជាត់ស្មាតែមួយស្រមក់ ។ លុះគេត្រឡប់ដឹងខ្លួនវិញ ហើយក្រោកឡើង គេឃើញគាហានតួរតែចាំងពីរដេកច្រឡាងឥតដឹងខ្លួន ឯកសណ្ឋារហែករំយ៉ែអស់មានកាយពាសពេញដោយរបួសគួរស្ញែង ។ ខ្មោចគាហាន ផ្សែងម្សៃរពេលភ្លៅឆ្ពិល ដេកវិនឆ្ពិនហាក់ដូចជាសំឡក់មករកគេ ដោយក្អែកបើតក្រលួងឥតវិញ្ញាណ ។ នេះគឺវាសនាល្អធ្វើឲ្យគេបានរួចខ្លួន ។

អ៊ីស្មាអ៊ីលញញឹមសប្បាយតែម្នាក់ឯង ។

ឥឡូវនេះ តើវាលស់អ្វី? មិនដឹងជាស្លាប់ដោយគ្រាប់កាំភ្លើងដូចទឹកភ្លៀងត្រង់កន្លែងណា? គេចាប់ដើរតេះតេះតែដោយសេចក្តីក្លាហានឥតកំរើក ដល់ដើងទឹងដុំថ្មក្តៅឆួល ទឹងផ្ទៅង ទឹងគំនរផ្ទុះកំពុងឆេះ ។ ខ្មោចស្រី-ប្រុស កូនក្មេងដេកវង្កវែលណែលគួរឲ្យស្ញែបពេក ។ ជញ្ជាំងកំពែងរលំខ្ទេចខ្ទី ពួតែសូរសេតូចំខ្ទួញចេញមកពីក្នុងរូង ពីក្នុងផ្ទះបាក់បែក ។ សូរកាំភ្លើងធំ ឮលាន់រំពងខ្ទាំង ។ នៅក្បែរភាងផ្ទះមួយរលំ អ៊ីស្មាអ៊ីលឃើញគាហានតួរតែមួយក្រុមស្លាប់ដេកតាមធម្មតា ប្រហែលជាកំពុងស៊ីផឹកនៅលើកនហាល បានជាគេឃើញ ខ្លះកាន់ចាន ខ្លះកាន់ក្អម ខ្លះកាន់កាំបិត គាហានទាំងនោះមើលទៅហាក់ដូចជានៅរស់ ។ អ៊ីស្មាអ៊ីលខាកស្តោះជាក់ដោយសេចក្តីខ្ពើម ។ ទឹកត្រង់ទាំងមូលហាក់ដូចជាប្រព្រឹត្តទៅក្នុងភ្លើងប្រល័យកល្ប ។

ឥឡូវសូរកាំភ្លើងធំអន់ថយ មិនត្រេយ៉ើចាប់ជាញ់បន្តឡើងទៀត ។ ខណៈនោះ អ៊ីស្មាអ៊ីលគិតថា ការទំដើរតាមផ្លូវដើម្បីឲ្យដល់ទី

ក៏លាចាប់ ដែលឯកសណ្ឋានរបស់គេជាសញ្ញាដោយឡែកដល់បច្ចាមិត្រ
នេះចំណាត្រីលសោះ ។ គេកាបតួនត្រង់ដំណូលមួយ ក្បែរផ្ទះលើ យក
ដញ្ជាំងជាគ្រឿងបាំង ។ ខៅខាងគ្រោយគេ ប្រហែលពីរ-បីដំហាន
ក្បែរម្ខាងដើមគ្នោតមួយ មានអាប៉ាច់ម្នាក់ដេកស្ងាប់ខៅនោះ ។ មនុស្ស
នោះគ្មានសំពត់រុំទេ មានតែអាវខ្មៅចាប់រហែកស្មា ដែលបង្ហាញឲ្យ
ឃើញប្រហោងមួយប្រហែលត្រង់ទ្រូងគាប់គាំក្តៅ ។ អ៊ីស្មាអ៊ីលចូលខៅ
ជិតសពមិនស្គាល់នោះ ហើយសូត្រលើកគុណព្រះអល្លស់ ដើម្បី
សម្រាកនៃដួងវិញ្ញាណរបស់មនុស្សកំសត់នោះ តាមសេចក្តីគោរពច្បាប់
សម្រាប់ជាតិ ។ លុះធ្វើដូច្នោះហើយ អ៊ីស្មាអ៊ីលទឹកដល់ក្រុងកាស-
ការកូលី ។ គេទឹកឃើញផ្ទះ ឃើញទ្វារ ឬទប្រស នាងឡឺឡា
វត្តពាំងប៉ុន្មានដែលគេស្រឡាញ់ពាប់អាន ។

ខ ! ប្រសិនបើគេបានរួចរស់ជីវិត ! . . .

ប៉ុន្តែ ក៏សនាបរបស់គេខៀងតែត្រូវស្លាប់ទឹងមើម្រៃយ៉ើរបស់សាសន៍
អ៊ីរ៉ុបមិនខាន ដូចគ្នាទឹងស្លាប់ដោយគេចងព្យួរដែរ ឆ្ងាយពីសាច់ញាតិ
កណ្តាលស្រុកគេ ។

ក្នុងគេលនោះ សូរកាំភ្លើងឈប់លាន់ឮ ប្រហែលបួន-ប្រាំនាទីរួច
មកហើយ ។ ប៉ែកខាងកុំតួច ។ កាំភ្លើងធំខៅស្ងៀមឈឹង ។ កាំភ្លើង
មើម្រៃយ៉ើខៅឮសូរផ្ទុះម្តង ។, អ៊ីស្មាអ៊ីលទឹកថា កាំភ្លើងពាន់នេះបាញ់
រះទីវាលដើម្បីឲ្យត្រូវពួករបស់ ។

ឥឡូវនេះ ប្រហែលជាប៉ុន្មាននាទីមកហើយ តើជារហាសភាពដែលស្ថិតនៅលើវត្ថុបាក់បែកនឹងខ្មោចតាំងឡាយស្ងាប់ប្រតរលើគ្នា ។ នៅទីឆ្ងាយឯណោះគេផ្ទុំត្រែបញ្ចេញសព្ទសំឡេងដ៏យូរជាន់នេះ ទំនងសេចក្តីរកកាយ ។ កាំភ្លើងឈប់បាញ់ កិច្ចបំផ្លាញចំពេញរួចអស់ហើយ ។ គេឃើញត្បែកនឹងត្មាតហើរតាមលើគេហស្ថានបាក់បែកតាំងឡាយ ដោយបក់ស្ងាបរង្គើលៗស្រឡាំងស្រឡាត់ ។

ក្នុងទីស្ងាត់ជ្រងំ ស្រាប់តែសំឡេងមួយលាន់ឮឡើងក្រាមថា:

– អ៊ីស្មាអ៊ីល ! ។ ឮសូរស្រែកហៅ អ៊ីស្មាអ៊ីលសុះគ្រែកឡើងបែរសំឡឹងទ្វេងស្តាំ ស្រែកតបវិញថា: ឡីឡា ! ។ សូរសំឡេងធ្វើយកាន់គ្នា គេសុះសំដៅរក ។ – អ៊ីស្មាអ៊ីល ! ។ – ឡីឡា !

គូរកំសត់សុះទ្វេងផុះបាក់បែករៀងខ្លួន លោតរំលងខ្មោចយាងប្រញាប់ដើម្បីជួបគ្នា ។ គេបានទល់មុខគ្នាមួយរំពេច ។ ជនតាំងពីរមានសរីរកាយរឹងគគ្រាំងដោយប្រឡាក់រំសេវនឹងធូលី ប៉ុន្តែគេះមិដូច្នោះ គេកំគង់ប្រែក្លាយទៅជាសប្បាយរីករាយកើត. ព្រោះអាស្រ័យកាមតណ្ហា ។ សេចក្តីសប្បាយពេញចិត្តពេក ធ្វើឲ្យជួងហឫទ័យនៃជនតាំងពីរកំរើកស្ទើរបែក ។ គេនៅទឹងស្ងៀមមួយស្របក់មិនអាចហាមាត់និយាយថាដូចម្តេច រួចគេនាំគ្នាយំដូចកូនក្មេង ។ លុះទីបំផុតគេហៅគ្នាទៅវិញទៅមក ។ សត្វតាំងពីរសោយឥដ្ឋារម្មណ៍យ៉ាងធំរួចថាដូចម្តេចមិនកើត គ្រាន់តែហៅឈ្មោះគ្នាថា: – អ៊ីស្មាអ៊ីល ! ។

- ឡើងវ៉ា ! ។ រួចគេចាប់ទុបគ្នាទៅវិញទៅមក ។ - តែវាគួសងឬវ៉ា ! ។ - ដួងដីវិតថ្លៃប្អូន ! អូនឈប់បែកពីរូបបងហើយ ! មាត់ទឹងមាត់កំប៉ះគ្នាក្លាម . . . !

ឥឡូវនេះ សន្តិសុខដ៏ធំនៃសាយណ្ហសម័យ ចុះគ្របដណ្តប់លើកន្លែងដែនដីគ្រង់នោះ គឺជាទីដែលមនុស្សខ្ទន់ខ្ទេចជាច្រើនតែនឹងត្រលែងខ្លួនព្យុះភ្លើងទឹងព្យុះអាវុធ ឲ្យដើរពាតត្បាត ហើយទឹងធ្វើឈាមឲ្យហូរពាសពេញ ។

ប៉ុន្តែដីវិតរបស់សត្វដែលត្រូវដុះដាល មានកម្លាំងជាងវត្តុតាងពួងជាងការព្រៃលដែលនាំឲ្យវិនាស ជាងការព្យាបាទពប់សតវត្សរ៍ ដីវិតនោះឆ្លើផ្កា គឺសេចក្តីស្នេហាឲ្យពកបុចឡើងលើខ្មោចទើបនឹងស្លាប់ថ្មីៗ តាំងឡាយ ។

សេចក្តីសុខកាយសប្បាយចិត្តវិលត្រឡប់ជាក់មកបួលក្នុងបេះដូងនៃសត្វដែលមានសេចក្តីស្នេហាចំពោះគ្នាទឹងគ្នាវិញ ។

ខាងត្រកាយចម្ងាំងជាតាតរកាត អនុស្សាវរីយ៍ អាចសំដែងនូវអាការដ៏ប្រពៃ ដ៏សុខឥតចលាចលចំពោះស្រីដែលប្រកបដោយសេចក្តីស្នេហាជាមេផ្ទះ ទឹងចំពោះការគោរពដល់ទឹកដីជាកើរកោះទឹងដល់ជាតិភូមិឲ្យកើតមានក្នុងចិត្តវិញ ។

ការសង្ឃឹមដ៏ធំអស្ចារ្យបំផ្លាំងបេះដូងនៃជនតាំងពីរនាក់ ។

ឯណោះ ខាងក្រោយកុំតាំងឡាយ ព្រះអាទិត្យដូចជាថាសមាស ក្រហមផ្លែយ៉ាងសម្បើម កំពុងលិចចុះឯដើងមេឃ ។ ជនតាំងពីរ គឺ អ៊ីស្មាអ៊ីល ទើងនាងឡីឡាស្រែរឭងដោយបុណ្យវាសនាប្រកៀកគ្នាទៅ វិញទៅមកដើរសំដៅព្រះអាទិត្យអស្តង្គត ។

ចប់

អ្នកបំពើផ្ទាល់បាទគាប់

៣៤- ថាបើគេសេពគប់ព្រះរាជា, អ្នកមិនមែនប្រធានអាចទៅជាប្រធានបាន, ថាបើរៀបចង់មិនសេពគប់ព្រះរាជាហើយ សូម្បីជាប្រធានក៏ថ្ងៃស់ងារធ្លាក់ខ្លួនទៅជាមិនមែនប្រធានវិញ ។

៣៥- ព្រះឧបតីតែងរាប់រកតែមនុស្សណាដែលនៅជិតផ្ទាល់ព្រះអង្គ មិនថាអ្នកនោះជាមនុស្សល្ងង់ខ្លៅ មានស្រមូលចោកទាប ឬពុំនោះ មានខ្លួនមិនបានខ្ពង់ខ្ពស់ទេ តាមធម្មតា ព្រះរាជាក្តី ស្ត្រីកាពក្តី លតាដាតិក្តី តែងទាក់ទងព័ទ្ធពន្ធតែនឹងអ្នកណា ឬ ដើមឈើណាដែលនៅជិត ។

៣៦- សេវកមាត្យណា ពិចារណាឃើញប្បាស់ឆ្ងល់ដូចំណុចដែលតាំងឲ្យក្រោធ ឬតាំងឲ្យកែវភ្លាយទ្រុះទ័យ សេវកមាត្យនោះ អាចឡើងថ្នាក់បន្តិចម្តងៗ ជាជិតបទៅបានទ ។

៣៧- មនុស្សមានវិជ្ជា មនុស្សប្រាជ្ញាធំ មនុស្សមានសិល្បសាស្ត្រ មនុស្សមានសេចក្តីក្លាហាន ទើងមនុស្សបេះប្រព្រឹត្តខ្លួនជាសេវកមាត្យទាំងអស់នេះ មិនមានទីពឹងអ្នកណាក្រៅអំពីព្រះរាជាទេ ។

បញ្ចតន្ត្រៈ

រឿងព្រេងនិទាន

លោកសមិទ្ធ ម្ចាស់ជីវិតតែង

លោករ៉ាយ-ប៊ុក ក្រមការដើមខ្សែប្រៃរៀបរៀង

(តមក)

និទានទីរូបទេពធិម្មិតទី ១៨

មានកាលមួយថ្ងៃ មហាក្សត្រកោដៈខ្ចីនស្តេចយាងមកដល់ព្រះបល្ល័ង្កទិព្វ ដើម្បីនឹងឲ្យគេអភិសេកព្រះអង្គ ស្រាប់តែរូបទេពធិម្មិតទី ១៨ មានទេវភាសាថា:

"ដើម្បីនឹងឲ្យមានសមត្ថភាពគង់លើព្រះបល្ល័ង្កទិព្វនេះបាន, ព្រះមហាក្សត្រិយត្រូវឲ្យមានព្រះគុណសម្បត្តិ គឺពលភាព, សប្បុរសធម៌ ។ល។ ទូលព្រះបង្គំនឹងក្រាបទូលខ្ចីន ដូចតទៅនេះ:

"មានកាលមួយថ្ងៃ, មហាក្សត្រិយមាតិត្យខ្ចីនគង់លើរាជបល្ល័ង្ក, នាយទ្វារបាលបានចូលមកធ្វើអញ្ជលិកម្មថ្វាយដំណឹងព្រះអង្គថា សូមខ្ចីនព្រះមេត្តាប្រោស, ទូលព្រះបង្គំទើបនឹងបានស្តាប់រឿងមួយប្លែកអស្ចារ្យ, រឿងនោះដូច្នេះ: នៅលើកំពូលភ្នំ:មានបូជនីយដ្ឋានមួយរបស់នាងទេវធីតាមួយអង្គ ។ នៅចំមុខបូជនីយដ្ឋាននោះ មានចឹងមួយដែលទូលព្រះបង្គំធ្លាប់ឃើញ ចឹងនោះមានជណ្តើរមាសក្បឿងព្រាងព្រាយ, មានដាំត្បូង, តជ្រុងនីមួយៗ ។ នៅពាក់កណ្តាលចឹងនោះ មានសសរមាស,

ហើយនៅលើសសរនោះ មានបល្ល័ង្កមាសមួយដាំត្បូង ។ គាំងពីបច្ចូសសម័យរហូតដល់ថ្ងៃត្រង់, សសរនោះកំឡើងបន្តិចម្តង ។ ស្តុយបល្ល័ង្កមាសខ្ពស់ឡើង ។ ទៅបះព្រះអាទិត្យ; គាំងពីថ្ងៃត្រង់រហូតដល់សាយណ្ហសម័យ សសរនោះក៏ស្រុតចាបចុះមក ។ រហូតមកស្ថិតនៅកណ្តាលបឹងដូចដើម ។ សសរនេះ មានសភាពប្លែកដូច្នេះពាល់តែថ្ងៃ ។

ព្រះបាទវិក្រមាទិត្យដល់ទ្រង់ព្រះសណ្តាប់នាយទ្វារបាលគ្រាបទូលរឿងនេះហើយ ទ្រង់មានព្រះពជបំណងចង់ទតរបស់ប្លែកនោះពន់ពេក, ទ្រង់ក៏ហោះទៅលើអាកាសដោយព្រះសុពណ៌បាទប្រកបដោយរំខ្ន, រួចទ្រង់ស្តេចយាងចុះទៅលើមាត់បឹង ។ ដល់ព្រះអារុណោះ, សសរនោះផុះលេចតិចតួចឡើងទៅឯអាកាស ។ ក្នុងពេលនោះ ព្រះបាទវិក្រមាទិត្យទ្រង់ឡើងគង់លើបល្ល័ង្កមាសនោះ ដែលកំពុងតែអណ្តែតឡើងទៅលើអាកាសជាមួយនឹងសសរហូតទៅដល់ជិតព្រះអាទិត្យ ។ ដោយត្រូវកំដៅព្រះសុរិយាយ៉ាងខ្លាំង ទ្រង់ក៏ដូចជាគេផ្តើរសន្ធប់បាត់វិញ្ញាណ ។ ព្រះអាទិទេពសុរិយា ទ្រង់ទតទៅឃើញនូវរឿងរ៉ាវនៃព្រះបាទវិក្រមាទិត្យទ្រង់សព្វព្រះពជប្លែកៗយពន់ពេក, ទ្រង់ក៏យកទឹកអម្រឹតមកស្រោចលើព្រះកាយព្រះបាទវិក្រមាទិត្យ ។ ទ្រង់ភ្ញាក់ឡើងដឹងព្រះស្មារតីមាំមួន, ទ្រង់ក៏វន្ទាថ្វាយបង្គំព្រះអាទិទេពសុរិយា, រួចទ្រង់សូត្រថ្វាយពរដោយមង្គលគ្រប់ប្រការ ។ ព្រះអាទិទេពសុរិយាទ្រង់សព្វព្រះពជប្លែកៗយនឹងព្រះបរិត្តដែលព្រះបាទវិក្រមាទិត្យទ្រង់សូត្រថ្វាយនោះ, ទ្រង់ក៏ព្រះពជគាទនំហូមាសមួយទម្ងន់ ១ ការៈ ។ ដល់ទ្រង់បានទំហូមាសពីព្រះអាទិទេពសុរិយា

ហើយ, ខ្ញុំក៏ហោះទៅលើអាកាស ដោយព្រះសុពណ៌ិចាទមានឫទ្ធិ ហើយក៏ខ្ញុំវិលកាន់ព្រះពជ្ឈាធីវិញ ។ កន្លងយ:ពាក់កណ្តាលផ្លូវ នៃព្រះពជ្ឈដំណើរ ខ្ញុំបានជួបប្រទះនឹងបុរសទុគ៌តម្នាក់, ខ្ញុំមានព្រះពជ្ឈហ្ឫទ័យអាណិតអាសូរពន់ពេក, ខ្ញុំក៏ព្រះពជ្ឈានឲ្យរំហូរមាសនោះទៅបុរសនោះ" ។

ដល់ចាន់ក្រាបបង្គំទូលនូវរឿងក៏វានេះចប់សព្វគ្រប់ចំពោះព្រះចាន់កោដ: រួចទេពនិម្មិតទី ១៨ ក៏ទូលបន្ថែមថា: "ឧព្រះចាន់កោដ:, បើខ្ញុំមានវិជ្ជាឫកាពដូចព្រះចាន់វិក្រមាទិត្យនេះ, ខ្ញុំទើបអាចគង់លើបល្ល័ង្កទិព្វនេះបាន ។

ព្រះចាន់កោដ: ខ្ញុំព្រះតម្រិះថា ខ្ញុំមិនមានវិជ្ជានុភាពដែលនេះទេ, ខ្ញុំក៏អាក់ខានមិនចានទទួលភាក់សេកថ្ងៃនោះ ហើយខ្ញុំស្តេចចេញពីទីនោះទៅ ។

* * *

ទិដ្ឋានទៀរួបទេពនិម្មិតទី ១៩

ព្រះចាន់កោដ: ខ្ញុំស្តេចយាងមកដល់បល្ល័ង្កទិព្វនោះ ដើម្បីនឹងឲ្យគេធ្វើមុខភាក់សេក, រួបទេពនិម្មិតទី ១៩ មានទេវរាជាថា: "ឧមហាពជ្ឈកោដ: ខ្ញុំមិនអាចគង់នៅលើបល្ល័ង្កទិព្វនេះបានឡើយ, មហាពជ្ឈដែលខ្ញុំមានសមត្ថភាពអាចគង់បាន គឺ ព្រះចាន់វិក្រមាទិត្យ, សូមខ្ញុំព្រះសណ្តាប់នូវរឿងដូចតទៅនេះ:

"មានកាលមួយថ្ងៃ, ព្រះបាទវិក្រមាទិត្យទ្រង់មានព្រះពាដចំណង ចង់ជ្រាបអំពីកិច្ចការប្រជាពស្ត្រាបស់ព្រះអង្គដែលធ្វើសព្វថ្ងៃ ។ ទ្រង់ ក្រោកព្រះបូបហើយ ទ្រង់ហោះទៅលើអាកាសដោយរិទ្ធីព្រះសុពណ៌ាបាទ ធ្វើព្រះពាដដំណើរគ្រប់វិធីគ្រប់ជ្រុង ទ្រង់ស្តេចទៅដល់ទីក្រុងមួយឈ្មោះ បទ្មាល័យ (Padmālaya) ។ ទៅទីនោះ ទ្រង់បានឧត្តទៅឃើញបូជនិយដ្ឋានមួយប្លែក ។ មានពួកព្រហ្មចារីនិយាយរឿងទៅវិញទៅមក ។ មានព្រហ្មចារីម្នាក់ពោលថា: "ខ្ញុំបានទៅដល់ប្រទេសមួយ ខ្ញុំបានឃើញឧទ្ទេសដ៏ក្តុដែលមានទៅតាជាច្រើនមកពីប្រទេសផ្សេង ។ មានប្រជុំទៅទីនោះ ។ មានក្តុមួយនោះឈ្មោះ កនកក្រិត (Kanakakrita), គេមិនអាចទៅដល់បានដោយងាយទេ ព្រោះបើអ្នកណាហ៊ានទៅហើយ មុខជាទីឆ្ងល់ជាវិតក្កដ៏ពេលនោះ ។ ហេតុនេះ បានជាខ្ញុំគេចមិនចង់ទៅទីនោះឡើយ ព្រោះថាស្ត្រីក្មេង គោគទ្រព្យទីឆ្ងល់សម្បត្តិឯទៀត ដែលរកបានមកដោយសេចក្តីព្យាយាមហើយធ្វើឲ្យបាត់បង់ទៅវិញ គេអាចផ្គាស់ប្តូរបាន; តែចំពោះរូបកាយបើស្លាប់បាត់បង់ហើយ, បើទុកជាព្យាយាមម៉ឺងម៉ាត់យ៉ាងណាក៏ដោយ ក៏មិនអាចយករូបនោះមកវិញបានឡើយ ។ ហេតុនេះ, សុក្រិតភាព ឬ ជោគជ័យ គឺត្រូវរក្សារូបនោះឲ្យបានស្ថិតស្ថេរតទៅអនាគត" ។

ព្រះមហាសត្វទ្រង់បានជ្រាបខ្លួវាក្យយោគដែលថ្លែង, ទ្រង់មានព្រះបន្ទូលចំពោះព្រះអង្គឯងថា: "ចំពោះមនុស្សដែលមានឋានភាពដ៏ឧត្តម មិនត្រូវមានសកម្មភាពដែលលំបាកធ្វើមិនបាននោះទេ;

ចំពោះបុគ្គលដែលមានចរិយាពាក្យយាម សម្រែចទៅតាមបទបញ្ញត្តិគម្ពីរ
នីតិសាស្ត្រ គ្មានអ្វីដែលលំបាកនឹងប្រព្រឹត្តប្រតិបត្តិសោះឡើយ; ចំពោះ
បណ្ឌិត, មាតុភូមិឬបរទេសក៏ដូចជាប្រទេសរបស់ខ្លួន; មនុស្សណា
ដែលពោលវាចាល្អឬពាក្យផ្អែមល្ហែម, មនុស្សនោះមិនមានបច្ចាមិត្រ" ។
ក្រោយដែលខ្ញុំមានព្រះបន្ទូលរួចហើយ, ព្រះមហាក្សត្រិយ៍ខ្ញុំក៏ចាន
ហោះទៅលើអាកាសដោយព្រះសុពណ៌ចាដ៏មានរិទ្ធ, ខ្ញុំស្តេចយាង
ទៅដល់រោងគីដែលស្ថិតនៅក្នុងកក្រើត រួចខ្ញុំប្រថាប់នៅទីនោះ ។

យោគីក្រឡេកឃើញព្រះមហាក្សត្រិយ៍ក្រាបបង្គំទូលថា: "ឧ
មហាភជវិក្រមាទិត្យ, សូមខ្ញុំព្រះមេត្តាជ្រាស, ហេតុម្តេចក៏ខ្ញុំ
ស្តេចយាងមកកាន់ទីនេះ ? ។ មហាភជខ្ញុំមានព្រះបន្ទូលតបថា:
"យើងមកសួរអ្នកឯង" ។ ក្នុងមួយរំពេចនោះ, យោគីជ្រាបច្បាស់ថា
មហាភជវិក្រមាទិត្យ ខ្ញុំមានព្រះរូបល្អ ដ៏ឧត្តមជាងមហាភជទាំងឡាយ
ហើយខ្ញុំមានព្រះភជហ្ស័យល្អលើសលប់, ក៏ចាន់ថាយទូវត្ថុតិសិដ្ឋ
បីយ៉ាងហៅថា កន្ថា (Kanthâ) ១, ខន្ធិកា (Khandikâ) ១, ទន្ឌ: (Danda)
១, ហើយក៏ចាន់ក្រាបបង្គំទូលខ្ញុំអំពីគុណសម្បត្តិនៃវត្ថុទាំងបីនោះ :

"សូមខ្ញុំព្រះមេត្តាជ្រាស, អំពីគុណសម្បត្តិនៃវត្ថុកន្ថា, បើខ្ញុំ
ព្រះតម្រែកក្នុងព្រះភជហ័យចង់ចាន់ចេញសម្បត្តិ, គ្រឿងអលង្ការ, ស្នាប់
ព្រះជង្ឃដ ឬព្រះកូសា ។ ល ។ ខ្ញុំគ្រាន់តែយកព្រះហស្តទ្វេងាល់កន្ថា
នោះ, វត្ថុអ្វីដែលខ្ញុំព្រះតម្រែចង់ចាន់ក៏ខ្ញុំចេញមកឯង។ ពីកន្ថានោះ ។
ចំណែកវត្ថុដែលហៅថាខន្ធិកា, ក៏មានចេញនូវចំនួនដ៏វែ, សេះ, រទេះ,

ភាហានថ្មើរដើន ។ ល ។ តាមចំនួនដែលព្រះអង្គទ្រង់សរសេរជាលាយលក្ខអក្សរ ។ ឯវត្ថុទន្ទេះ, ព្រះអង្គគ្រាន់តែយកព្រះហស្តស្តាំពាល់ហើយ, ក្នុងពេលនោះ បើមនុស្សស្លាប់ក៏ប្រែទៅជាមានជីវិតឡើងវិញ ។ វត្តចាំងបីយ៉ាងនេះ ដែលខ្ញុំព្រះបង្គំជាខ្ញុំបានដោយកំឡាំងព្យាយាម, ខ្ញុំព្រះបង្គំជាខ្ញុំ សូមថ្វាយចំពោះព្រះអង្គ ព្រោះខ្ញុំព្រះបង្គំយល់ថាព្រះអង្គទ្រង់មានព្រះពាជបរិយាណ្ឌមារក្សាវត្តុនេះបាន ។

ព្រះបាទវិក្រមាទិត្យ ទ្រង់បានវត្តុដ៏ប្រសើរចាំងបីដោយសេចក្តីអនុគ្រោះយោគី, ទ្រង់ក៏ធ្វើប្រទក្សិណ រួចទ្រង់ស្តេចហោះទៅលើអាកាសដោយព្រះសុពណ៌បាទមានរ័ទ្ធ, ហើយក៏វិលត្រឡប់ទៅកាន់ពាជធានីវិញ ។

នៅតាមរយៈផ្លូវនៃព្រះពាជដំណើរ ព្រះបាទវិក្រមាទិត្យ ទ្រង់បានឃើញទុគ្គមបុរសម្នាក់វង្វេងនៅកន្លែងព្រៃហើយ កំពុងមានទុក្ខជាខ្លាំង ទ្រង់ក៏មានព្រះបន្ទូលសួរទៅទុគ្គមបុរសនោះថា: “នុបុរស, ហេតុម្តេចក៏អ្នកឯងវង្វេងនៅកន្លែងព្រៃនេះ? ”

(មានត)

មុនិយាយគិតសិន

៣៣- ក្នុងកាលណា បុគ្គលហាមាត់និយាយទៅហើយថានផល ចិតថេរយ្យ ផ្ទុចជាពណ៌ជាប់ឮផសំពត់សន្លឹកោះ ក្នុងកាលណោះ បុគ្គលគប្បីហាមាត់និយាយចុះ ។

បញ្ចតន្ត្រៈ

ដំណឹងព្រះអនិច្ចធម្ម

នៃសម្តេចព្រះសុធម្មាធិបតី ពុទ្ធសាគោ អ៊ុង-ស្រ៊ី

ព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ

ក្នុងកម្ពុជវដ្ត

លោក ប៊ូ-ប៊ូ រៀបរៀង

សម្តេចព្រះសុធម្មាធិបតី ប្រឈួនពីថ្ងៃ ៤ ½ ១ ឆ្នាំមមែសប្តស័ក ព.ស. ២៤៨៨ (២៣ វិច្ឆិកា ១៩៤៤) ចំនួន ២ ខែ ៧ ថ្ងៃ ឋានទទួលព្រះអនិច្ចធម្មនៅថ្ងៃ ១ ½ ៣ ឆ្នាំមមែសប្តស័ក ព. ស. ២៤៨៨ (២៩-៣០ មករា ១៩៤៦) វេលាម៉ោង ៥ ទំនឹង ២០ នាទី ជិតភ្លឺ ក្នុងព្រះជន្មគរប់ ៨៥ ឆ្នាំ វស្សា ៦២ នៅទីកុដិរបស់សម្តេច នាវត្តប៉ុមតែ ។ ឯពិធីបូជាព្រះសពនោះ មិនទាន់កំណត់ពេលនៅឡើយ ។

ព្រះគុណជាអម្ចាស់ដ៏វិសេសលើសួង ទ្រង់សព្វព្រះរាជហឫទ័យតាំងព្រះពុទ្ធាចារ្យ កុល - ខេស ជាគណៈទី ១ ព្រះជន្ម ៦៥ ឆ្នាំ វស្សា ៤៥ ជាព្រះសង្ឃនាយកស្តាំ ទំពំទឹងទ្រង់តាំងជាព្រះសង្ឃនាយកពេញទី តេជ ។ ទ្រង់តាំងព្រះមង្គលទេពាចារ្យ កែប - ភួង ជាគណៈទី ១ ព្រះជន្ម ៧៧ ឆ្នាំ វស្សា ៥៧ ជាសម្តេចព្រះមង្គលទេពាចារ្យ ឧត្តមប្រឹក្សាខាងគណៈធម្មយុត្តិកនិកាយ ។

ប្រវត្តិរូបសង្ខេបនៃសម្តេចព្រះសុធម្មាធិបតី[1]

សម្តេច សម្ភពនៅថ្ងៃ ៩ ១៣ ១ ឆ្នាំមមែ ត្រីស័ក ព.ស. ២៤១៣ គ.ស. ១៨៧០ នៅភូមិស្វាយ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មាតានាម ណៃ បិតានាម អ៊ុន ។

– ព្រះជន្ម ១២ ឆ្នាំ បិតាអនិច្ចកម្មចោលទៅ សម្តេចនៅក្នុងសំណាក់មាតា ។

– ព្រះជន្ម ១៣ ឆ្នាំ ចាប់ផ្តើមសិក្សាអក្សរសាស្ត្រខ្មែរ នៅក្នុងសំណាក់លោកគ្រូ ឃួន ចៅអធិការវត្តស្វាយ គណៈមហានិកាយ នៅស្រុកកំណើត លុះរៀនបេះចាំឈ្មមប្រែការបានហើយក៏លាលោកគ្រូវិលទៅនៅផ្ទះជាមួយមាតាវិញ ។

ព្រះជន្ម ១៤ ឆ្នាំ ឃានបួលបួសជាសាមណេរ ក្នុងសំណាក់លោកគ្រូ ឃួន ជាបព្វជ្ជាចារ្យ នៅវត្តស្វាយដែលបានផ្ទាស់មកជាវត្តគណៈធម្មយុត្តិវិញ បួសនៅឆ្នាំទ្វីឯកស័ក ព.ស. ២៤៣២ គ.ស. ១៨៨៩ ។ បួសបាន ១ វស្សាលាចាកសិក្ខាបទហើយវិលទៅនៅផ្ទះជាមួយមាតាវិញ ។

– ព្រះជន្ម ២២ ឆ្នាំ បានបួលឧបសម្បទាជាភិក្ខុការ: ក្នុងសំណាក់នៃសម្តេចព្រះសុគន្ធាធិបតី បញ្ញាសីលោ ជ័ន ជាព្រះឧបជ្ឈាយ៍, សម្តេចព្រះមង្គលទេពាចារ្យ ភូគោតម អៀម កាលនៅជាព្រះមហាព្រហ្មមុនី ជាកម្មវាចាចារ្យ, លោកគ្រូ ជៀង ចៅអធិការវត្តត្រែកឫស្សី ជាអនុសាវនាចារ្យ មានគណៈសង្ឃ ២០ អង្គគង់ហត្ថបាស បានឆាយថា "ពុទ្ធនាគោ" សម្រេចញត្តិចតុត្ថកម្មវាចា ក្នុងសីមាវត្ត

---

១ ស្រង់ពីសំណុំរឿងរបស់ក្រសួងធម្មការ ។

បទុមវតី នៅថ្ងៃ ๙ ๙ ๖ ឆ្នាំម្សាញ់ចត្វាស័ក ព.ស. ๒๔๓๙ គ.ស. ๑๘๙๓ លុះស្រែចកិច្ចនេះហើយទិមន្តទៅគង់នៅវត្តស្វាយវិញ ចាប់ផ្តើមសិក្សាព្រះវិន័យជាតិជាតាំងអំពីវស្សាជាដំបូង ក្នុងសំណាក់លោកគ្រូអាចារ្យ ពៅ កេទគ្រហស្ថ ។

- ព្រះជន្ម ๒๙ ឆ្នាំ វស្សាបាន ๘ ទិមន្តចេញពីវត្តស្វាយមកគង់នៅវត្តបទុមវតី ក្នុងសំណាក់ព្រះគ្រូវិន័យធរ ខុត នៅឆ្នាំមមែសប្តស័ក ព.ស. ๒๔๓๘ គ.ស. ๑๘๙๕ ហើយចាប់សិក្សាព្រះវិន័យតមកទៀត ក្នុងសំណាក់លោកគ្រូអាចារ្យ ពៅ, ថែន, ជួរ, ណុប, កែវ, ជាកេទគ្រហស្ថ ។ ក្នុងពេលកំពុងតែរៀននេះ សម្តេចបានឈ្វេតបន្ទៀនព្រះវិន័យជាតិជាដល់កូនសិស្សជាច្រើនរូប រហូតអស់រៀល ๓๐ ឆ្នាំទើបឈប់ផ្ទាក ។

អំពីសមណៈសក្តិផែសម្តេច

ទី ๑ - ព្រះគ្រូវិន័យធម្ម ទីហានា ក្នុងព្រះជន្មគំរប់ ๔๐ ឆ្នាំ វស្សាបាន ๑๘ នៅថ្ងៃ ๙ ๙ ๖ ឆ្នាំចសស័ក ព.ស. ๒๔๙๓ គ.ស. ๑๙๑๐ ។

ទី ๒ - ព្រះធម្មវត្តម ទីភជាគណៈ ក្នុងព្រះជន្មគំរប់ ๔๓ ឆ្នាំ វស្សាបាន ๒๑ នៅថ្ងៃ ๑ ๙ ๖ ๑๒ ឆ្នាំច្រលាញស័ក ព.ស. ๒๔๙๖ (១ យូវ៉ាំង គ.ស. ๑๙๑๓) ។

ទី ๓ - ព្រះធម្មវិរិយត្រិណ ទីភជាគណៈ ក្នុងព្រះជន្មគំរប់ ๗๐ ឆ្នាំ វស្សាបាន ๔๘ នៅថ្ងៃ ๖ ๙ ๑๒ ឆ្នាំកេងសស័ក (១ វិច្ឆិកាមេ គ.ស. ๑๙๔๐) ។

ទី៤ - ស្តីទីព្រះសង្ឃនាយក ក្នុងព្រះជន្មគំរប់ ៧២ ឆ្នាំ វស្សាបាន ៥០ នៅថ្ងៃ ៥ ៦ ឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៥ (៣០ ខែមេសា គ.ស. ១៩៤២) ។ ជាដំណាលសម្តេចព្រះមង្គលទេពាចារ្យ សុក ដែលទទួលព្រះអនិច្ចធម្មនៅថ្ងៃទៃ ឆ្នាំខាងលើនេះ ។

ទី៥ - សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃនាយកទី៤ ក្នុងព្រះជន្មគំរប់ ៧៣ ឆ្នាំ វស្សាបាន ៥៣ នៅថ្ងៃ ៧ ៧ ឆ្នាំមមែបញ្ចស័ក ព.ស. ២៤៨៦ (១៩ ខែមិថុនា គ.ស. ១៩៤៣) ។

អំពីគ្រឿងឥស្សរិយយសនៃសម្តេច

ទី១ - ធិបឌិន ក្នុងឋានៈជាសម្តេចព្រះសង្ឃនាយក នៅថ្ងៃ ២ ៧ ៣ ឆ្នាំវកឆស័ក ព.ស. ២៤៨៧ គ.ស. ១៩៤៤ ។

ទី២ - ម៉ែជាយមាស នៅថ្ងៃ ១ ៥ ៦ ឆ្នាំរកាសប្តស័ក ព.ស. ២៤៨៨ (១៥ ខែមេសា គ.ស. ១៩៤៥) ។

(នៅមានគ្រឿងឥស្សរិយយសជាច្រើនទៀត តែពុំបានបញ្ជាក់ក្នុងទីនេះ)

អំពីកិច្ចការជាស្នាព្រះហស្តនៃសម្តេច

ក្នុងសម័យនៃសម្តេច បានកសាងជាវត្តជាច្រើនដូចតទៅនេះ ៖

១ - ទីប៉ាធ ព.ស. ២៤៨៩ គ.ស. ១៩៤៦ ។

២ - សាលាសម្រាប់ទទួលភ្ញៀវ ២ ខ្នង នៅជិតប៉ាធ ព.ស. ២៤៩២ គ.ស. ១៩៤៩ និងបានធ្វើចិញ្ចើមថ្នល់នៅមុខវត្តផង ។

៣ - សាលាកេសជ្ជៈ ១ ខ្នង ជិតទីប៉ាធ ព.ស. ២៤៩៣ គ.ស. ១៩៥០

៤ - សាលាចំណា ១ ខ្នង ព.ស. ២៤៩២ គ.ស. ១៩៤៩ ។

៥ - សាលាបរិយត្តិធម្មវិន័យ ១ ខ្នង ព.ស. ២៤៩៥ គ.ស. ១៩៥២

៦ - បង្កើតឱ្យមានក្រុមអភិបាលវត្ត ព.ស. ២៤៩៧ គ.ស. ១៩៥៤

៧ - ធ្វើកំពែងខាងលិចទិសខាងជើងវត្ត ព្រមទាំងខ្លោងទ្វារខាងលិចផង ព.ស. ២៤៩៨ គ.ស. ១៩៥៥ ។

៨ - ជួសជុលកំពែងព្រះពោធិព្រឹក្ស ព.ស. ២៤៩៣ គ.ស. ១៩៥០ ។

៩ - រុះរើរោងជួនធ្វើជាថ្មីខៅកន្លែងចាស់ជាដែល ព.ស. ២៤៩៨ គ.ស. ១៩៥៥ ។

១០ - ធ្វើជណ្តើរខាងដើម ទីធ្លាខាងត្បូងព្រះវិហារ ១ គូទៀតក្នុង ព.ស. ២៤៩៨ គ.ស. ១៩៥៥ ។

ចាវវត្តទាំងអម្បាលនេះ អ្នកឧកញ៉ាមហាមន្ត្រី ញឹក-នូវ ជាអ្នកខ្វល់ការៈចាត់ការគ្រប់ចំពូក ក្រោមអធិបតីភាពនៃសម្តេច ។

១១ - សម្តេចបានកសាងប្រាង្គណ ១ នៅវត្តស្វាយ នាស្រុកកំណើត ព.ស. ២៤៩៨ គ.ស. ១៩៥៥ ។

អំពីប្រឈួន ធំង ទទួលព្រះអធិប្បាធម្ម

សម្តេចព្រះសុធម្មាធិបតី ភុទ្ធនាគោ អ៊ុង-ស្រី ព្រះសង្ឃនាយកទី ៤ នៃគណៈធម្មយុត្តិកនិកាយ ក្នុងកម្ពុជរដ្ឋ បានទទួលឋានៈជាព្រះសង្ឃនាយកតាំងពីព្រះជន្ម ៧៣ ឆ្នាំ រហូតដល់ព្រះជន្ម ៨៥ ឆ្នាំ រសាប់បានខ ៦២ រួមត្រូវជា ១៣ ឆ្នាំ ។

សម្តេចពាប់ប្រឈួនបន្តិច ។ តាំងពីថ្ងៃ ៤ ឹ ១ ឆ្នាំមមែសប្តស័ក ព. ស. ២៤៨៨ (២៣ វិច្ឆិកា ៥៥) រួមរៀលប្រឈួន ២ ខែ ១៨ ថ្ងៃ ជានទ្ធួលព្រះអនិច្ចធម្ម នៅ ១ ។ ៣ ឆ្នាំជវែល ដោយព្រះរោគជក នៅវេលាម៉ោង ៥ ទី ២០ នាទីឯក្តី (២៩-៣០ មករា ៥៦) ក្នុងព្រះជន្មាយុ ៨៥ ឆ្នាំ វស្សាជាន ៦២ ។

ពិធីបូជាយព្រះសុគន្ធភារី[1]

នៅថ្ងៃទី ៣០ មករា ១៩៥៦ ព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី នរិន្ទសម្តេចព្រះនរបយុវរាជ ដែលមានសម្តេចចៅហ្វាំងវរៈវៀងជ័យ អធិបតីស្រីគ្នាវ ប៉ែន - ន្ទុត, ឯកឧត្តមឡេង - ង៉ែត ឯកឧត្តមយឹម - ឥត, ឯកឧត្តមសម - សារី ឯកឧត្តមប្រាក់ - ប្រាជ្ញឿន ជាសមាជិកឧត្តមប្រឹក្សានៃព្រះមហាក្សត្រិយ៍ ព្រមទាំងភរិយាជាច្រើនរូបហែហមអមព្រះអង្គផង ស្តេចយាងទៅកាន់វត្តបទុមវតី នៅវេលាម៉ោង ១៧ រសៀល ដើម្បីបូជាយព្រះសុគន្ធភារី ចំពោះព្រះសពនៃសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិ ដែលទទួលព្រះអនិច្ចធម្មកាលពីយប់ថ្ងៃទី ២៨ នៅថ្ងៃទី ៣០ មករានេះ វេលាម៉ោង ៩,២០ នាទីទៀបភ្លឺ ក្នុងព្រះជន្មាយុគំរប់ ៨៥ ព្រះវស្សា ។

នៅវិត្តបទុមវតី មុនដែលព្រះមហាក្សត្រិយានីតាំងព័ទ្ធព្រះអង្គ នរិន្ទសម្តេចព្រះនរបយុវរាជស្តេចយាងទៅដល់ យើងសង្កេតឃើញសមាជិកនៃពលរដ្ឋាភិបាល ដែលមានឯកឧត្តមអ៊ុំ - ឈាង ស៊ុន ជានាយក, ឯកឧត្តម

---

១ ស្រង់ពីសារពត៌មានកម្ពុជា លេខទី ៣០៨៣ ចុះថ្ងៃពុធ ទី ១ កុម្ភៈ ១៩៥៦ ។

ប្រធានវដ្ដសកា, ឯកទុតូមប្រធានក្រុមប្រឹក្សាព្រះពជអាណាចក្រនឹង
សមាជិកខ្លះនៃសភាតំណាងរាស្ត្រ អង្គទូតប្រចាំនៅប្រទេសកម្ពុជា នឹងនាម៉ឺន
សព្វមុខមន្ត្រីនៅក្រសួងផ្សេងៗ ក្នុងរាជធានី ចានឈរតង់តាំថ្វាយបង្គំ
គោរពព្រះពជាតំណាងព្រះអង្គនៅមុខសាលាបុណ្យ ដាក់ព្រះសព ។

នៅក្នុងសាលាជិតព្រះសព មានសម្តេចព្រះមហាសុមេធាធិបតី
សង្ឃនាយកគណៈមហានិកាយ វត្តឧណ្ណាលោម, សម្តេចព្រះធម្មលិខិត
វត្តលង្កា, ព្រះពោធិវង្ស ហួត-តាត នឹងពជាគណៈ ហានាទុក្រម ជា
ច្រើនអង្គ គង់នៅកែ្សព្រះសព ព្រមទាំងមានពួកពុទ្ធបរិស័ទអង្គុយគោរព
ព្រះសពនៅទីនោះផង ។

នៅម៉ោង ១៧ ព្រះមហាក្សត្រិយ៍តំាងពីព្រះអង្គស្តេចយាងទៅដល់
ហើយគ្រាយដែលព្រះពជាគោរពភ្ងេងជាតិ នឹងទទួលការវាយកិច្ចពីវរជន
រួចហើយ ស្តេចយាងចូលទៅកាន់ទីដាក់ព្រះសព មុនដំបូងព្រះអង្គ
ថ្វាយបង្គំព្រះសព, ថ្វាយបង្គំព្រះសង្ឃនឹងព្រះពុទ្ធបដិមាករ ដែលដាក់
កែ្សព្រះសពនោះ ។ បន្ទាប់ពីនោះភ្លាម អ្នកទុកញ៉ាមហាមន្ត្រីញឹក-ខូ
ចានហ្វាងពិធីការក្នុងព្រះបរមពជវាំង ថ្វាយព្រះសុគន្ធភ័ំពោះព្រះមហា-
ក្សត្រិយ៍ ព្រះអង្គយកព្រះសុគន្ធភ័ំនេះប្រស់ព្រំលើព្រះសពនៃសម្តេច
ព្រះសុធម្មាធិបតី សង្ឃនាយក, នៅពេលជាមួយនេះ ក្រុមចារគូដ្ឋសង្ឃ
ភ្លេងវៃគ្រឿងភ្លេងខ្លួនឆ្លាក់បន្ទប់មរណសញ្ញា គួរឲ្យសង្វេគដល់សង្វាមិន
ខៀងគ្រប់ៗគ្នា ។

ការថ្វាយព្រះសុគន្ធភ័ំនេះ ចានធ្វើជាបន្ទាប់ៗមក គឺសម្តេចព្រះ

មហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ, ក្រុមព្រះពន្ធវង្សានុវង្ស, សម្តេចចៅហ្វាំងវរៈវឿងជ័យ អធិបតីស្រឹង្គារ, សមាជិកទុតិយក្រុមប្រឹក្សាព្រះមហាក្សត្រិយ៍, ប្រធានវេជ្ជសភា, ប្រធានក្រុមប្រឹក្សាព្រះពុទ្ធគណាចក្រ, នាយករដ្ឋមន្ត្រី, សមាជិកពុទ្ធជាតិបាល រហូតដល់អង្គទូតប្រចាំនៅប្រទេសកម្ពុជាតៗ មកជាលំដាប់ ។ លុះចប់ហើយ ព្រះមហាក្សត្រិយ៍តាំងពីព្រះអង្គទ្រង់គោរពព្រះសព ស្តេចយាងវិលត្រឡប់ទៅគាន់ព្រះបរមពុទ្ធកំនប់វិញ ដែលមានព្រះពុទ្ធបរិពារហែហម ដូចកាលស្តេចយាងទៅ ។

ពិធីតែងតាំងព្រះសង្ឃនាយកគណៈធម្មយុត្តិស្តីទី ក្រោមអធិបតីភាពនៃសម្តេចចៅហ្វាំងវរៈវឿងជ័យអធិបតីស្រឹង្គារ ប៉ែន - នុត ជាព្រះរាជដំណាង (១)

កាលពីព្រឹកថ្ងៃទី ៣១ មករា ១៩៥៦ មានធ្វើពិធីតែងតាំងព្រះសង្ឃនាយកគណៈធម្មយុត្តិស្តីទី ជំនួសសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិ ដែលទទួលព្រះអនិច្ចធម្មកាលពីយប់ថ្ងៃទី ២៩ ទៅថ្ងៃ ៣០ មករា ១៩៥៦ វេលាម៉ោង ៩ ទឹង ២០ នាទី ទៀបភ្លឺ, ក្រោមអធិបតីភាពនៃសម្តេចចៅហ្វាំងវរៈវឿងជ័យអធិបតីស្រឹង្គារ ប៉ែន - នុត ជាព្រះរាជតំណាងនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ ទៅពេលដែលសម្តេចចៅហ្វាំងវរៈវឿងជ័យអធិបតីស្រឹង្គារ ព្រះរាជតំណាង នៃព្រះករុណាជា

---

១ ស្រង់ពីសារពត៌មានកម្ពុជា លេខ ៣០៨៤ ចុះថ្ងៃព្រហស្បត៌ទី ២ កុម្ភៈ ១៩៥៦ ។

អម្ចាស់ជីវិតលើតួង ដោយមានអ្នកទេពញ៉ាមហាមន្ត្រី ញឹក - ខ្លូ ចាង់ហ្វាង ពិធីការក្នុងព្រះបរមរាជវាំងអមដង ចាត់អញ្ជើញទៅដល់ទៅម៉ោង ៩, នោះ គេសង្កេតឃើញឯកទត្តម សុឹម - ភ័ ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឯកទត្តម ទ្រឹញ - ភ័ញ រដ្ឋលេខាធិការក្រសួងធម្មការ, ឯកទត្តម មៀច-គន្ធ ចៅហ្វាយក្រុង, សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងបុគ្គលិកក្រសួងធម្មការរង់ចាំទទួល, ព្រមទាំងមានកងទាហានរក្សាព្រះអង្គ ក្រុមតូរ្យតន្ត្រីព្រះរាជទេព្យគោរព ជាកិត្តិយសចំពោះព្រះរាជដំណាងផង ។

លុះទទួលការវិកិច្ចពីឥស្សរជនរួចហើយ សម្តេចអញ្ជើញចូលទៅកាន់ព្រះវិហារវត្តបទុមវតី ដែលមានដួចដុំព្រះរាជាគណៈ ឋានានុក្រម តិក្ខុសាមណេរបានទទួលទៅរួមក្នុងពិធីនោះផង ។ ក្រោយដែលព្រះរាជដំណាងបានក្រាបថ្វាយបង្គំព្រះសង្ឃរួចហើយ, ឯកទត្តម ទ្រឹញ - ភ័ញ បានប្រកាសប្រគេនព្រះសង្ឃ ទឹងដំរាបទីប្រជុំថា សម្តេចចៅហ្វាំងវរៈវៀងជ័យអធិបតីស្តីរាជ្យ ជាព្រះរាជដំណាងព្រះករុណាជាអម្ចាស់ជីវិតលើតួង ទទឹងថ្វាយព្រះរាជទង្ការប្រគេនដំណឹង ទទឹងជូនជ្រាប អំពីការតែងតាំងព្រះសង្ឃនាយកថ្មី ។ បន្ទាប់មក សម្តេចព្រះរាជដំណាងបានចាប់ផ្តើមសេចក្តីនៃព្រះរាជទង្ការ ខ្លូវព្រះបន្ទូលសូរសីហនាទ មានសេចក្តីដូចតទៅ ៖

ព្រះរាជទង្ការ ខ្លូវព្រះបន្ទូលសូរសីហនាទ នៃព្រះបាទសម្តេចព្រះនរោត្តម - សុរាម្រិត វិសុទ្ធមហាខត្តិយវង្ស វិសិដ្ឋបា-

វិពង្ស គុណាតិរេក ធម្មចរិយោត្តម បរមបពិត្រ ព្រះបៅព្រះ
រាជអាណាចក្រកម្ពុជា ជាអម្ចាស់ជីវិតលើត្បូង ។

នៅឧកាស ដែលសម្តេចព្រះសុធម្មាធិបតី អ៊ុង - ស្រី សង្ឃនាយក
គណៈធម្មយុត្តិកនិកាយ ទទួលព្រះអនិច្ចធម្មនៅយប់ថ្ងៃទី ២៩ ខែ ៣០
មករា ព. ស. ២៤៩៩ (១៩៥៦) វេលាម៉ោង ៩ នឹង ២០ នាទីឯក្តី ។

ទ្រង់សព្វព្រះរាជហឫទ័យ តាំងព្រះពុទ្ធាចារ្យ កុល - ទេស ជា
គណៈទី ១ ជាសង្ឃនាយកស្តីទី ដើម្បីសម្រេចកិច្ចការនានា ក្នុងសង្ឃ
មណ្ឌលគណៈធម្មយុត្តិ ។

ដូច្នេះ ចាប់តាំងពីថ្ងៃនេះតទៅ ព្រះពុទ្ធាចារ្យ កុល - ទេស មាន
សិទ្ធិពេញបរិបូណ៌ អាចសម្រេចកិច្ចការផ្សេងៗ ក្នុងគណៈសង្ឃតាំងពួន
បាន ទំពាំនឹងតែងតាំងជាសង្ឃនាយកពេញទីតទៅ ។

រីឯព្រះមង្គលទេពាចារ្យ កែប - កួន ជាគណៈទី ១ ទ្រង់សព្វ
ព្រះរាជហឫទ័យតាំង ជាសម្តេចព្រះមង្គលទេពាចារ្យ ឧត្តមប្រឹក្សា ខាង
គណៈធម្មយុត្តិកនិកាយ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ មករា ព. ស. ២៤៩៩

ព្រះរាជហត្ថលេខា :

នរោត្តម - សុភម្រិត

នៅពេលដែលចប់សេចក្តី នៃព្រះរាជឧទ្ទាវ ខ្ញុំព្រះបង្គំលសូរសើ-
ហាទាំ សម្តេចចៅហ្វាវាំងវរៈវៀងជ័យអធិបតីស្រឡាវ ជាព្រះរាជ-

តំណាង ក៏ចាប់មានប្រសាសន៍ឋន្តរៅខ្មៅត ដោយសូមឲ្យព្រះថេរ-
ន្ទុត្តេរៈគ្រប់ព្រះអង្គខ្លួលស្គាល់ ព្រះសង្ឃនាយកស្តីទីនេះតទៅ ។

តមក ព្រះសង្ឃតំាងអស់ក៏ចាប់ផ្តើមស្វាធ្យាយនធម្មដយន្តា
ប្រសិទ្ធិពរចំពោះព្រះសង្ឃនាយក ទំង សម្តេចព្រះមង្គលទេពាចារ្យ
ទត្តមប្រឹក្សា ដែលទើបខ្លួលព្រះហានន្តរសក្តិថ្មី ។ បន្ទាប់មក ព្រះភ-
តំណាងព្រមតំាងឥស្សរជនតំាងអស់ បានអញ្ជើញទៅកាន់មន្ទីរដំកល់
ព្រះសព ដើម្បីបួងសួងថ្វាយដំណឹងដល់ព្រះសពអំពីការតាំងព្រះសង្ឃ
នាយកស្តីទីនោះ ដោយមានអ្នកទកញ៉ាមហាមន្ត្រី ញឹក-ខ្លូ ចាងហ្វាង
ពិធីការក្នុងព្រះបរមរាជវាំង ជាអ្នកប្រកាសសូមឲ្យព្រះសពបង្ហិលមកនូវ
សេចក្តីសុខគ្រប់ប្រការ ដល់ព្រះថេរន្ទុត្តេរៈ គណៈធម្មយុត្តិគ្រប់ព្រះ
អង្គផង ។ នៅពេលនោះព្រះសង្ឃតំាងអស់ ក៏បានចំរើនសត្តប្បករណ៍
បង្សុកូលថ្វាយព្រះសព ។ ឥស្សរជនតំាងអស់ ក៏ខ្លួលអនុមោទនា
ទទួលផលចំពោះព្រះវិញ្ញាក្ខន្ធនៃព្រះសពដែរ ។

ពិធីនេះ បញ្ចប់នៅម៉ោង ៩ និង ៤០ នាទី ។

ក្រុមជំនុំជំរះទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

តន្តិបាលសុត្តវិនិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៨ លេខ ៣ ខែមីនា ព. ស. ២៤៩៨ គ. ស. ១៩៥៦

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
COMMISSION DES MOEURS & COUTUMES

តាន់ដងសង្ឃនាយ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	
– ពុទ្ធសរណគថា	មហា ហ៊ុន-ប្រ៊ិញ	២០៤
– មាតាបិតុគុណគថា	ព្រះអាចារ្យ ផៃ-ម៉ៃ	២១៣
– ជាតកថារឿងពុទ្ធរូបបុរាណ	ឃុនអត្ថកោវិទ ជា-យូរ	២២០
ផ្នែកអក្សរសាស្ត្រ		
– រឿងអ្នកស្នេហាជាតិសាសនាមហាក្សត្រ..	ឃុនបណ្ឌាគុរក្ស ប៊ូ-ប៉ូ	២២៨
– រឿងព្រះចាខវុសភ័ទសោដ និងព្រះនាង សេហេរីស្តាទី	អ្នកស្រី សារិះយ៉ាន	២៣៨
– សុភាសិតរាជនីតិ ពាក្យកាព្យ (តមក)..	អ្នកនាគញ៉ា នៅ	២៤៧
– ពេជ្រព្រះរាជា (តមក)	លោក ស៊ិន-ហ៊ាន	២៥៨
– រឿងសាមកុក (តមក)	នាគញ៉ា ង្វ - កន	២៦៨
– រឿងបល្ល័ង្កទីព្យ (តមក)	លោក វ៉ាយ - ប៊ុក	២៧៨
– ពុទ្ធសាសនបណ្ឌិត្យ និងពិព័រណ៌អន្តរជាតិ	លោក ជាប-ពិន	២៨៤
កំណត់ទិដ្ឋភាវណ៍		
– ពិធីបុណ្យគំរប់ ២.៥០០ ព្រះវស្សា នៃ ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា.	ពុទ្ធសាសនបណ្ឌិត្យ	៤៩១
– ពិធីបញ្ចប់កិច្ចសិក្សាខាងវិជ្ជាគរុកោសល្យ នៃសមណសាស្ត្រាចារ្យ	ពុទ្ធសាសនបណ្ឌិត្យ	២៩៧

មួយឆ្នាំមាន ១២ លេខ — ដំឡៃជាវ ២៣០រ,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Bouddhasaranakatha	*Moha HUN-PRENH*	204
— Matapitugunakatha (poème) .	*Vén. CHEY-MAY*	213
- La statue Bouddhique primitive	*M. CHEA-YOU*	220

PARTIE LITTERAIRE:

— Le Patriotisme	*M. BOU-PO*	228
— La Roi RUZVANSBHAD et la Princesse CHEHECISTANI . . .	*Mme SRIN-SARIS-YANN* .	238
— Subhasitarajaniti (suite) . . .	*Oknha NEOU*	247
— Conte "Le Diamant du Raja" (suite)	*M. SIN-HEAN*	258
— Histoire de SAMKOK (suite). .	*Oknha NOU-KAN*	268
— Les trente deux récits du TRONE (suite)	*M. RAY-BUC*	278
— L'Institut Bouddhique à l'Exposition Internationale de Phnom-Penh	*M. CHAP-PIN*	284

NOTES ET CHRONIQUES:

— Le 2.500è anniversaire de la mort du Bouddha	*Institut Bouddhique*	291
— La cérémonie de clôture des cours de perfectionnement des moines Professeurs . . .	*Institut Bouddhique*	297

Prix d'abonnement annuel (comprenant 12 numéros) 230$00

ក្តីឯកាសច្ចលង្ហាំប្តី នៃពុទ្ធសាសនបណ្ឌិត្យ

ឧកាសច្ចលង្ហាំរកអដ្ឋសំក ពុទ្ធស័កកន្ធឆ៍ជានពីរពាន់
បួនរយកៅច្រាំបួនដៀងជាក់ស្តាន់ គ្រិស្តស័កមួយពាន់ច្រាំបួនរយច្ចាយ ។
ហាសិបច្រាំមួយច្រាកដពិត ត្រូវតាមកម្រិតច្បាជ្ចបរិយាយ
ជាសកពជច្ចប្រែសើរសោយ សប្បាយជល់រដ្ឋខេមក ។
ក្រសួងពុទ្ធសាសនបណ្ឌិត្យ សូមប្រសិទ្ធិជោគជ័យយសស័ក្តា
ថ្លាយ ព្រះមហាក្សត្រ ដ៏ថ្លៃថ្លា ព្រមទាំងព្រះមហាក្សត្រិយានី ។
ហើយទាំង សម្តេចព្រះសីហនុ ដែលមានតន្ត្រីភ្លេងពិ
ការឯកក៏ផ្សះដោយសន្តិវិធី ច្បានមកអំពីច្បាកំឆ៍សែស ។
សូមពួកខេត្តាដែលមានវ័ន្ត ទឹងវាតសក្តិសិទ្ធិកុំបីរួស
ព្រមទាំងវត្តែរត្តន្តសំលើកេស ជួយទ្រទ្រង់ពិសេសច្បានសោយសុខ ។
ទឹងទ្រទ្រង់ច្រកបដោយព្រះជន្ម មួយរយទិវន្តរ៍នៃកសុក្ខ
ដើម្បីស្រោចស្រង់ច្រទេសស្រុក ឲ្យច្បានក្តីសុខចម្រើនក្តាត់ ។
មួយទៀតសូមក្រុមព្រះកជវង្ស នាម៉ឺនកៀកឆ៍ត្រួតសង្កាត់
ព្រមទាំងបណ្តាកស្រុកឆ៍វដ្ត ច្បានខ្វាត់ខ្លុះសោកពេតកយា ។
ច្បានសុខសប្បាយស្តាពរ មានកោតបវរត្រួប ។ គ្នា
ដោយតេជៈគុណនៃទេព ឆ្នាំថ្មីនេះជាកុំបីឃ្លាត !

ផ្នែកសាសនា

ពុទ្ធសរណាគមន៍

មហា ហ៊ុន-ប្រឿ ធិស្សរិតសាលាបាលីជាន់ខ្ពស់

រៀបរៀង

ឥមោ តស្សុ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សុ ។
ពាទិយាឆ្ពុឆ្ពុយំ វន្ទេ កាមា វា តិវិនាទរំ
តស្សេវ អានុភាវេន សោត្ថិ មេ ហោតុ សព្វទា

ខ្ញុំព្រះករុណាសូមធ្វើនូវសេចក្តីគោរព ថ្វាយបង្គំចំពោះព្រះវិត្រះត្ន មានព្រះពុទ្ធជាដើម ដោយកាយវាចាចិត្ត សូមសិរីសួស្តីសំរេចមានដល់យើងខ្ញុំគ្រប់កាលទាំងពួង ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំចំពោះព្រះវិត្រះត្នោះឯង ។

លំដាប់អំពីនេះ សូមសំដែងអំពីសរណាគមន៍; សរណាគមន៍ (វត្ត សម្រាប់ទីពឹង) ក្នុងព្រះពុទ្ធសាសនាមាន ៣ ប្រការ គឺ ពុទ្ធសរណៈ ១, ធម្មសរណៈ ១, សង្ឃសរណៈ ១ ។ ក្នុងទីនេះសូមសំដែងអំពីពុទ្ធសរណៈ ។

ក្នុងកាលមុនពុទ្ធសករាជ ៨០ ឆ្នាំ បើគិតថយក្រោយពីឆ្នាំមមែសប្តស័ក នេះត្រូវជា ២៥៧៨ ឆ្នាំ, ក្នុងថ្ងៃមហាមង្គលសម័យពេញបូណ៌មីខែវិសាខ ព្រះពុទ្ធជាម្ចាស់ជាសាស្តានៃយើងស្តេចទៅប្បត្តិឡើង ក្នុងត្រកូលក្សត្រិយ៍សាក្យវង្ស គោតមគោត្រ ជាព្រះរាជឱរសព្រះបាទសុទ្ធោទនៈ

សោយរាជ្យនៅក្រុងកបិលព័ស្តុ ទឹងព្រះនាងមហាមាយា, ជាអរិយជាតិ
តែជាជាតិដែលចំរើនដោយចំណេះវិជ្ជា រៀបចែបផែនចំនៀមទម្លាប់ត្រម
តាំងមានខ្លឹមអំណាចកងឥម្ជឹមប្រទេស ដែលហៅកងកាលឥឡូវនេះថា
ប្រទេសឥណ្ឌា តាំងនៅកងទិសតាយ៉ាយនៃប្រទេសកម្ពុជានេះ ។
ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ៣២ប្រការ គឺមានលក្ខណៈ
ជាមហាបុរិសត្រូវតាមគម្ពីរព្យាករណ៍សាស្ត្រចបស់ព្រាហ្មណ៍ ។ កាល
ប្រសូតបាន ៥ ថ្ងៃ ព្រះរាជបិតាឲ្យធ្វើមង្គលពិធីទទួលព្រះលក្ខណៈ
ព្រះអង្គព្រះរាជទាននាមថា "សិទ្ធត្ថៈ" ។ លោះនោះព្រាហ្មណ៍ដែល
ជំនាញកងក្បួនព្យាករណ៍សាស្ត្របានធ្វើទំនាយក្រាបបង្គំទូលថា "ព្រះ
រាជឱរសនេះមានលក្ខណៈល្អ ត្រូវតាមតម្រាមហាបុរិសលក្ខណព្យា-
ករណ៍សាស្ត្រយ៉ាងចបំបូណ៌ បើព្រះអង្គនៅគប់គ្រងគេហដ្ឋាន ទឹងបាន
ជាស្តេចចក្រពត្តិ មានអំណាចគ្របលើពិភពផែនដី; បើព្រះអង្គចេញ
ទ្រង់ព្រះផ្នួសទឹងបានត្រាស់ជាព្រះពុទ្ធ បានជាសាស្តាឯកកងលោក" ។
ព្រះសិទ្ធត្ថកុមារព្រះអង្គជាទីពេញព្រះហឫទ័យ នៃព្រះរាជបិតាណាស់
បានទទួលការទំនុកបំរុងផ្សេង ។ តាមផ្លូវលោកវិស័យ ប្រកបដោយសុខ
សម្បត្តិយ៉ាងចបំបូណ៌ ។ លុះមានព្រះជន្មល្មមសិក្សាវិជ្ជាហើយ
ក៏ស្តេចយាងទៅសិក្សាវិជ្ជាវជ្ជប្បសាសនសាស្ត្រ ទឹងវិជ្ជាផ្សេង ។ កង
សំណាក់គ្រូឈ្មោះ វិស្វាមិត្រ ទ្រង់រៀនចេះចប់ស្ទាត់យ៉ាងឆាប់ ពាល់
តែអស់ចំណេះអំពីគ្រូ ទឹងរកកុមារដទៃ ។ មកប្រៀបផ្ទឹមពុំបាន ។
កាលព្រះជន្មបាន ១៦ វស្សា ព្រះរាជបិតាទ្រង់ដណ្តឹងនាងយសោធរាពិម្ពា

ជាធ័តាព្រះចាទសុប្បពុទ្ធ កោលិយវង្ស មកអភិសេកជាព្រះរាជា ។ លុះដល់ព្រះជន្ម ២៩ វស្សា ទើបមានព្រះរាជឱរសមួយព្រះអង្គទ្រង់នាមថា រាហុល ។

គ្រានោះព្រះអង្គទ្រង់ជ្រាបសេចក្តីចាស់ ឈឺ ស្លាប់ ដែលគ្រប់សត្វតមហាជនគ្រប់រូប គ្មានអ្នកណាចៀសវាងបាន ។ ហេតុការណ៍ដូច្នេះ ព្រោះតែសេដែលសត្តនិករមិនស្តាប់ពាក្យប្រដៅអ្នកជ្រាជ្ញ ។ សត្តនិកឃើញអ្នកជរា ចាស់ ឈឺ ស្លាប់ ក៏ជិនឆ្កួនស្លុតខ្លឹម មិនគិតថា ខ្លួនឯងនឹងខ្លួនគេប្រហែល ។ គ្មាវង្វេងស្រើងក្នុងជីវិត ហាក់ដូចជាមិនចេះចាស់ ឈឺ ស្លាប់ មិនគិតរកឧបាយឱ្យរួចពីសេចក្តីចាស់ ឈឺ ស្លាប់ឡើយ ។ កាលបើដឹងឃើញយ៉ាងនេះហើយ គួរតែស្វែងរកឧបាយគ្រឿងរួចពីទុក្ខទាំងនេះទើបប្រសើរ; ព្រោះសត្វៈទាំងពួងសុទ្ធតែមានបងស់ដែលផ្ទួយគ្នាសម្រាប់តែជាជរាជ ដូចយ៉ាងមានក្តៅហើយមានត្រជាក់តែ, មានងងឹតហើយ មានពន្លឺតែ, ប៉ុន្តែដែលទឹងរកឧបាយកែទុក្ខទាំង ៣ យ៉ាងនេះ មិនជាការងាយឡើយ, អ្នកដែលនៅត្រង់ត្រង គេហស្ថាន ឃើញជាស្វែងរកមិនបាន ព្រោះគេហស្ថានជាទីចង្អៀតចង្អល់ណាស់ ហើយជាទីតាំងនៃការមួលណ៍ ដែលធ្វើចិត្តឱ្យសៅហ្មងផងខ្លែត ដោយហេតុសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីវង្វេង ថែមទាំងភាគច្រើនតែកូលកំតែតែចចូកចបល់ ដោយពួកស្ត្រីបំរើទាំងវៃថ្ងូទាំងយប់ តែតែធ្វើជីវិតឱ្យទទេណាស់ទៅខ្លែត ។ ទ្រង់ក៏ខ្វាយណាយក្នុងការរស់នៅរបស់ព្រះអង្គ ដែលអ្នកជរាសំគាល់ឃើញថាជាសុខក្រៃពេក

ក្នុងផ្លូវលោកិយ; ខ្ញុំយើញបព្វជ្ជាជាឧត្តមដែលឃ្លាតអំពីអារម្មណ៍ដែលដឹកនាំចិត្តឲ្យវង្វែងមួយម៉ៅ ជាឧត្តមស្រួលនឹងបានសេចក្តីសុខបាយនោះ ដើម្បីនឹងបំពេញឲ្យជាប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ, ធ្វើដើរឲ្យមានប្រយោជន៍មានផ្លែផ្កា កុំឲ្យអសារសូន្យសោះ ។ កាលខ្ញុំព្រះចន្ទាយើញដូច្នេះហើយ ក៏ខ្ញុំបង្អោនត្រអែងស្រ័យទៅក្នុងបព្វជ្ជាមិនអាឡោះអាល័យយកវាសសម្បត្តិ ។

សម័យថ្ងៃមួយ ព្រះសង្ខត្តកុមារចេញចាកនិវេសន៍ទៅដល់ឆ្នេរស្ទឹងអនោមា ខ្ញុំអធិដ្ឋានកេរបព្វជ្ជិត ហើយក៏ស្តេចទៅសិក្សាលទ្ធិសម័យក្នុងសំណាក់អាឡារតាបសនឹងឧទ្ទកតាបស ជាមេគណៈធំដែលល្បីល្បាញក្នុងស្រុកឈ្មោះមានមហាជនកាប់អានច្រើនក្នុងវេលានោះ ។ ព្រះអង្គខ្ញុំសិក្សាលម្អិតក្នុងលទ្ធិនោះត្រប់យ៉ាងទៅ ឃើញថាមិនមែនជាផ្លូវសម្មាសម្ពោធិញ្ញាណ ទើបព្រះអង្គចេញចាកសំណាក់អាចារ្យទាំងពីរ ស្តេចទៅដល់ដំបន់ទុរុវេលាសេនានិគម ទតឃើញទីនោះស្រួលសមាប់អ្នកប្រកបសេចក្តីព្យាយាម ។ ទើបខ្ញុំសំណាក់ទៅទីនោះ ខ្ញុំបំពេញទុក្ករកិរិយាយ៉ាងក្រៃលែងអស់ ៦ វស្សា ។ ខ្ញុំឃើញថា គ្មានផ្លូវសម្រេចហើយ ទើបផ្ទាស់ប្តូរដំណើរប្រព្រឹត្តជាថ្មី គឺខ្ញុំប្រព្រឹត្តតាមផ្លូវកណ្តាល ដែលហៅថាមជ្ឈិមប្បដិបទាបំពេញវីរិយៈក្នុងចិត្ត ទើបបានត្រាស់ដឹងនូវធម៌ដ៏វិសេសជាទីពេញព្រះហឫទ័យ ទើបលាន់ព្រះឧទានថា "ត្រាស់ដឹងហើយ។" គឺដឹងអរិយសច្ចនោះឯង ក្នុងភត្តីនៃវិសាខបុណ្ណមីក្រោមដើមអស្សត្ថព្រឹក្ស ក្នុងកាលមុនពុទ្ធសករាជ ៤៩ ឆ្នាំ ។

ឯកោ វិលោកេ អនុត្តរំ សម្មាសម្ពោធិ អភិសម្ពុទ្ធោ

ព្រះអង្គតែមួយអង្គប៉ុណ្ណោះ ក្នុងលោកនេះ ជាអ្នកត្រាស់ដឹងខ្ពស់ពោធិញ្ញាណ ដោយប្រពៃចំពោះព្រះអង្គ គ្មានបញ្ញាដទៃរបស់អ្នកណាមួយវិសេសជាងនេះទៀតឡើយ ។ ព្រះអង្គទ្រង់ដល់នូវសេចក្តីបរិសុទ្ធផុតប្រមាណ មានអសេក្ខធម្មក្ខន្ធ គឺ សីល - សមាធិ - បញ្ញា - វិមុត្តិ - វិមុត្តិញ្ញាណទស្សនៈ បរិបូណ៌ក្នុងព្រះសន្តានគ្មានអ្នកណាមួយក្នុងលោកធាតុប្រៀបផ្ទឹមឲ្យត្រឹមស្មើឡើយ ។ ទ្រង់លះកិលេសទាំងពួងព្រមទាំងវាសនា ឲ្យដាច់ដែនស្រឡះគ្មានសេសសល់, ព្រះអង្គមានកាយវាចាចិត្តដ៏បរិសុទ្ធ, សេចក្តីខ្ចះខ្ចែតណាមួយដែលព្រះអង្គលះមិនទាន់បាន គោរពប្រតិបត្តិទុកកុំឲ្យអ្នកដទៃដឹងឃើញ នោះគ្មានសោះឡើយ, ទ្រង់មានព្រះហឫទ័យតាំងស្មើក្នុងលោកធម៌ គ្មានរំភើបប្តេជ្ញាស្រឡាញ់ហើយអាចនឹងលើកបញ្ញត្តិឡើង ប្រដៅសត្វដទៃឲ្យរួចចាកសង្សារទុក្ខបានផង; ព្រះអង្គមានព្រះទ័យក្រៃថ្លាប្រយោជន៍ដល់សត្វសត្វជានិច្ច, ទ្រង់ប្រកបសត្វបកាតិច្ច ដោយមិនបានសំឡឹងលាភសក្ការៈអំពីអ្នកណា, ទ្រង់សំដែងធម្មកថាប្រដៅវិនេយ្យសត្វដោយត្រៃញ្ញាណ គឺសីល សមាធិ បញ្ញា ជាឧបាយគ្រឿងលះកិលេសយ៉ាងជ្រៅក ជ្រៅ យ៉ាងកណ្តាល យ៉ាងសុខុម គាល់តែអស់ទៅជាទីបំផុត, ទ្រង់ប្រដៅទេវតានឹងមនុស្សឲ្យចៀសចាកមគ្គមិច្ឆាប្រតិបត្តិដែលមិនមែនជាផ្លូវព្រះនិព្វាន ឲ្យប្រតិបត្តិជាដំណើរក្នុងមគ្គប្រតិបត្តិដ៏បរិសុទ្ធផុតប្រមាណ. បានមគ្គមានអង្គ ៨ គឺ :

១– សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ គឺចូលចិត្តត្រូវ ខុសៗចាំងផ្លូវ លោកចាំងផ្លូវធម៌;

២– សម្មាសង្កប្បៈ ការតម្រិះត្រូវ ចាន់ដល់ការតម្រិះកន្លងការចេញចាកកាម, តម្រិះកន្លងការមិនព្យាចាទសត្វដទៃ, តម្រិះកន្លងការមិនបៀតបៀនសត្វដទៃ;

៣– សម្មាវាចា ពាក្យត្រូវ គឺវៀរចាកវចីទុច្ចរិត ៤ ប្រការ គឺវៀរចាកការនិយាយកុហក, និយាយញុះញង់, និយាយពាក្យគ្រោតគ្រាត, វៀរចាកការនិយាយពាក្យផ្តេសផ្តាសឥតប្រយោជន៍;

៤– សម្មាកម្មន្តៈ ការងារត្រឹមត្រូវ គឺវៀរចាកកាយទុច្ចរិត ៣ ប្រការ គឺមិនសម្លាប់សត្វ, មិនលួចប្លន់គេ, មិនប្រព្រឹត្តខុសកន្លងកាម;

៥– សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ គឺវៀរចាកចិញ្ចឹមជីវិតខុសគ្រប់យ៉ាង ចាំងផ្លូវធម៌ ចាំងផ្លូវលោក;

៦– សម្មាវាយាមៈ ព្យាយាមត្រូវ គឺព្យាយាមកន្លងបាន: ៤ ប្រការ គឺ ព្យាយាមមិនឲ្យបាបកើតកន្លងសន្តាន, ព្យាយាមលះបង់បាបដែលមានកន្លងសន្តាន, ព្យាយាមចំរើនកុសល, ព្យាយាមរក្សាកុសលដែលកើតហើយមិនឲ្យសាបសូន្យទៅ;

៧– សម្មាសតិ ការរលឹកត្រូវ គឺរលឹកកន្លងសតិបដ្ឋានចាំង ៤ ប្រការ មានកាយានុបស្សនាសតិបដ្ឋានជាដើម;

๘- សម្មាសមាធិ ការតាំងចិត្តត្រូវ គឺដំកល់ចិត្តខ្ជាប់ខ្ជួនក្នុងឈានទាំង ៤ ប្រការ ។

មគ្គមានអង្គ ៨ មានសម្មាទិដ្ឋិជាដើមនេះ សង្គ្រោះចូលក្នុងកងសីល, សមាធិ, បញ្ញា នោះឯង ។ ពួកវេនេយ្យសត្វអ្នកមានឧបនិស្ស័យ បានស្តាប់ធម្មទេសនាដែលទ្រង់ប្រដៅនោះ ហើយប្រតិបត្តិតាមក៏បានលុះធម៌វិសេសគឺមគ្គ ផល និព្វាន កន្ទងបង់នូវភាពជាបុថុជ្ជនឡើងកាន់អរិយភូមិជាសោតាបន្ន, សកទាគាមិ, អនាគាមិ, អរហត្ត តាមសមគួរដល់ឧបនិស្ស័យរៀង ។ ខ្លួន ។

បើសរុបសេចក្តីទៅ គុណសម្បត្តិដែលមានប្រាកដក្នុងព្រះអង្គកំណត់ជាអាការមាន ៣ ប្រការ គឺវិសុទ្ធិគុណ ១ បញ្ញាគុណ ១ ករុណាគុណ ១ ។

ដែលព្រះអង្គមានព្រះនាមថា អរហំ ព្រោះព្រះអង្គជាអ្នកឆ្ងាយចាកកិលេសគ្រឿងសៅហ្មងចិត្ត គឺ ភគៈ ពោសៈ មោហៈ យ៉ាងរ៉ជ្រាកជ្រាក យ៉ាងកណ្តាល យ៉ាងល្អិត ព្រះអង្គលះបានដោយអំណាចសីលសម្មាធិ បញ្ញា ទៀងជាបុគ្គលមានខន្ធសន្តានដ៏បរិសុទ្ធិ គួរតែងតាំងបញ្ញត្តិដល់ពួកពុទ្ធបរិស័ទ គួរដល់អាមិសបូជារបស់សត្វលោកធ្វើសក្ការៈបូជាត ។ មកដល់សព្វថ្ងៃនេះ, ព្រះពុទ្ធគុណបទ អរហំ នេះ ជាគុណដ៏ធំប្រកាសព្រះវិសុទ្ធិគុណក្នុងអង្គព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ។

ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គជាអ្នកត្រាស់ដឹងនូវ

ធម៌ពិតយ៉ាងប្រសើរ គឺអរិយសច្ចធម៌ ๔ ដោយព្រះអង្គឯង ។ ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គជាអ្នកដល់ព្រមដោយវិជ្ជា ๓ វិជ្ជា ๘ នឹងចរណៈ ๑๕ ។ ព្រះនាមថា សុគតោ ព្រោះព្រះអង្គជាអ្នកទៅកាន់លោកុត្តរធម៌ដោយល្អ ។ ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជាអ្នកជ្រាបច្បាស់នូវលោក មានសង្ខារលោកជាដើម ។ បួនបទនេះជាគុណដ៏ធំ ប្រកាសព្រះបញ្ញាគុណក្នុងអង្គព្រះសម្មាសម្ពុទ្ធ ជាកំលាំងដ៏ធំរកែវលែង ក្នុងការត្រាស់ដឹង ។

ព្រះនាមថា: អនុត្តរោ, បុរិសទម្មសារថិ ព្រោះព្រះអង្គដូចជានាយសារថីដ៏សំខាន់ ទ្រង់ទូន្មានបុរសដែលគួរទូន្មាន គ្មានអ្នកណាមួយប៉ុនប្រសប់ទូន្មានជាងព្រះអង្គ គឺទ្រង់ទូន្មានឲ្យបានលុះលោកុត្តរធម៌ ជាអកុប្បធម៌ គ្មានវេលានឹងត្រឡប់មកកាន់លោកិយធម៌ទៀត ។ ក្នុងគម្ពីរខ្លះលោកពន្យល់ថា អនុត្តរោ ជាព្រះគុណ ๑ បុរិសទម្មសារថិ ជាព្រះគុណ ๑ ។ ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គបានជាសាស្តាបង្រៀនទៅតាឧដ៏មទុស្សទាំងឡាយ ។ ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គជាអ្នកភ្ញាក់ ព្រមទាំងជាអ្នកដាស់ពួកពុទ្ធវេនេយ្យសត្វឲ្យភ្ញាក់អំពីការដេកលក់គឺកិលេសនិទ្រាមួយណា, ទ្រង់បានធ្វើនូវពុទ្ធកិច្ចទាំង ๕ ប្រការពេញចិ ។ ព្រះនាមថា ភគវា ព្រោះព្រះអង្គជាអ្នកចែកចាយនូវធម៌ជាសភាវៈពិតដល់វេនេយ្យសត្វទាំងឡាយ ។ បួនបទនេះ ប្រកាសព្រះមហាករុណាគុណដែលមាននៅក្នុងព្រះអង្គ ។

គុណសម្បត្តិចាំង ៩ ប្រការនេះ ប្រកាសពុទ្ធគុណ ដែលជាកំពូលនៃសេចក្តីល្អចាំងពួង ដែលមានប្រាកដក្នុងអង្គសម្តេចព្រះបរមសាស្តាទើងស្ទះស្ទើងរកសាស្តាណាដែលទ្រទ្រង់គុណសម្បត្តិចាំងឡាយដូច្នេះគ្មានឡើយ ។ គុណសម្បត្តិចាំងឡាយដែលបានសំដែងមកយ៉ាងសង្ខេប ។ នេះជាគុណដ៏ល្អ គួរឲ្យសត្វលោកចូលពឹងភាក់អាស្រ័យយកជាសរណៈ (ទីពឹង) ។ ហេតុដូច្នេះ បានជាពាក់ថា "ព្រះពុទ្ធជាម្ចាស់ជាសរណៈរបស់សត្វលោក" ។

ឯធម្មសរណៈ ទើងសង្ឃសរណៈ មិនបានន៎ាយកមកសំដែងក្នុងទីនេះទេ សូមបញ្ចប់ធម្មទេសនា ដែលសំដែងអំពីពុទ្ធសរណៈ តែប៉ុណ្ណោះ ។

កាលបើចប់ហើយ ដោយអំណាចធម្មទេសនានេះ សូមសេចក្តីសុខ - ចំរើនកើតមានដល់ប្រជាជនក្នុងដែនកម្ពុជាចាំងមូល កុំបីឃ្លៀងឃ្លាតឡើយ !

ប្រយ័ត្ន ៤ :

១ - ហោចប្រយ័ត្នមាត់រអិល

២ - ជាងខាន់សីលប្រយ័ត្នខ្វៀង

៣ - ខៅកំប្រយ័ត្នការលំអៀង

៤ - អ្នកផ្សៀងប្រយ័ត្នជាត់អក្ខរ ។

សុត្តន្តប្រើជា ពីរ

មាតាបិតុកុលាកថា

ពាក្យកាព្យ

ព្រះអាចារ្យ ជៃ - ម៉ែ វត្តសំពៅមាស ភ្នំពេញ

រៀបរៀង

មាតាបិតាថ្លៃ　　មានគុណក្រៃយ៉ាងអស្ចារ្យ

ដោយធម៌ ៤ ប្រការ　　បុត្រធីតាគួរចាំទុក ។

ទី ១ គឺមេត្តា　　អត្ថប្រៃថាស្និតក្នុងសុខ

ចិត្តម្នាយទំនឹងឥតពុក　　ស្វែងរកសុខសព្វវេលា ។

តាំងពីថ្លៃពន្លោះ　　លោកតាំងនោះមានចិន្តា

អាណិតដល់បុត្រកូន　　ត្រមង់វេលាតាំងយប់ថ្ងៃ ។

ការងារលៀងជីវិត　　នោះធ្វើយកជិតឥតសំចៃ

ក្នុងស្រុកឬក្នុងព្រៃ　　ប្តីតែងលៃធ្វើគ្មានឈប់ ។

ស្វះស្វែងរកទ្រព្យ　　ទុកកិរិយាឲ្យនៅម្ខប់

អាស្រូវតាំងសព្វត្រប់　　ប្រពន្ធឈប់គ្មានខោសា ។

ផ្សុំថ្នាំរក្សាថ្លៃ　　យ៉ាងប្រពៃឲ្យកិរិយា

នេះឯងគឺមេត្តា　　ខាងបិតាបុត្រប្រុសស្រី ។

ចំណែកខាងមាតា　　ភ្ជាប់ពីសារអស់ចំណី

ហិលហាងយ៉ាងណាក្តី　　តាមប្រក្រតីឥតមានតម ។

តែដល់មានទិមិត្ត　　មកសណ្ឋិតតាំងនៅត្រម

មាតាក៏តាំងតម　　កាន់ត្រណមមិនកោក្តា ។

ព្រោះហេតុលោកអាណិត មេត្រីចិត្តជាប់មេត្តា
ចំពោះបុត្រធីតា ជាពារកានៅក្នុងផ្ទៃ ។
តរិយោបថទាំងបួន មានក្នុងខ្លួនមាតាផ្ទៃ
បើតាមដោយប្រក្រតី សឹងរហ័សត្រង់តរិយា ។
លុះដល់មានគតិហ៊ាយ មាតាស្បើយប្រែយឺតណា
ដោយចិត្តមានមេត្តា ឈប់សុះស្ទាយ៉ាងរហ័ស ។
ហើយតែងនឹកខន្ធឹង ដោយចង់ដឹងកូនពេកណាស់
ចង់ឃើញកូនឲ្យច្បាស់ តើពារកឬទារិកា ។
ទី ២ ភរុណាគុណ គុណានេះធ្ងន់ ។ មហិមា
ដោយអត្ថប្រែមកថា ការដួញខ្លួនរបស់បុត្រ ។
សេចក្តីអធិប្បាយថា ចិត្តមាតាតែងស្រយុត
កន្លងពេលដែលពួកបុត្រ មានខ្លួនក័យអ្វីកើតឡើង ។
បុត្រឬបុត្រា កើតមកណាម្តាយតំកើង
សម្រាមឬចម្ងៃ ជ្អាក់មកលើស្មើរពុំបាន ។
កំពុងបរិភោគ្តា អស់គោជនាក្នុងគ្រឹះស្ថាន
ឮមាត់កូនកល្បាណ ស្រែកយំស្ទុះឈប់ពីសា ។
បើកូនមានជម្ងឺ ត្រូនក្តៅឈឺយំសម្បា
ម្តាយឥតុកកំខ្លោចផ្សា ភ័យធ្វើឆ្ងាកពេទ្យហ្ន ។
បើពេទ្យឲ្យទិញថ្នាំ លក់បញ្ចាំស្រែវាលឆ្ការ
ខ្លីបុលគេបន្ត មានទឹងត្រូតិតទៅក្រោយ ។

បើកូនមានទុក្ខទោស ប្តូរគំហុសដោយថ្លូរថ្នាយ
បង់ខាតអ្វីក៏ដោយ ឲ្យតែកូនរួចទុក្ខភ័យ ។
យ៉ាងនេះហៅគុណា ចិត្តមាតាបិតាថ្លៃ
ផ្សាយលើកូនសព្វថ្ងៃ សព្វវិថីឧណៈចិត្ត ។
ទី ៣ មុទិតា អត្ថប្រែថាខន់ពេកពិត
តែត្រូវគ្នានឹងអាណិត ពោរពេញចិត្តឥតរសាយ ។
កូនប្រុសឬកូនស្រី តាមសេចក្តីនៃបរិយាយ
រមែងមានដេរម្តាយ ប្តូរយកបន់លោកវិញខ្លះ ។
ដុះជាន់ចាប់កេសា យំសម្លាដោយម្ចាស់
លុះតែលួងលោមខ្លះ ថ្នាក់សំពះកូនក៏មាន ។
បំពេហើយបីព័ត ពោលបន្តូរតែកំសាន្ត
ចិត្តខន់ល្អន់មែនមាន ដូចយើងបានអធិប្បាយមក ។
សំលៀកបំពាក់កាយ កូនទាំងឡាយម្តាយទំរក
ទំធ្វើឲ្យបានមក យកមកទុកឲ្យតែកូន ។
ឲ្យរៀនសព្វសិល្បសាស្ត្រ មិនឲ្យផ្តាសខ្ជិលរេះពួន
ឲ្យរៀនពេញសំខួន ឲ្យចេះចប់សព្វរហូត ។
ស៊ូទ្រឹយមិនគិតខ្លួន ឲ្យតែកូនទំរៀនសូត្រ
ឲ្យចេះចាំរហូត ស្រួតឲ្យផុតពីអវិជ្ជា ។
កូនសល្អស្រស់ផ្ការ ប្តូរយកភ្លៅសៅអង្គា
លោកផ្សាយព្រហ្មវិហារ ស្មើៗគ្នាគ្រប់ៗកូន ។

ឯកូនអ្នកដទៃ ខោះចេះស្តីយ៉ាងសមស្ងួន
មិនស្មើនឹងកូនខ្លួន គ្រាន់តែយំក៏ពីរោះ ។
ធម៌អាថ៌លោកសំដែង មានហ៊ានដែងពោលគ្រោះ
ថាធម៌មិនពីរោះ មោះគឺគ្មានមុខតា ។
ទ្រព្យធនមានច្រើនយ៉ាង ទំសំអាងឲ្យបុត្រា
បុត្រីមានប៉ុណ្ណា តិតរចនាទាល់តែគ្រប់ ។
រៀបចំគូស្រករ ខោះខ្វល់ក្រក៏មិនឈប់
ប្រឹងរកទាល់តែគ្រប់ នៅមិនទាន់ចប់ក្នុងចិត្ត ។
នេះហៅមុខតា អង្គសាស្តាមារំដិត
ទេស្នាពិស្តារពិត ថ្លែងពីគុណបុព្វាចារ្យ ។
គ្រាស់ថ្កាប់កិក្ខុទាំងឡាយ យ៉ាងក្បោះក្បាយដោយពិស្តារ
ដូចយើងបានបរបា គុណមុខតាថ្នាក់ទី ៣ ។
ទី ៤ ឧបេក្ខា ថ្កាដ្បិថាចិត្តប្រតិតី
មិនស្អប់មិនមេត្រី មិនបៃតីនៅព្រងើយ ។
ចំពោះបុត្រធីតា មានកិរិយាស្ងាម៉ៅហើយ
ចិត្តលោកបានធូរស្បើយ ចិត្តព្រងើយពីសុខទុក្ខ ។
ដោយអាងថារូបកូន រៀនពាល់ខ្លួនគេមានមុខ
រកស៊ីទៅតគុក ទាំងបានសុខក្នុងគ្រួសារ ។
កូនប្រុសឬកូនស្រី ដែលឃ្លាតខ្លីរៀនវិជ្ជា
អាចនឹងតដាក កង់អគ្គភាពនេះបានហើយ ។

ចិត្តណោកទុបក្ខា　　ទើបទៅជាខៅកន្លើយ

ឥតស្អប់ស្រឡាញ់ឡើយ　　នេះឯងហើយទុបេក្ខា ។

សប្បុរសចាំងឲ្យអើយ　　ស្តាប់ឮហើយគួរជ្រះថ្លា

ទីឯគុណ ៤ ប្រការ　　ដែលហៅថាវិហារធម៌ ។

សឹងមានក្នុងសន្តាន　　នៃអ្នកមានគុណហ្មត់

ចំពោះសត្វទាំងពួង　　ដែលជាបុត្រមាសឆ្អិនផ្លៅ ។

ជួបច្រេះយើងពាល់គ្នា　　ប្រសិនជាខៅម៉ែឪ

គួរគោរពឲ្យត្រូវ　　តបគុណលោកតាមលំនាំ ។

ធម៌នេះបង់ប៉ុណ្ណេះ　　សូមខុកស្ទេរពាក្យបណ្តាំ

អ្នកច្រេះជ្រកាចចេះចាំ　　ថ្លៃឯបណ្តាំនេះឯងហោង ។

អាសាឧកបា

មេជាធិដម្ម៌ម៉ែ　　ខ្ញុំបានលែចឯនិពន្ធ

ធម៌នេះឲ្យត្រូវគាប់គាន់　　តាមលំនាំជាពាក្យកាព្យ ។

ព្រោះខ្ញុំស្គាយក្តីពិត　　មានក្នុងចិត្តឥតប្រែកាព

នៃមាតាជាប　　ជាបុញ្ញាលាភនៃសត្វសត្ត ។

តែក្មេងស្រដី　　ចាំងប្រុសស្រីយូរមកក្តាត់

ថាគុណម្តាយត្រូវចាត　　តែដប់ពីរប្រការគត់ ។

បិតាមានម្តែ　　មួយទៀតន័យជាកំណាត់

យកជាតុមកសន្ធាត់　　ហើយកំណាត់ថាគុណថ្នូ ។

បើម្តុំដឿម្តេចបាន ខុសលំអានពីចាស៎
មិនដឹងអាងកងអ្វី ហាន[ស្រដីត ។ ភ្លា ។
ពាក្យនេះខុសយូរហើយ ញាតិញោមអើយកុំសង្ស
សម្តេចព្រះកតក់ មិនខេស្មាដូច្នេះទេ ។
ខែធំចាត់ព្រហ្មវិហារ ៤ ប្រការនេះជាមេ
គុណនោះឯណោះទេ ដែលជាគុណគួរគោរព ។
ដូច្នេះបុត្រធីតា គួរទស្សាហ៍រៀនឲ្យចប់
ស្គាល់គុណនេះឲ្យគ្រប់ ហើយគោរពកងគុណចុះ ។
បើបានគោរពហើយ មិនយូរឡើយទឹងផុលផុះ
ក្តីសុខកើតកកកុះ ដល់កូនប្រុសទឹងកូនស្រី ។
ដូចកាលពោធិសត្វ ខែធំលះកាត់ការលោភ័យ
ឋិតជាតាបសខ្ចី ខំស្មឹងស្មាធិធម៌ប្រសើរ ។
បានឈានជាលោកិយ ព្រះឥសីតែងហោះហើរ
វែងរកផលប្រសើរ មកបម្រើប្អូនាវ្យ ។
តើម្តាយទឹងផុត ព្រះអង្គខុកកងសាលា
បម្រើព្រះមាតា ទឹងបិតាសព្វ ។ ថ្ងៃ ។
ជាក់ពោសតាបសប្អូន ថាត្រូវសូន្យការប្រពៃ
ដ្បិតឯងមនុស្សចង្រៃ កុំបីមកជិតសាលា ។
កិច្ចដែលបម្រើខ្ញុំ ទឹងម៉ែគួរតាំងខ្លួនា
ខ្លួនយើងជាដេដ្ឋា យើងបម្រើតែម្នាក់ឯង ។

តាបសជាប្អូនស្រី
ទៅពឹងអស់ស្តេចស្តេច
ពួកស្តេចមួយរយមួយ
មកសុំទោសមាទោស
មាតាជួយសុំផង
សូមឲ្យព្រោធិសត្វ
តាបសក៏អាណិត
បើកឲ្យបម្រើវិញ
ឯអង្គព្រោធិសត្វ
ព្រះអង្គទ្រង់បង្វរ
ស្រ្តាសស្តេចមួយរយមួយ
លុះចប់ព្រះធម្មា
ប្រគេនបច្ច័យ ៤
និមន្តព្រោធ៏សម្ភារ
ថ្វាយខ្លួនជាឧបជ្ឈាក
នេះគឺជាអានិសង្ស
ដូច្នេះបុត្រធីតា
ធ្វើដូចព្រោធិសត្វ

មានក្តីសៅហ្មងចំបែង
ឲ្យមកថ្វាយបង្គំសុំទោស ។
យាងមកជួយដោយសន្តោស
ចំពោះព្រះព្រោធិសត្វ ។
ទោសធ្ងន់ធ្ងរដែលភ្ញាក់ភ្ញាត់
ដកបញ្ចុះកាត់ចោលចេញ ។
ដោយខ្ជាប់ចិត្តមាតាមិញ
បំពេញកិច្ចកតញ្ញូ ។
បុរសតេជាទន្ទឹង
ខ្ញុំមកធ្វើទេស្ថា ។
ដែលមកជួយប្អូនអាត្មា
អស់កាលកើតជ្រុះថ្លា ។
មានចំនួនច្រើនមហិមា
ទៅជានឹងរៀងពាល់អង្គ ។
បម្រើអ្នកដោយចិត្តផ្តង់
ការបម្រើព្រោធិសត្វ ។
បានបញ្ចាគួរប្រែតបត្តិ
កុំឲ្យភ្លក់ប្រមាទអើយ ។

ចប់

ទាប់តាបថារឿងពុទ្ធរូបបុរាណ

ឃុនអត្ថកោវិទ ជា - ឃ្លូរ៉ា នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែអំពីទស្សនៈវដ្ដីដំណាំនសាសនា ឆ្នាំទី ១ ចាប់ទី ៦ (ភាសាថៃ)

ជាបឹកថារឿងនេះ ហ្លួងបវរិទាលបុរីកែលូ ជាអ្នកដំនាញក្នុងបុរាណតំនៃក្រមសិល្បការ បានថ្លែងឲ្យប្រជាជនស្ដាប់ នៅរបៀងព្រឹះវិហារវត្តបញ្ចមបពិត្រ ក្នុងការប្រុងព្រឹះពុទ្ធរូបប្រចាំឆ្នាំ សំរាប់វត្តនោះ នៅថ្ងៃទី ៤ ពុធ ព. ស. ២៤៩១ ដារឿងនៃលពុទ្ធសាសនិកជនជាតិយើង គួរសិក្សាឲ្យដឹងឲ្យច្បាស់លាស់ ។

សូមទូល សូមជំរាប ដល់ព្រះសង្ឃនឹងសាធុជន !

ខ្ញុំព្រះករុណា ខ្ញុំមានសេចក្ដីត្រេកអរជាពន្លឹក ដែលបានឧកាសមកសំដែងបាប់តាបថារឿង ព្រះពុទ្ធរូបបុរាណ ក្នុងថ្ងៃនេះ, តែមុនទំនឹងគោលអំពីរឿងព្រះពុទ្ធរូបបុរាណ ខ្ញុំសូមពន្យល់អំពីវត្ថុបំណង ដែលមានការប្រឡងព្រះពុទ្ធរូបកន្លងមកនៃឆ្នាំនេះជាមុនសិន ដូចតទៅនេះ :

ពុទ្ធសមាគមនៃប្រទេសថៃ នៅក្នុងព្រះបរមរាជូបត្ថម្ភព្រមទាំងគណៈវត្តបញ្ចមបពិត្រ មានសម្ដេចព្រះវន្តេក្នុងជាប្រធាន បានរួបរួមគ្នាបានឲ្យមានការប្រឡងឡើង ដោយមានវត្ថុបំណងឲ្យពួកប្រជាជន ដែលកាប់អានព្រះពុទ្ធសាសនា បានទស្សនាព្រះពុទ្ធរូបដែលប្រកបដោយមហាបុរិសលក្ខណៈ ដើម្បីបំពេញបំណងសង្គហកន្លងព្រះពុទ្ធសាសនាឲ្យជាកិយ្យាភាពឡើង ។ ព្រះពុទ្ធសាសនាបានចូលមកប្រតិស្ឋានៅក្នុងប្រទេសថៃនេះជាង ២.០០ ឆ្នាំមកហើយ តាំងព្រះពុទ្ធរូបក៏មានមកជាយូរយារណាស់ជិតដល់ ២.០០០ ឆ្នាំដែរ ។ ចំពោះប្រទេសយើងមាន

ព្រះពុទ្ធរូបច្រើនណាស់ចាំងច្រើនយុគច្រើនសម័យផង មានចាំងព្រះពុទ្ធ-
រូបដែលសាងរោយស្មាដៃដ៏អាក្រក់ ឲ្យគ្រាន់តែជាព្រះបដិមាករប៉ុណ្ណោះ
ក៏មាន ដែលល្អវិចិត្របញ្ចង់រហូតដល់ដឿីថាខេរតាចុះមកកសាងក៏មាន
ដូចជាព្រះពុទ្ធជិនពជនៅខែត្រពិស្ទុលោកជាដើម ល្អហួសវិស័យនៃថ្វីដៃ
ជាងមនុស្ស តែដែលពិតនោះមិនមែនខេរតាចុះមកសាងឡើយ គឺ
មនុស្សក្នុងសម័យនោះឯងសាងឡើង ។ ព្រោះបុគ្គលដែលជ្រះថ្លាក្នុង
ពុទ្ធសាសនាមានច្រើនពួកច្រើនជាន់ ពាប់តាំងអំពីព្រះមហាកស្សបត្ថេរជាដរាប
រហូតដល់សាមញ្ញជនឬអ្នកទំលែក, បណ្តាជនទាំងនេះ អ្នកមានទ្រព្យ
សម្បត្តិច្រើន គេអាចរកជាងដែលមានថ្វីដៃល្អ ។ មកសាងព្រះពុទ្ធរូបបាន
តាមចំណង់របស់គេ ចំណែកអ្នកទំលែកដែលមានបសាទសទ្ធាតែមិន
មានទ្រព្យសម្បត្តិ ក៏មិនអាចមើរកជាងដែលមានថ្វីដៃល្អមកសាងព្រះ
ពុទ្ធរូបឲ្យល្អបានទេ ក៏សាងតាមតែកំលាំងទ្រព្យនឹងកំលាំងសទ្ធារបស់
ខ្លួន ហេតុនោះទើបមានព្រះពុទ្ធរូបទាំងពីរយ៉ាងដូចគោលមកហើយ ។
តែបំណងក្នុងការប្រឡងគ្រានេះ ក៏ព្រោះហេតុថាព្រះពុទ្ធរូបមាន
ច្រើនជាន់ច្រើនសម័យនោះឯង ថាបើមានការដឹកនាំបណ្តាភ្ញៀវទស្សន
ដែលមានព្រះពុទ្ធរូបសំពាប់ប្លូជា យកមកប្រមូលគ្នាដើម្បីប្រឡងមើលឲ្យ
ដឹងថា អង្គណាប្រកបដោយមហាបុរិសលក្ខណៈល្អបែបណា ខ្វែង
គ្រាយបែបណា ជាធំនាន់ចាស់លើសគេយ៉ាងណា ក៏ជាហេតុឲ្យកើត
បសាទសទ្ធាជាកំយោគាតឡើង ។ ព្រោះសេចក្តីល្អជាគុណសម្បត្តិ
អាចដឹកនាំចិត្តឲ្យកើតសទ្ធាជ្រះថ្លា ប្រៀបដូចពួកយើងបានចូលទៅ

ថ្វាយបង្គំព្រះដ៏វ័ក្កឯវិហារ ១ បើយើញព្រះរូបល្អ ដូចអង្គព្រះដ៏វ័ក្កឯវិហារនេះ គឺថ្វាយបង្គំព្រះដ៏នពាជអង្គនេះក្តី ឬព្រះដ៏នពាជនៅពិស្ណុលោកក្តី យើងក៏នឹងកើតសេចក្តីជ្រះថ្លាជាន់ខ្ពស់ថ្វាយបង្គំព្រះដែលមានព្រះរូបអាក្រក់ បើយើងបានទៅអង្គុយចំពោះព្រះភក្ត្រព្រះពុទ្ធដ៏នពាជ ហើយរំលឹកព្រះពុទ្ធគុណ ត្រេកអាងបានទស្សនាព្រះបដិមាករ យើងក៏នឹងកើតសទ្ធាត្រេកអាងបរិសុទ្ធយ៉ាងចំឡែកអស្ចារ្យ ។ ចំណែកការលំអរបស់ព្រះពុទ្ធជាម្ចាស់នោះ លោកដែលបានរៀនពុទ្ធប្បវត្តិ គង់ជ្រាបច្បាស់ថា ព្រះពុទ្ធជាម្ចាស់ទ្រង់មានព្រះរូបឆោមដ៏ល្អល្អះ ប្រកបដោយមហាបុរិសលក្ខណព្យាករណាសាស្ត្រ, សេចក្តីល្អនេះឯងជាគ្រឿងដឹកនាំបណ្តាជនឲ្យកើតបរិសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាជាច្រើន សូម្បីព្រះក្តលិថេរដែលបានចូលមកបួសក្នុងព្រះពុទ្ធសាសនា ក៏ព្រោះតែវាគារចង់មើលព្រះរូបព្រះបរមសាស្តាប៉ុណ្ណោះ ព្រោះដូច្នោះទើបយើញថា សេចក្តីល្អជាគ្រឿងដឹកនាំបណ្តាជនឲ្យទន្ទឹងមកបំអានមួយយ៉ាងដែរ ។ ព្រះពុទ្ធអង្គទ្រង់មានព្រះរូបសម្បត្តិដ៏ល្អលើសលុប ព្រះពុទ្ធរូបស្មង ព្រះអង្គក៏ដូចគ្នាដែរ បើយើងបានទៅអង្គុយមើលព្រះពុទ្ធរូបដែលល្អ។ ក៏ជាហេតុឲ្យកើតបសាទសទ្ធាដ៏វៃលែង សូម្បីតែអ្នកដែលមិនធ្លាប់ជ្រះថ្លាក៏ទៅជាជ្រះថ្លាបាន ។ យើងខ្ញុំធ្លាប់បាននាំពួក"អ៊ីរុប"ទៅមើលបុកណារត្តនៅពិស្ណុលោក នៅពេលដែលចូលទៅថ្វាយបង្គំព្រះពុទ្ធដ៏នពាជក្នុងព្រះវិហារ អង្គុយត្រង់តុដែលសម្រាប់ឲ្យបណ្តាជនដាក់បច្ច័យបូជា ព្រោះទីត្រង់ណោះជាទីដ៏គួរដល់ការទស្សនា ពួក"អ៊ីរុប"ទាំងនោះមិនបានកាន់ព្រះពុទ្ធសាសនាទេ តែគេធ្លាប់

យើងខ្ញុំថា ព្រះពុទ្ធជិនពជណ្ណាស់ មានទ្រង់ទ្រាយសក្តិសមត្រឹមត្រូវ តាមឋានវណ្ណៈស់ គេច្បាប់ខ្ញុំថា គេអាចនឹងអង្គុយតែមើលប៉ុណ្ណោះ ចំពោះព្រះកត្តិព្រះជិនពជប៉ុន្នានមៅ៎ង ក៏អង្គុយបានដែរ ដោយគ្មានទ្រាន់ណាយអ្វីសោះឡើយ ព្រោះសេចក្តីល្អពិតនោះ អាចទាំមកនូវផលដោយប្រការដូច្នេះ ។ បើយើងមានព្រះពុទ្ធរូបដែលមានទ្រង់ទ្រាយល្អ ។ សំពាប់ជា ក៏ទឹងបន្ថែមសទ្ធាជ្រះថ្លាតែតែច្រើនឡើង ហើយយើងក៏នឹងនឹកដល់គុណរបស់ជាងជាន់ចាស់ ហើយនឹកដល់គុណរបស់អ្នកដែលបានថែរក្សាព្រះពុទ្ធរូបមុនៗណាទុករហូតដល់យើងបានធ្វើសក្ការៈបូជាសព្វថ្ងៃនេះ ។ តែមានការចំឡែក ១ យ៉ាង គឺពុទ្ធសាសនិកជនដែលកាប់អានព្រះពុទ្ធសាសនា ច្រើនតែមានព្រះពុទ្ធរូបគ្រប់ៗផ្ទះ តាំងអំពីផ្ទះអ្នកធំរហូតដល់ផ្ទះជនសាមញ្ញ តែមិនសូវមានអ្នកណាបួលចិត្តរៀនលក្ខណៈរបស់ព្រះពុទ្ធរូបដែលខ្លួនគោរពបូជានោះ មានព្រះពុទ្ធរូបដូចម្តេចក៏ដោយ ក៏ដឹងតែតាំងប៉ុន្នឹងប៉ុណ្ណោះ ទោះបីកន្លងវត្តណាក៏ដោយ គេបួលទៅថ្វាយបង្គំព្រះដែលវត្តនិមួយ ក៏ចេះតែថ្វាយបង្គំទៅ មិនសូវចេះគិតថាអ្នកណាសាងហើយសាងពីកន្លងសម័យណា ស្នាដៃជាងដែលសាងល្អឬអាក្រក់ យើងមិនសូវយកចិត្តទុកដាក់កន្លងបៀបតាំងនេះ ខុសពីពួកអ៊ីរ៉ុបសូម្បីដោយច្រើនគេមិនបានកាន់ព្រះពុទ្ធសាសនា តែកន្លងពិពិធភ័ណ្ឌច្រើនគេ ក៏មានព្រះពុទ្ធរូបដែរ ហើយគេអាចអធិប្បាយច្បាប់យើងបានថា ព្រះពុទ្ធរូបបែបនោះសាងកន្លងយុគនោះ ឬកន្លងសត្តវត្សរ៍នោះ គេដឹងច្បាស់លាស់ជាងយើងដែលជាពុទ្ធសាសនិកជន ។ ឬនេះ

កាលខ្ញុំនៅធ្វើការក្នុងហោរព្រះសម្តែត នៅពេលរសៀលចុងរដូវកាលទី ៦ តាំង
ពីមានព្រះពជបញ្ញត្តិដំណាយពីការថែរក្សាបុពណវត្តគ្រាដំបូង ខ្ញុំទទួល
តំណែងជាកូឈួយចាងហ្វាងបុពណវត្ត (សាស្ត្រាចារ្យសិក-ស៊ុំដែស)
ខ្ញុំក៏ចាប់ផ្តើមរៀនលក្ខណៈរបស់បុពណផ្សេងៗ ដើម្បីឱ្យមានសមត្ថភាព
ក្នុងការពិនិត្យបុពណវត្ត ។ បណ្តាបុពណវត្តផ្សេងៗនោះ មានព្រះ
ពុទ្ធរូបរួមនៅផងដែរជាច្រើន ខ្ញុំចាប់យកចិត្តទុកដាក់សិក្សាលក្ខណៈព្រះ
ពុទ្ធរូបយ៉ាងម្តងម៉ាត់ សារជាវគ្រាមើលរូបក្នុងតំបន់ផ្សេងៗ ខ្លះ ដើរ
មើលតាមវត្តផ្សេងៗ ខ្លះ ។ ថ្ងៃមួយខ្ញុំបានសួរអ្នកធំម្នាក់ដែលជាកម្មការ
ហោរព្រះសម្តែតក្នុងពេលនោះថា ហេតុអ្វីជនជាតិឯង គេមិនសូវ
សិក្សាលក្ខណៈព្រះពុទ្ធរូបរបស់ខ្លួនឯង គេឆ្លើយថា ស្រុកយើងមិនខាន់ស៊ីវិទ្យា
ដល់ថ្នាក់នោះទេ ។ ខានេះជារឿងដែលពិតដូច្នោះមែន, ខ្ញុំដើរសួរ
អ្នកដទៃទៀតជាច្រើន ក៏មិនសូវមានអ្នកណាដឹងរឿងនេះជាពិតប្រាកដ
មានដឹងខ្លះតែជារឿងដែលតុំតែងថា ដែលមិនមែនជាទ្វារវិទ្យាសាស្ត្រ
ដ៏ពិតប្រាកដឡើយ ប្តូរមិនមែនជាទ្វារស្រាវជ្រាវផ្លូវគេដើមរកចុង ។
មកថ្ងៃនោះបានប្រាប់ខ្ញុំទៀតថា គ្មានអ្នកណារៀនទេ ព្រោះមានទំនៀម
ប្រកាន់ថា- អ្នកណាចាប់ពាល់ព្រះពុទ្ធរូបមានបាបដល់ខ្លួន ដើរស្តីផង
ហើយ រឹតតែមិនហ៊ានចាប់ជ្រៀតជ្រែកសោះតែម្តង ។ ខ្ញុំឆ្ងល់ថា ដែលលោក
ថានេះមិនពិតទេ ព្រោះមិនដែលឮមានក្នុងគម្ពីរណានិយាយថា ចាប់ពាល់
ព្រះពុទ្ធរូបមានបាបនោះទេ បើទុកជាមានបាប យើងក៏អាចសូមទោស
បានដែរ ដូចក្នុងពាក្យសូត្រថ្វាយបង្គំព្រះពេលល្ងាច អាលស្សូត្រ

សរសើរព្រះពុទ្ធគុណចប់ហើយ ក៏ត្រូវក្រាបថ្វាយសួរថា:

កាយេន វាចាយ ឥតេសា វា ពុទ្ធេ កុកម្មំ បកតំ មយា យំ
ពុទ្ធោ បដិគ្គណ្ហតុ អច្ចយន្តំ កាលន្តរេ សំវរិតុំ ឥ ពុទ្ធេ

ប្រែថា «ខ្ញុំព្រះករុណាបានប្រព្រឹត្តល្មើសកន្លងព្រះពុទ្ធជាម្ចាស់ ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី សូមព្រះពុទ្ធអង្គទ្រង់អត់ទោសដល់ខ្ញុំព្រះករុណា ដើម្បីសំរួមក្នុងព្រះពុទ្ធជាដរាបតទៅ» ។ នេះជាពាក្យសូមខមាទោសដែលពុទ្ធបរិស័ទធ្លាប់ប្រដិបត្តិមក; បើពាក្យសូមខមាទោសមានហើយ ហេតុអ្វីក៏នៅតែចាត់ការលើមិនបាន? មន្ត្រីខោះឆ្លើយមកខ្ញុំវិតថា ទោះបើមានពាក្យសូមខមាទោសបានក៏នៅតែមិនមានអ្នកណារៀនព្រោះរៀនចេះហើយ ក៏មិនបានអ្វី ខ្ញុំឯណាស់រដ្ឋាភិបាលយកធ្វើការ ២-៣ នាក់ហើយឲ្យឆ្លាក់ខែបន្តិចបន្តួចតាមតែយើងនឹងប្រាន់ បើដូច្នេះមានអ្នកណានឹងចង់រៀន ។ នេះប្រកាន់តែញាតិដូច្នោះដែរ ព្រោះថាបើគ្មានការតាក់តែងដោយការចិញ្ចឹមជីវិតទេ មិនមានអ្នកណាចង់រៀនសោះឡើយ ព្រោះមនុស្សត្រូវតែរកស៊ីការរៀនតែចំណេរវិស្សាដែលចិញ្ចឹមជីវិតបាន ។ សេចក្តីនេះជារឿងពិត ចំណែកណាដែលតក់ឆ្លាក់ដោយការចិញ្ចឹមជីវិតត្រូវតែរៀន បើមិនដឹងសូមអញ្ជើញទៅសួរចំនែលលក់បុកណាវត្តខោកាលជាសរៈឡើយ ណាខន ឡើយ) ម្ចើលចុះ សួរគេថាព្រះពុទ្ធរូបអង្គនេះសាងកន្លងសម័យណា គេនឹងឆ្លើយឲ្យដឹងជាមិនខាន សាងកន្លងសម័យខោះ សត្វតស៊ូរកស៊ីប៉ុណ្ណោះ ហើយបើដាក់ណាក្នុងដែលខាស់ជាងគេ គេ

កំរ៉ាយតម្លៃយ៉ាងថ្លៃទីបំផុត ។ ខ្ញុំនេះបញ្ជាក់ឲ្យឃើញថា ចេះចំណេះណាគេប្រើក្នុងការអាជីពហើយ គេត្រូវតែរៀនឲ្យចេះឲ្យដឹងដោយខាន មិនបាន ព្រោះជាប្រយោជន៍ក្នុងការស្វែងរកប្រាក់កាសឲ្យតែតែចំណេញច្រើនឡើង ។ ក្នុងពេលនេះអ្នកដែលរៀនដោយមិនប្រាថ្នាចង់ប្រកបអាជីពក៏មានច្រើនណាស់ដែរ តែដោយច្រើន ច្រើនតែអ្នកដែលមានចំណេះប្រកបអាជីពស្រេចហើយ រៀនរឿងព្រះពុទ្ធរូប រួបរួមព្រះពុទ្ធរូបឬសិក្សារឿងព្រះពុទ្ធរូប,ជាការពិសេស តែការពិសេសនេះ ពួកអ៊ីរ៉ុបប្រកាន់ថាជាការសំខាន់ជាងការញ៉ឹមដំរិតទៅទៀត អ្នកដែលមានកន្ត្រឹងកន្តែកក៏ព្រោះតែគេបានធ្វើការពិសេស ដូចជាសម្តេចក្រុមពញាតម្រង់ជាងទុគាព, ការពាដការបេស់ព្រះអង្គដោយច្រើនជារឿងដែលទាក់ទងដោយការគ្រប់គ្រងស្រុកទេស ទំនាការសិក្សា; រឿងពិនិត្យព្រះពុទ្ធរូបជាការពិសេសរបស់ព្រះអង្គ ព្រោះដូច្នោះទ្រង់ទើបមានព្រះកំតុំយសប្រាកដខ្ចរសៀកក្នុងនានាប្រទេស គ្រប់ៗសមាគមទំនាគ្រប់មន្ទីរសមោសរ ដែលទាក់ទងដោយវិជ្ជាសេចក្តីចេះដឹង គេរមួលស្គាល់ទ្រង់ថាជាអ្នកចេះដឹង ១ ក្នុងលោក សឹងតែអញ្ជើញស្តេចឲ្យទៅជួយគុបត្តម្ភកំមាន ឲ្យស្តេចទៅជាសមាជិកកិត្តិយសក៏មាន ឲ្យទៅធ្វើ ប្រធានប្តូរធ្វើជាអ្វីដទៃទៀតក៏មាន ចំណែកវិជ្ជាការគ្រប់គ្រងស្រុកប្រទេស នំាការសិក្សានោះមិនសូវមានអ្នកណាស្គាល់ព្រះអង្គប៉ុន្មានទេ ខ្ញុំលស្គាល់ទ្រង់តែក្នុងរង្វង់ការដែលទ្រង់កាន់តាប់ប៉ុណ្ណោះ បើវិជ្ជាការខាងក្រុកណាគតិវិញ ច្បាស់ជាស្គាល់ទ្រង់ខ្ចទៅទាំងលោក ។ ម្យ៉ាងវិញទៀតមន្ត្រីនោះបានប្រាប់ខ្ញុំថា

ក្បួនតំ"ដែលនឹងយកមករៀនលក្ខណៈព្រះពុទ្ធរូបបុរាណនោះមិនមាន បើ
មានខ្លះច្រើនតែជាភាសាអឺរ៉ុប ឬភាសាបាលី ដែលមនុស្សធម្មតាមើល
មិនបាន ។ តាមការពិតរឿងនេះដូច្នោះមែន អំពីដើមសៀវភៅរៀន
លក្ខណៈព្រះពុទ្ធរូបចាំងនោះកម្រនឹងរកបានណាស់ តែឥឡូវនេះមាន
ច្រើនបែបហើយ រឿងនេះព្រះពុទ្ធរូបបុរាណនេះ បុព្វបុរសយើងត្រូវការ
ឲ្យយើងសិក្សាសូត្ររៀនណាស់ ទើបលោកព្យាយាមតែងតម្រាយ៉ាង
ល្អៗ ដែលត្រូវប្រើជាបែបសិក្សាខុសច្រើនយ៉ាង ដូចសៀវភៅព្រះពោធិ-
រង្សី ពួកឡាន-ណា-ថៃតែង, សិហិង្គនិទាន ដំណាលរឿងព្រះពុទ្ធ
សិហិង្គ ហើយព្រះព្រហ្មពជបញ្ញា ពួកសុខោថៃ (សុខោថៃ) តែង,
រតនពិម្ពវង្ស គឺរឿងព្រះកែវមរកតនេះជាតម្រាបុរាណដែលយើងធ្លាប់ពាប់
អានសិក្សាសូត្ររៀនមកជាភាសាបាលី តែឥឡូវនេះប្រែជាភាសាថៃ
ហើយ អ្នកដែលមិនចេះភាសាបាលីត្រូវរកសៀវភៅដែលជាភាសាថៃមក
សិក្សាចុះ ។ (មានត)

រឿងអ្នកស្នេហាជាតិ សាសនា មហាក្សត្រ

ឃុនបណ្ណាឧរ៉ែក្ស ប៊្រ-ប៊្រ ស្រង់ចេញតម្រាផ្ទេង ។

គំនិតរបស់អ្នកដឹកស្រង់

រឿងអ្នកស្នេហាជាតិនេះ ដើម្បីទំនងជួយស្រោចស្រង់ប្រទេសជាតិ, ជួយទ្រទ្រង់ព្រះពុទ្ធសាសនា, ជួយដំកើងព្រះមហាក្សត្រ ទំនងជួយសង្គ្រោះអ្នកជាខ្មែរនេះ មិនមែនខ្ញុំតែងតាមគំនិតខ្លួនខ្ញុំទេ គឺខ្ញុំបានដកស្រង់យកមកអំពីច្បាប់ផ្សេង ។ ដែលលោកជាន់ដើមបានតែងទុកស្រាប់ហើយ ។ ខ្ញុំគ្រាន់តែស្រង់ដោយសេចក្តីសង្ឃឹមយកមកប្រមូលទុកក្នុងនេះ ។

រឿងនេះ ខ្ញុំយល់ឃើញថា មានសារប្រយោជន៍ជាយ៉ាងសំខាន់ណាស់ដល់មនុស្សគ្រប់ប្រភេទ ទាំងប្រុសស្រី ទាំងក្មេងចាស់ ទាំងគ្រហស្ថបព្វជិត ទាំងភស្តុមន្ត្រី ។ ដ្បិតមនុស្សគ្រប់រូបដែលកើតមកក្នុងលោកនេះ ដែលខ្លឹងមានជីវិតរស់នៅជាសុខសប្បាយបានដោយសារតែប្រទេសជាតិប្តីប្តង់រុងរឿង, ដែលប្រទេសជាតិបានរុងរឿងក៏ដោយសារតែអ្នកប្រទេសនោះប្រតិបត្តិតាមសាសនាធង គោរពធ្វើតាមច្បាប់នៃព្រះមហាក្សត្រផង ជួយសង្គ្រោះគ្នាគោរពគ្នាទៅវិញទៅមកផង ។

ហេតុនេះ យើងគួរយកតម្រាប់តាមអ្នកស្នេហាជាតិ សាសនា មហាក្សត្រ ដូចមានទំនាក់ទាក់នេះ ។

១— រឿងអ្នកស្ងប់រំងាប់ជួយប្រទេសជាតិ

រឿងអ្នកឧញ៉ាមនោមេត្រី (១)

កន្លងផុតកាលនៃព្រះបរមកជាពញា តន់ ៣. ស. ២១៣០ គ. ស. ១៥៨៦ នៅប្រទេសខ្មែរ ចាប់ផ្តើមចាំងទឹងប្រទេសសៀម ។ គ្រានោះ មានមន្ត្រីខ្មែរម្នាក់ឆ្មារជា ឧកញ៉ាមនោមេត្រី ចេវហ្វាយស្រុកចាត់ដំបងទឹង ឧកញ៉ាបរិនាយក ចាប់ដឹងថាកងទ័ពខ្មែរដែលឲ្យលើកទៅកាន់ទប់ទ័ពសៀមនោះ តឡូវចាញ់ទ័ពសៀម។ ពួយគេចាប់ខ្លួនបានច្រើន ។

ឧកញ៉ាចាំងពីនោក់ប្រឹក្សាទឹងមេទ័ពចាំងពួងថា "ទ័ពសៀមលើកមកជាន់នេះក្លៀវក្លាណាស់ ដ្បិតទ័ពព្រះមហាក្សត្រសៀមគាន់តែមកដឹតដល់ខ្មែរយើងហើយ យើងទឹងច្បាំងឬ ដូចម្តេច?" ។ មេទ័ពចាំងពួងឆ្លើយថា "ការដែលព្រះបាទអ្នកអម្ចាស់គ្រាស់ប្រើយើងមកនេះ ដើម្បីឲ្យធ្វើសង្គ្រាមទឹងសៀម បើយើងមិនចាន់បានច្បាំងសោះ ហើយលើកទ័ពថយទៅវិញ ឲ្យស្រុកឆ្កាក់ទៅដៃពួកសត្រូវទេ។ នោះយើញជាការមិនគួរ ខុសទឹងព្រះពួកអាជ្ញា គួរតែយើងច្បាំងល្បងមើលកំច្បាំងសិន បើមិនឈ្នះគេទេ ចាំថយទៅតតាំងច្បាំងនៅខ្មែរពោធិសាត់ទៀត" ។

លោះនោះ អ្នកឧកញ៉ាមនោមេត្រីទឹងមេទ័ពចាំងពួងយល់ព្រមព្រៀងគ្នា ទើបចាត់កងទ័ពឲ្យលើកទៅចោមព័ទ្ធពួយបង្ហួយសៀមទៅ

---

១ សូមចាកច្បាប់ត្រួតពិនិត្យសង្ឃរាជខ្មែរ ភាគ ទី ៤ អត្ថបទដែ ត្រង់ទំព័រលេខ ២៥៥-២៦១ មានក្នុងពុទ្ធសាសនបណ្ឌិត្យ ។

ស្ទឹងគ្នោត; ទ័ពខ្មែរចាញ់ទ័ពសៀមរត់ដោះថយមកតាំងបន្ទាយនៅខែត្រ
បាត់ដំបងវិញ ។ អ្នកទុកញ៉ាំងពីរដងឮថាទ័ពសៀមលើកតាមមកទាន់
ហើយ ក៏លើកទ័ពចេញច្បាំតទល់នឹងទ័ពសៀម ។ ពេលនោះ ទុកញ៉ា
បវរនាយកត្រូវគ្រាប់កាំភ្លើងស្លាប់ក្នុងសង្គ្រាម ។ ទុកញ៉ាមនោមេត្រី
ឃើញទុកញ៉ាបវរនាយកស្លាប់ដូច្នោះហើយ ក៏ទឹកភ្នែកចិត្តណាស់ បង្គាប់
ឲ្យបក់ទន់ដ៏យថយទ័ពចូលបន្ទាយវិញ ។

ព្រះនរេន្ទសូរស្តេចសៀមលើកទ័ពតាមមក ឲ្យចាមព័ន្ធបន្ទាយខ្មែរ
នៅបាត់ដំបង ។ បណ្តាកស្តេចខ្មែរឃើញទ័ពស្តេចសៀមលើកមកជាច្រើន
ដូច្នោះ ក៏មានចិត្តកិតក៏យជញ្ជួនព្រួយសម្បុត្ត ប្រពន្ធកូនចៅរត់ចូលពួន
ព្រៃអស់ ។ ពួកពលសៀមឃើញផ្ទះទទេគ្មានមនុស្សនៅ ក៏ដើររើជញ្ជួន
យកទ្រព្យរបស់ដែលសេសសល់ត្រមាំងស្រូវអង្ករយកជាស្បៀងអាហារ
អស់ហើយ ក៏ដុតផ្ទះសម្បែងនេះអស់ ផ្សែងភ្លើងហុយងងិតគគុំមេឃ ។

ទុកញ៉ាមនោមេត្រីដឹងដូច្នោះហើយលែងគិតខ្វាចស្លាប់ ព្រោះ
អាណិតបណ្តាកស្តេណាស់ ស្រែកប្រកាសប្រាប់សេនាពាហានថា ។ ព្រះ
ចៅក្រុងស្រីអយុធ្យាលើកទ័ពមកជាន់នេះ ដោយចំណងនឹងយកក្រុង
កម្ពុជាជាចំណុះឲ្យបាន ខែត្រយើងនេះជារនាំងព្រះនគរ បើគេវាយខែត្រ
យើងនេះបែកហើយ គេនឹងទៅដល់ក្រុងពុំខាន មួយទៀត យើងជាប់
ក្នុងចំណោមគេហើយ ប្រៀបដូចជាដំរីជាប់ប្រកាំនឹងស្រឡៃពុំបាន ត្រូវ
តែគិតដោះពីប្រកាំឲ្យរួចទើបហៅថា ដំរីសារ ជាតំណាប្រុសត្រូវខ្វាច
សង្គ្រាម ទើបហៅថាប្រុស ឥលូនេះយើងកុំស្តាយជីវិត ស៊ូយកឈាម

លាបផែនដី ទុកក្តីរំឭកឲ្យសេនាគហានខាងក្រោយដឹងថា ខ្ញុំឯកញ៉ាមនោមេត្រី មានចិត្តកតញ្ញូទឹងព្រះបាទអ្នកជាអម្ចាស់ស៊ប់ជីវិត ហេតុនេះត្រូវតែយើងលើកទ័ពចេញច្បាំងតទល់នឹងទ័ពព្រះមហាក្សត្រសៀម ឲ្យអស់ដំរេះ តើអ្នកពល់គ្នាយល់ដូច ម្តេច?" ។ មេទ័ពទាំងអស់ឆ្លើយថា "យើងខ្ញុំពល់គ្នាក៏មិនស្តាយជីវិតដែរ ទ័ពសៀមជាទ័ពព្រះមហាក្សត្រ យើងជាទ័ពខែត្រក្រៃតនឹងព្រះមហាក្សត្រពុំបានទេ ប៉ុន្តែស៊ប់ច្បាំងឲ្យយើញថ្វីដៃ" ។ ឯកញ៉ាមនោមេត្រីឮដូច្នោះ ក៏ត្រេកអរណាស់ទើបចាត់សេនាគហាន ១ ម៉ឺនឲ្យចេញច្បាំងនឹងទ័ពសៀម ខ្លួនឯងដឹះដំរីនាំពលចេញច្បាំងឥតខ្វាចស្លាប់ ។

សម្តេចព្រះនរេន្ទ្រសូរទេតពីលើដំរីព្រះទីនាំងទៅយើញឯកញ៉ាមនោមេត្រីនៅលើដំរីបែរពលចូលច្បាំងឥតក្តីកដូច្នោះ ក៏មានព្រះទ័យស្រឡាញ់ឯកញ៉ាមនោមេត្រី ។ វេលានោះ ដំរីដែលឯកញ៉ាមនោមេត្រីដឹះនោះត្រូវគ្រាប់កាំភ្លើងដួលទៅ ។ ឯកញ៉ាមនោមេត្រីលោតចុះពីលើដំរីហួតជាវនាំពលចូលប្រកាប់ទឹងសេនាសៀម ។ ព្រះនរេន្ទ្រសូរត្រាស់បង្គាប់ឲ្យចាប់ឯកញ៉ាមនោមេត្រីនាំឆ្ពោះមក ។ ឯកញ៉ាមនោមេត្រីលុតជង្គង់ថ្វាយទ្រង់ ។ ត្រាស់សួរថា "អ្នកឯងធ្វើរាជការអ្វី? ។ – ទូលព្រះបង្គំធ្វើរាជការឯកញ៉ាមនោមេត្រី ទៅហ្វាយស្រុកចាត់ដំបងនេះ ។ – ចុះអ្នកឯងមិនដឹងថាយើងជាមហាក្សត្រទេឬ ចានជាហ៊ានលើកទ័ពមកច្បាំងនឹងយើង? ។ – ទូលព្រះបង្គំជាខ្ញុំដឹង ប៉ុន្តែគិតយើញថា ធម្មតាអ្នកធ្វើជាខ្ញុំផែនដីគួរតែមានចិត្តកតញ្ញូទឹង

អម្ចាស់ ត្រូវយកដីតែឆ្នូតព្រះតេជៈព្រះគុណ ហើយខ្ញុំលព្រះបង្គំជាមន្ត្រី មានថ្វីដៃ ដែលគិតស្មាយដីតែដូចជាស្តុំមិនពេញជាប្រុសទេ អស់ខ្ញុំ ភជការកើតមកតន់តែស្ងាប់ដូចគ្នា ល្អអាក្រក់តាមកុសលអកុសល ធម្មតាឆ្កើសឆ្លាមតែងតែចាញ់ទីឆ្កែ គួរតែយកដីតែខ្លួនជូរទើងផែនដី ទើបពេញជាមន្ត្រី ។

ព្រះនរេន្ទ្រប្រទានទ្រង់ព្រះសណ្តាប់ពេញព្រះទ័យណាស់ ទ្រង់ សរសើរក្នុងព្រះទ័យថា គេញ៉ាំមនោមេត្តានេះមានចិត្តក្លាហានមែនប្រកប ដោយសត្យកតញ្ញូគួរតែអញ្ជើញទុក ទើបត្រាស់ថា "វេលានេះដីតែ អ្នកឯង ខៅក្នុងកណ្តាប់ដៃយើងហើយ តែយើងអាណិតមិនសម្លាប់ អ្នកឯងឡើយ ត្រូវអ្នកឯងនាំគ្នាសារមៅថ្វាយបង្គំយើងដោយស្រួលចុះ យើងមិនធ្វើអន្តរាយដល់អាណាប្រជាទុកស្លាប់ទេ" ។

ទេវញ៉ាំមនោមេត្តិ៍បានស្តាប់ព្រះតម្រាស់ហើយគិតថា "វេលានេះ ដីតែអញនៅក្នុងកណ្តាប់ដៃភជសត្រូវហើយ គួរតែអញទទួលត្រមតាមទៅចុះ ដើម្បីទីបានរក្សាប្រជាពលស្លាប់ក្នុងខែតទៅ បើសិនមធ្វើការ ចរយដៃអញទីឆ្លើតទំពាយផ្តាច់ពីក្បាយទៀត" គិតហើយទើបត្រាប ទូលដោយផ្តាំទេចាយតលថា "ការដែលទ្រង់ព្រះមេត្តាប្រទានកន្ទុងដីតែ ទូលព្រះបង្គំក្នុងគ្រានេះ ទូលព្រះបង្គំជាខ្ញុំទទួលតាម ប៉ុន្តែសូមព្រះពុទ្ធ អនុញ្ញាតកុំឲ្យកងទ័ពសៀមធ្វើបាបបណ្តាពលស្រុកខ្មែរ" ។ ស្តេចសៀម ក៏ព្រមអនុញ្ញាត ទើបឲ្យទេវញ៉ាំមនោមេត្តិ៍ទទួលដីតែនិងកូនស្តាប់ប្តូរប្រែ ស្រេច ឲ្យវាំនាំគ្រមការទីនិមេទ័ពមកតាល់ ។

ទុកញ៉ាំមនោមេត្រីម្យ៉ាយបង្គិលាបូលទៅក្នុងបន្តាយប្រដុំអស់ក្រមការបណ្តាកស្តែប្រាប់ថា ‘‘វេលានេះយើងគាល់តម្រែហើយ ត្រូវតែចុះបូលសិនទៅចុះ សិមគិតការតាមតម្រែប្រាជ្ញាខាងក្រោយ ហើយនាំក្រមការទាំងពួងទៅគាល់ព្រះទេវេន្ទសូរ។ ខ្ញុំត្រាស់ប្រសោមលួងសោមថា ‘‘យើងលើកទ័ពមកនេះ មិនមែនប្រឆាំងធ្វើបាបឱ្យអ្នកទាំងពួងបានសេចក្តីក្តៅក្រហាយទេ ដ្បិតយើងឮថាព្រះចៅក្រុងកម្ពុជាពុំប្រកបដោយទសពិធកដ្ឋធម៌ដូតរំលងព្រះភុទ្ធបដិមាកអំពីបុពណាចោលអស់ ធ្វើព្រះពុទ្ធសាសនាឱ្យសៅហ្មង យើងលើកទ័ពមកនេះប្រយោជន៍ទំនងធ្វើឱ្យវែនដីទាំង ៤ ឱ្យជាប់ជាព្រះពាជមេត្រីនឹងគ្នាដូចពីដើមវិញ ជាវិញ្ញាំងព្រះពុទ្ធសាសនាឱ្យរុងរឿង អ្នកទាំងអស់ចូរនាំគ្នាត្រឡប់ទៅភូមិលំនៅវិញចុះ’’ ។ ព្រះទេវេន្ទសូរត្រាស់យ៉ាងនេះរួចយកព្រះទ័យបំណងថា ទំនប្រមូលគ្នាខ្មែរយកទៅស្រុកស្រួច ។

អាណាប្រជាពស្តែខ្មែរឮព្រះតម្រាស់ដូច្នោះហើយត្រេកអរណាស់នាំគ្នាទៅនៅតាមភូមិលំនៅរបស់ខ្លួនដូចដើមវិញ ។

* * *

២— រឿងអ្នកស្លូបរំលឹកជួយព្រះពុទ្ធសាសនា

រឿងអ្នកតាគុយ (១)

កាលនោះស្រុកកូសាំងស៊ីនទៅជារបស់ខ្មែរទៅទៀត ។ មានព្រះ

---

១ ស្រង់ចេញពីសៀវភៅកម្ពុជសុរិយា ឆ្នាំ ១៩២៨ ។

មហាក្សត្រីខ្មែរ ១ ព្រះអង្គ ព្រះនាម អង្គីម៉ី ជាព្រះពុទ្ធបុត្រីនៃព្រះបាទ
អង្គប៉ិង្ហ បានសោយរាជសម្បត្តិគ្រប់គ្រងដែនដីខ្មែរ ។

កន្លះផ្នត់កាលនៃព្រះអង្គម៉ីនោះ (ព. ស. ១៨៣៤ ដល់ ១៨៤១)
មានយួនម្នាក់ឈ្មោះ ខ្វែង-មិញ-យ៉ាង ជាសេនាធិបតីហានធំរបស់ស្តេច
យួនលើកទ័ពមកច្បាំងដណ្តើមយកទឹកដីខ្មែរ ។ ស្តេចអង្គម៉ីបរាជ័យចាញ់
ទ័ពយួន ។ ដណ្តើមយកបានទីដាំព្រៃនគរ, មីថរ, ឡុងហោ, ផ្សារដែក,
ចាសាក់, ព្រះត្រពាំង ។

ព្រះអង្គម៉ីសោយរាជ្យបានតែ ៧ ឆ្នាំទៀតទេ ។ ក្រោយនោះ
ពួកយួនមានអំណាចដិះដាន់ញ៉ាំញីបណ្តាជនខ្មែរ ទាំងព្រះពុទ្ធសាសនាខ្លាំង
ណាស់ បង្គាប់ឲ្យពួកលោកសង្ឃខ្មែរស្លៀកខោពាក់អាវ ដូចជាពួក
លោកសង្ឃយួន ។ កន្លះសម័យនោះ មានចៅហ្វាយស្រុកនែ្នម្នាក់ឈ្មោះ
ពុំយ៉ែ ជាអ្នកត្រួតត្រាក្បាលខែ្មរនេះ ប៉ុន្តែនៅកន្លះអំណាចយួន លោកទឹក
តូចចិត្តពេកណាស់ ដោយបានឃើញពួកយួនដិះដាន់ជាតិខ្មែរញ៉ាំញីព្រះ
ពុទ្ធសាសនាច្បាច្បាន់ទាំងបំបាត់កេសមណៈដូច្នោះ លោកទឹករលឹកដល់
គុណព្រះពុទ្ធសាសនា ហើយកើតសទ្ធាដ្រះថ្លាដ៏មានកំឡាំងខ្លាំងក្លាអាច
ហ៊ានប្តូរជីវិតការពារជួយព្រះពុទ្ធសាសនា ទើបលោកចូលទៅនិយាយទាំង
ពួកអ្នករាជការយួនថា "បណ្តាជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា
ហើយបានលះបង់ផ្ទះសម្បែង ទៅសម្បត្តិ ប្រពន្ធកូន ចូលមកកាន់កេសជា
សមណៈនេះ ត្រូវតែស្លៀកសង្ឃាក់ចិវរតាមបែបបទច្បាប់លោកសង្ឃខ្មែរ
ទើបហៅថាជាអ្នកបួសដោយត្រឹមត្រូវ មិនត្រូវឲ្យស្លៀកខោពាក់អាវ

ដូចជាពួកលោកសង្ឃយួនទេ” ។ ពួកអ្នកភជការយួនមិនត្រេមស្តាប់ចេះតែបង្ខិញាំញីបៀតបៀនលោកសង្ឃខ្មែរឲ្យស្លៀកខោពាក់អាវ ដូចលោកសង្ឃយួន ។

លោកចៅហ្វាយស្រុក គុយ ឃើញដូច្នោះ អត់ទ្រាំមិនបាន ក៏កាត់ចិត្តស៊ូប្រថុយជីវិតខ្លួនប្តូរនឹងព្រះពុទ្ធសាសនា ចូលទៅនិយាយនឹងអ្នកភជការយួនម្តងទៀតថា “ខ្ញុំសូមឲ្យគេអ្នកឯងនឹងកិច្ចការក្នុងព្រះពុទ្ធសាសនាខ្មែរ ដែលតាំងនៅក្នុងស្រុកនេះប្រែតិបត្តិដូចពីដើមវិញ ចើលោកយល់ព្រមតាមខ្ញុំសុំនេះហើយ សូមលោកសម្លាប់ខ្ញុំចុះ” ។ ភជការយួនក៏សុខចិត្តព្រមទទួលធ្វើតាមសម្តីហើយ ទុកគេអ្នកឯងនឹងកិច្ចការខាងព្រះពុទ្ធសាសនារបស់ជាតិខ្មែរឲ្យនៅដូចដើម ទើបប្រហារជីវិតលោកចៅហ្វាយស្រុក គុយ នោះទៅ ។ ក្នុងវេលាដែលគេសម្លាប់លោកចៅហ្វាយស្រុក គុយ នោះ បង្កើតជាហេតុគេដ៏អស្ចារ្យក្រៃលែងមេឃមីរស្រែះឆនឹតចុះអ័ព្ទ ភ្លៀងបង្អុរយ៉ាងខ្លាំងអស់ ៧ យប់ ៧ ថ្ងៃ ។

ក្រោយតំពេលនោះមក បណ្តាជនជាតិខ្មែរទាំងឡាយ បបួលគ្នាលើកសពលោកចៅហ្វាយស្រុកគុយ ធ្វើបុណ្យឈាបនកិច្ចរួចស្រេចហើយ ជាន់សាងចេតិយ ១ បញ្ចុះជាតុលោកទុកជាទីលើក ទៅក្នុងវត្តកំពង់ធំ ខែត្រត្រាំញ៉ូ ខាងទិសឦសាណវិហារ ។ ចេតិយនោះនៅមានរហូតមកដល់សព្វថ្ងៃនេះ ដោយមានអ្នកស្រុកចេះតែជួសជុលតៗគ្នាមក ។

រឿងលោកចៅហ្វាយស្រុក គុយ នេះ ប្រៀបដូចជាជនជាតិខ្មែរនោះដែរ កូសាំងស៊ីន ស្រឡាញ់កប់អានឹកគុណលោកមិនភ្លេចថាជាអ្នកស៊ូប្តូរជីវិត

ដួយ ខ្ញុំខ្ញែន់ព្រះពុទ្ធសាសនាមែន បានតាំនគោរពបូជាប្រកាន់ថាជាអ្នកតា សម្រាប់ដួយកិច្ចការបុណ្យទានក្នុងផ្លូវព្រះពុទ្ធសាសនា តាល់តែក្លាយ ទៅជាទំនៀមទម្លាប់ជាប់មកដល់សព្វថ្ងៃនេះ ។

* * *

៣— រឿងអ្នកស៊ូប្តូរជីវិតដួយព្រះមហាក្សត្រ

រឿងអ្នកតាឃ្លាំងម្រឿង (១)

ក្នុងរជ្ជកាលនៃព្រះស្តេចកន វង្សកញ្ញ (គ.ស. ១៩០៥ ដល់ ១៩៥១) ។ វេលានោះ ព្រះបន្ទូរជា ដែលគង់នៅឯស្រុកសៀមបាន ជ្រាបដំណឹងថា ក្នុងស្រុកខ្មែរតែ្តសឹកសង្គ្រាមច្បាំងគ្នាជាយូរឆ្នាំ ទើប ខ្ញុំគង់ធ្វើទុក្ខយកលវត់រួចពីស្រុកសៀមមកដល់ខែត្រជាត់ដំបង ខ្ញុំបញ្ជូន បញ្ជូលបណ្តាពស្តួធ្វើជាសេនាពាហនបានច្រើន ខ្ញុំនឹងលើកទ័ពមក វាយបន្ទាយនៅខែត្រពោធិសាត់ខ្មែត ។ វេលានោះទុកញ៉ាសូតាហោក តែវ ចៅហ្វាយស្រុកពោធិសាត់ជាមេទ័ពខាងព្រះស្តេចកនបានដឹងថាព្រះ ចន្ទកជាយោងមកតង់នៅខែត្រជាត់ដំបងហើយ ក៏កេណ្តាវេហ៍ពលបាន ១ ម៉ឺននាក់ឲ្យចាំរក្សាបន្ទាយស្រុកពោធិសាត់ ហើយធ្វើសំបុត្រទូលទៅព្រះ ស្តេចកនត្រាប់សេចក្តី ។

នៅក្នុងខែត្រពោធិសាត់នោះ មានតាម្នាក់ឈ្មោះ ម្រឿង បានដឹងថា ព្រះចន្ទកជាយោងត្រឡប់ពីស្រុកសៀមមកតង់នៅខែត្រជាត់ដំបងហើយ

---

១ ស្រង់ចាកក្បាប់ព្រះរាជឥតិវារៈ ភាគទី ៣ អក្សរនៃ ទ្រង់ទំព័រ ១៦០—១៦៤ មានខោពុទ្ធសាសនបណ្ឌិត្យ ។

គាត់ក៏ចំដើរបញ្ចុះបញ្ចូលប្រមូលញាតិសន្តានជាន់គ្នា ៣ ពាន់នាក់ចូលធ្វើជាកងទ័ពទុកញ៉ាសួគាលោក កែវ លុះដល់វេលាយប់ស្ងាត់ទាំងពួកសម្លាប់ទុកញ៉ាសួគាលោក កែវ ស្លាប់ក្នុងបន្ទាយ ហើយតាមឿនប្រកាសប្រាប់ហៅពលទាំងអស់កុំឲ្យកិតក៏យថា ព្រះមហាក្សត្រជាអម្ចាស់យើងនឹងយាងមកដល់ក្នុងវេលាព្រឹកស្អែកនេះហើយ ។

លុះព្រឹកឡើងព្រះចន្ទកាយាងមកដល់ខែត្រពោធិសាត់មែន ទើបតាមឿនទាំងក្រមការនឹងហៅពលចូលទៅថ្វាយចង្គាល់ទូលសព្វសេចក្តី ។ ព្រះចន្ទកាជាខ្លាំងត្រេកអរណាស់ត្រាស់សរសើរតាមឿនផ្សេងៗ ហើយចាត់ការឲ្យធ្វើបន្ទាយពាយចម្រូងក្នុងខែត្រពោធិសាត់យ៉ាងមាំមួន ។

ព្រះចន្ទកាជាខ្លាំងឡើងសោយពាជសម្បត្តិគ្រប់គ្រងក្រុងកម្ពុជា ក្នុងព្រះជន្ម ៣៦ ឆ្នាំ ក្នុងឆ្នាំជូតអដ្ឋស័ក ព.ស ២០៦០ គ.ស. ១៥១៦ ខ្លាំងព្រះមេត្តាក្រសាំងតាមឿនឲ្យធ្វើជាទុកញ៉ាសួគាលោកទៅហ្វាយស្រុកខែត្រពោធិសាត់ ហើយឲ្យធ្វើជាមេទ័ពផង ។ ឯទុកញ៉ាសួគាលោកមឿន ឃុនតាំងកូនប្រុសទាំង ៤ នាក់ឲ្យធ្វើជាមេទ័ពលើកទៅកាយខែត្រក្រគរ, ខ្ពង, ក្រឆ ជាមុខ ។

(មានត)

រឿងព្រះចាន្ទកុសក៏ន្ទសាជ

និង

ព្រះចាន្ទសេហវ៏ស្តាន៏

អ្នកស្រីពេត្រូ–សល់ ហៅ សារិះយ៉ាង ប្រែរៀបរៀង

ថ្ងៃមួយ ព្រះចាន្ទកុសក៏ន្ទសាជ ដែលជាយុវាក្សត្រមួយព្រះអង្គ សោយភោជសម្បត្តិនៅឧត្តរចិន, ទ្រង់ចាន់តែឃើញឈ្លូសមួយសស្គុះមានពណ៌ចុចខ្មៅហើយនឹងខ្លៃ ក្នុងពេលដែលទ្រង់យាងចេញទៅក្រសាលបរបាញ់ម្រឹគក្នុងព្រៃ ។ ឈ្លូសនោះមានកង់មាសមួយនៅដើង ហើយមានគ្រាលធ្វើអំពីសំពត់រលើបពណ៌ស្បែង ប៉ាក់ស៊ែសយប្រាក់នៅពីលើខ្នងផង ។ លុះទ្រង់ចាន់យល់សភ្លួចម្លែក ទ្រង់មានព្រះទ័យចង់ចាន់យកទុកជាសម្បត្តិរបស់ព្រះអង្គ ដើមទ្រង់ឲ្យអមាត្យនឹងកងពលបំផាយសេះតាមចាប់ ក៏ប៉ុន្តែឈ្លូសសនោះរត់លឿន ហើយបន្តើរៗដើងលើដី គ្មានឃើញធូលីកុយឡើងបន្តិចសោះ ។ ព្រះអង្គទ្រង់ខ្ជាល់ទឹងការដេញតាមឈ្លូសនោះមិនចាន់, តែបន្តិចមកស្រាប់តែទ្រង់ក្រឡេកព្រះនេត្រទៅឃើញឈ្លូសដេកនៅលើស្មៅ ក្បែរមាត់ត្រពាំងទឹកមួយមែបដូចជាអស់កំលាំងល្ហិចល្ហើយគ្រោតត្បួយពេក . ។ ព្រះអង្គទ្រង់ញាក់សេះឲ្យចោលសំដៅទៅដិតឈ្លូស, សត្វឈ្លូសលុះឃើញសេះចោលតម្រង់មកកន្លង ក៏ងើបឈរឡើងហើយដើរពីរបីជំហានពុះទៅកងទឹកស្រាប់តែចាត់មួយរំពេច ។ ព្រះចាន្ទកុសក៏ន្ទសាជទ្រង់លោតចុះពីលើពាជី ដើរតេមើលជុំវិញថ្កុកទឹក ចាចកក្លាកទឹក ក៏នៅតែរកមិនឃើញ

ខ្ញុំនឹកឆ្ងល់នឹងការអស្ចារ្យនេះណាស់ ទើបខ្ញុំព្រះដំរែះថា ឈ្មួសនេះ ប្រហែលមិនមែនសត្វតៃរ៉ាធម្មតាទេ គឺជាអាទិទេពមួយរូប ដែលចូលចិត្ត ដំណែងខ្លួនធ្វើជាសត្វ ដើម្បីនឹងមកប្រឡែងលេងនឹងពួកព្រានតៃរ៉ាទេដឹង? ។ ពួកអ្នកហែហមព្រះអង្គក៏ចូលចិត្តយល់ដូចព្រះអង្គដែរ ។

ក៏ប៉ុន្តែព្រះបាទវុសភ័នសាជ នៅតែឆ្ងៀងព្រះនេត្រទៅត្រង់ថ្កុកទឹកនោះទៀត ហើយចេះតែខ្ញុំជកដង្ហើមធំ មិនដឹងជាខ្ញុំគិតដូចម្តេច ។ បន្តិចមកខ្ញុំមានព្រះឧទ្គារទៅនឹងរដ្ឋមន្ត្រីធំម្នាក់ឈ្មោះ មុយអេស៊ីន ថា ៖

– យប់នេះខ្ញុំនឹងសម្រាកនៅទីនេះ ដើម្បីមើលអាទិទេព ព្រោះខ្ញុំចេះតែនឹកមមៃថាខ្ញុំនឹងឃើញជាមិនខាន ។

លុះខ្ញុំមានព្រះបន្ទូលហើយ ទើបបង្គាប់ឲ្យពួកសេនាគាហានថយទៅវិញអស់ ទុកតែលោកមុយអេស៊ីនឲ្យនៅកំដរព្រះអង្គ ។ ជនទាំងពីរនៅអង្គុយជជែកគ្នាអំពីសត្វឈ្មួសចម្លែកគួរឲ្យតែព្រះអាទិត្យអស្តង្គត ។ បន្ទាប់មកព្រះបាទវុសភ័នសាជ ដោយខ្ញុំនឿយអស់ព្រះកាយពលខ្លាំង ខ្ញុំចង់ដំណេកឲ្យលក់យកកំលាំង ទើបខ្ញុំត្រាស់បង្គាប់ទៅលោកមុយអេស៊ីនថា ៖

– លោកមុយអេស៊ីន ! ខ្ញុំងងុយណាស់ រឹងត្របកភ្នែកអស់ហើយ ខ្ញុំគ្មានៅអង្គុយតទៅទៀតពុំបានទេ ដូច្នេះនៅពេលដែលខ្ញុំដេកលក់ ចូរលោកកុំដេក ទៅយាមចាំគន់មើលទៅក្នុងថ្កុកទឹកនេះ, បើលោកឃើញអ្វីផុសចេញពីក្នុងទឹកនោះមក ចូរលោកដាស់ខ្ញុំភ្លាម ។

ឯរដ្ឋមន្ត្រីដែលនៅកំដរស្តេច ទោះងងុយដេកយ៉ាងណាក៏ពុំហ៊ានដេក

ដោយបង់បំពេញព្រះទ័យស្តេច តែមិនយូរប៉ុន្មាន នាម៉ឺននោះក៏លង់លក់ទៅវិត ។ ព្រះពោធិសត្វដឹងអមាត្យទើបនឹងលក់បន្តិចសោះ ស្រាប់តែភ្ញាក់ព្រឺតខាំងពីរនាក់ ដោយឮសូរតូរ្យតន្ត្រីលាន់រំ ហើយឃើញប្រាសាទមួយក្តីចិញ្ចាចល្អហួសវិស័យនៃស្មារដៃមនុស្សលោក ផុសនៅត្រង់ថ្កុកទឹកនោះ ។ ព្រះចុតមុសព័ទសាដត្រាស់សួរទៅលោកមុយអេស៊ីនថា ៖

– ឃើ! ចុះសូរភ្លេងមកពីណា មុយអេស៊ីន? ហើយប្រាសាទនោះទៀត តើផុសពីណាមក? នេះប្រាកដជាមិនមែនប្រាសាទធម្មតាទេ ។

– គ្រាបទូលព្រះករុណាថ្លៃវិសេស! នេះម៉ិនគឺអ្វីក្រៅអំពីការឆ្លុបទេ... ន! បើសិនជាយើងនាំគ្នាដើរបញ្ជាក់ក្នុងនោះទៅ ប្រហែលជាគាប់ចិត្តទេវតា ប៉ុន្តែអ្នកណាទើបដឹងប្រាកដជាអ្វី តែនឹងប្រាសាទនេះជាអន្ទាក់ដែលមេធ្មប់ប្រាប់ដោយឆ្លាក់ព្រះឆ្អឹងទេតើមិនដឹង?

– អ្ហ៎ដោយ លោកកុំភ្លាមថាខ្ញុំឱ្យបានមិនហ៊ានទៅនោះ មកទៅ! យើងទៅមើលឱ្យឃើញ តើអ្នកណាខ្លាចទៅខ្លះ ។

ព្រះមហាសត្វត្រង់លោកមុយអេស៊ីននាំគ្នាដើរតម្រង់ទៅទីប្រាសាទ ហើយឃើញទ្វារចំហ ក៏ដើរចូលទៅក្នុងទីធ្លាមួយធំ ហើយដើរចូលទៅក្នុងបន្ទប់មួយ ក្រាលសុទ្ធតែឥដ្ឋធ្វើអំពីសាច់ដំដូចបានស្រុកចិន ហើយមានពួកកំណាល់សម្រាប់អង្គុយ មានតម្រាលសុទ្ធសឹងប៉ាក់ពេន ហើយធ្មុំចំហាយក្លិនពិដោរគ្រអូបក៏ប្លុយឈ្ងប់ ប៉ុន្តែគ្មានឃើញមនុស្សម្នាក់សោះ ត្រង់យោងតាមបន្ទប់នេះទៅចូលបន្ទប់មួយទៀត ឃើញសុទ្ធតែស្រីក្រមុំប្រហែលជាហាសិបឬហុកសិបនាក់ស្លៀកពាក់ពណ៌ផ្កាកូឡាប ហើយមានផ្ទាត

ឱ្យឯងស្លាប់ទីឯងសាច់សំពត់ផង ។ ស្រីតាំងនោះឈរដេញតំណាហើយដៀន
ទៅចំពោះមុខស្រីម្នាក់ អង្គុយលើបល្ល័ង្កមាសរំលេចដោយពេជ្រមុត្តា
ស្រីនោះមានរូបឆ្អែតធ្វើឱ្យព្រះបាទវរុសព័ន្ធសាជរំតើបព្រះហឫទ័យជាខ្លាំង ។

ទ្រង់នុនគំនាប់ព្រះទាន ហើយយាងចូលរហូតទៅដល់កណ្តាលប្រជុំជន ។ ពួកស្រីៗឃើញក្សត្រីវ ហើយ ក៏នាំគ្នាបញ្ឈប់ក្ងេង បញ្ឈប់ចម្រៀង ។ ព្រះអគ្គទ្រង់មានព្រះឧង្ការទៅកាន់ព្រះនាងថា:

- ឧ ! ម្ចាស់ក្សត្រីអើយ ! ដោយសារតែវែកវៃព្រះទេតព្រះនាងនេះហើយ បានជាខ្ញុំដែលជាស្តេចប្រទេសចិនធ្លាក់ខ្លួនទៅជាទាសៈនៃសេចក្តីស្នេហា ។ ដូច្នេះ សូមព្រះនាងព្រះពជ្ឈានអត់យោសដល់ខ្ញុំ ហើយសូមព្រះនាងមេត្តាច្បាប់ឈ្មោះស្ត្រីទេតកញ្ញា ដែលគាន់តែខ្ញុំក្រេះឡូតឃើញ ធ្វើឱ្យខ្ញុំរំភើបចិត្តជាខ្លាំង ។

ព្រះនាងទ្រង់ព្រះសណ្តាប់ហើយក៏ញញឹម ហើយទ្រង់ត្រាស់តបថា:

- ខ្ញុំជាសត្វល្អិតមួយដែលគាចចង់ដល់ទៅសត្វសឹង្ហក៏បាន រួចខ្ញុំនេះហើយជាសត្វល្អិតដែលអ្នកបានដេញតាមមក, ដើម្បីនឹងដោះខ្លួនឱ្យរួចអំពីដៃអ្នក ខ្ញុំបានលោតចូលក្នុងចក់ទឹក ។

ព្រះមហាក្សត្រទ្រង់ឆ្លើយថា:

- ឧ ! ព្រះនាង ! ចុះហេតុអ្វីបានជាព្រះនាងវៃប្រកេទទៅជាយ៉ាងដូច្នេះ? តួរឱ្យខ្ញុំតក់ស្លុតណាស់, តើរូបព្រះនាងដែលបង្ហាញឱ្យខ្ញុំឃើញទៅពេលនេះ ជារូបខ្លួនម្ចិតបន្ទុំទេឬ?

- ទេ គឺជាធម្មជាតិរបស់ខ្ញុំ តែតាមពិតគឺខ្ញុំផ្ទាស់តេជាសត្វនៅពេលណាដែលខ្ញុំចង់ផ្ទាស់, ខ្ញុំចង់ឲ្យមនុស្សឃើញក៏បាន មិនឲ្យឃើញក៏បាន ប៉ុន្តែមិនមែនខ្ញុំស្លូតសែកមន្តអាគមអ្វីទេ គឺជាធម្មជាតិរបស់ខ្ញុំតាំងតែអំពីកំណើតមកតែម្តង ។

គ្រាស់ហើយ ព្រះនាងយាងចុះពីលើព្រះទៃខន មកចាប់ព្រះហស្តព្រះមហាក្សត្រតាំងួលៅក្នុងបន្ទប់មួយ ដែលមានតុមួយពាសពេញៅដោយម្ហូបយ៉ាងឆ្ងាញ់ ។ ព្រះនាងទ្រង់គង់នៅកណ្តាល ព្រះមហាក្សត្រទ្រង់គង់អមម្ខាង, លោកមុយអេស៊ីនអង្គុយអមម្ខាង, ប៉ុន្តែលោកនេះ មិនមានចិត្តមុខរីករាយសោះ ព្រោះខ្លាចមានគ្រោះថ្នាក់ដល់ខ្លួន ។ ចំណែកព្រះបាទវុសវ៉ាន់សាដវិញ ទ្រង់ត្រេកអរតេត ទ្រង់គ្មានទុក្ខដល់គ្រោះថ្នាក់អ្វីបន្តិចសោះ ទ្រង់ងាកទៅរកព្រះនាង ដើម្បីទឹងលើកម្ហូបថ្វាយព្រះនាង ប៉ុន្តែព្រះនាងមានព្រះបន្ទូលថា :

- សូមទ្រង់សោយតែព្រះអង្គទឹងមន្ទីទៅចុះ ពួកខ្ញុំម្ចាស់ចាំងអស់គ្នានៅទីនេះស្រេងតែកូនអាហារប៉ុណ្ណោះទេ ។

លុះដល់ព្រះមហាក្សត្រទទឹងវដ្ដមន្ទីបរិភោគអាហារស្រេចហើយ មានស្រីពីរនាក់យកកែវចរណៃពីរជាក់ស្រាពណ៌ក្រហម ទាំមកថ្វាយព្រះអង្គ ហើយថែមស្រានោះមិនឲ្យកន្ទុះខាន់ទេ ។ គេយកស្រាបែបនេះមកថ្វាយព្រះនាងដែរ តែព្រះនាងគ្មានសោយបន្តិចបន្តួចសោះ ព្រះនាងគ្រាន់តែហិត ។ ប៉ុន្តែគេឃើញផលនៃស្រានោះលើព្រះភក្ត្រព្រះនាងដូចជានៅលើព្រះភក្ត្រព្រះមហាក្សត្រដែរ ។ អ្នកចាំងបីស្រីនេះស្រាតែរៀងខ្លួន

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលចែចង់ព្រះនាង ហើយព្រះនាង
ក៏បណ្តោយបន្ទូនខ្លួនតាមព្រះអង្គ ហើយមានបន្ទូលទៅកាន់ព្រះអង្គថា ៖

– តោះព្រះអង្គមានហ៊ានៈ តាបជាង ខ្ញុំម្ចាស់ក៏ដោយ ក៏ខ្ញុំម្ចាស់មិនអាច
ទ្រាំទ្រមិនស្រឡាញ់ព្រះអង្គបានឡើយ, ដើម្បីទ្រាំឲ្យព្រះអង្គជាបន្ទូវ
ដំណែនៃចិត្តរបស់ខ្ញុំ។ ចង់ទូលព្រះអង្គអំពីជាតិកំណើតរបស់ខ្ញុំនៅពេល
នេះក្រែមមិនបង្គន់ ‘‘ តែបទូលព្រះមហាក្សត្រ ! នៅក្នុងមហាសមុទ្រ
មានកោះមួយឈ្មោះ សេហៅស្តេង មានសុទ្ធតែអាទិទេពនៅ ហើយមាន
ស្តេចសោយរាជ្យព្រះនាម មេទូតសោ ។ ព្រះអង្គមានព្រះរាជបុត្រីតែ
មួយព្រះអង្គ គឺខ្ញុំម្ចាស់នេះឯង ហើយខ្ញុំម្ចាស់ឈ្មោះសេហៅស្តេង ខ្ញុំ
ម្ចាស់បានចេញឃ្លាតពីព្រះបិតាខ្ញុំម្ចាស់មកចរីនៃហើយ ដើម្បីទ្រង់ធ្វើដំណើរ
ទៅមើលស្រុកទេសផ្សេង។ ដែលមានមនុស្សនៅ ។ លុះខ្ញុំបានដើរមើល
នគរផ្សេង។ គ្រប់អស់ហើយក្នុងលោក, ហើយខ្ញុំនឹងត្រឡប់ទៅនគរវិញ
ខ្ញុំម្ចាស់ក៏បានឆ្លងកាត់តាមនគរព្រះអង្គនេះ ហើយបានឃើញរូបព្រះអង្គ
ខ្ញុំម្ចាស់ចាប់ចិត្តស្រឡាញ់ព្រះអង្គតាំងពីពេលនោះមក ហើយខ្ញុំម្ចាស់ហួស
ចិត្តនឹកតែក្នុងចិត្តខ្ញុំម្ចាស់ថា ‘‘ គួរអ្វីមកវង្វេចចិត្តចំពោះរូបមនុស្សលោក
យ៉ាងនេះ’’ តើឫកខ្ញុំដែលធ្លាប់តែធំ ហេតុម្តេចក៏ឋយមកស្រឡាញ់រូប
មនុស្សម្នាក់នេះវិញ? ខ្ញុំម្ចាស់នឹកអៀនខ្លួនពន់ពេក ខ្ញុំម្ចាស់ចង់ដៀសចេញ
ឲ្យឆ្ងាយពីព្រះអង្គ ប៉ុន្តែខ្ញុំម្ចាស់មិនជាប់ចិត្តសោះ ។ ម្ល៉ោះហើយ ដោយ
អំណាចនៃសេចក្តីស្នេហារបស់ខ្ញុំម្ចាស់។ ក៏គិតតែរកមធ្យោបាយណា ឲ្យ
ខាងតែទ្រង់សព្វព្រះរាជហឫទ័យ ។ ខ្ញុំម្ចាស់ក៏តំណែងខ្លួនធ្វើជាឈ្លួស

សមួយភ្លាម ហើយចេញបង្គាញខ្លួនចំពោះព្រះនេត្រទ្រង់ ដើម្បីឲ្យទ្រង់មកតាមខ្ញុំម្ចាស់ ។ ព្រះអង្គក៏បានតាមខ្ញុំម្ចាស់រហូតមកដល់ថ្ងៃទីកនេះ ខ្ញុំម្ចាស់សប្បាយចិត្តពេកណាស់ ដោយឃើញព្រះអង្គខំតស៊ូការពារទីកពុំម្ចាស់ ហើយខ្ញុំម្ចាស់ខំផ្ទៀងត្រចៀកស្តាប់ទ្រង់ ខ្ញុំម្ចាស់គ្រេកអរណាស់ ដែលឮព្រះអង្គមានព្រះទន្ទ្រាវថា ទ្រង់នឹងផ្ទំនៅលើមាត់ទីកនេះ ។ នៅពេលដែលទ្រង់ផ្ទំលក់ ខ្ញុំម្ចាស់បង្គាប់ឲ្យគេសង់ប្រាសាទនេះ ដើម្បីនឹងទទួលព្រះអង្គ ។ ពួកគាត់ទើបតែបានសង់ប្រាសាទនេះតែមួយភ្លែតហើយភ្លាម ។

ព្រះនាងសេហ៊ីស្តានីរៀបនឹងមានបន្ទូលតទៅទៀត តែសាប់តែមានស្រែបំរើម្នាក់ ទើតមុខស្ទុះតូចមកទូលព្រះនាងថា ៖

- ទូលព្រះនាង, ព្រះនាងជាបងេ: ពួកគាត់ទេត ដើម្បីនឹងរស់នៅបានយូរជាងមនុស្សលោក មិនមែនតុក្កដ្ឋខឲ្យស្លាប់ទេ, ឥឡូវនេះព្រះរាជបិតាព្រះនាង ឋានទ្រង់ពីដីវាគាងមិនទៀងទាត់ ទៅគាន់ដីវាគាងទៀងទាត់ហើយ ។ បណ្តាកស្តេ សូមឲ្យព្រះនាងយាងទៅគ្រប់គ្រងរាជ្យស្នងព្រះអង្គ ហើយនឹងចាំរៀបអភិសេកព្រះនាង បើដូច្នេះ សូមព្រះនាងយាងទៅទទួលអភ័ន្តរាការ នៃនាម៉ឺនសព្វមុខមន្ត្រីព្រះនាង ព្រោះរដ្ឋមន្ត្រីទាំងឡាយនាំគ្នារង់ចាំគ្រប់គ្រា ។ លោករដ្ឋមន្ត្រីដែលជាមុតុខ្ញុំម្ចាស់ឋានជ្រៃខ្ញុំម្ចាស់យ៉ាងច្បាស់ ឲ្យមកអញ្ជើញព្រះនាងស្តេចទៅ ។

ព្រះនាងកាលបានឃើញសេចក្តីទុក្ខធ្លាក់មកនៅលើខ្លួន ក៏ទ្រង់ព្រះ

កម្សៃនេះសោក, ព្រះបាទវុសភ័ន្តសាដក៏ស្រង្គត់ស្រង៉ាត់ដោយអាណិតព្រះនាង ។ ក៏មានបន្ទូលថា :

– នែម៉ែម៉ូណា ! ខ្ញុំនឹងទៅជាមួយនឹងនាងឥឡូវនេះ . . . បើដូច្នេះខ្ញុំសូមក្រាបថ្វាយបង្គំព្រះអគ្គីហើយ ព្រោះកន្លងពេលនេះខ្ញុំត្រូវតែឃ្លាតអំពីព្រះអគ្គី" ថាហើយព្រះនាងហុចព្រះហស្តព្រះនាងទៅថ្វាយស្តេច, ព្រះមហាក្សត្រទ្រង់ទទួលទាញមកថើបដោយសេចក្តីស្នេហាយ៉ាងខ្លាំង ។ ព្រះនាងមានបន្ទូលតទៅទៀតថា " សូមព្រះអង្គជ្រាបថាយើងមុខជានឹងបានជួបគ្នានៅថ្ងៃណាម្តងមិនខាន ហើយបើដល់ថ្ងៃនោះហើយ ខ្ញុំយើញទ្រង់នៅតែមានព្រះជន្មយឺនស្មោះត្រង់ទើបខ្ញុំម្ចាស់ជាដែល នោះខ្ញុំម្ចាស់គ្មានទទួលអ្នកឯណាមកធ្វើជាព្រះស្វាមីក្រៅអំពីព្រះអង្គទេ ។

ក្រោយពីមានព្រះបន្ទូលដូច្នេះហើយ ស្រាប់តែបាត់ព្រះនាងសេហៀស្តាទី កាលបាត់ព្រះនាងហើយស្រាប់តែឯងឮសំឡេងស្មូនៗមួយរំពេច បាត់ពន្លឺទៀនទាំងពន្លឺចន្ទ្រឿង ព្រះមហាក្សត្រចងនឹងវង្គមន្ត្រីដើមដាំមកទ្វេភ្លឺមិនដឹងជាទៅទាន់ណាមកទាន់ណា បើឯងឮតាក់ក្អែកមិនយល់យ៉ាងនេះ ។ លុះក្អឹស្វាងឡើងកាលណា ស្រាប់តែបាត់ប្រាសាទអស់ យើញតែកំលូរលូរលែតែផ្ទះមួយគ្មាន ។ ព្រះមហាក្សត្រសួរទៅលោកមុយអេស៊ីនថា:

– ម៉ែមុយអេស៊ីន ! តើការណ៍ដែលយើងយើញគាំងប៉ុន្មាននោះជាយល់សប្តិឬយ៉ាងណា ?

– ក្រាបទូលមិនមែនទេ ប្រាកដជាអំពើរបស់ពួកធ្មប់, ក្សត្រិ

ដែលយើងឃើញនោះ ច្បាស់ជាស្រែចេះធ្លប់ ហើយដើម្បីទំនងធ្វើឲ្យព្រះអង្គសព្វព្រះទ័យ ក៏ដំណែងខ្លួនធ្វើជាអាថិទេពមួយយ៉ាងល្អ, ពួកស្ត្រីបំរើដែលនៅក្នុងហើយល្អ ។ នោះទៀតក៏សុទ្ធតែព្រាយតាំងអស់ ។

ទោះជាយោបល់របស់លោកមុយអេស៊ីនត្រូវយ៉ាងណា ក៏ព្រះមហាក្សត្រនៅតែពុំទ្រង់សព្វព្រះទ័យឡើយ ហើយទ្រង់ក៏យាងត្រឡប់ទៅគាន់ព្រះបរមភជាំងវិញ ដោយតាំងក្នុងព្រះរ័យថាទឹងប្រគល់បេះដូងព្រះអង្គចំពោះតែព្រះនាងនោះមួយ ។ ចាប់តាំងតែពីថ្ងៃនោះមក ព្រះអង្គចេះតែមានព្រះភ័ក្ត្រស្រងូតស្រងាត់ ខុកជាព្រះអង្គពុំដែលបានដំណឹងអ្វីពីព្រះនាង ខុកជាលោកមុយអេស៊ីនចេះតែបន្ទោបន្ទប់យ៉ាងណា ក៏ព្រះអង្គនៅតែមិនក្តាប់ព្រះនាងសោះ ។ ព្រះអង្គលែងនឹកគ្រសាលលែងនឹកកំសាន្តអ្វីដទៃលើកតែការបរបាញ់ប៉ុណ្ណោះ ហើយទ្រង់ទំនងស្តេចទៅបរបាញ់នោះទៀត ក៏ស្តេចទៅតែត្រង់កន្លែងដែលទ្រង់បានប្រទះនឹងឈ្លួសសនោះទៀត ។ ទ្រង់ចេះតែសញ្ជប់សញ្ជឹងដូច្នេះពេញមួយឆ្នាំ ។

(មានត)

ពាក្យកាព្យ

អ្នកឧកញ៉ាមហាវិធីប្ដូយ ដៅ

រៀបរៀន

(តមក)

ប្រការមួយទៀតគឺឲ្យស្គាល់ រៀងកាល់ត្រកូលវតនាការ
មួយវែងធ្វើការស្មោះសារ មួយមិនឆក់ស្លៀកបំបាត់ហ្មង ។
ហេតុថ្នាំនេះពិតជាគ្រឹត្យក្រម នាយធំកងឃ្មាំងគប់ក្រសួង
ត្រូវតាមជំពូងពាំងពួង ខឹងហួងហែងខុកមិនខ្លាច់ខ្លាយ ។
បោរាណរឿងឆ្លុះ អ្នកប្រុំ ចាប់នេះប្រៀបរំយោយ
ប្រដៅប្រដាប់ថ្នាប់តំថ្នាយ អធិប្បាយចាយចែងសំដែងថា ។
មហាក្សត្រខឹងចាត់រើសបុរស តាំងស្មោះជាប់ស្មៅនៅត្រួតត្រា
ជានាយទ្វារកំងាំងរក្សា ប្រកបប្រការថ្នាំមួយពិត ។
មួយគឺឲ្យស្គាល់ពជបរិស័ទ ចាស់ថ្នាបញ្ញាត្តិគួរពិនិត្យ
មួយមានស្មារតីវៃគន់គិត មួយរូបល្អល្អិតកាយសមរម្យ ។
ប្រការមួយឲ្យមានការងារស្អាត មួយមានមារយាទបូករម្យទៀ
អត់ធន់លំបាកទុក្ខទោសធំ មួយឈ្វាសនិយមសាកសួរល្អិត ។
ថ្នាំមួយបទនេះជាបែបគួន កងខ្វួនមមាត្យជាក្រមក្រឹត្យ
ប្រកបប្រកាន់ជាប់កងឆ្ងិត្ត សុចរិតប្រពាន់ជានាយទ្វារ ។
បញ្ជាវិវាក្យំ សុរំ ប្រាប់ ចាប់ចប់គម្ពីរ

អធិប្បាយស្រាយថាព្រះពាន់ រើសនានៃអ្នកទាំងឥសារ ។
គួរកោយកមនុស្សដែលប្រកប ស្រេលស្រេបស្រេចសត្វគ្រប់ប្រការ
ប្រាំមួយប្រាកដបទបៃបថា មួយគឺប្រាជ្ញាក្នុងវិនុះឆ្ងាត ។
មួយមានថ្លើមាត់ស្អាត់បរបា មួយគឺក្នុងវិក្ខាតបសាមាថ
មួយមានគំនិតគិតល្អស្អាត មួយទ្រទ្រង់ធម៌ភាសាគួរនឹងស្តី ។
ប្រការមួយទៀតឲ្យប្រាកដ គំណាត់ដ៏ធំចិត្តជនប្រុងស្រែ
ប្រាំមួយបទនេះគាថាលី សេចក្តីគួរជាភាវនុតក្សត្រ ។
សក៌ិទ្ធិឬរិក្ខ៑ ស្តេចទ្រង់ធំធ៌តាំងពីរាជបរិស័ទ
ជាក្រុមអាល័ក្សអ្នកចែងចាត់ បញ្ជាក្នុងប្រាប្តីឬច្បាប់ពាជការ ។
គួរវើសរកមនុស្សប្រកបបទ តំណាត់ប្រាំមួយដូចថ្លែងថា
មួយគឺចាំពាក្យដែលបរបា តែម្តងអាចក្រាក្រាប់ចាំបាន ។
ប្រការមួយសរសេរក៏រហ័ស មួយគ្នាតនៅវិទ្យាសប្រាជ្ញរហាន
មួយមានថ្លើដែលក្លាចំណាន មួយមានស្ថានឈ្លាសសំដី ។
មួយឈ្លាសក្នុងលេខនឹងអក្សរ ហានន្តរាត្យញ្ញានៈបាឋបាលី
ឯកគោត្តណ្ណាជាតកក្តី ប្រកបសេចក្តីត្រូវបែបក្បួន ។
ប្រការប្រាំមួយនេះប្រាកដ សន្តតប្បវេសមានកង់ទ្វន
ជនបៃបនេះឯងទើបសមសួន សំខ្លួនក្នុងវិជាអាល័ក្ស ។
បញ្ញាវិ បរមទ្ធរេ ខុត្តិយេ ខ័ន្តាំងអគ្គឯកអគ្គ
សេនាបតិសិរីសក្តិ ជាឡាត់រាល់សលែងមុខទ្រង់ ។

គួរនេះត្រឹមរើសកាជសេវ៉ាគា
ថ្កាំបួនប្រការថ្កាកជខ្លី
មួយមានថ្កាជ្រាអាចបំថ្កាក់
មួយដឹងជយក្ខមិទ្ធិតាស
មួយគឺនាគាលជល់អាប់ពុន
មួយគឺជីងគលពលអាសា
មួយគឺប្រកបដោយសេចក្តី
មួយគឺក្ខ្វៃក្ខ្វៃហ៊ានតតាំង
មួយគឺអម្ចាស់លើសិរីសោ
អត់ធន់ថ្កាំទ្រជួយការភ័យ
មួយគឺអត់ធន់ឱនតួនខ្លួន
សន្ធោសរថ្កាសថ្កាប់ដោយខំនង
មួយចេះគម្ពីរសេនន្ត:
ថ្កាកជតំណាត់ជាសេនីយ
ថ្កាំបួនបទនេះថ្កាកជថា
តម្រិះត្រិះត្រែកតម្រែកគិត

បិតុបិតាមហាទុក្ខោ

ប្រយោជន៍ក្សត្រាក្នុងឆកជ្យាមេ្ស
ព្រះបមចក្រពត្តិទ្រង់តាំងតែង
គួរដ្ឋិសរើសរកកជបំរែង
តិរិយាប្រកបធម៌សេចក្តី
ទើបជាអធិបតីដោះទុក្ខក្រស្តេ ។
បរបក្សញ្ញាញាត់ឲ្យវិនាស
ឱពសថ្កាសចាកក្តីទុក្ខា ។
ស៊ូធន់ទឹងត្នាស្មើដីព៌
រអាលំថ្កាកគោកយ៉ាកខ្លាំង ។
ព្យាយាមគប្បីជាកម្លាំង
ប្រណាំងប្រយុទ្ធយកជោគជ័យ ។
មានការគពរិយុគទុក្ខមោះមៃ
ដោយន័យកតញ្ញូស៊ូព៌ប់វេង ។
មិនគួនសុខទុក្ខតិធ៌ាធ្ងន់
គន្ធង់ជំណើរប្រើសំដី ។
ព្យូហៈសង្គ្រាមសព្វសេចក្តី
ដោយន័យពិជ័យសង្គ្រាមពិត ។
ប្រកបកិរិយាការប្រតិត្តិ
បរិតសេនាបតីធំ ។

ជាបៅ ចុះបទនេះនិយម

សុទ្ធុមលៃបទាយធិប្បាយថា ។
តំណែងពិសេសគោជនាហារ
ប្រកបប្រការថ្កាំថ្កាកជ ។

មួយឆ្នាប់ជាប់តតីបិតា　　ធ្វើការពិសេសស្ម័គ់ចត់
មួយឈ្មោសធ្វៀរធ្វាតបានចាប់បទ　　កំណត់កងការសូដណ្តាំ ។
មួយច្បាជ្រអាចចេះក្បួនតម្រា　　សំឡីពីសាពិសេសចាំ
មួយចេះដាំសូតាមចំណាំ　　សៃមសាំថែមថយស្មមច្រមាណ ។

មួយទៅជាប់ជាពួកពិសេស　　ដកបម៉ិនធ្លេសច្រហែសខាន
ច្រាំបទកំណត់ពីបុពណ　　ស្តានក្នងពីពិសេសហ្លួន ។
អាយុភេទសត្តោទក្កោ　　រញ្ជោ ខែនតាំងក្រមក្រសួន
ពេទ្យនុសថាផងតាំងពួន　　គួរហ្លួនយកមនុឃ្យមានវិជ្ជា ។

ច្រកបគុណច្រាំចាំច្រាកដ　　ទីមួយគឺស្តាត់បទពេទ្យា
គម្ពីរនុសថតុតមហិមា　　វិឌ្ឍនាអាយុឲ្យវែងឆ្ងាយ ។
ហើយឲ្យអាចស្គាល់ឱ្យល់ដីពេរ　　ងាយក្រដូចម្តេចពេគកងកាយ
កំណត់ស្តាត់ចាំឱ្យល់សុះសាយ　　តាមដោយគម្ងាយគម្រាផង ។

មួយគឺធ្វៀរធ្វាសខាងរក្សា　　ពេគាព្យាធីឲ្យម៉ត់ម៉ង
មួយគឺអាចចាំថ្នាំគ្រប់កង　　ចេះចង់សារតើនុសថា ។
មួយមានស្តានកល្យាណខែង　　ល្អកង្គក្រង់ត្រឹមត្រូវលក្ខណា
មួយគឺច្រកបសីលាចារ　　សេដ្ឋច្រសើរដ៏ឧត្តម ។

ចាប់បទកំណត់ច្រាំវិជ្ជា　　ពណិនាមកនេះជាត្រីត្យក្រម
ប្រុសណាច្រាជ្រអាចចេះចំ　　កងទីពេទ្យធំចមកជគ្រូ ។
សុជាធន្តំ សុបិទកុំ　　រៀបចំសព្វនេះលោកផ្ទឹមផ្ទួ

តម្រង់ត្រឹមត្រូវក្បួនគំរូ ឃុំណាពជម្លេះពោលខុសមក ។
ថាព្រះបរមពាជទត្តិយា ត្រែកទ្រង់ចិន្តាតែលីលក
ខឹងដែសតើសបុរសស្មោះគួរយក រែរកមកតាំងជាសេវកា ។
គួរឲ្យប្រកបហេតុប្រាំពីរ មួយគឺមានស័ល្យសមាចារ
រក្សាសុចរិតចិត្តមេត្តា ប្រព្រឹត្តចរិយាធម៌ប្រពៃ ។
មួយឈ្មោសធ្នាសដឹងដោយហេតុ អធ្យាស្រ័យម្ចាស់សព្វព្រះទ័យ
មួយមានប្រាជ្ញាឆ្លៀវឆ្លាសវៃ ដឹងន័យខ្ទង់តាមដំណើរ ។
មួយអាចប្រាជ្ញដឹងគម្ពីរច្រើន ចំរើនតម្រិះដ៏ប្រសើរ
មួយជាមនុស្សស្អាតធ្មត់រៃ មិនមានសើរើធ្វើឲ្យហ្មង ។
មួយគឺមានចិត្តមិនលោភ មុខឡាវង្វិនតាមបំណង
មួយមានស្មោះតែរឹតខ្ទង ចាំចងចាប់ជាប់គ្រប់សេចក្តី ។
ប្រាំពីរបទនេះជាចរិក មហាតលិកចំរើតាល់ប្រកិត
ដំនិតដ៏តអគ្គព្រះចក្រី មេត្រីតាំងខុកជាសេវកា ។

ភេទាភេទង្គសត្តញ្ញោ

ចានបទកំណត់តាមតម្រា សារសេពូសេដោយវិត្តារ
សម្តែងចែងចាត់ខុកជាច្បាប់ តម្រាយក្បួនតាំពីបុពណ ។
ខឹងតាំងបុពេហិតគិតប្រមាណ សំពាប់តំណាពជក្បួនក្បាន្ត
មួយចេះតម្តីរវិចក្ខេ ប្រកបហេតុបានតាំងបីពិត ។
មួយឈ្មោសធ្នាតដឹងតម្រាយគិត សត្តសេដ្ឋធំតួចតែងប្រព្រឹត្ត
ប្រកាមួយប្រកបព្រហ្មវិហារ ប្រឌិតប្រដាប់ប្រជាយ័ទ្យ ។
តាំងចិត្តមេត្តាជាទំនួរ

ចំរើនព្រះជន្មឲ្យគ្រប់គ្រាន់ ជាទដល់រយពាន់អាវុធនៅ ។
បីបទគំណត់នេះជាទី វិធីព្រាហ្មណ៍ព្រឹទ្ធប្រកបទៅ
ប្រគាន់ប្រុកដបទពាក់ផ្នែ ទើបហៅថាពីរជបុរេហិត ។

រក្ខពិធ្យុយសាធុកំ

សម្តែងចែងច្បាប់ជាក្រមក្រិត្យ ចាបបទពាក់ចំតាំងតាសិត
សម្តេចបមពង្សខ្ញុំតាំងតែង លំនិតន័យនេះពណិនាថា ។
ស្តេចាវព្រះស្តុំក្រុមបរិវារ តំណែងក្រុមកាំងខាំងរក្សា
ដោយអគ្គិជ្រាំពីរជាសុភាព គួរហើសបុរិសាដែលប្រព្រឹត្ត ។
មួយរក្សាខ្លួនសួនតំនិត មួយចិត្តខន់ខាបត្រង់ស្មូតពិត
មួយធ្លាតឈ្លាសចេះពាក្យបរាបា គន់គិតរកាំងខ្លាចខោសភ័យ ។
មួយគឺត្រែកអរធម៌ប្រពៃ ភាសាប្រទេសផងដទៃ
មួយគឺប្រកបត្រកូលវង្ស ប្រព្រឹត្តដោយន័យពុទ្ធឧត្តម ។
មួយគឺអាចចេះសិល្បសាត្រ រចនាទ្រទ្រង់ស័ល្យដ៏ស្អាត
មួយគឺមានចិត្តគិតក្រែងខ្លាច ផ្សែង ៗ ជាខ្លាតមានក្តងខ្លួន ។
ជ្រាំពីរបទនេះទើបសមសួន អំណាចអម្ចាស់ណាស់ម៉ាំមួន
ឆ្លាប់ខ្លួនកងីក្រុមកាំងស្តេច ខ្លាប់ខ្លួនកងីក្រុមកាំងស្តេច ។

បញ្ជាវិអនុត្តោប

សម្រាប់បុរសស្រស់ស្រីបរិស្រេច អត្ថរះបទនេះលោកសម្រេច
ដែលគួរតែងតាំងជាមន្ត្រី តាមដោយចំណាប់បទវិរិយា ។
មួយគឺជាមនុស្សមានជ្រាជ្ញ ប្រកបសេចក្តីបួនប្រការ

មួយគឺការម្ចាស់មានវេល់ យកខ្លួនចង់ចល់ធ្វើការថ្នាយ
មិនមានធុញថប់ចំប្រែប់កាយ មិនណាយលះបង់ពាក្យត្រែត ។
មួយគឺប្រែកបចិត្តក្សៀវក្លា ប្រែគាន់ការកិច្ចតំចាត់
បំបាត់សត្រូវឲ្យបង់បាត់ ដោយពាក្យបញ្ជាត្តិព្រះអាជ្ញា ។
មួយមានគតិជាអ្នកគិត ប្រព្រឹត្តតែរឹះតាមត្រូវការ
ជីនយល់យោបល់កលបណ្ដា ដោយមានឧស្សាហ៍គន់គិតអាន ។
ប្លួនបង្កំណត់ដូចពាណិនា សាធារណ៍ខ្លួនឲ្យពាល់រូបប្រាណ
ដល់ខ្ញុំមូលីតាមហាក្យត្រែក្សត្ត ស្ថាននេះជាទីមន្ត្រី ។

សាមីមច្ចពារដ្ឋ

ភាវៈជាប្រពន្ធប្រុសសេចក្តី

សំដែងពីអគ្គម្ចាស់ផែនដី គប្បីប្រែកបអគ្គភ្ជាំមួយ ។
ប្រែការមួយគឺជាតិជាម្ចាស់ ត្រូវឈ្វាសដឹងពាក្យសុខទុក្ខគ្នាយ
មួយមានអមាត្យក្សៀវឆ្លាសដួយ ជំនួយឲ្យឈរកន្លងខេត្តដែន ។
ប្រែការមួយសោតប្រែកបមាន ឲាហានយោធាស្ងាត់ភ្លៃខ្លួន
ខ្លោះខ្លាំងក្លៀវក្លាពប់រយសែន ណាន់ណែនវក្សាពជ្រុតដំកៃ ។
ប្រែការមួយប្រែកបគួរកំពែង បន្ទាយប៉មតែងតាំងសព្វថៃ្ង
ប្រយ័ត្នសំកាប់អចិន្ត្រៃយ៍ អស្រែយខាំងខាបថ្មមិត្រ ។
មួយគឺព្រះឃ្លាំងពីរដណ្ដាប់ មានសព្វសម្បត្តិសម្បូរពិត
មួយគឺព្រះពាជសម្ពន្ធមិត្រ ស្គាល់ដឹងស្និទ្ធគ្នាគ្មានភ័យ ។
ភ្ជាំមួយបទនេះជានិយម បរមចក្រពត្តិដ៏ប្រពៃ
ប្រព្រឹត្តសុចរិតពិតដោយន័យ ជាមង្គលស្បែរពាជវង្ស ។

អត្ថាធម៌រាជនាមំ

ទីដ៏សេពសមាគមគ្រូអាចារ្យ ជាស្តេចគួរគាំងទ័ព្រាប្ញា
ហើយទ្រង់ប្រកបគុណវិជ្ជា ដ៏មានប្រាជ្ញាជាបណ្ឌិត ។
សូវញ៉ាស្ងាត់ប្រាកដដោយតេជះខ្ពើ ចំណាន់ដំនាចំណេះពិត
ឲ្យស្គាតប្រាកដទឹងព្រៃអេក្ខ ដំនិតចំណាប់សិល្បសាស្ត្រា ។
នៅព្រះទីនាំងរថភ្លើ មានដើមថាគជ៌ាជអស្សា
ហើយទើបដំរៃតិចារណា ភ្លៀវភ្លាតភ្លឹកដល់ប៉ុនល្អង ។
មានពួកអមាត្យជាដើមដង មើលខ្ញុំពាជការប្រុំមួយកង
បញ្ញាវិពុទ្ធិមាបេរី

សំពាំងគាំងទុកសំពាប់ស្តេច បំណាន់ចិញ្ចឹមដោយបំណាច់ ។
នេះគួរគប្បីឲ្យប្រកប អក្ខរៈបាទនេះលោកសំរេច
ឈ្វេងយល់អត្ថាស្រែយជនានា ប្រសើរលើសជាច់ផែនតពូតារ ។
គប្បីរៀបរាំពាក្យទ្រនោះ ដោយរបបប្រាជ្ញាធ្វាសវិជ្ជា
ទ្រង់គាំងអំណាត់ក្នុងព្រៃទ័យ មិនរួញពារហ៍សឈ្វាសពាងវៃ ។
មានព្រៃចរិតទ្រង់ប្រតិត្តិ អសុរោះគំរោះពុំប្រែពៃ
ព្រះមនោសោមនស្សប្រសុទ្ធថ្លា ដោយទ័យខន្តីទីងសត្យា ។
សុជិកពោសម្ភារាទិ

សំដែងចែងសំពូធ្លាប់អតិប្បាយ ទសពិធរាជធម៌សមាចារ
ដ៏ជាឥស្សរៈកំពូលពស្ត្រ មិនឫស្យាសម្បត្តិអ្នកគាំងឡាយ ។
តតិទ័យនេះលោកបរិយាយ
អធិប្បាយដើម្បីព្រះក្សត្រា ។
ទុកាសឥស្សរពជរង្គ

ទឹងខ្ពង់ប្រាសាទតើការ គួរខ្ចប់ព្រះចិន្តាដោយយោបល់ ។
ពិចារណាដោយល្អិតរួចសឹមធ្វើ សារតើតាំងពួងទើបមានផល
សម្រេចស្រេចតើតការកិច្ចកល ទឹងមិនឆ្ងឹងឆ្ងល់ដោយយល់ស្រាប់ ។
ហើយឲ្យប្រព្រឹត្តប្រកបបច ក្នុងត់ប្រាំមួយជាតំពប់
តំកយបុកណាចង់ជាច្បាប់ សំពប់ខត្តិយវង្សខ្ពង់ប្រព្រឹត្ត ។
ប្រការមួយគឺឲ្យប្រកបមាន ជាស្ថានមេត្រីសម្ពន្ធមិត្ត
ដើម្បីសេចក្តីរួមគំនិត រំនិតកំចាត់សត្រូវផង ។
ហើយឲ្យកងវៃតរណាវគ្គ ឈ្មោសក្នុងនុយដ៏កន្ទុង
កិច្ចកលសត្រូវឲ្យសៅហ្មង កាប់កងបំបាក់ឲ្យខ្ទួបខ្ទាប ។
ជាទីសរណាប្រជាការ ទឹងបានស្មោះសរដោយអំណាច
អំណាអោរខ្លើងដែលអង់អាច ប្រុះប្រាជ្ញប្រាប់ទុក្ខមានសុខសាន្ត ។
ប្រការមួយព្រះច័យខ្ពង់រាត មមៃញឹកការងារជាប្រមាណ
មិនមានប្រមាទឲ្យខាតខាន ជកបដល់បានសំរេចការ ។
ប្រការមួយចេះញ៉ាំងឋបច័ក្ស បំបាក់បំបះបង្ហាវគា
ដោយយុត្តិធម៌សម្ថាចារ ជាទ័នថ្នាំបំផ្លាញឲ្យកងចាល ។
ប្រការមួយប្រកបដោយព្រះច័យ ក្លៀវក្លាប្រៃពៃមិនស្រាកស្រាល
ត្រង់ក្តីព្យាយាមជានិច្ចកាល តែអាលត្រែកខ្ពង់គង់មាំមួន ។
ប្រការមួយគឺមានព្រះស្មារតើ មិនប្រហែងធ្វេសខ្ពង់ខ្ជាប់ខ្ជួន
គួបកត់កំណត់ចាំថែជួន កុំឲ្យគួនគិតក្រណាន់នៅ ។
ប្រការមួយគឺមានព្រះប្រាជ្ញា ជាបការវិនាសនិកសៅ

ជាបក្ខិចំរើនក្តីពាក់ព្រៃ គោតៅផុលផុសខ្ទុះសព្វសាយ ។

ឧបការរញ្ជោសុរោ

វិសុទ្ធសេដ្ឋាសព្វអធិប្បាយ

ថាព្រះចេមពង្សទ្រង់ខ្វល់ខ្វាយ ដល់គុណតាំងឡាយដែលគេមាន ។

ហើយឲ្យក្មៀវក្មាសមាគម អ្នកធំតាំងបីជាប្រធាន

មួយគឺបណ្ឌិតប្រាជ្ញវិញ្ញាណ ជាអ្នករៀនឡាសន្ធៀវក្រៃ ។

មួយគឺជនជាតិចាស់ព្រឹទ្ធា វឌ្ឍនាចំរើនអាយុក្ខ័យ

មួយគឺអ្នកមានត្រកូលថ្លៃ ខ្ពង់ខ្ពស់ដាមហៃលើសមហាជន ។

ហើយទ្រង់ប្រកបព្រមដោយអង្គ តាំងបីត្រឹមត្រង់ត្រូវពេកពន់

មួយមិនបានផ្ចើអំពើធ្ងន់ លើសលន់ឲ្យដល់វិនាសខ្លួន ។

មានដើរដល់មានន័យតាវក្នាល់ ត្រូវប្រកាល់ស្មៀងផងតុំទ្រង់គួន ។

ជាហេតុទុច្ចរិតមិនសមស្ម័ន កុំត្រូវគួនគួនតិតជាប្រក្រតី ។

ប្រការមួយគឺមិនគួរគិតដៀល ក៏ចាដំខៀលមិនគប្បី

គឺពោលផ្ទុសក់ពាក្យអប្រិយ ជាក្តីអំប្យយសចំពោះគ្នាន ។

ប្រការមួយគឺទ្រង់ព្រះប្តជ្ញា ប្រាវឮថាដូចម្តេចជាប្រធាន

ខ្ជាប់ខ្ជួនដូចាះចំពោះមាន មិនចំពានធ្លើខុសពីប្តជ្ញា ។

អរិត្ថសធការញ្ជោ

វិទោ បទនេះពណ៌នាថា

ក្សត្រដ៏ទ្រង់អង្គឥស្សរ គប្បីជ្រាបការណ៍ហេតុតំចាត់ ។

បរវ័ក្សគឺពជសត្រូវផង ត្រូវប្រកងដែលកើតនោះឲ្យខ្ចាត់

ជំនះក្តីក្រោធឲ្យបង់ចាត់ ទ្រង់កាត់ជាប់ចេញចាកសន្តាន ។

គឺឲ្យជំនះទូវតន្ទ្រិយ មានត្រតាំងខ្លីជាដើមដាន

ហើយមិនលោកលន់តន់ប្រមាណ តែតអរតាមបានមិនឈ្មោនខាន ។
ព្រះវិន័យប្រកបដោយទុស្សហ៍ ផ្ទះថ្នាប់ពុំគួតទេយ្យទាន
ទុស្សហ៍ប្រដៅច្បាប់ខ្ញុំខ្ញាន ប្រិតប្រៀនដល់ខ្ញុំព្រះពាជការ ។
ណាមួយមិនធ្លាតមិនឈ្មោសដឹង ដំណឹងដំណើរដោយច្បាស់
ទ្រង់ព្រះបញ្ញាតច្បាប់មាត្រា ប្រយោជន៍កិច្ចការឲ្យឈ្មោសឡើង ។
វិមោហោអបរិគ្គហោ ជាពាជទត្តិយោគល់ខ្ញុំថ្ងៃនេះ
លោកឲ្យរក់ធំគុំចេះដឹង តំកើងហើយក្នេចព្រះស្មារតី ។
ន័យមួយលោកប្រៀបធៀបឧបមា អគ្គិអគ្គក្សត្រាគួរកុំបី
កាច់បង់ចង្កឹមជង្កីប្តី កុំញីញាក់ទង់ដំយកជង្ហា ។
កុំឆ្កៀលវៀលក្បែកព្រះនគរ កុំរុះទុះរាជសីមា
កុំកាច់បំបាក់ជាតហត្ថា កុំទំលាក់មុខរាជក្រែងវៃក្រ ។
ហើយមានតិរោល្អវិស្សុទ្ធ វិសេសបំផុតដោយនិស្ស័យ
ដ៏ទ្រង់ឥស្សរភាពជាមហៃ អធ្យាស្រ័យពាប់រេជនសប្បុរស ។
ប្រព្រឹត្តតែមដោយពាជវត្តិ ថ្កាំពីរខ្នែងជាត់ស្មាត់ឥតខ្ចោះ
ជាហេតុចំរើនគរស្មោះ មិនមានចន្ទោះកង់បច្ចុប្បន្ន ។
ជាបន្ទូរប្រទេសអាក្រក់ស្អុះ ការក្រកក្តើតក្តីអាសន្ន
សុខទុក្ខកលិយុគជានិរន្តរ៍ អ័ប្បអន់ខន់ខាបប្រែការម្តេច ។
ជាបគាលដ៏គួរធំធំមិនគួរ មិនមួដូជាតិឃ្មោតកលកិច្ច
មិនហួសរំហែងទ្រង់ជាប់ខ្ចាចតិច ក្រឡិចកិច្ចការតំចាត់តាមការណ៍ ។

(មានត)

លោក ស៊ុន-ហាន ប្រែរៀបរៀង

លោក យ៉ូរ-អ៊ុង ពិនិត្យកែសម្រួល

(តមក)

មាណពបានសង្កេតឃើញនូវសេចក្តីគោរពចិត្តនៃអមាត្យ ដោយសារស្តាប់ពាក្យនៃខ្លួនក្រឹមលើកដំបូង ក៏គ្រេកអរយ៉ាងខ្លាំង តែមានបំណងនឹងឲ្យអមាត្យ ឃានចូលចិត្តនូវសេចក្តីពិតចំពោះភាក្យប្រដៅដែលជាគោលដំបូង ទើបប្រាប់ថា:

" ការបង្រៀនដោយសេចក្តីគ្រោធ ដោយសេចក្តីលោភនឹង ដោយសេចក្តីវង្វេង ជាហេតុធ្វើឲ្យមនុស្សគ្រេកសេចក្តីសុខគ្មានឡើយ សំឡាញ់ ! . . . " ។

"ការបង្រៀនមិនមានផ្លូវណាដែលទទឹងហាមឃាត់បានទេ មាណពសំឡាញ់, ព្រោះកាលកើតលោភឡើងហើយ អ្នកណាឈ្នះជាងគេ ក៏រមែងបានប្រៀបជាងគេ, អ្នកណាលង់ខ្លៅជាងគេក៏ត្រូវធ្លាក់ខ្លួនទៅជាទុយគេ ស្រេចហើយតែគេសង្កត់សង្កិនដំរជាន់បានតាមចិត្ត, លោកយើងនេះក៏យ៉ាងនោះដែរ ទណ្ឌនឹងអាចហាមលោកបាន, អ្នកធ្វើការបង្រៀនមានលក្ខណៈជាច្រើន ព្រះពុទ្ធទើបបានទ្រង់បញ្ញត្តច្បាប់ដាក់ទោស តែការប្រព្រឹត្តិអាក្រក់របស់មនុស្សអាក្រក់ក៏នៅតែមានជានិច្ច"

នេះជាពាក្យអមាត្យថ្កោលតិះដៀលដំណាស់ឡើង ក្នុងខណៈមាណពកំពុងនិយាយមិនទាន់ចប់ ទើបមាណពតបវិញ :

"សំឡាញ់ដ៏ ឈ្មោះថាការហាមអ្នកដទៃ បង្ខំអ្នកដទៃឲ្យធ្វើតាមពាក្យប្រដៅរបស់ព្រះពុទ្ធអង្គមិនមានឡើយ, ព្រះពុទ្ធអង្គសូម្បីក្នុងកាលដែលកំពុងផ្សាយសាសនា ក៏ព្រះអង្គទ្រង់ប្រោសប្រដៅចំពោះតែអ្នកដែលចូលចិត្តនឹងពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ព្រមទទួលធ្វើតាមព្រះអង្គ នរណាមិនជឿមិនជ្រះថ្លា ក៏ព្រះអង្គមិនទ្រង់ហាមឡើយ ។ ព្រះអង្គតែងទ្រង់ប្រដៅថាធ្វើអំពើបែបនេះគាត់គួរលះចេញ អំពើបែបនេះល្អ គួរគាប់យកធ្វើឲ្យមានឡើង អ្នកឈ្លាសវៃប្រែប្រាជ្ញាពិចារណាតាមតួរព្រះអង្គហើយ ក៏អាចយល់ហើយប្រតិបត្តិតាមបាន, វិសេសជាងនោះទៅទៀត កាលបើសាសនារបស់ព្រះអង្គត្រូវគេប្រៀនប្រៀន ព្រះអង្គមិនទ្រង់ហាមអ្នកប្រៀនប្រៀនឡើយ ព្រះអង្គទ្រង់ហាមចំពោះតែអ្នកពប់អានសាសនារបស់ព្រះអង្គទៅវិញ ដូចមានរឿងដែលកើតឡើងដល់ព្រះអង្គ កាលទ្រង់ស្តេចប្រោសសត្វលោកបានលើកតំកើងនូវសាវ័ក ១ រូបរបស់ព្រះអង្គ ខណៈដែលចេញទៅចំពេញការណីយកិច្ចទៅជនបទដទៃ ។ ដែលសម្បុរទៅដោយមនុស្សអ្នកប្រទូសរ៉ាយ, ព្រះអង្គបានត្រាស់សួរសាវ័ករបស់ព្រះអង្គនោះថា:

"បានឮថាពីដែលលោកទៅនោះមានមនុស្សពាលច្រើន ដែលប្រព្រឹត្តឲ្យជាទីស្តៅក្រហាយផ្សែង ។ មិនប្រាកដថានឹងបានធ្វើយ៉ាងណា ។ ល ។ តែបើប្រសិនជាលោកត្រូវគេស្តីថា តើនឹងធ្វើយ៉ាងដូចម្តេច ?

សារីកតបថា ៖

“ កាលបើគេស្តីថាឲ្យ កំគង់ល្អជាងគេជេរ, ខ្ញុំព្រះអង្គក៏ល្មមនឹងអត់ធ្មត់នៅបាន ”;

ព្រះសម្មាសម្ពុទ្ធមានព្រះតម្រាស់សួរតទៅទៀត ៖

“ កាលបើគេជេរលោក តើលោកនឹងធ្វើយ៉ាងដូចម្តេច? ”;

“ បពិត្រព្រះអង្គដ៏ចំរើន ! កាលបើគេជេរខ្ញុំព្រះអង្គ កំគង់ល្អជាងគេប្រហារខ្ញុំព្រះអង្គ, ខ្ញុំព្រះអង្គនឹងអត់ធ្មត់នៅក្នុងទីនោះបាន ”;

“ ម្នាលកិកុ ! បើប្រសិនជាគេធ្វើវិសេសជាងនោះទៅទៀត គឺគេមិនស្តីឲ្យ, មិនជេរ, មិនប្រហារលោកទេ តែគេសម្លាប់លោក? ”;

“ បពិត្រព្រះអង្គដ៏ចំរើន ! កាលបើគេសម្លាប់ខ្ញុំព្រះអង្គហើយ កំគង់ល្អជាងអ្នកដែលធ្លាប់ចង់ស្លាប់តែមិនមានអ្នកណាសម្លាប់? ”;

ឧទាហរណ៍មានន័យដូចបាននេះមកនេះឯង សំឡាញ់ ! ព្រះពុទ្ធអង្គមិនទ្រង់ហាមអ្នកដទៃ តែព្រះអង្គទ្រង់លើកតំកើងនូវការហាមខ្លួនឯង កាលបើសារីកខ្លួនតបដូច្នេះហើយ ព្រះអង្គទ្រង់សរសើរសារីកនេះថាជាឯតទគ្គៈខាងផ្លូវមានឧត្តិគុណ ព្រោះអត់ធន់ចំពោះការបៀតបៀនការជេរស្តី ការធ្វើប្រទូសក៉ាយ ។

អមាត្យជាលិតនៅស្ងៀម ក្នុងពេលដែលស្តាប់ពាក្យរបស់មាណពចប់ហើយ ព្រោះការភ្ញាក់ស្រឡាំងកំងចិត្តកើតឡើង ជាហេតុនាំឲ្យមានសេចក្តីជឿខ្លួន ក៏បន្ទូលថាថា:

“ មាណពសំឡាញ់ ! ព្រះពុទ្ធអង្គគឺនរណា? គង់នៅទីណា?

ផ្លែដូចម្តេច ខ្ញុំនឹងបានស្តាប់ពាក្យប្រដៅរបស់ព្រះពុទ្ធអង្គដ៏ជ្រាលជ្រៅ
ក្រៃលែងជាងនេះទៅទៀត ដែលអាចនឹងកើតប្រយោជន៍ដល់ខ្ញុំយ៉ាងច្រើន; សូមសំឡាញ់មេត្តាប្រាប់ទីរបស់ព្រះអង្គនឹងទិសដែលត្រូវទៅ
គាល់ព្រះអង្គដល់ខ្ញុំផង, ខ្ញុំគិតថាថ្ងៃណាមួយខាងមុខ ខ្ញុំគង់តែជួបនឹង
ព្រះពុទ្ធអង្គពុំខានឡើយ" ។

មាណពគ្រីក្សាល មុនដែលពោលពាក្យចេញមក ដោយមាន
សេចក្តីរំភើបភ្ញាក់ផ្អើលក្នុងខ្លួនយ៉ាងក្រៃលែង ក្នុងកាលបានដួចពាក្យដូច
ជាក្មេងមិនទាន់ដឹងក្តីមកអង្វរសូមវត្ថុដែលមិនមានក្នុងលោកនេះ សូម្បីតែ
ខ្លួនរបស់គាត់ក៏មិនបានដឹងនូវពាក្យប្រៀនប្រដៅ របស់ព្រះសម្មាសម្ពុទ្ធ
ម្ចាស់ដោយពិតប្រាកដផង ទាំងមិនភ្ញាប់ឃើញនូវតួអង្គរបស់ព្រះសម្មា-
សម្ពុទ្ធម្ចាស់ឡើយ, សេចក្តីតក់ស្លុតបានកើតឡើងក្នុងចិត្ត ទើបគេច
មុខចេញទៅអំពីអមាត្យ ហើយពោលថា:

"ព្រះពុទ្ធអង្គដែលលោកប្រាថ្នាចង់ជួបនោះ សូម្បីនរណា ។ ក៏មិន
អាចជួបនឹងព្រះអង្គបានទេ ព្រោះសេចក្តីពិតជាំទៀងទាត់ដែលព្រះអង្គ
ទ្រង់បានទទួលក៏ប់រងមកក៏កើតប្រាកដដល់ព្រះអង្គហើយ គឺព្រះអង្គ
បានស្តេចលែងទន្ទឹមនិញ្ញានហើយ ក្នុងកាល ១២០០ ឆ្នាំដែលកន្លងមក
នេះ" និយាយមកដល់ត្រឹមនេះ មាណពក៏លែងនិយាយតទៅទៀត
ហើយក៏គេចមុខចេញ ។

អមាត្យប្រាប់ត ឃើញមាណពគេចមុខទៅខាងម្ខាង ក៏ដេញស្តី
ថែមទៀតថា:

"បើដូច្នោះ ខ្ញុំអស់មានឧបាសនឹងជួបស្តាប់ពាក្យប្រៀនប្រដៅដ៏ល្អ អំពីព្រះពុទ្ធអង្គហើយឬ?" ។

កាលអមាត្យសួរយ៉ាងនេះ មាណពក៏ដកដង្ហើមធំ តបថា:

"ឧបាសនៅមាន សំឡាញ់, តែលោកអាចនឹងជួបបានចំពោះតែពាក្យប្រៀនប្រដៅរបស់ព្រះអង្គប៉ុណ្ណោះ, ចំណែកព្រះពុទ្ធអង្គគឺលោកមិនអាចនឹងជួបឡើយ" រួចមាណពពោលតទៅទៀតថា:

"សេចក្តីសាបសូន្យវត្តុគ្រប់យ៉ាងក្នុងលោកនេះ ជាវបស់ធម្មតា, ព្រះធម៌របស់ព្រះពុទ្ធអង្គនោមាន ទោះបីមិនសាបសូន្យទៅតាមក៏ដោយ តែក្នុងសភាពធម្មតា តែងប្រជុំបុរេក្នុងសេចក្តីសាបសូន្យជួបគ្នា, បើមិនមានសាវ័កបស់ព្រះសាស្តាដកបណា ដកបន្ទោះពាក្យប្រដៅរបស់ព្រះអង្គក៏ឈ្មោះថាសាបសូន្យអស់ទៅដែរ. . . " ។

អមាត្យបាលិតសំដែងទឹកមុខស្រស់ថ្លា ធ្វើអាការហាក់ដូចជាមានបំណងអ្វីមួយ និយាយតបថា:

"ខ្ញុំជឿជាក់ថាធម៌របស់ព្រះអង្គនៅមានពិតប្រាកដ, ព្រោះក្នុងនគរពាណាសី នៅមានព្រះសង្ឃ ๑ ពួកគង់ក្នុងអាវាសជាមួយគ្នា តែគ្រាប់ចាកអំពីអាវាសក្នុង ๑ ឆ្នាំ ๆ ឃ្លាំ ๆ ទើបត្រឡប់ចូលទៅនៅក្នុងអាវាសវិញ ខ្ញុំជឿថាព្រះសង្ឃទាំងនោះហើយជាសាវ័កបស់ព្រះសម្មាសម្ពុទ្ធមែន ព្រោះត្រូវនឹងពាក្យដែលលោកពោលអំពីដំបូងថា មិនបង្គាប់នរណាឲ្យកាប់អានឬដុះថ្ងាឡើយ" ។

"ត្រូវហើយ សំឡាញ់ជា! លោកជាអ្នកក្រុងពាណាសីឬ?

ហេតុដូចម្តេច លោកមិនស្គាល់សាវ័កបស់ព្រះពុទ្ធជាម្ចាស់? ព្រោះ
នគរពាណាសីជានគរមួយធ្លាប់ជាទីចារិកបស់សាវ័កព្រះគោតមមក តាំង
អំពីកាលព្រះពុទ្ធអង្គនៅមិនទាន់ស្តេចរំលត់ទន្លងបូលកាន់បរិនិព្វានម្ល៉េះ"
មាណពតប ។

អមាត្យបាលិតក៏ទីករយើញក្នុងខណៈនេះភ្លាម ពាំងនឹកតិះដៀលខ្លួន
ឯងដែលចេះតែមើលរំលងនូវសាវ័កបស់ព្រះសម្មាសម្ពុទ្ធម្ចាស់ សូម្បី
ធ្លាប់ជួបស្ទើរតែគ្រប់ពេលវេលា, ក្នុងពេលជួបម្តងៗ គួរណាស់
តែទិយាយសាកសួរកាត់ជាក់ខ្លះ, ទើបច្រាបមាណពថា:

"ព្រោះសេចក្តីល្ងង់ខ្លៅរបស់ខ្ញុំ ដែលខ្វះខាតការយកចិត្តទុកដាក់
ហើយច្រកាន់ក្នុងលទ្ធិរបស់ខ្ញុំថាមានខ្លឹមសារផង ជាន់ជាមិនជាន់តិតថា
នៅមានសាស្តាច្រើរក្រៅពីសាសនាព្រាហ្មណ៍" ។

មាណពស្តាប់ពាក្យអមាត្យបាលិតដោយសេចក្តីពេញចិត្តតាំងអំពី
ជានសន្ទនាតមក, អមាត្យបាលិតជាអ្នកចេះទន្លំគាន់មានកាតជាធំ
សមគួរដល់រៃយ លុះកាលជានស្តាប់រឿងរ៉ាវបស់ព្រះពុទ្ធគន្ធតែមតែបន្ថែម
បន្ថែមប៉ុណ្ណោះ ក៏ជានដឹងដោយជាក់ច្បាស់, មាណពក៏កើតសេចក្តីរាប់
អានចំពោះអមាត្យនោះរឹងតែតឹងឡើង ទើបពោលថា:

"សំឡាញ់ជាអ្នក! ឥឡូវនេះដល់វេលាដែលគួរនឹងឈប់សម្រាកហើយ
ខ្ញុំកំពុងគិតនឹងសង្គ្រោះចំពោះសត្វដែលត្រូវគេបៀតបៀន, សូមលោក

អញ្ជើញទៅសម្រាកនៅបន្ទប់ខាងណោះចុះ សូមសេចក្តីសុខសប្បាយ
កើតមានដល់លោកអស់រាត្រីកុំបីឃ្លាតឡើយ" ។

* * *

- ๒ -

ថ្ងៃ ๑๕ កើត ព្រះចន្ទពេញវង់ ជាថ្ងៃតំណត់ឫក្សធ្វើពិធីបូជាយ័ញ្ញ
របស់ព្រះពជាមកដល់ហើយ, ក្នុងកេងពិធីមុខព្រះបរមរាជវាំងសឹងណែន
ណាន់តាន់តាប់ ដោយទាហានត្រួតត្រាព្រះអង្គឈរជាជួរវៀងរាយ
ត្រៀមចាំរក្សាទ្វារសេចក្តីសូប់រៀបរយ ។ ការត្រៀមពិធីបុណ្យនេះ
ចាប់ផ្តើមឡើងអំពីព្រលឹម, ពួកព្រាហ្មណ៍កំពុងធ្វើពិធីសូត្រឮងសួង
ដោយមានពីការផ្សេងៗ, ពួកប្រជាជនខាំគ្នាដើរវាយចូលទៅក្នុងបរិវេណ
ដើម្បីមើលពិធីបុណ្យបូជាយ័ញ្ញទំនមហោស្រពផ្សេងៗ ។ ខណៈនោះ
ព្រះពជាមិនទាន់ស្តេចមកដល់នៅឡើយ តែជិតទំនឹងដល់វេលាដែលស្តេច
មកហើយ ។ ក្បួនហែ ๑ នាំមុខ ដោយមានទាហានសេះចេញតាមទ្វារ
ព្រះពជាំង ទាហានស្មែងស្មែងមានដំបូល ដែលបិទបាំងដោយកាំនន
ជិតស្និទ្ធស្អ កំមកក្នុងក្បួននោះ ។ សម្តេងប្រជាជនដែលនៅក្នុងបរិវេណ
កំពុងស្រែកច្បាប់គ្នាតៗថា "ព្រះអង្គម្ចាស់ក្សត្រីកំពុងប្រឈួនខ្លាំង, អាការ
ព្រះឈួននោះអាចនឹងដល់នូវសេចក្តីអន្តរាយ ព្រះជន្មបាន" ក្បួនហែលឿន
សន្សឹម ។ ចូលទៅតាំងនៅកេងពិធី ។ ខណៈនោះ ព្រាហ្មណ៍
កំពុងតែសូត្រឮងសួង, ទាហានឈរជាជួរវៀងរាយការពារប្រជាជនមិនឲ្យ
ចូលទៅក្នុងទ្វារដែលព្រះពជាំនឹងស្តេចមក ។

បណ្តាពួកមហាជនដែលនាំគ្នាដើរចូលមកមើលពិធីយ័ញ្ញ មាន
អមាត្យឈ្មោះសិតនឹងមាណពកម្មោះទៅផងដែរ ជន ២ នាក់នេះកំពុងយាម
វែកញែកជជែតជែកគេចូលទៅដល់ថែវាងមុខ ដែលជាទីអាចមើល
ពិធីគ្រប់យ៉ាងដោយជាក់ច្បាស់បាន ។

មាណពកេះអមាត្យឈ្មោះសិតឲ្យមើលក្រងំខាងសត្វក្នុងពេលពិធីដែល
ជាក់សត្វផ្សេង ។ មានពពែ សេះ គោ ក្របី ជាដើម ដែលគួរឲ្យវេទនា
ហើយថ្លែងថា:

សំឡាញ់ចាស់! ក្នុងសម័យមួយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់បាន
ទ្រង់ហាមឃាត់នូវពិធីបូជាយ័ញ្ញ របស់ព្រះពជាមកអំពីមុនដែរហើយ
ដោយព្រះអង្គជាបក្ខពួកព្រះទ័យថា កម្មមានទោសជាទម្ងន់ធ្ងន់តើតមាន
ដល់ព្រះពជាព្រោះតែពិឃាតសត្វមានជីវិត, បណ្តាសត្វទាំងនោះ សត្វខ្លះ
មានកូន ខ្លះកំពុងឈឺចាប់ ខ្លះមានគតិ មិនគួរដល់ការពិឃាត ដែលជា
ការណកម្មដ៏សាហាវយង់ឃ្នង" កាលនិយាយហើយក៏ចង្អុលទៅមេគោ ១
ដែលមានសម្បុរស កំពុងតែលិទ្ធតាមដងខ្លួនកូនគួចមួយ ដែលកំពុង
ចៅដោះដោយសេចក្តីសប្បាយ, ទាំងមេទាំងកូនក៏មិនដឹងថាសេចក្តីស្លាប់
កំពុងតែសសៀរចូលមកដល់ឡើយ; ហើយថ្លែងថា:

"សំឡាញ់ចាស់! ព្រះពុទ្ធអង្គទ្រង់សំដែងថា សេចក្តីស្លាប់ជា
របស់ដែលនរណា ។ មិនអាចដឹងពិតបានឡើយ ដូចសត្វទាំងឡាយនេះ
មិនដឹងនូវសេចក្តីស្លាប់របស់ក់ដែរ" ។

អមាត្យសិត មានសេចក្តីតក់ស្លុតចិត្តទៅតាមពាក្យរបស់មាណព,

ក្នុងចិត្តទឹកចង់ជួយសត្វទាំងនោះឲ្យផុតពីការពិឃាតក្នុងគ្រានេះ ទើប
សួរថា ៖

"លោកនឹងអាចជួយសត្វទាំងនេះឲ្យរួចផុតចាកអន្តរាយបានទេ?" ។
មាណពទ្រីងមួយស្រែបក់ ទើបតបថា:

"ក្នុងរឿងនេះ ខ្ញុំកំពុងតែគិតរកផ្លូវ" ។

ខណៈនោះ ពួកអ្នកប្រកបពាណិជ្ជបានទាំហូរសត្វទាំងនោះចូលទៅជិត
ខែនបូជា, ឯពួកសត្វសេះ គោ ឧទ្ធ ក្របី ដែលត្រូវគេដឹកនាំទៅ ក៏ក្រាក់
ផ្តើលប្រអូសប្រតាញគ្នាយ៉ាងកោលាហល ។

ប្រជាជនដែលនៅក្នុងបរិវេណជុំវិញរោងពិធី ក៏យល់ថាយញ្ញពិធី
ផ្តើមឡើងហើយ ។ សម្តេងស័ង្ខជាសញ្ញាថាព្រះពជារស្តេចមកហើយ
ក៏បន្ទឺឡើង សម្តេងគឹកគងរំពងនោះស្ងប់ស្ងាត់ទៅ, ព្រះពជាក៏ស្តេចចូល
ទៅប្រថាប់នៅព្រះពន្លា, ពួកព្រាហ្មណ៍ទើបស្មូតសម្តេងសូត្រ ក្អាត់ជារ
បានទាំគ្រឿងសំណែនថ្វាយព្រះពជា ទាំងថ្វាយព្រះអង្គម្ចាស់ក្សត្រី
ដែលសើយកាំងនន ឲ្យឃើញអង្គដ៏ស្គមកំព្រឹង គន់ផ្អែកនឹងក្អាក់ដៃ ថ្វាយ
បង្គំព្រះបិតា, ក្អាក់ជាវថ្វាយគ្រឿងសំណែនរួចហើយក៏នាំគ្នាចេញមក ។
បន្ទាប់មក ពួកព្រាហ្មណ៍ពោលពាក្យជូយ៉ាញ់ដ៏តួរតក់ស្លុត រួចទើប
ឲ្យគេនាំសត្វចូលមកសម្លាប់នាខែនបូជា:

"នុម: បពិត្រមហិស្សរខេត្តជាធំក្នុងកពជាអម្ចាស់ដ៏មានមហិស្សក្ត
តេជានុភាពលើសលប់ មិនមាននរណាខ្លាចខ្លាំងបាន, ឥឡូវនេះព្រះពជា
ដ៏ខ្ពង់ខ្ពស់ ខ្ពង់ស្តេចមកធ្វើពិធីបួងសួង សូមអំណាចមហិស្សក្តតេជា-

ខុកាពខែធ្នូ ការពារខ្លួនព្រោះពេជ្រ ខ្លាំងសត្វតាំងឡាយ សូមបំបាត់កំចាត់កាយខ្លួនឯងតាំងពួងបួងវិនាសសាបសូន្យ ហើយបណ្តាលឲ្យមានទឹកភ្លៀងធ្លាក់ត្រជាក់តាមរដូវកាល, សូមឲ្យពេជ្រដែលកើតដល់ពួកប្រជាជនស្តេចសាបសូន្យទៅ . . . " ។

ក្នុងខុកាសសូត្រខ្លួនខុងនេះ ដើងគ្រានភ្លើងធំដែលគេដុតកំនេះតែតែខ្លាំងឡើង ដុំផ្សែងធំកំកួចឡើងទៅលើពេញតាំងបរិវេណ, មួយរំពេចនោះ ព្រាហ្មណ៍ក៏បង្គាប់ឲ្យភ្នាក់ងារនាំសត្វចូលមក ។

មេគោសនឹងកូនខ្លួងជាសត្វចិញ្ចឹម មិនមានអាការតក់ស្លុតសោះព្រោះវាសាំងដោយសារចំណីគឺស្មៅនឹងទឹក ដែលគេចិញ្ចឹមពាល់ ១ ថ្ងៃ, កាលគេដឹកវាក៏ដើរតាមគេទៅដោយស្ងាត់ស្ងៀម, កូនគោអាល័យមេ ឃើញគេដឹកមេទៅក៏ដើរតាមមកផង ឥតដឹងថាគេដឹកមេយកទៅដើម្បីសម្លាប់សោះ ហើយខ្លួនឯងត្រូវគេសម្លាប់ទៅតាមមេផងដែរ មេគោដើរតាមគេដឹកមកដល់ទ្វារធំ, ព្រាហ្មណ៍បង្គាប់ឲ្យមនុស្សដឹកឈរចាំទ្វារមេគោនោះ, កាលមេគោត្រូវគេផ្លុំកំដេកសណ្តែកដើងតាំង ៤ ចេញទៅខាង មាត់ទៅចំពោះអៀង, មនុស្សដឹកតាញខ្សែមកដើម្បីចងដើង, កូនគោដើរចូលទៅជ្រៅដោះមេ, មនុស្សដែលកំពុងចងដើងមេគោឃើញដូច្នោះហើយ ឃាត់ចុងខ្សែរួយកូនគោនោះត្រូវត្រង់ក, កូនគោឈឺកំស្រែកកេរ៉ែតត្រឡប់ទៅ; ខណៈនោះ មេគោបានឮសម្លេងកូនកេរ៉ែកំគ្រែកឡើងតេះចេញទៅ ធ្វើឲ្យពួកភ្នាក់ងារតេះដេញចាប់តាក់តាំងពួន ។

រឿងសាមកុក

កណ្ឌទី ២៣

ឧកញ៉ាវិបុលរាជសេនា ស្វ - កាង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
ធំងបេះខួបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

គួនអ៊ូក៏ពណិនាសេចក្តីតាំងពីដើមដល់ចប់ ប្រាប់ស៊ុនខៀនស្តាប់គ្រប់ប្រការ; ស៊ុនខៀនក៏និយាយនឹងគួនអ៊ូថា ខ្ញុំបានឮដំណឹងថា ឡៅពីទៅនៅនឹងអ្នកនេសៀរចៅហ្វាយស្រុកគង្គជីវ, ដែលខ្ញុំមកទៅនឹងឡៅផេកនេះ ខ្ញុំក៏បាននិយាយបញ្ចុះបញ្ចូលឡៅផេកនឹងកុងតេ ។ ក៏ព្រមចូលទៅធ្វើការនឹងឡៅពី ដើម្បីជួយគិតការកំចាត់ចូឆូរចេញឲ្យបាន, ឥឡូវឡៅផេកដឹងថាអ្នកលើកទ័ពមក ទើបប្រើឲ្យហានេះឲ្យនាំផ្លូវខ្ញុំមក មានបំណងនឹងឲ្យខ្ញុំជូនដំណឹងអ្នកថា ពេលព្រឹកស្អែកឡៅផេកនឹងកុងតេនឹងចេញមកច្បាំង ហើយធ្វើជាចាញ់ថយទ័ពទៅឲ្យអ្នកមានបំណងចាប់បែរទៅនឹងចូឆូ ដើម្បីនឹងបានទាំងនឹងថ្ងៃទាំង ២ ទៅជួបនឹងឡៅពីឯគ្រុងគង្គជីវ ។

គួនអ៊ូបានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរណាស់ថា ឥឡូវយើង

ដឹងដំណឹងជាក់ហើយថា ខ្ញុំតើទៅទៀងអ្នកសៀវ មុខជាយើងនឹងនាំបងថ្លៃតាំង ២ ទៅជួបនឹងខ្ញុំតើមិនខាន ពេះបើអ្នកសៀវដឹងថាយើងបានសម្លាប់សេនាឯកអ្នកសៀវ ២ នាក់ស្លាប់ អ្នកសៀវនឹងសម្លាប់ដីវិតយើងវិញក៏តាមចិត្តចុះ សុំឲ្យតែយើញមុខខ្ញុំតើបងយើងសិន បើយើងមានជ័យជំនះខ្ញុំផេកហើយ យើងនឹងត្រឡប់ចូលទៅក្រុងហ្គូតោដើម្បីនឹងរាជូនាំបងថ្លៃតាំង ២ ទៅវិកខ្ញុំតើ ។ ស៊ុនខៀនថា បើដូច្នោះខ្ញុំនឹងទៅវិកខ្ញុំតើមុនអ្នក ដើម្បីស្តាប់ដំណឹងមើលជាអ្នកសៀវខឹងខ្លាំងនឹងអ្នកណាស់ទៅ ឬប្រការម្តេច? បើបានដំណឹងល្អ ឬអាក្រក់យ៉ាងណា ខ្ញុំនឹងស្រែតមកដំរាបអ្នកឲ្យដឹងវិញ ។ គួនអ៊ូក៏ពេញចិត្តណាស់ លុះពេលយាម ៣ ក៏បង្គាប់ឲ្យទាហានដែលចំនុកទុកចិត្តនោះ ស្រាយសែងស៊ុនខៀននឹងទាហានម្នាក់ឲ្យលបរត់ចេញទៅពីបន្ទាយ ដល់ពេលត្រឹកគួនអ៊ូក៏ចាត់ចែងទាហានលើកចេញទៅច្បាំងនឹងពួកខោវ ។

ឯកុងតេលុះដឹងថាគួនអ៊ូលើកទ័ពមក ក៏លើកទាហានចេញទៅត ។ គួនអ៊ូក្រែកឡែកយើញក៏បរសេះសុះទៅពីមុខទាហានហើយក៏ក្អែងស្រែកថា នែកុងតេ! ហេតុម្តេចបានជាខ្លួនមកតប់នឹងបក្សពួកខោវ ធ្វើអំពើខុសច្បាប់ក្សត្រដែនដីដូច្នេះ? ។ កុងតេវិធ្វើយតបថា យើងនឹងធ្វើជាមនុស្សខុសច្បាប់នឹងដែនដីក៏ទេ តែខ្លួនអ្នកឯងទេតើជាមនុស្សអកតញ្ញូមិនដឹងគុណនាយទៅហ្នឹង ដូចយ៉ាងខ្ញុំតើជានាយទៅហ្នឹងរបស់ខ្លួនទៅនៅត្រកកោននឹងអ្នកសៀវ ហេតុម្តេចក៏ខ្លួនទៅចូលខាងបក្ខពួ បើដូច្នេះខ្លួនមិនក្សត្រនឹងខ្ញុំតើឬ? ។ គួនអ៊ូមិនធ្វើយតបសោះក៏បរសេះចូលតយុទ្ធនឹងកុងតេ

ចាន ៥ ក្តៅ, កុងតៅធ្វើជាតាញសេះរត់ គួនអ៊ូកំប៉ាយសេះដេញពីក្រោយ កុងតៅឃើញគួនអ៊ូដេញតាហានចូលទៅកំពង់ន៏សេះមកទឹមស្មាគ្នា ហើយងាកមុខមកនិយាយទឹងគួនអ៊ូថា ស្រុកយើឡាំដែលនៅកងកណ្តាប់ដៃយើងនេះ យើងនឹងលើកប្រគល់ជូនអ្នកតាំងអស់ តែកុំឲ្យអ្នកភ្លេចគុណចំណាចរបស់ខ្លួនពីមុខ ។

គួនអ៊ូបានឮកុងតៅថាដូច្នោះ ក៏ឃើញត្រូវគ្នាទឹងសំដីស៊ុនខៀនទើបក្តៅបរសេះដេញចូលទៅកងពួកតាហានកុងតៅ។ កំនាំខ្លាផេកនឹងតាហានតាំងពួនរត់ទៅ ឯបណ្តាស្រុកចំណុះដែលខ្លើនស្តាប់បង្គាប់ស្រុកយើឡាំតាំងប៉ុន្មានដែលខ្លាផេកនឹងកុងតៅវាយយកបាននោះ គួនអ៊ូក៏ប្រាប់ប្រាមបានពាបតាបជូចដើម ហើយគួនអ៊ូក៏លើកកងទ័ពត្រឡប់ចូលទៅក្រុងហ៊ូគោវិញ នាំយកសេចក្តីទៅដំណាបចូនថា បានប្រាបប្រាមចោរពាបតាបហើយ ។ ចូនក៏សប្បាយរីករាយក្នុងចិត្តណាស់ ហៅគួនអ៊ូបរិភោគអាហារជាមួយគ្នា ហើយឲ្យបំណាចរង្វាន់សេនាតាហានតាមគុណានុរូបដ៏សមគួរ ។

គួនអ៊ូក៏លាចូនមកផ្ទះ ទើបចូលទៅគំនាប់បងថៃទាំង ២ ត្រង់មាត់ទ្វារពណិនាសេចក្តីដែលបានទៅធ្វើការសង្គ្រាម មានជ័យជំនះ ឲ្យបងថៃស្តាប់ត្រេប្រការ ។ នាងគាំហ៊ូយ៉ុនក៏សាកសួរថា ប្អូនទៅធ្វើសឹក ២ លើកហើយ បានឮដំណឹងបងអ្នកឯងខ្លះដែរឬទេ ? ។ គួនអ៊ូក៏តិតថា បើទឹងពណិនាដោយត្រង់ក្រែងខ្លួនខ្លាយសេចក្តីទៅដល់ចូនចូ ទើបដំកបថា " ខ្ញុំបានទៅធ្វើការនោះក៏បានយកចិត្តគំតសាកសួរដំណឹងជាជាពាប តែមិន

ចានដឹងថាបងនៅទីឯណាសោះ" និយាយដូច្នោះហើយ គួនអ៊ូក៏លាបងថ្លៃថយទៅទីក្នុងវិញ ។ នាងកាំហ៊ូយ៉ុនឮគួនអ៊ូនិយាយដូច្នោះក៏ឲ្យពិការណាស់ ប្រឹក្សាគ្នានឹងនាងប៉ូហ៊ូយ៉ុនថា "ប្រសិនលេខ្មៅពីស្លាប់ហើយ គួនអ៊ូខ្លាចយើងនឹងសៅសោក ក៏ក្លែងបញ្ឆោតកូតយើងមិនប្រាប់តាមត្រង់" និយាយហើយក៏ក្រៀកកន្ទាសោកាខ្លាយយំដំណាក់ ។

វេលានោះ មានឥហានចាស់របស់ខ្មៅពីដែលទៅជាទ័ពជាមួយនឹងគួនអ៊ូ ចានឃើញកវីយាខ្មៅពីសោកខ្លាយយំដូច្នោះ ក៏ចូលទៅឱបប្រាប់ថា អ្នកកុំជាទុក្ខព្រួយពេកឡើយ ខ្មៅពីចៅហ្វាយខ្ញុំចានមិនមានអន្តរាយអ្វីទេ សព្វថ្ងៃលោកទៅនៅទឹងអ៊ូនសៀវចៅហ្វាយស្រុកគីជីវ ។ នាងកាំហ៊ូយ៉ុន ឮឥហានប៉ូហ៊ូយ៉ុនចានឮដូច្នោះក៏ធូរស្រាលក្នុងចិត្ត ទើបសួរថា ហេតុម្តេចចានជាអ្នកឯងដឹងរឿងនេះ? ។ ឥហាននោះក៏ជំរាបថា ខ្ញុំចានចានទៅទ័ពជាមួយនឹងគួនអ៊ូមានគេមកប្រាប់ដំណឹងដូច្នេះ ។ នាងកាំហ៊ូយ៉ុនក៏ឲ្យហៅគួនអ៊ូមកហើយនិយាយថា អ្នកឯងនៅនឹងខ្មៅពី ។ មិនចានធ្វើអ្វីឲ្យទាស់ចិត្តសោះ គ្រានេះចានចូលមកនៅនឹងចូន ។ ក៏ទុកបំរុងឲ្យពេញប្រាថ្នា ចានជាសប្បាយដោយយសបណ្តាស័ក្តិក្រៅចនឹកដល់ខ្មៅពីហើយឬ? ចានជាមិនយកដំណឹងដែលពិតនោះមកប្រាប់ឲ្យយើងដឹងផង ។ គួនអ៊ូភ័យស្លុតចិត្តលុតជង្គង់ចុះហើយជំរាបថា ខ្ញុំចានឹងចានតិតប្រទូសាយេនឹងខ្មៅពីជាបង ប្តូរបងនឹងបំភ្លេចគុណមិនឮកនាដូច្នោះក៏ទេ តែថាបើខ្ញុំចានឹងជំរាបអ្នកជាបងតាមត្រង់ទៅ ខ្លាចគេដឹងសាយសុះបែករឿងនោះទៅដល់ចូន ។ ក៏ឹងប្រឆងប្រយ័ត្ន មិនឲ្យយើង

ចេញខ្លាត់ៗទៅបានដោយស្រួល ហេតុដូច្នេះបានជាខ្ញុំបានមិនដំណាបដោយត្រង់ ។

នាងកាំហ៊ុយនិងថា បើអ្នកមានចិត្តគិតដល់បងអ្នកជាក់ច្បាស់ដូចបងសូមឲ្យគុណសណ្តាំតជួយឲ្យអ្នកមានជ័យឈ្នះសត្រូវគ្រប់ទិសចុះ រីឯនេះបានដំណឹងហើយគួរតែអ្នកខំរិះគិត រកវិធីទៅរកបងឲ្យឃើញមុខគ្នាជាប្រញាប់ ។ គួនអ៊ុំក៏លាត្រឡប់មកវិញ ចេះតែរិះគិតមិនឈប់សម្រាកឃ្លាតចាកពេលបរិភោគអាហារទឹងនិទ្រាដាច់រន្ធត់ ។

ឯអ៊ុំគីមកាលទៅជំពាក់ជាមួយទឹងគួនអ៊ូនោះ លុះដឹងដំណឹងថា ឡៅតីទៅនៅទឹងអ៊ួនស្រីវដូច្នេះ អ៊ុំគីមក៏នាំសេចក្តីនោះទៅជំរាបចូនតួប្តូរប្រការ ។ ចូនតួបានស្តាប់ពាក្យមានការណាក៏មិនមានសេចក្តីសប្បាយសោះ ទើបប្រើខ្លៀវលៀវឲ្យទៅស្តាប់ដំណឹងគួនអ៊ូតើជាទឹងរិះគិតយ៉ាងណា បើបានដឹងដំណឹងឡៅតីដូច្នេះហើយ ។ ខ្លៀវលៀវក៏លាចូនតួទៅរកគួនអ៊ូដល់ហើយក៏គំនាប់គួរសមទឹងគ្នា ឃើញក៏រាយគួនអ៊ូមិនសប្បាយក៏និយាយថា ខ្ញុំឮគេថាអ្នកទៅគ្រានេះ បានឮដំណឹងឡៅតីថាទៅនៅស្រុកខាងទិសឯណោង ខ្ញុំក៏ភ្ញាក់មានចិត្តសប្បាយជាមួយទឹងអ្នក ។ គួនអ៊ូតបថា ខ្ញុំដឹងដំណឹងឡៅតីមានជីវិតរស់នៅឡើយ តទៅវិញក៏មានសេចក្តីព្រួយវិតក្កព្រោះតែពុំបានឃើញមុខឡៅតីនោះសោះ, ដែលអ្នកទឹងមានចិត្តសប្បុរសជាមួយទឹងខ្ញុំនោះ ធ្វើម្តេចទឹងត្រូវ ។

ខ្លៀវលៀវតបថា ខ្លួនអ្នកទឹងឡៅតីបានជាមិត្តភ័ក្តិ ហាក់ដូចជាបងប្អូនបង្កើតទឹងគ្នាទៅហើយ ខ្លួនខ្ញុំនេះក៏ជាមិត្តភ័ក្តិទឹងអ្នកដែរ តើចិត្តអ្នក

ដែលស្រឡាញ់ឡៅតីនីនីខ្ញុំនោះដូចគ្នាដែរ ឬដូចម្តេច? ។ គួនអ៊ូតបថា អ្នកនីនីខ្ញុំជាមិត្តភក់អានគ្នាក៏មែន តែខ្ញុំមិនមែនមានចិត្តស្រឡាញ់ឱ្យស្មើឡៅតីទេ ព្រោះឡៅតីនោះខ្ញុំបានតប់ប្រសព្វមកយូរហើយ ខាងខ្ញុំក៏លើកទុកជាក់ថាជាបងហើយជានាយចៅហ្វាយផង មួយទៀតបានតាំងស្បថសច្ចាន់ទុកនីនីគ្នាទៅវិញទៅមក ហេតុនេះ បានជាខ្ញុំត្រូវតប់អានស្រឡាញ់ឡៅតីជាជាងអ្នក ។ ខៀវលៀវថា ឥឡូវអ្នកជីនីដំណឹងថាឡៅតីនៅនីនីអ៊ូនសៀវហើយ អ្នកនីនីទៅវិកឬ។ នីនីគិតប្រការម្តេច? ។

គួនអ៊ូតបថា តីដើមដំបូងខ្ញុំក៏បានដំរាបទុកមកដល់មហាឧបាជដូចខ្លួនអ្នកធ្វើជាបន្ទាល់ខ្ញុំស្រាប់ ថាខ្ញុំសូមលាទៅតាមពាក្យសញ្ញា ហេតុនេះបើអ្នកស្រឡាញ់ខ្ញុំសូមឱ្យជួយអនុគ្រោះនាំយកផុរៈនេះ ទៅស្នើដល់មហាឧបាជឱ្យគានផងចុះ សូមកុំឱ្យមហាឧបាជមានតំហឹងនីនីខ្ញុំឡើយ ។

ខៀវលៀវក៏នាំយកសេចក្តីនោះ ទៅដំរាបចូនស្តាប់គ្រប់ប្រការ ចូនចូរកំថា យើងនិះគិតចងចិត្តគួនអ៊ូទុកឱ្យបាន តែគួនអ៊ូចេះរំខានព្រួយចិត្តគិតទៅរកឡៅតីមិនកើច ។

ខណៈនោះ មានបំរើទៅជ្រាបគួនអ៊ូថា មានគេមករកលោក ។ គួនអ៊ូឱ្យហៅចូលទៅហើយសួរថា អ្នកឯងឈ្មោះអ្វី, នៅស្រុកណា, មានការអ្វីមករកយើង? គាន់ជីនឆ្លើយថា ខ្ញុំបាទឈ្មោះគាន់ជីនជាគាហានអ៊ូនសៀវ ឥឡូវអ្នកនសៀវប្រើខ្ញុំបាទឱ្យនាំសំបុត្រឡៅតីមកជូនលោក ។ គួនអ៊ូមានសេចក្តីត្រេកអរពន់ពេក ទើបទទួលយកសំបុត្រនោះមកមើលឃើញសេចក្តីថា ‹‹សំបុត្រឡៅតីឱ្យមកដល់គួនអ៊ូបានដឹង តីដើមខ្លួនយើងបាន

ស្បថស្បាន់ទឹងគ្នាទៅវិញទៅមកចាំង ៣ នាក់នៅទីសួនដាច់ថា ទឹងរួមសុខ
ទុក្ខទឹងគ្នា តែខ្ញុំយើងបានទៅនៅពឹងប្រស័យទឹងអ្នកសៀវភៅហ្វាយ-
ស្រុកតែដីវ ខាងខ្ញុំអ្នកមកពឹងតាក់អាស្រ័យនៅទឹងបួនធ្វើការសង្គ្រាម
មានសេចក្តីគាប់ប្រសើរ គេក៏បានស្នើឲ្យគុណចំណាច់ទឹងយសបណ្តា-
ស័ក្តិសមនឹងគុណស្រ័យបានសេចក្តីសុខដោយស្រឹង្គារបរិវារ រៀល
នេះ ប្រហែលខ្ញុំអ្នកភ្លេចភាជាដែលបានស្បថស្បាន់ទឹងយើងនោះហើយ
តែនេះខ្ញុំយើងក៏រស់នៅឡើយមិនទាន់ស្លាប់ បើអ្នកប្តាប្តានឹងចង់បាន
គុណតាប់ឲ្យបួនបួរបាន បានឡើងយសស័ក្តិឡើងទៀត យើងសុំឲ្យអ្នក
ភ្លៀតចេញមកកាត់យកក្បាលយើងទៅឲ្យបួនចុះ” ។

* * *

កំណត់ ២៤

តាំងពីបួនអ៊ិទួលសំបុត្រភ្លៀតហើយយំរលឹកភ្លៀត រហូតដល់បួនអ៊ូរត់ពីបួនទៅ, ហៃហួរទុន
លើកទាហានទៅតាមចាប់ខ្លួន មានប៉ាវកាន់សំបុត្របួនមកឃាត់កុំឲ្យចាប់ឲ្យបើកបួនអ៊ូទៅ ។

លុះបួនអ៊ូមើលសេចក្តីសំបុត្រចប់ ក៏សួរសួរប់ជាទុក្ខស្រែកទឹកភ្នែក
ទៅមុខបំរើនោះហើយនិយាយថា ដែលខ្ញុំមកនៅទឹងបួនេះព្រោះតែ
ខាល់តំនិត ទឹងបានគិតបំភ្លេចមិនទឹកដល់ឡើយពីជាបងនោះក៏ទេ ពោះបើ
ខ្ញុំសុំយកអាសាចេញទៅច្បាំងវៀលណា ក៏តែងស៊ើបសួរដំណឹងជាជាបង
លុះបានដំណឹងថាបងទៅនៅទឹងអ្នកសៀវច្បាស់ ក៏រៃគិតទឹងរកឧបាស
ទៅ តែមិនទាន់មានពេលបន្តោះសោះ ។ តាន់ដិនថា បើអ្នកមានចិត្ត
សប្បុរសរក្សាភាក្យសច្ចពិតដូចវាថា ក៏គួរខំឧស្សាហ៍រៃគិតទៅរកឡើយពី

កុំឲ្យខាន ។ គួនអ៊ូតបថា "កាលខ្ញុំចុះចិត្តមកទៅនឹងចូនួជាបឋម ខ្ញុំក៏ជាន ប្តេជ្ញាខ្ចុកនឹងចូនួ ៣ ប្រការ, ឥឡូវនេះបើដឹងដំណឹងហើយប្រញាប់ទៅ តាមសញ្ញាមែនក៏គិតខ្លាចគេតវាទនិន្នា, ដូច្នេះ យើងត្រូវគិតរកឧបាយ លាចូនួទៅឲ្យបានដោយស្រួលសិន ទោះបីចូនួនឹងមិនព្រមឲ្យទៅ ខ្ញុំក៏ ត្រូវតែទៅឲ្យបាន" ហើយគួនអ៊ូក៏តែងសំបុត្រតបទៅឡាតវិញ តាម ដំណើរដើមទង្គែប្រការ ប្រគល់ឲ្យតាន់ដន ។ ទទួលសំបុត្រហើយក៏ លាគួនអ៊ូចេញទៅវិញ ។ គួនអ៊ូក៏នាំសំបុត្រនោះទៅពណិនាថ្វាយបង ថ្ងៃទាំង ២ ឲ្យថ្វាយទង្គែប្រការ ។ បងថ្ងៃទាំង ២ ក៏សោមនស្សត្រេកអរ ណាស់ គួនអ៊ូក៏លាបងថ្ងៃទៅកេចូនួដើម្បីនឹងលាទៅកេឡៅតី ។

ខណៈនោះមានមនុស្សចូលទៅជំរាបចូនួថា គួនអ៊ូនឹងចូលមកដំរាប លាលោកទៅកេឡៅតីហើយ ។ ចូនួក៏បិទទ្វារផ្ទះទាំងអស់ ហើយ សរសេរសំបុត្រចំរ៉ាមបិទខ្ចុកទៅមាត់ទ្វារថា មហាឧបាសមិនសូវសប្បាយ កុំឲ្យអ្នកឯងទាំងឡាយចូលទៅប្រឹក្សាការអ្វី ។ ឡើយ ។ គួនអ៊ូដឹងដូច្នេះ ក៏ទៅដល់មាត់ទ្វារមើលចំរ៉ាមឃើញហាមហើយ ក៏ត្រឡប់ទៅលំនៅវិញ ហើយឲ្យពាហនរបស់ខ្លួន ១១ - ១២ នាក់ រៀបប្រដាប់ប្រៀបរថសម្រាប់ ឲ្យបងថ្ងៃទាំង ២ ជិះនឹងអ្នកទ្រព្យរបស់ស្រាល ។ គឺគ្រឿងសម្លៀកបំពាក់ នឹងមាសប្រាក់ ឯរបស់ទ្រព្យឯទៀតនឹងស្រែចំការដែលចូនួឲ្យទៅទៅ សម្រាប់ប្រើប្រាស់នោះ កុំឲ្យនរណាយកទៅណា លុះពេលព្រឹកគួនអ៊ូ ក៏ចូលទៅលាម្តងទៀត ឃើញបិទទ្វារដៃដែលក៏ដើរចូលទៅផ្ទះទៀតលើរ, តែអ្នកចាំទ្វារមិនព្រមឲ្យចូលទៅប្រាប់ថាទៀតលើរឈឺ ។

គួនអ៊ូគិតថា "ចូរឆ្លើយដូចនេះគឺក្លែងមិនចង់ឲ្យយើងទៅចួបនឹងខ្មៅពីខ្លួនយើងក៏មានបរិវិតក្តីនឹងបង្អង់នៅតទៅមិនបាន" ក៏ត្រឡប់មកឱហានវិញ ហើយសរសេរសំបុត្រទុកថា "ខ្ញុំបាទគួនអ៊ូ សូមថ្វាយជំរាបសេចក្តីឲ្យមហាឧបរាជជ្រាប ព្រោះខ្ញុំបាទនឹងខ្មៅពីនោះបានស្បថសច្ចាន់ទុកនឹងគ្នាថា នឹងរួមចិត្តដរិតមួយគឺសុខទុក្ខជាមួយគ្នា បើនរណាស្លាប់ក៏សូមស្លាប់ជាមួយគ្នា នរណាៗក៏បានដឹងឮជាំងអស់ កាលលើកគងទ័ពទៅវាយយកស្រុកបៃហ្វីនោះ ខ្ញុំបាទក៏បានចុះសញ្ញាជូនលោកៗក៏ព្រមទទួលបដិញ្ញាណ បានជាខ្ញុំចូលមកនៅធ្វើការនឹងលោករហូតមកដល់ថ្ងៃនេះ តទ្បាយខ្ញុំបាទដឹងដំណឹងខ្មៅពីច្បាស់ហើយ ខ្ញុំបាទសូមប្រណិប័តន៍លាលោកទៅរកខ្មៅពីតាមភាក្យប្តេជ្ញា ដែលលោកមានគុណឧបការបានជួយឧបត្ថម្ភចំទុកបំរុងខ្លួនខ្ញុំបាទដរាបមកបានសេចក្តីសុខនោះ ខ្ញុំបាទក៏ត្រូវនឹករលឹកដល់ព្រះគេជព្រះគុណមិនភ្លេចទេ តែនឹងត្រឡប់លុបគុណខ្មៅពីដែលមានមកពីមុននោះមិនបាន បើអំណើះទៅមុខខ្ញុំបាទនៅមានជីវិត គង់នឹងត្រឡប់មកតបស្នងសងគុណលោកទៀត" លុះសរសេរចប់ហើយក៏បិទត្រាមប្រើបំរើយកទៅប្រគល់ឲ្យនាយទ្វារ ដែលរក្សាផ្ទះចួបខ្លួន ។ គួនអ៊ូក៏យកត្រាសម្រាប់ឆានឹងត្រឲ្យរបស់ដែលចួបខ្លួនឲ្យនោះដាក់ក្នុងហឹប ចាក់សោរព្រមទាំងប្រគល់ឲ្យស្រីបំរើរក្សាទុកហើយ ទើបអញ្ជើញចេញថ្វាយបង្គំ២ឡើងលើរថ ខ្លួនគួនអ៊ូឯងក៏កាន់ដាវដំរះសេះសឹកទៅនាំតាមហាន ១១,១២ នាក់ចេញតាមទ្វារស្រុកខាងទិសឯជើង នាយទ្វារឃាត់មិនឲ្យចេញ គួនអ៊ូស្រែកគំហកដោយសំឡេងខ្លាំង នាយទ្វារក៏ភ័យតាំងស្មារតី

សុះវត់ទៅ គួនអ៊ូឲ្យតាហាន ១១, ១២ នាក់រក្សាបង់ថ្លៃចេញទៅខាងមុខ, ខ្លួនគួនអ៊ូក៏នៅការពារពីខាងក្រោយ តាហានទាំងនោះក៏បររថបណ្តាយតាមផ្លូវហួងចេញទៅ ។

ឯចួតួប្រឹក្សាគ្នានឹងនាយតាហានទាំងពួង ដើម្បីនឹងរកទំនងបង់គួនអ៊ូទុកតែសេចក្តីនោះក៏នៅមិនទាន់ស្រុះស្រួលគ្នា ខ្លួលនាយឌូរយកសំបុត្រគួនអ៊ូទៅជូនចួតួ ។ ខ្លួលយកមកមើល លុះដឹងសេចក្តីហើយក៏ក្រាក់ស្មារតីធ្វើឆ្ងាន់ឆាយថា បើដូច្នោះគួនអ៊ូមិនទៅហើយឬ? ។ ខ្លួលស្រែបំរើ ១០ នាក់នាំយកហឹបដែលដាក់គ្រាប់ទឹងព្យរបស់ ដែលគួនអ៊ូប្រគល់ទុកឲ្យនោះនាំទៅជូនចួតួ ហើយជំរាបថា តឡាវគួនអ៊ូនាំបង់ថ្លៃទាំង ២ ចេញបាត់ទៅហើយ ។ ចួតួមិនទាន់ឆ្លើយតបថាម្តេច ស្រាប់តែនាយឌូរស្រុកខាងទិសឯដើង នាំយកដំណឹងមកជំរាបចួតួថា គួនអ៊ូនាំបង់ថ្លៃចេញទៅហើយ ខ្ញុំបាទឃាត់ក៏មិនស្តាប់ បើនឹងចាប់អូសទាំងក៏ខ្លាចគួនអ៊ូសម្លាប់ ។ ចួតួនឹងទីប្រឹក្សាមិនទាន់ថាដូចម្តេច សួយ៉ុងនាយតាហានបានស្តាប់ដូច្នោះទើបឆ្លើយជំរាបចួតួថា ដែលគួនអ៊ូវត់ទៅនោះ ខ្ញុំបាទសុំតាហាន ៣ ពាន់ យកអាសាទៅតាមចាប់យកខ្លួនមកជូនលោកវិញ ។

(មានត)

ជាតិព្រេងតំណៀ

លោកសមិត្ត ម៊ូត្យ៉ែនជិម: តែង

លោក រ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

– ខ្ញុំលព្រះបន្ទំជាមហាក្សត្រិយ៍សោយរាជ្យនៅប្រទេសនេះ; កងទ័ព សត្រូវដែលមានអានុភាពជាងកងទ័ពខ្ញុំលព្រះបន្ទំបានវាយកំទេចទៅកងទ័ព សមរភូមិ ដណ្តើមយកព្រះពរជអាណាចក្រ ទឹងព្រះស្នំខ្ញុំលព្រះបន្ទំ ។ល។ នេះបើយជាហេតុឲ្យខ្ញុំលព្រះបន្ទំតើតទុក្ខពន្ធប្រមាណ; ខ្ញុំលព្រះបន្ទំភ័យ កិតខ្លាចបញ្ហាមិត្តជាខ្លាំងមិនហ៊ានស្ថិតនៅក្នុងទីក្រុងណាសោះឡើយ ទើប ខ្ញុំលព្រះបន្ទំស៊ូដើរវង្វេងទៅក្នុងព្រៃតែម្នាក់ឯង ។ បើអ្នកណាបានស្តាប់ រឿងរ៉ាវប្រកបដោយសេចក្តីទុក្ខដែលខ្ញុំលព្រះបន្ទំនិទានេះហើយ អ្នក នោះឯងនឹងមានទុក្ខ ប្រៀបដូចជាថ្នាក់ចំមកលើខ្លួន” ។

ក្រោយដែលទ្រង់ព្រះសណ្តាប់ទូវាក្យនេះ, ព្រះបាទវិក្រមាទិត្យ ទ្រង់បានព្រះពរជទានទូវត្តិសិដ្ឋទាំង ៣ នោះទៅព្រះមហាក្សត្រិយ៍ដែលបរាជ័យនោះ, រួចទ្រង់បន្តព្រះពរជដំណើរទៅកាន់រាជធានីព្រះអង្គវិញ ។

ចំណែកព្រះមហាក្សត្រិយ៍បរាជ័យនោះ លុះដល់ទ្រង់បានវត្តុដ៏ ប្រសើរគាំងបីហើយ ទ្រង់ក៏បានវាយដណ្តើមយកព្រះពរជអាណាចក្រ, ព្រះស្នំ . . . ល . . មកវិញ” ។

រូបទេពធីម្មិតទី ១៩ ទូលបន្ទូលថា: "បពិត្រព្រះបាទកោដៈ, ខ្ញុំ ព្រះបង្គំបានតាំងនាអំពីមហាសប្បុរសនៃព្រះបាទវិកមាទិត្យ, បើខ្ញុំ មានព្រះពាដចរិយាបែបនេះ, ខ្ញុំអាចគង់លើបល្ល័ង្កទិព្យនេះបាន" ។

ក្នុងពេលនោះ, ព្រះបាទកោដៈខ្ញុំព្រះសណ្តាប់ នូវពាក្យដែល រូបទេពធីម្មិតបានថ្លែង ខ្ញុំក៏ចៀសចេញពីបល្ល័ង្កទិព្យនោះទៅ ។

ធីឋានទៀរូបទេពធីម្មិតទី ២០

មានមួយថ្ងៃ, រូបទេពធីម្មិតទី ២០ បានទតទៅឃើញមហាពដកោដៈ ខ្ញុំក៏តុងចិត្តស្តេចយាងមកដិតព្រះបល្ល័ង្កទិព្យ, ខ្ញុំក៏មានព្រះបន្ទូលថា: "បើខ្ញុំមានព្រះពាដចរិយាដូចគ្នានឹងព្រះមហាក្សត្រិយ៍វិកមាទិត្យ ខ្ញុំ ទើបអាចគង់លើបល្ល័ង្កទិព្យនេះបាន ដើម្បីខ្ញុំទូលព្រះរាជាតិសេក, សូមខ្ញុំជ្រាបអំពីព្រះពាដចរិយានៃព្រះមហាក្សត្រិយ៍វិកមាទិត្យ ដូចត ទៅនេះ :

' មានកាលមួយថ្ងៃព្រះពាដចរិយ៍ក្សត្រៈរបស់ព្រះបាទវិកមាទិត្យ មួយ នាក់ ឈ្មោះពុទ្ធិសាគរ (Buddhi Sagara) បានពិនិត្យទៅឃើញថាបុត្រ លោកនាមពុទ្ធិសេខរៈ (Buddhi Cekhara) ជាបុគ្គលល្ងង់ខ្លៅ, មាន ប្រាជ្ញាខ្វះខាតជាយ៉ាងវិសេស កំបានឱយាយនឹងកូនទោះថា: នែកូន! កូនឯងជាពូជព្រះពាដចរិយ៍ក្សត្រហើយ តែកូនឯងជាមនុស្សល្ងង់ ព្រោះ កូនឯងស្ថិតទៅជិតបណ្ឌិតតែមិនបានប្រតិបត្តិតាមពាក្យគួរគ្នាន ដែលមាន ចារទុកក្នុងសាស្ត្រៈ ។ មនុស្សណាដែលគ្មានប្រាជ្ញាមិនបានសូត្រវៀន

ខ្ញុំសាស្ត្រ: មិនបានព្យាយាមអប់រំខ្លួនទៅតាន់សុក្រិតភាព, មនុស្ស
នោះមានមុខមាត់ជាមនុស្សកំពិតមែនហើយ, តែត្រូវឲ្យដឹងថាជា
មនុស្សមានសភាពយោរយៅពាលសាមាន្យ ។ នែកូនសំឡាញ់ឧត្តម!
មែនពិត, មនុស្សយើងដែលៈពញចិត្តក្នុងការសិក្សារៀនសូត្រសាស្ត្រ:
តែងខុសគ្នាពីមនុស្សពាលសាមាន្យ តាមលំនាំដែលរស់នៅក្នុងលោក ។
ចើតាមសភាពផ្ទុយវិញ, មនុស្សណាដែលកង្វល់រវល់តែចំណីអាហារ,
ដេក, ខ្លាច, ស្រឡាញ់ ។ល។ មនុស្សនោះប្រៀបដូចជាសត្វតិរច្ឆាន ។
ចានសេចក្តីថាមនុស្សនោះខិលសត្វតិរច្ឆាន - មានសភាពមិនខុសគ្នាទេ ។
ប្រាជ្ញាដែលចានមកពីការសិក្សារៀនសូត្រសាស្ត្រ: កូនឯងគ្មានក្នុងខ្លួន
សោះឡើយ; ម្ល៉ោះហើយ ដីវភាពឯងជាការឥតប្រយោជន៍" ។

"ពុទ្ធិសេខរៈ, ក្រោយដែលចានស្តាប់ពាក្យបន្ទោសរបស់បិតា
ចំពោះការសិក្សាបស់ខ្លួន ក៏ចានធ្វើដំណើរទៅតាន់បរទេសដើម្បីខិត
សិក្សារៀនសូត្រសាស្ត្រ: លោកចានចូលទៅប្រឹស័យខិលលោកគ្រូ
មួយរូប, ចានរៀនសូត្រសាស្ត្រ: ពាក់អស់ចប់សព្វគ្រប់ហើយ ក៏វិល
ត្រឡប់មកប្រទេសលោកវិញ ។

តាមរយៈផ្លូវដែលលោកធ្វើដំណើរមក លោកចានត្រឡេកទៅ
ឃើញពីត្រែងមួយមានបូជនីយដ្ឋានតាងទេវតា, លោកក៏ចានអញ្ជើញ
ទៅតាន់បូជនីយដ្ឋាននោះ ហើយក៏សម្រាកនៅពីនោះ ។ ពេល
សាយណ្ហាសម័យ, លោកចានឃើញនាងតញ្ញា ៨ នាក់ ចេញពីចិនមួយ
ដែលស្ថិតនៅជិតបូជយនីយដ្ឋាននោះ; នាងចានខិតចូលទៅជិតបូជនី-

យដ្ឋាន ហើយក្នុងយប់នោះនាងសំដែងគារវភាពចំពោះនាងទេវធីតា, ត្រមាំងសូត្រធម៌សំដែងបសំសនកថាផ្សេង ។ ថ្វាយដង្គម ។ ដល់ពេលបច្ចុសសម័យ នាងក៏វិលចូលទៅក្នុងចឹងវិញ ។

ក្រោយដែលបានឃើញមហាអច្ឆរិយភាពនោះ ពុទ្ធិសេខរៈក៏វិលត្រឡប់មកកាន់មាតុភូមិវិញ, ហើយចូលទៅក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យ ។ កាលខ្ញុំព្រះសណ្តាប់នូវរឿងរ៉ាវនោះហើយ ខ្ញុំក៏យល់ថាជាអច្ឆរិយភាពពិតមែន, ខ្ញុំក៏ស្តេចយាងទៅកាន់បូជនីយដ្ឋាននោះ ។ ដល់ពេលសាយណ្ហសម័យ ខ្ញុំក៏បានឧតទៅឃើញនាងកញ្ញា ដូចជាពុទ្ធិសេខរៈបុត្រព្រះពជទីប្រឹក្សាបានក្រាបបង្គំទូលដូច្នោះមែន ។ លុះដល់ពេលអរុណរះ, នាងកញ្ញាក៏លោតទៅក្នុងទឹកចឹងនោះបាត់ទៅ ។ មហាពជខ្ញុំឧតទៅឃើញហេតុដូចនោះ, ខ្ញុំក៏លោតទៅក្នុងទឹកចឹងតាមស្តីនាងនោះ ។

"នាងកញ្ញាបានឃើញព្រះពជសកម្មភាព នៃមហាពជវិក្រមាទិត្យ ក៏ពោលពាក្យថា: "ខ្ញុំ! ព្រះបាទវិក្រមាទិត្យ! ព្រះអង្គខ្ញុំជាបមកព, ខ្ញុំមានព្រះពជប្អូនប្រុសមានស្បែកខ្មៅ ចំពោះអច្ឆរិយភាពដែល, ខ្ញុំឧតទៅឃើញ ខ្ញុំក៏បានតាមយើងមកកាន់ទីនេះ" ។ នាងកញ្ញា, ក្រោយដែលបានពោលពាក្យដូច្នេះហើយ ក៏ដង្ហែរមហាពជវិក្រមាទិត្យ ទៅកាន់ឧតរបស់ខ្លួនដែលរចនាដោយកែវត្បូងក្តីផ្ទេកច្រកត់, ស្ថិតនៅលើកពបាតាលហើយ ក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យ ថា: "បពិត្រព្រះសម្មតិទេព! សូមខ្ញុំគង់នៅឧតរនេះ ដូចជាឧតរ

របស់ព្រះអង្គចុះ ។ ព្រះបាទវិក្រមាទិត្យទ្រង់មានព្រះពាក្យតបទៅនាងកញ្ញាថា: "ខ្ញុំមានទុក្ខខ្ញុំហើយ ឲ្យខ្ញុំត្រូវការទុក្ខនេះដូចម្តេចបាន? តែខ្ញុំសូមសួរនាងថា: "តើទុក្ខនេះយ៉ាងណា?" ។ នាងកញ្ញាពាំងអស់ក៏ក្រាបបង្គំទូលថា: យើងខ្ញុំជានាងកញ្ញា ៨ នាក់ជាស្រីប្រកបដោយបញ្ញាពិភពល្បាណ៏" ទុក្ខនេះជាគេហដ្ឋានសម្រាប់លេងវល្បែងរបស់យើងខ្ញុំ យើងខ្ញុំមានចិត្តសោមនស្សពន់ពេកដោយបានយើញទ្រង់ក្នុងពេលនេះ, យើងខ្ញុំសូមថ្វាយទូវែត ៨, (១) សូមព្រះអង្គទ្រង់ទទួលយកចុះ ឯគុណសម្បត្តិនៃវែតពាំង ៨ នោះដូចតទៅនេះ :

វែតទី ១ អាចឲ្យមានព្រះជាជ្ញាជាសុក្រិត, វែតទី ២ អាចមានព្រះពាជំណាងចង់សោយព្រះក្រយាហារអ្វីតាមព្រះពាជហ្ឫទ័យ(២), វែតទី ៣ អាចបញ្ចេញកងទ័ពមាន ៤ កង(៣) ថ្វាយ; វែតទី ៤ អាចឲ្យមហាពាជសម្រេចទៅតាមជោគវាសនាជាទិព្យ(៤), វែតទី ៥ អាចថ្វាយទ្រង់នូវព្រះសុពណ៌ិចុទមានរ៉ូវ៉ាយ៉ាងវែលវែង; វែតទី ៦ អាចឲ្យមហាពាជធ្វើរបស់ដែលកម្រើកឲ្យស្ងៀតនៅទំនឹងបាន; វែតទី ៧ អាចឲ្យទ្រង់បានព្រះជ្ញាដ៏មោះមុត; វែតទី ៨ អាចឲ្យទ្រង់បានសេចក្តីសុខជាអនេក ។ នាងកញ្ញាពាំងអស់បានថ្វាយវែតពាំង ៨ ចំពោះមហាពាជ ក្រោយដែល

---

១ ត្រូវប្រៀបធៀបនឹងនិទានៃរូបទេពនិម្មិតទី ៣, ទី ១៣ និង ទី ១៩ ។

២ វែតទី ១ នៃនិទានរូបទេពនិម្មិតទី ៣ ។

៣ វែតទី ៣ នៃនិទានរូបទេពនិម្មិតទី ៤ ។

៤ គឺទ្រង់អធិដ្ឋានព្រះបរមរូប ជារូបទេវតា បានដោយទេវរីទ្ធិ ។

ចានក្រាបបង្គំទូលនូវគុណសម្បត្តិនៃកែវចំាងនោះ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ក៏ចានទទួលនូវកែវចំាង ៨ ពីនាងកញ្ញាចំាងនោះ ហើយក៏ទ្រង់ស្តេចយាងវិលត្រឡប់ទៅកាន់ព្រះពន្ធនាគារវិញ ។

ព្រះកាលដែលទ្រង់ស្តេចយាងតាមផ្លូវមក ទ្រង់ចានទតទៅឃើញព្រាហ្មណ៍ពុតត្អាក់ ។ ព្រាហ្មណ៍ក្រឡេកទៅឃើញព្រះបាទវិក្រមាទិត្យ ស្គាល់ជាព្រះអង្គហើយក៏មកថ្វាយបង្គំព្រះអង្គហើយស្រែកសូមចានព្រះអង្គថា: "បពិត្រព្រះសម្មតិទេព! ទូលព្រះបង្គំជាខ្ញុំ ជាព្រាហ្មណ៍មានសេចក្តីទុក្ខលំបាកត្រង់ចាំងក្នុងពេលនេះ, ទ្រង់ជាមហាក្សត្រប្រកបដោយមហាសប្បុរិសធម៌ សូមទ្រង់ព្រះកាចានអ្វីមួយ ដែលជាហេតុធ្វើឲ្យទូលព្រះបង្គំលែងមានទុក្ខលំបាក ដោយសេចក្តីត្រូវការអ្វីសោះឡើយ, សូមឲ្យទូលព្រះបង្គំស្ថិតនៅជាសុខ" ។ មហាក្សត្រវិក្រមាទិត្យទ្រង់ព្រះសណ្តាប់ទូវាក្យព្រាហ្មណ៍, ទ្រង់ក៏ចានព្រះកាចានកែវចំាង ៨ ទៅព្រាហ្មណ៍នោះហើយ ទ្រង់ក៏ចន្តព្រះកាដំណើរទៅដល់ព្រះកាន្ធនាគារវិញ ។

រួចទេពនិម្មិតទី ២០ ទូលបន្ទូលថា: "បពិត្រមហាក្សត្រិយ៍កោដ: បើទ្រង់មានព្រះមហាសប្បុរិសធម៌ ដូចព្រះបាទវិក្រមាទិត្យ, ទ្រង់ស្តេចយាងមកគង់លើបល្ល័ង្កទិព្យនេះចុះ ។ បើមិនដូច្នោះទេ, ទ្រង់កុំទិតចូលមកជិតបល្ល័ង្កទិព្យនេះឡើយ" ។

ក្នុងពេលនោះព្រះបាទកោដ: ខ្មាសអៀនក៏ទ្រង់ចុះពីទីតែម្តង់នោះ ។

* * *

(មានត)

ពុទ្ធសាសនបណ្ឌិត្យ

និង

ពិព័រណ៍អន្តរជាតិ នៅក្រុងភ្នំពេញ

លោក ជាប-ពិន រៀបរៀង

កាលពីថ្ងៃ ១៥ វិច្ឆិកា ដល់ថ្ងៃទី ១១ ធ្នូ ព.ស. ២៤៨៨ គ.ស. ១៩៤៤ ប្រទេសកម្ពុជាបានចាត់ការតាំងសម្ភារៈ ហៅថា "ពិព័រណ៍អន្តរជាតិ" នៅជុំវិញបរិវេណវត្តកុំ ក្រុងភ្នំពេញ ។ ការតាំងនោះមានជាតិនានាចំនួន ១២ ប្រទេសមករួមតាំងជាស្តង់មួយៗ ដោយឡែកតាមសញ្ជាតិ គឺប្រទេសអាមេរិក, ចាកំង, ឥណ្ឌា, ជប៉ុន, ថៃ, លាវ, វៀតណាមខាងត្បូង, អង់គ្លេស, ម៉ាឡេស៊ី សឹង្ហបុរី, ទឹង (ហុលួងដ៍មកមិនទាន់) ។

ក្រសួងពុទ្ធសាសនបណ្ឌិត្យ ទឹងក្រុមជំទុំទៀមទម្លាប់ខ្មែរ ក៏ត្រូវបូលតាំងជាមួយទឹងគេដែរ គឺតាំងសម្ភារៈដែលទាក់ទងនឹងវប្បធម៌ខ្មែរក្នុងស្តង់មួយនៅខាងត្បូងកុំជាមួយក្រសួងសិក្សាធិការជាតិ, សាលាវិចិត្រសិល្បៈខេមរៈ ទឹងសាលាចាកំងវែសនៅចុងបូតាប្រទេស ។

ការតាំងនេះចែកជា ២ ផ្នែក :

– ផ្នែកពុទ្ធសាសនបណ្ឌិត្យ តាំងបុកណាវត្តផ្សេង ។ ជាវត្តុសម្រាប់វត្តខាងព្រះពុទ្ធសាសនាហើយជាវចនានុក្រមរបស់ខ្មែរ មានដើមថា: គម្ពីរស្ទឹករឹតបិទមាសក្រហមផ្ទៅ, សៀវភៅព្រះវិន័យដកចោះពុម្ព, វចនានុក្រមខ្មែរ, ក្រាំងទឹងសៀវភៅក្របចម្លាក់បិទមាស, ចាត្រគ្រប់ជាំៗ,

ផ្ទៃតមន្ត្រីសង្ឃ, គ្រាសម្រាប់វត្ត, ច្រត់យោគី, ព្រះពុទ្ធរូបអង្គតូច ។ ។
វត្តចាំងនេះ តាំងលើតុំធំវែងមួយគ្រាលកម្រាលសំពត់ឡែនព័ណ៌ស៊ីខ្លួន
ខ្លីដ៏មានលំអគួរឲ្យចង់ទស្សនា ។ នៅខាងមុខតុមានគ្រែទេសនារូបកដ.
សីហ៍បិទមាសលំអដោយឥតរួតពាសអង្កាំ, មានទូបិទមាសសម្រាប់
ដាក់គម្ពីរ ឧដ្ឋានរទេះបំបោល ។ ល ។

— ផ្នែកក្រុមដំខុំទំខៀមខម្ងាប់តាំងពីបុកណាវត្តផ្សេង ។ ជារចនារបស់
ខ្មែរ ហើយជាវត្តចាក់ឧដ្ឋានទំខៀមខម្ងាប់ខ្មែរ មានដើមថា: រូបភាព
ពពិលជាវិការ នៃសម្តែងសម្រាប់ច្រែកក្នុងពិធីមង្គលផ្សេង ។, ព្រះពុទ្ធ-
បដិមាដែលគេសាងក្នុងវេលាភ្លុំបិណ្ឌ, រូបភាពព្រះសិវៈ-ព្រះវិស្ណុ ជា
សរណៈវត្តខាងសាសនាព្រាហ្មណ៍, ក្រាំងបម្ងាប់បិទមាសនិយាយពីក្បួន
ព្រហ្មជាតិមានគំនូរឲ្យពីណាជារូបសត្វផ្សេង ។ ដែលមាននាមលើធ្នាំនឹង
ខែចាំង ១២, ក្រាំងវែតក្បាមិនិយាយពីពិធីសង់គ្រឹះស្ថាន; ខែ្យគម្ពីរតស្សាញ
ជាអក្សរខ្មែរដាក់នាមទឹកខែ្យងនឹងសេចក្តីជ្រាបថ្វាអ្នកសាង, ក្រាំងបិទមាស
និយាយពីក្បួនតស្សាញខែ្យគម្ពីរ, អាវតេជៈសម្រាប់អ្នកច្បាំងតាក់ការពារ
ខ្លួន ។ ល ។ វត្តចាំងនេះ តាំងនៅលើតុំធំវែងមួយគ្រាលកម្រាលដូចគ្នា ។

នៅខាងជញ្ជាំងឯក្បួងខាងគ្រោយតុចាំង ២ មានបដាផ្ទាំងធំ។ គួរដាក់
ព័ណ៌ជារូបភាពល្បែងផ្សេង។ បង្ហាញឲ្យទស្សនជនស្គាល់ទំខៀមល្បែង
បុកណារបស់ខ្មែរមែន។ គឺល្បែងត្រួដ កំស្តេងខ្មោង កន្តែវែ សួរត្រីត្តដាំដូង ឃោលខោង ទំពែកជល់គ្នា គុនដំបង ស្ទិលតាំស្ទាល់ ព្រះកជពិធី
ច្រត់ព្រះខត្តិ ពិធីពួនកូនស្រូវ កខែ្យងយ័ន្ត ។ ល ។

នៅបន្ទោះខាងក្រោយតុតាំង ๒ មានខួរមួយធំជាក់ស្តែងកៅសំខាន់ៗ ដែលបានបោះពុម្ពផ្សាយចេញពីក្រសួងពុទ្ធសាសនបណ្ឌិត្យ សម្រាប់ផ្សាយទាំងផ្លូវលោកផ្លូវធម៌ ។

នៅបន្ទោះមុខតុតាំង ๒ មានដំកល់ព្រះបរមនាយាលក្ខណ៍ នៃព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម-សុភមិត្ត, សម្តេចព្រះមហាក្សត្រិយានី កុសុមនារីរ័តន៍ រចនាដោយកញ្ចក់ ទឹងសម្តេចព្រះឧបយុវរាជនរោត្តម-សីហនុ រចនាដោយម្ជាងសិលាខ្មែរព្រះសណ្ឋិតជាប្រមុខ នៅចំកណ្តាលត្រង់បន្ទោះខាងមុខតុតាំង ដ៏មានលំអដោយផើងដើមពោលស្រស់ញញឹមអមព្រះអង្គ ។

នៅជញ្ជាំងខាងកើតតុតាំងនោះ មានតាំងព្រះបដផ្ទាំងធំ ។ គឺព្រះពុទ្ធរូបគ្រាសំដែងព្រះធម្មចក្រប្រោសបញ្ចវគ្គីយ គ្រាសំដែងព្រះអភិធម្មប្រោសពុទ្ធមាតា ទឹងមានរចនាដោយសន្ធឹកព្រះបដតូច ។ រឿងទាំងនេះជាតក៏ព្រះពុទ្ធដ៏វិញ្ញបជាធំៗ ជាភាពអក្សរ ដែលសំគាល់សេចក្តីថា "ពុទ្ធសាសនបណ្ឌិត្យ ឬ ពុទ្ធសាសនា" នាំឲ្យទស្សនជនពិតពិលរមិលមើលដក់ភ្នែកយូរៗមិនចង់លែង ។

ស្តង់នេះមានខេមរជន ទឹងជនបរទេសមកទស្សនាជាច្រើនយ៉ាងកុះករ, រៀបណ្តាទស្សនជនទាំងនោះ ជនបរទេសចូលចិត្តទស្សនាបុរាណវត្ថុផ្សេង ។ ដោយសង្កេតហ្មត់ចត់ជាងខេមរជន; ដែលគេពេញចិត្តជាងគេនោះ គឺអារគេជៈ ទឹងពិល ។

មានភ្នាក់ងារសារពត៌មានបរទេសជាច្រើន មកថតមកសាកសួរយកការណ៍ទៅចុះសារពត៌មានផ្សេង។ សរសើរស្តីនេះពុំជាច់មាត់ ។ ដោយហេតុនេះហើយ ទើបគណៈកម្មាធិការពិព័រណ៌អន្តរជាតិ បានចេញត្រឿងឥស្សរិយយស (មេដាយ) ច្បាក់ ๑ ឲ្យទុកជាកិត្តិយសនឹងជាអនុស្សាវរីយ៍ដើម្បីបង្ហាញច្បៃជាជនខ្មែរជាតិឲ្យស្គាល់ថា ក្រសួងពុទ្ធសាសនបណ្ឌិត្យ បានរួបរួមតាំងស្តង់ខាងវប្បធម៌ខ្មែរ ដ៏ទូលាំទូលាយជាមួយនឹងពិព័រណ៌អន្តរជាតិ ដែលជាការណីយកិច្ចមានសារប្រយោជន៍ដល់ប្រទេសកម្ពុជាយើង ។

សម្ភាសន៍

នៅថ្ងៃទី ๑๗ ខែធ្នូ ๑๙๙๙ មានភ្នាក់ងារទស្សនាវដ្តីហ្វ្រង់-អាស៊ី ពីរនាក់ដែលមកសង្កេតយកការណ៍អំពីពិព័រណ៌អន្តរជាតិ នៅភ្នំពេញ បានមកធ្វើសម្ភាសន៍អំពីស្តង់ពុទ្ធសាសនបណ្ឌិត្យ ជាការសាបាំងជាមួយលោក យឿន-ចឹម អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ អំពីស្តង់នេះ ។ ការសម្ភាសន៍នេះ ដោយបញ្ចូលសំឡេងទៅក្នុងថាសម៉ាស៊ីនមានសេចក្តីដូចតទៅនេះ ៖

ស – សូមលោកមានប្រសាសន៍អធិប្បាយអំពីក្រសួងពុទ្ធសាសនបណ្ឌិត្យ អំពីកិច្ចការនឹងអំពីសារសំខាន់នៃក្រសួងនេះ ក្នុងការតាំងពិព័រណ៌នេះ ឲ្យខ្ញុំបាទជាំងពីរនាក់ស្តាប់បន្តិច ?

ច.– ក្រសួងពុទ្ធសាសនបណ្ឌិត្យជាទីប្រជុំចិត្តានៃប្រជាជនខ្មែរ ។ គោលបំណងធំ គឺត្រួតត្រា ទឹងសម្រុះសម្រួលការសិក្សាខាងលទ្ធិព្រះពុទ្ធសាសនាផ្នែកហីនយានឬហៅថា "ថេរវាទ" ជាមួយនឹង

ប្រជាជនខ្មែរក្នុងប្រទេសហើយនិងពួកខ្មែរមួយក្រុម ដែលនៅរៀតណាម ចែកខាងត្បូង ។

ឯការសំខាន់របស់ក្រសួងនេះ គឺ:

១.- ការបោះពុម្ពផ្សាយសៀវភៅជាភាសាជាតិនិងភាសាខ្មែរ ដូចជាសៀវភៅព្រះត្រៃបិដក (ដែលលោក.ឃីញនៅខាងមុខនេះស្រាប់) វចនានុក្រមខ្មែរ និងទស្សនាវដ្តីប្រចាំខែជាច្រើនទៀតជាភាសាជាតិ-ខ្មែរ និងជាភាសាបរទេស ។ សៀវភៅទាំងនេះអធិប្បាយអំពីសិល្បៈ អំពីការស្រាវជ្រាវរកបុរាណវត្ថុ អំពីសាសនានិងអំពីពង្សាវតារខ្មែរ;

២.- ការសិក្សាភាសាដែលជាឫសគល់នៃភាសាឯទៀត គឺជាតិនិងសំស្កឹត ។ មានព្រះសង្ឃជាអ្នកជាប្រមួយក្រុម កំពុងសិក្សាភាសាទាំងនេះដោយម៉ឺងម៉ាត់ ដើម្បីឲ្យចេះដឹងនូវលិខិតព្រះពុទ្ធសាសនាផង ដើម្បីឲ្យចេះដឹងភាសាទាំងនេះផង;

៣ - មានទិព្វបណ្ណិតមួយក្រុមជាអ្នកស្រាវជ្រាវរឿងរកនិងសរសេរអត្ថបទផ្សេងៗ ដើម្បីអប់រំនិងបណ្តុះនូវគុណសម្បត្តិខាងចរិយានិងខាងផ្លូវចិត្តរបស់ប្រជាជន;

៤.- ការបង្កើតឲ្យមានបណ្ណាល័យមួយ សម្រាប់ពួកបព្វជិត គ្រហស្ថ-និស្សិត-អ្នកពាក់ព័ន្ធក្នុងប្រទេសនិងបរទេស អានមើលសិក្សារៀនសូត្រ;

៥.- ការស្រាវជ្រាវរកនិងរក្សាទុកនូវឯកសារចាស់ៗ ដែលស្តីអំពីសាសនា និងទៀមទម្លាប់នឹងពង្សាវតារស្រុកខ្មែរ ។

ស.- ហេតុដូចម្តេចបានជាលោកមកតាំងស្តង់លោកនៅក្នុងបន្ទប់សម្រាប់តាំងរបស់ដែលជាប់ទាក់ទងនឹងវប្បធម៌ជាតិដូច្នេះ?

ឆ.- គោលបំណងធំនៃការតាំងនេះមានពីរយ៉ាង ៖

១.- ដើម្បីបង្ហាញដល់ទស្សនជន អំពីសារៈសំខាន់នៃព្រះពុទ្ធសាសនា អំពីការជឿនឆ្ងាការគោរពរបស់ប្រជាជនខ្មែរចំពោះព្រះពុទ្ធសាសនា;

២.- ដើម្បីបង្ហាញដល់ទស្សជនថា នៅពេលដែលអារ្យធម៌ក្នុងលោកកំពុងតែរីកចម្រើន ប្រជាជនខ្មែរចេះរក្សាភ្ជាប់នូវទំនៀមទម្លាប់ពីបុរាណ;

ស.- តើលោកអាចបង្ហាញឲ្យខ្ញុំស្គាល់របស់ក្នុងស្តង់លោកផងបានទេ?

ឆ.- ក្នុងស្តង់ខ្ញុំមានរបស់ ៣ ផ្នែក ៖

ផ្នែកទី១: របស់សម្រាប់វត្ត ដូចជាទូដាក់សាត្រា, គ្រែទេសនាធ្វើជារូបពស់វិហ៍មានកូនស់ចាំងពីលើផង, រនេះបំពោលសម្រាប់ពៅអធិការនិមន្តទៅណាមកណា, ផ្ទឹតសម្រាប់មន្តីសង្ឃ, ជាតសម្រាប់ព្រះសង្ឃនិមន្តបិណ្ឌបាត, តាសម្រាប់វត្ត, ឈើច្រត់, ផ្ទាំងព្រះបដសាត្រាស្ទឹកតែនឹងសៀវភៅឯទៀតដែលមានក្រមង្គើអំពីឈើចម្លាក់;

ផ្នែកទី២: វត្ថុនឹងរូបភាព ដែលសុទ្ធតែជារបស់ជាប់ទាក់ទងនឹងទំនៀមទម្លាប់ ដូចជាក្បួនទំនាយ, ក្បួនមន្តអាគម, រូបតំណាង ។ល។

ស.- សូមលោកអធិប្បាយពន្យល់អំពីរបស់ពីរមុខនេះឲ្យខ្ញុំបាទ

ស្តាប់បន្តិច គឺអាវតេជៈទំនិតពិល ព្រោះរបស់នេះធ្វើឲ្យខ្ញុំចាប់ចិត្តចង់ដឹងណាស់?

ច.- អាវតេជៈ អាវនេះធ្វើអំពីក្រណាត់សំពត់ធម្មតា មានពាក់ខ្លួឃយ ។ នៅលើផ្ទាំងអាវនោះតាំងសង្ឃាងមានគូរយ័ន្ត ទឹងតាថាបាល ផ្សេងៗ សរសេរជាកាប់លើអាវនោះ ។ អាវនេះគាលជាន់ដើម គេពាក់ចេញចម្បាំងដើម្បីកុំឲ្យគេចាញ់ត្រូវ ។

ជ.- តាពិលៈ ជាវត្ថុធ្វើអំពីសម្រឹទ្ធ សម្រាប់ប្រើជាមង្គលក្នុងពិធីវៀបការ ដែលជាទំនៀមព្រាហ្មណ៍ ទឹងកន្លងពេលបំបួសនាគ ។ ពពិលនេះ ខ្លះមានពាក់ស្មៅចងជាសន្ទឹកពោធ៍ ខ្លះមានពាក់មួល ហើយធ្លាក់ជារូបភាពផ្សេងៗ ។ ពពិលនេះគេធ្វើសម្រាប់សុំពរព្រះឥន្ទ ។

ស.- ចុះផ្នែកទី៣ គឺអ្វីខ្លះ?

ច.- ក្រោយបំផុតនេះ គឺគួរជាក់សៀវភៅ សម្រាប់ផ្សាយសៀវភៅសំខាន់ៗ តាំងពាក់ផ្លូវលោក តាំងពាក់ផ្លូវធម៌ ដែលបានចោះពុម្ពចេញពីក្រសួងនេះ ។



កំណត់ន័ន ប្រវត្តិការណ៍

ពិធីបុណ្យគម្រប់ ២៥០០ ព្រះវស្សា នៃព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជា

របស់ពុទ្ធសាសនបណ្ឌិត្យ

កន្លងថ្ងៃទី ២៥ មករា ១៩៥៦ នៅមហាបន្ទប់នៃពុទ្ធសាសនបណ្ឌិត្យ ដែលមានទូរសៀវភៅអមជុំវិញ ព្រមទាំងមានអគ្គិសញ្ញានិងធីវិជនីសំយុទ្ធពីលើជាតំកំដៅមិនឲ្យចូលមកបាន មានធ្វើមហាសន្និបាតមួយ ដើម្បីកំណត់ទីសម្រាប់ធ្វើពិធីបុណ្យគម្រប់ ២៥០០ ព្រះវស្សា នាអគ្គវត្ត នៅថ្ងៃ ១៥ កើតខែពិសាខ ព.ស. ២៥០០, គ.ស. ១៩៥៧ តាមរជ្ជកិច្ចាលសង្គមភស្តុនិយម ដែលមានសម្តេចព្រះឧបយុវរាជ នរោត្តម-សីហនុ ជាព្រះនាយក ទ្រង់តាំងគណៈកម្មការមួយក្រុមមានរដ្ឋមន្ត្រីក្រសួងធម្មការជាប្រធាន ។

កន្លងវេលានោះគេសង្កេតឃើញ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, ព្រះតេជព្រះគុណព្រះធម្មវិតលោកាចារ្យ កេត ចិតសីលោ តំណាងសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ លោក ព័យ-លត តំណាងពុទ្ធិកសមាគម, លោក អ៊ុក-សាអឿម តំណាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, លោក ព័យ-ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ, លោក ឡាំ-ឋាញ់សី តំណាងរដ្ឋមន្ត្រីក្រសួង

ហិរញ្ញវត្ថុ, លោក ហាំ - សុង តំណាងរដ្ឋមន្ត្រីក្រសួងការបរទេស, លោក លឿង - ណាល់ តំណាងឯកឧត្តមរាជប្រតិភូប្រចាំវៃតែ្រសៀមរាប, លោក ហែម - ចំរើន ចាងហ្វាងជាតិមន្ទីរទេសចរ, លោក ម៉ី - នាង អាចារ្យវត្ត ១ណ្ណាលោម តំណាងខាងគណៈមហានិកាយ ទឹង លោក ខន់ - កាន់ តំណាងខាងគណៈធម្មយុត្តិ ជានិមន្តជានអញ្ជើញទៅជួបជុំផង ។

លុះជួបជុំគ្នាហើយ លោក ឱ្យ - ភ័ញ ប្រធានគណៈកម្មការ ជានថ្លែងអំណរគុណចំពោះសម្តេច ទឹងអស់លោកទាំងអស់ជាសមាជិក ដែលជានិមន្ត ជានអញ្ជើញតាមសេចក្តីនិមន្តនឹងអញ្ជើញរបស់ក្រសួងធម្មការ ។ បន្ទាប់មក លោកប្រធានជានចាប់អធិប្បាយក៏យក៏ប់អំពីដើមហេតុនៃការរៀបចំធ្វើពិធីបុណ្យនេះ ។ រួចហើយលោកប្រធានជានជាក់ជូនគណៈកម្មការពិនិត្យទឹងសម្រេចនូវសេចក្តីគ្រោងដូចតទៅនេះ ៖

១ .- កន្លែងដែលត្រូវធ្វើពិធីបុណ្យ :

លោក ឱ្យ - ភ័ញ ជានដំរាបទីប្រជុំថា តាមព្រះទ័យសម្តេចព្រះឧបយុវរាជ ទ្រង់យល់ថាគួរធ្វើនៅអង្គរវត្ត ដែលជាអតីតទីក្រុងនៃប្រទេសកម្ពុជា ។ ចំពោះទីកន្លែងនេះ សមាជិកភាគច្រើន មានលោក លឿង - ណាល់ជាដើម ជានថ្លែងនូវការពិបាកគ្រប់យ៉ាង ក្នុងការរៀបចំទទួលភ្ញៀវបរទេសដោយខ្វះទីលំនៅ ទឹកភ្លើងទឹងកន្លែងបន្ទោបង់ ។ តែដោយគិតឃើញថាជាបុណ្យខាងព្រះពុទ្ធសាសនា ដែលព្រះមហាក្សត្រខ្មែរជានទ្រង់ទ្រទឹងមកជាយូរយារហើយ គួរតែបង្ហាញនូវស្នាព្រះហស្តរបស់ព្រះអង្គឲ្យជនបរទេសជានឃើញផង គឺប្រាសាទអង្គរវត្ត ទើប

គណៈកម្មការបានសម្រេចជាឯកច្ឆន្ទ យល់ព្រមយកអង្គវត្តធ្វើជាកន្លែងធ្វើបុណ្យ ស្របទៅតាមព្រះរាជបំណងសម្តេចព្រះឧបយុវរាជ ។

២ – តាំងគណៈកម្មាធិការនាយកមួយ សំរាប់ចាត់ចែងរៀបចំពិធីបុណ្យ :

ដោយយល់ឃើញថាពិធីបុណ្យនេះ ជាពិធីបុណ្យមួយដែលត្រូវធ្វើឲ្យបានអឹកឹកនោះ គណៈកម្មការបានរៀបចំឲ្យមានគណៈកម្មាធិការនាយកមួយ សម្រាប់ចាត់ចែងរៀបចំការគ្រប់ចំពូក ដោយមានសមាសភាពដូចតទៅ ៖

រាជមន្ត្រីក្រសួងធម្មការជាប្រធាន មានអនុប្រធាន ៥ រូបគឺ: សម្តេចសង្ឃរាំងពីរគណៈ, លោករាជមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាងលោករាជមន្ត្រីក្រសួងសាធារណការ ឬក៏តំណាងលោកចាងហ្វាងជាតិមន្ទីរទេសចរ ហើយមានសមាជិកឯទៀតជាច្រើន គឺមានតំណាងព្រះបរមរាជវាំង ១ រូប, តំណាងមន្ទីរស្តីការរាជមន្ត្រីជាទៀត ១ រូប, តំណាងនៅសៀមរាប ១ រូប, តំណាងរដ្ឋសភាពីរូប, តំណាងក្រុមប្រឹក្សាព្រះពុទ្ធសាសនិកពីរូប ទីឆ្នាំពុទ្ធសាសនិក ៤ រូប គឺខាងគណៈធម្មយុត្តិ ២ រូប ខាងគណៈមហានិកាយ ២ រូប ។

គណៈកម្មាធិការនាយកនឹងរៀបចំកម្មវិធី ព្រមទាំងតម្រូវដល់ក្រុមផ្សេងៗ ទៅក្រុងទីណាត្រូវរៀបចំអនុគណៈកម្មាធិការ ដើម្បីជួយកិច្ចរៀបចំនេះ ។

៣ កាលបរិច្ឆេទដែលធ្វើបុណ្យទីឆ្នាំថ្មី:

លោកប្រធានគណៈកម្មការ ថ្លែងថាពុទ្ធសាសនិកជនប្រទេសឥណ្ឌា លង្កា ទឹង កូមា ល្បឿនជាងពុទ្ធសាសនិកជនខ្មែរ, លាវ ទឹងថៃ ១ ឆ្នាំ គេទើរៀបចំធ្វើពិធីបុណ្យរំលឹកពាក់កណ្តាលព្រះពុទ្ធសាសនា នៅខែឧសភា ១៩៥៦ នេះ ចំណែកយើងខ្មែរ យើងទើរធ្វើនៅឆ្នាំក្រោយ (១៩៥៧) គឺក្រោយឥណ្ឌា ១ ឆ្នាំ ។ ចំពោះកាលបរិច្ឆេទនេះ សម្តេចព្រះសង្ឃនាយកថ្លែងថា ពុំដឹងជាខាងណាខុសខាងណាត្រូវទេ តែកាលបរិច្ឆេទកំណត់ពាក់កណ្តាលព្រះពុទ្ធសាសនា សម្រាប់ប្រទេសខ្មែរយើង គឺនៅថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំរកាទឫស័ក ព.ស. ២៥០០ គត់ត្រូវទឹងថ្ងៃទី ១៣ ឧសភា ១៩៥៧ ប្រទេសកម្ពុជាយើងកំណត់ធ្វើបុណ្យរំលឹកពាក់កណ្តាលព្រះពុទ្ធសាសនា ត្រួមទាំងបុណ្យសម្ពោធគ្នងព្រះចេតិយ ១ ដែលកំពុងកសាងសព្វថ្ងៃ នៅមុខស្ថានីយ៍ពាជអយស្ទ័យយានក្រុងភ្នំពេញជាមនុស្សវិស័យ ។

ពិធីបុណ្យនេះទឹងធ្វើចំនួន ១៥ ថ្ងៃ ដោយកំណត់តាមពិធីបុណ្យកាលព្រះមហាសមុទ្រទឹងបរិនិព្វានដែលមានចំនួន ១៥ ថ្ងៃដែរ ។

๔.- អំពីប្រទេសត្រូវអញ្ជើញមកកាន់ពិធីបុណ្យ:

គណៈកម្មាធិការបានគ្រោងថា ទឹងអញ្ជើញប្រទេសដែលកាន់ព្រះពុទ្ធសាសនាដូចតទៅនេះ គឺ ឥណ្ឌា, លង្កា, កូមា, នេប៉ាល, ថៃ, លាវ, វៀតណាម, ជប៉ុន, មហាពោធិសមាគមទឹងពុទ្ធិកសមាគមនៃប្រទេសខាងលើនេះ ត្រួមទាំងពុទ្ធិកសមាគមប្រទេសជ្វាកំឯ, អង់គ្លេស, អូស្ត្រាលី, ឥណ្ឌូណេស៊ី, អាល់ប៉ឺត៍ធី, អាម៉េរិក ទឹងម៉ាឡេស៊ី ។ល។

ចំពោះការអញ្ជើញនេះ គណៈកម្មការបានសុំឲ្យគ្រូសួងធម្មការពិនិត្យមើលគ្រៅពីប្រទេសខាងលើនេះ គ្រែងមានប្រទេសណាខ្លះទៀតកាន់ព្រះពុទ្ធសាសនាឬមានពុទ្ធិកសមាគម ដើម្បីនឹងបញ្ជូលបន្ថែមក្នុងបញ្ជីទៀត ។

๕.- គ្រោងប្រាក់ចំណាយសំរាប់ធ្វើបុណ្យ:

រឿងប្រាក់ចំណាយ ទីប្រជុំបានព្រមជាពីរផ្នែក:

ក) នឹងសុំពីពាជរដ្ឋាភិបាល ដែលគណៈកម្មាធិការនាយកនឹងគ្រោងចំនួនជាគ្រោយ;

១) នឹងអំពាវនាវដល់ពុទ្ធសាសនិកជនខ្លួនៗ គឺ:

๑- ដោយសុំផ្ទាល់;

๒- ដោយធ្វើសញ្ញាប័ណគោដ្ឋព្រះសារីរិកធាតុជាវ;

๓- ដោយធ្វើបុណ្យផ្សេងៗ ។

ចំពោះរឿងនេះគណៈកម្មការយល់ថា ពលរដ្ឋកម្ពុជាដែលរស់នៅសព្វថ្ងៃសុទ្ធតែជាអ្នកកសាងល្អ ទើបបានជួបនឹងឯកពរព្រះពេញបរិបូណ៌ថ្មីៗដោយសារព្រះមហាក្សត្រយ៍របស់ខ្លួន ហើយសុទ្ធតែមានសំណាងបានទាន់ពាក់កណ្តាលព្រះពុទ្ធសាសនាផង, បើទាន់ដូច្នេះ តើខ្មែរជនណាទំនងបណ្តាយឲ្យពិធីបុណ្យរំលឹកពាក់កណ្តាលព្រះពុទ្ធសាសនានេះមិនរុងរឿងថ្មីកើត ។

๖.- កិច្ចការដែលត្រូវធ្វើ:

ពិតមែនតែជាការលើគណៈកម្មាធិការនាយកដែលត្រូវចាត់ចែងតែទីប្រជុំបានគ្រាន់តែការខ្វះខុតដូចតទៅ ៖

- ត្រូវរៀបចំទីកន្លែងធ្វើបុណ្យឱ្យមានសមរម្យ;
- ត្រូវរៀបចំធ្វើបុស្បកដើម្បីដំកល់ព្រះសារីរិកធាតុ ដែលសុំយកមកពីប្រទេសលង្កា;
- រៀបចំទីលំនៅសំរាប់ទទួលភ្ញៀវបរទេស ភ្ញៀវក្នុងស្រុកដោយមានទឹក-ភ្លើង មន្ទីរបន្ទោបង់;
- រៀបចំសំអាតទីក្រុងសៀមរាប, ផ្លូវថ្នល់ទៅអង្គរ ទៅភ្នំក្រោមនឹងបាយណ៍ទឹកថ្លា ព្រោះនឹងមានភ្ញៀវបរទេសមកទស្សនាពុំខាន;
- ចាត់ចែងកន្លែងសំណាក់ដោយឡែក កន្លែងលក់ដូរដោយឡែក;
- រៀបចំចោះសៀវភៅអធិប្បាយ អំពីពិធីបុណ្យពាក់កណ្តាលព្រះពុទ្ធសាសនា ។

ទីប្រជុំបានបញ្ចប់ដោយសេចក្តីរីករាយ ហើយសូមឱ្យគណៈកម្មាធិការនាយកចាប់ផ្តើមធ្វើឱ្យរួសរាន់ ដើម្បីចាត់ការឱ្យបានស្រួលក្រែងពុំមានពេលវេលា ព្រោះ១ឆ្នាំក្លាយមិនជាយូរប៉ុន្មានឡើយ ។

ពិធីបញ្ចប់កិច្ចសិក្សា

ខាងវិជ្ជាគរុកោសល្យនៃសមណសាស្ត្រាចារ្យ

របស់តុទ្ធសាសនបណ្ឌិត្យ

—▪—

កាលពីថ្ងៃអង្គារ ទី ១៤ កុម្ភៈ ១៩៥៦ វេលាម៉ោង ១៦,៣០ នាទី ក្នុងកំពែងពុទ្ធិកវិទ្យាល័យ ព្រះសុកម្រិត មានធ្វើពិធីប្រគេនសញ្ញាប័ត្រ ដល់សមណសាស្ត្រាចារ្យចាំឆ្នាយចំនួន ១៦១ ដោយបញ្ចាក់អំពីបញ្ចប់កិច្ចសិក្សាខាងវិជ្ជាគរុកោសល្យ ក្រោមអធិបតីភាពនៃលោក ទិញ-ភ័ញ រដ្ឋលេខាធិការក្រសួងធម្មការ ។

ក្នុងវេលានោះគេសង្កេតឃើញ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, ព្រះតេជព្រះគុណព្រះធម្មវិត្រ លោកាចារ្យ កេត - បិតសីលោ ជាតំណាងព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ, លោក ម៉ី - នរសីហ៍, លោកហែរ្ស៍ លេខាធិការទី ២ នៃស្ថានទូតអាមេរិកាំង ទីឯកឥស្សរជនបរទេសឯទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយមិនបានកប់នាមទាំងអស់ក្នុងទីនេះ ។

នៅឧកាសនៃការជួបជុំឥស្សរជនទាំងនោះ ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត - តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុកម្រិត បានថ្លែងសុន្ទរកថាមួយដ៏ខ្លី ដែលយើងស្រង់យកមកសំដែងនៅខាងមុខឥតមានកែប្រែ ។ បន្ទាប់មក លោក ទិញ - ភ័ញ មានប្រសាសន៍ក្នុងនាមនៃរដ្ឋាភិបាល សរសើរចំពោះសមណសាស្ត្រាចារ្យចាំឆ្នាយ ដែល

សព្វព្រះទ័យបង្ហាត់បង្រៀន រួចរំលឹកនូវកិច្ចការដ៏ធ្ងន់ ដែលធ្លាក់មកលើសាស្ត្រាចារ្យទាំងឡាយដោយអនេកបរិយាយ ។ បន្ទាប់មកទៀត សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ បានថ្លែងសង្ខ្ចាមួយមានសេចក្តីដ៏ខ្លី ដោយរំលឹកថា សុំឲ្យសាស្ត្រាចារ្យទាំងនោះ ទំយកចិត្តទុកដាក់បង្ហាត់បង្រៀនតាមមុខងាររបស់ខ្លួន ដើម្បីឲ្យបានជាទីស្រឡាញ់កប់អាននៃអនាគតសិស្សទាំងឡាយ ទំងដើម្បីឲ្យគួរដល់សេចក្តីកប់អាននៃមាតុប្រទេស ។

ពិធីនេះបានចប់នៅវេលាម៉ោង ១៧, ១៥ ។

សុន្ទរកថាព្រះពោធិវង្ស ឬឪពុត-តាត

ចាងថ្វាងតុទ្ធិការវិទ្យាល័យព្រះសុរាម្រិត

សូមក្រាបថ្វាយបង្គំដោយគោរពចំពោះសម្តេច !

សូមដំរាបលោកវរជ្ជលេខាធិការទំងអស់លោកទាំងឡាយ !

ការបង្រៀនវិជ្ជាគរុកោសល្យនេះ, កាលពីក្នុងខែវិច្ឆិកា ១៩៥៥ បានផ្តើមធ្វើមួយលើកហើយ ចំពោះលោកអាចារ្យក្នុងសាលាចាស់រងំចំនួន ១៣៧ រូប ដល់មកកងខែមករា ទំង កុម្ភៈ ១៩៥៦ នេះ បានចាប់ធ្វើ ១ លើកទៀត ជាលើកទី ២ ចំពោះលោកអាចារ្យក្នុងសាលាចាស់រងំចំនួន ១៦១ រួមទាំងពីរលើកជាចំនួនលោកអាចារ្យអ្នកសិក្សា ២៩៨ រូប ។

ការបង្រៀនទាំងពីរលើកនេះ ដែលបានសម្រេច ដោយអាស្រ័យសេចក្តីឧបត្ថម្ភរបស់ក្រុមបេសកកម្មអាមេរិកាំង ក្នុងការជួយផ្តល់ដោយតម្លៃនៃអាហារូបករណ៍ចំពោះព្រះសង្ឃទាំងនោះ ។ មិនតែប៉ុណ្ណោះ

ការបង្រៀននេះបានទទួលព្រះបរមរាជានុញ្ញាតិអំពីសម្តេចព្រះឧបយុវរាជ
កាលទ្រង់ជានាយករដ្ឋមន្ត្រីលើកមុន ។

ចំណែកគ្រូបង្រៀនវិជ្ជាគរុកោសល្យនេះ បានតម្រូវលើគ្រូកង់ពុទ្ធិក-
វិទ្យាល័យនេះខ្លះ ក្រសួងសិក្សាធិការជាតិបានចាត់អស់លោកខ្លះ ដែល
មានចំណេះយ៉ាងជំនាញឲ្យមកជួយខ្លះ គ្រូចាំងអស់នេះ ក៏ត្រូវបាន
ទទួលបំណាច់ផ្សាន់អំពីក្រុមបេសកកម្មអាមេរិកាំង ដូចជាលោកអាចារ្យ
អ្នកសិក្សាចាំងនោះដែរ ។

ខ្ញុំព្រះករុណា អាត្មាភាព មានអំណរដ៏លើសលុបចំពោះព្រះគុណ
សម្តេច ដែលបានទិមន្តមកជាអធិបតីភាពនៃវិធីនេះ សូមទទួលអំណរ
ដ៏ក្រៃលែងចំពោះលោករដ្ឋលេខាធិការ នឹងអស់លោកចាំងឡាយដែល
បានអញ្ជើញមកជាមង្គលនឹងជាកិត្តិយសដ៏ប្រសើរក្នុងពិធីនេះ សូមអរ
គុណចំពោះក្រុមបេសកកម្មអាមេរិកាំង ដែលមានសេចក្តីសប្បុរសជួយឲ្យ
បានសម្រេចការបណ្តុះបណ្តាលវិជ្ជាគរុកោសល្យដល់លោកអាចារ្យ នៅ
សាលាចារីរឹងចាំងឡាយក្នុងព្រះពុទ្ធសាសនា សូមអរគុណចំពោះអស់
លោកជាគ្រូបង្ហាត់បង្រៀនចាំងឡាយ ដែលបានខំយកចិត្តទុកដាក់
បង្រៀនអស់រយៈកាល ១ ខែកន្លងមកនេះ ។

ចំណែកអស់លោកអាចារ្យចាំងឡាយ ដែលបានចូលមកសិក្សានេះ
ខ្ញុំសូមរំលឹក សូមឲ្យយកចិត្តទុកដាក់បង្ហាត់បង្រៀនសិស្សតទៅ ដើម្បី
ជួយឲ្យព្រះពុទ្ធសាសនា នឹងប្រទេសជាតិមានដំណើរទៅមុខបានដោយ
សុវត្ថិភាព ។

ម្យ៉ាងទៀតសញ្ញាប័ត្រដែលប្រគេនក្នុងកាលឥឡូវនេះ គ្រាន់តែជាគ្រឿងបញ្ជាក់ថា បានមកសិក្សាវិជ្ជាគរុកោសល្យប៉ុណ្ណោះឯង ហើយខុសគ្រាប់ជាអនុស្សាវរីយ៍តទៅ ។

ទីបំផុតនេះ សូមគុណព្រះរតនត្រ័យនឹងទេវតាគ្រប់ទិសទីជួយអភិបាលរក្សាសម្ពុទ្ធ លោករដ្ឋលេខាធិការនឹងអស់លោកអ្នកចាំងឡាយឲ្យបានសុខចំរើនតរៀងទៅ ។

ការប្រគល់ឲ្យជាឧទ្ទរិកនូវព្រះធាតុ
នៃព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ
ទៅសមាគម "មហាពោធិ" នៅប្រទេសឥណ្ឌា

នៅចំណតអាកាសយានដ្ឋ-ដែលី លោកឧទុតាយការដ្ឋមន្ត្រីបានប្រគល់ព្រះធាតុនៃព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ ចំនួន ៣ កោដ្ឋ ឲ្យទៅសមាគម "មហាពោធិ" ។ ពិធីបុណ្យនេះបានធ្វើជាឧទ្ទរិកនៅទីចំណតអាកាសយានដ្ឋ-ដែលីតែម្តង ។ ព្រះធាតុទាំងនោះ គេបានតាំយកមកពីប្រទេសអង់គ្លេសដោយស្នាដៃនៃលោកស្រី "វិសាយ៉ា-ឡាកាមី" ជានាយកមស្នងការនៅឥណ្ឌាប្រចាំប្រទេសអង់គ្លេស ។

នៅពេលដែលយន្តហោះទៅដល់ គេសង្កេតឃើញលោកឧទុតាយការដ្ឋមន្ត្រី ព្រមទាំងវរជនជាច្រើននាក់នឹងអ្នកការទូតប្រទេសនីមួយៗដែលកាន់ព្រះពុទ្ធសាសនា បានរង់ចាំទទួលព្រះធាតុទាំងនោះ ។ នៅក្នុងចំណោមវរជនទាំងអស់នោះ ឯកឧត្តម ភី-ពាមិល ជាឯកអគ្គរាជទូតខ្មែរប្រចាំនៅប្រទេសឥណ្ឌាបានមកប្រជុំមក្នុងពិធីបុណ្យនេះដែរ ។

ព្រះធាតុទាំងនោះ គេបានរកឃើញនៅក្នុងចេតីយ ដែលបិតនៅសញ្ជី តាំងពី គ. ស. ១៨៥៦ ហើយគេបានតាំយកទៅដាក់ទុកនៅក្នុងវិចិត្រសាលជាតិនៃប្រទេសអង់គ្លេស នៅក្នុងទីក្រុង «ឡុង» តាំងពី គ. ស. ១៨៨៧ ។ ឥឡូវ រដ្ឋាភិបាលឥណ្ឌាទើបនឹងទទួលនូវព្រះធាតុទាំងនោះពីទីចាត់ការនៃវិចិត្រសាលជាតិអង់គ្លេសមកវិញ ។

គេបានដឹងថា នៅក្នុងកោដ្ឋទី ១ នឹងទី ២ មានបញ្ចុះព្រះធាតុនៃព្រះមហាវីរយ, ព្រះអបគ្រីយ, ព្រះកោដីនិបុត្ត នឹងព្រះវិជីសុវិជីវត ។ នៅក្នុងកោដ្ឋទី ៣ មានព្រះធាតុនៃព្រះដោសេកេបុត្ត, ព្រះគោតិបុត្ត នឹង ព្រះមោគល្លីបុត្ត ។

កាលណាគេបានតាំព្រះធាតុទាំងអស់នោះ ទៅដល់ទីកន្លែងដើមឯសញ្ជីវិញហើយ រដ្ឋាភិបាលឥណ្ឌាប៉ំរុងនឹងបង្ហាញកោដ្ឋទី ៣ ទៅរដ្ឋាភិបាលកោះស៊ីរីលង្កាជាមិនខាន ។

នៅពេលឥឡូវនេះ សមាគម "មហាពោធិ" បានរៀបតាំងជាសាធារណៈនូវព្រះធាតុទាំងនោះ រួចហើយទើបតាំយកទៅដាក់ទុកឯសញ្ជីតាមដើមវិញ ។

គ្រួសជំនុំធំនៃព្រះមហាក្សត្រ
COMMISSION DES MŒURS & COUTUMES

ភាសិតសុភាសិត

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៨ លេខ ៤ ខែមេសា ព. ស. ២៤៩៩ គ. ស. ១៩៥៦



កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បណ្តឹះរឿង	ទំព័រ
— វិចារណកថា (ដំណើរជីវិត)	ឃុនបណ្ឌាគុរ័ក្ស ប៊ូ-ប៊ូ	៣០៣
— សង្ឃសារណកថា	ព្រះមហា ហ៊ុន-ប្រ៊ិញ.	៣១៣
— ជាប់កថារឿងពុទ្ធប្បបុណ (តមក).....	ឃុនអន្តរកៅវិទ្យា-យ៉ូរ ប្រៃ	៣២៣
ផ្នែកអក្សរសាស្ត្រ		
- រឿងអ្នកស្នេហាជាតិ សាសនា មហាក្សត្រ (ត-ចប់)	ឃុនបណ្ឌាគុរ័ក្ស ប៊ូ-ប៊ូ..	៣៣០
- រឿងព្រះចាវុសរ៉ាំនសាង និងព្រះនាងសេហេរីស្តាន៏ (តមក)	អ្នកស្រី សារិះយ៉ាន ប្រៃ	៣៣៦
— សភាសិតរាជនីតិ ពាក្យកាព្យ (តមក).....	អ្នកនាយ៉ា នៅ	៣៤៤
— ពេត្រាព្រះរាជា (តមក)	លោក សុំន-ហ៊ាន ប្រៃ	៣៤៩
— រឿងសាមកុក (តមក)	នាយ ខូ - កន.....	៣៥៧
— រឿងបល់ត្តិទ្យ (តមក)	លោក ព័ឃ - ប៊ុក ប្រៃ	៣៦៥
កំណត់ធម៌ប្រវត្តិការណ៍		
— សេចក្តីកត់ហេតុអំពីព្រះរាជការណ៍បុណ្យភាក់ពណ្តាលព្រះពុទ្ធ សាសនានៅប្រទេសកម្ពុជា	ក្រសួងធម្មការ	៣៧០
— ពិធីសម្ពោធឆ្លងមន្ទីរពេទ្យព្រះសង្ឃ	ពុទ្ធសាសនបណ្ឌិត្យ ...	៣៨២
— ពិធីបុ ណ្យព្រហ្មទានវិធីនៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ	លោក ជាម-ពិន	៣៩៨

មួយឆ្នាំមាន ១២ លេខ — ដំឡៃដាវ ២៣០រ, ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Editorial (la vie)	*M. BOU-PO*	303
— Sanghasaranakatha	*Moka HUN-PRENH*	313
— Les statues Bouddhiques primitives (suite)	*Traduit par M. CHEA-YOU*	323

PARTIE LITTÉRAIRE:

— Le Patriotisme, (fin).	*M. BOU-PO*	330
— Le Roi RUZVANCHAD et la Princesse CHEHERISTANI (suite)	*Traduit par Mme PICH-SAL née SRIN-SARIS-YANN*	336
— Subhasitarajaniti (suite) . . .	*Oknha NEOU*	344
— Conte "Le Diamant du Raja" (suite)	*Traduit par M. SIN-HEAN*	349
— Histoire de SAMKOK (suite) . .	*Oknha NOU-KAN*	357
— Les trente deux récits du TRONE (suite)	*Traduit par M. RAY-BUC*	365

NOTES ET CHRONIQUES:

— Procès-verbal de la fête du 2.500 anniversaire de la mort du Bouddha	*Ministère des CULTES* . . .	370
— Inauguration de l'Hôpital des Bonzes	*Institut Bouddhique*	382
— Distribution des prix à l'Ecole Supérieure de Pâli	*M. CHAP-PIN*	398

Prix d'abonnement annuel (comprenant 12 numéros) 250$00

វិចារណកថា

ដំណើររបស់ជីវិត

ឃុនបណ្ណានុរក្សប៊ូ-ប៊ូ រៀបរៀង

ជីវិត ជាពាក្យថ្មាលី ប្រែថា "ការរស់នៅ", សម្រាប់មនុស្សសត្វដែលមានវិញ្ញាណ សំដៅយកត្រង់មានខ្យល់ដង្ហើមចេញចូល បើអស់ដង្ហើមពេលណា ហើយ ពេលនោះឈ្មោះថា ស្លាប់ ។ ការរស់នៅនឹងការស្លាប់នេះ ជាគូសត្រូវនឹងគ្នា តែងប្រយុទ្ធគ្នាយកជ័យជំនះតែរៀងខ្លួនជានិច្ច គ្មានពេលណាឈប់ស្រួមទេ ចេះតែជណ្តើមរស់ជណ្តើមស្លាប់គ្រប់នាទី ។ ឯការរស់នឹងការស្លាប់ តាមក្បួនពេទ្យថា ស្រេចលើរូបមនុស្សជាអ្នកចេះថែរក្សានឹងមិនចេះថែរក្សាខ្លួនតាមក្បួនអនាម័យ ឬថាស្រេចលើទុសថតូកែ ឬមិនតូកែ ឧទាហរណ៍ស្រេចលើគ្រូពេទ្យអ្នកប៉ិនប្រសប់នឹងមិនប៉ិនប្រសប់មើលជម្ងឺ ។ តាមក្បួនពុទ្ធសាសនាថា ការរស់នៅនឹងការស្លាប់ស្រេចលើកម្មផល មិនមែនស្រេចលើទុសថតូកែមិនតូកែ ឬគ្រូពេទ្យប៉ិនប្រសប់មិនប៉ិនប្រសប់ទេ ។ មតិគ្រូពេទ្យតែងលោកនឹងមតិពុទ្ធសាសនាខ្វែងគ្នាយ៉ាងនេះ មិនដឹងនិយ័យឲ្យជាប់ស្រេចទៅតាមមតិណាទេ ប៉ុន្តែសូមលោកអ្នកអានសង្កេតមើលសេចក្តីបរិយាយតទៅនេះចុះ, មុននឹងបរិយាយខ្ញុំតាំងជាប្រស្នា ៣ យ៉ាង:

- ១.— អ្វីបង្កើតមនុស្ស សត្វ នឹងវត្ថុផ្សេង ??

២.— អ្វីធ្វើឲ្យមនុស្សមានអាយុវែងនៅរហូតដល់ចាស់ជរា ?

៣.— អ្វីធ្វើឲ្យអ្នកមានអាយុវែងនោះបានទទួលសុខទុក្ខទុសគ្នា ?

ប្រស្នាទាំង៣ខនេះ ខ្ញុំនឹងដោះស្រាយតាមមតិ (សេចក្តីយល់ឃើញ) ផ្សេងៗគ្នា ពុកជូនលោកអ្នកអានដូចតទៅនេះ ៖

មតិសាសនាខ្លះ.— សាសនាខ្លះប្រកាន់ថា ព្រះជាអ្នកបង្កើតមនុស្ស បង្កើតសត្វ ទើរតែទាំងពួង, ព្រះធ្វើឲ្យមនុស្សមានអាយុវែង, ព្រះធ្វើឲ្យមនុស្សសត្វមានអាយុវែងបានទទួលសុខទុក្ខទុសៗគ្នា ។

មតិអ្នកវិទ្យាសាស្ត្រ — អ្នកវិទ្យាសាស្ត្រប្រកាន់ថា ហេតុនឹងផលបង្កើតមនុស្ស សត្វ ទើរតែទាំងពួង ។ ហេតុផលធ្វើឲ្យមនុស្សមានអាយុវែង ។ ហេតុផលធ្វើឲ្យអ្នកអាយុវែងបានទទួលសុខទុក្ខទុសៗគ្នា ដ្បិតថា ជីវិតរបស់មនុស្សយើងសព្វថ្ងៃនេះ តាមពិត ជាការធ្វើដំណើរមួយបែប ហៅថា ជិណើររបស់ជីវិត ដែលដើរតាមផ្លូវពេញពោរពៅដោយទុក្ខកយច្រើនកយ តាត់សំដៅទៅរកទីរំលត់ទុក្ខព្រួយ ជាទុក្ខដែលខ្លួនធ្លាប់បានជួបប្រទះរួចមកហើយនោះឯង មិនថាខ្លួនអ្នកនោះស្គាល់ផ្លូវឬមិនស្គាល់ផ្លូវទេ ជីវិតចេះតែធ្វើដំណើរទៅមុខជាដរាបគ្រប់នាទីឥតឈប់ឈរសោះឡើយ សូម្បីតែដេកលក់ក៏មិននៅស្ងៀមដែរ ។ បើជីវិតដើរទៅទាំងឆន្ទៈតឹងរ៉ឹងមិនយល់ផ្លូវខុសផ្លូវត្រូវហើយ ជីវិតក៏រមែងទៅប៉ះទង្គិចនឹងឧបស័គ្គកយច្រើនកយ ដែលមានទៅកណ្តាលផ្លូវជាធម្មតា ជីវិតចេះតែមានទុក្ខព្រួយលំបាកតាមផ្លូវរហូតទៅ ។ ឯដំណើរបស់ជីវិត

នេះ មិនមែនជាដំណើរដើរទៅដោយជើងទេ ជាដំណើរបស់ចិត្ត ជាផ្លូវឥតអ្នកណាមើលឃើញដោយភ្នែកទេ ជាផ្លូវខ្ពស់ផុតហួសផ្លូវកាយ ឬផ្លូវដើង ។ ហេតុនោះ ឲ្យជាអ្នកជ្រាបច្បាស់ពីបុព្វណាតក់ស្ទុះនៃចិត្តខ្លួន ដំណើរបស់ជីវិតនេះខ្លាំងណាស់ ហើយចំព្យាយាមរៀបរៀងក្បួនច្បាប់សម្រាប់ពន្យល់ពីដំណើរបស់ជីវិតឲ្យកាន់ច្រើន ។

តាមធម្មតារបស់ផ្លូវ ទោះបីជាផ្លូវចិត្តក្តី ជាផ្លូវដើរដោយជើងក្តី ត្រូវតែប្រកបដោយអង្គគុណាច្រើនប្រការ ទើបអ្នកដំណើរបានសុខសប្បាយ គ្មានភយន្តរាយកណ្តាលផ្លូវ ។ មែនពិត ផ្លូវដើងជ័ន្ធាយជាច់ស្រយាលត្រូវតែមានស្ពានឆ្លងទឹក, មានម្លប់ដើមឈើ, មានទីស្នាក់អាស្រ័យ, មានការគ្រប់គ្រងរក្សាទៅតាមចន្លោះផ្លូវ, មានអាបាវល្មមកេចរំកោគបានតាមផ្លូវហួតទៅ ។ល។ លុះតែផ្លូវណា មានរបស់ប៉ុណ្ណោះជាដើម ទើបអ្នកដំណើរទៅតាមផ្លូវនោះបានសុខសប្បាយ គ្មានគ្រោះថ្នាក់កណ្តាលផ្លូវអាចដើរដល់ទីតន្លែងដែលខ្លួនដៅទុកបានដោយសុវត្ថិភាព ។ ផ្លូវដើងនេះយ៉ាងណា ចំណែកផ្លូវរបស់ជីវិតក៏យ៉ាងនោះដែរ សូម្បីជីវិតធ្វើដំណើរសំដៅទៅរកទីបំផុតខ្ពស់តែម្យ៉ាងប៉ុណ្ណោះ ក៏ពិតមែនហើយ ប៉ុន្តែត្រូវឲ្យប្រកបដោយអង្គគុណាច្រើនប្រការ ដូចជាផ្លូវដើងនោះដែរ ។ ឯអង្គគុណសម្រាប់ផ្លូវរបស់ជីវិតឲ្យបានសុខសប្បាយចំរើនខាងមាន ៨ (១) យ៉ាងគឺ :

---

១ ស្រង់ចេញពីទស្សនាវដ្តី អនុស្សរណៈមហាចុលាលង្ការណ៍ រាជវិទ្យាល័យ ភ្នំពេញ ។

๑.— សាសនា ជាអង្គគុណដ៏សំខាន់ អាចជួយចំទុកបម្រុងជីវិត ឲ្យមានសេចក្តីរីករាយជ្រះថ្លា ឲ្យដឹកចិត្តខ្ជួនឯង ឲ្យរស់នៅជាសុខ សប្បាយ ត្រជាក់ត្រជំមិនឲ្យក្តៅក្រហាយ ។ សាសនាប្រៀបដូចទឹក សម្រាប់ចំទុកបម្រុងព្រឹក្សាជាតិ ឲ្យត្រជាក់ត្រជំស្រស់បស់លូតលាស់ធំ ឡើងរាល់វេលា ។

๒.— ប្រាជ្ញា សំដៅយកប្រាជ្ញាដែលមានមកអំពីកំណើត (ជាតិក-ប្បញ្ញា) ។ ប្រាជ្ញានេះជាអង្គគុណដ៏សំខាន់ អាចជួយឲ្យកើតឧត្តមគតិ ដ៏មានកម្លាំងរឹងប៉ឹងក្នុងការប្រតិបត្តិសាសនា ឬធ្វើកិច្ចការដទៃ ។ ឲ្យដឹកចិត្តខ្ជួនឯង ឲ្យកើតសេចក្តីព្យាយាម ទើបឲ្យកើតគុណធម៌ដទៃ ។ ទៀត ដ៏ជាតួកម្លាំងយ៉ាងសំខាន់ដូចគ្នាទាំងអស់ ធ្វើចិត្តមិនឲ្យរួញរា មិនឲ្យលេះ ណោះសាវឬថយក្រោយ ។ បើនិយាយដោយសង្ខេប : ប្រាជ្ញាជួយឲ្យ មានសមត្ថភាពទៅជាអ្នកប្រាជ្ញ ឬជួយឲ្យគោលចំណងរបស់ខ្ជួនបាន សម្រេចផលដូចប្រាថ្នា ។

๓.— វិរិយៈសង្ខេប ជាអង្គគុណ អាចជួយតម្រែតម្រង់ប្រាជ្ញា ឲ្យធ្វើការត្រង់ផ្លូវដែលនឹងឲ្យបានសម្រេចផលល្អ ព្រោះថាមនុស្សខ្លះ កើតមកមានប្រាជ្ញាពីកំណើតឈ្វាសវៃណាស់, ប៉ុន្តែបើមិនរៀនសូត្រ ចំណេះវិជ្ជាណាមួយសោះ អ្នកនេះនឹងធ្វើការអ្វី ។ ច្រើនតែថ្លង់ ឆ្គាំឆ្គងខូចខាតផលប្រយោជន៍ ដ្បិតបេះតែគិតស្មាន ។ ផ្សេងទៀតក

តាមតំនិតរបស់ខ្លួន គ្មានអាងក្បួនច្បាប់អ្វីសោះ ឈ្មោះថាគ្មានវិន្យាសាស្ត្រជួយតម្រែតម្រង់ជាជ្រុងផង ។

៤.— សិល្បៈ ជាអង្គគុណ អាចជួយឲ្យចិញ្ចឹមជីវិតបានងាយ។ ព្រោះការរេះគំនូរផ្សេង ។ មានការជាងគំនូរ, ជាងធ្វាក់ជាដើម រហូតដល់ការកាំ, ការច្រឹង ឧដ្ឋត្ថរត្តន្ត្រី ជាការល្មមឲ្យជីវិតធ្វើដំណើរទៅបានសុខស្រួល ។

៥.— ភូមិធម៌ គួមិនមិកង់ទីនេះសំដៅយកសេចក្តីសុចរិតល្អសេចក្តីពិតត្រង់ ។ បើអ្នកណាប្រព្រឹត្តសុចរិតស្មូតត្រង់ល្អ, ប្រកាន់សច្ចៈហើយ អ្នកនោះឈ្មោះថាមានធម៌នៅក្នុងខ្លួន ។ ធម៌នេះអាចជួយឲ្យកើតបុគ្គលិកលក្ខណៈ: គឺធ្វើឲ្យកើតកិរិយាមារយាទព្រឿលក្ខណៈជាមនុស្ស មានការនាំឲ្យអ្នកផងស្រឡាញ់រាប់អានចង់សេពគប់យកជាមិត្ត អាចធ្វើជីវិតឲ្យតាំងនៅក្នុងឋានៈជាបុជនីយបុគ្គលគួរគេគោរពបូជា ដើម្បីជាទីពឹងដល់ខ្លួនឯងបានផង ដើម្បីទប់ទាញជីវិតរបស់មនុស្សឯទៀតឲ្យរស់នៅជាសុខសប្បាយតាមខ្លួនផង ។ ចំណែកមនុស្សដែលចេះសិល្បៈហើយ ប៉ុន្តែខ្វះភូមិធម៌ ចាត់ជាមនុស្សមិនចំនាន ព្រោះដំណើរជីវិតរបស់អ្នកឥតធម៌នោះ គ្មានសុខ គ្មានចំរើន ។

៦.— សេចក្តីបេះដឹង ជាអង្គគុណដ៏សំខាន់ អាចជួយឲ្យមានកម្លាំងក្នុងការតែរិះពិចារណាវិនិច្ឆ័យរឿងក៏ដូចផ្សេង ។, ក្នុងការស្រាវជ្រាវពិសោធមើល, ក្នុងការកែសម្រួលដោះស្រាយឧបសគ្គផ្សេង ។

ទឹងកន្លងរឿងដទៃទៀតបានយ៉ាងឆ្ងាយទូលាយ ដើម្បីរកផ្លូវដែលទឹងធ្វើដំណើរបស់ជីវិតឲ្យប្រព្រឹត្តទៅបានស្រួល ។ ងាយ ។ ។

៧.— ស្មារតី ជាអង្គគុណដ៏សំខាន់ អាចជួយឲ្យកើតសមត្ថភាពប្រុងប្រយ័ត្ន (ចុងក្រោយ) ក្នុងការធ្វើដំណើរបស់ជីវិតឲ្យបានសម្រេចផលល្អយ៉ាងជាប់ស្រេច គ្មានគ្រោះថ្នាក់កណ្តាលផ្លូវ ព្រោះបានទឹករលឹកដឹងផ្លូវរៀបប្រត្រង់ ខុសប្រត្រួស តាមតម្រាយនៃសេចក្តីចេះដឹងដែលមានក្នុងខ្លួនស្រាប់មកហើយ ។ ស្មារតីជាធំបំផុតក្នុងដំណើរបស់ជីវិត គ្រប់យ៉ាងគ្រប់លំដាប់ខ្សែដង្វើមចេញចូល, ធ្វើឲ្យដំណើរបស់ជីវិតប្រព្រឹត្តទៅបានដោយងាយ, ដោយសម្បូណ៌សប្បាយ ទឹងឲ្យរួចពីកយន្តភាយទាំងពួង ។

៨.— អ៊ីជាម៉ីយ ជាអង្គគុណដ៏សំខាន់ អាចជួយឲ្យមានកម្លាំងកាយខ្លាំងរឹងដ៏ជាបាទដ្ឋាននៃកម្លាំងចិត្ត, ជួយឲ្យកាយថ្នឹកគួរដល់ការងារផ្សេង ។, ជួយឲ្យចិត្តរីករាយក្សាហាន ដោយឥតភេតធ្ងន់ៗប្រចាំខ្លួនក្នុងខ្លួន, ជួយធ្វើរូបកាយមិនឲ្យមានជម្ងឺ ។ បើរូបកាយមិនឈឺចាប់ហើយរមែងមានកម្លាំងខ្លាំងអាចនឹងធ្វើការអ្វី ។ បានតាមចិត្តចង់ ប្រៀបដូចសេះដែលម្ចាស់ថែរក្សាដោយម៉ត់ចត់ ជាពាហនៈអាចដឹកនាំម្ចាស់ឲ្យទៅដល់ទីដៅបានដោយងាយ ដោយឆាប់រហ័ស ។ ឯរូបកាយរបស់យើងប្រៀបដូចខ្លួនសេះ, ចិត្តគំនិតរបស់យើងប្រៀបដូចម្ចាស់សេះ ។ ចុះបើយើងកើតជំងឺធ្ងន់ដែលឬជើងហើយ តើយើងអាច

ទីធ្វើការអ្វីៗបានតាមចិត្តចង់ដែរឬទេ? បុរេបើសេះកើតជំនៀតទៅបានដើរតាល់តែរបើតក្រចកចេញបាត់ហើយ តើវាទីធ្វើចោលទាំម្ចាស់ទៅរួចដែរឬទេ? អនាម័យនេះ ជាអគ្គគុណដ៏សំខាន់បំផុត លើសអគ្គគុណ ៧ ខាងដើម ព្រោះថាជួយទៅវិញ បើយើងកើតជម្ងឺគ្រុនពេងតាំងពីក្មេងតូចមកនោះ តើសាសនា, ច្បាប់, វិទ្យាសាស្ត្រ, សិល្បៈ, កូមិធមិ, សេចក្តីចេះដឹង ទីធ្វើស្មារតី មានទៅបរិបូណ៌ក្នុងខ្លួនយើងដែរឬទេ? សូមពិចារណាមើលចុះ ។

អគ្គគុណទាំង ៨ ប្រការ ដូចបានពន្យល់មកនេះ កាលបើរួមចូលគ្នាជាកម្លាំងតែមួយហើយ អាចទីធ្វើជួយឲ្យដំណើរបស់ជីវិតរស់ទៅបានរួងរួយរហូតដល់ចាស់ជរា មិនធាប់ស្លាប់ពីក្មេង ហើយថែមទាំងធ្វើជីវិតឲ្យបានសេចក្តីសុខសប្បាយច្រើនផង ឲ្យមានកោតសម្បទាបរិបូណ៌ ប្រយ័ត្នសុខភាពផង ។

ចំណែកមនុស្ស ១ ពួក ទៀត វែលមានអាយុវែងដូចគ្នាដែរ ប៉ុន្តែជាអ្នកមានសេចក្តីទុក្ខព្រួយលំបាកច្រើន ហើយថែមទាំងខ្លីលក្រណាស់ផងនោះ ព្រោះតែខ្វះអគ្គគុណ ៨ ប្រការនេះ បើទុកជាមានខ្លះ ក៏មានតែបន្តិចបន្តួចស្ទួចស្ទើមិនស្រួលបរិបូណ៌ ។

សត្វថ្ងៃនេះ មតិអ្នកវិទ្យាសាស្ត្រប្រកាន់ថា មនុស្ស, សត្វ ទីធ្វើតុ ទាំងអស់ដែលកើតមានឡើងក្នុងលោកនេះកើតឡើងតាមធម្មតានៃលោកធាតុ កាលកើតឡើងហើយតែងប្រែប្រួលសាបសូន្យទៅវិញ គឺមនុស្ស

កើតមកភ្លាមជាក្មេងតូច លុះយូរទៅធំចាស់ជរាឈឺស្លាប់ជាទីបំផុត, ពួជឈើកាលដុះពន្លកចេញមកពីគ្រាប់ហើយ ក៏ចេះតែចំរើនធំឡើងរាល់វេលាដោយគ្មានអន្តរាយអំពីអ្វី។ រហូតដល់ធំខ្ពស់អស់ចំណាស់ហើយក៏ត្រូវងាប់ទៅវិញ ។

មតិអ្នកវិទ្យាសាស្ត្រប្រកាន់យកហេតុផល (កម្មផល) ថាជាគោលធំបំផុតដូចមតិពុទ្ធៈដែរ, បដិសេធព្រះអ្នកសាងលោកដូចមតិពុទ្ធៈដែរ គឺគេមិនជឿថា លោកនេះមានព្រះសាងឡើងទេ ។ គេជឿថា លោកនេះកើតឡើងតាមធម្មតានៃលោកធាតុដោយអាស្រ័យហេតុផល (កម្មផល) ។ ហេតុជាគ្រែសែទ្យកើតផល ផលជាប់គ្រែសែមកពីហេតុ ប្រៀបដូចគ្រាប់គាំភ្លើងមានរំសេវនៅខាងក្នុងសម្រាប់នេះផ្ទុះស្រាប់ហើយ ប៉ុន្តែបើមនុស្សមិនបុចទ្រនិចឲ្យវានេះទេ វាក៏ចេះតែនៅស្ងៀមរហូតទៅ មើលគេបុចទ្រនិចវាកាលណាវាក៏នេះផ្ទុះក្នុងកាលនោះភ្លាម គ្រាប់គាំភ្លើងមានរំសេវនៅខាងក្នុងទុកជាពួជរបស់មនុស្ស សត្វទឹកត្តិរច្ឆានជាដើម, គ្រាប់កំរិយាបុចទ្រនិចទុកជាហេតុ (កម្ម), គ្រាប់វានេះផ្ទុះចេញទៅទុកជាផល ។

មតិអ្នកវិទ្យាសាស្ត្រប្រកាន់យកហេតុផល (កម្មផល) ថាជារបស់សំខាន់ណាស់, គោលទូទៅរបស់វិទ្យាសាស្ត្រនោះនៅត្រង់ហេតុផល ។ អ្នកវិទ្យាសាស្ត្រ កាលគេនឹងដឿប្រកាន់យករបស់ណាមួយ តែងពិសោធន៍ស្រាវជ្រាវរកហេតុផលឲ្យឃើញពិតជាមុនសិន, នេះជាគោលដែលគេប្រតិបត្តិជាប់ជានិច្ច ។ ការដែលដឿប្រកាន់ស្មាន។ ដោយមិនបាន

ដេញដោលរកហេតុផលឲ្យឃើញពិតទេ នោះមិនមែនជាគោលនៃវិញ្ញាសាស្ត្រឡើយ ។

មតិពុទ្ធ: ព្រះសម្ចាសម្ពុទ្ធទ្រង់ប្រកាន់ថា "លោកនេះ គ្មានអ្នកណាកសាងឡើងទេ កកើតឡើងឯង។ តាមធម្មតា, ដូចជាមតិអ្នកវិញ្ញាសាស្ត្រដែរ ។ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ ព្រះអង្គប្រកាន់ហេតុផលនឹងការពិសោធន៍រកហេតុផលជាគោលសំខាន់បំផុត ដូចមតិអ្នកវិញ្ញាសាស្ត្រដែរ សឹងមានពាក្យជាសំអាងដែលព្រះអស្សជិត្ថេរសំដែងតាមតិពុទ្ធៈ ដោយសារបគោលធម៌យ៉ាងខ្ជីបំផុតថា 'របស់ទាំងពួង (ធម៌) មានហេតុជាដែនកើតមុន, កាលបើហេតុរលត់ហើយ ផលក៏រលត់ទៅតាម, ហេតុនឹងផលជារបស់ដែលត្រូវតែជាប់ទាក់ទងនឹងគ្នាជានិច្ច

(យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ,
តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោតិ)" ។

មតិពុទ្ធ: ក្នុងព្រះសូត្រមួយ ចានដំណាលថា កាលព្រះពុទ្ធអង្គគង់ព្រះជន្មនៅឡើយ មានមាណពម្នាក់ជាអ្នកចេះដឹងវិញ្ញាសាស្ត្រច្រើនយ៉ាង ចានចូលទៅគ្រាបទូលសួរព្រះពុទ្ធជាម្ចាស់អំពីរឿងដែលមនុស្សកើតមកប្លែកៗ គ្នា អ្នកខ្លះល្អ, អ្នកខ្លះអាក្រក់, អ្នកខ្លះមាន, អ្នកខ្លះក្រ ។ល។ យ៉ាងនេះតើព្រោះហេតុអ្វី? ព្រះពុទ្ធទ្រង់ឆ្លើយប្រស្នានេះដោយគោលធម៌យ៉ាងខ្ជីថា :

"មនុស្សសត្វទាំងឡាយដែលកើតមកប្លែក ។ គ្នានោះ ព្រោះជាប់ចំពាក់ទឹងកម្មរបស់ខ្លួនឯង ជាទាយាទរបស់កម្ម ជាអ្នកមានកំណើតអំពីកម្ម ជាផៅពង្សរបស់កម្ម មានកម្មជាទីពឹង បើធ្វើកម្មល្អ ទើបបានទទួលផលល្អ បើធ្វើកម្មអាក្រក់ ទើបបានទទួលផលអាក្រក់ (សត្វេ សត្តា កម្មស្សកា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករិស្សន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវិស្សន្តិ)" ។

ព្រះពុទ្ធដីកាថា "កម្ម, ផល" នេះ ត្រូវទើងតាក្យថា "ហេតុ, ផល" ដែរ មិនខុសគ្នាទេ អាចប្រើផ្លាស់ប្តូរគ្នាបាន ចង់ថា "កម្ម" ក៏បាន ចង់ថា "ហេតុ" ក៏បាន ។

ការពិចារណាអំពីដំណើរដ៏វែង ពុកជាផ្លូវគំនិតនៃសាធុជនក៏ល្មមទើបបញ្ចប់ហើយ ដូច្នេះលោកអ្នកអានគួរដឿតាមមតិណា ? តាមមតិ-ពាហិរសាសនា ឬតាមមតិអ្នកវិទ្យាសាស្ត្រ ឬក៏តាមមតិពុទ្ធសាសនា ។ ចំណែកខាងខ្ញុំ ដឿធ្ងន់ទៅក្នុងមតិអ្នកវិទ្យាសាស្ត្រទើងមតិពុទ្ធសាសនា, នេះសូមដំរាបដោយត្រង់ហើយ ។

សង្ឃសរណគាថា

ព្រះមហា ប៊ុត - ប្រុញ្ញ រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះមានជោគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ត្រមាំងព្រះធម៌ទំងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

អត្ថាកាត សូមសំដែងអំពីសង្ឃសរណៈដូចមានសេចក្តីតទៅនេះ:

ព្រះពុទ្ធជាបវេណី ខ្ងំមានយុត្តិធម៌ស្មើភាគ គឺខ្ងំមិនលើកតំពស់ ឬកៀរគោយប្រមូលជាក់លើព្រះអង្គតែមួយ ព្រះអង្គប៉ុណ្ណោះឡើយ តាំងព្រះសទ្ធម្មជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដែលខ្ងំសំដែងទេ យព្រះអង្គ ក៏មិនមានសេចក្តីរង្កៀស ខ្ងំលើកឡើងជាសរណៈស្មើគ្នានឹងព្រះអង្គ, រកសាស្តាណាមួយដែលជាគ្រូកាន់យុត្តិធម៌ស្មើភាគដូចព្រះអង្គគ្មាន សាស្តាដទៃប្រែនតែលើកតំពស់ ឬកៀរគោយជាក់លើខ្លួន សម្រែចលើខ្លួន ធំលើខ្លួន ជាសេចក្តីមិនសមហេតុមិនសមផល ។ ដែលព្រះអង្គខ្ងំលើកជាសរណៈស្មើភាគគ្នានេះ ជាការប្រសើរណាស់ ព្រោះសរណវត្ថុតាំង ៣ ប្រការ គឺពុទ្ធសរណៈ ធម្មសរណៈ នឹងសង្ឃសរណៈនោះគោងអស្រ័យគ្នានឹងគ្នា, បើខ្វះខាងណាមួយមិនបានឡើយ មិនកើតឡើងទៅជាសាសនា ; ឧបមាដូចជាឈើ ៣ កំណាត់ ដែលបុគ្គលយកទៅបញ្ឆេះភ្លើងបុងខ្ងល់គ្នា ក៏អាចតាំងទៅបាន, កាលណាបុគ្គលយក

មួយកំណាត់ចេញ ពីរកំណាត់ទៀតមិនអាចតាំងនៅបានទេ, បើបុគ្គលយកពីរកំណាត់ចេញ មួយកំណាត់ទៀតក៏រឹតតែមិនអាចតាំងនៅបានណាស់ទៅទៀត ។ ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ, កំតោងអាស្រ័យទុំគ្នាដូច្នោះដែរ; ព្រោះថា បើមានព្រះសម្ពុទ្ធគ្រាស់ដឹងឡើងហើយ។ ប្រសិនជាព្រះអង្គមិនបានសំដែងធម៌ឲ្យអ្នកណាស្តាប់ទេ ក៏គ្មានប្រយោជន៍អ្វីដល់សត្វលោក ព្រះអង្គបរិនិព្វានទៅតែមួយអង្គប៉ុណ្ណោះ ។ បើព្រះអង្គសំដែងធម៌ហើយគ្មានអ្នកណាចូលទៅជិតត្រង់ត្រាប់ប្រតិបត្តិយក ក៏ទទេទៀត សំដែងទៅគ្រាន់តែឮកាត។ ដូចគ្នានឹងគ្រដៀកគៀកប៊ីអ្នកស្រុក ។ ប៉ុន្តែមិនដូច្នោះឡើយ អាស្រ័យដោយព្រះមហាករុណាជាកំពូលឯក កាលព្រះអង្គបានត្រាស់ហើយ បានសំដែងសាសនធម៌ចង្អុលប្រាប់ផ្លូវល្អក្រៃក្រក់ គុណទោស គួរធ្វើមិនគួរធ្វើ ឲ្យសត្វលោកបានស្តាប់យកប្រតិបត្តិតាម ទាល់តែដល់នូវសេចក្តីបរិសុទ្ធផូរផង់ផុតទុក្ខភ័យដូចជាព្រះអង្គដែរ ហើយពាក្យប្រៀនប្រដៅរបស់ព្រះអង្គនោះ ក៏ប្រតិស្ឋានជាពុទ្ធសាសនាត។ តាមក ជាប្រយោជន៍ដល់ប្រជុំជនច្រើនរហូតមកដល់សត្វថ្ងៃនេះ ។ បើប្រសិនជាគ្មានព្រះសង្ឃជាអ្នកត្រង់ត្រាប់ស្តាប់រៀនសូត្រប្រតិបត្តិតាមទេ ហើយគ្មានអ្នកនាំពាក្យប្រៀនប្រដៅប្រកាសតទៅមក, យើងពាល់គ្នាកន្ទឹងដំនាន់នេះ ក៏ឆ្ងីតស្ងប់ឥតដឹងជាបបុណ្យគុណទោសអ្វីឡើយ ។ សូមលើកយកឧទាហរណ៍ចំពោះការដែលព្រះសង្ឃធ្វើប្រយោជន៍ដ៏ធំទុកដល់យើងពាល់គ្នា ឲ្យឃើញដូចតទៅនេះ :

កាលព្រះបរមសាស្តាស្តេចរលត់ទន្ទេចូលកាន់ព្រះនិព្វានហើយ បើកប់ឈ្មោះវែងបាន ៤ ខែ, បើកប់ចំនួនថ្ងៃបាន ៩០ ថ្ងៃគត់ ព្រះអរិយសាវ័កពាំងឆ្ងាយនាំគ្នាធ្វើសន្និបាតប្រជុំនូវមណ្ឌបថ្មី ឈ្មោះសត្តបណ្ណគូហានាក្នុងវេភារៈ ក្បែរក្រុងរាជគ្រឹះមហានគរ ដែលព្រះបាទអជាតសត្រូវបានសាងប្រគេន, ជួយគ្នាប្រមូលព្រះធម៌ដែលព្រះអគ្គសាវ័កទ្រង់ប្រៀនប្រដៅនឹងព្រះវិន័យដែលទ្រង់បញ្ញត្តទុកជាផ្លូវប្រតិបត្តិសម្រាប់តក្កសង្ឃតាំងអំពីដើមរៀងមក ឲ្យចូលជារបៀបរៀបរយតែមួយ ។ ព្រះមហាកស្សបត្ថេរជាប្រធានក្នុងការប្រជុំនោះ បានចាត់ព្រះមហាអានន្ទត្ថេរដែលស្ទាត់ជំនាញក្នុងបទធម៌ឲ្យជាអ្នកវិសជ្ជនាបែកខាងព្រះធម៌, ចាត់ព្រះឧបាលិត្ថេរដែលស្ទាត់ជំនាញក្នុងវិន័យឲ្យជាអ្នកវិសជ្ជនាបែកខាងវិន័យ ។ លុះប្រជុំតម្រូវឲ្យត្រឹមត្រូវតាមព្រះពុទ្ធដីការហើយ ក៏សម្រេចទុកជាបែបផែន នាំគ្នាទន្ទេញស្វាធ្យាយព្រះធម៌វិន័យនោះចាំមាត់ស្ទាត់រៀងខ្លួន តែសម័យនោះមិនទាន់មានការចារកជាតួអក្សរនៅឡើយ ។ ក្នុងសន្និបាតនោះព្រះមហាកស្សបត្ថេរបានជ្រើសរើសព្រះអរហន្ត ដែលទ្រទ្រង់បដិសម្ភិទាញាណ ចំនួន ៤៩៩ អង្គ ជា ៥០០ និងអគ្គសោក, មានព្រះបាទអជាតសត្រូវជាសាសនូបត្ថម្ភក៍, ធ្វើចំនួន ៧ ខែទើបហើយស្រេច ហៅថា "បឋមសង្គាយនា" ។ ហេតុដែលកើតបឋមសង្គាយនានេះ មកពីភិក្ខុចាស់មួយរូប ឈ្មោះ សុភទ្ទ ជាអ្នកតោលប្រទូស្តទៅរកព្រះបរមគ្រូ ។ ព្រះមហាកស្សបត្ថេរបានជ្រាបពាក្យចម្រូងចម្រាសនេះហើយ ក៏យល់ថា "ពាក្យនេះអាចនាំបំបែកសាសនាជាថ្មីទៀតបានមិនខាន" លោកពិចារ-

ណាថា "កិច្ចសំខាន់ដែលនឹងរំដាច់នូវពាក្យចម្រូងចម្រាស់នេះបាន គឺត្រូវតែប្រមូលតុន្តវចនៈរបស់ព្រះបរមគ្រូ ឲ្យមានរបៀបរៀបរយឡើងវិញសិន" ។ លុះស្រេចការសង្គាយនាហើយ ព្រះអរិយសាវ័កទាំងឡាយ ក៏បែកទៅកន្លែងនៅក្នុងប្រទេសផ្សេងៗ គ្រាច់តែប្រកាសសាសនា ប្រដៅប្រជាជនព្រមទាំងឲ្យបព្វជ្ជាឧបសម្បទាដល់អ្នកមានសទ្ធា ។ ពួកគ្រោយៗមក ក៏នាំគ្នាទទួលធម៌វិន័យតាមបែបផែនដែលបានធ្វើសង្គាយនានោះ តាន់យកជាគោលថែរក្សាព្រះពុទ្ធសាសនា ។

លុះកន្លងយូរមក ព្រះអរិយសាវ័កលោកអ្នកធ្វើសង្គាយនាទាំងនោះចូលបរិនិព្វានអស់ទៅ, កិច្ចដែលជាថេរៈក្នុងគណៈនីមួយៗ ក៏គ្រប់គ្រងគណៈសង្ឃតមក សូម្បីអំពីដើមស្មាជ្ញាយន៍ធម៌វិន័យតាមបែបផែនដែលធ្វើសង្គាយនាមកជាមួយគ្នាក៏បែកគំនិតផ្សេងៗគ្នា តាមគណៈនោះៗ ។ កាលព្រះបរមសាស្តាស្តេចចូលកាន់ព្រះនិព្វានទៅ បានជាង ១០០ ឆ្នាំ មានភិក្ខុមួយពួកហៅថាវជ្ជីបុត្តកៈនៅនគរវេសាលី ។ ពួកវជ្ជីបុត្តកៈប្រហែលជាប្រកាន់យកនូវដែលមានក្នុងមហាបរិនិព្វានសូត្រថា "ព្រះពុទ្ធអង្គបានអនុញ្ញាតទុកថា បើភិក្ខុទាំងអស់យល់ឃើញព្រមព្រៀងគ្នាថា ខុទ្ទានុខុទ្ទកសិក្ខាបទ គឺសិក្ខាបទតូចៗ ណាមួយដែលខ្លះបានបញ្ញត្តរួចហើយ លុះកាលកន្លងទៅ បើប្រព្រឹត្តមិនស្រួលឲ្យតែប្រែបាន"; នេះជាមូលហេតុ ពួកភិក្ខុវជ្ជីបុត្តកក៏តែប្រែវិន័យបញ្ញត្តលើកយកវត្ថុ ១០ ប្រការឡើងប្រាប្តេ មានន័យថា កប្បតិ សិង្គិលោណកប្បោ ទុកអំបិលបម្រុងដើម្បីពរយោជាយចំណាកាត គរទៅថ្ងៃមុខទៀតបាន ។

គ្រានោះព្រះយសត្ថេរ ជាអ្នកឧត្តែងក្នុងការរម្ងាប់អធិករណ៍នោះ បានទំមន្តព្រះមហាថេរដែលជាមេគណាចារ្យក្នុងគណៈដទៃ ៗ មានព្រះសព្វកាមិត្ថេរ ធីរ៍ព្រះរេវតត្ថេរជាដើម ព្រមទាំងគណៈសង្ឃឯទៀតជាច្រើន មកប្រជុំគ្នានៅឧត្តរវេសាលី រំនិច្ចំយថាវុត្ត ๑๐ ប្រការ ដែលពួកភិក្ខុវជ្ជីបុត្តកែប្រែវិន័យនោះមិនសមគួរទេ ព្រោះកាលព្រះអរិយសាវ័កធ្វើបឋមសង្គាយនានោះ បានយល់ព្រមថា “ទោះព្រះពុទ្ធអង្គបានប្រទានខុកត្តីកំមិនគួរនឹងមកកែប្រែឲ្យខុសអំពីបទដែលទ្រង់បញ្ញត្តឡើយ” ។ ហើយបានរម្ងាប់វត្ថុ ๑๐ ប្រការឲ្យសាបសូន្យទៅ រួចប្រជុំព្រះអរហន្តចំនួន ๗๐๐ អង្គ លើកសង្គាយនាតាមលំអានព្រះមហាកស្សបត្ថេរមួយលើកទៀត ហៅថាទុតិយសង្គាយនា ប្រជុំធ្វើនៅវាលុការាម ទៀបក្រុងវេសាលី មានព្រះជាគាលាសោកជាសាសនូបត្ថម្ភក៍ធ្វើ ๘ ខែហើយស្រេច ។

លុះព្រះពុទ្ធសាសនាកន្លងទៅជាច្រើនឆ្នាំ ព្រះពុទ្ធសាសនាក្នុងបាតលិបុត្រ មានវិបរិតដោយពួកតិរ្ថិយចូលបួសបន្ធុំយកលាភសក្ការៈជាច្រើន; ព្រះមោគ្គលិបុត្តតិស្សត្ថេរ បានញ៉ាំងព្រះបាទអសោកព្រះចៅក្រុងបាតលិបុត្រឲ្យទ្រង់សិក្សាបានជ្រាបច្បាស់នូវពុទ្ធសាសនា ហើយទ្រង់ពិនិត្យផ្សឹកពួកតិរ្ថិយចេញអស់ ។ រួចហើយព្រះមោគ្គលិបុត្តតិស្សត្ថេរ រើសព្រះអរហន្តដែលទ្រង់ទ្រង់បដិសម្ភិទាជាច្រើនអង្គ ប្រជុំធ្វើសង្គាយនាទៀត ហៅតតិយសង្គាយនា នៅអសោការាម ទៀបក្រុងបាតលិបុត្រ មានព្រះជាអសោកជាសាសនូបត្ថម្ភក៍ធ្វើ ๙ ខែហើយស្រេច ។ រួចហើយ

ព្រះអាទិត្យអស្តង្គតទៅ ដែលអាចជាព្រះកិត្តិសង្ឃឲ្យចេញទៅប្រកាសសាសនាក្នុងប្រទេសផ្សេង ៗ ដូចតទៅនេះ :

๑ - ព្រះមហាទេវត្ថេរ ទៅមហិសមណ្ឌល (គឺដែនខាងត្រើមទន្លេគោទាវរី ប្រទេសម៉ៃសូរសព្វថ្ងៃនេះ) ;

๒ - ព្រះរក្ខិតត្ថេរ ទៅរដ្ឋវនប្រទេស (គឺដែនខាងលើ ជាខេត្តបុមប៉ៃសព្វថ្ងៃនេះ) ;

๓ - ព្រះធម្មរក្ខិតត្ថេរ ទៅបវត្តប្រទេស (គឺដែនជួរជាយទន្លេខាងលើស្រុកបុមប៉ៃសព្វថ្ងៃនេះ) ;

๔ - ព្រះមហាធម្មរក្ខិតត្ថេរ ទៅមហារដ្ឋប្រទេស (គឺដែនខាងដើមទន្លេគោទាវរី) ;

๕ - ព្រះមជ្ឈន្តិកត្ថេរ ទៅកស្មិរៈនិងគន្ធារៈប្រទេស (គឺអាហ្គានីស្ថានសព្វថ្ងៃនេះ) ;

๖ - ព្រះមជ្ឈិមត្ថេរ ទៅហិមវន្តប្រទេស (គឺមណ្ឌលដែលតាំងនៅជើងភ្នំហិមាល័យ មានឈ្មោះថាលវដ្ឋជាដើម) ;

๗ - ព្រះមហារក្ខិតត្ថេរ ទៅយោនកប្រទេស (គឺស្រុកដែលនៅក្នុងប្រទេសម៉ៃរ្យសព្វថ្ងៃនេះ) ;

๘ - ព្រះមហិន្ទត្ថេរ ទៅលង្កាទ្វីប ;

๙ - ព្រះសោណត្ថេរ ទើបព្រះឧត្តរត្ថេរមកកាន់សុវណ្ណភូមិ គឺដោយឥណ្ឌូចិនយើងនេះ ។

លុះដល់ព្រះពុទ្ធសកាជ ๙๙๖ ឆ្នាំ ព្រះពុទ្ធឃោសាចារ្យនៅក្នុង

ឥណ្ឌា ចូលទៅលង្កាទ្វីប ប្រែអដ្ឋកថាអំពីភាសាស័ង្ហឡៈ គឺភាសាអ្នកលង្កាទ្វីបមកជាមគធភាសាថាវង្សាក់ស្មឹកតែតាល់តែចប់ចាំងអស់ ។ លុះក្រោយមកមានព្រះសង្ឃខ្មែរនិងព្រះសង្ឃប្រទេសឯទៀត ចេញទៅរៀនព្រះត្រៃបិដកភាសាមគធៈទៅលង្កាទ្វីប ហើយត្រឡប់មកកាន់ប្រទេសរបស់ខ្លួន ចូលចាំងនាំយកព្រះត្រៃបិដក មកប្រែនប្រដៅប្រជាជនក្នុងប្រទេសរៀង ។ ខ្លួន ដែលជាប់មានមកដល់សព្វថ្ងៃនេះ ។ ពាក់ថាព្រះសង្ឃបានធ្វើប្រយោជន៍ដ៏ធំ ជាបរមិតសម្បត្តិដល់ប្រជុំជនជាច្រើន ។ នេះសំដែងតែប្រយោជន៍ខាងក្រៅ ដែលព្រះសង្ឃបានធ្វើដល់ពុទ្ធសាសនិកជន ។

ឯប្រយោជន៍ខាងក្នុង ដែលលោកចំបំពេញសម្រាប់ខ្លួនលោកជាអត្តហិតសម្បត្តិនោះ គឺលោកចំសិក្សាត្រង់តាប់នូវបទរបស់ព្រះបរមសម្ពុទ្ធហើយប្រតិបត្តិញ៉ាំងកាយ, វាចា, ចិត្តឲ្យសុភាពរាបសា ព្យាយាមលះសំយោជនៈជាគ្រឿងតភ្ជាប់ចិត្តដែលជាប់នៅក្នុងភព តាមលំដាប់តាល់តែបានលុះលោកុត្តរភូមិជាជាន់ ។ ទៅមុខទៀត ។ កំណត់តាមថ្នាក់ដែលលោកលះសំយោជនៈបាននោះមាន ៤ ថ្នាក់ :

ថ្នាក់ទី ១ លោកដែលបានសំរេចសោតាបត្តិមគ្គនិងសោតាបត្តិផល; លោកលះសំយោជនៈ បាន ៣ យ៉ាងគឺ សក្កាយទិដ្ឋិ, វិចិកិច្ឆា និងសីលព្វតបរាមាស;

ថ្នាក់ទី ២ លោកដែលបានសំរេចសកទាគាមិមគ្គនិងសកទាគាមិផល; លោកលះសំយោជនៈបាន ៣ យ៉ាង ដូចលោកដែលបាន

សំរេចសោតាបត្តិមគ្គនឹងសោតាបត្តិផលដែរ ប៉ុន្តែសំយោជនៈឯទៀតៗ លោកបានធ្វើឲ្យស្រាលស្តើងជាង, ទាំងរាគៈ ទោសៈ មោហៈ លោក ក៏បានធ្វើឲ្យខ្សោយទៅជាងសោតាបន្នបុគ្គល;

ថ្នាក់ទី ៣ លោកដែលបានសំរេចអនាគាមិមគ្គនឹងអនាគាមិផល; លោកលះសំយោជនៈ បាន ២ យ៉ាងថែមទៀត គឺកាមរាគៈ នឹងបដិឃៈ រួមជាសំយោជនៈ ៥;

ថ្នាក់ទី ៤ លោកដែលបានសំរេចអរហត្តមគ្គនឹងអរហត្តផល; លោក លះសំយោជនៈ បានទាំង ១០ គឺគ្មានសេសសល់ ។

ព្រះសង្ឃដែលរាប់ថាជាសង្ឃសរណៈក្នុងពីរនេះ សំដៅយកព្រះ សង្ឃទាំង ៤ ថ្នាក់ដែលសំដែងមកនេះ ។ លោកទាំងនេះជាតំណាងអង្គ សម្តេចព្រះបរមសាស្តា, សូម្បីព្រះសម្ពុទ្ធព្រះអង្គបរិនិព្វានទៅជាអង្វែង ហើយ ព្រះពុទ្ធសាសនាកាលកន្លងទៅបាន ២៤៩៩ វស្សាហើយ; ព្រះ ពុទ្ធសាសនាក៏បិតនៅបរិបូណ៌ ដោយព្រះសង្ឃយកចិត្តទុកដាក់ថែរក្សា បានប្រែប្រៃដៅពុទ្ធសាសនិកជនតៗមក រហូតមកដល់សម្តេចសង្ឃ ។ ក៏បានទទួលព្រះបន្ទូលព្រះពុទ្ធតាមនោះតមកទៀត ។ យើងរាល់គ្នាដែលកើត ជាន់ក្រោយ បានដឹងស្គាល់ព្រះពុទ្ធសាសនា ដែលជាសាសនាល្អឯកក្នុង លោក ជាសាសនាត្រឹមត្រូវបំផុតក្នុងលោក ដោយសារតែព្រះសង្ឃ ទាំងនោះ ។

ចំណែកគុណព្រះសង្ឃនោះលោកអាចារ្យទុកថា:

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជា

សាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយប្រពៃ គឺប្រតិបត្តិតាមគន្ធង៍ព្រះនព្វលោកុត្តរធម៌ ។

ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជា*សាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា ។*

ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជា*សាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីគ្រាស់ដឹងនូវព្រះនិព្វាន ។*

សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជា*សាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល, សមាធិ, បញ្ញា ។*

យទិទំ បត្តារិ បុរិសយុគានិ ព្រះសង្ឃណា បើពាប់ជាគូមាន ៤ គូ អដ្ឋ បុរិសបុគ្គលា បើពាប់រៀងជាបុរសបុគ្គលមាន ៨ ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនេះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ អាហុនេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលបូជាចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អែនចូលមកបូជា បាហុនេយ្យោ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិទីងមិត្រ ដែលមកអំពីទិសផ្សេង។ ហើយបង្អែនចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលផ្ទឿនូវកម្ម

ទំនឹងផលនៃកម្មហើយបូជា អញ្ជលិករណីយោ លោកគួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្បែលោកជាបុញ្ញក្ខេត្ត គឺជាទីដុះខ្នឹងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

លោកដែលបាននាមថាព្រះសង្ឃ គោរពខ្ពង់ខ្ពស់គុណសម្បត្តិដ៏អស្ចារ្យនេះ; ព្រះសង្ឃសាវ័កបស់ព្រះដ៏មានបុណ្យសុទ្ធតែខ្ពង់ខ្ពស់នូវគុណសម្បត្តិយ៉ាងនេះគ្រប់គ្រងអស់ ។ គុណរបស់ព្រះសង្ឃដែលសំដែងមកនេះ លោកពាប់ថាព្រះសង្ឃជាសរណៈរបស់សត្វលោក ។

សូមបញ្ចប់ធម្មទេសនា ដែលសំដែងអំពីសង្ឃសរណៈតែប៉ុណ្ណេះ ។

កាលបើចប់ហើយ ដោយអំណាចនៃធម្មទេសនានេះ សូមសេចក្តីសុខ-ចំរើន កើតមានដល់ប្រជាជនក្នុងដែនកម្ពុជាគ្រប់មូល កុំបីឃ្លៀងឃ្លាតឡើយ ។

ទាបកថារឿងពុទ្ធរូបបុរាណ

ឃុនអត្ថកោវិទ ជា-យ៉ូរ៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែជាភាសាខ្មែរថ្មី ដំណាំងសាសនា ឆ្នាំទី ១ ច្បាប់ទី ៦ ភាសាថៃ

(តមក)

ក្នុងសម័យវត្តនកោសិន្ធុ សម្តេចព្រះមហាសមណៈក្រុមព្រះបរមា-
ខុដតដែលជាសេចក្តីពិពន្ធតម្រាព្រះចាំង (តម្រាព្រះពុទ្ធរូបតាមសម័យ)
១ ដែរ, សម្តេចព្រះចូឡបមក្លៅចំយមហាពជ ទ្រង់និពន្ធតម្រាព្រះពុទ្ធ
ដ៏ពជវិទ្រតិស្ស្លោក, សម្តេចក្រុមពញាតទ្រង់ពជានុភាព ទ្រង់និពន្ធ
តម្រាច្រើនយ៉ាង តែដែលសំខាន់ជាងគេ គឺដំណាលព្រះពុទ្ធរូបសំខាន់
ទោលដោយព្រះពុទ្ធរូបសំខាន់ផ្សេង ។ ដែលមានទៅក្នុងអាណាចក្រថៃ
ពាំងអស់ ហើយតម្រាក្រាយបង្អស់ គឺដំណាលពុទ្ធចេតិយសព្វាម
តម្រាដែលប្រើជាគ្រឿងប្រកបក្នុងការសិក្សា ។ អំពីដើមតម្រានេះវាកបាន
ដោយតម្រណាស់ ហើយអ្នកដែលរួបរួមព្រះពុទ្ធរូប តំហៅឈ្មោះព្រះ
ពាំងនោះតាមអំពើចិត្តថា ព្រះខមខ្លះ ព្រះខ្មែរខ្លះ ព្រះឥណ្ឌាខ្លះ គេហៅ
មិនត្រឹមត្រូវ, តែតាំងអំពីមានតម្រាដំណាលពុទ្ធចេតិយឡើង ទើបគេហៅ
បានដោយត្រឹមត្រូវ ។ ព្រោះហេតុនោះ ការរៀនរឿងព្រះពុទ្ធរូប ទើបជា
ការគួរដ៏ត្រលែង ដូចពាក្យមន្ត្រីម្នាក់និយាយថាបាច់ចាំមែន ។ ក្នុងបណ្តា
អ្នកតែងតម្រា ដើម្បីធ្វើឲ្យការសិក្សាស្រួលឡើងនោះ សម្តេចព្រះចូឡបម
ក្លៅ បានទ្រង់ធ្វើការដ៏សំខាន់ ជាងអ្នកតែងតម្រាពាំងនោះ គឺការទ្រង់
កសាងវត្តបញ្ចមបពិត្រនេះជាព្រះអារាមហួងឡើង ក្នុង ព. ស. ២៤៤២

គេលុះដែលខ្ញុំសាងវិហារថ្មីរួចហើយ ក៏ខ្ញុំចាត់ឲ្យដំកល់ព្រះពុទ្ធរូបសម័យផ្សេង។ ដែលខ្ញុំស្វែងរកបានក្នុងអាណាចក្រថៃទឹងនានាប្រទេស ក្នុងវិហារនោះ ធ្វើជាពិពិធភ័ណ្ឌព្រះពុទ្ធរូបផ្សេង ។ តែកិច្ចការទាំងនេះជាព្រះរាជបំណង ដែលមានជាប់តមក តាំងអំពីព្រះបាទសម្តេចព្រះពុទ្ធយ៉ូតហ្វាចូឡាលោកគឺកាលខ្ញុំសាងព្រះវិហារស្រេចហើយក៏គ្រាសាងថែវដុំវិញសំពាប់ដំកល់ព្រះពុទ្ធរូបផ្សេង។ ដូចជាវត្តពោធិ៍ឬវត្តមហាធាតុ ដែលក្រុមព្រះរាជវង្សខ្ញុំសាង តែព្រះពុទ្ធរូបក្នុងថែវវិហារវត្តពោធិ៍នោះ ជាព្រះបុរាណនាំមកពីស្រុកលើខៅក្នុងរជ្ជកាលទី ១ តែបើព្រះអគ្គណាតូចមិនប៉ុនគ្នា គេយកកំភ្លោះបូកហើយលាបម្រក់ក្បាលបិទមាសឲ្យធំប៉ុនគ្នាឬទេ តែការធ្វើដូច្នោះដោការលុបក្បាច់ក្បួនចំថ្លៃដាងបុរាណ ជាការខូចដល់ការសិក្សា ព្រោះដូច្នោះយើងខ្ញុំឃើញថាព្រះពុទ្ធរូបក្នុងថែវវិហារវត្តពោធិ៍នោះ ជាព្រះប៉ាន់ដោយកំភ្លោះក្នុងសម័យតមកោសិ៍ខ្ញុំទាំងអស់ តែដែលពិតនោះជាព្រះលោហៈមិនព្រះសិទ្ធ ដែលយកពីខែត្រក្រៅមកទាំងអស់ ហើយយកមកលាបម្រក់ក្បាលបិទមាសជាថ្មី ។ កាលសម្តេចចូឡាលង្កាទេវមក្តៅខ្ញុំសាងវត្តឋមបពិត្រនោះ ដោយខ្ញុំប្តូរថ្នាក់ធ្វើឲ្យល្អវិសេសជាងគេ ឲ្យជាស្ថានដែលសម្រាប់សិក្សាយ៉ាងពិតប្រាកដ ទើបខ្ញុំឲ្យធ្វើព្រះខាត់ (គឺព្រះពុទ្ធរូបដែលសិទ្ធដោយខ្ញុំដែងជាដើម តែកាលណាមានពំណាំស្រអាប់គេយកថ្នាំមកជុសខាត់ឲ្យមានពន្លឺភ្លឺផ្លេកឡើងវិញ) ដំកល់ទុកមិនបាច់លាបម្រក់ក្បាលបិទមាស ព្រោះព្រះខាត់មានពន្លឺភ្លឺល្អស្រេចហើយ តែជាការ

ពាក្យដែរ បើជាធាតុមិនច្រេសបាត់ និងនាគឲ្យខូច ដូចព្រះពុទ្ធរូប
មានព្រះកន្ត្រកូលាយ ក៏នាគតាលតែមានចង្កានោះស្រួច ឬចង្កាវិលរេច
រៀតតូចទៅ ចួនកាលព្រះពុទ្ធរូបដែលគ្មានដើងព្រះកេស គេក៏នាគតាល
តែមានដើងព្រះកេសឡើង, ដែលធ្វើដូច្នេះជាហេតុឲ្យរលុបគន្ធងជង
ជាន ជាការខំទាស់កន្លងការសិក្សា ។ ដើម្បីមិនឲ្យទាស់ខុសកន្លងការសិក្សា
យើងត្រូវតែកុំខាត់ ព្រោះតាមរឿងដែលពាត៌ព្រះពុទ្ធរូបកន្លងសម័យនីមួយ។
គេធ្លើផ្សេង។ ពីគ្នា ។ នៅកន្លងពាក្យពណ៌ព្រះពុទ្ធរូបរបស់សម្តេចព្រះ
ចុឡចមក្លៅ មានព្រះពុទ្ធរូបគ្រប់ត្រកូលជាង់ដែលមានមកកន្លងលោកដូច
ព្រះពុទ្ធរូបធ្លើទុក្ខកកិយោ មានព្រះអង្គស្តុមនោះ ជាព្រះសម័យគន្ធាររដ្ឋ
ព្រះសម័យអមរាវតី គឺជាព្រះលង្កាចាស់ធ្លើពីថ្មស មានចំពារជ្រួញ
អង្កាញ់។ ដំកល់ទុកនៅរបៀងបែកខាងលិចជាន់ខាងក្រៅ ១ អង្គ, ១ អង្គ
ទៀតជាព្រះលោហៈ សិទ្ធពីកព្រះពុទ្ធរូបអមរាវតី របស់សម្តេចក្រុម
ពញាតម្រង់ជាទុកាពនៅកន្លងពាក្យពណ៌ស្ពាន ដំកល់ទុកក្បែរព្រះពុទ្ធរូប
ស្តុមនោះ, ដល់មកសម័យគុប្ត: គេសិទ្ធពីកព្រះពុទ្ធរូបដែលពាត៌នៅ
កន្លងពាក្យពណ៌ស្ពាន ដំកល់ទុកកន្លងរបៀងខាងដើងបំផុតបែកខាងកើត ។
នៅកន្លែងនោះមានព្រះពុទ្ធរូបគ្នារាវតី គេដំកល់ទុកនៅរបៀងខាងក្រៅ
បែកខាងត្បូង ១ អង្គ នៅជ្រងខាងលិច ១ អង្គ ធ្លើដោយថ្មខៀវ នៅខាង
កន្លងមានព្រះពុទ្ធរូបគង់ពត់ព្រះក្បែនសម័យគ្នារាវតី តែមិនមែនជាព្រះជាន់
ដើមទេ ជាព្រះដែលសិទ្ធពីកអំពីអង្គគួច។ របស់សម្តេចក្រុមពញា
តម្រង់ជាទុកាព ដែលនៅកន្លងពាក្យពណ៌; ព្រះសម័យស្រីវិជ័យក៏មាន

១ អង្គដែរ នៅក្នុងសាលាមួយឈ្មោះ តែឥឡូវនេះគេយកទៅខ្ទុកទៅ
ពីពីឆកណ្តាលស្ពានទៅហើយ ។ កាលខាងដើមរដ្ឋការទី ៧ តាំ
សម័យស្រីវិជ័យមក ក៏មកដល់សម័យលពបុរី មានព្រះច្រើនអង្គទៀត
អង្គដែលនៅក្នុងសុមត្តារគ្រាយព្រះវិហារនេះ ក៏ចំពួកព្រះសម័យលពបុរី
ដែរ ។ តាំលពបុរី ក៏មកដល់ព្រះពុទ្ធរូបសម័យជៀងសែន មានច្រើនអង្គ
ក្នុងរបៀងវិហារនេះ ។ តាំជៀងសែនក៏ដល់សម័យសុខោទៃយ៍ (សុខោ
ថៃ) គឺព្រះពុទ្ធរូបលីលា ដូចជាព្រះ ១ គូ នេះ ជាអង្គដ៏ធំហើយមាន
គ្រាយស្អាតស្អាងស ។ តាំសុខោទៃយ៍មក ក៏មកដល់ព្រះសម័យអយុធ្យា
មានតាំងអយុធ្យាជាន់ដំបូង គឺសម័យអ៊ូថង ទីឯអយុធ្យាជាន់គ្រាយគឺ
អយុធ្យាធម្មតា ។ ក្រៅពីព្រះដែលបានប្រទះឃើញនៅអាណាចក្រថៃ
ទីឯព្រះដែលជាដើមឡើមកពីឥណ្ឌាហើយ ក៏នៅមានព្រះដែលមកពី
ប្រទេសផ្សេងៗទៀត ដូចជាព្រះដប៉ុន ព្រះចិន ព្រះកូមា ក៏មាននៅក្នុង
កន្លែងនេះដែរបូណា ។ ព្រោះហេតុនោះពាក្យពិតណាស់ព្រះពុទ្ធរូបរបស់សម្តេច
ព្រះបូរ្ណចមក្តៅ យើញថាឲ្យប្រយោជន៍ច្រានយ៉ាងពិតប្រាកដមែនដល់
អ្នកសិក្សាលក្ខណៈព្រះពុទ្ធរូបបុរាណ ។ ព្រះពុទ្ធរូបបុរាណនោះយើង
រៀនត្រឹមតែថ្នាក់បរិយត្តិ តែរៀនត្រឹមតែមើលតម្រាប៉ុណ្ណោះមិនទាន់គ្រប់
គ្រាន់ទេ ត្រូវរៀនឲ្យដល់ថ្នាក់ប្រតិបត្តិ គឺពិចារណារូបលក្ខណៈឲ្យ
យើញពិតប្រាកដ ដូចលោកដែលមើលពិពិធកណ្តាលព្រះពុទ្ធរូបគ្រប់ៗគ្នា
លោកត្រូវយកចិត្តទុកដាក់មើលឲ្យដឹងថា ជាព្រះសម័យណា មានលក្ខណៈ

ដូកម្តេចជាត្រឿងសង្កេត ហើយម៉េចមានលក្ខណៈច្រើនសម័យមកច្រកបគ្នា ក៏ជាបញ្ហាឲ្យដាវដែកគ្នាបានយ៉ាងសប្បាយ ។

ខ្ញុំពោលមកខាងនេះ ដើម្បីទីឆ្លងសំដែងឲ្យឃើញថា ព្រះពុទ្ធរូបរបស់យើងគួរយើងសិក្សា ព្រោះយើងជាពុទ្ធមាមកជន (អ្នកពាក់អាន ព្រះពុទ្ធសាសនា) គួរសិក្សារឿងព្រះពុទ្ធឲ្យចេះដឹងខ្លះទើបជាការគួរ តែដោយច្រើនគេមិនសូវយកចិត្តទុកដាក់សោះ បើមានពួកនានាជាតិគេមកសួរ យើងទំនងប្រាប់គេឲ្យដឹងរឿងក៏វាខ្លះមិនបាន សូម្បីតែកូនពួកអ្នកសិក្សាទៀត ក៏មិនមានអ្នកចេះប៉ុន្មាន ព្រោះដូច្នោះការដែលពុទ្ធ-សមាគមប្រចេសថៃ ចាត់ឲ្យមានការបែឡងព្រះពុទ្ធរូបឡើងក្តី សម្តេចព្រះបូរមប្រកៀងទំនងពិពិធកំណាព្រះពុទ្ធរូបឡើង ជិត ៥០ ឆ្នាំមកហើយក្តី បានធ្វើឲ្យបណ្តាជនដែលមកទស្សនា ធ្វើទុកកំចិត្តខាល់តែចូលចិត្ត ហើយបែរមកសិក្សាលក្ខណៈព្រះពុទ្ធរូបជាច្រើន ត្រូវតាមព្រះពាជបំណង នឹងត្រូវតាមបំណងនៃពុទ្ធសមាគម ដែលបានចាត់ឲ្យមានបែឡងកន្លងមកនេះ ។

ខ្ញុំពោលមកខាងនេះជារឿងបកស្មាក់ច្រើនណាស់ ឥឡូវនេះនឹងបែរមកពោលដល់រឿងដែលនាំឲ្យកើតមានព្រះពុទ្ធរូបតទៅ :

រឿងព្រះពុទ្ធរូបបុពណ្ណោះ យើងបានសិក្សាសៀវភៅ ๑ ហៅថា "សៀវភៅដំណាលព្រះឱមថន្ទ" តាមសៀវភៅនោះពោលថា :

"កន្លងកាលដែលព្រះសម្មាសម្ពុទ្ធ ស្តេចទៅគង់ចាំវស្សានៅឯស្ថានតាវត្តឹង្ស ដើម្បីទេសនាទូព្រះអភិធម្មប្រោសព្រះពុទ្ធមាតា, ព្រះបាទ

បសេនទិកោសលទ្រង់មានព្រះទ័យរលឹកព្រះពុទ្ធអង្គជាខ្លាំង ព្រោះទ្រង់ធ្លាប់បានចូលទៅគាល់ជាញឹកញយ ទើបទ្រង់ព្រះបញ្ជាពួកជាងឲ្យយកឈើខ្នុរមួយដុនមកធ្វាក់ធ្វើជាព្រះពុទ្ធរូបដ៏គួរគប់ទុកធ្វើសក្ការៈបូជា ទំរាំដល់ពេលចេញវស្សា ព្រះពុទ្ធអង្គនឹងស្តេចត្រឡប់មកវិញ ។ លុះដល់ចេញវស្សាហើយ ព្រះដ៏មានព្រះភាគក៏ទ្រង់យាងត្រឡប់ចុះមកវិញ ហើយទ្រង់ពុទ្ធដំណើរមកកាន់ក្រុងកោសល ព្រះខ្នុរមួយដុននោះក៏រំកិលចុះមកពីលើពុទ្ធាសនៈ ព្រះពុទ្ធអង្គទ្រង់គ្រាស់ឲ្យដាក់ព្រះពុទ្ធរូបនោះទុក ។ តាមតម្រានេះសំដែងថា ព្រះពុទ្ធរូបនោះកើតមានឡើង តាំងពីកាលព្រះពុទ្ធអង្គទ្រង់ព្រះដន្មនៅឡើយ ហើយជាព្រះបរមពុទ្ធានុញ្ញាតផង យើងរឿមកដូច្នេះអស់កាលជាយូរអង្វែងណាស់មកហើយ តាំងរឿថាព្រះពុទ្ធរូបនោះមានរូបរាងដូចព្រះពុទ្ធអង្គ ព្រោះហេតុថាគេបានសាងចំឡងពីព្រះរូបព្រះដ៏មានព្រះភាគយ៉ាងពិតប្រាកដ តែបើតាមរឿងដែលពិតនោះមិនមែនដូច្នោះទេ ព្រោះគេបានដើរតាមនិត្យវត្តស្ថាន ដែលចាក់ទងដោយព្រះពុទ្ធសាសនាតាមត្រាំងការដ៏ធំនៅអាណាចក្រឥណ្ឌូ បានសេចក្តីថា កុងកាលដែលព្រះពុទ្ធអង្គទ្រង់ព្រះដន្មនៅ មិនដែលមានព្រះពុទ្ធរូបសោះឡើយ សូម្បីព្រះពុទ្ធសាសនាកន្ទុងមកជិតដល់ ៤០០ ឆ្នាំ ក៏នៅតែគ្មានព្រះពុទ្ធរូប ។ បូជនីយដ្ឋានដែលព្រះចាទអសោកមហាពជាពុទ្ធសាសនូបត្ថម្ភក៍ ១ អង្គដ៏សំខាន់ក្រៃលែង បានទ្រង់សាងទុកគ្រប់កន្លែង ក៏សុទ្ធតែគ្មានព្រះពុទ្ធរូបដែរ ។ តាមដែលពិតនោះ ព្រះចាទអសោកមហាពជ បានទ្រង់ធ្វើការគ្រប់យ៉ាង ដែលរាប់ថាជាបុណ្យ

កុសលក្នុងព្រះពុទ្ធសាសនា កាប់តាំងពីខ្ញុំឲ្យធ្វើសង្គាយនាព្រះធម៌
វិន័យ, បញ្ជូនព្រះសង្ឃឲ្យទៅប្រកាសព្រះពុទ្ធសាសនាក្នុងនាទាប្រទេស,
សាងស្តូបចេតីយច្រើនបួនខាន់ សាងរូបតែគប់កន្លែងទៅប្រទេស
ឥណ្ឌា បញ្ជូនព្រះមានុទៅបញ្ចុះក្នុងទីផ្សេង ។ តែស្តូបដែលសំខាន់ទី
បំផុត គឺសញ្ចិស្តូបទៅស្រុកសញ្ចិ ដែលព្រះបាទអសោកខ្ញុំសាង
ខ្សែនតាំងពីខ្ញុំទៅជាព្រះអគ្គមាស់, ទៅអគ្គីព្រះស្តូបនោះគេធ្លាក់ជា
រឿងពុទ្ធប្រវត្តិ តែមិនឃើញមានព្រះពុទ្ធរូបសោះឡើយ ។ ទាំងនេះ
កំព្រាក្នុងប្រទេសឥណ្ឌា គេប្រកាន់ជាច្រើនខាន់ឆ្ងាមកបើយថា មិន
គួរសាងរូបដែលជាទីគោរពទុកទេ ។ ព្រោះដូច្នោះទៅកន្លែងត្រង់ណា
ដែលគេចង់ឲ្យយើងបួលចិត្តថាមានរូបព្រះពុទ្ធអង្គ គេសាងរូបជាថៃជំនួស
គឺរូបប្រៀបសម្គាល់ឲ្យដឹងថាមានព្រះពុទ្ធអង្គដែរ ដូចក្នុងកាលដែលស្តេច
ចេញចេញផ្សងគេធ្វើរូបសេះមានតែកែបទេ មិនមានមនុស្សជិះ ឬបួន
កាលធ្វើជាតន្ទុងព្រះបាទ, ក្នុងកាលគ្រាស់ដើង គេធ្វើជាជង្គង់ក្រាមឈើម
ពោធិព្រឹក្ស, កាលចេញបរិនិព្វាន គេធ្វើជារូបស្តូបទៅទីនោះ ។

ចំណែរមកដល់ពាក្យសុង្គ:បានគ្រប់គ្រងប្រទេសឥណ្ឌា ក៏បាន
ជួសជុលព្រះស្តូបនេះជាការធំមាំមួន តែក៏មិនបានសាងព្រះពុទ្ធរូបដែរ ទី
ត្រង់ណាដែលគួរមានព្រះពុទ្ធរូបគេសាងតែជថៃជំនួសគប់កន្លែង, ចំណែរ
តមកជាន់ក្រោយទៀត ទើបគេបានប្រទះឃើញព្រះពុទ្ធរូបនៅក្រុងគន្ធារៈ
ជាស្នាដៃជាងក្រិកសាង មិនមែនស្នាដៃពួកឥណ្ឌា ទាំងមិនមែនតំនិត
ពួកឥណ្ឌាដែរ ។

(មានត)

រឿងអ្នកស្នេហាជាតិ សាសនា មហាក្សត្រ

ឃុនបណ្ឌាន៉ុក្ស ប៊ូ-ប៊ូ ស្រង់ចាកតម្រាផ្សេង ។

(ត-ចប់)

ចំណែកព្រះស្តេចកន ជ្រាបសេចក្តីក្នុងសំបុត្រដែលទុកញ៉ាកែវ ជូលមកនោះហើយ ក៏គ្រាស់បង្គាប់ឲ្យទុកញ៉ាចក្រី ចេញទៅកេណ្ឌពលខែត្រខាងលិចជាយ៉ាងប្រញាប់ឲ្យទាន់គារ លើកទៅកាំងផ្លូវនៅខែត្រលង្វែក, ឲ្យចៅហ្វាក្រៅលើកទៅខាងផ្លូវកំពង់សៀមទៅជួយទុកញ៉ា-ចក្រី ។ ចៅហ្វាក្រៅ លើកទៅដល់ខែត្រកំពង់សៀមបានជួបទ័ពទុកញ៉ាទ័យធិពជ្រដុំកងទ័ពទាំង ២ លើកទៅដល់ខែត្រត្រែង ទៅជួបប្រទះទ័ពទុកញ៉ាសួគាំលោកមៀង ។

ពេលនោះ ទុកញ៉ាមៀង ឃើញទ័ពគេលើកមកដល់មានវេហ៍ពលច្រើន ក៏ចាត់កូនច្បងឲ្យធ្វើជាមេទ័ពកាន់ពល ២ ពាន់ ចេញច្បាំងនឹងទ័ពទុកញ៉ាទ័យធិពជ។ ស្មាប់កងសង្គ្រាម ។ កូនច្បងទុកញ៉ាមៀងដឹងថាពលខ្លួនតិច ទឹងតែគាំពុំបានក៏ទាំពលដោះថយមកប្រាប់បិតាឲ្យថយទ័ពទៅខែត្រពោធិសាត់វិញ ។ ឯទុកញ៉ាចក្រីនឹងចៅហ្វាក្រៅ ដឹងថា ទុកញ៉ាទ័យធិពជស្មាប់ហើយ ក៏លើកទ័ពតាមទៅចាមព័ទ្ធបន្ទាយទុកញ៉ាមៀងនៅខែត្រពោធិសាត់គ្រប់ទិសទាំងបួន ។

គ្រានោះ ឧកញ៉ា មឿង ក្រាបទូលព្រះបន្ទូលជាថាទ័ពគេលើកមកច្រើនណាស់ ។ ខ្ញុំប្រកាន់ធឹងមេទ័ពចាំងអស់ថា យើងនឹងគិតឆ្លើយដូចម្តេចឲ្យបានរួចពីចំណោមគេ ។ ទើបឧកញ៉ាសួគាំលោកមឿងក្រាបទូលថា "បើយើងនឹងគិតរកយុទ្ធលាយចេញទៅ ពលយើងតិចណាស់ ពលគេមានច្រើនជាង បើទុកជាចេញរួច ក៏គង់តែស្លាប់ចាំងសងខាង ទូលព្រះបង្គំជាខ្ញុំគិតឃើញគំនិតមួយ សុំទូលអាសាទៅកេណ្ឌកងទ័ពបំសាចមកជួយវាយ យល់ជានឹងឈ្នះគេបានងាយណាស់, សូមខ្ញុំឲ្យដីតរណ្តៅទៅកណ្តាលទីនេះ ជាធាប់នឹងបានគិតការថ្វាយ" ។

ព្រះបន្ទូលជាខ្ញុំគ្រវីព្រះសិរហើយត្រាស់ថា "តាំងពីបុពណរៀងមក មិនដែលឮថាយកភ្នោចមកជួយច្បាំងដល់ម្តង តាលែងគិតគំនិតនេះចេញទៅ" ។ ឧកញ៉ាមឿងក្រាបទូលថា "បើខ្ញុំពុំព្រមអនុញ្ញាតទេ ទូលព្រះបង្គំជាខ្ញុំនឹងអារកឲ្យស្លាប់នៅទីនេះ" ទូលហើយក៏ចាប់អាវុធអារក ។ ព្រះមហាក្សត្រទតឃើញសុះទៅចាប់ដាវជាប់ ខ្ញុំត្រាស់អង្វរថា "តាកុំសម្លាប់ខ្ញុំនឡើយ បើតាគិតឃើញដូចម្តេច ចូរធ្វើតាមគំនិតតាចុះ" ។ ឧកញ៉ាមឿងបានឮត្រេកអរណាស់ ថ្វាយបង្គំលាមកគ្រៀ បង្គាប់ឲ្យមនុស្សដីតរណ្តៅយ៉ាងជ្រៅ ជាក់គ្រឿងអាវុធទៅចាំតរណ្តៅជាច្រើន ហើយរៀបតាំងពលិការគាំង៨ទិស រួចប្រដុកងទ័ពមកដួចជុំស្រែច ទើបឆ្លូតទឹកដម្រែកាយឲ្យស្អាតស្អំ លើកកជណម្យនមស្ការដល់គុណព្រះរតនត្រ័យទឹងទេវតា តាំងសច្ចាធិដ្ឋានថា "សូមជួយព្រះមហាក្សត្រកំចាត់អស់សត្រូវ" ក៏ឈរឡើងស្រែកប្រកាសថា "អស់អ្នកទាំងពួងចូរត្រួត

គ្នាធ្វើការឲ្យមាំមួនថ្វាយ កុំកោតញញើតអាក្បាច់ឡើយ យើងលាអ្នក ទាំងពួងទៅកេណ្ឌពលបិសាច មកជួយឲ្យទាន់ការក្នុងវេលាយប់នេះមិនខាន" ថារួចលោតចុះទៅកន្លែងណាត្រូវនឹងគ្រឿងអាវុធស្លាប់ក្នុងវេលាយប់នោះទៅ ។ ឯកូនច្បងទី ២-៣ ឃើញបិតាលោតទៅហើយ ទឹកក្នុងចិត្តថា "បិតាទៅកេណ្ឌកងទ័ពបិសាចជាការធំ ពុំមានអ្នកឯណាទៅជាគំនរ ក្រែងក្រគ្មានអ្នកណាជួយ យើងជាកូនគួរតាមបិតាយកអាសាម្ចាស់ផែនដីទើបគួរ" គិតព្រមគ្នារួចស្រេច ក៏អារកក្ស័យដំរីតាំង ២ នាក់ ។ ឯកូនច្បងនឹងកូនពៅស៊ុះទៅនឹងសម្លាប់ខ្លួនឯង មេទ័ពព្រួតគ្នាចាប់ជាប់មិនឲ្យទៅបាន ហើយគោះគងខ្លួងស្គរ តាំងហៅលាប់ដកប់ខ្មោចតាំង ៣ ពួនជាផរសន្ទតហៅថា អ្នកតាឃ្លាំងមើង តាមបណ្តាំគាត់ ស្រេចហើយនាំគ្នាទៅគាបចូលស្តេច ។ ខ្ញុំជាបក៏ស្តុតព្រះទ័យ ខ្ញុំព្រះកន្ទែងសោកស្តាយពន់ប្រមាណ ទើបគ្រាស់ឲ្យនិមន្តព្រះសង្ឃសូត្រសត្តប្បករណ៍ ហើយខ្ញុំជ្រាបប្រណីកូនច្បងរបស់ខុកញ៉ាមឿងឲ្យធ្វើជាខុកញ៉ាសុគាលោកដូសបិតា ឲ្យកូនពៅធ្វើជាខុកញ៉ាសេនាធិបតីចៅហ្វាយស្រុកវៃតអមរៈគិរីទ្វបុរណិ ជាមេទ័ពរក្សាប៉មបន្ទាយក្នុងវេលាយប់នោះ ។

លុះដល់ព្រឹកឡើង ព្រះពជាឲ្យត្រួតត្រាមើលរបៀបពលទឹងលើកទៅលុកសត្រូវទៅវេលាយប់, ពេលនោះមានហ្វូងដំរីម្ខាក់ៗដំរីសឈ្មោល ១ រូបល្អបរិសុទ្ធកំពស់ ៦ ហត្ថមកថ្វាយ, ខ្ញុំព្រះពជានាមដំរីនោះហៅ

ថា ព្រះពិជ័យកុញ្ជរ ជាព្រះទីនាំងគន់, ហ្នាំរីនោះទ្រង់តាំងឲ្យធ្វើជា
ទៅហ្វាយស្រុកខែត្រកែង រួចយាងចេញទៅមុខព្រះពន្លា ។ រាស្ត្រ
ប្រជានាំដំរីសេះមកថ្វាយ អ្នកខ្លះបាន ១ អ្នកខ្លះបាន ២ រួមបានដំរី ៣៥
សេះ ៣០ ទ្រង់ត្រេកអរណាស់ ក្រោសព្រះពជគាខយសសក្តិឲ្យធ្វើជា
មន្ត្រីតាមសមគួរគ្រប់ខ្នួន ។

ព្រះបន្ទូរជាទ្រង់ចែកទំពាជា ៤ កង ឲ្យទុកញ៉ាសេនាធិបតីជាទំពាមុខ
ឲ្យទុកញ៉ាសួគ៌ាលោកជាមេទំពាឃុំពល ៥ ពាន់ ទៅលុកទំពាទុកញ៉ាបក្រី,
ព្រះអង្គទ្រង់ពល ១ ហ្មឺនជាទំពាហ្លួងលើកទៅក្រយទៅហ្វាំកៅ ព្រះយស
រាជានីធ ព្រះកិរៀងឃុំពល ៣ ពាន់ទៅរក្សាបន្ទាយក្នងយប់នោះ ។ លុះ
ទ្រង់រៀបចំស្រេច ដល់ពាក់កណ្តាលអធ្រាត្រ ទ្រង់អុជទៀនធូបក្តាំធ្វើ
សក្ការបូជា ទ្រង់អធិដ្ឋានទឹករំលឹកគុណព្រះរតនត្រ័យនិងឥន្ទ្រព្រហ្មទេវតា
ដែលមានបុណ្យស័ក្តិសំខ្ចីនឹងអ្នកតាយ៉ាងមឿង សុំឲ្យមានតេជះជោគជ័យ
លុះទ្រង់តាំងអធិដ្ឋានរួចស្រេចហើយ ទ្រង់ឡើងគន់ព្រះទីនាំងគជន្ធូស
ឈប់ចាំបុក្ខរោ កំស្រាប់តែឮសូរសន្ធឹកគ្រាមដែនដីព្រមទាំងវាលស្រែក
ហោសូរសព្ទកគ្រើកកំពើកដែនដី ទ្រង់ឮបន្ទរស្ទាំងមេទំពាសេនាទីករ
ក៏ឮបន្ទរស្ទាល់គ្នា ទើបទ្រង់ឲ្យគោះគន់ខ្ចង់ស្គរវេហ៍ពលតាំងហោ
ទ្រង់លើកទំពាចេញទាំង ៤ កងតម្រង់ទៅក្រយបន្ទាយសត្រូវ ។

ចំណែកទៅហ្វាំកៅនឹងទុកញ៉ាបក្រីដឹងហើយ ក៏តឿនពលឲ្យចូល
ច្បាំង ។ វេលានោះ ដូចជាមានទាំងទំពាមកព័ទ្ធព័ត្រាយឮសូរសៀមក
ស្រែកហោជាខ្លាំង សេនាគហានទាំងទំពាសត្រូវពលសេះដំរីផ្លែលចោល

ជាន់ គ្នារត់យកតែជីវិតរៀងខ្លួន ។ ទុកញ៉ាសូគាលោកដេញទ័ពសត្រូវទៅ
ដល់ទុកញ៉ាចក្រីៗបរដំរីចូលប្រជល់គ្នា តែតុំខាន់ចាប់ប្រជល់ ស្រាប់តែ
ដំរីទុកញ៉ាចក្រីផ្តើល គេចរត់ជួចជាគេចាប់គ្រាត់ធ្លាក់ទុកញ៉ាចក្រីទៅលើ
ក្បូកដំរីនៃទុកញ៉ាសូគាលោក។ ទទួលចាក់ទុកញ៉ាចក្រីស្លាប់ ហើយកាត់
យកក្បាលនាំមកថ្វាយព្រះរាជា។ ឲ្យដោតក្បាលអាក្បាថទៅពីខោះ លុះ
ព្រឹកឡើងចាប់បានគោក្របីដំរីសេះជាវគាំក្តើងអាវុធផ្សេង។ ទឹងស្បៀង
អាហារជាច្រើន ។ ព្រះបន្ទូលជាបានចម្បាំងឈ្នះទ័ពសត្រូវក្នុងគ្រានេះ
រហូតដល់ពីរដងទៀតចម្បាំងឈ្នះទ័ពព្រះស្តេចកនរៀត ទើបបានសោយ
រាជសម្បត្តិគង់នៅព្រះបរមរាជវាំងលវែងជាសុខរៀងមក ។

អស្រ័យមានរឿងនេះហើយ បានជាអ្នកស្រុកតោធិសាត់តែងនាំគ្នា
ធ្វើបុណ្យឡើងអ្នកតាឃ្លាំងមឿងរៀងរាល់ឆ្នាំ ក្នុង ១ ឆ្នាំធ្វើម្តង ជាប់ជា
ទំនៀមទម្លាប់ត ។ គ្នាមក ដើម្បីនឹកលើកគុណទុកញ៉ាសូគាលោកទៅ-
ហ្វាយស្រុកតោធិសាត់ ដែលជាអ្នកសូប្បុរជិវិតទឹងព្រះមហាក្សត្រ ។

*
* *

៤ — រឿងអ្នកសូប្បុរជីវិតជួយសង្គ្រោះគេ

រឿងទាហាន ហ៊ាន (១)

កាលពីព្រេងនាយ មានស្តេចម្នាក់ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ។
នាងនេះស្រឡាញ់បានខាំង ១២ ជាទីបំផុតចិត្ត ។ ថ្ងៃមួយ មានឡុំស្រី

---

១ រឿងនេះខ្ញុំសរសេរតាមពាក្យលោកហង់-តិមសេង កាលធ្វើភូឈួយទី ២ នៃព្រះសាសន-
បណ្ឌិត្យបានដំណាលប្រាប់ខ្ញុំ ។

ម្នាក់ធ្វើឲ្យបែកចាននោះមួយ ។ ស្រីជាម្ចាស់ចានខឹងណាស់យកកាំភ្លើងបាញ់ខ្ញុំស្រីនោះស្លាប់មួយរំពេចទៅ ។

លុះនោះ មានភាហានម្នាក់ឈ្មោះ ហាន ចានដឹងរឿងនោះ ហើយក៏កាត់ចិត្តប្រថុយស្លាប់ចូលទៅនិយាយនឹងស្រីជាម្ចាស់ចានថា "សូមជំពាក់អ្នកស្រី ខ្ញុំជាអ្នកចេះជ្យាចានដែលបែកហើយឲ្យជាប់គ្នាដូចដើមវិញបាន ខ្ញុំនឹងជ្យាចានដែលបែកនោះជូន ប៉ុន្តែខ្ញុំសុំចានតាំង ១១ ដែលនៅល្អមកមើលសិន ដើម្បីខ្ញុំនឹងធ្វើចានបែកនោះ ឲ្យជាប់ដិតស្និទ្ធដូចចានដែលនៅសល់តាំងអស់" ។ ស្រីម្ចាស់ចានឮដូច្នោះមានចិត្តត្រេកអរណាស់ ក៏ទៅលើកយកចានតាំង ១១ មកហុចឲ្យភាហានៗទទួលយកចានតាំង ១១ នោះបានមកហើយ ក៏លើកបោកបែកខ្លះតាំងអស់ទៅនៅមុខនាងម្ចាស់ចាន ហើយប្រាប់ថា "សូមអ្នកស្រីយកកាំភ្លើងមកបាញ់សម្លាប់ខ្ញុំចុះ ត្បិតថាបែកចាន ១ អ្នកស្រីសម្លាប់ជីវិតមនុស្សម្នាក់ នៅសល់ចាន ១១ មុខជាអ្នកស្រីសម្លាប់ជីវិតមនុស្សអស់ ១១ នាក់ទៀត ហេតុនេះខ្ញុំសុខចិត្តយកជីវិតខ្ញុំមកស្លាប់ជួសជីវិតមនុស្សតាំង ១១ នាក់នោះ ។

ស្រីម្ចាស់ចានឮដូច្នោះ ក៏ស្ងុតស្ងាំងកាំងកាំងស្មារតីជួលសន្ធប់ទៅលុះដឹងខ្លួនឡើងហើយប្រាប់ភាហានថា "ខ្ញុំខឹងខុសហួសទៅហើយពីកាលមុន ឥឡូវនេះខ្ញុំមិនខឹងនឹងអ្នកទេ ព្រោះអ្នកជាប់ចិត្តយកជីវិតខ្លួនមកស្លាប់ជួសគេ ដោយសារតែចង់ជួយសង្គ្រោះគេ ហេតុនេះខ្ញុំអរគុណអ្នកណាស់ សូមអ្នកអញ្ជើញទៅវិញចុះ" ។

ចប់

រឿងព្រះចាន្ទវុសភ័ន្តសាដ

និង

ព្រះចាន្ទសេហវិស្ដាន៏

អ្នកស្រីពេជ្រ–សល់ ហៅ សារិះយ៉ាំង ប្រែរៀបរៀង

(តមក)

ថ្ងៃមួយ នៅពេលដែលពួកនាម៉ឺនត្រឹមខ្នះត្រឹមបែគ្រា ចាំគាល់ព្រះមហាក្សត្រនៅពេធ៌ដំទុំ ស្រាប់តែនាម៉ឺនហ្វូងជ្រាបថា មិនដឹងជាស្ដេចយាងទៅឯណាបាត់ ព្រោះតាំងថ្ងៃម្សិលកន្លងពេលល្ងាចព្រះអង្គផ្ទំនៅលើព្រះទែន ប៉ុន្តែឥឡូវនេះ ព្រះអង្គមិនដឹងជាស្ដេចយាងទៅទីណា ឃើងរកពេញក្នុងព្រះបរមភជាំងហើយមិនឃើញសោះ ។ ប៉ុន្មានថ្ងៃក្រោយមកក៏នៅតែរកព្រះមហាក្សត្រមិនឃើញទៀត ពួកចៅដែនចៅបមម៉មម៉ែនាងក៏នាំគ្នាលាបមុខលឿង ឃកផ្ការុឡាបទៅបាបសាបពាសពេញមុខស្ងួតប្ដូគ្រែ ហើយនាំគ្នាយំសោកស្ដាយតែពាល់រូប ។

កងចំណោមអ្នកទាំងនោះ លោកមុយអេស៊ីនសោកសង្រែងជាងគេ ព្រោះមិនដឹងជាម្ចាស់ខ្លួនទទួលទុក្ខឬសុខយ៉ាងម្ដេច លោកយំរៀបរាប់ថា ៖

– ខ្ញុំ ! ព្រះមហាក្សត្រ តើព្រះអង្គស្ដេចយាងទៅណា ? ម្ដេចបានជាស្រាប់តែបាត់សូន្យឈឹង ? ឬមួយព្រះអង្គចង់យាងទៅដោយព្រះទ័យព្រះអង្គទេ ? ទេ ប្រាកដជាមិនមែនដូច្នេះទេ ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថាយើងទាំងអស់គ្នាស្រឡាញ់ព្រះអង្គណាស់ ម្ដេចក៏ព្រះអង្គ

ធ្វើឲ្យយើងកើតទុក្ខដូច្នេះ, ប្រសែហើលជាអំពើបស់ពួកធ្មប់ខ្មែដឹង ដែល
លួចលាក់ព្រះអង្គនេះ ។

ពាក្យលោកមុយអេស៊ីនខាងក្រោយនេះ ហាក់ដូចជាមើលឃើញ
ព្រោះព្រះនាងសេហេរិស្តាន៍ ដែលទៅតាំងកោះសេហេរិស្តាន៍បានប្រែ
បំរែឲ្យមកនាំព្រះអង្គចេញពីព្រះបរមរាជវាំងទៅ ។ ព្រះមហាក្សត្រ
កំពុងតែសម្លេយរកអ្វីប្រៀបគ្មាន ឯពួកនាម៉ឺនទៅកន្លែងព្រះនគរតិតតែនាំ
គ្នាយំទៅវិញ ។

ទៅពេលដំបូងដែលព្រះនាងឡើងគ្រងរាជ្យស្នងព្រះបិតា ព្រះនាង
វៃលំតែការផែនដី ។ ក្រោយមក ដោយព្រះនាងទៅតែទឹកស្រឡាញ់
ព្រះបាទសុភ័នសាដ ហើយទឹងខ្លាំងជាបថា ព្រះអង្គស្មោះត្រង់ទឹងព្រះ
នាងពិត ព្រះនាងក៏ប្រើឲ្យគេទៅនាំព្រះអង្គមកថ្វាយព្រះនាង ។

ព្រះមហាក្សត្រលុះទ្រង់ទតឃើញព្រះនាង ក៏ទ្រង់សោមនស្សជា
អនេក ហើយក៏មានព្រះបន្ទូលទៅកាន់ព្រះនាងថា ៖

- ឧ ! ព្រះនាងអាទិទេពអើយ ! ម្ចាស់នេះខ្ញុំបានមកជួបព្រះនាង !
កាលពីមុនខ្ញុំអស់សង្ឃឹមទៅហើយ ព្រោះខ្ញុំស្មានថាព្រះនាងក្បេចខ្ញុំ ។

- ទេព្រះអង្គ ! ទៅស្មានយើងនេះការព្រាត់ប្រាសគ្នាជាការធម្មតាទេ
មិនមែនជាការបង្គ្នាឲ្យមានទុក្ខទ្បើយ ហើយយើងគ្មានព្រួយបារម្ភអ្វីសោះ ។

- ចិត្តរបស់ខ្ញុំក៏ទៅនឹងដូចជាព្រះនាងដែរ, ខ្ញុំគ្រាន់តែជា
មនុស្សលោក ក៏ប៉ុន្តែពេលដែលយើងបែកគ្នានោះដូចជាយូរពេកណាស់
ខ្ញុំទន្ទឹងចាំតែពេលនឹងបានជួបព្រះនាង ។

— ខ្ញុំម្ចាស់ដឹងច្បាស់ហើយរឿងនេះ ព្រោះឃើញថាព្រះអង្គ
ស្រឡាញ់ខ្ញុំម្ចាស់មែន គ្មានជាកលល្បិចទេ ។ បើដូច្នេះ យើងត្រូវ
រួមវាស្នាទឹងគ្នា ។

ព្រះមហាក្សត្រទ្រង់អនុញ្ញា ចំពោះព្រះទ័យដ៏វិសេសនៃព្រះនាង
សេហេរិស្តានី ហើយទ្រង់សន្យាអំពីសេចក្តីស្នេហាគ្មានទីបញ្ចប់ចំពោះ
ព្រះនាង ។ ក្រោយមកព្រះនាងទ្រង់បង្គាប់ឲ្យពួកបណ្ណាក្សត្រតាំងកោះ
នោះមកចុះ ហើយព្រះនាងបែកាសថា:

— អាទិទេពធំ-គួចតាំងឡាយ ដែលបានអញ្ជើញមកស្តាប់ខ្ញុំក្នុង
ពេលនេះ ខ្ញុំសូមជំរាបថា ក្រោយដែលព្រះវរបិតាខ្ញុំទ្រង់សុគតទៅ អ្នក
បានប្រគល់រាជសម្បត្តិឲ្យខ្ញុំត្រួមតាំងបានសព្វថ្ងៃ ទឹងស្តាប់បង្គាប់ខ្ញុំផង
ឥឡូវនេះ ខ្ញុំសូមជំរាបអស់លោកថា ខ្ញុំទឹងរៀបអាពាហ៍ពិពាហ៍ខ្លួនខ្ញុំ
ជាមួយនឹងព្រះមហាក្សត្រក្រុងចិន ហើយខ្ញុំសូមឲ្យអ្នករាល់គ្នាតុកស្តេច
អង្គនេះជាចៅហ្វាយនាយដូចជាខ្លួនខ្ញុំដែរ ។

ពួកអាទិទេពតាំងឡាយនាំគ្នាទទួលដៃ ទទួលអរសាទរទឹងការត្រួស
រើសរបស់ព្រះនាង ហើយព្រះបាទសុះភ័នសាដក៏ទទួលអគ្គិសេកជាស្តេច
នៅកោះសេហេរិស្តាន់ ។ ប៉ុន្តែមុនទឹងបានរួមវាស្នាជាមួយនឹងព្រះនាង ។
ទូលព្រះអង្គថា ៖

— ព្រះមហាក្សត្រដ៏ប្រសើរ, ដើម្បីសម្រេចសុភមង្គលដល់យើងតាំង
ពីនាក់ ខ្ញុំសូមព្រះអង្គសច្ចាទឹងខ្ញុំម្ចាស់ ហើយសូមទ្រង់តាន់ពាក្យនោះឲ្យ

ជាប់, បើកាលណាព្រះអង្គមិនគោរពជល់ពាក្យសច្ចារបស់ព្រះអង្គទេ យើងទាំងពីរនាក់នឹងមានទុក្ខ ។

— ឱ ! ព្រះនាងខ្ញីមបណ្តាលចិត្តខ្ញុំអើយ ! ឲ្យតែព្រះនាងនិយាយមកចុះ បងចេះតែធ្វើតាមប្អូនទាំងអស់ សុំឲ្យតែប្អូនសប្បាយចិត្ត ។

— ការដែលខ្ញុំម្ចាស់សុំឲ្យព្រះអង្គគាន់កន្ត្តងពេលនេះ ជាការដែលព្រះអង្គត្រូវខំអត់ធ្មត់យ៉ាងពិបាកក្នុងព្រះទ័យណាស់ ខ្ញុំម្ចាស់ខ្ជាបព្រែងព្រះអង្គទប់ព្រះទ័យពុំបាន, ពួកអាទិទេពដូចជារូបខ្ញុំម្ចាស់មានអារម្មណ៍ផ្សេងអំពីមនុស្សលោក ហើយយើងប្រព្រឹត្តផ្សេងអំពីមនុស្សលោកទៀត ដោយយើងមានទម្លាប់នឹងប្បាប់បញ្ជាត្តិពិសេសផ្សេង ។ រួមសេចក្តីថា គឺថាបើព្រះអង្គពុំសព្វព្រះពជ្ឈទ័យនឹងទូលធ្វើតាមខ្ញុំម្ចាស់ ទាំងនឹងតែងតែលះទោះ ខ្ញុំម្ចាស់មិនអាចនឹងនៅរួមរាស្ត្រនឹងព្រះអង្គបានយូរឡើយ ។

— យើ ! ស្អី ? តែប៉ុណ្ណឹងទេ ការដែលថាឲ្យខ្ញុំប្រែនោះឬ ខ្ញុំរំតែធ្ងល់ បើដូច្នេះបួរប្អូនមានមតិល្អចំពោះមនុស្សលោកផង ហើយប្អូនផ្ញើប្បាស់ចុះថា ពីថ្ងៃនេះទៅបងគ្មានធន្ទះអ្វីក្រៅអំពីធ្វើតាមបង្គាប់របស់ប្អូនទាំងអស់ទេ ព្រោះបងត្រូវនៅក្រោមអំណាចប្អូន ។

— បើដូច្នេះ កាលណាទ្រង់ឃើញខ្ញុំម្ចាស់ធ្វើអ្វីខុសនឹងព្រះទ័យព្រះអង្គ សូមទ្រង់កុំបន្ទោសខ្ញុំម្ចាស់ឲ្យសោះ ។

— ពិតហើយប្អូន ! តើប្អូនធ្វើអ្វីដែលបងមិនត្រូវចិត្ត ?

— ទោះជាការដែលខ្ញុំម្ចាស់ប្រព្រឹត្តខុសឥតធម្មតាលោកយ៉ាងណា ក៏សូមទ្រង់យល់ថាជាការចាំបាច់ទាំងអស់ តើទ្រង់ព្រមសន្យាជាដរាបឬ ?

— ជាដរាប ! ចូរអ្នកសំឡាញ់ !

ក្រោយពីចុះខសន្យានោះមក គេក៏រៀបចំអកិសេកព្រះពុទ្ធជាទាំងពីរព្រះអង្គ ។ ព្រះបាទវុសវ៉ាទសាជ សោយសុខអស់រាជ្យមួយឆ្នាំគត់ ជាមួយនឹងព្រះនាងសេហៈវិស្ពានី ក្នុងពេលនោះព្រះអង្គក្ងេចព្រះពុទ្ធានីចិន ក្ងេចបណ្ដាជនចិន ។ ព្រះនាងសេហៈវិស្ពានីទ្រង់ប្រសូតបានព្រះពុទ្ធបុត្រមួយព្រះអង្គប្រកបដោយរូបឆោមល្អគ្មានពីរ នៅពេលនោះព្រះមហាក្សត្រទ្រង់យាងចេញទៅបរបាញ់សត្វ ។ លុះឮអមាត្យទៅទូលទ្រង់ថាព្រះនាងទ្រង់ប្រសូតបានព្រះពុទ្ធបុត្រា ទ្រង់ត្រេកអរពន់ពេក ហើយក៏ទ្រង់ត្រឡប់ចូលមកព្រះបរមរាជវាំងភ្លាម, ដល់ហើយទ្រង់ទតឃើញព្រះនាងគង់ក្បែរក្មេងប្រុសមួយនេះរន្ធាល ប៉ាំងព្រះពុទ្ធបុត្រានៅទីនឹងព្រះហស្ថផង ។ ព្រះមហាក្សត្រទ្រង់យកព្រះពុទ្ធបុត្រមកបីថ្នមថើបហើយក៏ទ្រង់ហុចទៅឲ្យព្រះពុទ្ធទេពីវិញ . . . ស្រាប់តែព្រះនាងលើកព្រះពុទ្ធបុត្រនោះចោះទៅក្នុងភ្លើង ហើយស្រាប់តែបាត់ទាំងភ្លើងទាំងកូនតូចនោះទៅ ។ ព្រះមហាក្សត្រទ្រង់ស្ងុតព្រះទ័យដោយឃើញការដ៏ចំឡែកយ៉ាងនេះ តែទ្រង់នឹកឃើញកិច្ចសន្យារបស់ព្រះអង្គ ទ្រង់ទំនុកព្រះទ័យហើយក៏ទ្រង់ថយទៅក្នុងក្រឡាបខ្ញុំ, ទ្រង់សោកស្ដាយព្រះពុទ្ធបុត្រតែមួយព្រះអង្គឯងឯ,ថា ៖

ឱ ! ចុះខ្ញុំមានបាបកម្មអ្វី មកធ្វើឲ្យខ្ញុំវេទនាយ៉ាងនេះ ! ទេវតាលោកបានធ្វើឲ្យខ្ញុំមានកូនប្រុសមួយ ហើយម្ដាយយកកូនទៅចោះភ្លើង ហើយគេងាយើញនូវអំពើដ៏សាហាវយ៉ាងនេះហើយ កំនៅតែនិយាយ

ពុំបានទៀត ។ ខ្ញុំ! លោកអើយ ចុះម្តាយអីក៏ខ្ជុលគេដូច្នេះ! ម្តាយអី
ក៏តាមម្ល៉េះ? ប៉ុន្តែ ល្អើយចុះ អញត្រូវស្ងៀម, ការដែលគេធ្វើយ៉ាងនេះ
ប្រហែលជាមានហេតុផលរបស់គេខ្លាំង! ។

លុះខ្ញុំគិតដូច្នេះហើយក៏ខ្ញុំនៅស្ងៀម, គោះជាខ្ញុំចង់ជ្រាបហេតុ
យ៉ាងណាក៏ខ្ញុំពុំហ៊ានសួរ ។

មួយឆ្នាំក្រោយមក ព្រះនាងខ្ញុំប្រសូតបានព្រះពជបុត្រីមួយព្រះ
អង្គល្អលើសព្រះអង្គម្ចាស់ប្លងទៀត ។ ខ្ញុំក៏ប្រទានព្រះនាមថា
ជាល់តីស ។ រូបទោមនើតនាយនៃព្រះពជបុត្រីធ្វើឲ្យព្រះបាទវុសភ៍នសាជ
រីករាយព្រះហឫទ័យពន់ពេក ព្រះអង្គមិនខឿយណាយនឹងតយគន់ព្រះ
ព្រះពជបុត្រីសោះ នាំឲ្យខ្ញុំក្តៅព្រះពជបុត្រាប្លង ។ ក៏ប៉ុន្តែមិន
យូរប៉ុន្មាន ស្រាប់តែមានឆ្កែញីមួយធំសស្គុះ ហាមាត់ជន្លីងដើរចូលទៅ
កន្លែងព្រះបរមពជកំង ព្រះនាងសេហៃស្តាន៍ខ្ញុំតាស់ហៅឆ្កែថា:

- នែ ចូរឯងយកកូនស្រីនេះទឹងអង្រឹងរបស់ក់ទៅ ។

ឆ្កែក៏ស្ទុះភ្លែតទៅដឹតអង្រឹងកូនហើយក៏ទាំពាំយកចេញបាត់ទៅ ។
យើងពិបាកនឹងថ្លែងអំពីទុក្ខនៃព្រះមហាក្សត្រ ដែលខ្ញុំយល់ឆ្កែពាំយក
ព្រះពជបុត្រីនោះទៅណាស់ ។ ការដែលខ្ញុំបានសច្ចាចំពោះព្រះនាង
រួចទៅហើយនោះ នាំឲ្យព្រះអង្គខំទប់ស្ងៀតែឯង ព្រះទ្យ ។ ព្រះអង្គ
ខ្ញុំរត់ទៅពួនសោកសង្រេងតែមួយព្រះអង្គឯងក្នុងបន្ទប់ ហើយខ្ញុំ
ទឹកឃើញដល់ទៅក់ស្នាំនៃព្រះពជបុត្រាព្រះអង្គផង ។ ខ្ញុំព្រះកន្ទ្រែង
រៀបរាប់ថា:

- យ៉ា! នាងសេហវិស្ដាសានី! នាងគ្មានចិត្ដធម៌កន្ដឹងខ្លួនសោះ គួរអ្វីនាងហ៊ានធ្វើកម្មកូនខ្លួនដូច្នេះ, តែថាបើគ្មានការប្ដឹក ពួកអាទិទេព មិនធ្វើទេ, នាងបាននិយាយច្រាប់យើងដែរតើដំបូង ថាមានតែការចាំបាច់ទេដែលត្រូវឲ្យនាងបំពេញកិច្ចម្ដងមួយៗបាន, ប៉ុន្ដែការចាំបាច់យ៉ាងនេះដូចជាជ្រលេចក, អ្វីក៏ដល់ទៅបង្កាប់ឲ្យម្ដាយលះបង់កូនបង្កើតរបស់ខ្លួន ទាល់តែ... ន! ខ្ញុំទ័កឃើញហើយ: តែការណាអាទិទេពយកមនុស្សលោកធ្វើជាប្ដី ច្រហែលជាមានច្បាប់ថាឲ្យបំបាត់ផលដែលបានមកអំពីការរួបរួមនោះ, យ៉ាអ្វីក៏សម្បើមម្ល៉ះ!... ន! ព្រះនាង! ទោះជាខ្ញុំស្រឡាញ់ព្រះនាងយ៉ាងណា ក៏ខ្ញុំពុំអាចនឹងតាំនៅជាមួយនឹងព្រះនាងតទៅទៀតបានឡើយ ។

ព្រះមហាក្សត្រជាបុគ្គលមួយរូបដែលមានសតិវែង ទ្រង់មិនបង្ហាញទឹកព្រះភក្ដ្រឲ្យព្រះនាងជ្រាបទេ ប៉ុន្ដែថ្ងៃមួយព្រះអង្គមានបន្ទូលច្រាប់ទៅព្រះនាងថា:

- ព្រះនាង! បងបង់ទៅមើលនគរបងណាស់ ច្រើរាស្ដ្រចង់បងស្រេចឲ្យតែបងត្រឡប់លែវិញ សូមព្រះនាងបើកឲ្យបងទៅមើលរាស្ដ្របងវិញផង ។

ព្រះនាងទ្រង់តបវិញថា:

- ខ្ញុំម្ចាស់សុខចិត្ដបំពេញព្រះរាជប្ញើយ្យព្រះអង្គ ទឹងបំពេញចិត្ដរាស្ដ្រព្រះអង្គ ។ ម្យ៉ាងទៀត ក្នុងខណៈនេះព្រះរាជានីព្រះអង្គត្រូវការព្រះអង្គជាជាងខាត ខ្ញុំម្ចាស់ដឹងច្បាស់ថាពួកមុនគោលលើកទ័ពមួយ

កន្លះយ៉ាងពួកគេមកច្បាំងនឹងព្រះអង្គ សូមស្តេចយាងទៅការពារអាណាចក្រ
ព្រះអង្គកុះ បើទុកជាពួកសេនាគាហានព្រះអង្គពួតគេណែនណាក៏ដោយ តែ
កាលណាព្រះអង្គនាំមុខ ពួកនោះនឹងមានសេចក្តីក្លាហានជាជាងទៅច្បាំង
តែឯង ខ្ញុំម្ចាស់នឹងទៅតាមមើលព្រះអង្គដែរ ។

គ្រាស់ហើយព្រះនាងទ្រង់មានបន្ទូលហៅខ្ញុំអាឌិទេពមួយរូបមកហើយ
បង្គាប់ឲ្យជូនព្រះពរទៅទីក៏ងនៅប្រទេសចិនមួយរំពេច ។ ការត្រឡប់
ទៅនគរវិញនៃព្រះបាទសុសាន្តសាជនោះធ្វើតែមួយភ្លែតក៏ដល់ភ្លាម ។

លោកមុយអេស៊ីនគ្រាន់តែក្រឡេកឃើញព្រះអង្គភ្លាម ក៏ត្រេកអរ
ឥតឧបមា លោករត់ទៅក្រាបថ្វាយបង្គំព្រះអង្គ អោនក្បាលចាល់តែដល់ដី
ហើយទូលថា ៖

— ឧ ! ព្រះគុណម្ចាស់អើយ ! ព្រះលោកជួយខ្ញុំមែន ! ហើយ
ព្រះលោកប្រគល់មហាក្សត្រមកដល់ប្រជាជនរបស់លោកវិញ. កន្លះពេល
ដែលព្រះអង្គយាងទៅបាត់ ខ្ញុំលព្រះបង្គំជាខ្ញុំបានការពារអាណាចក្រ
ជំនួសព្រះអង្គ, ហើយដល់ឃើញមក ដោយគ្មានបានដំណឹងអ្វីអំពីព្រះអង្គ
សោះ ក៏អស់សង្ឃឹមថាទ្រង់នឹងយាងត្រឡប់មកវិញ ពួកនាម៉ឺនសព្វមុខ
មន្ត្រីពាំងប៉ុន្មានគាំគាលើកពលសម្បត្តិប្រគល់ឲ្យខ្ញុំលព្រះបង្គំ ដោះជាខ្ញុំ
ព្រះបង្គំខំប្រែកែកយ៉ាំងណាក៏គេពុំសុខចិត្ត ។ ឥឡូវនេះទ្រង់យាងមកដល់
ហើយ ឧ ! ព្រះករុណាជាម្ចាស់ជីវិតខ្ញុំអើយ សូមព្រះអង្គទ្រង់គន់លើ
ស្មូតច្ចែត ដែលខ្ញុំព្រះអង្គបានអង្គុយដំនួសព្រះអង្គជាយូរណាស់
មកហើយ ។

(មានត)

ពាក្យកាព្យ

អ្នកឧកញ៉ាមហាវិនិច្ឆ័យ នៅ

រៀបរៀង

(តមក)

អធិប្បាយ ចុះយល់ប្រែកែតាមប្រៀប លោកធ្វើបរៀបរាប់តាមតម្រា
គឺព្រះពាជបុត្រនូវដេជ្ឈា សញ្ញាសន្ធតចាកដឈ្មោះ ។
ជាធង់ចង្អឹមព្រះនគរ ព្រោះអាចទ្រទ្រង់ទង្វើខ្ពង់ខ្ពស់
បុរោហិតបណ្ឌិតពិតចំពោះ នោះលោកពិគ្រោះសន្ធតថា ។
ជាក្អែកព្រះនគរពិតចាកដ កំណត់ដូចតរេះក្បួនតម្រា
ឥសីមុនីមានទ្ធិក្នុង ឈ្មោះថាខង់ជ័យដែនកពការ ។
សេដ្ឋីគហបតីជាមានទ្រព្យ លោកពាំជាពោះនគរ
បុត្រីបុត្រាភស្តុប្រជា ដូចទាកញ្ចក់ធ្លុះវិស័យ ។
ជាតាមាតាលោកប្រៀបខុក ដូចមណ្ឌលមុខតែងអាស្រ័យ
កញ្ចក់ធ្លុះស្មាងក្តីសព្វថ្ងៃ ឧបមេយ្យដូច្នេះទើបពាត់ថា ។
កូនប្រុសកូនស្រីជនគាំងឡាយ អធិប្បាយឈ្មោះមុខពាជស័ម្ភា
យោធាគាហានជាំក្នុងវាំង ឈ្មោះថាដៃដើងព្រះនគរ ។
ហេតុនោះគួរខ្ញង់កុំឃ្លានតាន ទន្ទ្រានពានរំបង្វែរកែវ
ទង់ជ័យនេះក្សេមក្សាន្តស្មោះសាទរ ដោយព្រះកូនរក្សាទង់ប្រណី ។
ន័យមួយទៀតក្សត្រទង់អមាត្យ គប្បីនុហាតជាប្រក្រតី

ប្រជុំប្រកួតការគ្រប់គ្រី គឺបីវេលានាមួយថ្ងៃ ។
ហើយខ្ញុំប្រកបព្រមដោយអង្គ ប្រាំពីរគឺមគ្គដ៏ប្រសើរ
ប្រព្រឹត្តពិនិត្យតាមនិស្ស័យ អធ្យាស្រ័យមិនលាក់មិនលះលា ។
មួយគឺញុំងកិច្ចការទាំងឡាយ សប្បាយក្សេមក្សាន្តវឌ្ឍនា
ពាបពាប់ព្រមព្រៀងក្នុងភាព ឥតមានឥស្សាជាសៅហ្មង ។
មួយបានយកខ្លាត់ចាត់ជាសួយ មិនឲ្យស្តួតព្រួយដល់ប៉ុនល្អង
នឹងជាក់គាជាទោសាផង តាមសមគួរហោងគឺមត្រូវល្អិត ។
មួយគឺពាប់អានចាស់ព្រឹទ្ធា ប្រព្រឹត្តធម្មាជាសុចរិត
មួយមិនបៀតបៀនគិតស្នេហ៍ស្មុំខ្ញុ រិតត្បិតបុត្រីអ្នកនគរ ។
មួយគឺធ្វាប់ពាប់អានទៅតា បូជាព្រឹការដោយសាខរ
ឲ្យធ្វើតាមធ្វាប់ជាប់រៃ សូមពរទៅរ៉ាប់ប្រសិទ្ធិសិទ្ធិ ។
មួយខ្ញុំរក្សាសមណព្រាហ្មណ៍ មានឧបការខ្ញុំលើលះស្មោះស្មើស្មុំគ្រ
ខុបត្ថម្ភគាំពារមិនឲ្យអាក់ សំណាក់អាស្រ័យព្រះទំយស្ញ ។
ធម៌ប្រាំពីរនេះគួរមហាក្សត្រ ប្រតិបត្តិជាទិច្ចដ៏ប្រសើរ
ខ្ញុំគ្រប់សត្វសុសតាមដំណើរ កុំឲ្យសើរើឆ្ងៃសាតខាន ។

សទ្ធត្ថញ្ញោនយោសមហោ ក្សត្រខត្តមោគ្គឆ៍ភជហាន
គប្បីជ្រាបកិច្ចគិតប្រមាណ សម្រួលចិត្តក្សាន្តពស្តប្រជា ។
ហើយធ្វាសក្នុងខ័ពិចារណា កាត់ការសន្ធិរពស្តនានា
ដោយព្រះយោបល់យល់តុះពារ ឲ្យស្តួលាភលាការសង្ឃ័យ ។
ខ្ញុំខ្ញាន់ប្រៀនប្រាប់ពស្តគ្រប់ប្រាណ ឲ្យបានស្មោះស្មានពន់ពេកក្រៃ

ត្រែតអវគានសីលអចិន្ត្រៃយ៍ អធ្យាស្រ័យស្រោចស្រង់ខ្ញុំមេត្តា ។
ញុញុំមជាមុនទើបខ្ញុំគ្រាស់ តម្រាស់ភាសិតគតិកិច្ចការ
តាមព្រះយោបល់យល់ភ្លឺថ្លា ដល់ខ្ញុំបរិវារពហុវិសេស ។
យថាវុត្តេហិគុណេហិ គតិអធិប្បាយថាយថែងចាត់
ថាព្រះចម្បតន្ទ្រវង្សមហាក្សត្រ គប្បីប្រតិបត្តិប្រកបយក ។
ខ្ញុំវគុណតាំងឡាយលោកសំដែង តាំងតែងថ្វែងពុកពីមុនមក
គួរខ្ញុំត្រែតត្រាប់ចាប់រំលេក លៃលកឲ្យត្រូវគ្រប់ប្រការ ។
ទើបនឹងថ្កាប់ថ្កុមហាមប្រជុំ អស់ពស្ត្រកន្លះត្រៃវែកន្លះអា
ខ្ញុំបខ្ញាចអំណាចព្រះចេស្តា សុខាក្សេមក្សាន្តតាំងផែនដី ។
ហើយនឹងចំរើនព្រះកិត្តិយស ខ្ពង់ខ្ពស់ដោយវិជ្ជាបុណ្យកុសី
មង្គលវិមលសុខសិរី សូវគ្គីជេរបិតតាមថ្កាថ្លា ។
អិប្បិសុត្តធម្មោបញ្ញោ ទុតិយវិជ្ជោ អគ្គឯណា
ខ្ញុំមានព្យាយាមដ៏ក្លៀវក្លា ឧស្សាហ៍ត្រង់ត្រាប់ស្តាប់ព្រះធម៌ ។
ជានិច្চកាលជាប់ប្រតិទិ ជ្រាបអត្ថលោកិយលោកុត្តរ
ព្រះទ័យមោះមុតមិនញាប់ញ័រ ខ្ញុំវិវត្តទាល់សល់ចំពាក់ ។
ហើយមានព្រះទ័យមិនឫស្យា ឥច្ឆាសម្បត្តិជនជាតិជាក់
គួរខ្ញុំសមាគមកិរិយាវ័ក្ស សំណាក់អាស្រ័យគ្រូអាចារ្យ ។
លោកជាអ្នកថ្កាដ្ឋអាចចេះដឹង អត្ថធម៌ផ្សឹង ។ ត្រប់ប្រការ
ជាតិកាត់បង់ក្តីកង្វាំ ឈ្វេងយល់បញ្ហាអត្ថធម៌ផង ។
បើបានប្រកបព្រមដោយអង្គ ថ្កាំពីរត្រឹមត្រង់ត្រូវឥតហ្មង

ព្រមទាំងពាជវត្តច្រាំពីរកន្ល បុពណាចៃន្ចធ៌ពណិនាថា ។
ក្សត្រអង្គនោះនឹងបរិបូណ៌ ឥស្សរសិរីយសខ្ពស់សក្តា
ព្រមទៅដោយយសបរិវារ ទ្បាវពន្ធឹកអធិកវិត្រ ។
នឹងបានចំរើនគ្រប់ប្រការ រដ្ឋាប្រសើរអចិន្ត្រៃយ៍
ប្រកបសុវត្ថិសុខសព្វថៃ្ង អាស្រ័យដោយខ្លៃយុត្តិល្អ ។
អំណាចអាចឈ្នះបច្ចាមិត្រ ឆ្ងាយជិតពិតពុំហ៊ានតាំងត
មូលមកកក្តីសមោសរ អំណរសាន្តសុខទាំងផែនដី ។
មហាក្សត្រខ្លៃធម៌ទសពិធ បណ្ឌិតសរសើរគុណជាមិ
ស្មើគុណទេវតាទាំងច្រាំបី មានអង្គគោស៊ីជាប្រធាន ។
យថាសង្ខោទេវោជា សម្តេចឥន្ទ្រាខ្លៃរំងាន
សន្ត្រែះទេវតាដោយខួនាន ប្រតិបត្តិគុណទោសច្រាសប្រដៅ ។
ដូចព្រះមហាក្សត្រខ្លៃមេត្តា ដល់ខ្ញុំពជការទាំងក្នុងក្រៅ
ល្បីកលើកទោសតាមល្ងង់ខ្លៅ ច្រើសហៅហាមច្រាមដូច្នោះឯង ។
អដ្ឋមាសំយថាកិច្ចោ រីព្រះសុរិយោរះចាំងចែង
ញ៉ាំងទឹកឲ្យស្ងួតរីងហួតហែង ដោយសែងរស្មីច្រាំបីខែ ។
នេះដូចជាអង្គមហាក្សត្រ ទឹងយកសួយទ្រាត់ប្រយ័ត្នថែ
ហ៊ារម្តងម្កាលស្តួតឈួតច្រណែ សន្ត្រែះយកតែតាមសមគួរ ។
យថាបិយំអបិយំវា ព្រះយមកជាទឹងសាកសួរ
បុណ្យច្បាបសត្វនរកឲ្យគ្រប់គួ មិនមួរើសមុខស្អប់ស្រឡាញ់ ។

នេះដូចអង្គក្សត្រខត្តិយវង្ស ទ្រង់ទឹងរិទ្ធិយមិនគ្នាន់ញ្ញាញ់
ប្រៀបផ្ទឹមសេចក្តីតាមឈ្នះចាញ់ តិតកាញ់ឲ្យគួរតាមត្រឹត្យា ។
មិនរើសមុខថាស្អប់ស្រឡាញ់ ពោះចាញ់ពោះឈ្នះដូចម្តេចម្តា
ព្រះទ័យតាំងស្មើបរិសុទ្ធថ្លា សត្យាដូចអង្គព្រះយមពិត ។

យថាបុព្វេ្ពទុកា

មិនមានច្រណែនប៉ងគន់គិត ធម្មតាសមុទ្រទំពាំនិត
ពីស្មើតូច ។ ផងនានា បព្រឹត្តយកគុណប្រយោជន៍ផល ។
សព្វស្មើចឹងបួងស្តប់ស្តល់ ហើយអាចជានាហូរឲ្យដល់
ប្រៀបដូចមហាក្សត្រខត្តិយវង្ស ពោរពេញមិនសល់ដោយជលសា ។
សម្បត្តិផងក្រស្តេរុំភជការ គ្មានព្រះបំណងប៉ងច្រណែនថ្នា
សង្គ្រោះចំពោះដោយសាធារណ៍ ទ្រង់មានមេត្តាជាប្រធាន ។
ដល់ក្រស្តេប្រជាណាដែលគ្មាន បវិច្ឆាគទ្រព្យឲ្យជាទាន
មិនឲ្យអត់ឃ្លានរនាថា ។ មិនឲ្យអន្តរាយដោយសាធារណ៍

បរិបុណ្ណាំយថាបទ្ធំ

ចិត្តជនក្រុងស្រុកទាំងលោកា វាក្យំ ចាប់បទពាក្យឧបមា
ចាន់ឃើញចន្ទ្រាពេញបូណ៌មី ។ ចានឃើញចន្ទ្រាពេញបូណ៌មី ។

(មានត)

ពេជ្រព្រះភជា

លោក ស៊ីដ្ន - ប៉ាវ៉ង ប្រែរៀបរៀង

លោក យ៉ូរ៉ូ - អ៊ីដ្ន ពិនិត្យកែសម្រួល

(តមក)

មើលៗទៅ យើញគួរឲ្យតក់ស្លុតពន់ពេក, មាណពយើញដូច្នោះ ក៏មានសេចក្តីវេទនាចំពោះមេគោនឹងកូនគោយ៉ាងក្រៃលែង ដោយយើញអាការរបស់កូនគោដែលត្រូវគេព័យរត់ត្រឡប់ទៅនោះ ក៏កើតសេចក្តីតក់ស្លុតខាល់តែហូរទឹកភ្នែកចេញច្រោកៗ ព្រោះបានគិតដល់ខ្លួនឯងដែលមានម្តាយ តើសេចក្តីស្រឡាញ់របស់ម្តាយដែលមានមកលើខ្លួននោះប៉ុនណា ? មាណពរើបសម្រេចក្នុងចិត្តថា "ស្រួលហើយ ! អាត្មាអញនឹងបួលទៅគាល់ព្រះភជា ខ្លួចាស់មិនឲ្យព្រះភជាធ្វើពិធីបូជាយ័ញ្ញ សូម្បីខ្លួនឯងត្រូវអស់ជីវិត ក៏ត្រូវទៅតាមហេតុការណ៍" ហើយក្រោកឡើងចាកទីដែលខ្លួនអង្គុយ ទើបថ្កាប់អមាត្យថ្កាលិតថា ៖

"សំឡាញ់ហស់ ! ខ្ញុំនឹងអត់ក្រែងមើលខ្លួវសភាពខ្លួនចិត្តតាមរបៀបនេះមិនបានទេ ខ្ញុំនឹងខ្លួចាស់ខ្លួវការធ្វើពិធីរបៀបនេះឲ្យបាន" ។

អមាត្យថ្កាលិតឃើញអាការរបស់មាណព រំភាវដូច្នោះហើយក៏ថ្នាក់ទឹកចិត្តជាខ្លាំង ពាញដៃមាណពឲ្យអង្គុយវិញ មាណពក៏មិនត្រូវស្បាយមរលាស់ចេញ អមាត្យថ្កាលិតមិនត្រូវបណ្តោយ ។ អាការចាប់ប្រទង់ប្រទាញគ្នាទៅវិញទៅមក នៃជនទាំង ២ នាក់នេះ ធ្វើឲ្យ

ព្រះពុទ្ធវរៈព្រះភ័ក្ត្រមកឃើញ ទើបខ្ញុំបង្គាប់ឲ្យភ្ជាក់ងារចូលមកចាប់ខ្លួនមាណពយកទៅ ។

អមាត្យចាស់ត្រមះបណ្តែយមាណពឲ្យទៅតាមភ្ជាក់ងារ ព្រោះមិនអាចការពារបាន តែក្នុងចិត្តនឹកវិតក្កដំនួសមាណពយ៉ាងក្រៃលែង ។ ពួកប្រជាជនដែលឃើញហេតុការណ៍ដូច្នោះក៏នឹកថា ប្រហែលមាណពនេះ បង្កហេតុអ្វីមួយឡើង ដែលនាំឲ្យព្រះពុទ្ធជាអង្គទ្រង់ព្រះកម្មយ៉ាងធ្ងន់ ។

មាណពចូលមកថ្វាយបង្គំព្រះពុទ្ធហើយអង្គុយស្ងៀម ព្រះពុទ្ធទ្រង់ទតសម្លឹងដោយព្រះនេត្រដ៏តឹងព្រោះមានព្រះតម្រិះពេញយ៉ាងខ្លាំង :

" នែមាណព ! ហេតុអ្វី ឯងចូលមកធ្វើចលាចលក្នុងកេរព្រះពិធីបូជាយ័ញ្ញរបស់អញ ? តាំងមានកិរិយាទទឹងសំលៀកចំពាក់ទន្ទឹងដូចជាមិនមែនមនុស្សក្នុងក្រុងរបស់អញ, ឯងដឹងឬទេថាឯងមានទោសត្រូវប្រហារជីវិត ! " ។

មាណពថ្វាយបង្គំព្រះពុទ្ធម្តងទៀត ដោយសំដែងអាការគក់ស្មូតញាប់ញ័រក្នុងព្រះតម្រិះរបស់ព្រះពុទ្ធជាបន្តិចបន្តួចសោះ ហើយទូលថា :

" សូមទ្រង់ព្រះមេត្តាប្រោស ! សូមព្រះពុទ្ធគេជះតំកល់លើត្បូង ! ព្រះអង្គធ្លាប់ជាក់ព្រះពុទ្ធអាជ្ញាដល់ទ្រង់ ។ ជានិច្ច, តែមុខនឹងជាក់ព្រះពុទ្ធអាជ្ញានោះ ព្រះអង្គទ្រង់ប្រើព្រះឫជាតិរឹងត្អឹងគ្រប់គ្រាន់ហើយឬ ? ជីវិតរបស់ព្រះអង្គមានតម្លៃកម្រើបពុំបាន, ចំណែកជីវិតរបស់ខ្ញុំព្រះអង្គឥតតម្លៃសោះ, តែខ្ញុំព្រះអង្គស្រឡាញ់ជីវិតខ្ញុំព្រះអង្គណាស់, ប្រសិន

បើខ្ញុំព្រះអង្គមានជីវិតខ្លួនឯងដូចព្រះអង្គហើយ ខ្ញុំព្រះអង្គក៏មិនច្បាស់ថា
ខ្លួនមានជីវិតរស់នៅតទៅឡើយ" ។

ពាក្យតបដូច្នេះ ជាពាក្យតបដែលពោលប្រៀបធៀបដល់ការរស់
នៅនៃព្រះពុទ្ធ ប្រហែល ។ ទើបថាវគតម្លៃគ្នាន ជាពាក្យដែលធ្វើឲ្យព្រះ
ពុទ្ធរើតតែខ្លាល់ឡើង ព្រះពុទ្ធទើបត្រង់សន្ទាប់ដោយព្រះសូរសៀង
យ៉ាងខ្លាំង ៖

"នែអាបុរសអប្បលក្ខណ៍! ឯងហ៊ានមើលងាយការរស់នៅនៃ
អញថាតាបថោកជាងការរស់នៅរបស់ឯង! ល្អហើយ បើឯងមិនអាច
ឲ្យអមាត្យទាំងឡាយយល់ឃើញពិត តាមដែលឯងថាបានទេ អញនឹង
ប្រហារជីវិតឯងពុំខាន" ។

"បពិត្រព្រះសម្មតិទេព! នរណាសោតនឹងអាចហ៊ានមើលងាយ
បន្ទាបបន្ថោកព្រះបរមគេជាទុកាពព្រះអង្គបាន, ការរស់នៅរបស់ព្រះអង្គ
ប្រសើរបំផុត, ឥឡូវនេះ ខ្ញុំព្រះអង្គបានសម្លឹងឃើញនូវកាពជាព្រះពុទ្ធ
របស់ព្រះអង្គ ត្រូវសេចក្តីល្ងង់ខ្លៅទំលាយចោល, សូមព្រះអង្គទ្រង់
ជ្រាបចុះ" ។ មាណពព្យាយាមរកពាក្យក្រាបទូលជាស់ព្រះស្ងោរតើនៃ
ព្រះពុទ្ធាសន្សឹម ។ បន្តិច ។ ព្រោះដឹងថាបើធ្វើឲ្យព្រះពុទ្ធខ្លាល់ខ្លាំង អ្នក
ធ្វើនឹងដល់នូវសេចក្តីស្លាប់ ។

ព្រះពុទ្ធបានត្រង់ព្រះសណ្តាប់ កំត្រង់ព្រះសម្លួលភ្នាក់ភ្លាយ :
"ហ៊ាស ។ ហ៊ា នែបុរសកម្ទេច! ឯងសំគាល់ឃើញអញថាជាមនុស្ស
ល្ងង់ខ្លៅទៀតហើយ; ដែលឯងថាយ៉ាងនេះ ព្រោះឯងខ្វាចអញជាក់អាជ្ញា

ជាខម្ញុំ, តែណ្ហើយចុះមិនអ្វីទេ អញនឹងបង្អង់ការពិយោគឯងក្នុងថ្ងៃនេះសិនចុះ, តែទោះបីយ៉ាងណាក៏ដោយ ចើឯងនិយាយមិនល្អក៏មិនរួចពីសេចក្តីស្លាប់ដែរ ដូច្នេះ ត្រូវតែឯងនិយាយមកចុះ" ។

មាណពសំគាល់ឃើញបានការខ្លះហើយ ទើបក្រាបទូលថា:

"បពិត្រព្រះករុណាថ្លៃវិសេស! សូមព្រះអង្គទ្រង់ជ្រាបថា ព្រះពុទ្ធទាំងឡាយសុទ្ធតែជាអ្នកប្រាជ្ញ, វត្ថុអ្វីដែលព្រះអង្គមិនទាន់ជ្រាប ព្រះអង្គតែងទ្រង់ស្វែងរកដើម្បីទ្រង់ឲ្យជ្រាប, វត្ថុអ្វីដែលព្រះអង្គទ្រង់ជ្រាបហើយ តែងទ្រង់ជ្រាបច្បាស់ថា នេះខុស នេះត្រូវ, ខ្ញុំព្រះអង្គដឹងបានយ៉ាងនេះ, ព្រោះហេតុនេះ ទើបខ្ញុំព្រះអង្គមកមើលកម្មពិធីបែបរបស់ព្រះអង្គដែលខុសប្លែកអំពីកម្មពិធីទាំងឡាយដែលខ្ញុំព្រះអង្គធ្លាប់បានឃើញមក, ឯកម្មពិធីបែបនេះ ព្រះសម្ពុទ្ធជាអម្ចាស់ព្រះអង្គមានព្រះទ័យប្រសើរខ្ពស់ជាងមនុស្សទាំងឡាយ ទ្រង់បានប្រកាសថាជាកម្មមានទោសដ៏ធ្ងន់របស់អ្នកប្រកប ព្រោះធ្វើដំរីតសត្វចំនួនច្រើនឲ្យស្លាប់ ហើយព្រះអង្គបានទ្រង់ហាមព្រះពុទ្ធក្នុងអតីតសម័យមកហើយថា មិនឲ្យធ្វើកម្មពិធីបែបនេះទៀតទេ, កម្មពិធីយ៉ាងនេះគេក៏បានលើកលែង ឈប់ធ្វើទៅហើយ, ខ្ញុំព្រះអង្គពុំទាន់បានដឹងអំពីយោបល់ឈ្វេងយល់របស់ព្រះអង្គ តើទ្រង់ជ្រាបហេតុនឹងផលនៃកម្មពិធីនេះ ពិតប្រាកដហើយឬទេ? ដោយខ្ញុំព្រះអង្គនឹកឃើញយ៉ាងនេះឯង សូមព្រះអង្គទ្រង់ព្រះពុទ្ធានុញ្ញាតព្រះតម្រាស់តបឲ្យខ្ញុំព្រះអង្គបានដឹងផង" ។

ពាក្យរបស់មាណពនេះជាពាក្យកំប៉ាំងគំនិត ដែលអាចធ្វើឲ្យព្រះទ័យ
នៃព្រះរាជាទង់ធ្វើគំនិតច្រជាជន នៅក្នុងទីនោះឲ្យទឹកឃើញចំឡែក
ជាពន់ពេក ។ កាលព្រះរាជាបានទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ
ទ្រង់បែកព្រះច្បាប់ជាបន្ទូរវត្តផ្សេង ។ ទង់រឿងក៏រំពាំងអស់ ជាហេតុនាំ
ឲ្យទ្រង់រិះគិតឃើញ ដោយព្រះអគ្គិញាប់សិក្សាមកយ៉ាងជ្រៅជ្រះដែរ តែ
មិនឆ្លាប់បានទ្រង់ជ្រាបរឿងក៏រវៃរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ឡើយ ។

បរិយាកាសក្នុងខណៈនេះកំពុងស្ងប់ស្ងៀម អមាត្យចាស់តអង្គុយ
ស្តាប់ព្រះរាជាដែលទ្រង់សន្ទនាទង់មាណពដោយរំភើបក្នុងចិត្ត ខំទឹករកផ្លូវ
ទង់ជួយមាណពអស់កាលដំយូរ ហើយក៏ចាប់ក្តីកទឹកឃើញភ្លាមថា "ព្រះ
រាជាអង្គនេះឆ្លាប់ស្តេចទៅគាល់ព្រះធម្មបតីរាជាម្តងមកហើយ ឯខ្ញុំនេះ
ក៏ឆ្លាប់បានគាល់ព្រះអង្គមកយ៉ាងជិតស្និទ្ធ អំពីពេលនោះដែរ រាប់ជាវេលា
យូរមកហើយ ស្ទើរតែភ្លេចអស់ទៅ ទើបតែទង់ទឹកឃើញបានក្នុងពេល
នេះឯង លុះឃើញហេតុការណ៍ក្នុងឋានៈដែលព្រះរាជាទ្រង់មានព្រះទ័យ
ផ្សឹទៅតាមពាក្យមាណពហើយ ទោះជាយ៉ាងណាក៏ដោយ ក៏ត្រូវតែ
ចូលទៅគាល់ក្នុងពេលនេះកុំខាន ពាន់មាណពកំពុងមានទុក្ខាសនៅក្នុង
ទីនោះនៅឡើយ, បើមិនចូលទៅជួយមាណពក្នុងពេលនេះទេ មាណព
ក៏មិនអាចផុតភ័យបាន ហើយអាចមានផ្លូវដែលមាណពទង់សូមឲ្យព្រះ
រាជាលើកលែងធ្វើពិធីបូជាយ័ញ្ញាចេញបាន" កាលគិតយ៉ាងនេះហើយ
ទើបក៏រួចូលទៅហ្មចចំពោះព្រះភក្ត្រព្រះរាជាជិតមាណព ។

ព្រះពាជាកំពុងតែទ្រង់នឹកឆ្ងល់ កន្លងពេលដែលទ្រង់ទតឃើញអមាត្យចាស់ជិត, ឯអមាត្យចាស់ជិតក៏ក្រាបបង្គំទូលឡើងៈ

"សូមព្រះពាជតេជះដ៏កល់លើត្បូង! ខ្ញុំព្រះអង្គជាខ្ញុតនឹងជាអមាត្យធំនៃព្រះធម្មបតីពាជា, សូមចូលគាល់, សូមទ្រង់ព្រះបាសព្រះពាជទានអភ័យឱាសចំពោះការណ៍ដែលខ្ញុំព្រះអង្គចូលមកគាល់ខុសកាលវេលានេះ" ។

ព្រះពាជាបែរព្រះភ័ក្ត្រដោយចំឡែកក្នុងព្រះទ័យថា "ឃើ! មានខ្ញុតបរទេសចូលមកគាល់ផង" ហើយទ្រង់ញាក់ព្រះភ័ក្ត្រខ្លួន, ទ្រង់ទតសម្លឹងមួយស្របក់, ទើបការស្គាល់ក៏ច្បាស់ជឡើងបាន ។

"ឧ! លោកជាអមាត្យចាស់ជិតឬ? ឬហេតុមានការពាក់ព័ន្ធនឹងខ្ញុំជាច្រើនយ៉ាប់ ទើបព្រះពាជទ្រង់បញ្ជូនលោកមកទេដឹង?

"មិនមែនទេព្រះករុណា! ដែលខ្ញុំព្រះអង្គមកនេះ មិនមានការពាក់ព័ន្ធជាប់ទាក់ទងនឹងព្រះអង្គទេ, ខ្ញុំព្រះអង្គមកនេះដោយបំណងនៃមាណពម្នាក់នេះ" ថាហើយក៏ប្រដូសទៅមាណព" ។

"ឧ! មាណពនេះឬ! មាណពនេះហ៊ានមើលងាយយើងខ្លាំងពេក ពាក្យទោសគ្រានេះធ្ងន់ណាស់ ត្រូវដល់ប្រហារជីវិត តែយើងខ្លួនឯងសឲ្យ បើមិនអាចលុបលាងពាក្យមើលងាយបានទេ យើងនឹងឲ្យគេប្រហារជីវិតបង់" រួចទ្រង់បែរទៅខាងមាណព សួរមាណពថាៈ

"មើលឯងថាទៅ!" ។

មាណពទូលថាៈ

"គ្រាបទូល ! ការបូជាយ័ញ្ញដោយសត្វរស់ ដើម្បីព្រះពុទ្ធតា ដែលកំពុងប្រឈមនឹងដើម្បីឲ្យពេតរប៉ក្សាវិនាសទៅនេះ ពុំសមហេតុផលទេ ព្រះករុណា !" ។

"ពុំសមហេតុផលដូចម្តេច" ព្រះរាជាត្រាស់សួរផ្ទួនថា "ឯងមានអ្វីមកអាងឲ្យល្អវិសេសជាងនេះទៅទៀត ចូរថាមកចុះ !" ។

"បពិត្រព្រះករុណាវិជ្ជាវិសេស ! វត្តុត្រូវយ៉ាងក្នុងលោកវៃមែងកើតមកតែអំពីហេតុ, កាលណាគ្មានហេតុទីវិញ ក៏ត្រូវលេត់ត្រង់ដើមហេតុជាមុន ព្រះអង្គ !" ។

"ខ្ញុំចង់ដឹងណាស់ ហេតុដូចម្តេច ព្រះពុទ្ធតាបានជាយើងប្រឈមនពេលនេះ ទាំងពេតរប៉ក្សាក៏កើតមាន? តើឯងនឹងកំណត់ត្រង់ណាថាជាហេតុផលដូច្នេះ? សូម្បីនរណា ។ ក៏មិនអាចដឹងបាន, មនុស្សក្នុងនគរយើងនេះដែលជាពេទ្យពូកែ ។ ក៏ធ្លុះចំណេះនឹងកែទៅបាន យើងទើបយល់ឃើញថាគួរតែធ្វើទៅតាមប្រពៃណីដើមដែលធ្លាប់ធ្វើមក កន្លងពេលដែលមានសេចក្តីបត្តិកើតឡើង ដើម្បីនឹងកែទៅនូវហេតុអាក្រក់នេះឲ្យសូន្យរម្ងាប់ បានជាធ្វើពិធីនេះឡើងនៅគ្រាចុងបំផុត" ។

"ខ្ញុំព្រះអង្គនឹងជាអ្នកអង់អាចបាន កន្លងពេលដែលគ្មាននរណាអាច, ហើយខ្ញុំព្រះករុណាសូមទទួលយកអាសា ដោយវាចាសច្ចារបស់ខ្ញុំព្រះអង្គ, សូមព្រះអង្គទ្រង់ប្រោសព្រះរាជទានឱកាសឲ្យខ្ញុំព្រះអង្គផង" ។

ដោយសេចក្តីទឹកសង្ឃឹមកន្លងចិត្តជាមុន មាណពទើបក្រាបបង្គំទូលថា "បើព្រះអង្គទ្រង់បញ្ជាប់ខ្ញុំពិធីយ័ញ្ញនេះ, ខ្ញុំព្រះអង្គនឹងធ្វើឲ្យពេតរប៉ក្សា

ទឹងព្រះអង្គម្ចាស់ក្សត្រិយ៍ចាត់ប្រឈួនក្នុងវេលា ៧ កត្រាខាងមុខ, បើមិនដូច
ពាក្យដែលខ្ញុំព្រះអង្គក្រាបបង្គំទូលទេ ខ្ញុំព្រះអង្គសូមថ្វាយជីវិត" ។

"ពិតប្រាកដឬ, ឲ្យតែពិតប្រាកដចុះ មាណព!" ព្រះពាក្យទ្រង់ពាក្យ
ព្រះទ័យ ត្រាស់ផ្ទួន ។ ទឹងមាណព តែព្រះសូរសៀងអន់ខ្សោយតិចៗ ។

"ខ្ញុំព្រះអង្គសូមរ៉ាប់រង ព្រះករុណា!" អមាត្យចាស់តដណ្តើម
ក្រាបទូលព្រះរាជា រួចក្រាបទូលម្តងទៀតថា "សូមព្រះអង្គទ្រង់ព្រះ
រាជបញ្ជាឲ្យបញ្ឈប់នូវពិធីបូជាយ័ញ្ញនេះចេញទៅ" ។

ព្រះរាជាទ្រង់ពាក្យព្រះទ័យមួយស្របក់ធំ ទើបទ្រង់ព្រះតំរិះឃើញថា
"សូម្បីមាណពមិនអាចធ្វើឲ្យសម្រេចបានតាមពាក្យដែលបានទូលមក
ហើយ ក៏ទ្រង់ទឹងផ្តើមធ្វើពិធីនេះឡើងវិញក្នុងកាលជាខាងក្រោយ"
ហើយទ្រង់ព្រះតម្រិះតទៅទៀតថា "អមាត្យចាស់ជាមនុស្សរបស់ព្រះ
ធម្មបតីរាជាហ៊ានទទូលអះអាងដូច្នេះ កាលបើមាណពធ្វើមិនបានសម្រេច
តាមពាក្យដែលទូលនោះ ព្រះធម្មបតីរាជាក៏ទឹងត្រូវអាប់ព្រះភ័ក្ត្រ ទឹង
សាចសូន្យព្រះកិត្តិយសនៃព្រះអង្គជាអនេកប្បការ" ។

ដោយវិស័យក្សត្រិយ៍ ទើបទ្រង់ផ្តឹបព្រះពាក្យអំណាចទុក ។

"បានឮថា មាណពម្នាក់នេះជាទីត្រេកព្រះទ័យនៃព្រះធម្មបតីរាជា,
យើងទឹងល្បងមើល" ព្រះរាជាទ្រង់ព្រះចិន្តាដូច្នេះហើយក៏ទ្រង់ព្រះបញ្ជា
ឲ្យបញ្ឈប់នូវការធ្វើពិធីបូជាយ័ញ្ញនោះមួយគ្រាសិន ។

(មានត)

(តមក)

រឿងសាមកុកទុកជាប្បុន្នសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
នឹងបេះខបាយកលចំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ចូរចូរកំសៃកុតគំហកឲ្យស្ងប់ឆ័ងថា ដែលគួនអ៊ូទៅនេះព្រោះមានចិត្ត កតញ្ញូទើងទៀតជានាយចៅហ្វាយ ប្រការ១ យើងក៏បានទទួលពាក្យ ប្ដេជ្ញាឲ្យគេហើយ គេក៏បានជួនសំបុត្រនៃកលាយើងតាមគួរសម ហេតុម្ដេចមកថា នេះល្ងង់ដូច្នេះ អ្នកទាំងឡាយចូរមើលបែបយ៉ាងគួនអ៊ូចុះ ត្រូវឲ្យមានចិត្តស្រឡាញ់នាយចៅហ្វាយដូចគេនេះ ។ ឆៀយកន្ទើយថា មហាឧបាជ្ឈាយ៍អើយ គួនអ៊ូក៏ដល់ខាតហើយ គួនអ៊ូក៏ទៅមើលងាយមិនបានគោរពគ្រាបលា ហានិសារសេរសំបុត្រមកឲ្យដូច្នេះមិនគួរសោះ បើនឹងលែងគួនអ៊ូឲ្យទៅដល់អ្នកនៅវិញ ចូលទៅទឹងអួនសៀវគាលណាក៏មានចិត្តកំរើកឡើងទៀត ឧបមាដូចជាលែងខ្លាឲ្យមានកំឡាំង សុំឲ្យលោកគែណ្ដាបាននលើកតាមទៅចាប់គួនអ៊ូមកសម្លាប់ចេញ តទៅមុខទើបមិនមានចំរូងចំរៃ ។

ចូតួតបថា "យើងបានទទួលប្តេជ្ញានឹងគេទុកមកហើយ បើឥឡូវ
ទៅតាមនាំយកខ្លួនមកវិញ ក៏ឥតបានការតាមសំដីដែលនិយាយ,
ប្រការ១ ចិត្តគួនអ៊ូជាមនុស្សរក្សាសត្យសុចរិតពិតត្រង់ណាស់ អំណើះ
ទៅមុខគង់ឥតមានធ្វើអន្តរាយដល់យើងជាប្រាកដ" ហើយចូតួនិយាយ
នឹងខៀវលៀវថា យើងខំទុកបំរុងគួនអ៊ូដល់ខ្នាតប៉ុណ្ណេះហើយ គួនអ៊ូក៏មិន
ឃើញដល់យសបណ្តាស័ក្តិនឹងឲ្យសម្បត្តិ គាំងចិត្តរក្សាសេចក្តីសត្យ
ពិតត្រង់នឹងកន្លែងណាស្មើគ្មាន យើងក៏មានចិត្តគោតខ្ចាចគួនអ៊ូ ហេតុនេះ
អ្នកចូរស្រួតទៅតាមប្រាប់គួនអ៊ូចុះ ថាយើងស្រឡាញ់សេចក្តីសត្យសុចរិត
ចិត្តគួនអ៊ូដែលត្រង់ល្អដូច្នេះ យើងក៏សុំជូនដំណើរទៅដល់ភាក់តណ្តាល
ផ្លូវ ហើយនឹងឲ្យរង្វាន់ជាគ្រឿងសម្ងែកចំពោះមាសប្រាក់ ដល់គួនអ៊ូជា
គុណថែមទៀត យូរទៅ មុខជាគួនអ៊ូនឹងតបគុណយើងមិនក្រេចទេ ។

ខៀវលៀវក៏លាចូតួឡើងសេះស្រួតបញ្ជាប់តាមទៅ ចូតួក៏រៀប
ចាត់ចែងតាហានមានយកតាំងមាសប្រាក់ឲ្យរបស់ ឡើងសេះនាំ
តាហានប្រមាណ ៣០ នាក់មិនបានកាន់គ្រឿងអាវុធ ស្រួតទៅតាម
ជាគ្រាយ ។

ឯគួនអ៊ូនោះ លុះបានឮសំឡេងវៃស្រែកហៅពីក្រោយថាឲ្យឈប់សិន
គួនអ៊ូឮហើយក៏និយាយឲ្យតាហានរបស់ខ្លួនឃុំទាំរត់ទៅមុន ខ្លួនគួនអ៊ូនៅ
ការពារពីខាងក្រោយ ព្រោះមានតាហានចូតួវៃស្រែកហៅឲ្យឈប់មិនដឹង
ជាជាឫកាច ហើយគួនអ៊ូក៏ញាក់សេះឈប់ត្រឡេកទៅឃើញខៀវលៀវ
គួនអ៊ូក៏សួរទៅខៀវលៀវថា អ្នកតាមមកនឹងចាប់យើងឬ? ខៀវលៀវ

តបថា មិនមែនទេ ដ្បិតមហាឧបាសិកាបាបថា អ្នកនឹងទៅផ្សារជាប់ស្រែយាលឆ្ងាយណាស់ លោកមានចិត្តអាណិតអ្នកទើបប្រើខ្ញុំឲ្យស្រែតតាមមកឃាត់ឲ្យអ្នកឈប់សិន មហាឧបាសិកានឹងតាមមកជួនដំណើរផង គួនអ៊ូឮហើយក៏មានសេចក្តីសង្ស័យ ថ្ងៃរសៀលមកគ្រាយបញ្ឈប់នៅលើស្ពានសិន ក្រឡេកទៅឃើញចូនូលើកមហានឯកប្រហែល ៣០ នាក់ លុះចូនូទៅដល់ក៏ឲ្យមហានដំរៀបគ្នាឈរជាបែកធ្នែងស្តាំ គួនអ៊ូឃើញមហានចូនូគ្មានកាន់គ្រឿងអាវុធនៅដៃ ក៏អស់សេចក្តីសង្ស័យ ។

ចូនូក៏សួរគួនអ៊ូថា ហេតុម្តេចបានជាអ្នកឯងនិងចេញមកមិនឲ្យយើងដឹង? គួនអ៊ូក៏បន្ទន់ខ្លួនគំនាប់ដំណថា ពីដើមឡើយខ្ញុំបាទក៏ដំណមហាឧបាសិកាដែរ ដោយយល់ថា សូមប្តេជ្ញា ៣ ខ ប្រសាសន៍ក៏បានត្រមល្មមតាមបដិញ្ញាណ លុះខ្ញុំបាទបានដឹងដំណឹងឡើងហើយបានចូលទៅជំរាបលាប្រសាសន៍ដល់ ២-៣ ដង ក៏មិនបានដូចប្រាថ្នាសោះ ព្រោះអ្នកចាំទ្វារឃាត់ហាម ហើយមានពាក្យបំពាមបំទេចមកទៅមាត់ទ្វារទៀតថា ប្រសាសន៍ហាមមិនឲ្យចូល ខ្ញុំបាទក៏មានសេចក្តីតក្កាខ្លួន បង្អៀតចិត្តគិតនឹកដល់ឡើងពីជាទីបំផុត បានជាសរសេរសំបុត្រគំនាប់លាប្រគល់ឲ្យអ្នកចាំទ្វារទុកជូនប្រសាសន៍ ឯបស់ទ្រព្យជាគ្រឿងមាសប្រាក់ដែលប្រសាសន៍បានឲ្យមានខ្ញុំបាទ ហើយនឹងគ្រាសម្រាប់ដាវនោះ ខ្ញុំបាទក៏បានប្រគល់ឲ្យស្រីបំរើទុកជូនប្រសាសន៍ទាំងអស់ ដែលខ្ញុំបាទខំដោះស្រួតមកនេះប្រាថ្នានឹងឲ្យបានឃើញមុខឡើងពីដែលនិកសន្តាជាយូរហើយនោះ ហេតុ

នេះសូមប្រសាសន៍មានសេចក្តីកុណាគតដល់ពាក្យប្តេជ្ញាពីបឋម បើក
ឲ្យខ្ញុំបានទៅដោយស្រួលចុះ ។

ចូឆូថា "យើងធ្វើការសត្វថ្ងៃនេះ ដោយតាំងចិត្តប្តូរថ្នាក់អ្នកណា
ដែលកាន់ពាក្យសត្យសុចរិតត្រង់ ឲ្យដូចខ្លួនអ្នកមានចិត្តស្រឡាញ់ឡៅពី
នោះណាស់ដែរ តែកម្រិបនេះ ទើបមកឃើញអ្នកល្អត្រង់ណាស់ យើងក៏
មានចិត្តស្មោះសរស្រឡាញ់, ដែលយើងបានទទួលពាក្យប្តេជ្ញាគុនន៍អ្នក
នោះមិញ យើងក៏រក្សាពាក្យនោះឲ្យតង់ទៅមិនត្រូវឲ្យប្រែប្រួលទៅជា
ពាក្យ ២ បាន អ្នកនឹងទៅហើយយើងក៏មិនត្រូវឃាត់ទាំងឲ្យឈប់ខានទេ
តែយើងក្រែងផ្លូវដែលទៅនោះជាចំងាយស្រយាល ខ្លាចស្បៀងអាហារ
មិនគ្រប់គ្រាន់បានជាយើងតាមមកឲ្យទាន់ខឹងជូនដំណើរ ហើយដើម្បី
ទឹងយកវបស់មកធ្វើជាស្បៀងថែមទៀត" ចូឆូនិយាយហើយក៏ឲ្យ
គាហានយកមាសមួយសំពៀតចាក់លើថាសមួយ ឲ្យទៅគួនអ៊ូ។ ក៏មិន
ត្រមទទួលយកមាសនោះ ដំពាបតបទៅចូឆូវិញថា ប្តូរក់ពៀវត្រូវដែលខ្ញុំ
បាទបានទទួលព្រះរាជទាននោះ ក៏នៅមានលម្អមប្រើចាយគ្រប់គ្រាន់
ហើយ សូមមហាឧបរាជកុំព្រួយរវល់ឡើយដល់ខ្ញុំបាទចុះ សូមទុកមាស
នោះទឹងចែកឲ្យគាហានដែលបានធ្វើការខ្លឹយហត់តទៅ ។ ចូឆូក៏ថា
កាលអ្នកធ្វើការទឹងយើង អ្នកក៏មានសេចក្តីគាប់ប្រសើរច្រើនណាស់
ដែលយើងឲ្យមាស ១ ថាសនេះ ក៏មិនទាន់ជួនល្មមទឹងគុណបំណាច់អ្នក
ទេ ហេតុម្តេចបានជាអ្នកមិនទទួល? ។

គួនអ៊ូតបថា ខ្ញុំបាទទៅជ្រកកោនទឹងមហាឧបរាជ ក៏មិនបានធ្វើ

ការគាប់ប្រសើរណាស់ណាប៉ុន្មានទេ គ្រាន់តែបានយកអាសាចេញទៅ
ធ្វើការសង្គ្រាមម្ភៃដងប៉ុណ្ណោះ មិនគួរទើសចាប់ថាគាប់ប្រសើរប៉ុន្មាន ។
ចូរឆ្លុបានឮគួនអ៊ូថាដូច្នោះក៏ធ្វើយ៉ាថា "ខ្ញុំនអ្នកជាគាហានមានថ្លៃដៃខ្លាំង
ពូកែ ព្រមទាំងសេចក្តីសត្យកតញ្ញូធីរកេនណាស្មើមិនមានខ្ញុំនយើងជា
មនុស្សក់សនាទន់ បុណ្យគ្មាន ទើបមិនបានខ្ញុំនអ្នកទុកឲ្យដូចសេចក្តី
ប្រាថ្នា មាសនេះបើអ្នកមិនត្រូវការក៏ពាហ៊ីទៅចុះ ចូរខ្ញុំលយកតែអាវ
លាយមាសនេះទុកជាទីលើកកប់អាន បំណាច់យើងជូនដំណើរមកកុំ
ឲ្យបង់ពាថា" ហើយចូឆ្លុក៏ឲ្យគាហានយកអាវនោះហុចទៅឲ្យគួនអ៊ូ។ លុះ
ទើចុះពីលើសេះទំលយកអាវគាហានក៏មិនបានទុកចិត្តចូឆ្លុទេ ទើប
បង្អោនខ្ញុំនចុះហើយក៏ហុចចុងជាវទៅទំលយកអាវ មកពាក់ត្រលើ
ខ្ញុំនហើយក៏ថា "ព្រះតេជព្រះគុណមហាឧបាជ ដែលមានលើខ្ញុំនខ្ញុំ
ជាទំពីមុនមកក៏ច្រើនលើសលប់ធើរប្រៀបប្រាត្បូពុំអស់ ថែមវេលានេះ
លោកក៏បានមកតាមដូនដំណើរហើយឲ្យពាក់អាវថែមទៀត ប្រសិនបើ
ជីវិតខ្ញុំបានរស់ទៅ ខ្ញុំបានក៏ត្រូវចាំតបស្នងសងគុណមហា-
ឧបាជមិនភ្លេចឡើយ" គួនអ៊ូគំនាប់ហើយក៏លាចូឆ្លុបរសេះចេញទៅ ។

ទៅដល់ជំរុបចូឆ្លុថា គួនអ៊ូនេះព្រហើនមើលងាយមហាឧបាជណាស់
លោកបានឲ្យអាវទៅហើយក៏ហុចចុងជាវមកទំលួល ធ្វើដូច្នេះ ជាទីមាក់
ងាយហួសពេក ហេតុម្តេចបានជាលោកមិនយកទោស? ។ ចូឆ្លុថា "ដែល
ទើមិនប្រកាន់ទោសគួនអ៊ូនោះមិនបានទេ ព្រោះគេតែម្នាក់ឯង យើងគ្នា
ច្រើនជាងគេ។ មិនទុកចិត្តយើង។ បានចេញវាចាថា ឲ្យគេទៅហើយកុំយក

ទោសគេឡើយ" ហើយចូចក៏នាំតាហានទាំងពួងត្រឡប់ទៅត្រងហ៊ូគាវិញ ចេះតែសរសើរគួនអ៊ូថា មានសេចក្តីសត្យពិតត្រង់មិនដាច់ព័ទ្ធ ។

ឯគួនអ៊ូនៅចម្ងាយផ្លូវប្រហែល ៣០០ សិន (១២ គ.ម.) មិនឃើញរថបង់ថ្លៃសោះ គួនអ៊ូក៏ភ័យស្ទុះចិត្តត្រឡែកមើលទៅខាងណាក៏មិនឃើញ ខ្លួលឮសំឡេងស្រែកមកពីលើភ្នំថា គួនអ៊ូឈប់សិន ! ។ គួនអ៊ូត្រឡែកទៅឃើញតាហានកំឡោះតូចដួតក្បាលលឿង ពាក់អាវលាយមាស ដឹះសេះកាន់ខ្លួនយកក្បាលមនុស្សចង់សេះ នាំប័ក្សពួកប្រហែល ១០០ ជ្វាយ ចុះមកខ្លឹមមុខគួនអ៊ូ។ សួរថា អ្នកឯងឈ្មោះអ្វី ។ មកពីណា ? ឈ្មោះនោះចុះពីលើសេះចោះខ្លួនចេញ ហើយលុតជង្គង់គំនាប់គួនអ៊ូថា "ខ្ញុំបាទឈ្មោះលៀវហួនៅស្រុកសុងយ៉ង កាលគ្រាចោរដួតក្បាលលឿង ខ្ញុំបាទក៏បែកមកនៅកង់ក្នុងនេះ ប្រមូលតាហានបានប្រហែល ៥០០ ជ្វាយ ពាយដណ្តើមយកស្រូវអង្ករចំណីអាហារគេចរិគោគចិញ្ចឹមជីវិត តៅអ្នកនាយចោរជាសំឡាញ់ខ្ញុំបាទ លើកពួកមកចុះមកពាយដណ្តើមយកបានស្រី ២ នាក់ ខ្ញុំបាទសោកស្តាយមនុស្សដែលធ្វើដំណើរមកជាមួយ គេប្រាប់ថា កវិយាឡៅពីមកជាមួយនឹងលោក ខ្ញុំបាទថានឹងយកជូនឲ្យលោក, តៅអ្នកមិនព្រម ខ្ញុំបាទក៏សម្លាប់តៅអ្នកចេញ កាត់ក្បាលនាំយកមកជូនលោក, កវិយាឡៅពីរនាក់នោះ ខ្ញុំបាទឲ្យតាហានយុំនាំមកជាគ្រោយ," ខ្លួលពួកចោរនាំរថមកដល់ ។

គួនអ៊ូក៏ចុះពីលើសេះទៅគំនាប់បង់ថ្លៃទាំង ២ ហើយថាដែលអ្នកជាបង់មានសេចក្តីភ័យខ្លាច នោះគេសខ្ញុំបាទខុសធ្ងន់ណាស់ ។ បង់ថ្លៃ

ចាំង ២ ក៏និយាយថា កាលចោរវៅនាំបងវៅលើភ្នំនោះ បើកុំតែលឿវហួ
មកជួយ បងក៏ទឹងមានសេចក្តីអន្តរាយ ។ គួនអ៊ូក៏សួរវៅតាហានដែល
ធ្វើដំណើរជាមួយថា កាលចោរនាំវៅនោះ ហេតុម្តេចបានជាលឿវហួ
មកជួយ? ។ ពួកតាហានឆ្លើយថា កាលខ្ញុំបាទយុំនាំវៅនោះ យើញ
តៅអ្នួនយុំនាំពួកចោរចុះមកនាំយកវង្វេងវៅលើភ្នំ ហើយប្រាប់លឿវហួ
ថា បានស្រែមក ២ នាក់ ទឹងបែកឲ្យជាកំយោលឿវហួម្នាក់ លឿវហួ
សួរខ្ញុំថា ស្រែ ២ នាក់នេះជាកំយោអ្នកឯណា ? ខ្ញុំបានប្រាប់ថា ជាកំយោ
ឡៅព័ គួនអ៊ូជាប្អូនយុំនាំមកទឹងវៅកន្លែងឯស្រែកគីជីវ លឿវហួក៏
និយាយទឹងតៅអ្នួនថា ឲ្យនាំអ្នកស្រែមកជូនលោកវិញ តៅអ៊ូនមិនព្រម
ធ្វើតាម លឿវហួទឹងក៏សម្លាប់តៅអ្នួនស្លាប់ ហើយឲ្យពួកម៉ាកយុំនាំវង្វេចុះ
មកនេះ ។

គួនអ៊ូបានស្តាប់ហើយក៏មានចិត្តត្រេកអរណាស់ គំនាប់លឿវហួ
ហើយថា ដែលអ្នកបានធ្វើគុណទុកដល់យើងគ្រានេះ យើងមានសេចក្តី
ត្រេកអរពន់ប្រមាណណាស់ បើដំរិតយើងមិនស្លាប់ យើងបានជួបច្រទះ
ទឹងអ្នកវេលាណា យើងនឹងជួយទូបត្ថម្ភតបស្នងសងគុណអ្នកវិញ ។

លឿវហួនិយាយទឹងគួនអ៊ូថា ដែលលោកទឹងវៅឯមុខនោះជាផ្លូវ
ឆ្ងាយដាច់ស្រយាលណាស់ ខ្ញុំបានសុំលើកតាហានតាមជូនលោកវៅ
ត្រាតែផុតដែនស្រែកហ៊ូតោ ។ គួនអ៊ូឮហើយក៏គិតតែកងចិត្តថា "លឿវហួ
នេះជាចោរដួតក្បាលលឿង បើយើងឲ្យវាយុំនាំបក្សពួកជូនយើងវៅ អ្នក
ស្រែកតាមផ្លូវទឹងតវាហានិង្ខាថា យើងគប់ទឹងពួកចោរ" គួនអ៊ូក៏និយាយ

ទីឯលៀវហួថា ដែលអ្នកទីឯជូនយើងទៅ យើងក៏អរគុណណាស់ហើយ កុំឲ្យអ្នកព្រួយ ទីឯជូនយើងទៅឲ្យលំបាកឡើយ ។ លៀវហួក៏យកមាសទៅឱ្យគួនអ៊ូ។ មិនព្រមទទួល តបថា បើសន់នេះអ្នកយកទុកចុះ ។

លៀវហួក៏ណាគួនអ៊ូនាំពួកចោរត្រឡប់ទៅលំនៅលើភ្នំនោះវិញ ។ គួនអ៊ូក៏អធិប្បាយឲ្យបងថ្លៃទាំង ២ ស្តាប់ អំពីបុព្វកម្មកាលមកជួនដំណើរនោះ ហើយក៏បង្គំឲ្យបរបថទៅតាមផ្លូវ លុះគេលះសៀលល្ងាចឃើញផ្ទះនៅតំបន់ ១ គួនអ៊ូក៏នាំបងថ្លៃចូលទៅសុំសំណាក់ ។ ឈ្មោះហាហួជាម្ចាស់ផ្ទះនោះអាយុចាស់ជាង សក់ទីពុកមាត់ពុកចង្កាសុទ្ធតែទាំងអស់ លុះឃើញគួនអ៊ូទៅដល់ក៏ចេញទៅទទួលដោយសប្បុរសហើយសួរថា អ្នកឈ្មោះអ្វី? មកពីណាទៅណា? ។ គួនអ៊ូប្រាប់ថា ខ្ញុំឈ្មោះគួនអ៊ូ ជាប្អូនឡៅពីខ្ញុំទីឯទៅរកបងឯស្រែកគីដីវ ។

ហោក្លេសួរថា ខ្ញុំនអ្នកនេះហើយឬ? ដែលសម្លាប់ឆាន់លៀង ប៊ុនធីវ តាហាតានឯកអ្វីនសៀវ? ។ គួនអ៊ូឆ្លើយថា ចាន ខ្ញុំនេះឯង ។ ហោហួបានស្តាប់ ក៏មានចិត្តត្រេកអរណាស់ ទើបថា អញ្ជើញអ្នកចូលទៅក្នុងផ្ទះចុះ ។ គួនអ៊ូថា បងថ្លៃខ្ញុំទាំង ២ នៅឯស្រែ ។ ហោហួគ៏ហៅបុត្រទីឯកវិយាឲ្យចុះទៅទទួលគួរសម នាំកវិយៃឡៅពីឡើងមកហើយក៏នាំចូលទៅខាងក្នុង ហោហួក៏អញ្ជើញគួនអ៊ូទីឯនាងទាំង ២ ឲ្យបរិភោគអាហារជាមួយគ្នា ។ គួនអ៊ូថា ខ្ញុំទីឯអង្គុយទទួមទីឯបងថ្លៃនោះមិនគួរ ។ ហោហួក៏ឲ្យអញ្ជើញនាងទាំង ២ ចូលទៅបរិភោគខាងក្នុង រៀបឲ្យគួនអ៊ូទីឯហោហួទៅបរិភោគខាងក្រៅ ។

(មានរ)

រឿងព្រេងនិទាន

លោកសមិនមូត្យនជីមៈតែង
លោកវ៉ាយ-ប៊ុក ក្រមការ ដើមខ្សែប្រៃរៀបរៀង

(តមក)

ទិទានទៃរូបទេពធិម្មិតទី ២១

មានកាលមួយវេលា រូបទេពធិម្មិតទី ២១ បានឃើញព្រះបាទកោដៈ ស្តេចចូលទៅជិតបល្ល័ង្កធិព្យ ក៏ក្រាបបង្គំទូលថា: បពិត្រមហាកដកោដៈ សូមទ្រង់ព្រះសណ្តាប់ នូវព្រះមហាសប្បុរិសធម៌នៃព្រះបាទវិក្រមាទិត្យ ដែលទ្រង់មានព្រះពជសមត្ថភាព អាចគង់នៅលើព្រះបល្ល័ង្កធិព្យនេះបាន ដូចតទៅនេះ ៖

"កន្លងថ្ងៃមួយ ដើម្បីទ្រង់ទតនូវតថាអច្ឆរិយភាពឯប្រទេសនានាព្រះបាទវិក្រមាទិត្យទ្រង់ព្រះសុពណ៌ថាទិព្វ ទ្រង់ស្តេចហោះធ្វើព្រះពជ-ទស្សនាការតាមស្រុកទឹកមជ្ឈមជនបទនៅក្នុងព្រះពជអាណាចក្រ ៗ ទ្រង់ស្តេចយាងទៅដល់នគរមួយ ទ្រង់គំណប់ប្រថាប់នៅទីនោះ ត្រង់ខាងមុខបូជនីយដ្ឋានមួយ ។ កន្លងពេលនោះ ទ្រង់កំពុងធ្វើអញ្ជលីកម្ម ប្រទក្សិណដុំវិញបូជនីយដ្ឋាននោះ ក៏ស្រាប់តែមានជនបរទេសម្នាក់ទៅដល់ទីនោះដែរ ។ ជនបរទេសបានឃើញព្រះបាទវិក្រមាទិត្យ ក៏ក្រាបបង្គំទូលថា ៖ បពិត្រព្រះមហាសប្បុរស, ទូលព្រះបង្គំបានយល់ឃើញថាទ្រង់ជាមហាពជប្រកបដោយព្រះគុណសម្បត្តិជាសុត្រិតភាព; បានជាទូល

ព្រះបង្គំយល់ថា ខ្ញុំជាកូដជាពូជស្តេច ។ បើព្រះមហាក្សត្រអង្គណា
លែងមានព្រះពលតម្រិះដល់ព្រះពលអាណាចក្ររបស់ព្រះអង្គ ហើយខ្ញុំ
ស្តេចយាងក្រសាលទៅប្រទេសដទៃ ព្រះពលអាណាចក្រនៃព្រះមហា-
ក្សត្រនោះនឹងមិនបានបំផ្លាញរាលរាយទៅអនាគតឡើយ ។ ព្រះពល-
ករណីយកិច្ចគ្រប់យ៉ាងសម្រាប់ព្រះមហាក្សត្រគឺខ្ញុំលះបង់ ខ្ញុំគ្រាន់
តែមានព្រះពលតម្រិះទៅកាន់សម្បូណ៌ភាព ឬហាយនភាព នៃព្រះ
អាណាចក្រប៉ុណ្ណោះ ។ ព្រះចុងក្រមាទីត្យ ខ្ញុំព្រះសណ្តាប់ធ្នូវពាក្យ
ពោលរបស់ជនបរទេសនោះ ខ្ញុំក៏មានព្រះពលន្ទូរតបវិញថា: " ឧ
បុរស ! បើគ្មានច្បាប់ទេ, ព្រះមហាក្សត្រអង្គណា មើខុកជាខ្ញុំព្រះតម្រិះ
ទៅកាន់សម្បូណ៌ភាព ឬហាយនភាពនៃព្រះពលអាណាចក្រយ៉ាងណាក៏
ដោយ, ព្រះពលអាណាចក្រនៃព្រះហាក្សត្រនោះក៏មិនអាចបំផ្លាញរាល
រាលបានឡើយ ។ មួយទៀត បើព្រះមហាក្សត្រអង្គណាមិនព្រមប្រតិបត្តិ
តាមបទបញ្ញត្តិច្បាប់ទេ មើខុកជាខ្ញុំមានព្រះតម្រិះទៅកាន់សម្បូណ៌ភាព
ឬហាយនភាពនៃរដ្ឋព្រះអង្គក៏ដោយ ក៏ព្រះពលគេជាខ្មាតនៃព្រះមហា-
ក្សត្រអង្គនោះ ឬព្រះពលអាណាចក្ររបស់ព្រះអង្គ នឹងមិនអាចបំផ្លាញ
បាន ។ តាមសភាពផ្ទុយទៅវិញ, បើព្រះមហាក្សត្រអង្គណា បាន
ប្រតិបត្តិតាមច្បាប់ដោយទៀងត្រង់, ខ្ញុំមិនចាំបាច់ព្រះតម្រិះពីសម្បូណ៌ភាព
ឬហាយនភាពនៃអាណាខ្លួនក្នុងប្រទេសទេ ព្រះពលអាណាចក្រនៃ
ព្រះមហាក្សត្រនោះនឹងអាចបំផ្លាញទៅបានដោយពលភាពនៃច្បាប់ ។
ព្រោះហេតុនេះ . ដើម្បីនឹងធ្វើព្រះពលអាណាចក្រឲ្យមានសភាពរឹងប៉ឹង

ឡើង, ត្រូវព្រះមហាក្សត្រអនុវត្តន៍តាមបទបញ្ជាត្តិច្បាប់, គឺច្បាប់នេះឯង ហើយដែលព្រះមហាក្សត្រត្រូវប្រតិបត្តិ ។ ចំណែកខាងយើង ដែលធ្វើដំណើរមកកាន់ទីនេះក៏ដោយហេតុបទបញ្ជាត្តិច្បាប់, យើងអាចដឹងបានថាអ្នកឯងមកនេះដើម្បីនឹងប្រព្រឹត្តនូវសកម្មភាពអ្វីមួយជាប្រាកដ" ។

ជនបរទេសបានស្តាប់នូវព្រះពាក្យរាជឫទ្ធានុភាពព្រះបាទវិក្រមាទិត្យ ក៏ក្រាបបង្គំទូលថា: "បពិត្រព្រះសម្មតិទេព, ខ្ញុំមានព្រះពាក្យហ្លួងយ៉ាប់ខ្លួននឹងច្បាប់ជាយ៉ាងខ្លាំងខ្លះ, ល្អហើយ ! ខ្ញុំបានមានព្រះឫទ្ធានុភាពទូលព្រះបង្គំដែលមកកាន់ទីនេះ ដើម្បីនឹងប្រព្រឹត្តសកម្មភាព នោះត្រូវហើយ !" ។ ព្រះបាទវិក្រមាទិត្យខ្ញុំមានព្រះបន្ទូលនឹងជនបរទេសថា: "ចូរអ្នកនិយាយមកចុះ តើទ្យើយើងធ្វើអ្វី?" ។ បុរសក៏ក្រាបបង្គំទូលថា: "បពិត្រព្រះចមពល នៅលើកំនិល (Nila) មានខាងខេត្តតាមួយអង្គនាម កាមខ្យា (Kamakbya), ទូលព្រះបង្គំជាខ្ញុំបានសូត្រមន្តថ្វាយបង្គំព្រះនាងកាមខ្យានេះអស់រយៈពេល ១២ ឆ្នាំ ដើម្បីឲ្យបានសម្រេចនូវសេចក្តីស្នេហានឹងមនោសញ្ចេតនាផ្សេងៗ តែមិនបានដូចបំណងសោះ ព្រោះហេតុនេះបានជាទូលព្រះបង្គំមានចិត្តព្រួយជាខ្លាំង" ។

ព្រះបាទវិក្រមាទិត្យខ្ញុំព្រះសណ្តាប់នូវពាក្យបុរសហើយ ខ្ញុំក៏មានព្រះតម្រិះក្នុងព្រះពាក្យហ្លួងថា "បុរសនេះបានសូត្រមន្តជាច្រើនលើកហើយមិនបានសម្រេច ប្រហែលជាមានហេតុអ្វីមួយជាពិសេសគួរ" ។

ដល់ខ្ញុំព្រះតម្រិះយ៉ាងនេះហើយ, ខ្ញុំក៏នាំបុរសនោះហោះទៅកាន់កំនិលជាមួយព្រះអង្គ, ដ៏តបូដនីយដ្ឋាននៃនាងខេត្តតា "កាមខ្យា"

ហើយ ខ្ញុំឈប់ប្រថាប់នៅទីនោះ ។ ដល់ពេលយប់ ខ្ញុំក៏ផ្តើលក់ ខ្ញុំបានសុបិននិមិត្តឃើញនាងទេវធីតា "កាមវ្យា" មកគាបបង្គំទូល ព្រះអង្គថា "បពិត្រមហាកប, ហេតុដូចម្តេចបានជាព្រះអង្គខ្ញុំស្តេចយាងមកកាន់ទីនេះ? បើខ្ញុំស្តេចយាងមកនេះដោយហេតុមនោសញ្ចេតនានៃបុរសនោះ ដែលសុំពរសព្វសាធុការឲ្យបានសម្រេចដូចបំណង, សូមខ្ញុំធ្វើពលិកម្មចំពោះទូលព្រះបង្គំ ខ្ញុំរមែងសម្លាប់ដែលមានរូបលក្ខណៈ ជារូបទង់ជ័យពេជ្រ, ជន្លួញ . . . ល . . . គឺបុរសមានរូបលក្ខណៈដ៏ឃ្លាំង ដែលបានចារកត់ក្នុងគម្ពីរសាមុទ្រកសាស្ត្រ (Sâmudrakacâstra), ពរនោះទើបនឹងបានសម្រេចទៅតាមបំណងមិនខាន" ។ ព្រះបាទវិក្រមាទិត្យ. ក្រោយដែលខ្ញុំព្រះសុបិននិមិត្ត, ខ្ញុំតើនឡើងពីក្រឡាព្រះបន្ទំ ខ្ញុំព្រះពស្ត្រ ហើយខ្ញុំព្រះពាដតម្រិះថា: "ក្រៅតែពីខ្លួនអញចេញ, គ្មានបុរសណាមានរូបលក្ខណៈគាំង ២០ ប្រការនេះសោះឡើយ គឺព្រះនាងសំដៅយកអញនេះឯងធ្វើពលិកម្ម ដើម្បីនឹងអនុគ្រោះដល់បុរសនោះ" ។

កាលខ្ញុំព្រះតម្រិះដូច្នោះហើយ, លុះដល់ពេលបច្ចូសសម័យ ខ្ញុំស្តេចយាងទៅស្រង់ព្រះទន្តៈ ខ្ញុំសូត្រមន្តធ្វើអញ្ជលីកម្មសព្វគ្រប់ ហើយខ្ញុំគាន់ព្រះទ័នថ្វា ទើបខ្ញុំវែកប្រកាសជាទន្ទ្រាំកថា សូមយកខ្ញុំធ្វើពលីកម្មចំពោះព្រះនាងទេវធីតាចុះ ។ ព្រះនាងក៏បង្ហាញខ្លួរូបជាក់ច្បាស់ ចំពោះភ្នែកខ្ញុំ, ព្រះនាងបានគាន់ព្រះហស្តព្រះអង្គគាំងពីរ រួចទូលថា: "បពិត្រព្រះអធិកប, ព្រះអង្គខ្ញុំ

ជាមហាបុរសផ្សែកពីជនធម្មតា, ទ្រង់មានព្រះពាជប្អូនស្ងួនខ្ញាប់ខ្ជួនចំពោះ ច្បាប់ ដោយគ្មានអ្នកណាមួយដូចព្រះអង្គ, ខ្ញុំម្ចាស់បង់ដឹង តើពលីកម្ម របស់ព្រះអង្គត្រឹមណា, បានជាខ្ញុំម្ចាស់មកសំដែងអាការៈកង់សុបិននិមិត្ត ចំពោះព្រះអង្គ; តទ្បាវខ្ញុំម្ចាស់បានដឹងសព្វគ្រប់ហើយ, ព្រះអង្គមិនបាច់ យកព្រះរូបព្រះអង្គធ្វើមហាយ័ញ្ញៈទ ខ្ញុំម្ចាស់សូមព្រះអង្គមានព្រះពាជទុង្ការ ចុះ តើទ្រង់សព្វព្រះពាជប្អូនយ៉ាងម៉ាន់ម៉ានអ្វី?" ។ មហាពាជទ្រង់មានព្រះ បន្ទូលតបថា: "នុនាង៎ទេវធីតា, បើនាង៎សប្បាយចិត្តនឹងខ្ញុំ។ សុំឲ្យនាង៎ សម្រែចនូវមនោសញ្ចេតនានៃបុរសនេះឲ្យបានតាមបំណង៎ចុះ" ។ ព្រះ នាង៎ទ្រង់សណ្តាប់នូវព្រះបន្ទូលរបស់ព្រះអង្គហើយ ក៏បានញុំង៎បុរស នោះឲ្យសម្រែចទៅតាមបំណង៎ ហើយព្រះនាង៎ក៏បាត់ខ្លួនពីទីនោះទៅ ។ ដោយសេចក្តីអនុគ្រោះព្រះនាង៎ទេវធីតា, មនោសញ្ចេតនាទាំង ៩ ប្រការ ក៏បំពេញខ្ជាប់ខ្ជួនទៅក្នុង៎ចិត្តបុរស គឺ ស្នេហា ១, វិរាគៈ ១, មុទិតា ១, ការធ្លាល់ ១, ការសប្បាយ ១, ការព្យាយាម ១, ការខ្ចីមរអើម ១, ទោមនស្ស ១, សោចៈ ១ ។ ចំណែកឯមហាពាជ, ទ្រង់ក៏ស្តេចលិ តត្បាប់ទៅកាន់ព្រះពាជនិវេសនដ្ឋានវិញ ។

រួចទេពនិមិត្តទី ២១ ទូលបន្ថែមថា: "មហាក្សត្រិយ៍កោជៈ: បើ ទ្រង់មានព្រះពាជប្អូនយ៉ាងអនុគ្រោះអ្នកដទៃបែបនេះ ទ្រង់អាចនឹងតង់ទៅ លើព្រះបល្ល័ង្កទិព្យនេះបាន" ។

ព្រះបាទកោជៈ: ទ្រង់ព្រះសណ្តាប់នូវព្រះបន្ទូលនៃរួចទេពនិមិត្ត ទីម្តងមួយហើយ ទ្រង់ក៏ស្តេចចេញពីទីនោះទៅ ។ (មានត)

*
* *

កំណាត់ឧទ្ធរត្តិការណ៍

សេចក្តីកត់ហេតុ

អំពីព្រឹត្តិការណ៍បុណ្យពាក់ព័ន្ធសាសនាព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា ដែលត្រូវធ្វើក្នុងថ្ងៃ ១៥ កើតខែពិសាខ ឆ្នាំរកានព្វស័ក (១៣ ឧសភា ១៩៥៧)

របស់ក្រសួងធម្មការ

ឆ្នាំមួយពាន់ប្រាំបួនរយហាសិបប្រាំមួយ ខែមករា ថ្ងៃទី២ខែក្រុម្ភៈ ត្រូវនឹងថ្ងៃដប់បីកើត ខែមាឃ ឆ្នាំមមែ ព. ស. ពីរពាន់ប្រាំបួនរយកៅសិបប្រាំបី វេលាម៉ោង៩ព្រឹក សាមសិបនាទី ។

នៅមន្ទីរស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ, សមាជិកគណៈកម្មការដែលកើតឡើងដោយអំណាចប្រកាសក្រសួងនាយករដ្ឋមន្ត្រីលេខ ៤.៨៥៨ ចុះថ្ងៃទី ១៣ ខែធ្នូ គ. ស. ១៩៥៥ បានមកប្រជុំក្រោមអធិបតីភាពនៃលោក ខៀវ-រ៉ាញ រដ្ឋលេខាធិការក្រសួងធម្មការ សាសនសិក្សាធិការ។ សមាជិកដែលបានមកប្រជុំក្នុងពេលនោះមានសមាសភាពដូចតទៅនេះ :

– លោក ខៀវ-រ៉ាញ រដ្ឋលេខាធិការក្រសួងធម្មការជាប្រធាន;

– សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ ជាសមាជិក;

– ព្រះធម្មវិត្រៃលោកាចារ្យ ប៊ិត សីលោ តំណាងសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិ ជាសមាជិក;

- លោក ភ័យ-ល្មុត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ តំណាងពុទ្ធិកសមាគមកម្ពុជរដ្ឋ ជាសមាជិក;

- លោក ភ័យ-ប៊ុក នាយប៉ុយរ៉ូក្រសួងយោសនាការតំណាងសមាគមមិត្តពុទ្ធិកវិទ្យាល័យ ជាសមាជិក;

- លោក អ៊ុន-សាអឿន អនុរដ្ឋមន្ត្រី តំណាងក្រសួងមហាផ្ទៃ ជាសមាជិក;

- លោក ឡាំថាញ់-ស៊ី នាយការិយាល័យក្រសួងហិរញ្ញវត្ថុ តំណាងក្រសួងហិរញ្ញវត្ថុ ជាសមាជិក;

- លោក លឿង-ណាល់ ភូឈួយខែត្រសៀមរាប តំណាងឯកទូតមកជប្រតិភូប្រចាំខែត្រសៀមរាប ជាសមាជិក;

- លោក ហែម-ចំរើន នាយកជាតិមន្ទីរទេសចរ ជាសមាជិក;

- លោក អំ-ម៉ន ហៅ ចាំសុង តំណាងរដ្ឋមន្ត្រីក្រសួងការបរទេស ជាសមាជិក;

- លោក ខន់ កាន់ តំណាងឧបាសកខាងគណៈធម្មយុត្តិ ជាសមាជិក;

- លោក ម៉ី-ខាង តំណាងឧបាសកខាងគណៈមហានិកាយ ជាសមាជិក;

- លោក ម៉ៅ-គាអុន នាយការិយាល័យក្រសួងធម្មការ ជាលេខាធិការ ។

លុះដួចដុំហើយ លោក ទ្រិញ · ភ័ញ ប្រធានបានថើតពេលប្រជុំ ដោយមានថ្លែងអំណរគុណ ចំពោះសម្តេចនឹងអស់លោកជាសមាជិក ជាមុន រួចហើយ លោកមានប្រសាសន៍រៀបរាប់អំពីរបៀបរាប់ដែលត្រូវយកមកជូនសន្និបាតពិភាក្សា ដោយបានលើកយកអត្ថន័យនៃប្រកាសក្រសួងនាយករដ្ឋមន្ត្រី លេខ ៤.៨៩៨ ខាងលើមកពិតទូល ដំរាបសម្តេចនឹងអស់លោកជាសមាជិកតាមន័យដូចតទៅនេះ:

សូមពិត ទូល សម្តេច !

សូមជំរាប អស់លោក !

តាមអត្ថន័យនៃប្រកាសខាងលើនេះ កើតឡើងក្នុងជំនាន់រដ្ឋាភិបាលសម្តេចព្រះនរោត្តម សីហនុ ព្រះអង្គបានឆ្លងព្រះរាជហ្វូរ័យ ជាទំនៀមប្រពៃណីបុណ្យភាក់កណ្តាលព្រះពុទ្ធសាសនា នៅខែកន្ទួលអគ្គិវត្ត ខែត្រសៀមរាប ហើយសុំឲ្យគណៈកម្មការគ្រប់គ្រងការអំពីមុខប្រាក់ចំណាយទំនិញការអញ្ជើញអ្នកបរទេស ឬប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា ទំនិញប្រទេសជាមិត្តកក្តិឲ្យមកជាភ្ញៀវយើងក្នុងពេលបុណ្យនេះ ។

អំពីទឹកឆ្លងបុណ្យ

នៅខាងដើមនៃសេចក្តីពិភាក្សានេះ ខ្ញុំព្រះករុណា · ខ្ញុំសូមឲ្យទីប្រជុំពិភាក្សាអំពីកន្លែងសម្រាប់ធ្វើបុណ្យជាមុន តើគួរយកអគ្គិវត្តតាមព្រះរាជឆន្ទៈនៃសម្តេចព្រះនរោត្តមឬយ៉ាងណា ?

លោក លឿង · ណាល់ថា ទឹកន្លែងនេះប្រពៃណាស់ហើយ ព្រោះ

ជាគោលចារិកនៃប្រទេសខ្មែរសម័យឯកភាជ្ញសម្បូណ៌, តែមានសេចក្តីលំបាកយ៉ាងខ្លាំងក្នុងការទទួលក្បៀវ ព្រោះខ្លះផ្ទះជាកន្លែងទទួលក្បៀវខ្លះទឹកប្រែជ្រាស់ ខ្លះក្តៅ ហើយមានឧបសគ្គមួយទៀត គឺថាពួកខ្មែរយើងពីខែត្រដទៃ ដែលត្រូវការទៅមើលបុណ្យនោះ មិនដឹងជាទៅអាស្រ័យកន្លែងណា ព្រោះខែត្រសៀមកាបនេះ ខ្ញុំតែងប្រទះឃើញក្នុងពេលបួលផ្ទាំម្តង ។ ទ្វារពួកអ្នកពីខែត្រក្រៅដែលទៅមើលអង្គរហើយគ្មានស្គាល់គេ តែងឃើញអាស្រ័យដំណេកក្រោមម្ងប់ឈើតាគ្រែខ្លះ ឃើញថាលំបាកក្រៃលែងក្នុងការទទួលក្បៀវ តែស្រេចលើសម្តេចនឹងអស់លោកពិចារណាតទៅទៀតចុះ ។

លោក ខ្វែញ - ភ័ញ មានប្រសាសន៍ថា បើដូច្នេះ សូមសម្តេចនឹងអស់លោកដំណាលម្តងទៀត ទ្វារកន្លែងសម្រាប់ធ្វើបុណ្យ ។

សម្តេចព្រះសង្ឃនាយកគណៈមហានិកាយ នឹងលោក ប៉ាយ - លុត ក៏មានយោបល់ស្របគ្នាថា បើគិតពីសេចក្តីលំបាកយើញថាពិតមែនហើយ តែគួរគោរពតាមព្រះពាជបំណងនៃសម្តេចព្រះឧបយុវរាជដែលព្រះអង្គបានផ្តួចផ្តើមកហើយ ។

លោកប្រធានសួរថា បើដូច្នេះ អស់លោកយល់ដូចម្តេច ?

អស់លោកជាសមាជិកទាំងអស់មានយោបល់ស្របតាមសម្តេច នឹងលោក ប៉ាយ-លុត បានអនុមតិយកអង្គរ ខែត្រសៀមកាបជាទីកន្លែងបុណ្យ ។

អំពីការតាំងគណៈកម្មាធិការនាយកធ្វើបុណ្យ

លោកប្រធានថា គួរយកកន្ទែងណានៅអគ្គវត្តធ្វើជាកន្ទែងបុណ្យ? ។

លោកហែម - ចំរើនថា ត្រូវយកអគ្គវត្តជាកន្ទែងធ្វើបុណ្យ ព្រោះមានទឹកដីតផង ស្អាតល្អផង ជិតទីក្រុងសៀមរាបផង ។ សមាជិកទាំងអស់យល់ស្របតាមលោក ហែម - ចំរើន ។

លោកប្រធានសួរថា បើមានយោបល់ស្របគ្នាថាយកកន្ទែងអគ្គវត្តដូច្នេះហើយ សូមអស់លោកនឹងសម្តែងមេត្តាជ្រើសរើសរូបឥស្សរជន ឬបុគ្គលិក ដើម្បីជ្រើសតាំងជាសមាជិកគណៈកម្មាធិការនាយក ១ ក្រុមសម្រាប់ចាត់ការបុណ្យនេះ តើគួរយកប៉ុន្មានរូប?

សម្តេចព្រះសង្ឃនាយកថា គួររើសតាំងចំនួន ២០ រូប ហើយត្រូវរើសតែឥស្សរៈជនឬបុគ្គលិកពជការដែលមានសមត្ថភាព ព្រមទាំងមានសេចក្តីព្យាយាមឲ្យបានម៉ឺងម៉ាត់ល្អ កុំឲ្យឈរតែឈ្មោះទទេហើយមិនព្រមជួយធ្វើការនោះមិនកើតទេ ។

ក្រុមសន្និបាតយល់ស្របតាមសម្តេច ។ បន្ទាប់តទៅទៀត ក្រុមសន្និបាត បានពិភាក្សាអំពីការជ្រើសរើសរូបឥស្សរជនឲ្យធ្វើជាសមាជិកគណៈកម្មាធិការនាយកសម្រាប់ចាត់ការបុណ្យនេះ ។ ក្រុមសន្និបាតបានសម្រេចជ្រើសរើសរូបឥស្សរជនមានសមាសភាពដូចតទៅនេះ:

១- លោកវរជ្ញទ្ធិក្រសួងធម្មការ ជាប្រធាន;

២- សម្តេចព្រះសង្ឃនាយកតាំង ៤ គណៈ ជាអនុប្រធានកិត្តិយស;

៣- លោកវេជ្ជបណ្ឌិតសួង មហាផ្នែកប្តូតំណាង ជាអនុប្រធាន;

៤- លោកវេជ្ជបណ្ឌិតសួង សាធារណការប្តូតំណាង ជាអនុប្រធាន,

៥- លោក ហែម - ចំរើន នាយកជាតិមន្ទីរទេសចរ ជាអនុប្រធាន,

៦- លោកវេជ្ជបណ្ឌិតសួង យោសនាការប្តូតំណាង ជាសមាជិក,

៧ លោកវេជ្ជបណ្ឌិតសួង ការបរទេសប្តូតំណាង "

៨- លោកវេជ្ជបណ្ឌិតសួង ហិរញ្ញវត្ថុប្តូតំណាង ជាសមាជិក

៩- លោកវេជ្ជបណ្ឌិតសួង សិក្សាធិការប្តូតំណាង "

១០- លោកវេជ្ជបណ្ឌិតសួង ពាណិជ្ជកម្មប្តូតំណាង "

១១- លោកវេជ្ជបណ្ឌិតសួង សុខាភិបាលប្តូតំណាង "

១២- លោកវេជ្ជបណ្ឌិតសួង យុត្តិធម៌ប្តូតំណាង "

១៣- នាយកវិទ្យុតេសៀមរាបប្តូតំណាង "

១៤- ប្រធានពុទ្ធិកសមាគមកម្ពុជវដ្ឋ "

១៥- ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ "

១៦- ខាងក្រមគង្គារុក្ខានឹងប្រមាញ់ "

១៧- ខាងព្រះបរមរាជវាំង ១ រូប "

១៨- ខាងក្រមសុរិយោដី ១ រូប "

១៩- យកខាងអ្នកជំនួញ ៤ រូប គឺខាងគណៈធម្មយុត្តិ

៤ រូប ខាងគណៈមហានិកាយ ២ រូប "

២០- ខាងតំណាងកសិករ ២ រូប "

๒๑ – ខាងក្រុមប្រឹក្សាព្រះពុទ្ធសាសនាចក្រ ២ រូប សមាជិក ។

អំពីការជ្រើសតាំងសមាជិកគណៈកម្មាធិការនាយកដែលបានតម្រូវ
ទៅលើគ្រប់ក្រសួងវដ្ដមន្ត្រីខាងលើនេះ ក្រុមសន្និបាតបានសម្រេច
ប្រគល់ការៈឲ្យលោការដ្ឋមន្ត្រីក្រសួងធម្មការ ដែលមានឋានៈជាប្រធាន
តាមប្រកាសក្រសួងនាយករដ្ឋមន្ត្រីខាងលើនេះ ខ្លួលការៈធ្វើចុតហ្វាយ
ទៅគ្រប់ក្រសួងសុំតំណាង ១ រូប ដែលមានសមត្ថកាពគ្រប់គ្រាន់ធឹងមាន
សេចក្ដីព្យាយាមជួយចំរេញមុខការគណៈកម្មាធិការនាយក ឲ្យបានចំរើន
លឿនទៅមុខតាមគ្រោងការដែលត្រូវចាត់ ។ តមកទៀតក្រុមសន្និបាត
បានសម្រេចមូលម័តថា ឲ្យតាំងគណៈកម្មការរងមួយក្រុមទៀត ដើម្បី
ជួយចាត់ការគណៈកម្មាធិការនាយក, គណៈកម្មការរងនេះត្រូវយកលោក
ចៅហ្វាយខែត្រឧទ្ទរមួយ ។ ឲ្យធ្វើជាប្រធាន, ឯសមាជិកត្រូវរើសកងវែខែត្រ
តាមយោបល់យល់ឃើញនៃចៅហ្វាយខែត្រ ដែលតម្រូវលើបុគ្គលិក
គ្រាមនុវាទឲ្យធ្វើជាសមាជិក ។

អំពីបេតិយនៅមុខស្ថានីយ៍រាជអយស្ដុយយាន ធឹងព្រះសារីរិកធាតុ

បន្ទាប់មកទៀតសម្ដេចព្រះសង្ឃនាយកគណៈមហានិកាយបានមាន
ថេរដីកាថា "ការធ្វើបុណ្យនេះធឹងធ្វើតែនៅអង្គរតែម្ដងមិនបានទេ ត្រូវធ្វើ
ទៅកន្លែងព្រះចេតិយ៍អនុស្សាវរីយ៍ ដែលតាំងទៅមុខស្ថានីយ៍អយស្ដុយ-
យានក្នុងពេញផង ព្រោះព្រះចេតិយ៍នេះ ពួកអ្នកនគរគេនាំគ្នាចូលបុណ្យ

បានច្រាក់ប្រហែល ៦០ ម៉ឺនយកមកបំពេញការកសាងព្រះចេតិយនេះ ។ មួយទៀត មុនទឹងច្រានធ្វើបុណ្យនេះ ត្រូវក្រសួងធម្មការសុំព្រះសារីរិកធាតុពីប្រទេសសិរីលង្កាចាំង ៣ ប្រភេទ មកដាក់ឲ្យនៅប្រទេសយើង ព្រោះកាលបុណ្យព្រះបរមសារីរិកធាតុរួចហើយ គេបានសន្យាទឹងយើងថា គេនឹងឲ្យព្រះបរមសារីរិកធាតុមកប្រទេសយើង បើជាយើងត្រូវការសុំគេយកមកធ្វើសក្ការបូជា ។ នាកាលបានព្រះសារីរិកធាតុមកហើយ យើងនឹងចាត់ការឲ្យពួកជាងសាលារចនាធ្វើបុស្បកដាក់លើរថយន្តពីក្រុងភ្នំពេញ ទៅប្រតិស្ឋានធ្វើសក្ការបូជានៅអង្គរ លុះរួចពិធីបុណ្យនេះហើយ យើងនឹងនិមន្តព្រះសារីរិកធាតុនេះមកប្រតិស្ឋាននៅក្នុងព្រះចេតិយអនុស្សាវរីយ៍នាក្រុងភ្នំពេញវិញ តាមកម្មវិធីបុណ្យដែលគណៈកម្មាធិការនាយកបានចាត់ ។ ឯការសុំព្រះបរមសារីរិកធាតុពីប្រទេសសិរីលង្កាមកប្រទេសយើងនេះ ត្រូវប្រគល់ឲ្យក្រសួងធម្មការចាត់សុំក្នុងនាមនៃព្រះពុទ្ធសាសនា ។

លោកប្រធានបានទទួលថាទឹងធ្វើតាមសម្តេច តែចាំទូលស្តេចដល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងសុំព្រះពុទ្ធយោបល់ព្រះអង្គជាមុនសិនទើបចាត់ការតទៅ ។ សមាជិកទាំងអស់យល់ព្រមតាមយោបល់សម្តេចទឹងលោកប្រធាន ដោយបានអនុមតិជាឯកច្ឆន្ទ ។

អំពីគ្រោងប្រាក់បំណាយ

មន្ត្រីជាយកច្រាក់សម្រាប់ចំណាយធ្វើបុណ្យ, លោកកុយ-លុត

ចានមានប្រសាសន៍ថា ត្រូវរក្សាដោយវិធានការ ២ យ៉ាង គឺ

១) ដោយសុំព្រះពរជ័យពីចាស់ ចំណាយទូរទាក់ទងវិភាជាតិតាមចំនួនដែលគណៈកម្មាធិការនាយកបានគ្រោងទុកហើយសុំតាមមុនការ ។

២) ដោយពិធីអំពាវនាវអ្នកស្រុកជាពុទ្ធបរិស័ទឲ្យជួយផ្តល់តាមធនធានដោយមេត្តាចិត្តគ្រប់ប្រភេទគ្រប់យ៉ាង មានធ្វើសលាកសញ្ញាដើរលក់ជាដើម ។ សម្តេចថា គួរធ្វើសលាកសញ្ញាទ្រង់ព្រះរាជទានដូចកោដ្ឋដំកល់ព្រះបរមសារីរិកធាតុ ។ លោកហែម - ចំរើនថា គួរធ្វើសលាកសញ្ញានេះ ដោយវត្ថុភ្ញៀវការគឺ មាស, ប្រាក់, ស្ពាន់ លក់ឲ្យពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ ដែលមានសទ្ធាជ្រះថ្លាជួយទុបត្ថម្ភបុណ្យនេះ ។ ក្រុមសន្និបាតបានយល់ព្រមជាឯកច្ឆន្ទ ។

អំពីអញ្ជើញភ្ញៀវបរទេស

ការអញ្ជើញជនបរទេសឲ្យមកជាភ្ញៀវកិត្តិយសពិធីបុណ្យនេះ ក្រុមសន្និបាតបានមូលមតិគ្នាសម្រេចអញ្ជើញភ្ញៀវបរទេសដូចខាងក្រោមនេះ :

- ប្រទេសឥណ្ឌា ជៃកខាងអ្នកកាន់ព្រះពុទ្ធសាសនា
- ប្រទេសស៊ីលង្កា
- ប្រទេសកូមា
- ប្រទេសនេប៉ាល់
- ប្រទេសថៃ
- ប្រទេសលាវ

- ប្រទេសយួនខាងជាតិនិយម
- ប្រទេសជប៉ុន
- ប្រទេសអូស្ត្រាលី
- ប្រទេសឥណ្ឌូណេស៊ី
- ប្រទេសបាកំង
- ប្រទេសអាមេរិក
- ប្រទេសម៉ាឡេស៊ី ។

ចំនួនក្មៀវគ្រប់ប្រទេសដូចមាននាមខាងលើនេះ, យើងត្រូវអញ្ជើញតែត្រឹម ២ រូបក្នុងប្រទេសមួយ ។ ហើយយើងត្រូវទទួលការៈម្ហូបអាហារ, យានជំនិះ, កន្ទែងសំណាក់ទឹងដឹកនាំជូនដំណើរទស្សនាចីកន្ទែងផ្សេង ។ ក្នុងប្រទេសយើង តាមកម្មវិធីដែលនឹងរៀបចំទៅថ្ងៃមុខ ។ ឯក្មៀវដែលមកលើសពីចំនួនដែលយើងត្រូវអញ្ជើញ គឺក្មៀវដែលគេត្រូវការមកមើលបុណ្យនេះ យើងត្រូវបើកសិទ្ធិឲ្យគេមកតាមចិត្ត តែត្រូវសុំឲ្យគេបញ្ជូនបញ្ជីចំនួនក្មៀវទាំងនេះមកឲ្យយើងដឹងមុន ៣ ខែ ឯការគ្រប់យ៉ាងមានអាហារគោជនទីសំណាក់ជាដើម ត្រូវការៈគេវិកខ្លួនឯង យើងគ្រាន់តែបើកសិទ្ធិឲ្យមកជាក្មៀវធម្មតា ។

អំពីកាលបរិច្ឆេទដែលធ្វើបុណ្យ

លោកប្រធានបានថ្លែងថា ពុទ្ធសកវជប្រទេសឥណ្ឌូ, លង្កា នឹងកូមា លឿនជាងពុទ្ធសកវជខ្មែរ, ថៃ, លាវ មួយឆ្នាំ គេនឹងរៀបចំ

ធ្វើពិធីបុណ្យពាក់កណ្តាលព្រះពុទ្ធសាសនា នៅថ្ងៃ ១សភា ១៩៥៦ នេះ, ចំណែកប្រទេសខ្មែរយើងនឹងធ្វើនៅឆ្នាំក្រោយ (១៩៥៧) គឺក្រោយឥណ្ឌា ១ ឆ្នាំ ។ ចំពោះការបរិច្ចេទនេះ សម្តេចព្រះសង្ឃនាយកបានថ្លែងថា ពុំដឹងជាខានណា ខុសខានណាត្រូវទេ, តែការបរិច្ចេទកំណត់ពាក់កណ្តាលព្រះពុទ្ធសាសនា សម្រាប់ប្រទេសខ្មែរយើងគឺនៅថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំរកានឆស័ក ព. ស. ២៥០០ គត់ត្រូវនឹងថ្ងៃទី ១៣ ឧសភា ១៩៥៧, គឺថ្ងៃទី ១៣ ឧសភា ១៩៥៧ នេះឯង ប្រទេសកម្ពុជាយើង កំណត់ធ្វើបុណ្យរំលឹកពាក់កណ្តាលព្រះពុទ្ធសាសនា ត្រមាំងធ្វើបុណ្យសម្ពោធព្រះចេតិយ ១ ដែលកំពុងសាងនៅមុខស្ថានីយ៍រថភ្លើងកំពង់ឆ្នាំងឆ្ពោះមកថ្ងៃទុកជាអនុស្សាវរីយ៍ ។

អំពីចំនួនថ្ងៃដែលត្រូវធ្វើបុណ្យ

អំពីចំនួនថ្ងៃដែលធ្វើបុណ្យនេះ, សមាជិកក្រុមសន្ទិដ្ឋិតមានយោបល់ផ្សេងៗគ្នា លោកខ្លះថាធ្វើ ៣ ថ្ងៃ លោកខ្លះថា ៧ ថ្ងៃ លោកខ្លះថា ១៥ ថ្ងៃ; ក្រុមសន្ទិដ្ឋិតបានអនុម័តិកំណត់បុណ្យនេះចំនួន ១៥ ថ្ងៃ ឲ្យសមតាមការដែលយើងបានរៀបចំអស់ប្រាក់ច្រើនផង សមតាមយោបល់សម្តេចព្រះសង្ឃនាយកផង ដែលសម្តេចបានផ្ញើតជូនន័យដល់សមាជិកក្រុមសន្ទិដ្ឋិត ដោយលើកពិធីបុណ្យដែលបានធ្វើក្នុងកាលព្រះអង្គបរិនិព្វានមានកំណត់ ១៥ ថ្ងៃដែរ គឺដំណល់ព្រះបរមសព ៨ ថ្ងៃ រើសព្រះ

បរមធាតុរួចហើយ គេធ្វើ ៧ ថ្ងៃតមកទៀត គំរប់ជា ១៥ ថ្ងៃ; ឯពិធីបុណ្យយើង ១៥ ថ្ងៃនេះ គឺតាំងទៅក្នុងពេញ - អង្គវង ។

ការសំអាតក្រុងសៀមរាប

បន្ទាប់ពីនោះមកទៀត លោកលឿង - ណាល់ បានធ្វើតទុកាសនេះសុំក្រមសន្ទិបាតជួយសុំដល់ព្រះពជវជ្ជាគិបាលចំណាយថវិកា សំអាតក្រុងសៀមរាប គឺធ្វើថ្នល់ពីខែត្រទៅអង្គរ - ទៅភ្នំក្រៃម - ទៅបាកយណ៍ ទឹកថ្លា ផ្លូវបន្ទាយស្រី ដើម្បីឲ្យសមរម្យដល់ពួកបរទេស ដែលគេត្រូវការទៅទស្សនាបុរាណវត្ថុទាំងនោះ ។ ក្រមសន្ទិបាតយល់ព្រមថានឹងសុំឲ្យគណៈកម្មាធិការនាយកស្ថាពរជួយសុំដល់ពជវជ្ជាគិបាល តាមសេចក្តីសុំនៃលោកលឿង - ណាល់ ។

ទីបំផុត លោកប្រធានបានមានប្រសាសន៍ឲ្យ - ជំពាក់ទីប្រជុំថាការដំនុំនេះនឹងចុះកន្លងសេចក្តីកត់ហេតុ ហើយធ្វើចុតហ្វាយថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះអង្គទ្រង់សព្វព្រះរាជហ្ឫទ័យយ៉ាងណា យើងនឹងចាត់ការជ្រើសរើសរូបសមាជិកគណៈកម្មាធិការនាយកឲ្យសម្រេចការតាមព្រះពជវោចល់តទៅ ។

ការប៉ះពេលប្រជុំនៅវេលាម៉ោង ១០ ត្រឹក ។

បានលើកពេលប្រជុំនៅវេលាម៉ោង ១០ កាលបរិច្ឆេទដូចមានខាងលើ ។

ពិធីសម្ពោធធ្លងមន្ទីរពេទ្យព្រះសង្ឃ

ពុទ្ធសាសនបណ្ឌិត្យ

វេលាព្រឹកថ្ងៃទី ២១ កុម្ភៈ ១៩៥៦, នៅខាងត្បូងស្ពានយោមភជ មានធ្វើបុណ្យមួយដ៏ឧឡារិក ហៅថា "ពិធីសម្ពោធធ្លងមន្ទីរពេទ្យព្រះសង្ឃ" ក្រោមព្រះពរជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង។

ក្នុងកំពែងនៃមន្ទីរពេទ្យនោះ មានបាកំធំៗសម្រាប់ទទួលព្រះសង្ឃ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, វរជនខាងប្រទេសក្រៅ ក្នុងប្រទេសនិងពុទ្ធបរិស័ទជាំងឡាយឯទៀត។ ព្រមទាំងមានវេទិកាខ្ពស់តូចមួយនៅបន្ទោះបាកំធំៗ ទំនើមន្ទីរពេទ្យសម្រាប់ធ្វើសង្កថា ។ បាកំទាំងនោះ គេប្រក់ដោយសំពត់, នៅជាយដុំវិញ គេចងក្រងស្វឹកកុរុក្ខជាតិពណ៌ខៀវខ្ចីស្រស់, គេដោតទង់ជាតិនិងទង់សាសនាជាបន្ទោះៗ ព្រាងព្រាតព្រមទាំងក្រាលកម្រាលរំលេចពណ៌ក្រហមស តាមផ្លូវពីបាកំដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ប្រថាប់រហូតដល់ខ្លោងនៃមន្ទីរពេទ្យ ។

រីឯមន្ទីរពេទ្យនេះមានទំហំទឹងកំពស់សមរម្យតាមសម័យ នាំឲ្យពួកជនដែលបានទស្សនាកោតស្ងប់ស្ងែងយ៉ាងក្រៃលែង គឺគេធ្វើដោយគ្រឿងសម្ភារៈបេតុងអារម៉ែនឥដ្ឋ មានបណ្តោយ ៨២ ម៉ែត្រ, ទទឹងត្រង់កន្លែងធំ ២០ ម៉ែត្រ ត្រង់កន្លែងតូច ១០ ម៉ែត្រ, កំពស់ ១៦ ម៉ែ ៨០ ត្រឹមលាន មានបន្ទប់សម្រាប់ព្រះសង្ឃសឹង ៣០, ចំណុះបាន ១៥០ គ្រែ ។

នៅថ្នាក់ក្រោមគេចែកជាបន្ទប់ៗ បន្ទប់មួយចំណែកសម្រាប់ធ្វើជាឃ្លាំង,

មួយចំណែកជាការិយាល័យក្រុមអភិបាល, មួយចំណែកជាការិយាល័យក្រុមបច្ចេកទេស (តិចនិក), មួយចំណែកទៀតជាសាលពិគ្រោះ ។

នាថ្ងាក់លើបំផុត (លានខាងលើ) គេរចនាចាក់ក្រាលដោយបេតុងអារម៉េហើយក្រាលដោយឥដ្ឋ ៤ ជ្រុង ធ្វើជាលានលាតឥតមានដំបូល, គេជាំដើមផ្កាផ្សេង ។ ព័ទ្ធជុំវិញឲ្យកវះឡើងព័ទ្ធពីលើ ដើម្បីបំបាត់កំដៅថ្ងៃដល់តំណាងសមណៈ ដែលឡើងទៅលំហើយកាយម្តងម្កាលមួយកាល, ប៉ុន្តែតែងជាយខាងលិចខាងកើតនឹងខាងជើង មានបន្ទប់តូច ។ មានដំបូលគ្រងជាខ្លីជ្រះថ្លា ។

កន្លងពីធីសម្ពោធនោះ យើងសង្កេតឃើញពុទ្ធបរិស័ទ ជាព្រះសង្ឃខ្លះ ជាគហស្ថខ្លះ; ខាងព្រះសង្ឃ មានសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ, ព្រះតេជព្រះគុណព្រះអរិយកស្សប អ៊ុច តំណាងព្រះសង្ឃនាយកគណៈធម្មយុត្តិ, ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុពន្ធមីត, ព្រះតេជព្រះគុណព្រះមហាព្រហ្មមុនី ខេត-អ៊ី ចាងហ្វាងវិនពុទ្ធិកវិទ្យាល័យព្រះសុពន្ធមីត ទីឯកិក្ខុសង្ឃឯទៀតជាច្រើន; ខាងគហស្ថ មានសម្តេចក្រុមព្រះស៊ីសុវត្ថិ-មុនីវ៉ែត, ព្រះអគ្គម្ចាស់ប៉ែង-ប៉ាះ-យុគន្ធរ, ប្រធានសភាខាងពីរ, លោកអ៊ុំ-ឈាង-ស៊ុន នាយកវេជ្ជមន្ត្រី, លោកហ៊ុយ-កន្ទុល អតីតនាយកវេជ្ជមន្ត្រី, លោកមៀច-គន្ធ ចៅហ្វាយក្រុងភ្នំពេញ, អគ្គទូតនិងនាយតាហានខ្មែរគ្រប់ក្រុម ព្រមទាំងក្រុមពុទ្ធសាសនិកឯទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយមិនបានរាប់នាម

តាំងអស់កន្លងទីនេះ ។

ក្រៅពីព្រះករុណាជាម្ចាស់ដីតែលើស្ថាន ឃុនស្តេចយាងទៅដល់មុខឃុកំ ដែលមានតាហានរក្សាព្រះអង្គរង្វើតារវៀកច្រ ទឹងក្នុងព្រះពជ្រឲ្យបន្ទឹមខនតរពេជជាព្រះពជកិត្តិយសហើយ មានពុទ្ធសាសនិកម្នាក់ឡើងលើវេទិកា ថ្លែងពាយនាមពុទ្ធសាសនិកដែលមានបសាទសទ្ធាយ៉ាងខ្លាំងក្លាបានបរិច្ចាគបច្ច័យក្នុងការកសាងមន្ទីរពេទ្យនោះ ចំពោះតែអ្នកដែលមានសទ្ធាបរិច្ចាគ ច្រើនជាងពុទ្ធសាសនិកឯទៀត ។ ។ តមកលោក ឃួន-ណៃ អធិបតីសមាគមគិលានសង្គ្រោះ ថ្លែងសុន្ទរកថា, បន្ទាប់មក លោកតែ.ណុល អគ្គលេខាធិការខាងក្រុមប្រឹក្សាចាត់ការរបស់សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃ ថ្លែងសុន្ទរកថាបេសល់លោកឃួន-ណៃ ទៅជាការសាបាកំង ។ តមកទៀត សម្តេចព្រះមហាសុមេធាធិបតីជួន-ណាត សង្ឃនាយកគណៈមហានិកាយ តំណាងព្រះសង្ឃគណៈមហា-និកាយក្នុងប្រទេសកម្ពុជាទាំងមូល បានថ្លែងសុន្ទរកថាដោយឥតបានត្រាងទុកជាមុន មានសេចក្តីយ៉ាងខ្លីល្អយ ។ បន្ទាប់ពីសម្តេចព្រះមហាសុមេធាធិបតីមក ព្រះតេជព្រះគុណព្រះអរិយកស្សប អ៊ុច តំណាងព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ ថ្លែងសុន្ទរកថា ។ បន្ទាប់មកទៀត លោកមាស-យ៉ង់ រដ្ឋលេខាធិការក្រសួងសាធារណសុខាភិបាល ថ្លែងសុន្ទរកថាយ៉ាងក្បោះក្បាយ ។ បន្ទាប់ពីលោក មាស-យ៉ង់ មក លោកទិញ-ភ័ញ រដ្ឋលេខាធិការក្រសួងធម្មការថ្លែងសុន្ទរកថា ។

លុះចប់សុន្ទរកថា នៃព្រះសង្ឃនឹងវេជន្តាំងនោះហើយ ព្រះករុណាជា

ម្ចាស់ជីវិតលើត្បូង ស្តេចយាងតមន្លឺរពេទ្យ ដោយមានអង្គខ្លួនទីវរជន តាំងឡាយហែហមទៅផង រួចស្តេចបានយាងត្រឡប់ទៅគាន់ព្រះបរម-កដកំនិរាញ ដោយមានព្រះពជបរិពារជវែលហែព្រះពជដំណើរផង ទីតាហានធ្វើតាវគិច្ចដូចកាលយាងមកដល់ ចំណែកអង្គខ្លួនទីវរជនឯទៀត គឺអញ្ជើញទៅគាន់អាសយដ្ឋានរៀងខ្លួនវែរ ។

ឯសុន្ទរកថា នៃព្រះសង្ឃទីវរជនតាំងនោះ យើងដកស្រង់យកមកបុះក្នុងខាងមុខនេះ ។

ដល់វេលាយប់ថ្ងៃដដែល ម៉ោង ១៩,៣០ នាទី គេបាននិមន្តសម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត សង្ឃនាយកគណៈមហានិកាយ សំដែងធម៌ទេសនា ។ បន្ទាប់មក គេបញ្ចាំងភាពយន្តជាការបង្ហើយពិធីបុណ្យនេះត្រឹមប៉ុណ្ណោះ ។

* * *

សុន្ទរកថាលោកឃួន - ណៃ

ប្រធានសមាគមគិលានសង្គ្រោះ

សូមព្រះតេជះដ៏កល់លើត្បូង !

សម្តេច ! ព្រះថេរានុត្តរត្រែប់ព្រះអង្គ !

ឯកទត្តម !

លោកអ្នកសប្បុរសទាំងឡាយ !

តាងនាមនៃសមាគមគិលានសង្គ្រោះ ចំពោះព្រះសង្ឃពុទ្ធសាសនិក ទីងក្នុងនាមជាលំនៃព្រះអង្គ, ខ្ញុំព្រះបង្គំជាខ្ញុំ សូមទទួលអំណរព្រះគុណ

ជើខ្ពង់ខ្ពស់នៃព្រះករុណាជាម្ចាស់ដីវិតលើត្បូង ដែលខ្ញុំស្តេចមកជាអធិបតីតំកើងពិធីបុណ្យនេះ ឲ្យបានថ្លៃថ្លាថ្កើងថ្កាន ទូលព្រះបង្គំជាខ្ញុំ, ខ្ញុំព្រះករុណាសូមទទួលអំណរគុណសម្តេច ទីឆ ព្រះថេរានុត្តេរៈ គ្រប់អង្គ, ខ្ញុំបាទសូមអរគុណសម្តេច, ឯកឧត្តមអង្គទូតទាំងអស់, ឯកឧត្តមរដ្ឋមន្ត្រីកងជាទីឆអតីត ព្រមទាំងអស់លោក-អ្នកដែលបានឧទ្ទិមគ្គ បានអញ្ជើញមកជាកិត្តិយស ដួយឲ្យពិធីបុណ្យសម្ភោធរុងរឿងយ៉ាងក្រៃលែង ។

សូមខ្ញុំមេត្តាជ្រាប ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូខ្ញុំសំដែងថា សត្វលោកទាំងអស់មិនមានសេសសល់ ដែលមានជាតិហើយតែងប្រកបដោយសភាវធម៌ ៣ ប្រការ គឺជរា ព្យាធិ ទីឆមរណៈ ។

ប្រសិនបើសត្វលោកមានដំណើរតាមធម៌នេះ ជាលំដាប់មុនក្រោយ សត្វទាំងនោះអាចដឹងបានថា កំណត់មរណកាល អាត្មាអញមិនទាន់ដល់នៅសល់ប៉ុណ្ណេះប៉ុណ្ណោះទៀតទើបដល់ ទីឆបានប្រកបការចិញ្ចឹមជីវិតតាមកំណត់ពេល ដែលសល់ទានតទៅ សេចក្តីទុក្ខសោកក៏មានកំណត់ហើយស្រាលផង ។

តែការពិតពុំបានដូច្នោះឡើយ យើងគ្រាន់តែដឹងថាធម៌ ៣ ប្រការនេះមានជាកដមែន ប៉ុន្តែយើងពុំអាចដឹងថា ទីឆមានមកនៅកាលបរិច្ឆេទពេលមោងណាឡើយ ព្រោះដួនកាលអ្នកកើតមុន ទទួលមរណភាពមុនដួនកាលអ្នកកើតក្រោយ តំត្រឡប់ជាទទួលមរណភាពមុនអ្នកកើតមុនទៅវិញក៏មាន ។ យ៉ាងនេះហើយដែលបណ្តាលឲ្យកើតសេចក្តីសោក

សង្រែងសង្រែងខ្សឹកខ្សួល ព្រោះជាការត្រាត់ប្រាស់ទិកសចាកបុត្រធីតា-ស្វាមី-ភរិយា ដែលតំពុងស្នេហាកន្ធិចិត្ត មកពុកផតមានខ្លួលអង្វរបន្ទរប្តូរបន្តួយពេលវេលាបន្តិចបន្តួចសោះឡើយ ។

ព្រះសម្មាសម្ពុទ្ធបានសំដែងទៀតថា ដែលទីណំលត់ទុក្ខតាំងឡាយដែលមានកំណើតពីធម៌ ៣ ប្រការ (ជាតិ ភ្យាធិ-មរណៈ) នេះបាន តោងរំលត់ជាតិ ដែលជាឫសជាគល់នៃធម៌តាំង ៣ ប្រការនេះ ។ ដែលយើងរំលត់ជាតិបាន មានតែធម៌ ១ គឺព្រះនិព្វាន ប៉ុន្តែព្រះនិព្វានជាធម៌វិសេសបំផុតមិនងាយនឹងបាន ហើយមុនទីណាទៅដល់ព្រះនិព្វានទោះសោត សត្វលោកវែងឆ្ងាយប្រសប់ទីណាទុក្ខសោកគណនាពុំបាន, តាលបើដូច្នេះ, តើមានមធ្យោបាយណាមួយ ដើម្បីបញ្ឈប់សង្ខារបន្តួយនូវទុក្ខសោកតាំងឡាយនោះបានដែរឬទេ? បើយកធម៌ខាងវេមមកពិចារណា គង់យើញថាសេចក្តីសោក អាឡោះអាល័យ មកពីសេចក្តីត្រាត់ប្រាស់ទិកសដែលជាបច្ច័យនៃមរណៈ ។ មរណៈមកពីភ្យាធិគឺការឈឺចាប់ដោយពេគគ្រប់សង្កត់ លុះត្រាតែបែកវិលាយរូប ។

តាលបើដូច្នេះ, ការសង្រែងដល់សត្វលោក ដោយការបែកថ្នាំតែពេគឲ្យសន្សើយចាកជម្ងឺឲ្យបានជូរថយនូវទុក្ខវេទនាតាំងឡាយ នេះហើយដែលជាកុសលកម្មគប្បីធ្វើ តែថាការបែកចាយថ្នាំទូទៅមិនរើសមុខចំពោះជនក្រីក្រតាំងយកពាសតាំងបព្វជិតនោះ ព្រះពុទ្ធជ្ញាតិបាលបានធ្វើហើយ, មានមន្ទីរភ្យាបាលពេគគ្រប់ខែត្រក្នុងព្រះពុទ្ធអាណាចក្រ; ប៉ុន្តែព្រះសង្ឃ ដែលមានវិន័យហាមឃាត់មិនឲ្យសឹងជាមួយអនុបសម្បន្ន

គឺបុគ្គលដែលមិនមែនជាកិកូដូចគ្នា មិនអាចចូលទៅសឹងព្យាបាលពេតឥត
ត្រូវអាបត្តិបានឡើយ, តាលបើដូច្នេះ ព្រះសង្ឃជាពពួកតុទ្ធបរិស័ទមួយ
ដែលពុំបានទទួលអំណោយទាន ដូចជនសាមញ្ញ តម្រូវសាងសង់អា-
ពេតស្សាលាដោយឡែក សម្រាប់ព្យាបាលជម្ងឺពេតាព្យាធិព្រះសង្ឃឲ្យ
បានផ្លូវយ៉ាងខ្លួនវេទនាខ្លាំងពេក ។

ការធ្វើទានទុសចំពោះព្រះសង្ឃបែបនេះ មានប្រវត្តិការណ៍
តាំងពីសម័យពុទ្ធកាល តែកាលដែលព្រះពុទ្ធអង្គគង់នៅមានទៅឡើយ ។

មានដំណាលថា ព្រះបាទពិម្ពិសារជាព្រះមហាក្សត្រសោយរាជ្យ
ក្នុងក្រុងរាជគ្រឹះដែនមគធៈ ទ្រង់បានសាងតំលោទសាលាសម្រាប់ព្រះសង្ឃ
សាវ័កនៃព្រះសម្មាសម្ពុទ្ធមិនឲ្យព្រះសង្ឃដែលមានអាពាធចូលទៅលាយ
ឡំក្នុងតំលោទសាលាសម្រាប់គ្រហស្ថ ។ ទ្រង់បានចាត់តាំងគ្រូពេទ្យធំ
ម្នាក់ឈ្មោះកោមារភច្ច ឬហៅថាកុមារភច្ចដូច្នេះក៏បាន ។ កោមារភច្ច
នេះ ជាគ្រូពេទ្យធំកង់មន្ទីរពេទ្យ ដែរហេតុបានពិម្ពិសារពេជទ្រង់តសាង
នោះ ។ កាលបើព្រះសម្មាសម្ពុទ្ធទ្រង់ប្រឈួនមួយដងមួយកាល ក៏ត្រូវ
គ្រូពេទ្យកោមារភច្ចតំនិត្យមើលរក្សាប្រឈួនទៃព្រះអង្គដែរ ។

សម័យដែលព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ មានព្រះមហាក្សត្រ
មួយព្រះអង្គទ្រង់ព្រះនាមថា "ធម្មាសោកពេជ" ឬព្រះបាទអសោកពេជ
សោយរាជ្យក្នុងក្រុងបាតលិបុត្រដែនមគធៈ (ប្រទេសឥណ្ឌា) មាន
ព្រះពេជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ទ្រង់បានជួយឧបត្ថម្ភទំនុកបំរុង
ព្រះពុទ្ធសាសនាដោយពេញព្រះកំឡាំង បានសាងអារោគ្យសាលាជាច់

ដោយឡែក សម្រាប់ព្រះសង្ឃចូលព្យាបាលរោគបានដោយស្រួល ឥតខាន់ធីវិន័យ ។

ក្រោយតមកទៀត នៅលង្កាទ្វីបមានព្រះមហាក្សត្រមួយព្រះអង្គ ព្រះនាមវុដ្ឋគាមិនីអភ័យ បានកសាងមន្ទីរពេទ្យមួយសម្រាប់ព្យាបាលរោគព្រះសង្ឃដោយឡែកនៅក្នុងក្រុងអនុរាធបុរី ។ មន្ទីរពេទ្យនោះបាក់បែកអស់ទៅហើយ នៅសល់តែកន្លែងដំណែលមកដល់សព្វថ្ងៃ ។

ក្នុងចំណោមពួកបបួលាប្រទេសដែលព្រះពុទ្ធសាសនាសាយរុងរុយមកដល់ប្រទេសកម្ពុជា កាលសម័យនគរធំមានព្រះមហាក្សត្រមួយព្រះអង្គ មានព្រះកិត្តិសព្ទល្បីល្បាញខ្ចរខ្ចាយក្នុងលោក គឺព្រះបាទជយវរ្ម័នទី ៧, ព្រះបរមក្សត្រអង្គនេះ មានព្រះរាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាលើសលុប បានកសាងអារោគ្យសាលាដោយឡែក សម្រាប់ព្រះសង្ឃដូចកាលព្រះបាទធម្មាសោកដែរ ។

មន្ទីរពេទ្យព្រះសង្ឃនេះ តែងមានឧកតាំងពីអតីតកាលដូចរៀបរាប់ដោយសង្ខេប តែពុំបានបិតវេរចិរកាល រៀងរាបដរាបមកលង្វែកជាច់ពីគ្នាយ៉ាងយូរអង្វែងណាំ, ដូចជាក្នុងប្រទេសកម្ពុជានេះ តាំងពីសម័យនគរធំមកទល់សព្វថ្ងៃ ទើបមានលេចឡើងក្នុងរជ្ជកាលនៃព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូងព្រះអង្គនេះ ។

មន្ទីរពេទ្យព្រះសង្ឃនៃប្រទេសកម្ពុជាដែលស្ថាបនាទើបនឹងហើយនេះ បានរចនាតាមផែនទីរបស់លោកវិស្វកររដ្ឋ ជាអ្នកដាក់ពាក្យសារឡើងធ្វើឲ្យ

ដោយអនុញ្ញាតព្រះពរជវង្គតិបាល ដែលបានជួយឧបត្ថម្ភគាំទ្រពីដំបូង រហូតមក ។

មន្ទីរពេទ្យនេះធ្វើដោយគ្រឿងទ្វសម្ភារៈបេតុងអារម៉ែនឥដ្ឋ មានបណ្ដោយ ៨២ ម៉ែត្រ, ទទឹងត្រង់កន្លែងធំ ២០ ម៉ែត្រ ត្រង់កន្លែងតូច ១០ ម៉ែត្រ, កំពស់ ១៦ ឬ ៨០ ត្រឹមពន្លាល មានបន្ទប់ព្រះសង្ឃសឹង ៣០, ចំណុះ បាន ១៥០ គ្រែ ។

នៅថ្នាក់ក្រោមចែកជាបន្ទប់ៗ បន្ទប់មួយចំណែកធ្វើជាឃ្លាំង, មួយចំណែកឲ្យក្រុមអគិបាល, មួយចំណែកឲ្យក្រុមបច្ចេកទេស (តិចនិក), មួយចំណែកទៀត ធ្វើជាសាលពិគ្រោះ ។

មន្ទីរពេទ្យនេះចាប់សង់ក្នុង គ. ស. ១៩៥៣ បានធ្វើបុណ្យបញ្ចុះបឋមសិលានៅថ្ងៃទី ២១ កុម្ភៈ ១៩៥៣ មកដល់ថ្ងៃសម្ពោធទី ២១ កុម្ភៈ ១៩៥៦ នេះ ត្រូវជា ៣ ឆ្នាំគត់ ។ តម្លៃ ១២ លានរៀល ។

ក្នុងចំនួនថ្លៃក់នេះ ចំណែកប្រជាជនខ្មែរបានចេញថ្លៃក់ចំនួន ៣ លាន ៥ សែនរៀល, ដំនួយពីពរជវង្គតិបាល ៦ លាន ៥ សែនរៀល, ដំនួយអាមេរិកាំង ២ លានរៀល រួមជា ១២ លានរៀល ។

ការសាងសង់ទីកន្លែងនេះបានតើបប្រទះនឹងបរស័ព្គផ្សេង ។ គឺ ខ្លះកម្មករ, ខ្លះភ្លើង, ខ្លះទឹក ខ្លះបុគ្គលិក ។ ល ។

កាលមន្ទីរពេទ្យចាប់សង់ដំបូងក្នុង គ. ស. ១៩៥៣ នៅកន្លែងវាលទីបុង្គមិឃាត់ខ្លួកមកលន់នឹងថ្លល់យោមកជ ឃើញតែមានវាលស្រែ គ្មានផ្ទះអ្នកស្រុក ១ ខ្នងសោះឡើយ, លុះមន្ទីរពេទ្យសង់បានចំរើនជា

លំដាប់ឡើង ប្រជាជនកំពុងតែសង់ផ្ទះទីលំនៅច្រើនឡើង ។ ពេលនេះទីវាលស្រែកំពុងតែឡប់ក្លាយទៅជាភូមិមួយសព្វ រកដីទំនេរមួយផ្ទាំងគ្មានការខ្វះកម្មករកំដោះស្រាយទៅឯង ។

ចំណែកបញ្ហាទឹកភ្លើង បុគ្គលិកនឹងធ្វើការសម្រាប់ផ្គត់ផ្គង់មន្ទីរពេទ្យក៏បានដោះស្រាយរួចស្រេចដែរ, តែការអនុវត្តន៍យឺតយូរបន្តិច មិនបានឲ្យផលទាន់ពេលសម្ពោធ ។

សូមទ្រង់ព្រះមេត្តាប្រោស !

តាងនាមនៃសមាគម ខ្ញុំព្រះបង្គំជាខ្ញុំ សូមព្រះពុទ្ធានុញ្ញាតយកឱកាសនេះ សំដែងជាឧឡារិកនូវព្រះអំណរព្រះគុណាទិគុណដ៏ខ្ពស់ចំពោះព្រះគុណាជាម្ចាស់ដីវត្តលើត្បូង ដែលទ្រង់ព្រះពុទ្ធានុញ្ញាតឲ្យព្រះពុទ្ធជ្ញាកិច្ចាលជួយឧបត្ថម្ភសមាគមនេះ ពេញកំឡាំងតាំងពីដំបូងរហូតមក ។

ខ្ញុំព្រះបង្គំជាខ្ញុំ សូមព្រះពុទ្ធានុញ្ញាតសំដែងចំពោះព្រះទីនាំង នូវអំណរគុណចំពោះព្រះពុទ្ធជ្ញាកិច្ចាលព្រមទាំងវេជ្ជមន្ត្រីគាន់តំណែងត ។ គ្នាមក ដែលបានជួយពេញកំឡាំងដោះស្រាយបញ្ហាដ៏លំបាកគ្រប់ប្រែបគ្រប់យ៉ាងបានរួចពីដំណាក់ ។

ការជួយនេះ មិនមែនគ្រាន់តែកំឡាំងរបស់ខ្លួន ថែមទាំងយកចិត្តទុកដាក់ចំពោះការដែលខ្លួនធ្វើពុំកើត ពីងពាក់ប្រទេសក្រៅឲ្យជួយខ្លះថែមទៀតផង ។

ខ្ញុំព្រះបង្គំជាខ្ញុំ ចង់ក្រាបបង្គំទូលអំពីដំនួញសេដ្ឋកិច្ចអាមេរិកាំង

ទឹងជំនួយសេដ្ឋកិច្ចថ្មាំងសែស ព្រះពរជវង្ឆាកិច្ចលបានជួយពាល់ឆ្នាំ ក្នុង ១ ឆ្នាំ ២ លានរៀល ព្រមទាំងកិច្ចការគ្រប់ចំពូកផង ដែលជួយបានដូច គំណាទុប្បដ្ឋាក ទឹងការជួយផ្តល់ថ្នាំតែពេតខ្លះជាដើម, ជំនួយនេះយើញ ថាពេញកំណត់ហើយ លើសពីនេះទៅទៀតពុំកើត តែថាយកមកបូមួល ទឹងប្រាក់ភាគទានសមាជិកទឹងអំណោយគ្រប់យ៉ាងពីពុទ្ធបរិស័ទ ទាំងឡាយ ក៏ពុំទាន់គ្រប់គ្រាន់, ទើបព្រះពរជវង្ឆាកិច្ចលធ្វើពាក្យសូម ទៅបេសកកម្មសេដ្ឋកិច្ចអាមេរិកាំង ទឹងបេសកកម្មសេដ្ឋកិច្ចថ្មាំងសែស ឲ្យជួយតាមកំឡាំងចិត្តរបស់គេ ។

អាមេរិកាំង គេបានជួយប្រាក់លើកដំបូងមួយលានប្រាំសែនរៀល ដើម្បីបង្កើយគ្រឹះស្ថាន ទឹងបានជួយប្រដាប់ប្រដាសម្រាប់ពេទ្យភូមិភាគ ចំនួនគ្រែ ១០០ រួចពេលបន្ទាប់គ្នាមក ជួយប្រាក់ជាលើកទី ២ ប្រាំសែន រៀលទៀត សម្រាប់ទិញសេនាសនគ័ណ្ឌ ។

ដោយកម្លាំងជំនួយប្រាក់គេលើកដំបូងនេះហើយ ទើបគ្រឹះស្ថាន នេះបានសង់រួចស្រេចក្នុងឆ្នាំនេះ តែគ្មានរបស់អ្វីសម្រាប់ប្រើប្រាស់ នៅឡើយ ។

ដោយកំឡាំងជំនួយផ្លាល់ប្រដាប់ប្រដាសម្រាប់មន្ទីរពេទ្យ ភូមិភាគ នេះហើយ ទើបគ្រឹះស្ថាននេះមានគ្រែ ៨៥ ព្រមទាំងបរិវារទឹងប្រដាប់ ប្រដាប្រើប្រាស់ក្នុងមន្ទីរពេទ្យនេះខ្លះនៅវេលាសម្ពោធ ។

ដោយកម្លាំងជំនួយ ៥ សែនរៀលខាងគ្រែយាននេះទៀត ទើបមន្ទីរ ពេទ្យព្រះសង្ឃទឹងមានសេនាសនគ័ណ្ឌប្រើប្រាស់នៅវេលាឆាប់ៗ នេះ ។

ដោយជំនួយគ្រូពេទ្យនាយមួយរូប គិលានុប្បដ្ឋាកនាយមួយរូប ឱ្យានដឹកទឹកមួយគ្រឿងពីវេសកកម្មសេដ្ឋកិច្ចទឹងតិចទឹកចាក់ឆ្ងាសេស តាមពាក្យសុំពីព្រះពជរដ្ឋាភិបាល ទើបសមាគមដោះស្រាយរួចនូវបញ្ហាបុគ្គលិកនឹងទឹកសម្រាប់ប្រើប្រាស់ក្នុងមន្ទីរពេទ្យ ។

ខ្ញុំលព្រះបង្គំជាខ្ញុំ សូមព្រះពជាខុញ្ញាត សូមព្រះពជរដ្ឋាភិបាលផ្តើរទៅវេសកកម្មជំនួយអាមេរិកាំង នឹងវេសកកម្មជំនួយចាក់ឆ្ងាសេស ខ្ញុំអំណរគុណដ៏ក្រៃលែង ពីសមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃគាំងអស់ក្នុងព្រះពជអាណាចក្រ ។

ទីអរសាទ, ខ្ញុំលព្រះបង្គំជាខ្ញុំសូមអរគុណចំពោះលោកវិស្វករ ជីនឹងលោកមេការ ញ៉ា ដែលជាអ្នកគ្រួតគ្រាការសាងសង់នេះតាំងពីដើមរហូតដល់ហើយ ។

ខ្ញុំលព្រះបង្គំជាខ្ញុំ សូមអរគុណចំពោះពជការគ្រួង ដែលបានចែកដីធ្វើមន្ទីរពេទ្យព្រះសង្ឃនេះ នឹងបានជួយខ្ញុំកិច្ចការបន្តិចបន្តួច មានការលក់ឹកឱ្យជាដើម ព្រមទាំងលោកអ្នកសប្បុរសទាំងឡាយ ដែលបានជួយចំនុកបម្រុងគោះតិចគោះច្រើនក្នុងការសាងសង់មន្ទីរពេទ្យនេះ ដោយកម្លាំងចិត្តក្តី ដោយកម្លាំងកាយក្តី ដោយកម្លាំងចិត្តក្តី សូមប្រកបដោយពរ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ប្រតិភាណៈ នឹងវិឌ្ឍភាពជានិច្ចនិរន្តរ៍រៀងទៅ កុំបីឃ្លាតឡើយទៅជាប្រការដទៃឡើយ ។

ចប់សុន្ទរកថាលោក ឃួន . ណៃ

សុន្ទរកថា ព្រះពេជព្រះគុណព្រះអរិយកសប អ្ញប

ខ្ញុំព្រះករុណា អាត្មាភាពកូនឥតនាមនៃព្រះសង្ឃគណៈធម្មយុត្តិកនិកាយ ប្រតិស្ឋានក្នុងឧត្តមអធិបតី នៃសមាគមគិលានសង្គ្រោះនិមន្តមកកាន់សន្និបាតកូនថ្ងៃនេះ ដើម្បីថ្លែងនូវសុន្ទរកថាមួយតាងនាមនៃព្រះសង្ឃគណៈធម្មយុត្តិនិកាយក្នុងព្រះពុទ្ធចក្រកម្ពុជា ក្នុងឧកាសនៃពិធីសម្ពោធនូវមន្ទីរពេទ្យព្រះសង្ឃនេះ ។

បពិត្រព្រះនរបតី !

បពិត្រសម្តេចជាអម្ចាស់ !

ព្រះករុណាគ្រប់ព្រះអង្គ !

ខ្ញុំឯកឧត្តម អស់លោក អ្នកគង់ជាបានយ៉ាងជាក់ច្បាស់ហើយថា គិលានុប្បដ្ឋាកវិជ្ជសម្រាប់ខំទុកបម្រុងព្រះសង្ឃពុទ្ធសាសនិកនៅប្រទេសយើង បានវិនាសបាត់បង់ទៅជាច្រើនរយឆ្នាំណាស់មកហើយ ។ ទើបតែមកដល់វដ្ឋកាលនៃព្រះបាទសម្តេចព្រះនរោត្តមៈសីហនុវ័រ្ម ទំនឹងកន្លងវដ្ឋកាលនៃព្រះបាទសម្តេចព្រះនរោត្តមសុភមង្គល ព្រះចៅព្រះពុទ្ធចក្រយើងសព្វថ្ងៃនេះ ព្រះពុទ្ធសាសនានៅប្រទេសយើង ក៏ត្រូវបានជួបប្រទះនឹងសេចក្តីចំរើនរុងរឿងឡើងវិញ ស្ទើរតែប្រៀបធៀបទៅនឹងសេចក្តីចំរើនរុងរឿងនាសម័យព្រះបាទជយវ័ម្ន ទី ៧ បាន, ដោយសារតែព្រះប្រាជ្ញាមហាកម្សត្រៃរបស់យើងខ្ញុំជាពុទ្ធសាសនូបត្ថម្ភក៍ ។

ឯសេចក្តីចំរើនដែលបានបង្ហាញនូវរូបភាពឲ្យយើងបានឃើញជាក់ច្បាស់ នឹងចង្អុលប្រាប់ក្នុងបច្ចុប្បន្នសម័យនេះ គឺស្តាប់នានូវមន្ទីរ

ពេទ្យព្រះសង្ឃ ដែលព្រះគុណគ្រប់ព្រះអង្គ ទ្រង់ឯកឧត្តមនឹងអស់លោក អ្នកបានដួបប្រទះក្នុងថ្ងៃនេះឯង ។

រីឯមន្ទីរពេទ្យសម្រាប់ព្រះសង្ឃពុទ្ធសាសនិក ដែលបានចាប់កំណើតជាថ្មីឡើងវិញ នៅក្នុងចំណោមនៃសេចក្តីក្រឡាត់របស់ពួកពុទ្ធបរិស័ទ្ធគ្រប់រូបយ៉ាងនេះបាន, តាមដែលខ្ញុំព្រះគុណ - អាត្មាភាព បានសង្កេតឃើញដោយជាក់ច្បាស់ថា មិនគួរណានឹងឧប្បត្តិកើតឡើងបានឡើយ, ព្រោះអំពើព្រះគុណគ្រប់ព្រះអង្គ - ទ្រង់ - ឯកឧត្តម - អស់លោក - អ្នកឆ្នៀងទេគ្រាំសំឡឹងមើលទៅខាងអតីតកាលដែលកន្លងទៅហើយថ្មី ។ នេះគង់នឹងឃើញបានថា ប្រទេសយើងបានគប់ប្រទះនឹងឧបស័គ្គដ៏អពូមង្គលយ៉ាងសម្បើមក្រៃលែង ដែលនាំឲ្យពុទ្ធមាមកជនយើង ដល់នូវសេចក្តីលំបាកច្រើនប្រការ ហួសវិស័យនឹងពណ៌នាឲ្យសព្វគ្រប់បាន ។

ប៉ុន្តែជាភ័ព្វល្អ ដែលបណ្តាលឲ្យប្រទេសយើងត្រូវតែបានដួបប្រទះនឹងសេចក្តីចំរើន, ទោះបីនៅក្នុងទេសៈកាលៈដ៏ក្រៀមក្រំដូចម្តេចក៏ដោយ ព្រះពុទ្ធសាសនាដែលជាសាសនាប្រចាំជ្រលងស្រែយើង ក៏ត្រូវតែចំរើនរុងរឿងឡើងវិញ តាមសភាពរបស់ប្រទេសឥតមានអ្វីមកពាំនាំសូន្យបានឡើយ ដោយសារតែព្រះបិយមហាក្សត្រជាទីស្នេហានឹងព្រះពុទ្ធសាសនិកជាលរបស់យើងបានជួយទំនុកបម្រុង ។

ទើបក្នុងឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ ដែលកន្លងទៅហើយនោះ ឯកឧត្តមឃួន - ណៃ ដែលជាប្រធាននៃសមាគមគិលានសង្គ្រោះព្រមទាំងសហការីទាំងឡាយនៃសមាគមនេះ មុនពេលដែលនឹងបង្កើត

ជាសមាគមមានចិត្តគិតនឹកជានិច្ចដល់សេចក្តីមិនទៀងទាត់ នៃសង្ខារបស់ខ្លួនៗថា រមែងមានសេចក្តីប្រែប្រួលទៅជាធម្មតា ដោយសារតែការកើត ចាស់-ឈឺ-ស្លាប់ ដែលនាំឲ្យសត្វលោកគិតភ័យ ហើយផុតវិស័យទីដ៏ គេចវេះចៀសវាងបាន ។

កាលបើគំនិតយ៉ាងនេះកើតឡើង, ឯកទគ្គមក៏ពុំបានបំភ្លេចចោលឡើយ ទំរឹងថ្នលុះត្រាតែបានសម្រេចនូវគោលបំណងយ៉ាងធំទូលាយ គឺការកសាងទូរមន្ទីរពេទ្យព្រះសង្ឃ ដែលឯកទគ្គមយល់ឃើញថាជាមហាកុសលមួយយ៉ាងធំបំផុត អាចកំចាត់បង់នូវទុក្ខសោកភេតភ័យរបស់ខ្លួនទៅអនាគតបាន ។ ឯកទគ្គមតាំងផ្តើមបង្កើតជាសមាគមមួយ ដើម្បីសាងនូវមន្ទីរពេទ្យមួយទ្វងសម្រាប់ទំនុកបំរុងព្រះពុទ្ធសាសនិក ។

ឋបតិកូព្រះនរបតី !

ព្រះករុណាគ្រប់ព្រះអង្គ !

ខ្ញុំ, ឯកទគ្គម, អស់លោក-អ្នក !

ការស្ថាបនានូវមន្ទីរពេទ្យសម្រាប់ព្រះសង្ឃ ដែលប្រកបដោយជាន់ ៤ ទីដ៏ធំហ៊ាងយ៉ាងធំល្វឹងល្វើយ ហើយប្រកបទៅដោយលំអរគួតនាយស្រស់បំព្រងយ៉ាងខាន់សម័យនេះ បានឲ្យខ្ញុំព្រះករុណាអត្មាភាព ដែលបានមកប្រទះឃើញច្បាស់ទីដ៏កែករបស់ខ្លួនក្នុងពេលនេះ មានសេចក្តីរំភើបស្ងប់ស្ងែងក្នុងចិត្តយ៉ាងក្រៃលែង គួរឲ្យពោលសរសើរនូវស្នាដៃនៃឯកទគ្គម ឃួន-ណៅ ព្រមទាំងសហការីទាំងឡាយនៃសមាគម ដែលជេះ

ប្រមូលផ្តុំនូវកំឡាំងសាមគ្គីនៃពុទ្ធបរិស័ទគ្រប់ជាន់គ្រប់ថ្នាក់ ឲ្យចេះស្គាល់នូវដំណែឡនៃព្រះពុទ្ធសាសនារបស់ខ្លួន ។

បពិត្រព្រះនរបតី ! បពិត្រសម្តេច !

ព្រះគុណាគ្រប់ព្រះអង្គ ! ខ្ញុំ, ឯកឧត្តម, អស់លោក-អ្នក !

ខៅទីបំផុតនៃសុន្ទរកថានេះ ក្នុងនាមនៃព្រះសង្ឃគណៈធម្មយុត្តិកនិកាយ ខ្ញុំព្រះករុណាអាត្មាភាព សូមសំបូងសំរែងជល់គុណព្រះរតនត្រ័យទាំង ៣ ប្រការគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយនឹងវត្ថុដ៏ស័ក្តិសិទ្ធិទាំងអម្បាលម៉ានដែលមានខៅក្នុងពិភពលោកនេះ សូមជួយអភិបាលនូវព្រះប្រិយមហាក្សត្រទាំង ៣ ព្រះអង្គរបស់យើង ព្រមទាំងព្រះពជរដ្ឋាភិបាលរបស់ព្រះអង្គ សូមឲ្យបានប្រកបដោយសេចក្តីសុខក្នុងព្រះសេរីពជសម្បត្តិគ្រប់កាលទាំងពួង កុំបីមានសឹកសត្រូវណាមួយមកបៀតបៀនព្រះអង្គ ព្រមទាំងព្រះពជវង្សានុវង្សទ្រង់ប្រជារាស្ត្ររបស់ព្រះអង្គបានឡើយ ។

ហើយសូមឲ្យឯកឧត្តមអធិបតីនៃសមាគមគិលានសង្គ្រោះ ព្រមទាំងសមាជិកទាំងឡាយនៃសមាគមនេះ ហើយនឹងឲ្យឯកឧត្តម, អស់លោក-អ្នក ដែលបាននៅប្តេជ្ញាមកកាន់ទីសន្និបាតនេះ បានប្រកបដោយសេចក្តីសុខដ៏គ្រាប់ប្រសើរ ប្រាស់បាតទុក្ខសោកពេគភ័យចរៃ្ចរបត្រគ្រប់ប្រការ សមតាមប្រាថ្នានៃឲ្យ, ឯកឧត្តម, អស់លោក-អ្នកកុំបីឃ្លៀងឃ្លាត ។ ហើយសូមឲ្យខៅតាទាំង ១ ម៉ឺននាក់ជាតុជួយគាំទ្រសមាគមគិលានសង្គ្រោះនេះ ឲ្យមានអាយុគ្រប់ ៥ ពាន់ព្រះវស្សា កុំបីឃ្លាតឡើយ ។

ពិធីបុណ្យព្រហ្មទានលើកទី ៧
នៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ

ប្រគេនសង្ឃាន់ដល់សមណានិស្សិតដែលប្រឡងចេញពីពុទ្ធិកវិទ្យាល័យព្រះសុភម្រឹត

លោក ចាប - ពិន រៀបរៀង

កាលពីថ្ងៃទី ២៦ កុម្ភៈ ព.ស. ២៤៩៩ គ.ស. ១៩៥៦,

នៅបរិវេណពុទ្ធិកវិទ្យាល័យព្រះសុភម្រឹត មានធ្វើពិធីបុណ្យព្រហ្មទាន ប្រគេនសមណានិស្សិតដែលប្រឡងចេញពីពុទ្ធិកវិទ្យាល័យនេះ ក្រោមព្រះពាធិបតីភាពនៃព្រះគុណា ជាអម្ចាស់ជីវិតលើត្បូង ។

បុណ្យនេះជាបុណ្យព្រហ្មទានលើកទី ៧ នៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ ដែលមានលោក ង៉ែយ - ប៊ុក ជាប្រធាន ទើបក្រុមអភិបាលសមាគមនេះ ចាត់ធ្វើរួមជាមួយពុទ្ធបរិស័ទអ្នកជិះថ្នាក់ទុក្ខមគតិនេះ, គេឆ្លើមធ្វើពីល្ងាចថ្ងៃសៅរ៍ទី ២៥ កុម្ភៈ ១៩៥៦ ដោយកម្មវិធីទំនៃព្រះសង្ឃចម្រើនព្រះបរិត្តរួចនិមន្តព្រះតេជព្រះគុណ ព្រះពោធិវង្ស ហួត - ភាត ចាត់ហ្វាតពុទ្ធិកវិទ្យាល័យព្រះសុភម្រឹតសំដែងធម៌ ។

នៅថ្ងៃអាទិត្យទី ២៦ កុម្ភៈ វេលាព្រឹលម៉ោង ១០ សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត សង្ឃនាយកគណៈមហានិកាយ, ព្រះថេរៈមួយអង្គតំណាងព្រះសង្ឃនាយកស្តីទីគណៈធម្មយុត្តិ, សម្តេចព្រះធម្មលិខិតទត្តមច្រីក្សា ល្វី - ឯម, ព្រះពោធិវង្ស ហួត - ភាត ចាត់ហ្វាតពុទ្ធិកវិទ្យាល័យព្រះសុភម្រឹត, ព្រះមហាព្រហ្មមុនី ខេត - ស៊ូ ចាត់ហ្វាតវត,

ព្រះពុទ្ធសាសនៈហានាទូក្រម, សាស្ត្រាចារ្យទាំងបព្វជិតទាំងគ្រហស្ថ ព្រមទាំងសមណនិស្សិតដែលត្រូវទទួលព្រហ្មទាន បានទទួល-បានអញ្ជើញមកជួបជុំក្នុងទីសន្និបាតនេះ ។

នៅថ្ងៃដដែល វេលាម៉ោង ១៦ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងស្តេចយាងដល់ ដោយមានសម្តេចជហ្វាកំងវរៈរៀងជ័យអធិបតីស្រីគ្នាវ ប៉ែន-ឌុត, លោក ឃឹម-ទិត, ឯកឧត្តមចាក់-ចូរ៉ាត្រឿង, ឯកឧត្តម សម-សារី សមាជិកក្រុមប្រឹក្សាព្រះពុទ្ធសាសនា, លោក ស៊ឹម-ភ័ ប្រធានក្រុមប្រឹក្សាព្រះពុទ្ធសាសនាចិត្រ, លោក អ៊ុំ-ឈាង ស៊ុន ប្រធានវេជ្ជសភា ទីឯវេជ្ជបណ្ឌិតចូលរួមក្នុងពិធីនេះ ដែលយើងសូមអភ័យទោសដោយពុំបានលេខាមសព្វគ្រប់ បានអញ្ជើញមកជួបជុំជាពុទ្ធបរិពារ ។

បន្ទាប់ពីគេលធ្វើគារវកិច្ចចំពោះព្រះពុទ្ធសាសនាមួយរំពេចមក, លោកយ៉ុយ-ប៊ុក ប្រធានសមាគមបានថ្លែងសុន្ទរកថា ទទួលអំណរស្វាគមន៍ព្រះពុទ្ធសាសនាចិត្តថ្លាយតបិមានតាមដែលសមាគមបានធ្វើមធ្វើព្រហ្មទាន ។ រួចហើយព្រះគោធិវង្ស ហួត-តាតចាងហ្វាងពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត បានថ្លែងសុន្ទរកថាពណ៌នាអំពីព្រឹត្តិការណ៍នៃពុទ្ធិកវិទ្យាល័យនេះនឹងព្រហ្មទាន ។ បន្ទាប់ពីនេះ ព្រះពុទ្ធសាសនាចិត្រថ្លែងព្រះពុទ្ធសុន្ទរកថាតប; ក្នុងព្រះពុទ្ធសុន្ទរកថានោះទ្រង់ព្រះពុទ្ធបានព្រះបរមការណោវាទ ដំលឹកសមណនិស្សិតឲ្យប្រតិបត្តិតាមព្រះពុទ្ធដីកា ដើម្បីឲ្យចំរើនទាំងផ្លូវលោកផ្លូវធម៌ ដល់ប្រទេសជាតិ ។

លុះចប់ព្រះពុទ្ធសុន្ទរកថា, គណៈកម្មការបុណ្យព្រហ្មទានបានអាន

ថ្វាយខ្ញុំវបញ្ជីកយនាមសមណានិស្សិតដែលជាប់សញ្ញាប័ត្រលេខ ១ ហើយ
លើកព្រហ្មទានទី ១ ថ្វាយព្រះពុទ្ធ ។ ខ្ញុំទទួលហើយខ្ញុំប្រគេនដល់
សមណានិស្សិតនោះ ។ បន្ទាប់ពីនោះ គណៈកម្មការបានអានដូនខ្ញុំវបញ្ជី
កយនាមសមណានិស្សិតដែលជាប់សញ្ញាប័ត្រតមក ទើលើកព្រហ្មទាន
ជូនវេជ្ជទាំង ៦ ឱ្យមានសម្តេចជហ្វាកាំង ជាដើមឱ្យប្រគេនសមណានិស្សិត
តាមលំដាប់លេខរៀង ព្រមទាំងអញ្ជើញព្រះពុទ្ធបរិស័ទជាម្ចាស់ព្រហ្មទាន
ឱ្យប្រគេនដកបដល់គ្រប់ចំនួនសមណានិស្សិតគឺ ២០ រូប តាមដែល
គណៈកម្មការបានកំណត់ខុសថាត្រូវផ្អាកការប្រគេន ១ លើក ដើម្បីថ្វាយ
ព្រះពុទ្ធសាសនចំពោះព្រះពុទ្ធជាស្តេចយាងទៅ កុំបាច់តង់ចាំយូរនាំពិបាក
ព្រះអង្គ, ចាំព្រះពុទ្ធជាស្តេចយាងចេញហើយ ទើបប្រគេនតទៅទៀត ។
លុះចប់កិច្ចប្រគេនព្រហ្មទានលើកទី ១, សំឡេងស្មូធ្យាយដយន្តោ នៃ
ព្រះសង្ឃក៏លាន់ឮរំពងឡើង ដែលនាំឱ្យគេតប៉ាតិជ្ជោមដល់អ្នកស្តាប់
យ៉ាងក្រៃលែង ។ កាលចប់ការស្មូធ្យាយន៍នៃព្រះសង្ឃ, ពុទ្ធបរិស័ទ
បានទទួលផលដោយបត្តិទានគាថា (យំកិញ្ចិ) ។ លុះព្រះពុទ្ធជាស្តេចយាង
ហើយ គណៈកម្មការបានផ្តើមប្រគេនព្រហ្មទានម្តងទៀតជាលើកទី ២
ដកបដល់គ្រប់ចំនួនសមណានិស្សិតដែលប្រឡងជាប់ទាំង ៥២ រូប ។

ពិធីបុណ្យនេះបានបញ្ចប់នៅវេលាម៉ោង ១៧ កន្លះ ប្រកបដោយ
បរិយាកាសដ៏រីករាយមហិមា ។

គ្រួមជំនុំកំណែទម្រង់ធម្លាប់
COMMISSION DES MŒURS & COUTUMES

ភាសិតសង្ឃរាយ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៨ លេខ ៥ ខែឧសភា ព.ស. ២៤៩៩ គ.ស. ១៩៥៦

ក្រុមជំនុំនៃប្រពៃណីទម្លាប់
COMMISSION DES MOEURS & COUTUMES

ភគ្គវជសនីយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មាតិកា	ទំព័រ
— រឿងប្រៀបធៀបរកសេចក្តីពិត	ឃុនអគ្គកោវិទ ជា-យូរ	៤០៣
— ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា	លោក ទៀង-តៃឈុន ប្រែ	៤១២
— ឥទ្ធិបាទធម៌	ព្រះមហា អ៊ុម-ផេង	៤១៨
— ជាតកថារឿងពុទ្ធរូបបុរាណ (តទៅ) ...	ឃុនអគ្គកោវិទ ជា-យូរ ប្រែ	៤២៧
ផ្នែកអក្សរសាស្ត្រ		
— ចិត្តល្ងង់ខ្មៅនឹងចិត្តឆេះដឹង	ឃុនបណ្ឌាគុរ័ក្ស ប៊ូ-ប៉ូ	៤៣៣
— រឿងព្រះបាទវុសភ៏ខសាជិ និងព្រះនាង សេហេរីស្តានី (ត-ចប់)	អ្នកស្រី សារិះយ៉ាន ប្រែ	៤៣៨
— សុភាសិតរាជនីតិ ពាក្យកាព្យ (ត-ចប់)..	អ្នកឧកញ៉ា នៅ	៤៤៧
— ពេត្រព្រះរាជា (តទៅ)	លោក ស៊ុន-ហ៊ាន ប្រែ	៤៥៦
— រឿងសាមកុក (តទៅ)	ឧកញ៉ា នូ-ហន	៤៦៣
— រឿងបល្ល័ង្កទិព្យ (តទៅ)	លោក វ៉ាយ-ប៊ុក ប្រែ	៤៧០
កំណត់ទំនឹងប្រវត្តិការណ៍		
— ពិធីសម្ពោធសាលាបាលីជាន់ខ្ពស់ នៅ ខែត្រសៀមរាប	ពុទ្ធសាសនបណ្ឌិត្យ	៤៧៥
— ពិធីបុណ្យទក្ខិណានុប្បទាន	ព្រះអាចារ្យ នូ-ភីញ	៤៨៥
— ពិធីសម្ពោធក្នុងមន្ទីរពេទ្យព្រះសង្ឃ(តចប់)	ពុទ្ធសាសនបណ្ឌិត្យ	៤៩១

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ២៣០រ, ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Sur la vérité	*M. CHEA-YOU*	403
— Le Bouddhisme au Cambodge..	*Traduit par M. TIANG-TAY-CHHUN*	412
— Iddhipadadharma	*Vénérable OUM-PHENG.*	418
— Les statues Bouddhiques primitives (suite)	*Traduit par M. CHEA-YOU..*	427

PARTIE LITTÉRAIRE:

— La pensée juste et la pensée fausse	*M. BOU-PO*	433
— Le Roi RUZVANSCHAD et la Princesse CHEHERISTANI (suite et fin)	*Traduit par Mme PICH-SAL née SRIN-SARIS-YANN*	438
— Subhasitarajaniti (suite et fin)	*Oknha NEOU*	447
— Conte "Le Diamant du Raja" (suite)	*Traduit par M. SIN-HEAN* .	456
— Histoire de SAMKOK (suite) . .	*Oknha NOU-KAN*	463
— Les trente deux récits du TRONE (suite)	*Traduit par M. RAY-BUC* .	470

NOTES ET CHRONIQUES:

— Inauguration de l'Ecole Supérieure de Pali de la Province de Siemreap	*Institut Bouddhique*	475
— Cérémonie "dakkhinanuppadana"	*Vénérable NOU-KENH*	485
— Inauguration de l'Hôpital des Bonzes (suite et fin) . .	*Institut Bouddhique*	491

Prix d'abonnement annuel (comprenant 12 numéros) 230$00

ផ្នែកសាសនា

រឿងប្រៀបធៀបក្នុងការរកសេចក្តីពិត

ឃុនអត្តកោវិទ ជ៉ា - ប៉ូរ៉ែ ពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

អ្នកប្រាជ្ញចាំង ឡាយពោលថា "ការពិសោធន៍ស្រាវជ្រាវរក សេចក្តីពិតនឹងសម្មដ្ឋានៃរបស់ពិត គេអាចរកឃើញបានដោយការ ប្រៀបធៀប" ហេតុនោះការប្រៀបធៀប ទើបជាមេរៀនដ៏សំខាន់ ក្នុងការនិយ្យយទូរសេចក្តីសន្និដ្ឋាន ចំពោះការនិយាយកូតករកុហក ឬការនិយាយពិតត្រង់ ។

ចាប់តាំងពីសញ្ញាតញ្ញាណរបស់មនុស្សចេះប្រើការប្រៀបធៀបមក, ការប្រៀបធៀបក៏ទៅជាគោលពិសោធន៍រកសេចក្តីពិត ក្នុងវត្តចាំងពួន ហើយតាំងពីសម័យនោះរហូតមកដល់សម័យឥឡូវនេះ ការប្រៀបធៀប ក៏ទៅជាមេរៀនដ៏សំខាន់ ជួយកំទៅកណ្តាលនៃសេចក្តីនិយមចាប់អាន ដែលមិនមានចំនេះនឹងជ្រាស់ប្លុកបានឡើយ ។

សេចក្តីនេះក៏ជាគ្រឿងបញ្ជាក់ឲ្យឃើញច្បាស់ថា គ្រប់ ៗ បណ្តា អ្នកដែលមានសេចក្តីចេះដឹងល្អ ចូលចិត្តល្អ ទឹងមានសមត្ថភាព អាចផ្តល់ ចំណេះឲ្យអ្នកដទៃបានចេះដឹងបានចូលចិត្តផងនោះ ត្រូវជាអ្នកមានគំនិត ចេះគិតប្រៀបធៀបយ៉ាងល្អបំផុត ។ សូម្បីក្នុងការប្រតិបត្តិកិច្ចការផ្សេង ៗ ឬនឹងនិយាយនឹងធ្វើអ្វី ។ ក៏ដោយ ត្រូវតែអាស្រ័យយកការប្រៀបធៀប

មកធ្វើជាបន្ទាត់ដឹកតម្រង់មើលការប្លែក ។ ក្នុងវិធានការដែលត្រូវធ្វើ ឬ ពាក្យដែលត្រូវនិយាយ ដែលនាំឲ្យដឹងខុសដឹងត្រូវ ។

អ្នកដែលមានការចេះដឹងច្រើន កំព្រោះមានការគិតប្រៀបធៀបច្រើន, អ្នកដែលមានការចេះដឹងល្អ កំព្រោះមានការគិតប្រៀបធៀបល្អ, អ្នកដែលមានសមត្ថភាព អាចផ្តល់ចំណេះឲ្យអ្នកដទៃបានដោយល្អ កំព្រោះឈ្លាសក្នុងការប្រៀបធៀបល្អ ដែលនាំឲ្យអ្នកទទួលចំណេះបានបូលចិត្តយ៉ាងធាប់រហ័ស ។

គោលនៃការប្រៀបធៀបមានដូច្នេះជាដើម គឺ :

១.- បើចង់ដឹងរបស់ខ្ពស់ ត្រូវយករបស់ទាបមកប្រៀបធៀបគ្នាមើល, បើចង់ដឹងរបស់ទាប ត្រូវយករបស់ខ្ពស់មកប្រៀបធៀបគ្នាមើល;

២.- បើចង់ដឹងការជ្រៅនឹងការរាក់ ត្រូវយកការរាក់នឹងការជ្រៅនៃវត្ថុនោះមកប្រៀបធៀបគ្នាមើល;

៣.- បើចង់ដឹងវត្ថុចម្ងាំ ត្រូវយកការតូចម្ងាការធំនៃវត្ថុនោះមកប្រៀបធៀបគ្នាមើល;

៤.- បើចង់ដឹងវត្ថុស្តើងឬក្រាស់ ត្រូវយកការស្តើងឬក្រាស់នៃវត្ថុនោះមកប្រៀបធៀបគ្នាមើល;

៥.- បើចង់ដឹងល្អឬមិនល្អនៃវត្ថុណា ត្រូវយកការល្អឬមិនល្អនៃវត្ថុនោះមកប្រៀបធៀបគ្នាមើល ។

ការប្រៀបធៀបនេះ ជាការងាយណាស់ ស្រួលគិតណាស់ ។ តែទោះបីជាការងាយស្រួលគិតដូច្នេះក៏ដោយ ក៏នៅតែមានមនុស្សជា

ច្រើនណាស់ ដែលមិនព្យាយាមរកសេចក្តីចេះដឹងនឹងសេចក្តីចូលចិត្តដោយការប្រៀបធៀបទេ តែងតែធ្វើតាមដោយការមិនចេះមិនចូលចិត្តរហូតមួយជីវិត ។

គោលសំខាន់ក្នុងការប្រៀបធៀបនោះ នៅត្រង់ការពិចារណារកសេចក្តីចូលចិត្តក្នុងរបស់ណាមួយជាមុនសិន ថារបស់នេះមានរូបសំឡេងក្លិន, រស, សម្ផស្ស ដូចម្តេច? មានគុណ, ដំណើរ, ហេតុ, ផល ដូចម្តេច? មានអាការជាដើមថា កើត, ឋិតនៅ, រលត់ទៅ ដូចម្តេច? ត្រឹមណា? ព្រោះថា កាលបើយើងយល់ជាក់នូវអាការរបស់វត្ថុនោះហើយ ។ យើងយកទៅប្រៀបធៀបនឹងវត្ថុដទៃទៀត ដែលមិនទាន់ចេះដឹងឲ្យចេះដឹងឡើងដូច្នេះឈ្មោះថា យើងមានសេចក្តីចេះដឹង ដោយការប្រៀបធៀប ។ ពាក្យថាលីថា "តីរណបញ្ញា" ប្រែថា "សេចក្តីចេះដឹងដោយការពិចារណាប្រៀបធៀប" ហើយមានសេចក្តីចេះចាំយ៉ាងជាក់ច្បាស់នៅក្នុងដួងចិត្ត រហូតអស់ជីវិត មិនសូវមានការច្រឡូកច្រឡំភ្លាំងភ្លេចឡើយ ។

ហេតុនោះ ការប្រៀបធៀប ជាមេរៀនប្រចាំនៅក្នុងលោក ដែលមនុស្សគ្រប់ៗគ្នា មានបំណងចង់ឲ្យជីវិតរបស់ខ្លួនចំរើនរុងរឿងដោយប្រាជ្ញា ។ សិក្ខាកាមកុលបុត្រត្រូវព្យាយាមយកចិត្តទុកជាក់ក្នុងមេរៀននេះឲ្យយ៉ាងច្រើនជាទីបំផុត ទើបប្រាជ្ញាលូតលាស់បាន ។ មែនពិតប្រាជ្ញារបស់មនុស្សដែលនឹងចំរើនរុងរឿងបាននោះ មិនមែនទៅត្រង់រៀនសូត្រតែមួយមុខប៉ុណ្ណោះទេ ព្រោះយើងនឹងរៀនសូត្រគ្រប់វ័យមិនបាន ដោយអាជីវកម្មមិនបើកឱកាសឲ្យ សូម្បីតែក្នុងវ័យដែលកំពុងរៀន ឬក្នុងថ្ងៃ

ដែលយើងរៀន យើងគង់មិនបានរៀនរហូតមួយរ័យឬពេញមួយថ្ងៃទៅ
បានទេ តែដែលថ្ងៃជាវេបស់យើងចេះតែចំរើនទៅបាននោះ ព្រោះមាន
ការប្រៀបធៀបជាគ្រឿងជួយជ្រោមជ្រែង ទើបជាឧកាសនឹងជាផ្លូវឲ្យ
អ្នកដែលកើតមានពេលរៀនតិច តឡប់ទៅជាអ្នកថ្ងៃជ្ញនឹងជាមនុស្ស
សំខាន់ក្នុងលោកបាន ។

គោលនៃការប្រៀបធៀបនេះ មិនបានកំណត់ប្រទេស មិនបាន
កំណត់ពីលំនៅ ទាំងមិនពិបាកដល់ការរៀនទេ យើងនឹងរៀនសូម្បីតែកន្លះ
ក្នុងកំពីរាល កណ្តាលផ្លូវថ្នល់ រហូតទៅដល់ព្រៃកំបុកក៏បាន ត្រូវចាំពុកថា
"វិជ្ជាដែលពិបាក តែរៀនចេះដឹងឡើងបានដោយការប្រៀបធៀប" ។

ព្រោះហេតុនោះ ក្នុងការទន្ទេញក្តី ក្នុងការរៀនក្តី ក្នុងការបង្ហាត់
បង្ហាញក្តី ក្នុងការជាស់គ្នីនខ្លួនឯងក្តី បើយើងព្យាយាមរកគោលនៃ
សេចក្តីប្រៀបធៀបឲ្យបានច្រើនប៉ុន្មាន លទ្ធផលដ៏ល្អក៏នឹងចំរើនដល់
យើងបានច្រើនប៉ុណ្ណោះដែរ ។

កាលព្រះពុទ្ធអង្គទ្រង់ស្វែងរកព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ បាន
ទ្រង់ធ្វើទុក្ករកិរិយាដោយសេចក្តីវង្វែង គឺទ្រង់ប្រតិត្តខុសផ្លូវមជ្ឈិម
បដិបទា ព្រះអង្គបានទទួលសេចក្តីលំបាកស្ទើរនឹងបង់ព្រះជន្ម តែពេល
ក្រោយទ្រង់តឡប់ព្រះទ័យវិញ ដោយទ្រង់ប្រើវិធីប្រៀបធៀបជាគ្រឿង
ជាស់គ្នីនព្រះអង្គឯងថា :

"ធម្មតាឈើស្រស់ដែលទទឹកជោកជាំទៅដោយជ័រ ទាំងត្រាំនៅ
ក្នុងទឹក បុរសត្រូវការភ្លើងបានយកឈើនោះមកព្តត ដើម្បីឲ្យឆេះជាភ្លើង

ឡើង គេនឹងត្រូវហត់ខ្សែយ៉ាងខ្លាំង មិនអាចញាំងក្តៅឲ្យឆេះឡើងបាន, ប្រៀបដូចបុគ្គល ដែលមានចិត្តទន់ភ្លន់ជាប់តាំងនៅដោយកិលេស ត្រូវតាំងនៅក្នុងបក្ខបក្ខពលដោយកាមារម្មណ៍, បុគ្គលពួកនេះ មិនអាចញាំងខ្លួនឲ្យដល់នូវទីបំផុតទុក្ខបានទេ ។

មួយទៀត ឈើស្រស់ដែលទន់ភ្លន់ជាប់តាំងនៅដោយជ្រុះ សូម្បីបុគ្គលលើកស្រង់ផុតពីទឹក ហើយយកទៅដាក់នៅលើគោក បុរសត្រូវការភ្លើង បានយកឈើនោះមកពួត ដើម្បីឲ្យឆេះជាភ្លើងឡើង គេមិនអាចញាំងភ្លើងឲ្យកើតឡើងបានដោយឈើនោះទេ, ប្រៀបដូចបុគ្គលមានចិត្តទន់ភ្លន់ជាប់តាំងដោយកិលេស សូម្បីចេញចាកផ្ទះតែកាមារម្មណ៍ហើយ ក៏មិនអាចញាំងខ្លួនឲ្យផុតទុក្ខបាន ។

មួយវិញទៀត ឈើស្ងួតដែលដាក់នៅលើគោក បុរសត្រូវការភ្លើង បានយកឈើនោះមកពួត គេអាចពួតឲ្យឆេះជាភ្លើងឡើងបាន ព្រោះឈើនោះស្ងួតតាំងដាក់នៅលើគោក, ប្រៀបដូចបុគ្គលដែលចេញចាកកាមហើយ តាំងបានលះតម្រេកក្នុងកាមឲ្យបានស្ងប់រម្ងាប់ដោយប្រពៃ, បុគ្គលពួកនេះ អាចព្យាយាមញាំងខ្លួនឲ្យផុតទុក្ខបាន" ។

កាលព្រះសម្ពុទ្ធទេវតាប្រៀបធៀបដាស់តឿនព្រះអង្គ ដោយព្រះអង្គឯងស្រេចហើយ ក៏ទ្រង់លើកលែងធ្វើទុក្ករកិរិយា ហើយមកបំពេញព្យាយាមផ្លូវចិត្ត គឺទ្រង់ចំរើនសមថភាវនា ធ្វើចិត្តឲ្យជាសមាធិ មានអារម្មណ៍តែ១ រហូតដល់សម្រេចឈាន ៤ ញាណ ៣ អរិយសច្ច ៤ ក៏ដល់នូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ បានបរមាភិសេកជាព្រះសម្ម-

សម្ពុទ្ធ ច្រើកដងណាស់ ។ ពាក្យនេះសម្រាប់ឃើញថា ព្រះពុទ្ធទ្រង់ បានសម្រេចព្រះពោធិញ្ញាណ ក៏បានដោយការព្យាយាមយក ដែលមាន ការប្រឹងប្រែងមកជាមុន ។

សូម្បីក្នុងសម័យដែលមុនទើនចេញទ្រង់ចំពេញសត្តបការកិច្ច គឺ ទ្រង់ចេញសំដែងធម៌ច្រើនសន្ធឹក ទ្រង់រួញរកអល់អែកព្រះហ្ឫទ័យ ព្រោះទ្រង់ព្រះតំរិះឃើញថា ធម៌ដែលព្រះអង្គបានត្រាស់ដឹងហើយនោះ ជាគុណធម៌ដ៏ល្អិតផ្សាលជ្រៅក្រៃលែង អ្នកដែលត្រៃកអរក្នុងគាមគុណ កម្រទើនត្រាស់ដឹងតាមបាន តែអាស្រ័យព្រះមហាករុណាសមាយោគ ក្នុងពពួកសត្វដ៏ខ្ជាំងក្លាណាស់ ទើបទ្រង់ពិចារណាទៀតថា :

"បុគ្គលដែលមានកិលេសតិចតួចស្តួចស្តើងក៏មាន, មានកិលេស ក្រាស់ក៏មាន, មានឥន្ទ្រិយចាស់ក្លាក៏មាន, មានឥន្ទ្រិយទន់ខ្សោយក៏មាន, ជាបុគ្គលដែលគួរប្រៀនប្រដៅឲ្យដឹងបានដោយងាយក៏មាន, ដឹងបាន ដោយក្រក៏មាន ប្រៀបដូចជាបទុមជាតិ (ផ្កាឈូក) ដែលកើតក្នុង ទឹក ចំរើនក្នុងទឹក មានទឹកចិញ្ចឹមបំប៉ន់ទុក ផ្កាខ្លះលិចនៅក្នុងទឹក ខ្លះបិត នៅត្រឹមទឹក ខ្លះបិតនៅផុតពីទឹក, បណ្តាផ្កាឈូកទាំងនោះ ផ្កាឈូក ដែលបិតនៅផុតពីទឹក ត្រូវកំដៅព្រះអាទិត្យទើរកក្នុងថ្ងៃនេះ ដែលបិត នៅត្រឹមទឹកទើរកក្នុងថ្ងៃស្អែក ដែលបិតនៅក្នុងទឹកទើរកក្នុងថ្ងៃតទៅ ។ ចំណែក ផ្កាឈូកដែលទើរកមានអាការផ្សឹងគ្នាដូច្នេះម្តេចមិញ ពោនយ៉ាសត្វក៏មាន ឧបនិស្ស័យផ្សឹងគ្នាដូច្នោះដែរ" ។

កាលខ្ញុំប្រៀបធៀបឃើញប្រចក្សដោយព្រះញាណដូច្នេះហើយ
ក៏ខ្ញុំបើកផ្លូវព្រះមហាករុណាឲ្យជាបុរេចារិកតទៅ ហើយខ្ញុំសំដែងធម៌
ប្រោសសត្វ រហូតដល់ស្តេចរំលត់ខន្ធបរិនិព្វាន ។ សូម្បីសាសនធម៌
ពាក្យប្រៀនប្រដៅ ដែលប្រជុំចុះក្នុងព្រះត្រៃបិដកទាំងអស់ ក៏មានពាក្យ
ប្រៀបធៀបជាឧទាហរណ៍ ច្រើនហួសវិស័យតុំអាចនាំមកពណ៌នាក្នុងទីនេះឲ្យអស់ដើងបាន ឱនឹងសាធកៈតែព្រះបច្ចុប្បន្នក៏ថា ក្នុងអាសានកិច្ចថាៈ

"ម្នាលភិក្ខុទាំងឡាយ! តថាគតជាសាស្តឿនលោកទាំងឡាយថា
សង្ខារទាំងឡាយមានសេចក្តីអស់ទៅនឹងសាបសូន្យទៅជាធម្មតា, លោក
ទាំងឡាយចូរញ៉ាំងសីល, សមាធិ, បញ្ញាឲ្យដល់ព្រមដោយសេចក្តីមិនប្រមាទចុះ ព្រោះថាធម៌ទាំងឡាយ ដែលជាកុសលទាំងអស់មានសេចក្តីមិនប្រមាទជាឫសគល់ មានសេចក្តីមិនប្រមាទជាទីប្រជុំចុះ, សេចក្តីមិនប្រមាទ បណ្ឌិតពោលថា ជាធម៌ដ៏ប្រសើរលើសលប់ជាងធម៌ទាំងអស់ ប្រៀបដូចស្នាមជើងនៃសត្វទាំងឡាយ ដែលដើរលើផែនដីទាំងប៉ុន្មាន ស្នាមជើងសត្វទាំងអស់នោះ តែងប្រជុំចុះក្នុងស្នាមជើងនៃដំរី ស្នាមជើងដំរី បណ្ឌិតពោលថា ជាធំលើសលប់ជាងស្នាមជើងសត្វទាំងអស់" ។

ដែលពោលមកទាំងនេះសំដែងឲ្យឃើញថា រឿងប្រៀបធៀបជាមេរៀនដ៏ធំសំខាន់ក្រៃលែង សូម្បីតែព្រះពុទ្ធអគ្គជាអគ្គបុគ្គលដ៏ធំលើសលប់ជាងអ្នកប្រាជ្ញជាបណ្ឌិតក្នុងលោក កាលស្តេចដំរិះបរិនិព្វាន ក៏បានខ្ញុំជាស្តឿនភិក្ខុសង្ឃដោយធម៌ដែលមានពាក្យប្រៀបធៀបជាប់នៅផង ដូចបានពោលមកហើយ ព្រោះដូច្នេះយើងទើបឃើញថា ការប្រៀប

ធៀបនេះ ជាមេរៀនដែលត្រូវតែមានខាងមិនបាន ទាំងផ្លូវលោកទាំងផ្លូវធម៌ សំរាប់វិនិច្ឆ័យសេចក្តីសន្ទិះសង្ស័យ កូតកវកុហកអាក្រក់ល្អត្រង់យ៉ាងដូចបានពោលមកហើយពីខាងដើម ។

សមដូចបុរាណបណ្ឌិតបានឲ្យនូវទៀតថា:

១- កូនអើយកូនសំឡាញ់ អ្នកចូរគិតកាញ់មើលសត្វខ្លា
សូម្បីសាហាវកាចយ៉ាងណា ក៏មិនញាំកូនច្រៃឡើយ ។

២- បុណ្យអើយបុណ្យលើសលប់ គិតត្រង់គួរគោតសត្វខ្លាញី
ស្នេហាកូនឈ្លោលពេកពេញទី ភាវៈស្ងួរគាល់អស់ជន្ម ។

៣- កូនអើយកូនសួនក្លា មើលបៃបបក្សាក្នុងព្រឹក្សាព្រៃ
រកគោជន៍ឲ្យគូក្នែកវៃ បានវៃនាំមកឲ្យច្រៃឡើយ ។

៤- កូនអើយកូនឧរស កូនស្រស់មើលបៃបបក្សីញី
ប្តីខ្លួនល្ងង់លោមឲ្យសាមគ្គី យកស្មាបចក់រើបាទោសប្តី ។

ទាំងនេះយើងឃើញបានថា ទុក្ខ ១ បទ ។ សុទ្ធតែប្រដៅដោយលើកយកនិស្ស័យសត្វមកឲ្យយើងគិតប្រៀបធៀបមើល ដើម្បីឲ្យយើងចូលចិត្តបានងាយ ។ យើងឃើញថាជាការងាយយល់ពិតមែន គ្រាន់តែបានឃើញឬបានឮប៉ុណ្ណោះ ក៏អាចបង្អោនចិត្តយើងឲ្យទន់ភៅតាមនិស្ស័យសត្វទាំងនោះបាន ។

មួយទៀត បណ្តាសុភាសិតដែលអ្នកប្រាជ្ញប្រៀនប្រដៅពួកនិស្សិត, សុភាសិតខ្លះ ក៏លើកយកគុណនៃវិទ្យាមកប្រៀបធៀបឲ្យសិស្សស្តាប់ដែរ ដូចជ្រុះថា:

វិទ្យាគ្រឿងសួយ ហើយថែមទាំងដួយ អ្នកឲ្យត់ថោកទាប ទាំង
រូបអាត្រក់ ឲ្យមានសុភាព ល្អឡើងជាប ក្នុងពិភពលុំ ។

វិទ្យាជាទ្រព្យ សំពាប់នៅជាប់ ខ្វះគ្មានលំ មានផលវិបុល្លទ្ធ
ទៀងទាត់ឧត្តម មិនលះបង់អ. ម្ចាស់វិទ្យាឡើយ ។

វិទ្យាលោកប្រៀប ដូចសោនៅទៀប ជិតដៃបង្គើយ សំពាប់ចាក់
យក យសស័ក្តិជាគ្រើយ សម្បត្តិផងហើយ សន្តានត្រឿងលាន ។

វិទ្យាគ្រូអ្នក ប្រាជ្ញបណ្ឌិតជាក់ ពីមានញាណ មនុស្សទាំង
ពិភព ស្រឡាញ់ពាប់អាន អស់លោកដែលមាន ចំណេះវិទ្យា ។

មួយវិញទៀតថា:

វិទ្យាប្រៀបដូចកំភ្លាំងកាយ សុចរិតប្រៀបប្រាយដូចគ្រោះកាំង
ការពារអាវុធដូចទាំង សំពាប់ពាក់ងអ្នកនោះណា ។
បញ្ញាប្រៀបដូចគ្រឿងអាវុធ ខ័នថ្នាំមុនមុតគ្រែសោះសា
សតិប្រៀបដូចខែលរឹង ការពារអាវុធបច្ចាមិត្រ ។

អ្នកប្រាជ្ញដែលសរសើរកេរ្តិ៍ឱយមនៃវិទ្យាគុណ ដោយមានការ
ប្រៀបធៀបត្រង់ៗមេបទ នេះសំដែងឲ្យឃើញថាការប្រៀបធៀបនោះ
ជាគុណជាតិដ៏សំខាន់ក្នុងការពិសោធន៍ស្រាវជ្រាវរកសេចក្តីពិត ឱ្យ
សម្រេចនូវបំណងរបស់ពិត រហូតដល់ការសិក្សាប្រៀនប្រដៅគ្រប់យ៉ាង, ព្រោះ
ហេតុនោះ ការប្រៀបធៀប លោកទើបចាត់ជាមេរៀនដ៏សំខាន់ ប្រចាំ
នៅក្នុងលោកដោយមានមិនបាន យ៉ាងដាច់ខាត ។

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា

ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ-សុម្ពាជ ធម្មារាម:

សាស្ត្រាចារ្យនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅភ្នំពេញ,
សមាជិកឆ្លើយឆ្លងនៃសាសាថាភ័ងសែសប៊ែកជុងបូព៌ាប្រទេស,
សមាជិកនៃគណៈកម្មការវប្បធម៌ខ្មែរ បានតែងជាភាសាថាភ័ង

លោក ទៀង-តៃ-ឈុន ក្រមការជើមខ្សែ ប្រែជាភាសាខ្មែរ

ប្រទេសកម្ពុជា ជាប្រទេសមួយតូច តាំងមនុស្សក៏មានស្តួចស្តើង ប៉ុន្តែបើយកប្រទេសនេះទៅធៀបនឹងប្រទេស ដែលកាន់ព្រះពុទ្ធសាសនាដូចគ្នានៅក្នុងសាកលលោក យើញថាជនជាតិខ្មែរយើង គោរពព្រះពុទ្ធសាសនា ដោយស្មោះស្មគ្នាជាងប្រជាជនក្នុងប្រទេសទាំងនោះពិតប្រាកដ, បន្ទាប់មកទៀត គេពោលដោយឥតញញើតមាត់ហើយគ្មានបំផ្លើសផង ថាខ្មែរយើង ៩៩ ភាគរយកាន់លទ្ធិព្រះពុទ្ធសាសនា ។

យើងដឹងច្បាស់ហើយថាកាលពី ៤០០ ឆ្នាំមុននេះ ស្រុកចម្បា ដែលបិតនៅត្រង់ប្រទេសយៀកណាមកណ្តាលសព្វថ្ងៃនេះ មានប្រជាជនជាតិជ្រាំនឹងចាមជាកូនចៅនៃអ្នកកាន់សាសនាអ័ស្លាម ដែលចេញចាកស្រុកចម្បា នាំយកសាសនាអ័ស្លាម ចូលមកក្នុងប្រទេសកម្ពុជា, នៅគ្រាដដែលនេះ ប្រជាជនជាតិអ៊ីប៉ុបក៏បាននាំយកសាសនាគ្រីស្តចូលមកប្រទេសកម្ពុជាដែរ ។ ពួកបរិស័ទនៃសាសនាខាងលើនេះ បានសាងព្រះវិហាររបស់ខ្លួននៅជិត ។ ព្រះវិហារខ្មែរ តែជនជាតិខ្មែរដោយ

គាប់ចិត្តនឹងសាសនាព្រះពុទ្ធយ៉ាងស៊ប់ស្អួន ក៏គ្មានបែរគំនិតទៅរកសាសនាអ័ស្លាមនឹងសាសនាគ្រីស្តឡើយ ។

តាមប្រវត្តិសាស្ត្រ : មហាក្សត្រនឹងមន្ត្រីធំៗ សម័យនោះ បានទាំយកសាសនាព្រាហ្មណ៍ចូលមកប្រទេសកម្ពុជាយើង តាំងពីដើមសកពជនៃសាសនាគ្រីស្ត, ចំណែកឯសាសនាព្រះពុទ្ធវិញ ក៏បានជ្រាបចូលមកស្រុកខ្មែរក្នុងរវាងឆ្នាំ ៤៩០ ក្រោយព្រះយេស៊ូគ្រីស្ត គឺជាព្រះពុទ្ធសាសនាដែលគេហៅថាថេរវាទ ឬទក្ខិណនិកាយ ។

ព្រះពុទ្ធសាសនានោប្រទេសកម្ពុជា ចាប់មានពន្លឺរស្មីត្រាឆនត្រាយខ្លឹងតាំងពីសតវត្សទី ១៣ ក្នុងរជ្ជកាលនៃព្រះបាទជយវរ្ម័នទី ៧ ។ ព្រះបាទជយវរ្ម័នទី ៧ មិនត្រឹមតែជាមហាក្សត្រខ្លាំងពូកែខាងសឹកសង្គ្រាមប៉ុណ្ណោះទេ ទ្រង់ប្រសប់ត្រប់ត្រងផែនដីណាស់ទៀតផង ទ្រង់បានប្រារព្ធឲ្យរៀបចាប់ត្រប់តំណែងសំពះព្រះនគរ ដែលធំទូលាយឲ្យចំរើនខ្លឹង ហើយទ្រង់ឲ្យសាងប្រាសាទសុទ្ធតែថ្ម ដើម្បីទុកសំពោះព្រះសម្មណគោតមជាអម្ចាស់នៃយើង ។ ឯប្រាសាទដែលល្បីឈ្មោះជាងគេនោះគឺប្រាសាទបាយ័ន (បញ្ជាធំ) ប្រាសាទនេះល្អអស្ចារ្យមួយ ហើយដែលនាំឲ្យសាកលលោកស្ងប់ស្ងែង ។

ខាងមុខនេះ ខ្ញុំនឹងអធិប្បាយលោតត្រជាងអំពីស្ថាបនកម្មនៃប្រាសាទខ្មែរដោយសង្ខេប ជូនអស់លោកអ្នកអាន ៖

ប្រាសាទអង្គរ បើយើងក្រឡេកមើលភ្លាមទៅយើញជាដុំថ្មជាក់តរលើគ្នា ប៉ុន្តែបើយើងដើរចូលទៅជិតនឹងឃើញជារបៀង បរិវេណ ឬ

ថ្កុំសាទគួច ។ ពាសពេញទៅរៀញ ហើយគ្រឹះស្ថានទាំងនេះនាំឲ្យយើងឃើញថា មហាក្សត្រខ្មែរបានកាលពីដើមមានកោតសម្បុទ្ធិជ្រះថ្លាខ្លាំងណាស់ ហើយបានគ្រប់គ្រងប្រទេសដែលធំទូលាយអស្ចារ្យ ។

កាលពីសតវត្សទី ១៦-១៧-១៨ ដែនកូសាំងស៊ុនទាំងមូលនិងខ្លះអាស៊ីកាគអាគ្នេយ៍មួយផ្នែក ក៏ជាដែនដីប្រទេសកម្ពុជាដែរ ។ តាំងពីយូរណាស់មកហើយ គេពុំអាចដឹងច្បាស់ត្រឹមសាស្ត្រនៃសិល្បៈខ្មែរដោយច្បាស់លាស់ទេ គេគ្រាន់តែដឹងថាសិល្បៈនេះកើតមានឡើងជាយូរអង្វែងហើយ ។ ដោយហេតុដែលគេឃើញថាថ្កុំសាទអង្គរ គេសាងឧទ្ទិសថ្វាយអាឌិទេពតាមទំនៀមតណ្ហ ហើយនិងគេឃើញមានសិលាចារឹកជាអក្សរសំស្ក្រឹតទាំងឲ្យគេអាចសន្និដ្ឋានថាបានយ៉ាងធាប់ថាស្ថាបនកម្មខ្មែរ ជាសំណាកចម្លងមកពីស្ថាបនកម្មឥណ្ឌា ។ ប៉ុន្តែការស្មានទេនេះមិនត្រូវទេ ព្រោះដូនជាតិបុរេសដែលគេបានទៅបំពេញបេសកកម្ម នៅប្រទេសឥណ្ឌាបានទទួលដឹងតាមផ្លូវការថាស្ថាបនកម្មឥណ្ឌា មានចិត្តគំនិតនឹងការគាក់តែងនឹងច្នៃឆ្លាយផ្សេងស្រឡះពីស្ថាបនកម្មរបស់ខ្មែរ ។ ក្រោយពីនោះមកក្រោមឥទ្ធិពលឥណ្ឌា ទើបស្ថាបនកម្មព្រះពុទ្ធសាសនាជ្រាបចូលមកប្រទេសកម្ពុជា ។

រវាង ព.ស. ៤៩០ ក្រោយព្រះយេស៊ូគ្រិស្ត យើងសង្កេតឃើញថា ស្ថាបនកម្មបានផ្លាស់ប្តូរឆ្លាយយ៉ាងច្បាស់លាស់ ឧទាហរណ៍ដូចជាពុទ្ធរូបដែលកើតមានឡើងក្រោយរូបចម្លាក់នៃព្រះឥសូរព្រះព្រហ្ម ហើយទិន្នន័យព្រះនាគយណ៍ ។ យើងសូមរំលឹកដល់អ្នកដើរមើលប្រទេសថា កន្លែ

ចំណោមប្រាសាទអង្គរ មានតែប្រាសាទតាកែវមួយទេដែលគ្មានចម្លាក់អ៊ីសោះ គ្រាន់តែមានចលនាវិលវៀន ៥ ជាន់នៅលើកំពូលប៉ុណ្ណោះ ។ ប្រាសាទបក្សីចាំក្រុងជាប្រាសាទមួយយ៉ាងតូច បិតនៅមុខប្រាសាទភ្នំក្រុងអង្គរធំ ហើយមានទ្រង់ទ្រាយស័ក្តិសមអស្ចារ្យ ។ តាមគេស្មានថា: ស្ថាបនកម្មវិធីរកើតមានឡើងខ្លះ អំពីចិត្តនឹងគំនិតមុនកសាងប្រាសាទដែលយើងបានអធិប្បាយខាងលើនេះ ។ ស្តេច «អង្គិកឆ្លង ឬក្រែង» បានទាំសិល្បៈ «ក្រិច» ចូលទៅប្រទេសឥណ្ឌា ហើយគេស្មានថាជាង «ក្រិច» ឬជាងឥណ្ឌាដែលទៅរៀនសូត្រក្នុងសាលានៅប្រទេស «ក្រិច» បានធ្វាក់ព្រះពុទ្ធរូបជាដំបូង ។ ហេតុនេះហើយបានជាព្រះពុទ្ធរូបដែលគេបានធ្វាក់មុនគេ នាំឲ្យនឹកដល់ព្រះរូបនៃព្រះបាទ «អាប៉ូលឆ្លុង» ។ នៅទីបំផុតនេះ គេដឹងថាក្បាច់ចម្លាក់ខ្មែរ ដែលមានតំណើតមុនគេ ហើយដែលមាននៅក្នុងរវាងសតវត្សទី ៨ ទីឆ្នាំ ១០ ជាចម្លាក់មានតុជាវេស ហើយគេអាចយកទៅផ្ទឹមបានជាមួយនឹងចម្លាក់ប្រាសាទនៅប្រទេសឥណ្ឌាលិច ដែលសាងនៅក្នុងរវាងសតវត្សទី ១៧ ទីឆ្នាំ ១៨ ។

នៅគេលនោះ រឿងព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងកោះសេរីលង្កា ដែលជាទីកន្លែងពុទ្ធសាសនាខាងថេរវាទ ចំណែកខាងផ្លូវគូតវិញ ប្រទេសកម្ពុជានេះមានការពាក់ព័ន្ធជាមួយនឹងប្រទេសចិន ។ ពិតមែនតែការពាក់ព័ន្ធខាងលើនេះមានដំណើរការអាក់អួលនៅក្នុងសម័យខ្លះ តែមិនអាចនាំឲ្យបាត់មេត្រីភាពឡើយ នៅតែមានហូរហែរហូតមកដល់សព្វថ្ងៃនេះ ។

តាំងពីសតវត្សទី ៧ គ្រាយព្រះយេស៊ូគ្រីស្ត បើគេនាំយកឯកសារ
ខ្លះមកពិនិត្យមើលឲ្យម៉ត់ចត់ទៅឃើញថា ភាសាខ្មែរគ្មានផ្លាស់ប្តូរគោល
ការណ៍ណាមួយសោះ មានតែលូតលាស់ចំរើនឡើង ។ ដូនតាលមាន
ពាក្យពេចន៍ខ្លះធ្លុងទៅធ្លុងមក ជាមួយនឹងប្រទេសដែលជាអាណានិគម
ឬដែលជាអាណាព្យាបាលរបស់កម្ពុជរដ្ឋ ។ ប៉ុន្តែពាក្យបរទេសទាំងនោះ
ពុំបានធ្វើឲ្យពាក្យពេចន៍ខ្មែរប្រែប្រួលឡើយ ពាក្យពេចន៍ខ្មែរសឹងបិត
ទៅតាមភាពដើមហើយច្រើនតែជាពាក្យព្យាង្គតោល ហេតុដូចពាក្យទាំង
នោះមានដើមកំណើតអំពីបរទេស ជាពាក្យពហុព្យាង្គក៏ដោយក៏ច្រើនតែ
ប្រែមកជាពាក្យឯកព្យាង្គតាមទម្លាប់ភាសាខ្មែរវិញ ។

គម្ពីរខ្មែរបុរាណច្រើនតែធ្វើពីស្លឹករឹត ហើយមានភាសាសំស្ក្រឹតនឹង
ប្រាលី ៣០ ភាគរយ ។ គម្ពីរបែបនេះនាំឲ្យជនជាតិខ្មែរឬបរទេសដែល
មានកំណើតទៅប្រទេសអាស៊ី និយាយគ្នាយល់ទៅវិញទៅមកបានយ៉ាងស្រួល ។ យើងសូមបញ្ជាក់ថែមទៀតថា អត្ថបទបុរាណឬបច្ចុប្បន្ន
ច្រើនតែអធិប្បាយពីរឿងព្រះពុទ្ធសាសនាដែលមានសព្វថ្ងៃនេះ ។

ដើមកំណើតនៃអក្ខរៈខ្មែរ មានមកពីប្រទេសឥណ្ឌាខាងត្បូង ។
អក្សរដែលមានតំនូសដាយ ឬពិបាកខុតដូចជាព្យាង្គមួយ ។ ព្យញ្ជនៈ
នីមួយ ។ មានស្រៈមួយ បើគ្មានស្រៈទេ ព្យញ្ជនៈនោះនឹងចេញសំឡេង
ពុំកើត កាលណានៅឆ្ងាយតែឯង, តែមានអក្សរខ្លះស្រៈនោះត្រូវបាត់អង្គ ។

ខ្មែរទិយាយភាសាខ្មែរដែលពោលសារុបខាងលើនេះ ហើយដែល
ប្រទេសនឹងជនជាតិខាងស្ដុចឲ្យឈ្មោះថា ប្រជាជនកម្ពុជា ។

សព្វថ្ងៃ ខ្មែរមានចំនួន ៤.៥០០.០០០ នាក់ ដែលចែកញែកនៅតែបក់ខ្យែងក្នុងដែនដីខ្មែរ ។ នៅក្នុងប្រទេសខ្មែរ, គេឃើញជនជាតិយួន ៣៥០.០០០ នាក់, ជនជាតិចិន ២០០.០០០ នាក់, ជនជាតិចាមទឹងជ្រា ១០០.០០០ នាក់, ជនជាតិលាវ ២០.០០០ នាក់, ជនជាតិភូមា ២០០ នាក់ ហើយទឹងជនជាតិអឺរុបប្រែចន្លាន់នាក់ តែភាគច្រើនជាកំង ។

នៅប្រទេសកម្ពុជាមានបព្វជិតជាគណៈថេរវាទ ២ គឺ

១— គណៈមហានិកាយ

២— គណៈធម្មយុត្តិកនិកាយ

គណៈទាំងពីរខាងលើនេះ ខុសគ្នាខ្លះតែត្រង់របៀបពោលជាភាសាបាលី និងការប្រព្រឹត្តតាមទំនៀមទម្លាប់ខ្លះៗ ប៉ុណ្ណោះ ។

ព្រះពុទ្ធសាសនាចក្រកម្ពុជា មានវត្តចំនួន ២.៨០០, មានភិក្ខុសាមណេរចំនួន ៨២.០០០ អង្គ; ក្នុងព្រះវិហារនៃវត្តនីមួយ ។ គេបានសាងព្រះពុទ្ធរូបដំកល់ទុក ដើម្បីជាទីគោរពនៃព្រះសង្ឃ-ភិក្ខុ-សាមណេរ ដែលចូលមកជួបក្នុង ។ ព្រះសង្ឃទាំងនោះមានសមណសក្តិ ទីពាគណៈ: ទីឋានានុក្រម ដែលតាំងតាមព្រះពុទ្ធកិត្យក្រឹមត្រូវ ។

ព្រះពុទ្ធសាសនាយើងបានចំរើនរុងរឿងឡើង ដោយថ្លៃព្រះហស្តព្រះមហាក្សត្រិយ៍ទឹងកម្ងាំងព្រះពុទ្ធវង្សាកិបាល ដែលគាន់លទ្ធិព្រះពុទ្ធសាសនាឥតមានស្រឡាំង ។ គាលពីឆ្នាំ ១៩១៤ ព្រះពុទ្ធាទឹងព្រះពុទ្ធវង្សាកិបាលបានសង់សាលាបាលីជាន់ខ្ពស់នៅទីក្រុងភ្នំពេញ ។

(មានត)

ព្រះមហា អ៊ុម - ធ្មៃជ័ង វត្តសារាវ័ន

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះគតន្តមុនីអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ត្រមាំង ព្រះធម៌ ទឹង ព្រះអរិយសង្ឃ ដោយគោរព) ។

រីឯនេះ អាត្មាភាព សូមលើកយកឥទ្ធិបាទធម៌ គឺធម៌ជាដំហារនៃឫទ្ធិ ដែលខុកជាដើងទ្រសម្រាប់ធ្វើសេចក្តីថ្នាក់ថ្នាឲ្យសម្រេច មកសំដែងដើម្បីជាសណ្តាប់នៃសាធុជន តែមុនទើសំដែង សូមអធិប្បាយ ៨ម្រាលសេចក្តីដោយសង្ខេបសិន ដូចតទៅនេះ :

មនុស្សក្នុងលោកសន្និវាសនេះ មានច្រើនជាតិច្រើនសាសន៍ ច្រើនភាសា, មនុស្សទាំងអស់នោះ ទោះថ្នាក់ណាក្តី ប្រកេទណាក្តី សុទ្ធតែមានសេចក្តីថ្នាក់ថ្នាមានចំណង់ក្នុងសន្តានជានិច្ចគ្រប់ៗ គ្នា, ប្លែកតែត្រង់មនុស្សខ្លះ ចង់បានខ្លះ ខ្លះចង់បាននោះ ។ តែការចង់បាន នៃមនុស្សនោះ ជួនណាក៏បានសម្រេច ជួនណាក៏មិនបានសម្រេច, ដែលបានសម្រេចសមតាមចំណង់នោះ មកពីមានអង្គនៃធម៌ជាគ្រឿងធ្វើឲ្យសម្រេចសេចក្តីថ្នាក់ថ្នាគ្រប់គ្រាន់, ដែលមិនបានសម្រេចមកពីខ្វះខាតមិនគ្រប់គ្រាន់អង្គណាមួយ ។ ឯអង្គនៃធម៌សម្រាប់ធ្វើសេចក្តីថ្នាក់ថ្នាឲ្យសម្រេចសមតាមចំណង់នោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា មាន ៤ យ៉ាង គឺ

๑— ឆន្ទៈ: សេចក្តីប្រាថ្នា , បំណងយ៉ាងមុតមាំ ;

๒— វីរិយៈ: សេចក្តីព្យាយាម, ប្រឹងប្រែង, ខ្នះខ្នែង ;

๓— បិត្តៈ: ការគិត, ការយកចិត្តទុកដាក់មិនទម្លាក់ធុរៈចោល;

๔— វិមំសា ការពិចារណា, ការត្រួតត្រា ។

ធម៌ទាំង ๔ យ៉ាងនេះឈ្មោះថា ឥទ្ធិបាទ ប្រែថា "ធម៌ជាដំហរនៃឫទ្ធិ", វេលានេះ សូមអធិប្បាយធម៌នោះមួយម្តង ។ ដូចតទៅនេះ ៖

๑— ឆន្ទៈ: "សេចក្តីប្រាថ្នា, សេចក្តីប៉ុនប៉ង, ការចង់បាន, ការពេញចិត្ត" ចែកជាពីរផ្នែកគឺ ៖

ក) សេចក្តីប្រាថ្នាចង់បាន ទ្រព្យសម្បត្តិទៃព្យជាសវិញ្ញាណកទៃព្យ មានគោ, ក្របី, ដំរី, សេះជាដើម ឬជាអវិញ្ញាណកទៃព្យ មានមាស, ប្រាក់, កែវ, កង, ផ្ទះសំបែង, វែស, ចំការ, ច្បារដំណាំ, គ្រឿងអលង្ការសម្រាប់ប្រដាប់តាក់តែងកាយ ទឹងសំពត់អាវជាដើម ។

ខ) សេចក្តីប្រាថ្នា ឬការចង់បំពេញកងការកុសលណាមួយក្តី ចង់ចេះដឹងចំណេះវិជ្ជាណាមួយ ជាវិជ្ជាសម្រាប់ប្រកបកិច្ចការចិញ្ចឹមជីវិតក្នុងបច្ចុប្បន្នក្តី ចង់ចេះដឹងចំណេះវិជ្ជាក្នុងពុទ្ធសាសនា ជាច្បាប់សម្រាប់ខ្លួនខ្លួន តាមប្រក្រតីសាសនាក្តី សុទ្ធតែហៅថា សេចក្តីប្រាថ្នា ការចង់បានទាំងអស់ ។ សេចក្តីប្រាថ្នា ការចង់បាន ទាំងពីរផ្នែកនេះ បើកើតមានជុះជាលពេញត្រប់គ្រាន់ក្នុងខន្ធសន្តាន បព្វជិត គ្រហស្ថ បុរស ស្ត្រី កាន់តែច្រើនឡើង។ រហូតដល់អត់ទាំមិនបាន ហៅថា ឆន្ទិទ្ធិបាទ

"សេចក្តីប៉ុនប៉ងជាដំហរឬដំហានៃបុគ្គ ដែលអាចឲ្យសម្រេចសេចក្តីប្រាថ្នាបាន" ។ នេះជាអត្ថន័យ ១ ។

២.- រឿយ៉ែ: "សេចក្តីព្យាយាម, សេចក្តីខ្នាត" បានដល់កិច្ចការអ្វី។ ប្រចំណេះវិជ្ជាអ្វី។ ដែលបុគ្គលណាមួយជាគ្រហស្ថក្តី បព្វជិតក្តី មានសេចក្តីប្រាថ្នា សេចក្តីប៉ុនប៉ង ចង់ប្រកបកិច្ចការ ចង់ចេះដឹងចំណេះវិជ្ជានោះ។ ហើយផ្គងចិត្តយ៉ាងម៉ឺងម៉ាត់ប្រឹងធ្វើប្រឹងរៀន ដោយមិនបណ្តែតបណ្តោយបណ្តោះបណ្តែការធ្វើការរក ការរៀនខោះ មិនឲ្យខណៈតន្ទឹងទៅទេ។ គឺមិនអាងថា ពេលនេះនៅព្រឹកណាស់ ចាំដល់ថ្ងៃត្រង់, ដល់ថ្ងៃត្រង់ថាចាំល្ងាច, ដល់ល្ងាចថាចាំស្អែក, ដល់ស្អែកថាចាំខានស្អែក, ដល់ខែនេះ ថាចាំខែក្រោយ, ដល់ឆ្នាំនេះ ថាចាំឆ្នាំក្រោយ, ដល់អាយុប៉ុណ្ណេះ ថាចាំអាយុប៉ុណ្ណោះ សឹមចាប់ផ្តើកិច្ចការនោះ។ សឹមរៀនវិជ្ជានោះ។; បើមានការអាង ការបណ្តោះបណ្តែយ៉ាងនេះ មិនរាប់ថា សេចក្តីព្យាយាមឡើយ; លុះតែបុគ្គលណាមួយមានចិត្តក្លាហានមោះមុត មិនខ្លាចខ្មីឃើញហត់ អត់ធ្មត់សេចក្តីដោកដុយ អត់ធ្មត់ក្តៅត្រជាក់ អត់ធ្មត់សេចក្តីស្រេកឃ្លាន, មានចិត្តក្លៀវក្លា ក្នុងការរៀនសូត្រ ក្នុងការងារដែលខ្លួនត្រូវធ្វើត្រូវប្រកប មិនដំអក់ចំរន់មិនបង្អែបង្អន់ តែងតែមានចិត្តរវៃសរវៃវិតចំរៀនសូត្រ ឬឃ្នាតធ្វើការត្រាតែបានសម្រេចដូចបំណង ទើបសមតាមសុភាសិតថា ភយមេធេវ បុរិសោ យាវ អត្ថស្ស និប្ផទា "កើតមកពេញអង្គជាបុរសស្ថិ ត្រូវតែព្យាយាម ត្រាតែសម្រេច

ប្រយោជន៍" ។ សុភាសិតនេះ បំភ្លឺឲ្យយល់ថាការណ៍ដែលនឹងសម្រេចប្រយោជន៍ទៅបានដោយសេចក្តីព្យាយាម ។ ឯប្រយោជន៍នោះមាន ២ យ៉ាង គឺ ប្រយោជន៍ក្នុងលោកិយនឹងប្រយោជន៍ក្នុងបរលោក ។

១— ប្រយោជន៍ក្នុងលោកិយ គួយ៉ាងដូចការប្រកបការងារឬការរៀនសូត្រវិជ្ជាណាមួយ ជាហេតុដល់បានសម្រេចប្រយោជន៍ល្អ តាមបំណងក៏ព្រោះតែបុរសបុគ្គលនោះមានព្យាយាមធ្វើ ព្យាយាមរៀន ឬក៏ប្រកបកិច្ចការដែលគួរប្រកប មានធ្វើស្រែ ចំការ ត្បាញវៃ ធ្វើជាងមាស ជាងច្បាក់ជាដើម ហើយសម្រេចបានជាផលប្រយោជន៍ដល់ខ្លួន គឺបានជាអ្នកមានទ្រព្យសម្បត្តិ បានជាសេដ្ឋីគហបតីសម្បូរដោយសម្បត្តិស្តុកស្តម្ភ ក៏ព្រោះសេចក្តីព្យាយាម ។ ប៉ែកខាងវិជ្ជាចំណេះដែលអ្នកប្រាជ្ញទាំងឡាយអំពីបុរាណក្តី អ្នកប្រាជ្ញទាំងឡាយក្នុងបច្ចុប្បន្នក្តី ដែលលោកបានសិក្សាត្រាតែចេះដឹងហើយបានប្រយោជន៍ដល់ខ្លួន ទាំងបានធ្វើប្រយោជន៍របស់លោកនោះ ឲ្យជាប្រយោជន៍សាធារណៈថែមទៀត គឺបានរួបរួមតាក់តែងចងក្រងជាគម្ពីរដីកា ក្បួនច្បាប់ផ្សេងៗ សំដែងសេចក្តីខុសត្រូវ ផ្តូរអាក្រក់ល្អឲ្យយើងសិក្សាបានចេះដឹងតាមផង ក៏កើតឡើងព្រោះសេចក្តីព្យាយាម បើមិនមានការព្យាយាមរៀន ព្យាយាមគិត ព្យាយាមធ្វើទេ មុខជាមិនបានសម្រេចប្រយោជន៍នោះៗឡើយ ។ សមដូចព្រះពុទ្ធភាសិត ១ កន្លែងទៀត ក្នុងគម្ពីរធម្មបទថា:

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឬ្ឍំ

"បុរសបុគ្គលណា ជាអ្នកខ្ជិលច្រអូស គ្មានសេចក្តីព្យាយាម បើទុកជារស់នៅ ១០០ ឆ្នាំ (កំឥតបានការអ្វី) ឯបុគ្គលមានជីវិតរស់នៅ សូម្បីតែ ១ ថ្ងៃ ប៉ើជាអ្នកមិនខ្ជិលច្រអូស ជាអ្នកមានសេចក្តីព្យាយាមមុតមាំ គំប្រសើរជាងអ្នកដែលរស់នៅ ១០០ ឆ្នាំនោះ" ។

ហេតុដូច្នេះ បុគ្គលអ្នកប្រាថ្នាប្រយោជន៍ គួរតែមានព្យាយាមច្រើនច្រែងធ្វើការរកវបចិញ្ចឹមជីវិតពល់ថ្ងៃ តាមមុខងារនាទីដែលត្រូវធ្វើ, ព្យាយាមសិក្សារៀនសូត្រ តាមចំណេះវិជ្ជាដែលត្រូវរៀន ដកបដល់បានត្រឹមសម្បត្តិ បានចេះដឹង ដែលជាផលកើតមកអំពីហេតុ គឺសេចក្តីខ្ជិលច្រែងច្រែងច្រកបការងារ ទឹងការរៀនសូត្រនោះ។ ។ មានពុទ្ធភាសិត ១ កន្លែងទៀតថា អ៊ីយេន ឧក្កុមញ្ញេតិ "បុរសបុគ្គលធ្វើនសេចក្តីទុក្ខបាន ដោយសារសេចក្តីព្យាយាម" គឺថា សេចក្តីទុក្ខគ្រប់ថ្នាក់គ្រប់ប្រភេទ ដែលកើតអំពីការស្រេកឃ្លានក្តី កើតអំពីការរកចិញ្ចឹមជីវិតក្តី ដែលជាហេតុធ្វើចិត្តឲ្យក្រៀមក្រំឲ្យសូតសូប់សញ្ជប់សញ្ជឹង គេនឹងបំបាត់ទុក្ខនោះទៅបាន ដោយសារសេចក្តីព្យាយាមពេញបរិបូណ៌មិនខ្វះខាត ។ ការបានទទួរសេចក្តីសុខសេចក្តីចំរើនក្នុងបច្ចុប្បន្ជាតិនេះ ហៅថាប្រយោជន៍ក្នុងលោកិយ ។

២- ប្រយោជន៍ក្នុងបរលោក បានដល់បុណ្យកុសលដែលបុគ្គលត្រូវធ្វើ ត្រូវកសាង ទុកជាយាន ជាស្បៀងអាហារ ឬជាគ្រឿងអលង្ការរបស់ចិត្ត សម្រាប់ធ្វើកុំឲ្យចិត្តកំព្រាកំព្រា កុំឲ្យចិត្តគ្មានទីពឹង កុំឲ្យចិត្តគ្មានមិត្តសំឡាញ់ ក្នុងពេលដែលធ្វើដំណើរទៅកាន់កន្លែងខាងមុខ

សមដូចព្រះពុទ្ធភាសិតថា សយំ កតានិ បុញ្ញានិ តំ មិត្តំ សម្បរាយិកំ "បុណ្យទាំងឡាយដែលគេបានធ្វើហើយដោយខ្លួនឯង បុណ្យនោះជាមិត្តក្នុងលោកខាងមុខ" ។ បណ្ដាតទាំងឡាយ មានព្រះពុទ្ធជាដើម ដែលសម្រេចមគ្គផល បានទៅសោយសេចក្ដីសុខដ៏សុខុមក្នុងសិវដ្ឋាន គឺព្រះនិព្វានក្ដី ជនទាំងឡាយក្រៅពីនោះ ដែលបានកើតមកជាមនុស្សឬបានទៅកើតក្នុងឋានសួគ៌ ហានព្រហ្មសោយសេចក្ដីសុខជានិព្វានក្ដី សុទ្ធតែបានប្រកបសេចក្ដីព្យាយាមប្រឹងកសាងយ៉ាងពេញកម្លាំង ។ ការបានសេចក្ដីសុខក្នុងជាតិខាងមុខ ហៅថា បានប្រយោជន៍ក្នុងបរលោក ។

រួមសេចក្ដីថា ការបានទ្រព្យសម្បត្តិក្ដី ការបានរុះដឹងចំណេះវិជ្ជាណាមួយក្ដី សុទ្ធតែបានដោយវីរិយភាព គឺសេចក្ដីឃ្នាតប្រឹងប្រែងយ៉ាងមុឺងម៉ាត់ ។ បើគ្រាន់តែមានធន្ទៈ គឺចំណង់ថាចង់រក ចង់រៀន សូម្បី ១០០ ឆ្នាំ តែមិនរៀសវៀរ មិនគ្រើនគ្រេតើន មិនព្យាយាមរក ព្យាយាមរៀនទេ ក្រែកដជាមិនបានសម្រេចដូចបំណងឡើយ ។ នេះជាអត្ថទី ២ ហៅថា វីរិយិទ្ធិបាទ ប្រែថា "សេចក្ដីព្យាយាមជាធំហានប្ដូនៃឫទ្ធិដែលអាចឲ្យសម្រេចសេចក្ដីក្រាថ្នាបាន" ។

๓ - បិត្តិ: ប្រែថា "ការគិត, ការយកចិត្តទុកដាក់" ។ អធិប្បាយថា អ្វីៗទាំងអស់ គោះការងារដែលយើងត្រូវប្រកបក្ដី គោះចំណេះវិជ្ជាដែលយើងត្រូវសិក្សាក្ដី បើយើងគ្រាន់តែចង់រកចង់រៀន ទាំងបានរកបានរៀនតាមបំណងហើយ ដោយមានសេចក្ដីព្យាយាមពេញ

ចន្ទកក៏ដោយ, យើងត្រូវតែគិតវែមទៀត ទើបានពុំបាន តើត្រូវគិតថាសេចក្តីប៉ុនប៉ងនិងសេចក្តីថ្នាំងថ្នាររបស់អាត្មាអញានោះ សមរម្យឬមិនសមគួរឬមិនគួរ ល្អឬអាក្រក់ គុណឬទោស ត្រឹមត្រូវឬមិនត្រឹមត្រូវទេ បើគិតទៅហើយឃើញថា សេចក្តីប៉ុនប៉ងនិងដើមនោះសមរម្យត្រឹមត្រូវល្អគួរដល់សេចក្តីសុខសេចក្តីចំរើន មិនច្រកបដោយទោសទេ សឹមចង់រកចង់រៀន; បើការងារឬចំណេះវិជ្ជាណា ដែលច្រកបដោយទោស យើងមិនត្រូវមានចំណង់ តឹមិនត្រូវចង់រកចង់រៀន ចំពោះការងារ ចំពោះចំណេះវិជ្ជានោះ។ ឡើយ ព្រោះសេចក្តីថ្នាំងណាមួយ ដែលពាន់ពារពាក់ព័ន្ធទៅលើហេតុដែលមិនគួរ អំពើដែលអាក្រក់, សេចក្តីថ្នាំងនោះឯង ទើបបណ្តាលទៅជាទោស ឲ្យកើតមានដល់ខ្លួនយើងវិញ; បើសេចក្តីថ្នាំងណាមួយ ដែលពាក់ព័ន្ធទៅលើហេតុដែលគួរ អំពើដែលល្អ, សេចក្តីថ្នាំងនោះនឹងនាំឲ្យទៅជាគុណ គឺនាំយកសេចក្តីសុខសេចក្តីចំរើនមកឲ្យខ្លួនយើងវិញ ។ មួយទៀតការគិត បើកើតមាន ពេញបរិបូណ៌ក្នុងខន្ធសន្តានជនណាហើយ ជននោះឈ្មោះថា មានគំនិត, បើមានគំនិតហើយ ទោះមានចំណង់ចង់ច្រកបការងារអ្វីក្តី ចំណង់នោះច្រើនល្អច្រើនត្រូវ, លុះព្យាយាមធ្វើ ព្យាយាមរៀន តាមគំនិតនោះទៅហើយ ក៏មុខជានឹងបានទទួលផលប្រយោជន៍ល្អពុំខាន; ព្រោះថាមនុស្សណាមានគំនិត មនុស្សនោះពុកដូចជាមានតម្រង ឬកញ្ជើសម្រាប់ដាក់វត្ថុផ្សេង។ បានត្រប់យ៉ាងតាមសេចក្តីថ្នាំង ដ្បិតសេចក្តីថ្នាំងក្តី សេចក្តីព្យាយាមក្តី បើពុកជាកើតមានភាប់រយៈ

ពាប់ពាន់ឆ្នាំក៏ដោយចុះ តែគ្មានគំនិតជាចំនង់សម្រាប់ថែរក្សាការពារ
ទេ ក៏មុខជានឹងរលុបរលាយសាបសូន្យបាត់បង់ ពុំបានសម្រេចផល
ប្រយោជន៍នោះ ប្រៀបដូចទឹកត្នោតបើពុតជាស្រស់មិនស្រាកយ៉ាងណា
ក៏ដោយ តែចំពង់ធ្លុះហើយ កុំថាឡើយដល់ទៅបានតេញឬកន្ទុះចំពង់
សូម្បីតែមួយដំណក់ក៏មិនអាចតាំងនៅបានឡើយ ។ នេះជាអង្គ ទី ៣
ហៅថា បិត្តិទ្ធិប្បាទ ប្រែថា "ការតិតជាដំហរ ឬ ដំហានៃបុគ្គ
ដែលអាចឲ្យសម្រេចសេចក្តីប្រាថ្នាបាន" ។

៤ — វីមំសា "ការពិចារណា ការត្រួតត្រា" នោះ បានដល់ការ
រិះរៃលៃលកគ្នេគ្នាន់ ពិនិត្យពិច័យដោយហ្មត់ចត់ ឲ្យឃើញច្បាស់ជាក់
ដឹងជាក់ ឲ្យយល់ច្បាស់ គឺថាកិច្ចការ ឧបាយចំណេះវិជ្ជាគប់យ៉ាង បើយើង
គ្មានតែមានធន: (ចំណាំ) វីរិយ: (ព្យាយាម) ចិត្ត: (គំនិត) ដូច
រៀបរាប់មកខាងដើមប៉ុណ្ណោះ ក៏មិនទាន់ធួនល្មមនៅឡើយទេ លុះតែមាន
វីមំសា ការពិចារណាលៃលកត្រួតត្រាមើល ឲ្យបានច្បែងលើកច្បែងដង
ថែមហើយថែមទៀតរឿយៗ ទើបប្រពៃ, សមដូចពុទ្ធភាសិតថា ឯសុ
ការណំ សេយ្យោ ហោតិ ប្រែថា "មុនធ្វើការអ្វីៗត្រូវពិចារណា
ឲ្យល្អិតល្អ ទើបការនោះប្រសើរ អាចញ៉ាំងផលប្រយោជន៍ឲ្យសម្រេច
ដោយប្រពៃបាន" ។ ព្រោះការពិចារណាលោកប្រៀបដូចគ្រដាសខាត់
សម្រាប់ខាត់រំលីងសំអាតសង្ហារមែវត្ថុតាំងពួងមានតុ ទូ តាំង កៅអីជាដើម
ដែលគេធ្វើសម្រេចហើយ ឲ្យស្អាតរលីងម៉ដ្ឋហ្មត់ តាំងតម្កែតម្កន់

ដ្ឋានដ្ឋោយ កុំឲ្យមានគ្រោតគ្រាតរដិបរដុបខ្លួសខាច, អាស្រ័យហេតុ ប៉ុណ្ណេះដោយ ទើបវត្ថុតាំងនោះ ឋានឈ្មោះថា សមរម្យល្អ គួរដល់ទស្សនីយភាព គួរដល់ភ្នែកមើលបាន មានឧបមាយ៉ាងណា, មានឧបមេយ្យយ៉ាងការដែរ ទំនងចំណេះវិជ្ជាគ្រប់យ៉ាងដែលបុរសបុគ្គលបានធ្វើឲ្យកើត បានរៀនឲ្យចេះដឹង កំតែងអាស្រ័យវិមំសាការពិចារណាឲ្យហ្មត់ចត់ ទើបកើតឆលប្រយោជន៍បាន ។ នេះជាអង្គទី ៤ របស់សេចក្តីថ្នាក់ ហៅថា វិមំសិទ្ធិបាទ ប្រែថា «ការពិចារណាជាដំហរឬដំហាននៃឫទ្ធិ ដែលអាចឲ្យសម្រេចសេចក្តីថ្នាក់បាន» ។

កំណត់តាំង ៤ ប្រការគឺ ឆន្ទៈ (បំណង) វីរិយៈ (សេចក្តីព្យាយាម) ចិត្តៈ (គំនិត) វិមំសា (ការពិចារណា) ដូចពណ៌នាមកនេះ បើកើតមានតេញ្ចាបរិបូណ៌ក្នុងខន្ធសន្ដានៃបុគ្គលណា បុគ្គលនោះគេហៅថ្នាក់យ៉ាងណា ក៏ទំនងបានសម្រេចដូចបំណងពុំខាន; បើធម៌តាំង ៤ ប្រការនេះមិនមានទេ ឬមានដែរ តែខ្វះខាតអង្គណាមួយ ក៏មិនអាចនឹងញ៉ាំងសេចក្តីថ្នាក់ឲ្យសម្រេចបរិបូណ៌បានឡើយ ។

សំដែងមកកន្លងនូវឫទ្ធិបាទធម៌ ៤ ប្រការ ចប់តាមកាលវេលាតែប៉ុណ្ណេះ ឯរ ។

ទាបកថារឿងពុទ្ធរូបបុរាណ

ឃុនអត្ថកោវិទ ជា - ឃ្លែ នៅពុទ្ធមាសនបណ្ឌិត្យ

ប្រែចាកទស្សនាវដ្តី ដំណាំងសាសនា ឆ្នាំទី ១ ច្បាប់ទី ៦ ភាសាថៃ

(តមក)

ចាំដែនេះកំព្រែងមានហេតុផលដូចពោលមកហើយ គឺពួកឥណ្ឌៀ មានហាមមិនឲ្យសាងរូបបុគ្គល ដែលជាទីគោរពទុកធ្វើសក្ការៈបូជាទេ ។ ការណ៍ដែលសាងព្រះពុទ្ធរូបឡើងនោះ ជាគំនិតជនជាតិជវៃដែលកាច់អានព្រះពុទ្ធសាសនា មានប្រាកដតាមប្រវត្តិសាស្ត្ររបស់ឥណ្ឌៀថា ព្រះពុទ្ធសកកាជប្រហែលជាង ២០០ ឆ្នាំ ព្រះបាទអង្វេក្សន៍ជ្រមហាពជនៃរដ្ឋមសិដោនទៀ ក្នុងប្រទេសក្រិក បានលើកព្យុហសេនា ទៅបង្ក្រាបដណ្តើមយកស្រុកតូចស្រុកធំនិគមជនបទ តាំងពីអ៊ីរ៉ុបរហូតដល់ឥណ្ឌៀ ទិសខាងលិចឈៀងខាងដើង ដែលហៅថា រដ្ឋបញ្ចាប កន្លងសម័យនេះ ។ ព្រះបាទអង្វេក្សន៍ជ្រកាយបានស្រុកឥណ្ឌៀតែត្រឹមប៉ុណ្ណោះ ហើយស្តេចត្រឡប់ទៅវិញ តមកមិនយូរប៉ុន្មានក៏ទ្រង់ទិវង្គត ពួកមេទ័ពមេកងដែលសំខាន់ ។ ក៏សឹងតែតាំងខ្លួនឡើងជាក្សត្រចែកគ្នាគ្រប់គ្រងរដ្ឋផ្សេង ។ ដែលជាអាណាចក្រវេសព្រះបាទអង្វេក្សន៍ជ្រមហាពជ ។ ស្រុកគន្ធារៈ គឺប្រទេសអាហ្វហានិស្ថានកន្លងសម័យនេះ ទើរដ្ឋបញ្ចាបមានស្រុកចំការត្រៀជាដើម បានទៅកណ្តាប់ដៃមេទ័ពម្នាក់ ដែលបានតាំងខ្លួនជាធំជ័ពទ្ធឹក ។ ចំណោះតមកស្តេចក្រុងចំការត្រៀបានធ្វើសង្គ្រាមទើរព្រះ

ចៅចន្ទគុប្ត ជាព្រះពជអយ្យកោខ្លួនរបស់ព្រះបាទអសោកមហាពជ (ព្រះចៅចន្ទគុប្តជាព្រះពជបិតាព្រះបាទពិន្ទុសារ, ព្រះបាទពិន្ទុសារជាព្រះពជបិតារបស់ព្រះបាទអសោក) បរាជ័យចាញ់ស្នាព្រះហស្តព្រះបាទចន្ទគុប្ត រដ្ឋបញ្ជាបក់ធ្លាក់មកជារដ្ឋឥណ្ឌវិញ ។ ក្រោយពីនោះមក ក៏ដល់មកពល់ព្រះបាទអសោក ជារដ្ឋកាលទី ៣ នៃពជវង្សមោរិយៈ ទ្រង់ជានបញ្ជូនសមណទូត ឲ្យទៅផ្សាយព្រះពុទ្ធសាសនានៅស្រុកគន្ធារៈ ហើយសាងស្តូបបញ្ចុះព្រះបរមធាតុធង (នៅមានប្លាកជាដល់មកឥឡូវនេះ ឈ្មោះថា "ធម្មរាជិកស្តូប") តមកគេបានដួសដុលស្តូបនេះជាច្រើនគ្រា ។ កាលស៊ី-ចន-ម៉ាំងែល អធិបតីក្រុមពិនិត្យបុរាណវត្ថុនៅឥណ្ឌ បានឲ្យដឹកពិនិត្យមើលក្នុង គ. ស. ១៩១៤ - ១៩១៥ បានប្រទះឃើញព្រះបរមធាតុក្នុងស្តូបបុរាណនោះ ហើយឃើញមានចារឹកខ្លីៗថា "ព្រះបាទធម្មរាជាធិរាជជាអ្នកសាង" គេសន្និដ្ឋានថា គឺព្រះបាទអសោកមហាពជនោះឯង, ព្រះធាតុនោះ គឺព្រះធាតុដែលរដ្ឋាភិបាលឥណ្ឌបានប្រគល់ឲ្យតណៈខ្លួនថៃ ដែលចៅចន៍សម្ពន្ធមេត្រី កាល ព. ស. ២៤៨៣ រដ្ឋាភិបាលថៃបានទាំមកបញ្ចុះឡុកក្នុងព្រះស្តូបចេតិយវត្តព្រះស្រីមហាធាតុតំបន់ចាំងរេន ។ ខ្មែរជាគោលជំហ្មាស់លាស់ថា ព្រះពុទ្ធសាសនាបានផ្សាយទៅដល់ស្រុកគន្ធារៈ កាលក្នុងពជ្យព្រះបាទអសោកមហាពជ ទើបមានព្រះបរមធាតុប្លាកជានៅក្នុងព្រះចេតិយនោះ ។ កាលអស់ពជ្យព្រះបាទអសោកហើយ ស្តេចដែលខ្លួលរដ្ឋាយាតមកមិនរឹងប៉ឹង, អាណាចក្រយបស់ព្រះបាទអសោកក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃពជវង្សសុង្គ ។

ពាជវង្សសុង្គតែប់តែងមកមិនបានប៉ុន្មានឆ្នាំ ពួកក្រែកក៏លើកពលចុះមកទៀតកើតច្បាំងគ្នាឡើង ពួកពាជវង្សសុង្គចាញ់ ពួកក្រែកក៏ពង្រីកអាណាចក្រចូលមកកន្លែងដែនតន្លាះនឹងរដ្ឋបញ្ចាបដូចពីដើម ហើយតាំងរដ្ឋតន្លាះនឹងរដ្ឋបញ្ចាបឲ្យជាឯកពាជ្យច្រើនខែត្រ មានស្តេចផែនដីក្រែកតែប់តែងតៗមករហូតដល់ពុទ្ធសករាជ ៣៦៥ ទើបដល់មកពាជ្យព្រះបាទមិលិន្ទ ។ ព្រះបាទមិលិន្ទជាជាតិអ៊ីប៉ុបាត់ឥណ្ឌា] មិនមែនជាតិឥណ្ឌាសុទ្ធទេ ព្រះបាទមិលិន្ទពង្រីកអាណាចក្រមកខាងក្រោមរហូតដល់មគធរដ្ឋ តែទ្រង់នៅកាន់សាសនាដើម គឺសាសនាដែលជនជាតិក្រែកធ្លាប់កាន់មក ចំណែកពលរដ្ឋតន្លាះនៅកាន់ព្រះពុទ្ធសាសនាជាច្រើនតែប់ៗគន្លង តាមដែលព្រះបាទអសោកបានផ្សាយចូលទៅ ។ ថ្ងៃមួយ ព្រះបាទមិលិន្ទបានជួបនឹងព្រះនាគសេន បានឱយោយធម៌នឹងព្រះនាគសេនច្រើនជាន់ច្រើនគា ព្រះនាគសេនក៏បានធ្វើយដោះស្រាយនឹងថ្វាយអត្ថាធិប្បាយផ្សេង ។ ជាច្រើន ព្រះបាទមិលិន្ទទ្រង់ឃើញជាមិ ក៏ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយបានធ្វើការដ៏ធំសំខាន់ពួកយើង ដែលយើងគួរលើកដល់បុណ្យគុណរបស់ទ្រង់ គឺទ្រង់បានសាងព្រះពុទ្ធរូបឡើង ដាំងនេះគឺព្រោះហេតុពួកក្រែកគេគ្មានហាមការសាងរូបជាទីគោរព គេមានរូបសម្រាប់គោរពប្រចាំសាសនារបស់គេស្រាប់ កាលគេបែរមកចាប់អានព្រះពុទ្ធសាសនាគេក៏សាងព្រះពុទ្ធរូបឡើងសម្រាប់បូជា ដោយហេតុនោះ ព្រះពុទ្ធរូបទើបកើតមានឡើង ដោយប្រការដូច្នេះ គឺមានកន្លែងពេញ ព.ស. ៣៦៥ ដល់ ព.ស. ៣៨៣ ក្នុងពាជ្យនៃព្រះបាទមិលិន្ទ ។

ព្រះពុទ្ធរូបសម័យស្តេចមិលិន្ទ ហៅថាព្រះគន្ធារៈ តែតាមពិតនោះ ដែលថាយ៉ាងនេះមិនត្រូវទេ ព្រោះមិនមានអ្នកណាដឹងជាត្រូវថា ព្រះពុទ្ធរូបដែលសាងឡើងក្នុងរាជ្យព្រះចាខមិលិន្ទនោះផ្សេងពីព្រះគន្ធារៈសព្វថ្ងៃនេះដោយមានទ្រង់ព្រាយខុសគ្នាបែបណា ។ តែអ្នកប្រាជ្ញបែកខាងបុរាណគតិបានសន្និដ្ឋានថា ព្រះពុទ្ធរូបដែលមានសាយការយខូវៗនោះ ប្រហែលជាមិនមែនព្រះពុទ្ធរូបសម័យព្រះចាខមិលិន្ទទេ ព្រោះព្រះចាខមិលិន្ទគ្រងរាជសម្បត្តិបានត្រឹម ១៨ ឆ្នាំប៉ុណ្ណោះ ព្រះពុទ្ធរូបដែលបានផ្សាយខូវៗនោះ ប្រហែលជាកើតមានក្នុងរាជ្យព្រះចាខកនិស្កៈទេដឹង ។ សូមនិយាយប្រវត្តិសាស្ត្រតទៅបន្តិចទៀតដូចតទៅនេះ: កាលព្រះចាខមិលិន្ទទិវង្គតទៅហើយនោះ មិនមានរដ្ឋាយាណា ដែលមានសមត្ថភាពក្នុងការគ្រប់គ្រងសុកទេស ព្រោះដូច្នោះ រាជវង្សព្រះចាខមិលិន្ទគ្រប់គ្រងរដ្ឋគន្ធារៈបានតែត្រឹម ៩០ ឆ្នាំប៉ុណ្ណោះ ក៏ចាញ់ដៃពួកសកៈ ដែលលើកចំពមកពីតំណាលទ្វីបអាស៊ី ។ ពួកសកៈគ្រងគន្ធារៈមិនបានយូរប៉ុន្មាន ក៏ចាញ់ដៃកុសាន ដែលបានលើកចំពមកពីជាយដែនខាងលិចឈៀងខាងត្បូងនៃប្រទេសចិន ។ ក្នុងពួកកុសាននោះមានមនុស្សសំខាន់ម្នាក់ គឺព្រះចាខកនិស្កៈ បានពង្រីកអាណាខេត្តចូលមកក្នុងអណ្តៀរហួតដល់មគធរដ្ឋដែលជាមជ្ឈមប្រទេស ហើយទ្រង់កាប់អានព្រះពុទ្ធសាសនា ទ្រង់បានបំពេញការណ៍យកិច្ចគ្រប់យ៉ាងដូចព្រះចាខអសោកធ្លាប់បំពេញមក ដូចទ្រង់ឲ្យធ្វើសង្គាយនាព្រះធម្មវិន័យ បញ្ជូនព្រះសង្ឃឲ្យទៅផ្សាយព្រះពុទ្ធសាសនាក្នុងប្រទេសផ្សេងៗ ទ្រង់ធ្វើការដែល

ព្រះបាទមិលិន្ទបានធ្វើមកហើយនោះ ឲ្យរំងឹតតែចំរើនឡើង គឺទ្រង់សាង
ព្រះពុទ្ធរូបជាការធំបំផុត ។ ព្រះពុទ្ធរូបនេះបានផ្សាយទៅតាមស្រុក
ទេសផ្សេង ។ ដែលធ្លាប់រាប់អានព្រះពុទ្ធសាសនាមកហើយ គឺផ្សាយទៅ
ខាងក្រុងមធុរា, ក្រុងអបរាតិ, កោះលង្កា ។ តែព្រះពុទ្ធរូបគន្ធារៈនោះ
ឃើញមានក្រសែតំនិតរបស់ជាងអ៊ីរ៉ុប ពួកអ៊ីរ៉ុបគេឃើញថា ធ្វើដូចម្តេច
ជាការល្អគេក៏ធ្វើបែបនោះទៅ គេអាស្រ័យពួកតណ្ហៀតែត្រឹមគោលចារិក
ខាងប្រវត្តិសាស្ត្រប៉ុណ្ណោះ ពោលគឺព្រះពុទ្ធអង្គទ្រង់គង់ស្បង់ចីវរបែប
ណា, ព្រះអង្គជាជាតិក្សត្រ ធម្មតាក្សត្រតែងមានគ្រឿងទ្រង់ព្រះសិរ
គេទើបធ្វើព្រះពុទ្ធរូបឲ្យមានព្រះមោលីឡើង ព្រះពុទ្ធរូបទាំងពួងដែល
មានព្រះមោលី ព្រោះមានរឿងដូចអធិប្បាយមកនេះ មិនមែនជាព្រះ
ពុទ្ធអង្គទ្រង់មានព្រះសិរចោង្គ្គស់ឡើង ដែលជារបស់ខុសធម្មតាដូច្នោះ
ទេ ។ តាមដែលពិតរឿងព្រះមោលីនេះ ជាងដែលប្រាថ្នាធ្វើជាន់ដំបូង
គេមានតំនិតល្អណាស់ ទាល់តែជាងជាន់ក្រោយមិនអាចនឹងរកឧបាយ
កែទៀបាន ។ រឿងព្រះមោលី ជារឿងដែលគេបានតាំងតាំងពាណា
ច្រែនណាស់មកហើយ តាំងពីសម័យរដ្ឋកាលទី ៤ តែយើងសូមលើកទុក
នឹងអធិប្បាយទៅពេលក្រោយវិញ ។ បញ្ហារឿងនេះមានសាស្ត្រាចារ្យ
ម្នាក់ ឈ្មោះហ្វូឈេជាតិបាក់ងឹសេសបានអធិប្បាយថា ព្រះពុទ្ធរូបដែល
គេធ្វើឲ្យមានព្រះមោលីនោះ សម្រាប់ឲ្យដឹងថាជាព្រះពុទ្ធអង្គ ព្រោះថា
បើព្រះពុទ្ធរូបមានព្រះសិរដូចព្រះសាវ័កធម្មតា ក៏ងឹចឡំទៅនឹងរូប
ព្រះសាវ័ក បើយ៉ាងនេះធ្វើម្តេចនឹងដឹងថាអង្គណាជារូបព្រះសាវ័ក អង្គ

ណាជារូបព្រះពុទ្ធអង្គ, គេត្រូវការឲ្យព្រះពុទ្ធរូបមានលក្ខណៈផ្សេងពីរូបព្រះសាវ័ក គេទើបធ្វើឲ្យមានព្រះមោលីសម្រាប់សំគាល់ឡើង ដោយអាស្រ័យគោលដែលថាព្រះពុទ្ធអង្គជាជាតិក្សត្រ ដោយហេតុនេះព្រះពុទ្ធរូបទើបមានព្រះមោលីឡើង តែមោលីដែលគ្រែកធ្វើជាមោលីក្ដងសក់បួនឡើងមកលើ, ចីវរដែលគ្រែកធ្វើជាចីវរដែលដួញអង្ករាញ់ ។ ព្រះសមាធិរបស់គ្រែកមានតែសមាធិពេជ្រ ១ យ៉ាង គ្មានសមាធិកបរេ ។ ដែលអធិប្បាយមកនេះ បំភ្លឺឲ្យឃើញថា ការកសាងព្រះពុទ្ធរូបជាដំបូងនោះ ជាគំនិតរបស់គ្រែក ចំណែកពួកឥណ្ឌា គេមានតម្រា ហៅថា មហាបុរិសលក្ខណសាស្ត្រ គឺតម្រាទំនៀយយ៉ាងតាមទុស្សសំខាន់ មានពាក្យអធិប្បាយលក្ខណៈមនុស្សសំខាន់ជាដើមថា សរសៃព្រះកេសាវិលជាទក្ខិណាវ័ត្តិ ដូចគូថខ្មៅ កាលពួកឥណ្ឌាបានទទួលគំនិតកន្ដឹការកសាងរូបជាទីគោរពឡើង គេបានផ្ទាស់ប្ដូរច្រើនយ៉ាង ដូចសរសៃព្រះកេសាគេធ្វើឲ្យវិលជាទក្ខិណាវ័ត្តិ តាមតម្រាមហាបុរិសលក្ខណសាស្ត្រ, ព្រះកន្ទ្រៃពីដើមដូចមុខពួកអឺរ៉ុប គេផ្ទាស់ឲ្យដូចមុខពួកឥណ្ឌាទៅវិញ ដូចព្រះពុទ្ធរូបនៅក្រុងមធុរា ទន្ទឹងក្រុងអមរាវតីជាដើម ហើយចីវរដែលដួញអង្ករាញ់ ។ ខាងឥណ្ឌាឃើញថាមិនល្អ សំឡឹងមើលមិនឃើញទ្រនំ ទ្រាយរូបចង្អាស់លាស់ គេត្រូវការនឹងអះអាងភាពកាយថា ព្រះពុទ្ធអង្គមានព្រះសរីរកាយល្អ គេទើបធ្វើចីវរស្តើង ដើម្បីឲ្យឃើញភាពកាយយ៉ាងចង្អាស់លាស់ ទេវរូបនៅឥណ្ឌាគេក៏ធ្វើដូច្នោះដែរ ។

(មានត)

ផ្នែកអក្សរសាស្ត្រ

កំណត់ពុទ្ធសំណេរ (១)

ឃុនបណ្ណានុរក្ស ប៊ុ - ប៊ុ រៀបរៀង

—■—

គំនិតពុទ្ធទឹងគំនិតត្រូវទាំង ២ យ៉ាងនេះ សុទ្ធតែជាអ្នកកសាង សង្វាទឲ្យកើតមានឡើងដូចគ្នា តែគាន់តែមានប្រភេទប្លែកពីគ្នាប៉ុណ្ណោះ ដូចមានអត្ថាធិប្បាយតទៅនេះ ៖

គំនិតដែលមិនដឹងច្បាស់នូវសភាពនៃកាយតាមការពិត ហៅថា គំនិតពុទ្ធសាទេះ រមែងសំគាល់ថា កាយជាខ្លួនបុគ្គលរបស់អាត្មាជានិច្ច ជាងសំគាល់ថា ខ្លះជាគេ, ខ្លះជាយើង, ខ្លះជាប្រុស, ខ្លះជាស្រី ។ កាលបើសំគាល់យ៉ាងនេះហើយ ក៏គិតចង់ចាន់រូបកាយរបស់គ្នាទឹងគ្នា ដែលសន្ធត់តាមភេហារនិយមថា ស្វាមីភរិយា ជួយទំនុកបម្រុងគ្នាទឹងគ្នាខ្លះ បៀតបៀនគ្នាខ្លះ តាមតែចិត្តមានធម៌ជាកុសលឬជាអកុសល ច្រើនតិចជាងគ្នា ។ ប៉ុន្តែ កុងទីបំផុតរូបកាយទោះ ត្រូវបែកធ្លាយទៅមុនចិត្ត បើមិនបែកធ្លាយកាយរបស់គេទេ ក៏បែកធ្លាយកាយរបស់ខ្លួនដែរជាមិនខាន ។ បើរូបកាយអ្នកម្ខាងត្រូវបែកធ្លាយ (ស្លាប់) ទៅហើយ ចិត្តដែលបិតនៅកុងរូបកាយអ្នកម្ខាងទៀត ក៏សំគាល់ថាគូស្រករបស់ខ្លួនស្លាប់ទៅហើយ ទើបកើតសេចក្តីសោកខុកខ្ចល់ខ្លាំងខ្លះ ស្រាលខ្លះ

---

១ អធិប្បាយតាមន័យក្នុងអាទិត្តបរិយាយសូត្រ ។

តាមការស្រែឡាញ់ ពប់អានតិចច្រើន ព្រោះហេតុចិត្តអន្ទះអន្ទែងមិនចង់ឲ្យគួរស្រែករនោះស្ងប់សោះ, ចិត្តបែបនេះចាត់ជាតណ្ហា ជាចិត្តរងទុក្ខយំសោកអាក់អន់ចង្អៀតចង្អល់ជាដើម ។ ចិត្តជាធម្មជាតិឥតរូបកាយទ្រង់ទ្រាណកំពុតមែនហើយ ប៉ុន្តែអាចអន្ទះអន្ទែងបានដាពិតប្រាកដ បើអន្ទះអន្ទែងចង់បានខ្លាំង ក៏ក្តៅក្រហាយខ្លាំង បើអន្ទះអន្ទែងចង់បានតិច ក៏ក្តៅក្រហាយតិចដែរ ។ ប៉ុន្តែចិត្តឥតដឹងយល់ខ្លួនឯងថាជាអ្នកល្ងង់ខ្លៅទេ ព្រោះមិនបានពិចារណាឲ្យស្គិតស្គៃឲ្យគ្រប់គ្រាន់ទៅដល់សេចក្តីពិតរបស់ហេតុនឹងផល ។ ហេតុតែចិត្តមិនយល់ហេតុនឹងផលយ៉ាងនេះហើយ បានជាទទួលទុក្ខទោមនស្សក្តៅក្រហាយជានិច្ច កំណត់ពប់ពេលវេលាមិនចេះអស់ ។ ចុះចិត្តកើតក្តៅក្រហាយនោះតើព្រោះមានរបស់អ្វីមកដុតកំដៅ ? ព្រោះមានភ្លើងគឺតម្រេក (ពគៈ), សេចក្តីក្រោធខឹង (ទោសៈ), សេចក្តីវង្វេង (មោហៈ) នេះឯងដុតចិត្ត ។

បើចិត្តខំព្យាយាមគ្រិះរិះឲ្យស្គិតស្គុំមជ្ឈេលជ្រៅទៅទៀត មុខជាឱនឱ្យញ៉ាំហេតុផលជាគួគ្នាមិនខាន តើរូបកាយដែលឈឺចាប់ជាហេតុ, រូបកាយដែលត្រូវបែកខ្ចាយស្ងាប់ជាផល ។ ហេតុនឹងផល ១ គូនេះកើតមានទៅតែនឹងរូបកាយ ជារបស់ប្រព្រឹត្តទៅក្រៅអំណាចចិត្ត ។ ចិត្តជាធម្មជាតិមានអំណាចយ៉ាងខ្លាំងលើរូបកាយក៏ពិតមែនហើយ ប៉ុន្តែឱនហាមឃាត់ហេតុផល ១ គូនេះថា កុំឲ្យកើតជាមួយនឹងរូបកាយនោះ ក៏ឃាត់ខាំងមិនបានឡើយ ដ្បិតថា ទៅមានហេតុផលដ៏ស្ងួតក៏ជាំងស្គិតស្គុំម ១ គូទៀត ដែលកើតមានឡើងជាមួយនឹងចិត្តហើយបិតទៅកន្លែ

រូបកាយនាំបណ្តាលឲ្យចិត្តនោះវង្វេងភាន់ច្រឡំ ទៅគ្រែកអស្រឡាញ់ ពប់អានរូបកាយរបស់មនុស្សម្នាក់ទៀតប្រកាន់ថា ជាគូព្រែងរបស់ខ្លួន លុះដល់គូព្រែងនោះស្លាប់ទៅហើយ ចិត្តក៏អន្ទះអន្ទែងចង់ឲ្យតែមានជីវិតរស់នៅរួមគ្នាជានិច្চកាលទៅ មិនចង់ឲ្យគូព្រែងស្លាប់ឃាត់ទៅសោះ ចិត្តបែបនេះចាត់ជាចិត្តមានតណ្ហា តណ្ហានេះជាហេតុធ្វើឲ្យចិត្តរងទុក្ខ ។ ហេតុនេះបានជាបណ្ឌិតយល់ឃើញថា ការគិតដូច្នេះខុសណាស់ ព្រោះសំគាល់ថា រូបកាយជាខ្លួនឬណា ហើយវង្វេងស្រឡាញ់រូបកាយ ចេះតែអន្ទះអន្ទែងចង់បានរូបកាយ ពាល់តែត្រូវទុក្ខលំបាកទុក្ខយ៉ាងធ្ងន់ ។ ការគិតខុស មិនបានដឹងហេតុរបស់ទុក្ខដ៏ស្វាត់កំបាំងនេះឡើយ បានជាសម្តេចព្រះបរមសាស្តាជាចមអ្នកប្រាជ្ញក្នុងលោក ទ្រង់ត្រាបហេតុផលរបស់ទុក្ខនឹងសុខច្បាស់ហើយទ្រង់ត្រាស់ប្រាប់ថា "តណ្ហាទាសោ បុរិសោ មនុស្សបុរុសដែលជាទាសៈនៃតណ្ហា" ។ ចិត្តវង្វេងអន្ទះអន្ទែងចង់មានចង់បានកើតឡើងគាលណា ក៏ត្រូវរងទុក្ខក្នុងកាលនោះភ្លាម ។ ព្រោះហេតុនោះ គួរតែកំណត់ដឹងថា សេចក្តីទុក្ខពប់តាំងពីសោកជាដើមទៅ សុទ្ធតែជាផលរបស់តណ្ហាទាំងអស់ ។ ចុះចិត្តបែបណាចាត់ជាមានតណ្ហា? ចិត្តដែលអន្ទះអន្ទែងចង់មានចង់បានខ្លាំងកើត ចង់ឲ្យទៅជាយ៉ាងនេះជាយ៉ាងនោះ ចង់ឲ្យបានសុខស្រួល នេះចាត់ជាមានតណ្ហា ។ ចុះតណ្ហានុ៎ះ កើតមានមកអំពីទីណា? តណ្ហាកើតមានមកអំពីចិត្តដែលល្ងង់ខ្លៅនោះឯង ។ ចិត្តទៅត្រង់ណា តណ្ហានៅត្រង់នោះ ។ ប្រសិនបើតណ្ហាកើតមានមកពីទីកន្លែងឯទៀតក្រៅពីចិត្តវិញ តើចិត្តអាចនឹងលះបង់តណ្ហានោះឲ្យដាច់ដូ

ស្រឡះបានដែរឬទេ ? ត្រាកដជាលះបង់មិនជាប់ទេ ។ ព្រះតុន្តដីកា ដែលព្រះបរមសាស្តាទ្រង់ត្រាស់ប្តូន្មានថា "សមុទ័យ (តណ្ហា) ជាចំណែកដែលគួរលះបង់" ដូច្នេះនោះ ក៏អាចបង្អុលឲ្យយល់បានជាក់ច្បាស់ថា តណ្ហាជាហេតុនៃទុក្ខតែងកើតមានទៅក្នុងចិត្ត តណ្ហានេះនៅក្រៅអំណាចរបស់ចិត្ត ព្រោះថាក្រៅពីចិត្តហើយ ឥតរបស់ណាមួយទាំងអស់អាចអាចបង្កាប់បញ្ជាតណ្ហាបានឡើយ ។ ហេតុនេះ ចិត្តត្រូវតែដឹងស្គាល់ខ្លួនឯង ត្រូវតែប្រឹងប្រយ័ត្នខ្លួនឯង កុំឲ្យវង្វេងភាន់ច្រឡំទៅចង់បានអាម្មណ៍ដែលគួរស្អប់ខ្ពើម ដូចរូបល្អ, សម្លេងពីរោះ, ក្លិនក្រអូប, រសឆ្ងាញ់ពិសា, របស់ប៉ះទង្គិចកាយដ៏ទន់ភ្លន់ ។ ចិត្តដែលចង់បានរបស់ល្អទាំងនេះ ឈ្មោះថាកាមតណ្ហា ។ ចិត្តដែលប្រាថ្នាឲ្យរបស់ល្អទាំងនេះទៅតាំងខ្លួនជាប់ជាទិប្តិទៅ ឈ្មោះថា ភវតណ្ហា ។ ចិត្តដែលមិនចង់ឲ្យរបស់អាក្រក់កើតមានទៅជាប់រហូតទៅ ឈ្មោះថា វិភវតណ្ហា ។ ចិត្តជាអរូបធាតុ គឺជាសភាពឥតរូប ដ៏ប្លែកអស្ចារ្យជាងធម្មជាតិទាំងពួងយ៉ាងក្រៃលែង ។ ប៉ុន្តែសូម្បីចិត្តអស្ចារ្យដល់ម្ល៉ោះ ក៏ទៅតែមិនផុតពីសេចក្តីល្ងង់ខ្លៅដែរ ចេះតែចង់បានសុខ ស្អប់ខ្ពើមទុក្ខណាស់ ហេតុតែមិនដឹងខ្លួនថាខ្លួនវង្វេងភាន់ច្រឡំ ទៅបង្ហាត់ភ្លើងកិលេសឲ្យឆេះឡើងដុតពេលខ្លួនឯងជាទិប្តិឡើយ ។ ការវង្វេងទុក្ខជាផលរបស់ចិត្តអន្ទះអន្ទែងបងបាន ។ មនុស្សត្រៃរូបចេះតែទំនៃស្រែកថា "ខ្ញុំចង់បានសុខណាស់ ខ្ញុំស្អប់ខ្ពើមទុក្ខណាស់", ប៉ុន្តែតាមការពិត អ្នកទាំងនោះបែរជាខំគ្នាធ្វើទុក្ខសមុទ័យ (តណ្ហា) ឲ្យចម្រើនគឺឲ្យកើតឲ្យមានតែច្រើនឡើងទៅវិញ

ដូចជាអ្នកខ្ចីមលាមកណាស់ ប៉ុន្តែត្រឡប់ជាទៅដើរជាន់លាមកវិញ ។
សម្តេចព្រះបរមសាស្តា មានព្រះមហាករុណាចំពោះសត្វសត្វណាស់
ជាន់ជាខ្ពង់ត្រាស់ពន្យល់អំពីការត្រេកត្រអឺងជីវិតនោនាបច្ចុប្បន្ន នឹងខ្ពង់
ចង្អុលប្រាប់ហេតុរបស់សុខទុក្ខយ៉ាងជាក់ស្តែងថា ផ្លូវដ៏ប្រសើរសម្រាប់
រំលត់ទុក្ខមានអង្គ ៨ (អដ្ឋង្គិកមគ្គ) ជាផ្លូវអាចខ្ពង់ខ្ពាញចិត្តដែលធ្លាក់ទៅ
ទៅត្រេកអំណាចរបស់អវិជ្ជាគណ្ហានោះឲ្យប្រតិបត្តិតាម ដើម្បីឲ្យបាន
សម្រេចដល់សន្តិសុខ ដ៏ជាសុខពេញបរិបូណ៌ ។

យើងតាំងឡាយគួរណាស់តែខំត្រិះរិះតាមដំបូន្មានរបស់ព្រះសាស្តា
ឲ្យដឹងច្បាស់ថា របស់ណាព្រះអង្គប្រាប់ឲ្យលះបង់ ត្រូវលះបង់របស់
នោះចេញ, របស់ណាព្រះអង្គប្រាប់ឲ្យចំរើន ត្រូវចំរើនរបស់នោះ ឲ្យ
កើតមានច្រើនឡើង ទើបនឹងផុតពីទុក្ខដែលចិត្តស្អប់ខ្ពើម ហើយបាន
ទទួលសុខដែលចិត្តប្រាថ្នាយ៉ាងបំផុតនោះ ឲ្យសមតាមពាក្យដែលពោល
ប្រាប់អ្នកផងថា "ខ្ញុំចង់បានសុខណាស់ ខ្ញុំស្អប់ខ្ពើមទុក្ខណាស់" ។

រឿង ព្រះចាន់ទុសក៉ន់សាជ

និង

ព្រះចាន់សេហោរិស្ដាន៏

អ្នកស្រីពេត្រូ–សល់ ហៅ សារីន៉ែរ៉ាង ប្រែរៀបរៀង

(តពីបរិច្ឆេទ)

ព្រះចាន់ទុសក៉ន់សាជ លុះទ្រង់យល់ឃើញថា លោកមុយអេស៊ីន ដែលធ្លាប់បំរើព្រះអង្គដោយសុទ្ធចិត្តមកជាយូរណាស់ហើយ ។ នៅតែស្មោះត្រង់ទីនឹងព្រះអង្គជាដែល ទ្រង់ក៏មានព្រះបន្ទូលរៀបរាប់ អំពីការដែលទ្រង់ចាន់ទៅជួបនឹងព្រះនាងសេហោរិស្ដានិ ។ លោកមុយអេស៊ីនគ្មានកើតសេចក្ដីអស្ចារ្យប៉ុន្មានទេ ព្រោះធ្លាប់ចាន់ដឹងខ្លះៗមកហើយ ។ ប៉ុន្តែពេលនោះ ពួកមុង្គោលចាន់លើកទ័ពច្រើនជាអនេក ចូលមកលុកច្រៃទេសចិន ដើម្បីនឹងទ្រាន់យកនគរទាំងមូលតែម្ដង ។

ព្រះចាន់ទុសក៉ន់សាជ លុះទ្រង់ត្រូវដូច្នោះ ក៏ទ្រង់បង្គាប់ឲ្យប្រមូលទ័ពជាប្រញាប់ ដើម្បីទៅតទល់នឹងទ័ពបច្ចាមិត្ត ។ ទ្រង់នាំទ័ពចេញទៅជួបនឹងទ័ពបច្ចាមិត្ត ដែលបោះដំរំនៅក្នុងទីវាលមួយធំ ទ្រង់ព្រះបញ្ជាឲ្យពួកទ័ពឈប់នៅទំមិនឆ្ងាយពីគ្នាប៉ុន្មាន ។ បន្ទិចមកទ័ពដឹកស្បៀងអាហារដែលរង្គមន្ទីរៀលលីជាមេបញ្ជាការមកដល់ មានច្រជាប់ចរកោតគ្រប់ប៉ាន់ ទំច្រអប់ ផ្លែឈើគំប៉ុន . គ្រណាប់ នឹងគ្រឿងកេសដ្ឋ:គ្រប់យ៉ាង ។ នៅពេលដែលទ័ពនាំអាហារទាំងនោះ រៀបនឹងចូលមក

ដល់កាលដែលព្រះបាទសុសាន្តរាជដោះទ័ព ព្រះនាងសេហាវិស្ពានី
ហើយទទឹងពួកអាដិទេពជារៀងរូបនាំគ្នាស្តាត់ទ័ព គាញកំប៉ុងអាហារ
ផ្សែង។ ទម្លាក់ពីលើខ្នងសត្វ ហើយនាំគ្នាជាន់ចោលពេញទាំងដី គ្មាន
សល់អ្វីបន្តិច។ លុះលឺកាលឃើញដូច្នោះហើយមានសេចក្តីព្រួយណាស់
តែព្រះនាងសេហាវិស្ពានីគ្រាស់បង្គាប់ថា ៖

- ចូរឯងទៅទូលស្តេចថា ព្រះពុទ្ធទេពព្រះអង្គបានបំផ្លាញ
អាហារសម្រាប់ទ័ពអស់ទៅហើយ។

លុះលឺក៏នាំសេចក្តីទៅទូលព្រះមហាក្សត្រ។ ទ្រង់អស់សង្ឃឹមហើយ
ទ្រង់ព្រះតម្រិះណាថា ការដែលខ្ញុំចចង់កូនពីរដួចជាទៅអត់ទោសឲ្យនៅ
ឡើយ មិនដូចអំពើគ្រាយនេះទេ។ ទៅពេលដែលព្រះអង្គ
កំពុងតែគ្រាជ ស្រាប់តែព្រះនាងយាងមកដល់ ព្រះអង្គក៏មានព្រះ
បន្ទូលថា ៖

- ព្រះនាង, ម្តងនេះខ្ញុំទទឹងអត់ទ្រាំទៀតពុំបានទេ ព្រះនាងធ្វើ
ឲ្យខ្ញុំទ្រាំអត់ពុំបាន ព្រះនាងបានយកកូនប្រុសខ្ញុំទៅចោះក្នងក្តើង រួចឲ្យ
កូនស្រីខ្ញុំទៅឲ្យផ្លែ ហើយទៅពេលនោះ គោះជាខ្ញុំពិបាកចិត្តយ៉ាងណា
ក៏ខ្ញុំពុំហ៊ានហាមាត់ស្តី ប្តូរភ្លេញអាកប្បកិរិយាឲ្យដឹងសោះ ប៉ុន្តែអំពើ
ដែលព្រះនាងទើបទទឹងធ្វើអំបាញ់មិញនេះ ជាអំពើមិនចំពោះរូបខ្ញុំទេ
ហើយគោះជាខ្ញុំបានសន្យាទទឹងព្រះនាងហើយក៏ដោយ ម្តងនេះគឺត្រូវតែ
ខ្ញុំមានអំណាចតវ៉ា ព្រោះពួកទ័ពរបស់ខ្ញុំរកអាហារអ្វីបរិភោគគ្មាន តើគិត
ដូចម្តេច? សូមនិយាយមក! តើរូបខ្ញុំទៅជាយ៉ាងណាទៅ? ពុះព្រះ

នាងចង់ឲ្យពួកបច្ចាមិត្ត ចាប់ខ្លួនខ្ញុំបានដោយមិនចាប់ច្បាំងឬ? នែស្រីអកតញ្ញូ!... តើនាងនឹងយកអ្វីមកសងសេចក្តីស្នេហារបស់ខ្ញុំបាន? ។

- ព្រះមហាក្សត្រ បើសិនជាព្រះអង្គទ្រង់នៅឲ្យស្ងៀមម្តងនេះទៀត ជាការប្រសើរ, ការអត់ត្រាំមិនបាននេះ ជាការរំខានដល់សេចក្តីអត់ធ្មត់ដែលព្រះអង្គបានគាន់មកយូរហើយ ។ ក្នុងពេលនេះ គ្រោះថ្នាក់មកដល់ហើយរកថ្នាំអ្វីនឹងជាក់គ្មាន. តើព្រះអង្គទ្រង់ជ្រាបថា ក្មេងដែលខ្ញុំម្ចាស់ចោះព្រះពជបុត្រាទៅឲ្យនោះជាអ្វីទេ?... គឺជាអាវក្បក្មេងមួយយ៉ាងជំនាញ ដែលខ្ញុំម្ចាស់ប្រគល់ព្រះពជបុត្រាឲ្យគេបង្រៀន ឯឆ្កែញីសនោះទៀត ក៏ជាទេវតាមួយអង្គដែរ ដែលចង់ឲ្យព្រះពជបុត្រីព្រះអង្គចេះវិជ្ជាសាស្ត្រផ្សេងៗ ដែលបុត្រនៃអាទិទេពត្រូវចេះ ។ អាវក្បក្មេងនឹងទេវតានោះ គ្មានធ្វើឲ្យខ្ញុំម្ចាស់អន់ចិត្តបន្តិចទេ ដោយគេបានយកចិត្តទុកដាក់នឹងថែរក្សាកូនខ្ញុំម្ចាស់ទាំងពីរបែបដោយម៉ត់ចត់ណាស់ ហើយព្រះអង្គនឹងទ្រង់យល់ការពិតឥឡូវនេះភ្លាម ។

ថារួចហើយ ព្រះនាងក៏មានព្រះបន្ទូលហៅឆ្មាំដែលតាមដង្ហែព្រះនាងថា: ចូរឯងទៅប្រាប់ឲ្យគេនាំព្រះពជបុត្រានឹងព្រះពជធីតាអញមកទីនេះភ្លាម ។

មួយមុខតែក្រោយមក ព្រះពជកុមារ នឹងព្រះពជធីតាក៏ចូលមកដល់ជំរំព្រះអង្គ ។ ទ្រង់មានសេចក្តីត្រេកអរនឹងឃើញព្រះពជបុត្រមានព្រះកត្តិស្អាតប្រិមប្រិយ ហើយសួរទៅនុបព្រះពជកុមារចាំងពីរព្រះអង្គដោយពេញព្រះទ័យពន់ពេក ។ តមកព្រះនាងមានបន្ទូលទៀតថា:

- ឥឡូវនេះ សូមព្រះអង្គជ្រាបថា ហេតុអ្វីបានជាខ្ញុំម្ចាស់បំផ្លាញនូវស្បៀងអាហារគាំងឡាយចោល ? ព្រោះស្តេចមុនគោលចង់ធ្វើគត់ព្រះអង្គហើយដាក់នូវចិនជានតំណុះ; ដើម្បីទីសំរេចគោលបំណងនោះដោយមិនបាច់ចាំច្បាំង ព្រោះការច្បាំងតែងតែមានការខ្ជះខ្ជាយ គេបានយកប្រាក់ទៅសូករដ្ឋមន្ត្រីរបស់ព្រះអង្គ ដែលត្រួតការៈខាងផ្គត់ផ្គង់ស្បៀងអាហារទ័ព ។ គេបានសូកមាសមួយរយពាន់សីកាំង ហើយដោយអំណាចជម្លៃមាសនោះ វៃលីបានដាក់ថ្នាំបំពុលគ្រប់កំប៉ុងអាហារគាំងអស់ ហើយថ្នាំនោះនឹងបណ្តាលឲ្យស្លាប់ភាន់ច្រឡំមួយរំពេច បើសិនជាខ្ញុំម្ចាស់មិនបំផ្លាញនូវអាហារគាំងនោះទេ ពួកសេនាពាហានទឹងនាយពាហានព្រះអង្គនឹងស្លាប់គ្មានសល់ ។ ប៉ុន្តែបែរជាព្រះអង្គតុំទ្រង់ដៀលខ្ញុំម្ចាស់ទេ សូមព្រះអង្គទ្រង់ប្រើឲ្យវៃលីបរិភោគអាហារមួយមាត់នៅចំពោះព្រះភ័ក្ត្រព្រះអង្គលមើលចុះ ។

លុះមន្ត្រីទទួលការៈខាងស្បៀងអាហារមកដល់, ព្រះមហាក្សត្រទ្រង់បង្គាប់ឲ្យទៅរើសយកកំប៉ុងស្បៀងអាហារដែលនៅសល់ខ្លះ ។ បំរើម្នាក់បានយកត្រណាប់កំប៉ុងមួយទៅថ្វាយ ហើយមានត្រារបស់មន្ត្រីនៅលើនោះផង ។ ព្រះមហាក្សត្រទ្រង់ប្រើឲ្យពោះកំប៉ុង ហើយប្រើឲ្យវៃលីភ្លក្សមើល ។ មន្ត្រីទូលតបវិញថា ៖

- សូមទ្រង់ព្រះមេត្តាជ្រាស សូមព្រះអង្គព្រះពរជានពោស ត្បិតនៅពេលនេះ ទូលព្រះបង្គំជាខ្ញុំពុំមានទឹកចង់ទេ ។

- បើឯងមិនសុខចិត្តស៊ីភ្លាមទេ ក្បាលអាក្បត់ឯងនឹងខ្ចាត់ចេញពីខ្លួនឥឡូវនេះ ។

លោកវែលលីតិតថា "ទៅខាងណាក៏ស្លាប់ បើដូច្នេះសុខចិត្តស្លាប់របៀបណាដែលមិនសូវមានឈាមហូរ" ទឹកហើយមន្ត្រីអាក្រក់យកគ្រណាប់មកលិត ស្រាប់តែដួលស្លាប់នៅក្បែរព្រះបាទព្រះមហាក្សត្រមួយរំពេច ។

ព្រះនាងសេហេរិស្តានី លុះទតឃើញហើយក៏មានបន្ទូលថា ៖

- ម្ដងនេះ ព្រះអង្គដឿងជាក់ - អំពីការក្បត់នៃមន្ត្រីព្រះអង្គហើយ ប្រហែលជាព្រះអង្គយល់ច្បាស់ថាអាទិទេពមិនមែនធ្វើការអ្វី ដែលគ្មានប្រយោជន៍ទេ ។

- ពិតមែនហើយ ព្រះនាង ! បងខុសត្រង់មិនបានការបញ្ជាតិដែលប្អូនដាក់ឱ្យបង ឱ្យបានផុតចុងផុតដើម ប៉ុន្តែបងនៅតែពុំទាន់អស់សេចក្តីត្រេកអរនៅឡើយទេ ព្រោះកងទ័ពគ្មានអាហារបរិភោគ, ការអត់ឃ្លានឹងធ្វើឱ្យស្លាប់ដូចជាថ្មាំពុលដែរ ។

- ទេ, ទេ ព្រះអង្គ ! ស្បៀងអាហារមិនខ្វះទេ ។ យប់នេះសូមព្រះអង្គចូលទៅលុកវាយទ័ពបច្ចាមិត្ត ហើយដណ្តើមយកស្បៀងអាហារមក សឹមត្រឡប់ចូលព្រះនគរវិញ ដោយមានជ័យជំនះផង ។

នៅពាក់កណ្តាលអធ្រាត្រ ព្រះនាងសេហេរិស្តានីហើយនឹងអាទិទេពទាំងអស់នាំគ្នាទៅកាន់ក្បាលទ័ពចិន ហើយចូលលុកវាយទ័ពមុងគោលទាល់តែដួលដេកដូចជាដើមស្រូវត្រូវខ្យល់ព្យុះ ។ ការប្រយុទ្ធមានដំណើរលឿនសម្បើម ទាល់តែមហាក្សត្រជាតិមុងគោលដែលខ្លាំង

បេញ្ចាដឹកមុខខ្ញុំតែងដោយព្រះអង្គឯង រកសុំរត់ឲ្យរួចអាយុជីវិតដោយលំបាក ។ លុះត្រលឹមស្អែកឡើង យើញខ្មោចតាហានដេកស្លាប់ពេញតែវាល, ព្រះបាទអុសក៏ទសាដទ្រង់សរសើរអំពីជ័យជំនះ របស់ព្រះអង្គ ដោយយើញស្លាប់តាហានរបស់ព្រះអង្គតិច ។

ព្រះពាជទេពីមានព្រះបន្ទូលចំពោះព្រះបាទអុសក៏ទសាជថា :

- ពួកបច្ចាមិត្តព្រះអង្គទៅជាធធ់ធួលីអស់ហើយ ការច្បាំងក៏ចប់តែមនេះ ។ ឥឡូវនេះ សូមព្រះអង្គត្រឡប់ចូលព្រះនគរធំទៅជាសុខវិញចុះ ។ ចំណែកខ្ញុំម្ចាស់ខឹងសូមលាព្រះអង្គ ម្ដងនេះយើងត្រូវខាតជួបគ្នាអស់មួយជីវិត ។ ព្រះអង្គទំងវែងបានយល់ខ្ញុំម្ចាស់ខ្លៃតហើយ គឺជាកំហុសរបស់ព្រះអង្គទេ ព្រោះព្រះអង្គពុំគាន់ពាក្យសច្ចៈ ។

- ថាម៉េច ! ឧព្រះគុណអើយ សូមព្រះនាងកុំនាំរឿងអតមង្គលនេះមកនិយាយទៀត សូមប្អូនអត់ទោសឲ្យបងចំពោះការដែលពុំបានគោរពពាក្យសច្ចៈ បងមានសេចក្ដីបន្ទោសខ្លួនបងខ្លាំងណាស់ទៅហើយ ពីថ្ងៃនេះទៅបងស្បថជូននាង ថាបងលែងធ្វើអ្វីឲ្យប្អូនខាស់ចិត្តទៀតហើយ ទោះប្អូនធ្វើអ្វីក៏ដោយ សូមត្រឹតែនឹកកងចិត្តកំបងលែងនឹកទៀត ។

- ការស្បថស្បែរបស់ព្រះអង្គជាការឥតប្រយោជន៍ទេ តែតច្បាប់តម្រូវឲ្យខ្ញុំម្ចាស់ទៅឆ្ងាយពីព្រះអង្គ សូមទ្រង់កុំឃាត់ខ្ញុំម្ចាស់ . . . . . បើសិនជាត្រឹមតែខ្លួនខ្ញុំម្ចាស់មួយ ដែលត្រូវអត់ទោសចំពោះព្រះអង្គនោះ ខ្ញុំម្ចាស់មិនមែនជាអ្នកចិត្តរឹងថ្ងឹងទេ . . . . បើដូច្នេះ ខ្ញុំម្ចាស់ថ្វាយបង្គំលាព្រះអង្គហើយ ឧ ! ប្ដីសំឡាញ់ . . . ព្រះអង្គបាត់ទាំងព្រះពាជបុត្រ

ខ្ញុំនឹងព្រះទេពីផង . . . ហើយគោះជាព្រះអង្គជន់ស្រែន់យ៉ាងណា ក៏មិនឃើញវិញដែរ ។

ថាហើយព្រះនាងព្រមទាំងព្រះពជបុត្រទាំងពីរព្រះអង្គ ក្រេងព្រះកន្សែង ហើយស្រាប់តែបាត់អស់រលីងទៅ ។ គោះបីព្រះអង្គបរាជ័យហើយធ្លាក់ទោក្នុងដៃបច្ចាមិត្ត ក៏ក្រេងពុំសោកសង្រែងយ៉ាងនេះដែរ ។ ក្រេងទ្វាទាំព្រះកំភ្លូព្រះអង្គ ក្រេងយកដីមកជាក់លើព្រះសេរីសាហើយនឹងធ្វើអំពើផ្សេង ។ ទៀត ហាក់ដូចជាក្រេងវិកលចរិត ។

ប៉ុន្តែ ក្រេងនាំក្បួនទ័ពភាល់តែមកដល់ក្រុងបេតាំងវិញ លុះក្រេងយាងចូលទៅដល់ព្រះបរមពជភ័ន ក្រេងគ្រាស់ទឹងលោកមុយអេស៊ីនថា ៖

— ប្រមុខរដ្ឋ ! ខ្ញុំសូមប្រគល់ការៈការៈផ្សេង ៗក្នុងនគរលើអ្នក សូមអ្នកមើលការខុសត្រូវដំនួសខ្ញុំចុះ ខ្ញុំពុកពេលតិចថ្ងៃនេះទៅទល់ទឹងថ្ងៃស្អាប់ដើម្បីសោកស្តាយប្រពន្ធទឹងកូនខ្ញុំ ដែលគេលែងឲ្យខ្ញុំឃើញមុខគេទៀតដោយខ្ញុំមិនគាន់ពាក្យសម្តី ។ ខ្ញុំលែងចង់ឃើញមុខអ្នកណាទៀតហើយលើកតែលោកមួយទេ ហើយលោកមិនត្រូវនឹកនិយាយរឿងអ្វី ក្រៅអំពីរឿងប្រពន្ធកូនខ្ញុំមកប្រាប់ខ្ញុំទេ ចំណែកខ្ញុំ ។ គ្មានធ្វើអ្វីក្រៅអំពីកិច្ចព្រួយបារម្ភឡើយ ។

ក្រោយមកព្រះបាទសុសាន្តសាជ តន់សំងឹកក្នុងបន្ទប់ ដូចព្រះបន្ទូលក្រេងមែន ហើយមានតែលោកមុយអេស៊ីនទេដែលក្រេងអនុញ្ញាតឲ្យចូលបាន ។ រដ្ឋមន្ត្រីល្អនេះចេះតែចូលទៅសង្កេតមើលព្រះអង្គរាល់ថ្ងៃហើយសង្ឃឹមថាសេចក្តីទុក្ខរបស់ព្រះអង្គ នឹងរសាយទៅតាមពេលវេលា

មិនខាន ។ ប៉ុន្តែសេចក្តីទុក្ខរបស់ព្រះអង្គបែរជាធំធៃតែខ្លាំងឡើង ។ ទៅវិញ ។ ព្រះមហាក្សត្រខែធំសង្រែងសង្រៃយ៉ាងនេះ អស់រវាងជប់ឆ្នាំ ។ ថ្ងៃមួយ នៅពេលដែលព្រះអង្គ ទំនេរសេចក្តីមរណៈនៅឃ្លាតពីគ្នាតែពីរឆ្នាប់ ស្រាប់តែលេចព្រះនាងសេហៈវិស្តារមក ហើយព្រះនាងមានបន្ទូលទៅព្រះអង្គថា ៖

- ព្រះមហាក្សត្រ ! ខ្ញុំម្ចាស់មកបញ្ចប់នូវសេចក្តីទុក្ខរបស់ព្រះអង្គ ហើយជួយព្រះអង្គឲ្យបានមានព្រះជន្មឡើងវិញ ។ កិច្ចបញ្ញត្តិរបស់យើងតម្រូវឲ្យខ្ញុំម្ចាស់ព្រាត់ពីព្រះអង្គជប់ឆ្នាំ ដើម្បីជាខណ្ឌកម្មដល់ការប្រែប្រួលស្មើស ហើយបើកន្លងរវាងជបឆ្នាំនោះ ព្រះអង្គនៅតែមានព្រះទ័យស្មោះស័ក្តិទន្ធិខ្ញុំម្ចាស់ ទើបខ្ញុំម្ចាស់ត្រឡប់មកជួបនឹងព្រះអង្គបាន ។ ហេតុដូច្នេះហើយបានជាខ្ញុំម្ចាស់ស្មានថា ពុំបានជួបព្រះភ័ក្ត្រព្រះអង្គទៀតទេ ព្រោះធម្មតាមនុស្សលោកពុំអាចនឹងអត់ធន់យូរឆ្នាំបាន មិនយូរប៉ុន្មានទ្រង់នឹងក្សោះខ្ញុំម្ចាស់ ។ ប៉ុន្តែខ្ញុំម្ចាស់ស្មានខុស ព្រោះព្រះអង្គនៅតែស្មោះត្រង់នឹងខ្ញុំម្ចាស់ជាដរាប ឥឡូវនេះខ្ញុំម្ចាស់ត្រឡប់មកវិញហើយ ។ ដើម្បីនឹងបំពេញអំណរព្រះអង្គខ្ញុំម្ចាស់នាំគាំងកូនពីរមកថ្វាយព្រះអង្គផង ។

នៅពេលនោះ ព្រះមហាក្សត្រស្រាប់តែទ្រង់ទតឃើញព្រះរាជបុត្រគាំងពីរព្រះអង្គនៅជិតព្រះអង្គ ធំហើយល្អចំណាប់... ព្រះអង្គម្ចាស់ក្សត្រានឹងព្រះនាង ចាល់-គីស សំដែងមនោសញ្ចេតនាស្រទន់ទៅកព្រះបិតាដែលទ្រង់ពុំបានគាំងស្គាល់ជាក់ផង ។ ព្រះមហាក្សត្រលុះទ្រង់យល់

ឃើញដូច្នោះហើយ ទ្រង់ព្រះកន្សែងដោយរំជួលព្រះហឫទ័យពេក ។ ប៉ុន្មានថ្ងៃក្រោយមក សុខភាពរបស់ព្រះអង្គក៏ចេះតែស្រេស្រាយមួយថ្ងៃបន្តិចៗ ។

ក្សត្រតាំង ៤ ព្រះអង្គ សោយរាជសម្បត្តិប្រកបដោយសុភមង្គលដ៏ប្រសើរ ។ ក្រោយព្រះភ្នំសុរ៉ាន្ទសាជទឹង ព្រះនាងសេហរិស្តាទ្រង់សុគតទៅ ព្រះអង្គម្ចាស់សេហរិស្តង់ទ្រង់ឡើងគ្រងរាជ្យទៅបែរទេសចិន ឯព្រះនាងចាល់តីសទ្រង់ទៅសោយរាជ្យឯកោះសេហរិស្តង់ តាល់តែព្រះនាងចាទមហាហោក សាលម៉ុងជាព្រះស្វាមី ។

ចប់

ភាគ៣

អ្នកឧកញ៉ាមហាវិនិច្ឆ័យ នៅ

រៀបរៀង

(ត - ចប់)

សោតសឹងអំណរអរស្រែបស្រុះ ស្រីប្រុសសាទរតាំងផែនដី
ដោយសែងចាំងចែងកេចន៍រស្មី សឹងមានមេត្រីតែគ្រប់ប្រាណ ។
នេះដូចប្រដាជនជាតិជាក់ មានបានឃើញព្រះគន្ធមហាក្សត្រក្សាន្ត
មានចិត្តត្រេកអរពន់ប្រមាណ ដូចបានឃើញវង់ព្រះច័ន្ទស្មោះ ។

យថាសព្វភិភូតាធិ អាទិវាទោ ភាគ្យសម្បុរស

ពោលថាផែនដីឥតចន្លោះ ខ្សែតូចាំងអស់ឲ្យអាស្រ័យ ។
ពោះល្អាត្រក់មិនរើសមុខ តែងខ្ចែងខ្ចប់ទុកទៅសព្វថ្ងៃ
ពប់រកស្មើគ្នាដោយនិស្ស័យ ឧបមេយ្យប្រៀបនេះដូចក្សត្រា ។
គ្រប់គ្រងអាណាប្រជាកន្លង ទៅថាសកម្មករខ្ញុំពជការ
ខាងក្នុងខាងក្រៅពជសីមា មេត្តាពប់ស្មើដូច្នោះឯង ។

បដុណ្ណោបតុមាសំ

វស្សាទបួនខែមិនហួតហែង កំណែតាំងតែងតាមកំណត់ ។
នេះដូចព្រះចៅចម្ងផែនដី ប្រណីយោងាមិនឲ្យអត់
ព្រះទានធនធានមានច្រើនជ សន្ធតតាមរូបគុណវិជ្ជ ។

តាំងគ្រឿងបរិភោគផងតាំងឡាយ ចែកចាយសាយសព្វពលយោធា
សឹងមានបរិតអត្រៃបន្តូ ដោយបុណ្យសម្ភារព្រះចារមី ។
បព្វជ្ជាគង្គបដិវេធៈ ខត្តិយៈ ប្រសើរសុទ្ធសីរី
គួរខ្ពង់ប្រព្រឹត្តគំតគប្បី សេចក្តីខសពីធដប់ប្រការ ។
មួយតឹបរិច្ចាគព្រះកដ្ឋឥព្យ គួរតាប់ជាភានតាមច្បាប់
មួយខ្ពង់និច្ចសីលសមាចារ ដែរថ្នាបរិសុទ្ធជាប្រក្រតិ ។
មួយដប់លៀងខ្ញុំពជការ មេត្តាសន្តោសច្រាសប្រណី
មួយមានសន្តានល្អគប្បី ព្រះទ័យសូត្រតែងខ្ពង់សុចរិត ។
មួយមានព្រះទ័យខ្ពង់លំនោន អត់ធនសន្តោសដោយក្រមក្រិត្យ
មួយមានព្រះទ័យតាំងជាប់ស្និទ្ធ ថេរបិតដោយខ្លួវក្តីមេត្តា ។
មួយខ្ពង់ខ្លួវសីលឧបោសថ លំនុតវិរតិប្រុងរក្សា
មួយមានព្រះទ័យខ្ពង់ករុណា មិនហិង្សាបៀតបៀនសត្វតាំងឡាយ ។
មួយខ្ពង់ខន្តីក្តីអំណត់ សង្កត់ក្តីក្រោធឱ្យរសាយ
មួយមានភជកិច្ចខ្ពង់ខ្លួលឡាយ តាមតំរាយបូកណាក្យត្រា ។
ទសពិធដប់នេះជាក្រិត្យក្រម ក្យត្រទុត្តមគួរខំថែរក្សា
ប្រព្រឹត្តប្រតិបត្តិគប់ប្រការ ហោមហាក៏ត្តិយសខ្ពស់មែនមាន ។
ហើយខ្ពង់ប្រកបដោយទសាហ៍ មនសិការធម្មសាត្រជាប្រធាន
ត្រមតាំងភជនីតិគិតរិះធ្យាន មិនបំពានឱ្យក្លាត់ពីព្រះទ័យ ។
ប្រកបត្រមហេតុបួនប្រការ មួយខ្ពង់ពិចារណាដោយប្រពៃ

សេចក្តីតាប់ខុសធ្ងន់រឿងវៃ ជាបន័យខំនឹងដំណើរកស្តួ ។
ជាធ្វើអំពើប្រយោជន៍ផល ប្តូរធ្វើកង្វល់ឲ្យវិនាស
ប្រយោជន៍ហោចហ៊ានមិនទុកាស ធ្វាសជៀសប្រយោជន៍ចាកព្រះអង្គ ។
មួយទ្រង់ទុកត្តម្ភបម្រុងមនុស្ស ដែលលុះសីលសត្យសុចរិតត្រង់
ធ្វើវត្តប្រតិបត្តិចិត្តផ្តិតផ្តង់ គួរទ្រង់ស្រោចស្រង់ដោយត្រូវការ ។
មួយទ្រង់ប្រមូលព្រះពាជទ្រព្យ រិះពាប់តាប់គួរទុកវក្សា
តាមដោយយុត្តិធម៌ថ្លៃថ្លា សម្ធាសុចរិតពិតប្រពៃ ។
មួយទ្រង់រក្សាព្រះនគរ មិនឲ្យរឹកវៃមានមោះមៃ
ក្សេមក្សាន្តសាន្តសុខឥតទុក្ខភ័យ ដោយន័យយុត្តិធម៌ទៀងពិត ។
មួយបិតកង់កិច្ចពាជវណី វិធីគួរទ្រង់តាមពាជនីតិ
សំដែងថាស្តេចគួរិះគិត ប្រតិត្តឲ្យត្រមសុវត្តិ ។
តីពោលត្រលប់យប់សន្ធិយា ពាជាក្រសាលត្បូរដន្ត្រី
ហួសយាមបឋមគួរចក្រី ស្តាប់អាថ៌សេចក្តីរឿងបុពណ ។
ហើយព្រះសណ្តាប់ច្បាប់វណ៌ វិធីយុត្តិត្រប់ស្មាន
ដើម្បីជ្រាបកិច្ចធម៌កល្យាណ លំអានក្តីល្អលោកពណិនា ។
លុះដល់បច្ចូមយាមចូលបន្ទំ មនោរម្យកំសាន្តព្រះទយ
ផ្ទំស្តាប់លុះដល់ពេលវេលា ពាជាតើនចាកបន្ទំទី ។
បែរអង្គផ្ងោះត្រង់ប្លូពិទិសា ទ្រង់ស្រប់តក្តាដោយភាវ
ស្រេចទ្រង់គ្រឿងត្រប់រឿងរូដី ចរលើចេញទតខ្ញុំពាជការ ។
តីពួកអមាត្យពាជបណ្ឌិត ព្រាហ្មណ៍ព្រឹទ្ធកវីហោរាចារ្យ

ត្រមត្រែរាជវង្សទ្រង់ស្បា　　មន្ត្រីសេនាត្រប់ត្រសួង ។
ខើបស្តេចសីហនាទយោងយាត្រា　　កាន់សាល់អាយ៉ាសាលហួង
សំរាប់រំទិច្ច័យក្តីទាំងពួង　　ឆ្នង់ដួងហ្លួងច័យខ្លង់សណ្តាប់ ។
អស់ទាំងតុលាការប្រឹក្សាក្តី　　យុត្តិតប្បីប្តូរសច្បាប់
ប្តូរមួយវៀចវេរវេកឡាប់　　ខ្លង់ច្បាប់ហាមច្បាមតាមអាជ្ញា ។
ហើយតាំងព្រះច័យដោយសុចរិត　　ប្រព្រឹត្តយុត្តិសមាចារ
យកព្រះធម្មសាស្ត្រជាទេគ្រា　　ទតអាថ៌សេចក្តីយល់ពត់ជ្រះ ។
យកសតិសម្បជញ្ញៈ　　ជាហត្ថៈទាំងស្តាំចាំជាប់នៅ
ខ្លង់ព្រះទ័នតែវាក្តីសន្ធៅ　　តោលហៅវិចារណាបញ្ញា ។
ទំនងខ្លង់រំទិច្ច័យសេចក្តីពិស្តរ　　ឲ្យច្បាស់រង្គំស្មះចាកតរហា
ដំរិះត្រិះរិះពិចារណា　　ចរិយាយុត្តិធម៌ប្រពៃ ។

កាលិនោសុបិយាសុរា　　សេរតាអមាត្យណាមួយនៃ
មានវង្សត្រកូលឥតមោរមៃ　　រៀនរៀក្លៀវក្លាការទាំងឡាយ ។
ហើយបានត្រៃតត្រាប់ស្តាប់ត្រង់រង　　កន្ទុំដំណើរត្រប់បរិយាយ
ស្ទាញស្ទាត់ចាប់បទអត់ច្រាយ　　ខ្លាំងខ្លាយអាចចាំទូវាជន៍តី ។
ជាទីសំឡាញ់នៃជនជាតិ　　មារយាទជាមនុស្សតែងរិះគិត
គួរខ្លង់យកប្រើតាល់ជាប់ជិត　　ជំនិតដឹតកង្គ្រឹតរបក្រិ ។

សុត្តវិសំលវិសុរោ　　ប្បាបៅ ចាប់ខ្មែរលោកស្រដ
សំដែងថ្វែងចាជាមន្ត្រី　　មានអង្គច្បាំបិជាប្រធាន ។

មួយគឺបានស្តាប់ត្រាប់មកច្រើន　　ចំរើនដំរេះបេះរេះធ្យាន
មួយគឺប្រែកបដោយសីលទាន　　មួយគឺសោតមានចិត្តភ្ញៀវភ្ញា ។
មួយមានព្យាយាមច្រើនអនេក　　អតិរេកប្រែកបដោយឧស្សាហ៍
មួយគឺទិតទំធ្វើកជការ　　ប្រាថ្នាឲ្យរួចហើយឲ្យធាប់ ។
មួយមានកំឡាំងខ្លាំងច្រើនជ　　មួយអត់មិនណេកទុសត្រៃបច្ឆាប់
មួយមានរូបខ្ពង់អគ្គចំណាប់　　ជនជាតិចង់ចាប់ចិត្តស្នេហា ។
បុរសប្រែកបអគ្គច្រើបើ　　ប្រាកដសេចក្តីដូច្នេះណា
ទើបនឹងសមគួរជាមាតា　　សញ្ញាសន្ធតជាមន្ត្រី ។

អត្ថុទ្ធរោធិយិអត្ថិ

វាបំបទនេះតែសេចក្តី ។
សំដែងថាអម្ចាស់ផែនដី　　គប្បីឲ្យជាបប្រជៀវស្តួ
ណាមួយមិនដឹងប្រយោជន៍ផល　　កិច្ចកលការងារជាឧតាស
ខ្ពង់ប្រឹងប្រែងតរង្គ្រឹស　　ឲ្យឈ្មោសទ្វាតដឹងគ្រប់ប្រការ ។
ហើយកាត់សន្ទុះពស្តួសង្រ្គាម　　ឧបមេយ្យពន្យល់ឲ្យក្តីថ្លា
ខ្ពង់តែងសំដែងគុណក្សត្រា　　ដល់ពជបវ៌ាក់ខេត្តឹងព្រះអគ្គ ។

បាបំខត្ថនិរាធយ្យ

ឮញ្ញនេះជាបនេះលោកថ្លែងត្រង់
ថាខ្ញុំពជការគួរឲ្យតផ្ទង់　　តាំងចិត្តតម្រង់តម្រែកតិត ។
ដោយហេតុជាមួយកងសន្ធាន　　ស្ថានទីមួយគួរពិនិត្យ
គប្បីទូលថាស់ព្រះបពិត្រ　　កាលខ្ពង់ប្រឹត្តមិនគប្បី ។
មួយឲ្យប្រែកបក្តីចំរើន　　ប្រយោជន៍ដ៏ច្រើនក្នុងផែនដី

មួយជួយចំពោះការអប្រិយ　　ដែលព្រះបក្រីធ្វើមិនល្អ ។
មួយគឺសំដែងគុណអម្ចាស់　　ឲ្យបា្រស់ច្រាកដដោយស្មោះសរ
មួយកាលអម្ចាស់មានក្រែក្រ　　កំដរគ្រាំទ្រមិនចោលម្ចាស់ ។
មួយកាលអម្ចាស់លើសិរសា　　មានការខិតខាត់កម្រណាស់
អាចជួយសង្គ្រោះចំពោះបា្រស់　　ក្រឲ្យាស់គិតកែតាមកំឡាំង ។
លក្ខណៈថ្នាំមួយនេះជាខ្នាត　　អមាត្យគួរមានជាទីតាំង
ពាល់ខ្លួនតួនគួរជាទាំសំ　　សញ្ញាំមានសព្វគ្រប់ប្រុា ។

កោធំសោកំភាយំលោភំ　　វាក្យំ បទនេះសំដែងថា
ជាស្តេចគប្បីតាំងប្តេជ្ញា　　កន្ទុងហេតុការណ៍ថ្នាំមួយពំត ។
មួយគឺកាលខ្មែរព្រះពំពេធ　　ក្រែវក្រោធសោតសឹងមិនពិនិត្យ
មួយគឺសោយសោកអម៉ោកគិត　　មួយគឺក័យកិតនឹកខ្លាចក្រែង ។
មួយគឺលោភោក្រៃតន្ទុង　　កន្ទុងចំនួងព្រះសំដែង
ច្រកាមួយខ្នើតលោកថ្នាថ្លែង　　គឺរវែងវិនាសត្រកូលស្មោះ ។
មួយគឺខ្ទង់ខ្លាចវិនាសខ្លួន　　រិះកប់ខ្លាចខ្លួនខ្លួនខ្លាចអស់
មិនច្រែងខ្ទង់ច្រើរដោយសប្បុរស　　តាមរបស់ដែលគួរជាពជការ ។
ហេតុថ្នាំមួយនេះគួរមហាក្សត្រ　　លះកាត់លាកចេញកុំកន្ទ្រា
ទើបធ្វើជាស្តេចអង្គឥស្សរ　　ក្នុងមហាស្មុតដ៏ត្រជាកជបាន ។
ពលំសមេធសាធេយ្យៈ　　ភរះកំណត់បទបុព្វកណ
សំដែងចែងទុកជាលំអាន　　ដើម្បីក្សត្រក្សាខ្លួនបមដែនដី ។

ទឹងច្រែងដល់ខ្លួនមានប្រៃជាមនុស្ស ឲ្យលុះអំណាចខ្លាចចាប់មើ
នោះឲ្យច្រែកបដោយសេចក្តី គប្បីដោយន័យដូច្នេះណា ។
បើមនុស្សមានវិជ្ជាខ្ញុំឯងពូកែ មានតែខ្លួនមើលកល់ការ
ដោយឲ្យត្រមៃត្រងើបរអា មិនក្លាទឹងខ្លាចអំណាចបាន ។
ខ្លួនមានមនុស្សខ្លាចនោះឲ្យច្រែក ចំណែកបក្សពួកជាប្រមាណ
ទើបមិនរាជច់ចុចចប់ខាន ទឹងក្រៀវក្លាហានមិនក្តីកត័យ ។
ខ្លួនមានមនុស្សលោកដោយឲ្យច្រែញ្ញ របស់គួរគាប់ផងទើរៃ
ទើបទឹងមានចិត្តស្និទ្ធច្រៃពៃ ឥតមានមោះមៃក្តីឫស្សា ។
បើមនុស្សទិដ្ឋប្រជៅក្រែ ខ្លួនខាងល្អមិនច្បាច្បា
ប្រជៅឲ្យដាក់ព្រះអាជ្ញា ទើបរអាកពងខ្លាចចាប់មើ ។

កោសោរាជាគ្រូម្ចាស់ រឿង តាំងតែងតាមចាលី

ប្រៀបច្បាយអធិប្បាយជាសេចក្តី ដើម្បីជ្រាបដល់អង្គក្សត្រា ។
ឯអង្គឥស្សរៈរៈវត្ត សន្ទុះប្រៀបដូចដើមវុក្ខា
កាជវង្សានុវង្សមិត្តមាត្យា ឧបមាដូចមែកឈើតាំងឡាយ ។
នាយឃ្លាំងលោកខុកដូចឫសឈើ ហេតុធ្វើគំនិតគិតខ្វល់ខ្វាយ
រក្សាកដច្រែញ្ញមិនខ្ចាត់ខ្ចាយ មិនឲ្យអន្តរាយវិនាសបង់ ។
ក្សត្រាបើច្បាស់វិនាសច្រែញ្ញ សម្បត្តិគួរគាប់ពីព្រះអង្គ
ដូចកល់វិច្ចាកបក្សីហង្ស ច្បាស់បង់ចាកស្លាបដូច្នោះឯង ។
ដូច្នេះគួរព្រះមហាក្សត្រ ត្រៃតិបត្តិព្យាយាមខ្នះខ្នែង

រកទ្រព្យដោយធម៌ជ្រាកជស្តែន តាក់តែងតាំងទុកការអន្តរាយ ។
ធិប្ចាវិល្លភតិទ្ធាតិ អាទិវាទោ ពាក្យបរិយាយ
សំដែងថាស្តេចផងតាំងឡាយ គួរទ្រង់ខ្វល់ខ្វាយរំរែកក្សា ។
ព្រះពជអាណាខៃត្រដែនខេតរ ឲ្យសុខសាទរគ្រប់ប្រការ
រួចពាកសត្រូវចិត្តក្តៀវក្លា មិនហ៊ានជ្រាបថ្នាមកុរកាន ។
ហើយរួចពាកមនុស្សប៊ីប្រការ កំណាត់ច្នេះថាជាប្រធាន
មួយរួចពាកមនុស្សស្ងួនស្មាលហ៊ាន ឥតមានវែងឆ៊ីក្រែងមិនគួរ ។
មិនឲ្យរួចពាកមនុស្សមានទ្រព្យ មួនមាំលើសលុបអ្នកមានតួ
មួយរួចព័មហាចោរជ្រួរ ម៉ៅម្ហូមែនមានតែទុច្ចរិត ។
មួយទៀតគប្បីទ្រង់រក្សា ទាំងខាព្រះឃ្លាំងឲ្យថេរបិត
សម្បត្តិសម្បូណាជ័រចិត្រ ឲ្យស្ងួនច្រៃតែគ្រប់ប្រការ ។
ទើបបានជ្រាកជប្រកបឈ្មោះ ចំពោះពេញពិតជារក្សា
ព្រះពជអាណាខៃត្រដែនសីមា ឲ្យវិត្ថារថេរបិតឥតមោះមៃ ។
ពីទំសត្តអធិយោគោ វាទោ ជាបទកំណាត់ទីយ
គម្ពីរពជនិតិពិតច្រៃ បណ្ឌិតគិតតែកែទុកមក ។
ថាបើជាក្សត្រអគ្គឯណា មនសិការត្រែកត្រាប់ស្តាប់តាន់យក
ទុកកងព្រះទ័យរំរែក លែលះការឿយរាប់ឲ្យខ្ជាប់ខ្ជួន ។
ទង់ជ្រាបហេតុកលដែលកំសត់ សត្រូវឲ្យបាត់ខ្លាត់មែនមួន
ខ្លួបខ្លាចមិនអាចមកគុំគួន ថែថ្នូនរាបតាបតាំងតាក ។

លុះដល់អវសានកាលចំផុត ទីវង្គតរលត់ព្រៃជន្ម
ទឹងជានសោយសុខក្នុងសួគ៌ា វឌ្ឍនាចំរើនបុណ្យជាមី ។
ព្រោះព្រះពជាចែងប្រពឹត្ត ទេសតាឯកជនមិលួតបប្បី
សុខតាំងបរលោកតាំងលោកតីយ ច្រាកដសេចក្តីដូច្នេះឯង ។
គាសិតកជន៏តែនេះអ្នកទុកញ្ញា មហាវិនិច្ឆ័យជ្រៅចាត់ចែង
តាមក្បួនព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតតែង សំដែងជាច្បាប់ច្រាប់តំច្រាយ ។
មួយឈ្មោះអនន្តញ្ញាណព្រាហ្មណ៍ មួយទាមសុកៈព្រាហ្មណ៍ចាំបរិយាយ
ជាចមកជគ្រូតែងឲ្យល់ឱ្យ អធិប្បាយរឿងនេះកាលសាសនា ។
កន្ទុងទៅហើយហួសច្រកដ កំណត់ជានច្រើរយព្រះវស្សា
ថ្វាយអគ្គមមពង្សព្រះក្បួត្រា អកយគាមណីក្បួត្រទុត្តម ។
តែក្បួនបូកណាជាពាក្យពាយ និយាយសារសំខ្ចួច្រាប់ត្រឹមត្រូវក្រម
ទើបវិវរិះគិតលិខិតផ្សំ ឲ្យចំជាប់ដួនជាគាថា ។
ប្រយោជន៍ដើម្បីជាសណ្តាប់ ជនជាតិតែងត្រាប់ច្បាប់ពណិនា
ជាក្បួនគួនគួរចាំត្រប់ឃ្លា វណ្ណនាគាសិតចប់ម្ល៉ះហោង ។

ចប់

ពេទ្យព្រះភ្លើង

លោក ស៊ីង - ហ៊ាង ប្រែរៀបរៀង

លោក ឃ្លូរ - អ៊ីង តិនិត្យកែសម្រួល

(តមក)

មាណពមានសេចក្តីត្រេកអរពន់ពេក កើតមានតំណាងពោះបុណ្យដែលកើតឡើងព្រោះការជួយសត្វមានជីវិតជាច្រើន ដែលកំពុងមានទុក្ខក្តៅក្រហាយ, ទើបថ្វាយបង្គំព្រះពុទ្ធ ហើយត្រាច់ទៅចាប់ដៃអមាត្យជាសិតនាំដើរទៅឯកន្លែងមេគោស ស្រាយចំណងដែលចងរឹតតាំងខាងមុខនឹងខាងក្រោយបណ្តោយឲ្យដើរទៅតាមសេរី, កូនគោរត់តាមម្តាយរបស់ពួកវៃស្រែកកេងហ្មងៗបណ្តើរៗទៅ សភាពដូច្នេះ បណ្តាលឲ្យមាណពនឹងអមាត្យជាសិតមិនអាចអត់ទ្រាំខ្លួនការក្រាក់ផ្អើលញាប់ញ័រក្នុងចិត្តបានឡើយ ។

បុគ្គលអ្នកមានជម្ងឺនៅក្នុងខ្លួន រមែងដួចច្រេះខ្លួនសេចក្តីសុខសេចក្តីចំរើន ជាទីស្រេរសើរបស់មនុស្សតាំងពួកយ ដូចមាណពកន្លះនេះជាដើម ។ មាណពបានយកជីវិតរបស់ខ្លួនទៅរងគ្រោះជួសជីវិតសត្វជាច្រើន ដោយការធានារក្សាព្រះពោគព្រះអង្គម្ចាស់ក្សត្រដោយទុសថ ១ មុខ, មាណពស្គាល់គុណានុភាពរបស់ថ្នាំ ១ មុខនេះ អំពីពួកអ្នកដើរព្រៃដែលណែនាំឲ្យមានទុកសម្រាប់ការពារខ្លួន, ទុសថនោះគឺជាប្រភេទ ១ បែបកើតមានក្នុងព្រៃ តែមានអ្នកណាខ្លះស្គាល់, ប្រភេទ ១ មុខនេះឯងជាថ្នាំកែរោគបានច្រើនបែប; អ្នកដែលនៅក្នុងព្រៃច្រើនច្រើ

ប្រជាលនេះសម្រាប់តែពេតប្រយ៉ាង ។ កាលបើមាណពនាំប្រជាល ១ មុខនេះមកហើយ ក៏យកមកស្ងោរជាមួយនឹងសាច់ឆ្មាឈើ រួចបញ្ចូនទៅថ្វាយព្រះអង្គម្ចាស់ក្សត្រី, ចាប់អំពីថ្ងៃនោះមក ថ្នាំរបស់មាណពក៏ឲ្យផល គឺព្រះអង្គម្ចាស់ក្សត្រីសោយទុសថនេះទៅបានកំចាត់ពេតដែលប្រឈួននោះ, ចាប់អំពីថ្ងៃដំបូងដែលបានសោយថ្នាំនេះ ដូចបានសោយអាហារទិព្វដ៏វិសេស ធ្វើឲ្យមានព្រះកាយពលចម្រើនសោយព្រះក្រយោ-ស្មោយ, តែមតែ ៦ ក្រឹតទ្វង់ផុតទៅ ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះអាការប្រក្រតីដូចដើមវិញ ។

ពួកអ្នកស្រុកដែលកើតពេតរបំក្បា បានទទួលថ្នាំរបស់មាណព ១ មុខនេះគ្រប់គ្នា, ថ្នាំពិសេសអស្ចារ្យនេះ ដែលអ្នកស្រុកមានទុក្ខវេទនាបានបរិភោគទៅហើយ អាចធ្វើឲ្យវិនាសចាកពេតក្នុងរយៈដំរាំស, មិនយូរប៉ុន្មាន អ្នកស្រុកស្ទើរតែក្លេចនូវពេតដ៏អាក្រក់ដែលគួរស្រឡាំងខ្លាចនោះ. ការរៀបរយោគពេលកាលដែលធ្លាប់មានក្នុងស្រុកពួកទៅ ក៏បានច្បាស់ចេញអស់ មានតែសម្លេងអ៊ូអរដែលធ្លាប់មានមកក្នុងនគរវេសាលីដូចពីដើមឡើងវិញ ។

អ្នកស្រុកនាំគ្នាសរសើរកិត្តិគុណរបស់មាណព ស្ទើរតែពុំដាច់ពីមាត់ហើយទុកមាណពនោះដូចជាទេវតា ១ អង្គ ។ ការសរសើរបែបនេះមិនមែនតែពួកអ្នកស្រុកប៉ុណ្ណោះទេ ព្រះពុទ្ធទីព្រះពុទ្ធជាតាក៏ទ្រង់សរសើរដូច្នោះដែរ, សេចក្តីទុក្ខរបស់ព្រះពុទ្ធជាម្ចាស់ក្នុងគ្រានេះ ក៏ផុតរលត់អស់ពីព្រះទ័យ ។

ទឹងថ្ងៃឥមាណពទឹងអមាត្យបាលិតវិញ, ព្រះពាជាបានចាត់ឲ្យកន្ទែងឲ្យជនពាំង ២ នាក់នេះទៅស្នាក់ក្នុងបរិវេណព្រះបរមពាជវាំង ឲ្យមានគាហានចាំយាមល្បាតយ៉ាងម៉ឺងម៉ាត់ ដើម្បីការពារមិនឲ្យលបរត់ចេញបាន, តែលុះដល់មាណពរក្សាព្រះមគ្គម្ចាស់ក្សត្រីទឹងពេនរម៉ក្សាដែលកើតមានដល់អ្នកស្រុកឲ្យស្លប់រម្ងាប់ហើយ ព្រះពាជាទើបបន្ធូរការតឹងតែងឲ្យមាណពទឹងអមាត្យមានសេរីភាពឡើងវិញ ។

ក្នុងវេលាល្ងាចនៃថ្ងៃទី ៦ មាណពទឹងអមាត្យអង្គុយសន្ទនាគ្នានៅត្រើមម្ចប់ចាមចុរី ជិតទីស្នាក់របស់ខ្លួន ។ មាណពអង្គុយស្តាប់ឮត្រែកអរចំពោះសេចក្តីសម្រេចនូវវត្ថុបំណងដ៏ធំរបស់ខ្លួនផង ទើបពោលតបនូវសេចក្តីមួយវគ្គចំពោះអមាត្យថា ៖

" ចាត់ជាវាសនាល្អរបស់ខ្ញុំ ដែលខ្ញុំបានមកជួបនឹងលោកជាអមាត្យធំ របស់ព្រះបាទធម្មបតី ជាព្រះពាជានៃនគរពាណស៊ី ដោយមិនបានទឹកយល់សប្តិជាមុនសោះ " ។

អមាត្យបាលិតបានស្តាប់មាណពពោលលើកតំកើងដូច្នោះ ក៏ពោលតែជាន់សាថា ៖

" កុំថាដូច្នោះឡើយ មាណព ! ការណ៍នេះចាត់ជាវាសនាល្អរបស់ខ្ញុំដូចគ្នានឹងលោកដែរ ខ្ញុំបានចេះដឹងឡើងដោយសារលោក ចាត់ថាលោកជាអ្នកមានគុណដល់ខ្ញុំច្រើនប្រការ " ។ ពាក្យរបស់អមាត្យបាលិតនេះនិយាយផ្សំទៅតាមសេចក្តីដឹងខ្លួន ទឹងសេចក្តីពេញចិត្តយ៉ាង

ក្រែលែងចំពោះមាណព អមាត្យទើបកើតមានគំនិតចង់ដឹកអនុជ្ញាមាណព ឲ្យទៅគាល់ព្រះបាទធម្មបតី ក៏ពោលថា:

" មាណព ខ្ញុំជាមនុស្សចាស់ជាងលោកក៏ពិត តែខ្ញុំនាប់ផ្ងើគេដាយ ។ ចំពោះពាក្យដែលគេនិយាយទូវសេចក្តីមិនមានខ្វល់សារ គាល់តែដីវិតខ្ញុំកន្លងមកដល់ឥឡូវប៉ុណ្ណោះ បើប្រសិនជាខ្ញុំមិនបានជួបនឹងលោកទេ ខ្ញុំក៏មិនអាចដឹងបានថា ខ្ញុំនឹងត្រូវធ្វើដំណើរដីវិតបែបណាកន្លងឥឡូវខាងមុខតទៅឡើយ " ។

សំដីរបស់អមាត្យជាលិត បរិបូណ៌ទៅដោយសេចក្តីពិតគ្រប់ប្រការ ព្រោះចាប់តាំងតាមកស្មាក់ទៅជាមួយនឹងមាណព បានសាកសួរសេចក្តីផ្សេង ។ ដែលជាប់ទាក់ទងនឹងព្រះសម្មាសម្ពុទ្ធជាម្ចាស់ ហើយមាណពក៏អាចតទល់ឲ្យចូលចិត្តបាន ។ មាណពកាលដឹងនូវគោលសេចក្តីឯណាដែលជ្រាលជ្រៅនឹងពាក់ព័ន្ធ អំពីកិក្ខុសង្ឃតាំងឡាយ មាណពក៏យកសេចក្តីនោះមកជ្រាប់អមាត្យ ដើម្បីឲ្យអមាត្យបានយល់ច្បាស់លាស់ឡើង, ចំណែកអមាត្យជាលិតមានជំនឿរឿងព័ត៌មានព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះខ្លះដែរ ដោយចំពោះតែតិចដែលព្រះសម្មាសម្ពុទ្ធទ្រង់រំលត់ខ្លួចូលកាន់បរិនិព្វាន ។

អមាត្យជាលិតកាលសន្ទនាមកល្មមសមគួរហើយ ក៏មានការចង់ដឹងដល់ត្រកូលដ៏ពិតជាកជបស់មាណព ព្រោះបានសង្កេតឃើញថាជាអ្នកមានសេចក្តីចេះដឹងនឹងមានសមត្ថភាពគ្រប់គ្រាន់ តាំងសរីរៈកាយ

កំសួរដល់ខ្លួវភាពជាអ្នកល្អ មានទម្រង់នៃការសិក្សាមកយ៉ាងខ្ពង់ខ្ពស់ ទើបសួរខ្លួវរឿងក៏វែនេះឡើងថា:

" អើមាណព ! ខ្ញុំនៅស្នាក់រួមជាមួយនឹងលោកនាំឲ្យខ្ញុំមានសេចក្តីស្និទ្ធស្នាល ព្រោះលោកមានអធ្យាស្រ័យល្អមកកាន់ខ្ញុំ ឥឡូវនេះ ខ្ញុំចង់ដឹងម្លូវតែក្នែងស្រុកទេសដ៏ពិតប្រាកដរបស់លោក ព្រោះខ្ញុំមិនទាន់បានដឹងថាលោកមានតួជតង្ហូវខ្សែស្បែយបែបណា ទឹងស្រុកកំណើតនៅទីណាឡើយ បើលោកមិនមានបំណងទឹងចិត្តចាំងទេ សូមមេត្តាប្រាប់ខ្ញុំឲ្យបានដឹងផង " ។

កាលអមាត្យបានលិតសួរដល់រឿងក៏វែរបស់មាណព។ ក៏ប្រែទឹកមុខឆ្លើយតបទាំងទឹកមុខស្លូតថា :

" ខ្ញុំមិនរង្កៀសទេ ចំពោះការរៀបរាប់ប្រាប់ខ្លួវសេចក្តីប្រព្រឹត្តទៅនៃខ្លួនខ្ញុំឲ្យលោកបានជ្រាប តែបើលោកជ្រាបហើយក៏មិនមានប្រយោជន៍អ្វីដល់លោក, នែលោក ! ដីវិតខ្ញុំសុទ្ធតែអំពីបងទឹងប្អូនខ្ញុំ ពុកជាមនុស្សអកតូពន់ពេក, ត្រកូលរបស់ខ្ញុំក៏មិនមែនទំលែកប៉ុន្មានទេ បិតារបស់ខ្ញុំជាសេដ្ឋីមហាសាលឈ្មោះជោតិក: មាតាឈ្មោះចន្ទាវតី, ដំបូងឡើយបិតារបស់ខ្ញុំជាជាងមាសម្នាក់ ដែលមានស្នាដៃដ៏ជំនាញក្នុងនគរពាជគ្រឹះ លុះកាលលោកជរាហើយ ក៏បានបញ្ជូនមុខរបរនេះចេញទាំងមិនបានប្រកបការលក់ដូរអ្វីដទៃទៀតទេ ព្រោះទ្រព្យសម្បត្តិដែលមានមកពីមុន ទឹងយកមកបរិភោគប្រើប្រាស់ថាយវាយដរបដល់អស់ជីវិតក៏មិនអស់ផង ។ ចុងឆ្នាំដែលកន្លងមកនេះ ព្រះពាជាមានព្រះពាជបំណង

ឲ្យបិតាខ្ញុំធ្វើម្តេចវិញ ព្រោះខ្ញុំធ្លាប់ឮថា បិតាខ្ញុំមានស្នាដៃជាជាងមាសដ៏ជំនាញ ដោយហេតុនេះបិតាខ្ញុំមិនអាចនឹងដាស់ព្រះពាជបំណងបានឡើយ, កាលបើព្រះពាជាប្រគល់មាសនឹងពេជ្រឲ្យបិតាខ្ញុំ ខ្ញុំក៏មិនបាននឹកដល់ដើមហេតុ ដែលគ្រប់នាំឲ្យមានរឿងមានសេចក្តីទុក្ខធំដល់រូបខ្ញុំទេ; សេចក្តីទុក្ខធំដែលកើតឡើងក្នុងគ្រានោះ នៅជាប់តាមខ្ញុំដរាបដល់សព្វថ្ងៃនេះ" និយាយចប់ មាណពក៏ដកដង្ហើមធំ មានទឹកមុខប្រែប្រួលប្រកតី ។

អមាត្យចាស់តស្តាប់ហើយទើបតបថា:

"ចុះមានហេតុការណ៍យ៉ាងណាកើតឡើងដល់លោក? ខ្ញុំមិនចង់ឮទេថាក័យកើតឡើងដល់បិតាមាតារបស់លោក, ហើយខ្ញុំស្មានថាមិនមែនដូច្នោះទេដឹង!" ។

"មែនលោក! ខ្ញុំមិនកុហកលោកទេ មនុស្សក្នុងស្រុកខ្ញុំ មិនមានឧបាយណាចង្អៀតចង្អល់ចិត្តក្នុងរឿងនេះស្មើនឹងខ្ញុំឡើយ, ព្រះពាជានោះ កាលទ្រង់ប្រគល់ដុំមាសឲ្យបិតាខ្ញុំ បិតាខ្ញុំក៏បានធ្វើឡើងដោយឆ្លៀតផ្តង់ក្នុងវេលាតែមួយ ២ ថ្ងៃប៉ុណ្ណោះហើយស្រេច ទើបប្រើមនុស្សឲ្យទៅណាត់ពេលវេលានឹងអមាត្យធំ ឲ្យមកទទួលយកម្ចាស់ទៅថ្វាយព្រះពាជា, អមាត្យនោះជាមនុស្សស្មោះត្រង់ ជាទីពុកព្រះទ័យរបស់ព្រះពាជាជាងនាម៉ឺនតាំងច្រើយ, សូម្បីលោកជាមនុស្សស្និទ្ធស្នាលរបស់ព្រះពាជាមកប៉ុណ្ណាក៏ដោយ ទ្រព្យរបស់លោកក៏មានតែមួយរិះគោតគ្រប់គ្រាន់ប៉ុណ្ណោះ មិនដល់ទៅមានស្តុកស្តម្ភដូចជាសេដ្ឋីឡើយ ។ ការទទួលបំរើព្រះពាជាក្នុងការគ្រប់គ្រងតំណាងព្រះនេត្រព្រះកាណ៌ ដែលជាប់ទាក់ទងនឹងប្រជា

ក្រសួង ប្រព្រឹត្តទៅយ៉ាងស្មោះត្រង់ ដើម្បីជាទីពាក់អាន្តរបស់ប្រជាជនខ្មែរទាំងនេះ, គេនាំគ្នាសន្មតឈ្មោះសម្រាប់ហៅ "នន្ទិអមាត្យ" ។

លោកនន្ទិ កាលបានដឹងថាបិតាខ្ញុំធ្លុះក្តីម្តងរួចស្រេចហើយ ក៏ប្រែចិត្តមកខ្លួល តែជួនជាមិនសូវសប្បាយខ្លួនក៏ឲ្យបុត្តប្រុសមកខ្លួលជំនួស បិតាខ្ញុំបានប្រគល់ម្តងឲ្យបុត្តប្រុសរបស់លោកនន្ទិហើយ លុះតមកខ្មែតចំនួនពីរថ្ងៃ ហេតុអាក្រក់ក៏បានកើតឡើង, លោកនន្ទិមករកបិតាខ្ញុំហើយសួរបិតាខ្ញុំថា បានប្រគល់ទាំងពេជ្រទាំងម្កុដទៅផងឬទេ? ខណៈនោះបិតាខ្ញុំកំពុងឈរខ្លួលលោកនន្ទិ មិនទាន់នាំលោកនន្ទិចូលមកក្នុងបន្ទប់ខ្លួលក្បែរផងទេ ក៏ឮកន្ទួលម្នាក់ស្រែក ដោយលោកមិនឮកស្មានថា លោកនន្ទិនឹងមកសួរដូច្នេះឡើយ ស្ទើរតែនឹងក្រោធខឹងចំពោះលោកនន្ទិដែលសំដែងអាការមិនល្អមករកទៅហើយ តែបិតាខ្ញុំប្រញាប់ប្រញាល់នាំលោកនន្ទិចូលមកក្នុងបន្ទប់ខ្លួលក្បែរ ហើយឈប់សម្រាកមួយស្របក់ ដើម្បីបិតាខ្ញុំនាំយកសំបុត្រដែលលោកនន្ទិ ប្រគល់ជាឯកច្ឆន្ទឲ្យបុត្តប្រុសមកខ្លួលយកម្កុដពេជ្រទៅ ព្រមទាំងសំបុត្ររបស់លោកសរសេរទុកជាសំគាងយ៉ាងត្រឹមត្រូវថា ម្កុដនោះប្រាប់ពេជ្រមានខ្នាតនឹងមួយប៉ុន្មាន? ម្កុដមានមួយប៉ុន្មាន? ដែលបុត្តរបស់លោកនន្ទិ បានចុះហត្ថលេខាទុកត្រឹមត្រូវហើយ ។

(មានត)

កណ្ឌទី ២៤

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធំងបេះខួរបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

គួនអ៊ូក៏សួរហោហួថា ហេតុម្តេចបានជាអ្នកមកនៅទីនេះ? ។ ហោហួឆ្លើយថា ពីដើមខ្ញុំក៏បានធ្វើជាឥស្សរជនក្នុងស្រុកក្រែង លុះខ្ញុំជកហើយក៏សូមលាចេញពីពជការ មកធ្វើស្រែចម្ការរកទទួលបាននៅតំបន់ស្រុកនេះ, កូនខ្ញុំឈ្មោះហោប៉ាន់ជាគាហានអង្គរសេកហៅហ្វាយស្រុកអៀងយ៉ុង ជាផ្លូវដែលអ្នកទីឆ្ងាយៗស្រុកគីជីវនេះ ខ្ញុំនឹងផ្ញើសំបុត្រ ១ ឲ្យអ្នកយកទៅឲ្យហោប៉ាន់ផង ។ គួនអ៊ូក៏ទទួលត្រាម. លុះពេលត្រីកហោហួរៀបលៀងគួនអ៊ូនឹងបងថ្លៃគួនអ៊ូទាំង ២ ឲ្យបរិភោគហើយក៏ប្រគល់សំបុត្រឲ្យគួនអ៊ូ ។ ក៏គំនាប់លាហោហួចេញទៅផ្ទះទិសឯដើង ។

ឯខុងស៊ីវជានាយឃុំគាហាន ៩០០ នៅរក្សាគយ តាំងឡើងគួនបានចាត់ឲ្យគាហានដើរល្បាត ។ បំរើសេះក៏នាំសេចក្តីទៅប្តឹងខុងស៊ីវថា ឥឡូវ

គួនអ៊ូនាំគ្រប់គ្រួឡៅពីមកដាំតន៏ដល់គយហើយ ។ ខុងស៊ីវដឹងដូច្នោះ
ក៏នាំគាហានចេញទៅទួលគួនអ៊ូ។ កំពុះពីលើសេះគំនាប់នាយគយ ។
ខុងស៊ីវសួរថា អ្នកមកនេះទឹងទៅណា ? គួនអ៊ូជ្រាបថា ខ្ញុំមកនេះបានលា
មហាឧបរាជទឹងទៅរកឡៅពីឯស្រុកតីជីវ ។ ខុងស៊ីវតបថា អ្នួនសៀវ
ចៅហ្វាយស្រុកតីជីវនោះ ជាសត្រូវទឹងមហាឧបរាជ; ដែលអ្នកទឹងទៅ
ស្រុកតីជីវនោះ បើមានសំបុត្រមហាឧបរាជបើកគយឲ្យមកយើង យើង
ទឹងបើកឲ្យទៅបាន ។ គួនអ៊ូឆ្លើយថា កាលខ្ញុំមកនោះជាការប្រញាប់គ្មាន
សំបុត្រគយមកទេ ។ ខុងស៊ីវថា បើគ្មានសំបុត្របើកគយទេ សូមលោក
បង្អង់នៅទីនេះសិន ចាំខ្ញុំទឹងឲ្យចំរើចូលទៅថ្វាយមហាឧបរាជ បើមាន
សំបុត្រជ្រាប់មកឲ្យបើក សឹមខ្ញុំបើកឲ្យទៅ ។ គួនអ៊ូថា ខ្ញុំមានការ
ប្រញាប់ បើអ្នកឲ្យខ្ញុំឈប់បង្អង់ នោះទឹងមិនយូរការទៅឬ? ខុងស៊ីវថា
ច្បាប់សម្រាប់គយដូច្នេះ ខ្ញុំទឹងបើកឲ្យទៅមិនបានទេ ។ គួនអ៊ូថា ដែល
អ្នកនិយាយដូច្នេះទឹងឃាត់ខ្ញុំជាក្បាកដឬ? ។ ខុងស៊ីវថា បើអ្នកមានការ
ទៅប្រញាប់ ត្រូវទុកគ្រប់គ្រួឲ្យនៅជាបញ្ចាំ ខ្លួនអ្នកទឹងទៅក៏ទៅចុះ ។

គួនអ៊ូខឹងណាស់ កន្ត្រាក់ជាវលើកឡើងទឹងកាប់ខុងស៊ីវ ហើយថា
បើមិនឲ្យយើងទៅ យើងទឹងចំណាយទៅឥឡូវនេះ ។ ខុងស៊ីវគេចខាន
ក៏នាំគាហានរត់ចូលទៅក្នុងគយហើយលើកគ្នាចេញមក សុទ្ធតែពាក់
ក្រឹសកាន់គ្រឿងអាវុធគ្រប់ដៃ ខុងស៊ីវស្រែកឲ្យគួនអ៊ូថា ខ្លួនខ្ញាំងតូចក
ទឹងអាចហានកាត់ចំណាយគយចេញទៅបាន កំចូរទៅលមើលចុះ ។
គួនអ៊ូ ក៏តតែខឹងឲ្យគាហានបវរថបងថ្លៃថយចៀសទៅម្ខាង ហើយ

គួនអ៊ូកំបរសេះកំជាវិបូលតយុទ្ធនឹងខុងស៊ីវបាន ១ ស្រែបក់ គួនអ៊ូយក ជាវគាប់ខុងស៊ីវធ្លាក់ពីលើសេះស្លាប់ ពាហានទាំងពួងឃើញខុងស៊ីវស្លាប់ ដូច្នោះ ក៏ភ័យតក់ស្លុតតក់ខ្លាតខ្លាយចេញទៅ ។

គួនអ៊ូស្រែកប្រកាសប្រាប់ពាហានទាំងពួងថា អ្នកទាំងអស់គ្នា កុំភ័យកិតបារម្ភខ្លាចអ្វីឡើយ យើងមិនធ្វើអន្តរាយដល់អ្នកទាំងឡាយទេ ដែលយើងសម្លាប់ខុងស៊ីវនោះ ព្រោះខុងស៊ីវឃាត់ទាំងយើង ហើយប្រមាថមើលងាយយើងផង អ្នកទាំងឡាយចូរនាំយកសេចក្តីទាំងនេះ ទៅប្តឹងមហាឧបរាជ ដោយពិតត្រង់ផងចុះ ។ ពាហានទាំងនោះបានឮ ហើយក៏នាំគ្នាចូលមកគំនាប់គួនអ៊ូ ។

ឯបំរើសេះបានឃើញហេតុដូច្នោះ ក៏ស្រូតត្រួតនាំរឿងនោះទៅប្តឹងហាន់ហុកលៅហ្គាយស្រែកឡូកអឿង ។ ហាន់ហុកបានដឹងសេចក្តីក៏ប្រឹក្សាទឹងពាហានទាំងពួងថា គួនអ៊ូគ្មានសំបុត្របើកគយពីមហាឧបរាជឲ្យមកសោះ លុះខុងស៊ីវឃាត់ឃាំង គួនអ៊ូក៏សម្លាប់ចេញហើយ បើដូច្នេះ អ្នកទាំងអស់គ្នាទឹងគិតប្រការម្តេច ? បេងថាន់ធ្វើយថា ដែលគួនអ៊ូមកនេះ មិនមានសំបុត្របើកផ្លូវគយ ខ្ញុំយល់ឃើញថា ប្តឹកជជារត់មកពីមហាឧបរាជ បើយើងទឹងបើកលែងឲ្យទៅ ទោសក៏ទឹងមានដល់យើង ។

ហាន់ហុកធ្វើយថា គួនអ៊ូនេះមានថ្លៃដៃខ្លាំងពូកែណាស់ ជាន់លៀងប៊ុនធីវដែលជាសេនាឯកអ៊ូនសៀវល្បីល្បាញជាអ្នកខ្លាំងពូកែ គួនអ៊ូក៏សម្លាប់ចេញបាន បើយើងទឹងតប្បាងចាប់យកខ្លួនក្នុងគ្រានេះ មុខជាខ្លាំងគួនអ៊ូមិនបានទេ បើដូច្នេះត្រូវតែគិតកល១បាយ ទើបចាប់

ខ្លួនគួនម្ចាស់ ។ បេន់ថាន់ឆ្លើយថា លោកគិតនេះត្រូវណាស់ ខ្ញុំនឹងសុំ
យកអាសាលើកតាហានចេញទៅច្បាំងនឹងគួនអ្ងិ ហើយធ្វើជាថយរត់ ឲ្យ
លោកនាំយកតាហានទៅចង្កឹះ បើកាលណាឃើញគួនអ្ងិដេញខ្ញុំមក
ឲ្យលោកយិតធ្នូបាញ់ឲ្យត្រូវ បើគួនអ្ងិធ្លាក់ពីលើសេះឲ្យលោកស្ទុះទៅ
ចាប់យកខ្លួនបញ្ជូនទៅស្រុកក្រុង សេចក្តីគាប់ប្រសើរក៏គង់នឹងមានដល់
លោក ។ ហាន់ហុកឃើញត្រូវផងក៏កេណ្ឌតាហានត្រៀមចំបុងខ្មុក ។
ខ្មួលចំរើសេះមកជូនហាន់ហុកថា ឥឡូវគួនអ្ងិលើកមកដល់ជិតស្រុក
ឡុកអៀងហើយ ។ ហាន់ហុកក៏ពាក់គ្រឿងសាន្តធ្វើឆេះនាំតាហាន
១ ពាន់លើកចេញទៅដល់ភ្នំវាស្រែក ខ្មួលត្រឡែកឃើញគួនអ្ងិ ហាន់
ហុកក៏លើកតាហាន ៥០០ អែបបង្កឹះប្រៃបភ្នំវា ។ បេន់ថាន់ក៏បរសេះនាំ
តាហាន ៥០០ ចេញទៅធ្វើជាមិនដឹងឆឹង ហើយសួរគួនអ្ងិថា អ្នកឯងឈ្មោះ
អ្វី? មកពីណាទៅណា? គួនអ្ងិឆ្លើយថា យើងឈ្មោះគួនអ្ងិជានាហ្ន
ទីហាន់ស៊ីវតេងហោ ដែលមកនេះនឹងសុំឆ្លងស្រុកឡុកអៀង ទៅផ្ទះទិស
ឯជើង ។ បេន់ថាន់ឆ្លើយថា អ្នកជានាហ្នចេញមកពីស្រុកក្រុង បើ
មានធុរៈនឹងចេញទៅស្រុកឯជើងនោះ គួរតែឲ្យមានសំបុត្រពិនិត្យបើកឲ្យ
ពីមហៈបាកជទើបទៅបាន ។ គួនអ្ងិថា យើងមកនេះជាការហ៊ាន
ប្រញាប់ប្រញាល់ពេកណាស់ មិនបានសុំសំបុត្របុគ្គហ្នាយអ្វីទេ ។ បេន
ថាន់ថា ទីស្រុកឡុកអៀងជាដើមផ្លូវនឹងទៅស្រុកខាងទិសឯជើង មហា.
ៈបាកជប្រើហាន់ហុកមកឈរក្បាស្រុកនេះ បើខ្លួនអ្នកជានាហ្នមានការ
ធុរៈចេញទៅ ត្រូវតែមានសំបុត្របើកគយ បើគ្មានហើយយើងយល់

ឃើញថា អ្នកមកនេះដោយវេះតែជាប្រាកដ ។ គួនអ៊ីឮដូច្នោះក៏ខឹងណាស់ថា ខ្ញុំស៊ីវាយតយាំងឡើងគួនឃាត់ទាំងយើងដូច្នេះ យើងក៏សម្លាប់ចេញហើយ ហេតុម្តេចក៏ខ្លួនចង់មកឃាត់ទាំងយើង? ខ្លួនមិនស្រឡាញ់ជីវិតទេឬ? បើងថាន់ឮដូច្នោះក៏ខឹងណាស់ បរសេះកាំជាវចូលតយុទ្ធនឹងគួនអ៊ី ។ ក៏ឲ្យគាហានញាក់រវៃចៀសចេញទៅ ហើយក៏បរសេះចូលប្រយុទ្ធគ្នានឹងបើងថាន់ជាន ៣ ក្មេង បើងថាន់ធ្វើជាចរយត់ទៅក្រោយ គួនអ៊ីក៏ដេញបណ្តាយ ដោយកំភ្លាំងដើងសេះសឹកថាលឿនហ៊ាសជិតដល់ទ្វារស្រុក គួនអ៊ីយកជាវគាប់បើងថាន់ត្រូវជាប់ពាក់កណ្តាលខ្លួន ហើយញាក់សេះវេះត្រឡប់មកវិញ ។ ហាន់ហុកដែលជាពួកបង្កប់ប្រុបមាត់ទ្វារ ក៏លើកធ្នូឡើងបាញ់តម្រង់ដោយកំភ្លាំងដៃព្រួញត្រូវជាប់ទឹងស្មាគួនអ៊ីខាងឆ្វេង គួនអ៊ីក៏យណាស់យកដៃកន្ត្រាក់ដកព្រួញចោលទៅ ឈាមក៏ហូរជោកពេញទាំងខ្លួន ឈឺពេកពិសាជាខ្លាំងណាស់ ក្រឡេកមើលទៅឃើញហាន់ហុកនៅលើខ្នងសេះតែបប្រុបមាត់ទ្វារ គួនអ៊ីក៏មិនបានគោតញញើតឬគិតឈឺក្តងខ្លួន ក៏បំផាយសេះស្ទុះទៅដល់ទឹមទឹងហាន់ហុក យកជាវគាប់ជាប់ខ្លួនហាន់ហុកធ្លាក់ពីលើសេះស្លាប់ ហើយក៏ដេញកាប់គាហានហាន់ហុកស្លាប់ពីការជាច្រើន រួចគួនអ៊ីក៏បំផាយសេះត្រឡប់ទៅតាមបងថ្លៃ ហើយមិនហ៊ានបង្អង់ឈប់កងស្រុកឡុកអៀងព្រោះមិនឧកចិត្ត ទើបយកព្រៃមកពុំព័ទ្ធមុខរបួសហើយក៏នាំបងថ្លៃទាំង ២ បរវេរស្រុតចេញទៅតាមផ្លូវគយតីស៊ុយគួន ។

ប៉ុន្តែសេះក៏នាំយកពត៌មានដែលគួនអ៊ីសម្លាប់ហាន់ហុកស្រុក ឧត្តង

នាយគយគ្រប់អន្ទើ ទៅស្នើប្តីឆ្លៀតហ៊ីនាយគយតស៊ីយគួនថា ឥឡូវ
គួនអ៊ីមកជិតដល់ទីនេះហើយ ។ ពៀនហ៊ីនោះចំណាន់ស្មាត់ខាងចោល
កូនឃ្មុប លុះដឹងសេចក្តីហើយក៏គ្រិះរិះគិតថា ធ្វើម្តេចយើងនឹងចាប់ខ្លួន
គួនអ៊ីបាន” លុះគិតទៅគិតមកក៏ទឹកឃើញថា វត្តចិនកុកជាដែលនៅមុខ
គយនោះជាទីចំណាប់ស្រួលណាស់ យើងនឹងរៀបចំឲ្យពាហានទៅពួន
បង្កប់ទុកប្រហែល ១០០ ថ្ងៃ ហើយបបួលគួនអ៊ីចូលទៅបរិភោគអាហារ
រួចនឹងចោលពែងស្រាជាសំគាល់ឲ្យពាហានទាំងពួងសុះចូលព្រមគ្នា ចាប់
ខ្លួនគួនអ៊ីមុខជានឹងបានដោយស្រួល ។ លុះពេលព្រឹកពៀនហ៊ីក៏នាំ
ពាហានទៅពួនបង្កប់ទុកក្នុងវត្ត ហើយបង្គាប់ទុកតាមគំនិតដែលគិតនោះ
រួចពៀនហ៊ីក៏ចេញទៅទួលគួនអ៊ី ។ ឃើញពៀនហ៊ីនាយគយនឹងពាហាន
ទាំងពួង គ្មានអារក្ខកាន់នៅដៃចេញទៅទួលដោយល្អក់អស់សេចក្តី
សង្ស័យ ទើបចុះពីខ្នងសេះគំនាប់ពៀនហ៊ី ។ ក៏ដំកបថា ខ្ញុំបាទជានាយ
គយទៅទីនេះ បណ្តាមនុស្សទាំងពួងក៏ព្រមគ្នាឈ្មោះថាលោកខ្ញុំឯ
ភ្លែកណាស់ មានទាំងសេចក្តីសត្យកតញ្ញូជាទីបំផុត ឥឡូវខ្ញុំបាទ
ឮថា លោកនឹងទៅរកឡៅពីជាបង ខ្ញុំបាទក៏មានអំណរផង ទើបនាំ
បណ្តាក្រស្តូពួកគយមកចាំទទួលលោក ។

គួនអ៊ីបានស្តាប់ ក៏នាំយកគ្រឿងក៉ាវដែលខុងស៊ូវ, បេងឆាន,
ហាន់ហុក, ឃោត់ទាំងខ្លួននោះឲ្យពៀនហ៊ីស្តាប់ត្រប់ប្រការ ។ ពៀនហ៊ី
ក៏ក្រែងនិយាយថា ដែលលោកសម្លាប់អ្នកទាំង ៣ នាក់នោះចេញ ក៏គួរ
ដល់ទោសហើយ តែខ្ញុំបាទបានចូលទៅដល់មហេឃរាជ ខ្ញុំបាទ

ខ្ញុំឯងសុំជួយថ្វាយបៀងស្មៅ តាមដំណើរជូនតាមសុភាព រៀលនេះសូមឲ្យលោកឡើងសេះទៅកាន់ទីហានរបស់ខ្ញុំចុះ ។ គួនអ៊ូក៏មានសេចក្តីត្រេកអរណាស់ ស្តុះឡើងសេះនាំគ្នាហានចរៀថតាមពៀនហ៊ីទៅដល់មុខវត្ត ។ ពៀនហ៊ីក៏អញ្ជើញគួនអ៊ូឲ្យចូលទៅក្នុងវត្តខ្ញុំនកុកដី, ឯវត្តនោះជាដំណែលរបស់ព្រះចៅបេងគេសង្ខ័ត់កសាងខុកពីបុរាណ ផ្ទាប់ស្តេចមកនមស្សការព្រះជារឿយ ។ លោកសង្ឃទាំងពួងឃើញគួនអ៊ូចូលទៅ ក៏រាយគាំងគងស្តារទទួលគំនាប់ ឯលោកចិនកៅចេងជាមេវត្តកំណើតនៅស្រុកជាមួយនឹងគួនអ៊ូជាប់ស្គាល់គ្នាមកពីដើម លុះឮដំណឹងថា ពៀនហ៊ីគិតនឹងធ្វើអន្តរាយគួនអ៊ូដូច្នេះ លោកចិនកៅចេងក៏ចេញទៅទទួល ជ្រាបថានឹងខ្សឹបជ្រាប់សេចក្តីឲ្យគួនអ៊ូដឹងខ្លួន ហើយលោកនោះក៏សាកសួរគួនអ៊ូថា អ្នកស្គាល់អាត្មាឬទេ? គួនអ៊ូថា ខ្ញុំចាំមិនបានទេ ។ លោកចិនកៅចេងថា អ្នកចេញមកពីស្រុកកំណើតប៉ុន្មានឆ្នាំហើយ? គួនអ៊ូថា ខ្ញុំចេញពីស្រុកមកបាន ២០ ឆ្នាំហើយ ។ លោកចិនកៅចេងថា កូមិអ្នកនឹងកូមិអាត្មាភាពនៅត្រង់មាត់ទន្លេត្រើយម្ខាងម្ខាក់ ។

ពៀនហ៊ីឃើញលោកគ្រូចិនកៅចេងនិយាយសាកសួរគួនអ៊ូថាជាពួកម៉ាកស្រុកទេសជាមួយគ្នាដូច្នេះ ពៀនហ៊ីខ្លាចបែកការដែលគិតខុកនោះនឹងខ្លួនខ្លាយឡើង ក៏ស្រែកគំហកឲ្យលោកគ្រូចិនកៅចេងថា យើងអញ្ជើញគួនអ៊ូនឹងបរិភោគអាហារកេងវត្តនេះ ហេតុម្តេចលោកមកនាំនិយាយឲ្យយូរការ។

(មានត)

រឿងព្រេងនិទាន

លោកសមិន មួត្យ៍នជម: តែង

លោក រ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(ត្រមក)

ធិទានដែរូបទេពធិម្មិតទី ២២

រូបទេពធិម្មិតទី ២២ បានក្រាបបង្គំទូលព្រះបាទគោជ:ថា បពិត្រ ព្រះបាទគោជ: សូមទ្រង់លះបង់នៃការធ្វើមុខតំណែងទៅលើបល័ង្កធិត្យ នេះ ព្រោះទ្រង់មិនអាចតាំងព្រះអង្គជាបុព្វការីបុគ្គល ដូចព្រះបាទ វិក្រមាទិត្យបានឡើយ ។ សូមទ្រង់ព្រះសណ្តាប់ តើដោយហេតុអ្វីបាន ជាព្រះបាទវិក្រមាទិត្យ ទ្រង់ព្រះនាមថាបុព្វការីបុគ្គល ដូចតទៅនេះ ៖

ព្រះបាទវិក្រមាទិត្យ កាលទ្រង់ព្រះជន្មាយុ ១៦ ឆ្នាំ ទ្រង់មាន មហិទ្ធិរិទ្ធិផ្តាញ់មហាក្សត្រិយ៍ជាច្រើននៅភូមិភាគសំខាន់ៗ ឲ្យនៅក្រោម បង្គាប់បញ្ជាព្រះអង្គ, ទ្រង់ជាពន្ធុនៃមហាក្សត្រិយ៍ទាំងអស់ ទ្រង់បាន តែងព្រះម្កុដជាមួយជាំត្យ៍ភ្លឺច្រាលរន្ធាល, ទ្រង់មានស្នាមតំនូសជាផ្កា ឈូកត្រង់ព្រះបាទាជាព្រះរូបលក្ខណ:, ទ្រង់សោយរាជសម្បត្តិ ជាស្តេច ចក្រពត្តាធិរាជ ។

ពេលមៅង៍ព្រះព្រហ្ម (គឺមៅង៍ជាបឋម), ទ្រង់តើនពីក្រឡា ព្រះបន្ទំដោយមានក្តៅសំពួសរពីពោះអស្ចារ្យ ខឹងសំឡេងផ្គរលាន់ សន្ធរសើរ ព្រះអង្គជាអនេកប្បការ ។ ក្រោយដែលទ្រង់សំបូងសន្លូន

ដល់គុណព្រះនាកយណ៍, ខ្ញុំព្រះតម្រិះដល់សមាធិចិត្ត ហៅថា
ចរណារវិន្ទ (Caranaravinda) រួចខ្ញុំប្រតិបត្តិតាមព្រះពាជករណីយ-
កិច្ចគ្រប់យ៉ាង ហើយថ្វាយបង្គំអាទិទេព, ខ្ញុំស្តេចយាងទៅកាន់
យោធស្ថាន ដើម្បីនឹងហាត់អាវុធគ្រប់បែប ។ តមកខ្ញុំព្រះពាជកុមារ,
ស្តេចយាងធ្វើព្រះពាជអំណាចយូរថ្ងៃក៏ទាំងគាន់សុវ័ណ (Suvarnas)
លំដាប់តមកទៀត ខ្ញុំស្តេចយាងចូលទៅកាន់ទីជំនុំគណៈរដ្ឋមន្ត្រី មាន
រដ្ឋមន្ត្រីជាព្រះពាជទីប្រឹក្សា រដ្ឋមន្ត្រីអ្នកប្រតិបត្តិតាមព្រះពាជនិយ្យោ នឹងពួក
បណ្ឌិតជាច្រើន ។ នៅទីនោះខ្ញុំសម្រេចរឿងការក្នុងព្រះពាជអាណា-
ចក្រ ទៅតាមច្បាប់ក្រមព្រហ្មទណ្ឌ (ច្បាប់ទណ្ឌនីតិ) នឹងច្បាប់
នយោបាយ (ពាជនីតិ) ។ ដល់ពេលថ្ងៃត្រង់, ក្រោយដែលបានប្រតិបត្តិ
ប្រតិបត្តិព្រះពាជករណីយកិច្ចតាមច្បាប់រួច, ខ្ញុំព្រះពាជាន្តរូវ
ព្រះពាជអំណាចដល់ពួកជនអាពាធ, ពួកជនទុគ៌ត ។ល។ គ្រប់យ៉ាង
ហើយគ្រាស់បង្គាប់ឲ្យលៀងភោជនាហារបួនបែប គឺ អាហារដែលទំពា,
អាហារដែលជញ្ជក់, អាហារដែលលិទ្ធ, អាហារដែលត្រែបព្រឹក
មានឧជារស ៦ យ៉ាង គឺ ស្ករ ឆ្ងាញ់ ជែប ខ្ញាំង ហើរ ជូរចំពោះ
ព្រះពាជវង្សានុវង្ស នឹងពាជមិត្តរបស់ព្រះអង្គ ។ លំដាប់តមក, ក្រោយ
ដែលខ្ញុំស្រោយព្រះស្រែសន្ធឹក (មួ) លាយដោយគ្រឿងក្រអូបផ្សេង។,
មានទឹកហាវ ក្តាំពូ ។ល។ រួចខ្ញុំទាត់ព្រះបាទនឹងគ្រឿងក្រអូប
មានក្រអេះបូងច័ន្ទន៍ជាដើម ខ្ញុំកូងមាល័យជាច្រើន, ខ្ញុំលា
ព្រះពាជវង្សានុវង្សទឹងពាជមិត្តរបស់ព្រះអង្គហើយ ផ្ទំមួយស្របក់ទៅលើ

ព្រះមញ្ជុះ (វគ្គ) ។ ក្រោយមក, ខ្ញុំព្រះសង្ឃនាខ្លួនពួកបក្ខពួកបក្សវែលចេះពោលពាក្យគឺសេក, សារិកា, ខ្ញុំក្រសាលសប្បាយព្រះពុទ្ធហ្វូងយើងនឹងស្រីស្នំក្រមការ ដែលមានរូបនោមល្អស្រស់ឆើតជាងគេ ។ ដល់ពេលរសៀល ខ្ញុំព្រះសង្ឃាប់ខ្លួរឿងភ័ស, រឿងបុកណ ។ ល ។ ខ្ញុំយាងទៅធ្វើព្រះពុទ្ធទស្សនាការនៅកងចំពុ ព្រះពុទ្ធទ្យ, ព្រះសំហារមៈ ដោយមានលោកអធិការដែលត្រួតត្រាមុខងារនីមួយ ។ អមព្រះអង្គផង ។ ដល់ពេលល្ងាច ខ្ញុំបានប្រតិបត្តិតាមពិធីវេទ ។ ក្រោយដែលខ្ញុំធ្វើពុទ្ធសន្ធិបាតនឹងពួកបណ្ឌិត, ប្រព្រឹត្តព្រះពុទ្ធករណីយកិច្ចតាមបទបញ្ញត្តិនៃសាស្ត្រ, ខ្ញុំស្តេចយាងទៅជួបនឹងពួកបុគ្គលដែលចូលចិត្តខាងល្បែងរបាំ ហើយខ្ញុំកំសាន្តខ្លួនពួកគាត់, ខ្ញុំព្រះសង្ឃាប់ខ្លួរបម្រើងន៍ងក្មេងតូចតូចនិ្ត, ខ្ញុំរួមមេចុងសំវាសនឹងស្ត្រីតាមគួរការ, រួចខ្ញុំផ្លូវហូតដល់បច្ចុសសម័យសុខកាយសប្បាយព្រះពុទ្ធហ្វូងយើង ។ នេះជាព្រះពុទ្ធករណីយកិច្ចដែលខ្ញុំបានព្រះពុទ្ធកំណត់ធ្វើពាល់ថ្ងៃ ។

មានមួយថ្ងៃ, នៅពេលជិតព្រលប់ ព្រះពុទ្ធាខ្ញុំរៀបនឹងយាងចូលទៅគាន់ក្រឡាព្រះបន្ទំ, ខ្ញុំមានព្រះពុទ្ធពិតាល់ (ថៃដន្យ) ក្នុងព្រះពុទ្ធហ្វូងយើងដែលជាសន្ទុស្សន៍នៃសេចក្តីលំបាកក្នុងប្រទេស ។ ដល់ពេលអរុណរះ ខ្ញុំក៏មានព្រះបន្ទូលទៅគាន់ពួកបណ្ឌិតអំពីហេតុខាងលើ ។ ពួកបណ្ឌិតបានក្រាបបង្គំទូលមហាពុទ្ធថា "បពិត្រព្រះសម្មុតិទេព, ខ្ញុំព្រះបង្គំគាំងឡាយយល់ថាព្រះពុទ្ធពិតាល់ ក្នុងព្រះ

ភជប្បាទ័យនោះ ជាហេតុឲ្យកើតសេចក្តីលំបាកក្នុងព្រះពុទ្ធសាសនាច្រើនរបស់ព្រះអង្គដោយពិត" ។ ព្រះមហាកាជ លុះទ្រង់ព្រះសណ្តាប់ខ្ញុំវាក្យពួកបណ្ឌិតទាំងនោះហើយទ្រង់ព្រះតម្រិះថា "គ្មានបុគ្គលណាដៀសវាងនូវមច្ចុរាជបានឡើយ ។ ភរិយា, បុត្រ, ធីតា, ទ្រព្យសម្បត្តិនឹងតែងតាំងឡាយ ដែលសង្ខារតាត់តែងឡើង តែងប្រកបដោយ អនិច្ចំ, ទុក្ខំ, អនត្តា មិនបានបឋមវេរកាលទេប្រៀបដូចពពុះទឹក; ដល់ពេលធ្វើមរណកាល គ្មានវត្ថុណាអាចទៅតាមបុគ្គលបានសោះឡើយ មានតែបទបញ្ញត្តិច្បាប់ដែលគេយកទៅប្រើនៅបរលោក ។ ព្រោះហេតុនេះក្រោយដែលទ្រង់បានពិចារណាយល់ឃើញថា: សង្ខារទាំងឡាយមានតម្លៃតិចតួចស្ទួចស្តើងណាស់ ទើបសម្រេចក្នុងព្រះពុទ្ធប្បាទ័យថា: បុគ្គលសប្បុរសត្រូវតែសន្សំនូវកុសល ហើយលះបង់ទ្រព្យសម្បត្តិទៅឲ្យអ្នកកើតលំបាក" ។

ព្រះបាទវិក្រមាទិត្យ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ទ្រង់គាស់បង្គាប់ឲ្យបើកទ្វារព្រះបន្ទំនៃប្រាសាទទាំងអស់ក្នុងព្រះបរមរាជវាំង ហើយទ្រង់បាត់ឲ្យប្រកាសផ្សាយថា "បើអ្នកណាមានបំណងចង់បានគោគ.ទ្រព្យអ្វី ឲ្យចូលមកខាងនេះ យកតាមចិត្តប្រាថ្នាចុះ" ។ ក្នុងពេលនោះក្រោយដែលទ្រង់បានព្រះរាជប្រកាសរួចហើយ, ពួកប្រជារាស្ត្រអ្នកកើតលំបាកក៏នាំគ្នាចូលទៅក្នុងព្រះបរមរាជវាំង ទទួលយកនូវគោគទ្រព្យតាមបំណងរៀងខ្លួន ។

រួចទេពនិម្មិតទី ៦២ ទូលបង្គំមកទៀតថា "បពិត្រមហាកាជកោជ: !

នេះហើយជាមហាសប្បុរសនៃព្រះចុន្ទវិក្រមាទិត្យ ព្រោះហេតុនេះ បានជាព្រះអង្គទ្រង់គង់នៅលើបល្ល័ង្កទិព្យនេះបាន ។ សម័យបច្ចុប្បន្ននេះ គ្មានមហាពាជអង្គណាមានព្រះពាជសទ្ធា ដូចព្រះចុន្ទវិក្រមាទិត្យសោះឡើយ ។

ក្នុងពេលនេះ, ព្រះចុន្ទគោជ:ក៏មិនបានធ្វើមុទ្ធាភិសេក ទ្រង់យាងថយចេញពីបល្ល័ង្កទិព្យនោះទៅ ។

*
* *

ទិទានដែរឬទេពធិម្មិតទី ២៣

មានកាលមួយថ្ងៃ ព្រះចុន្ទគោជ: ទ្រង់បានស្តេចចូលទៅដិតបល្ល័ង្កទិព្យនោះ ដើម្បីនឹងធ្វើមុទ្ធាភិសេក ។ រូបទេពនិម្មិត បានឃើញព្រះចុន្ទគោជ:បញ្ចេញព្រះពាជកាយវិការដូច្នោះ ក៏បានទូលថា "បពិត្រព្រះចុន្ទគោជ: អ្នកណាមួយមានចិត្តអង់អាច, អំណត់, មហាសប្បុរស ដូចព្រះចុន្ទវិក្រមាទិត្យ អ្នកនោះអាចអង្គុយលើបល្ល័ង្កទិព្យនេះបាន ។ ព្រះចុន្ទគោជ:ទ្រង់ត្រាស់សួររូបទេពនិម្មិតនោះថា សភាពក្លាហានអង់អាច ទឹងព្រះពាជគុណសម្បត្តិនៃព្រះចុន្ទវិក្រមាទិត្យនោះហ៊ាន់ណា ?

រូបទេពនិម្មិតទូលតបថា:

ព្រះមហាពាជវិក្រមាទិត្យ ទ្រង់សោយពាជសម្បត្តិកន្លងនូវអវត្តី ។ នៅក្នុងនគរនោះមានពាណិជម្នាក់ឈ្មោះ ធនបតិ មានប្រាក់ ៣០ កោដិ មានបុត្រ ៤ នាក់ ។ (មានត)

កំណត់ទំនៀបប្រវត្តិការណ៍

ពិធីសម្ពោធសាលាចាស់ជាន់ខ្ពស់

នៅវត្តសៀមពប

របស់ពុទ្ធសាសនបណ្ឌិត្យ

នៅថ្ងៃទី ៣០ មីនា ១៩៥៦ ក្នុងវត្តតំណាក់វត្តសៀមពប មានធ្វើពិធីសម្ពោធគ្រឹះស្ថានមួយខ្នងយ៉ាងធំធ្ងាក ក្រោមអធិបតីភាព នៃលោកទិញ - ភីញ រដ្ឋលេខាធិការក្រសួងធម្មការ ។

គ្រឹះស្ថានមួយខ្នងនេះ សង់ពីឥដ្ឋធំថ្ម ប្រកបដោយជាន់ ២ ខ្ពស់ជាបន្ទប់រៀន ៤ ថ្នាក់, គ្រឹះស្ថាននេះកើតដោយស្នាព្រះហស្តនៃព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យមេគណវត្តសៀមពប និងពួកពុទ្ធបរិស័ទជើងវត្តដែលមានសទ្ធាក្នុងព្រះពុទ្ធសាសនា ។

ក្នុងឱកាសពិធីសម្ពោធនេះ គេបានសង្កេតឃើញពុទ្ធបរិស័ទជាច្រើនដែលអញ្ជើញទៅរួបរួម មានឯកឧត្តមឈួន - ម៉ុលពេជ ព្រះពជប្រតិភូប្រចាំវត្តសៀមពប, លោកគាន់ - គិមតិក ចាងហ្វាងសាលាដំបូងវត្តសៀមពបនិងលោកជំទៀត ដែលយើងសូមអភ័យទោសដោយមិនបានកប់នាមពាំងអស់ក្នុងទីនេះ ។

ក្នុងទីសន្និបាតនោះ ព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យ បានថ្លែងសុន្ទរកថា រៀបរាប់អំពីប្រវត្តិនៃវត្តតំណាក់យ៉ាងក្បោះក្បាយ

នាំឲ្យពុទ្ធបរិស័ទដែលនៅស្តាប់ពាំនប៉ុន្មានរំភើបក្នុងចិត្តយ៉ាងក្រៃលែង ។

បន្ទាប់មក លោកទេព្យ-ភ័ព្យ រដ្ឋលេខាធិការក្រសួងធម្មការ បានឡើងលើវេទិការថ្លែងសុន្ទរកថា តបនឹងព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យមេគណវិញ ។

មុនឡើងសំដែងសុន្ទរកថា លោករដ្ឋលេខាធិការក្រសួងធម្មការបានមានប្រសាសន៍ ទូលព្រះសង្ឃនឹងជំរាបពុទ្ធបរិស័ទអំពីសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង នៃសម្តេចព្រះឧបយុវរាជ ព្រមទាំងព្រះរាជរដ្ឋាភិបាល ចំពោះការស្តាបនាទ្វីសាលានេះ ។

លុះចប់ប្រសាសន៍ដ៏ខ្លីនេះហើយ ទើបថ្លែងសុន្ទរកថាក្នុងនាមនៃព្រះរាជរដ្ឋាភិបាលទទួលយកសាលានេះ ជាសម្បត្តិរបស់រដ្ឋតទៅ ។

រីសុន្ទរកថានៃព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យ នឹងលោករដ្ឋលេខាធិការក្រសួងធម្មការ យើងនឹងស្រង់យកមកចុះ ដូចតទៅនេះ៖

សុន្ទរកថា

នៃព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យមេគណ

សូមក្រាបថ្វាយបង្គំ សម្តេច !

សូមថ្វាយបង្គំ ព្រះមហាថេរានុត្តរៈ !

លោករដ្ឋមន្ត្រីក្រសួងធម្មការ !

ឯកឧត្តមព្រះរាជបតិភូ !

លោកអ្នកសប្បុរសពាំងឡាយ !

ខ្ញុំព្រះករុណា អគ្គាភាព មានសេចក្តីត្រេកអរនឹងថ្វាយទ្វេនពុំបាន ចំពោះសម្តេច, ព្រះតេជព្រះគុណ ដែលបានធ្វើតទុកាសដ៏ប្រសើរនេះមក ជាអធិបតីសិរីសួស្តីក្នុងពិធីបុណ្យសម្ពោធសាលានេះ ។

សូមសម្តេច, ព្រះតេជព្រះគុណ, ឯកឧត្តម, លោកសប្បុរសគាំង ឮយមេត្តាច្រោសប្រទានទុកាស ខ្ញុំព្រះករុណា អគ្គាភាពនឹងប្រគេនសេចក្តី ជូនសេចក្តីអំពីការកសាងសាលានេះ ដូចតទៅ៖

អស់កាលយូរថ្ងៃមកហើយ តាំងតែអំពីកាលដែលព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ព្រះមេត្តាច្រោសតែងតាំងខ្ញុំព្រះករុណា អគ្គាភាព ឲ្យឧទ្ទេសនាទីជាមេគណវែត្រសៀមកាបមក ខ្ញុំព្រះករុណា អគ្គាភាព តែងតែមានចិត្តបារម្ភជានិច្ចក្នុងកិច្ចការរបស់ខ្លួន ព្រោះវែត្រនេះឆ្ងាត់ឆ្ងាយ ឲ្យសម្បត្តិចំណេះវិជ្ជាជាងវែត្រដ៏ទៃ។ ក្នុងព្រះពុទ្ធសាសនាហើយ ចំការកែមធ្យោបាយតំកំតំកើងព្រះពុទ្ធសាសនា ដើម្បីតបស្នងគុណព្រះតេជព្រះគុណ ព្រះបរមគោធិសម្ភារបារមី ដែលទ្រង់តែងតែទុកព្រះពុទ្ធប្អូនយ៉ាងចំពោះមកលើរូបខ្ញុំព្រះករុណា អគ្គាភាពថានឹងអាចជួយសម្រាលព្រះពុទ្ធកិច្ចដ៏ធ្ងន់នោះបានខ្លះ ។

ដោយអានុភាពនៃព្រះពុទ្ធគុណ នឹងព្រះពុទ្ធគុណដែលបង្កើតឲ្យមានសាលាបាលីវង្សនឹងសាលាធម្មវិន័យឡើង កិត្តិសាមណេរក្នុងវែត្រនេះច្រើនរូបបានទទួលការបេះដឹង ខ្លះបានចូលទៅបន្តវិជ្ជានាក្រុងភ្នំពេញខ្លះទៅសល់ខាន លទ្ធផលនេះគួរសង្ឃឹមទុកចិត្តថា ពុទ្ធសាសនាក្នុងវែត្រនេះមុខជានឹងចំរើនទៅអនាគតពុំខាន ។ តែការសិក្សាមិនមានចប

ខែត្រ កាលបើប្រទេសជាតិកាន់តែចំរើនឡើងហើយ ការសិក្សាជាន់ខ្ពស់នៃសិក្ខាកាមកុលបុត្រ ក៏រឹតតែមានសេចក្តីត្រូវការជាចាំបាច់កាន់តែច្រើនឡើងណាស់ដែរ តិក្ខុសាមណេរដែលបានទទួលការសិក្សារយើញថាសមគួរមកហើយអំពីអតីតសម័យ បែរទៅជាយើញថានៅខន់ខ្លីសេចក្តីទៅវិញ តិក្ខុសាមណេរខ្លះ ដែលមានវិជ្ជាល្មមនឹងទៅបន្តវិជ្ជាជាន់ខ្ពស់នាក្រុងភ្នំពេញបានក៏មានច្រើនរូប តែញាតិញោមក្រីក្រ មិនមានមធ្យោបាយនឹងកែខៃបន្តវិជ្ជាកូនចៅឲ្យរៀនបាន តំណៅតឿគ្រិនភ្លិបក្តៀបការចេះដឹងដូចផលានុផលក្នុងវដ្តវុឌ្ឍិ មិនមានវិជ្ជាជាពន្លឺក្នុងខ្លួនឆ្លងល្មមក្នុងការប្រតិបត្តិព្រះពុទ្ធសាសនាយកផលប្រយោជន៍ខ្លួន ឬប្រយោជន៍ដួយខ្លួនឲ្យនៅប្រៀនប្រដៅប្រជាជន ឲ្យមានចក្ខុមើលឃើញផ្លូវដើរទៅតាមគន្ធងមិដ៏ច្រើនពៃ បានឡើងហានៈជាពលវដ្ឋល្អរបស់ប្រទេសជាតិ ឬជាកស្តល្អរបស់ព្រះមហាក្សត្រិយ៍ ឲ្យបានសមតាមព្រះរាជបំណងប៉ងថ្នាថ្នាថានឹងនាំប្រទេសជាតិទៅកាន់សេចក្តីរុងរឿងដូចសម័យព្រៃងនាយ ។

ខ្ញុំព្រះករុណា អាត្មាភាពយល់ឃើញថា ក្នុងសម័យព្រៃងនាយខែត្រសៀមរាបនេះជាទីក្រុងធំមួយ បរិបូណ៌ដោយប្រាង្គប្រាសាទពាជហានខ្ពង់ខ្ពស់ត្រដឹមស្លឹមស្អែ មានកំពូលដោមដុងផុតចុងព្រឹក្សា ទៅខាងនាលិយប្រទេស ជាទីគោចរនៃអ្នកទេសចរបរទេសត្រង់ជាតិដែលមកពីគ្រប់ជ្រុងពិភពលោក គួរតែមានវិជ្ជាហានការសិក្សាជាន់ខ្ពស់មួយឲ្យសមកិត្តិយសជាព្រះមហានគរបរមបុរាណ ។ ដោយសេចក្តីយល់ដូច្នេះហើយ បានជាព្រះរាជរដ្ឋកិច្ចលក្នុងអតីតកាល បាន

បង្កើតសាលាបាលីជាន់ខ្ពស់ឡើងក្នុងខែត្រសៀមរាបនេះមុនដំបូង កាលពីគ្រិស្តសករាជ ១៩១២ យកព្រះពជតំណាក់ ព្រះករុណាជាអម្ចាស់ជីវិតកាលនោះ នៅមុខនាគចំមុខប្រាសាទអង្គរវត្តជាគ្រឹះស្ថាន ហើយទិមន្តព្រះតេជព្រះគុណ ព្រុំព្រុន្ទរ៉ាជ្បម្រ៉ី មកធ្វើចាងហ្វាង ។ តែអនិច្ចាសាលានេះមានអាយុខ្លីពេក បានត្រឹមតែ ៣ ឆ្នាំ គឺពីគ្រិស្តសករាជ ១៩១២ ទៅ ១៩១៤ ក៏រាជរដ្ឋាភិបាលលើកយកទៅតាំងនៅនាក្រុងភ្នំពេញវិញ រហូតមកដល់សព្វថ្ងៃនេះ ព្រោះទីនេះក៏ក្រមិនមានអាហារគោជនគ្រប់គ្រាន់ទឹងចិញ្ចឹមកិក្ខុសាមណេរអ្នករៀនសូត្របាន ខ្លួនខ្ញុំព្រះករុណា អាត្មាភាពនេះជាសិស្សមួយរូបរៀនក្នុងសាលានោះដែរ រៀនបានត្រឹមតែ ៣ ឆ្នាំ ក៏ឈប់រៀនតាំងពីកាលនោះរហូតមក ទឹកស្ពាយជាទីបំផុត ទឹងតាមទៅរៀនឯក្រុងភ្នំពេញ ញាតិញោមក្រីក្រមិនមានមធ្យោបាយជួយបាន ។

សេចក្តីខ្លី ។ ដូចខ្ញុំព្រះករុណា អាត្មាភាពក្រាបបង្គំទូល ថ្វាយព្រះពរមកនេះ ផ្សំទឹងយោបល់ស្របគ្នារបស់លោករដ្ឋមន្ត្រីក្រសួងធម្មការ ប្រែនរូបកាលពីរាជ្ជាភិបាលមុន ។ មក នាំឲ្យខ្ញុំព្រះករុណា អាត្មាភាពសម្រេចចិត្តជាប់ខាតថា ត្រូវតែកសាងគ្រឹះស្ថានបង្កើតការសិក្សាជាន់ខ្ពស់ក្នុងខែត្រនេះឡើងវិញ ដើម្បីបន្តសាលាបាលីជាន់ខ្ពស់អំពីកាលនោះឲ្យមានឡើងវិញផង ដើម្បីបំពេញសេចក្តីត្រូវការនៃកិក្ខុសាមណេរជាសិក្ខាកាមបុគ្គលក្នុងខែត្រនេះ ដែលក្រីក្រទៅរៀនឆ្ងាយពុំបាន

ឲ្យបានមានវិជ្ជាជាន់ខ្ពស់ឡើង សមនឹងកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់ព្រះមហានគរ
សម័យត្រែងនាយនៅក្បែរនេះផង ។

លុះមូលគំនិតហើយ ខ្ញុំព្រះករុណា អាត្មាភាពរួបរួមនឹងគណៈ
កម្មការវត្ត ចាត់ការរៀបចំកសាងគ្រឹះស្ថាននេះឡើង ក្នុងគ្រិស្តសករាជ
១៩៥៣ មកដល់គ្រិស្តសករាជ ១៩៥៦ នេះទើបស្រេច ។ សាលា
ចារ្យនេះទទឹង ១០ ម៉ែត្រ បណ្តោយ ២០ ម៉ែត្រ សង់ដោយឥដ្ឋ
មានព័រជាន់ ដំបូលឈើ ប្រក់ក្បឿង, សាលាចារ្យនេះ អាចធ្វើជា
កន្លែងសិក្សាបាន ៤ ថ្នាក់ ។ កន្លែងកណ្តាលខាងលើក្រោម អាចធ្វើជា
ការិយាល័យបាន ។ សាលានេះមានលោកសប្បុរសជាច្រើនខាង
មានសទ្ធាជួយជាកំឡាំងទ្រព្យផង កំឡាំងកាយផង បព្វជិតក៏មាន
គ្រហស្ថក៏មាន នៅដើរវត្តនេះផង ក្នុងវិស័យសៀមរាបខាងមូលផង,
វិស័យដទៃទូរទៀតផង រួបរួមគ្នាកសាងឡើង អស់ទឹកប្រាក់ចំនួន
៣៧២.៤៦៤ រៀល ។

ខ្ញុំព្រះករុណា អាត្មាភាពមានសេចក្តីត្រេកអរក្រៃលែង ព្រោះបាន
សម្រេចដូចបំណងហើយ ។

រោះនេះ, សម្តេចព្រះតេជព្រះគុណ ព្រះពោធិវង្ស្ យោគវដ្ដលេខា-
ធិការ ឯកឧត្តមព្រះរាជប្រតិភូ និមន្តមក អញ្ជើញមកជួបជុំក្នុងថ្ងៃនេះ
កំណត់ទុកថាជាឧក្តដ្ឋឫក្សមានសិរីសួស្តី ខ្ញុំព្រះករុណា អាត្មាភាព សូម
លើកគ្រឹះស្ថាននេះ ជូនចំពោះព្រះរាជវង្សាគិបាល ដែលមានសម្តេចព្រះ
ឧបយុវរាជជាប្រមុខ, សូមព្រះរាជវង្សាគិបាលឧបត្ថម្ភគ្រឹះស្ថាននេះទុកជា

សម្បត្តិដ្ឋ ហើយចាត់ការបង្កើតជាពុទ្ធិកវិញ្ញាល័យពុទ្ធសាសនាក្នុងខែត្រ
សៀមរាប ឲ្យត្រាតែបានសម្រេច ដើម្បីអនុគ្រោះដល់កុលបុត្រជាសិក្ខា-
កាមបានក្រែបរសៃព្រះធម៌វិញ្ញូ កើតចក្ខុមើលឃើញធម៌ ប្រយោជន៍
លុបលាងបំបាត់មិច្ឆាទិដ្ឋិ ហើយសាបព្រោះសម្មាទិដ្ឋិឲ្យមើលឃើញផ្លូវ
ដើរទៅរកសេចក្តីសុខពិត ជាកំពូលសេចក្តីប្រាថ្នានៃសត្វលោក ទុកជា
ព្រះកិត្តិយសដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រនីធីសម្តេចព្រះមហាក្សត្រិយានី
ព្រមទាំងសម្តេចព្រះទេពយុវរាជ តទៅហួតកល្បាវសាន ។

ពុទ្ធបរិស័ទទាំងឋាវជិតទាំងគ្រហស្ថក្នុងខែត្រសៀមរាបនេះ មាន
សេចក្តីត្រេកអរជាទីបំផុត ឋានៈមើគ្រឹះស្ថាននេះកើតបានជាពុទ្ធិកវិញ្ញា-
ល័យ ដោយព្រះបរមរាជូបត្ថម្ភជូចបំណងហើយ នឹងបានតំកុំសាមណេរ
ជាកូនចៅនៅសិក្សារៀនសូត្រគ្រោមម្លប់ព្រះបរមរោគសម្ភារបុណ្យឋារមី
នៃព្រះករុណាជាអម្ចាស់ជីវិតជាសុខក្សេមក្សាន្តតរៀងទៅ ។

ក្នុងទីបំផុតនេះ, ខ្ញុំព្រះករុណា អាត្មាភាព សូមលើកយកផលនៃ
ការកសាងនេះ

– ថ្វាយចំពោះព្រះករុណា នឹងសម្តេចព្រះមហាក្សត្រិយានី សូម
ទ្រង់បានប្រកបដោយសុខសួស្តីក្នុងសិរីរាជសម្បត្តិតរៀងទៅ ។

– ប្រគេនសម្តេច នឹងព្រះតេជព្រះគុណព្រះពោធិវង្ស សូមមាន
ព្រះជន្មាយុយឺនយូរ ព្រមទាំងសេចក្តីសុខសាន្តអស់កាលជាអង្វែងទៅ ។

– ថ្វាយចំពោះសម្តេចព្រះទេពយុវរាជ, សូមសម្តេចទ្រង់បានប្រកប

ដោយព្រះពរគឺ អាយុ វណ្ណៈ សុខៈ ពលៈ ទំនប្រតិភាណគ្រប់ទីភ
ពត្រឹតរៀងទៅ ។

- សូមជូនលោកវដ្ឋលេខាធិការក្រសួងធម្មការ ទំនងឯកឧត្តមព្រះ
ពជប្រតិភូ ព្រមទាំងអស់លោកអ្នកទាំងឡាយ ឲ្យបានប្រកបដោយ
សេចក្តីសុខចំរើនគ្រប់ប្រការតរៀងទៅ ។

*
* *

សុទ្ធរកថា

នៃលោកវដ្ឋលេខាធិការក្រសួងធម្មការ

សូមថ្វាយបង្គំសម្តេច !
ព្រះតេជព្រះគុណគ្រប់ព្រះអង្គ !
សូមជំពាកឯកឧត្តមព្រះពជប្រតិភូ !
សូមជំពាកលោកអ្នកសប្បុរសទាំងឡាយ !

ក្នុងនាមនៃព្រះពជរដ្ឋកម្ពុជ, ខ្ញុំព្រះករុណា, ខ្ញុំសូមថ្វាយនូវឧប.
ការគុណ ដ៏ជ្រាលជ្រៅចំពោះព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យ
ដែលមានឧត្តមគតិដ៏ប្រសើរ ប្រទានដឹកនាំពុទ្ធបរិស័ទឲ្យដួយកសាង
គ្រឹះស្ថានមួយទៀត សម្រាប់ជាពុទ្ធិកន្ទ្រាល័យចំពោះព្រះពុទ្ធសាស
នុកជាសម្បត្តិបេស់រដ្ឋ. ឧត្តមគតិនេះអាចនុកជាគំរូមួយ កើតមានឡើង
ក្នុងវេលាដែលប្រទេសកម្ពុជា កំពុងបិតនៅក្នុងស្ថានការណ៍ហ៊ាវញ្ជាវត្តដ៏
ចង្អៀតក្រៃលែង អាចទំនងបាន់ថាជាមហាពលីមួយយ៉ាងថ្លៃថ្លារបស់

ព្រះតេជព្រះគុណ ទីឯពុទ្ធបរិស័ទចំពោះមាតុភូមិទីឯពុទ្ធសាសនា ។
ពលិកម្មមានសភាពប្លែកដូចនេះ មិនសូវកើតមានញឹកញាយទេ កាល
បើកើតមានម្តង ។ អាចធ្វើទឹកចិត្តព្រះសង្ឃ ទីឯពុទ្ធបរិស័ទទាំងឡាយ
ឲ្យរំភើបយ៉ាងក្រៃលែង មិនត្រឹមតែប៉ុណ្ណោះទេ ពលិកម្មជាតំរូវនេះ ពុកជា
ជំនួយមួយយ៉ាងសម្រាប់ប្រទេសជើង ព្រោះអាចជួយសម្រួលបានខ្លះ នូវ
បន្ទុកដ៏ធ្ងន់នៃថវិកាជាតិ ហើយជាមធ្យោបាយមួយដ៏ប្រសើរ សម្រាប់តំកល់
តំកើងព្រះពុទ្ធសាសនាឲ្យមានស្ថិរភាពរឿងកង៏សាកលលោក ។

ចំពោះការសិក្សាវិជ្ជាផ្នែកពុទ្ធសាសនា ព្រះពជរជ្ជាកិឃ្លាតពុំបាន
ព្រងើយកន្តើយសោះ ក្នុងបច្ចុប្បន្ននេះ ខ្ញុំព្រះករុណាពុងរៀបចំកិច្ចការ
សិក្សាវិជ្ជាជាន់ខ្ពស់ខាងពុទ្ធសាសនារួបរួមជាមួយព្រះតេជព្រះគុណ ព្រះ
ពោធិវង្សជាចាងហ្វាងពន្លឹកវិទ្យាល័យព្រះសុភមិត ហើយទីឯពន្លឿកការ
សិក្សានេះ ឲ្យបានធំទូលាយដល់ទៅទីប្រជុំវិទ្យតនានា ក្នុងព្រះពជ-
អាណាចក្រ ឲ្យបានសមដូចបំណងព្រះតេជព្រះគុណ ទីឯពុទ្ធបរិស័ទ
ក្នុងទីនេះ សូមព្រះតេជព្រះគុណសង្ឃឹមទុកក្នុងព្រះទ័យចុះថា ទីឯបាន
សម្រេចដូចសេចក្តីប្រាថ្នា ក្នុងអនាគតដ៏ខ្លីនេះ ។

ក្នុងនាមនៃប្រជាជាតិ ដែលមានសម្តេចព្រះនរបយុវរាជខ្ចង់ជាប្រមុខ
និងក្នុងនាមនៃព្រះសង្ឃ ដែលមានសម្តេចព្រះមហាសុមេធាធិបតីទិមន្តមក
គង់ជាប្រធាន ខ្ញុំព្រះករុណា ខ្ញុំបានទទួលគ្រឹះស្ថានមួយខ្នងនេះដោយ
សោមនស្សរីករាយយ៉ាងក្រៃលែង ហើយទីឯរៀបចាត់ចែងបង្កើតឲ្យមាន
ការសិក្សាជាន់ខ្ពស់ឡើង ក្នុងវិទ្យតសៀមរាបនេះ ក្នុងកាលវេលាដ៏សមគួរ

ដើម្បីឲ្យស្រេចតាមព្រះពរជ័យសម្តេចដែលទ្រង់តែងតែមានព្រះហឫទ័យ
ធ្ងន់ ក្នុងការពង្រីកព្រះពុទ្ធសាសនា ឲ្យបានរីកលូលាយត្រឡប់ត្រឡាយ
ខ្សែ សមជាសាសនារបស់ប្រទេសឯកពាជ្យផង ដើម្បីធ្វើយតបនឹង
សេចក្តីត្រេកអរព្រះតេជព្រះគុណ ត្រមាំងពុទ្ធបរិស័ទក្នុងទីនេះផង ។

ព្រះតេជព្រះគុណ !

មុននឹងបញ្ចប់, ក្នុងនាមនៃប្រជាជាតិ ដែលមានសម្តេចព្រះឧប-
យុវរាជជាប្រមុខ នឹងក្នុងនាមនៃព្រះសង្ឃ ដែលមានសម្តេចព្រះមហា
សុមេធាធិបតីជាប្រធាន ខ្ញុំព្រះករុណា ខ្ញុំ សូមព្រះតេជព្រះគុណ នឹង
ពុទ្ធបរិស័ទទាំងឡាយ មេត្តាទទួលខ្ញុំវអំណរគុណដ៏ជ្រាលជ្រៅនឹងកត្តីភាព
ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំព្រះករុណា ខ្ញុំ ។

សូមអញ្ជើញគុណព្រះរតនត្រៃដួយអកប្រាលថែរក្សា ព្រះតេជព្រះ
គុណនឹងពុទ្ធបរិស័ទទាំងឡាយ ឲ្យបានបរិតោគក្នុងសេចក្តីសុខចំរើនគ្រប់
ប្រការ ជាប់តាំងពីពេលនេះរហូតតទៅ ។

ពិធីបុណ្យទក្ខិណានុប្បទាន

របស់លោក ឯន - ប៉ង់ ធ្វើនៅភូមិតាលាស់ ស្រុកមោងឫស្សីខែត្រចាត់ដំបង

ព្រះអាចារ្យ នួ - កិញ

វត្តសុវណ្ណភូមិ ឃុំតាលាស់ ស្រុកមោងឫស្សី រៀបរៀង

នៅថ្ងៃទី ១៦ មេសា ១៩៥៦ ក្នុងអាគារស្ថានៃ។ចាស់កា នួ - ខួន ក្នុងភូមិតាលាស់ ឃុំតាលាស់ ស្រុកមោងឫស្សី (ចាត់ដំបង) មានធ្វើពិធីបុណ្យទក្ខិណានុប្បទានយ៉ាង។ឡូរាក ដើម្បី។ឧទ្ទិសកុសលជូនដល់បុព្វបុរសគឺព្រះតេជព្រះគុណ ហ៊ុល - ចាយ, ។ចាស់ក ឯន ទីង។ចាស់កា ជូ ដែលអស់ព្រះជន្ម ទីងជន្មាយុទៅហើយ ក្រែមការចាត់ចែងនៃលោកឯន - ប៉ង់ ទីងក្រុមគ្រួសាររបស់លោក ។

ដោយការគាក់តែងរបស់លោក ឯន - ប៉ង់ លើផែនពស់ជាជុំវិញនៃអាគារស្ថានមោះ មានពន្ធឹកក្ងឹងអគ្គិសនីក្ងឹចែងចាំង ចាំងមានគ្រឿងច្រកស្រមាប់ពន្លឺកស់ឡេងលាន់ឮគឹកកងំពេង ដែលឮពីចម្ងាយ អាចឲាញអារម្មណ៍ឲ្យដឹងថាជាពិធីបុណ្យបានផង, អាចឲាញមនុស្សដែលមានចិត្តមច្ចរៃយ ឲ្យអាក់ខានលះបង់ធនធានមិនបានផង ។

ក្នុង។ការមោះ យើងសង្កេតយើញតាំងពីម៉ោង ១៦, ១៥ នាទី មានការអញ្ជើញមកនៃពុទ្ធបរិស័ទចាំងប្រុស - ស្រី ជាញាតិសាលោហិត ច្រើនមើរដងរោសដែលខានជួបគ្នាយូរថ្ងៃហើយ សុទ្ធតែមានមុខស្រែះស្រាយរីករាយរកគ្នា ។

- ដោយសេចក្តីសាមគ្គីនៃអស់លោក-អ្នកជាសប្បុរសទាំងឡាយ ពិធីបុណ្យនេះ ក៏បានកើតឡើងដោយសុភមង្គលយ៉ាងក្រៃលែង ។

ព្រះករុណាគ្រប់ព្រះអង្គ !

អស់លោក-អ្នកសប្បុរសទាំងឡាយ !

យើងខ្ញុំ សូមនាសាថ្វាយជាមួយដំណើរ ដូចតទៅនេះ ៖

កាលព្រះសម្ពុទ្ធជាបរមគ្រូទ្រង់ធរមាននៅឡើយ ទ្រង់សំដែងថា " សត្វលោកទាំងអស់សុទ្ធតែប្រកបដោយសេចក្តីព្រាត់ប្រាសចាកមាតាបិតាគ្រូអាចារ្យបុត្រកិយា ទីឥញ្ជាតិសាលោហិតទាំងឡាយជាធម្មតាមិនថាមនុស្ស សត្វ ឬទេវតាទេ ទុសគ្គតែត្រង់មុនក្រោយ អាយុច្រើនតិចប៉ុណ្ណោះ ទីឯគេចឲ្យផុតពីការព្រាត់ប្រាសនិកសត្តាពុំបាន " ។ តាមការចេះចាំបន្តិចបន្តួចខាងផ្លូវពុទ្ធសាសនានៃយើងខ្ញុំថា សត្វលោកខ្លះគ្រាន់តែដឹងថា ការព្រាត់ប្រាសនិកសមានប្រាកដមែន. ប៉ុន្តែពុំអាចដឹងថាទីមានមកនៅកាលបរិច្ឆេទណាមៅងណាឡើយ, ព្រោះដូនកាលអ្នកកើតមុនព្រាត់ប្រាសចាកបិយជនទាំងឡាយ មានមាតាបិតាជាដើមមុនក៏សឹងមាន, ដូនកាលអ្នកកើតក្រោយក៏ត្រូវប់ជាបានទទួលការព្រាត់ប្រាសចាកញាតិទាំងឡាយមុនអ្នកកើតមុនទៅវិញក៏សឹងមាន ។

រីការព្រាត់ប្រាសនិកសចាកមាតាបិតាគ្រូអាចារ្យជាដើម ដែលកំពុងមានសេចក្តីស្នេហាប្រកាន់ជាប់ស្និតនោះ ជាហេតុនាំឲ្យសត្វលោកកើតសេចក្តីសោកសង្រេងសង្រៃខ្សឹកខ្សួលយ៉ាងមហិមា ។

ការព្រាត់ប្រាសរបស់សត្វលោកមានច្រើនជាអនេក, តែបើពោល

ចែងដោយចំណែកមាន ៤ ប្រការ គឺ ព្រោត់ប្រាសដោយធ្វើកាលកំរៃ ចែកស្ថានទៅគាន់បរលោក ១, ព្រោត់ប្រាសដោយមានជីវិតរស់នៅ តែទៅនៅផ្សងអាសយដ្ឋានជួបជាជនចំពូកខ្លះ មានមាតាបិតាត្រូវជាដើម នៅស្រុកនេះភូមិនេះ ខ្លួនឯងទៅនៅស្រុកឯណោះភូមិឯណោះជាដើម ១ ។

ការព្រោត់ប្រាសទាំងពីរដូចសំដែងមកខាងលើនេះ ប៉ើប៉ះទៅលើរូបជនណា ជននោះមុខជាមិនខានបានឮរំសេចក្តីទុក្ខព្រួយខ្លាចឡើយ ។

ព្រះករុណាគ្រប់ព្រះអង្គ !

អស់លោក - អ្នកសប្បុរសទាំងឡាយ !

កាលយើងខ្ញុំនឹកដល់សេចក្តីព្រោត់ប្រាស់ដូច្នោះ ក៏កើតសេចក្តីអណោចអធម្មកនឹងចិត្ត នឹកធុញព្រាន់ចំពោះសេចក្តីព្រោត់ប្រាសនោះវែកពេក ទើបលះបង់នូវប្រយោជន៍ផ្ទាល់ខ្លួន ស៊ូបរិច្ចាគជនជាន់បន្តិចបន្តួចមកចំពេញបុញ្ញកិរិយាវត្តុកនឹងទីនេះ ដើម្បីជាកំណាប់បុណ្យ ទុនជាស្បៀងកនឹងកាលព្រោត់ប្រាសដែលចៀសវាងពុំរួចនោះ ។

ម្យ៉ាងទៀត យើងខ្ញុំនឹកមមៃដល់បុព្វបុរសគឺ ព្រះគេជព្រះគុណ ព្រះសព ទាំងមាតាបិតា លោកទាំង ៣ នេះ សុទ្ធតែមានគុណអនេកអនន្តលើរូបយើងខ្ញុំ, កាលដែលលោកទាំងនោះកំពុងមានព្រះជន្មនឹងមានជន្មាយុនៅឡើយ យើងខ្ញុំបានប្រកបកាតព្វកិច្ចជាកុសលតបខ្លះដែរតែមិនទាន់អស់ចិត្ត ដ្បិតយើងខ្ញុំចង់បំពេញកតវេទិតាមិ ដែលជាកាតព្វកិច្ចជាកុសលតបគុណលោក ឲ្យបានដាបដល់អស់ជីវិតសង្ខារនៃយើងខ្ញុំ តែលោកទាំងនោះទៅជាអស់ព្រះជន្ម ទាំងជន្មាយុទៅ, មិនតែប៉ុណ្ណោះ

សូមឪ្យឪពុកធំ, ម្តាយធំ, ឪពុកមា ម្តាយមីង, សាមីតវិយានីងញាតិ ឯទៀត ដែលគួរគោរពរបស់យើងខ្ញុំដែរ ក៏ធ្វើមរណកាលទៅទៀត ។

ព្រះកុណាត្រៃព្រះអង្គ !

អស់លោក - អ្នកសប្បុរសទាំងឡាយ !

ដោយកតញ្ញូតាធម៌កើតមានក្នុងចិត្ត ទើបយើងខ្ញុំនាំគ្នាចំពេញ ករណីយកិច្ចជាកុសល ដើម្បីឧទ្ទិសជូនដល់បុព្វបុរសទាងលើនេះផង ។ ហេតុនេះ យើងខ្ញុំសូមឧទ្ទិសកុសលនេះជូនដល់បុព្វបុរសដូចតទៅនេះ ៖

ព្រះតេជព្រះគុណព្រះសង្ឃ !

លោកឪពុកលោកម្តាយ !

យើងខ្ញុំជាសិស្ស ជាបុត្រាបុត្រី នឹងជាបុត្រប្រសា សូមលើកកុសលនេះ ប្រគេនដល់ព្រះតេជព្រះគុណ នឹងជូនដល់លោកឪពុកម្តាយ សូមលោកទទួលយកនូវកុសលនេះទុកថាជូចជារបស់នៃខ្លួនចុះ កាលបើបានទទួលហើយ សូមឪ្យបានសម្រេចនូវផលមនុញ្ញផលកុំបីខានឡើយ ។

ក្នុងទីបំផុត យើងខ្ញុំសូមឧទ្ទិសកុសលនេះថ្វាយចំពោះព្រះករុណា ជាម្ចាស់ដីតែលើតួង, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ នរោត្តម - សីហនុ, នឹងព្រះរាជវង្សានុវង្ស, ចាំងសូមឧទ្ទិសកុសលនេះ ជូនដល់ព្រះរាជរដ្ឋាភិបាល សូមកុសលនេះជួយឧបត្ថម្ភគ្រប់នឹងព្រះរាជ-រដ្ឋាភិបាលឪ្យបានប្រកបតែនឹងសេចក្តីសុខសេចក្តីចំរើនយូរអង្វែងទៅ ។

ម្យ៉ាងទៀត យើងខ្ញុំសូមរំលែកភាគផលនៃបុណ្យនេះ ជូនដល់អស់លោក - អ្នកដែលបានអញ្ជើញមកក្នុងទីនេះក្តី ដែលមិនបានមកគ្រាន់តែ

ពេញចិត្តជ្រះថ្លាក្នុងកុសលនេះក្តី សូមអស់លោក - អ្នកទទួលអនុមោទនា ដោយសន្ធឹសញ្ញាថា សាធុ ត្រមៗគ្នា; កាលបើបានទទួលអនុមោទនា ហើយ សូមឲ្យអស់លោក - អ្នកបានសម្រេចនូវគោតផលស្មើៗគ្នា ទាំងសូមឲ្យកុសលនេះជួយបីបាច់រក្សា នូវអស់លោក - អ្នកឲ្យបាន សេចក្តីសុខចំរើនតាំងពីបច្ចុប្បន្ននេះរហូតដល់ព្រះនិព្វាន កុំបីឃ្លៀង ឃ្លាតឡើយ ។

ពុទ្ធសាសនបណ្ឌិត្យ

(តមកពីសៀវភៅលេខ ៤)

សុន្ទរកថាឯកឧត្តម មាស-យ៉ង់

លុះចប់សុន្ទរកថាព្រះអរិយកស្សបអ៊ូចហើយ ឯកឧត្តម មាស-យ៉ង់ រដ្ឋលេខាធិការក្រសួងសាធារណសុខាភិបាល បានថ្លែងបន្តមកទៀតដែលមានសេចក្តីដូចតទៅនេះ ៖

សូមព្រះតេជះដ៏ឧត្តុង្គ

សូមព្រះពជ្ឈាន ក្រាបបង្គំទូលព្រះកុរណាជាអម្ចាស់ជីវិត

សូមខ្ញុំជាបក្រោមល្អង់ធូលីព្រះបាទ ។

មុនដំបូង ទូលព្រះបង្គំជាខ្ញុំសូមព្រះពជ្ឈាន ថ្លែងអំណរព្រះគុណ-ខ្ញុំគុណដ៏ជ្រាលជ្រៅដោយគោរព ចំពោះព្រះកុរណាជាអម្ចាស់ជីវិតលើត្បូង ដែលខ្ញុំសព្វព្រះពជ្ឈាទ័យស្តេចយាងមកជាព្រះពជ្ឈាធិបតី ចំពោះពិធីបុណ្យសម្ពោធនេះ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះពជ្ឈាន ថ្លែងសេចក្តីកោតសរសើរយ៉ាងក្រៃលែង ចំពោះសម្តេចព្រះឧបយុវរាជ ដោយខ្ញុំមានព្រះពជ្ឈបញ្ញា-ញាណដ៏វិសេសកុងការច្រមាណគប់ចំពូកភ្លឺថ្លា ឧត្តមព្រះពជ្ឈឧទ្ទេះដ៏ពិតប្រាកដរបស់ព្រះអង្គ ដែលនាំឲ្យគតិនៃក្រុមគិលានសង្គ្រោះ ចំពោះព្រះសង្ឃពុទ្ធសាសនិក បានផុសចេញជារូបរាងជាក់ស្តែងឡើង ។

ខ្ញុំព្រះកុរណាសូមនុនកាយដោយគោរព ចំពោះសម្តេចព្រះសង្ឃ

នាយកទាំងពីរគណៈ ព្រមទាំងព្រះថេរានុត្ថេរៈទាំងអស់ ដែលបានទទួលមកកាន់ពិធីបុណ្យសម្ពោធនេះ ។

- សម្តេច
- ឧត្តម
- លោកឧត្តមស្នងការ
- ឯកឧត្តមឯកអគ្គរាជទូត
- ឯកឧត្តម
- លោកស្រី
- អស់លោក

ឧកាសនេះ គឺជាកត្តិយសមួយដ៏ប្រសើរ ដែលតម្រូវឱ្យទូលព្រះបង្គំជាខ្ញុំ . ខ្ញុំ មានការណិយកិច្ចទទឹងថ្លែងសេចក្តីយ៉ាងខ្លី ចំពោះព្រះតេជគុណមុខឥស្សរជន ដែលបានស្តេចយាងអញ្ជើញមកកាន់ទីសន្និបាត ដើម្បីសម្ពោធបើកមន្ទីរព្យាបាលរោគដ៏ល្អឆើតនេះ ។

ថ្ងៃនេះ ទូលព្រះបង្គំជាខ្ញុំសូមប្រកាសជូនថា ជាថ្ងៃដែលជាប់ចារឹកក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ។

មាតុភូមិយើងបានឯកភាពព្រមព្រៀងគ្នាហើយ ក៏ប៉ុន្តែបើយើងមានសិទ្ធិកាន់តែច្រើនទៀង យើងក៏ត្រូវតែបំពេញការណិយកិច្ចកាន់តែច្រើនដែរ ជាប្រថម គឺការណិយកិច្ចដែលត្រូវលើកតំកើងសុខភាពប្រជាជន ។ ថ្វីបើមានឧបសគ្គគ្រប់មុខយ៉ាងណាក៏ដោយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ ជាទីគោរពហើយជាទីស្នេហា

ព្រមទាំងសម្តេចព្រះនរបយុវរាជជាទីស្ងួមភក្តីនៃយើងទាំងអស់គ្នា ទ្រង់
តែងមានព្រះរាជចំណាងការខ្ជាប់ខ្ជួនខ្លាំងរឿយៗថែទេ ។

ហេតុដូច្នេះហើយ បានជាកាលពីថ្ងៃទី ៧ មករា គ.ស. ១៩៥៦
នេះ សាលាកូមិន្ទរឹង្សាទេព្យបានសម្ពោធបើកជាផ្លូវការរួចហើយ ។ តទ្ទឹង
ពីពេលនោះមក ពុំទាន់បានពីរខែផងមានការសម្ពោធបើកគ្រឹះស្ថាន
យ៉ាងប្រពៃនេះទៀត ដែលអាចពុកជាគំរូដល់មន្ទីរទេព្យនៅអនាគត ។

សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃ បានចេញមូលធនមុនដំបូង
ដើម្បីទិញសង់គ្រឹះស្ថាននេះ ។ ដោយការជឿជាំជ្ជឹងខ្ជាប់ខ្ជួនៃសម្តេចព្រះ
នរបយុវរាជ ពរវរ្ជាកិបាលក៏បានផ្តល់ជាជំនួយហិរញ្ញវត្ថុដ៏សំខាន់ក្នុងការ
កសាងគ្រឹះស្ថាននេះដែរ ។ ប្រជាជាតិសហរដ្ឋអាមេរិកាំង បានជួយ
ឧបត្ថម្ភបង្កើយការស្ថាបនា ទឹងបានផ្តល់នូវគ្រឿងសម្ភារៈបច្ចេកទេស
ទាំងអស់ ។ ចំណែកខាងប្រទេសបារាំងវិញ ក៏បានយកចិត្តទុកជាក់
ជួយជ្រោមជ្រែងក្នុងការនេះដោយមុតមាំដែរ បានជួយគ្រឿងសម្ភារៈខ្លះ
ហើយទឹងបញ្ជូនបុគ្គលិកទេព្យឱ្យមកធ្វើការនៅមន្ទីរនេះ ក្នុងពេល
ឆាប់ៗ ។

សហប្រតិបត្តិការនេះ ជាកស្តុតាងមួយបញ្ជាក់ឱ្យឃើញជាក់ច្បាស់
នូវមិត្តភាព នៃមហាជនរវាងពីរចំពោះប្រជាជនខ្មែរ ហើយរឹតចំណង
កាន់តែជិតស្និទ្ធឡើងនៃការរួបរួមមនុស្សជាតិទៀតផង ។

ស្នាដៃថ្មីនេះ បូកបញ្ចូលទឹងស្នាដៃឯទៀតៗ ជាច្រើន ដែលបាន
សម្រេចក្រោយពេលដែលប្រជាជនខ្មែរបានឯករាជ្យហើយ បង្ហាញជា

កស្តុតាងជាក់ស្តែងនៃសារវន្តភាពយើង ព្រមទាំងបញ្ជាក់ថែមទៀតថា ប្រទេសយើងបានចូលមកនៅក្នុងសកពជម្ជយថ្មីហើយ ។

តាមចំណងនៃប្រជាជនខ្មែរ មន្ត្រីព្យាបាលភេគនេះពុកសម្រាប់ខ្លួលតែព្រះសង្ឃដែលមានអាពាធទេ ។

បដិសណ្ឋារកិច្ចនេះ បង្ហាញឲ្យយើញច្បាស់នូវសេចក្តីគោរពនៃពលរដ្ឋខ្មែរ ចំពោះព្រះសង្ឃពុទ្ធសាសនិក ដែលបានគាំទ្រចរិយាសាស្ត្រនឹងចិត្តសាស្ត្រ ឲ្យនៅក្នុងហានៈដ៏ខ្ពង់ខ្ពស់ជានិច្ចក្នុងប្រទេសកម្ពុជា ។

វេបៀបនេះអាចធ្វើឲ្យព្រះសង្ឃពុទ្ធសាសនិកយើង កាន់ក្រឹត្យវិន័យបានដោយខ្ជាប់ខាត់ ក្នុងពេល ដលកំពុងខ្លួលនូវការព្យាបាលភេគយ៉ាងខ្លាំង ។

ខ្លួលព្រះបង្គំជាខ្ញុំ សូមថ្លែងអំណរព្រះគុណនឹងគុណដ៏ជ្រាលជ្រៅចំពោះខ្ញុំ - លោកស្រី នឹងអស់លោកអ្នកទាំងអស់ ដែលបានជួយឧបត្ថម្ភក្នុងការកសាងនេះ ។ សូមឯកឧត្តមតំណាងប្រទេសនានាដែលបានធ្វើអំណោយយ៉ាងប្រសើរ ដល់គ្រឹះស្ថាននេះ ខ្លួលនូវសក្តីភាពនៃសេចក្តីកតញ្ញូរបស់ប្រទេសកម្ពុជា ។

ក្នុងហានៈជារដ្ឋលេខាធិការក្រសួងសាធារណៈសុខាភិបាល ខ្ញុំក្នុងហានៈជាឯកជន ខ្លួលព្រះបង្គំជាខ្ញុំសូមក្រាបបង្គំខ្លួលព្រះគុណជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ ព្រមទាំងសម្តេចព្រះឧបយុវរាជជាទីស្នេហា សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានខ្លួលនូវបដិសារគុណដ៏ជ្រាលជ្រៅនៃពលរដ្ឋខ្មែរ ។

មិនត្រឹមតែប៉ុណ្ណោះ ដោយស្នាព្រះហស្តមានវស្សាភ្លឺត្រចះនៃព្រះ
ករុណាជាអម្ចាស់ដ៏វិតលើត្បូងពាំងពីរព្រះអង្គ ព្រមទាំងសម្តេចព្រះឧប-
យុវរាជខ្ចីបានត្រាស់ខ្លួលខុកជាព្រះបរមរាជាវបស់ព្រះអង្គ នូវព្រះ
បរមរាជាវនៃព្រះអយ្យកោ ដ៏មានព្រះឥទ្ធិឫទ្ធិដ៏ល្បីល្បាញ ហើយទឹង
ព្រះមហាវីរក្សត្រ ព្រះជយវរ្មនទី ៧ របស់យើងដែលមានចារឹកនៅថ្ម
តាមន័យដូចតទៅនេះ ៖

« ខ្ចីមានព្រះរាជប្អូនឈ្មោះចាប់ទឹងជម្ងឺរបស់ពលរដ្ឋព្រះអង្គ ជាង
« ព្រះកេតរបស់ព្រះអង្គទៅទៀត ព្រោះថាជម្ងឺសាធារណៈនេះហើយ
« ដែលធ្វើឲ្យព្រះមហាក្សត្រគ្រប់ព្រះអង្គ ខ្លួលនូវព្រះរាជទុក្ខជាជាង
« ព្រះរាជទុក្ខរបស់ព្រះអង្គទៅទៀត » ។

សុន្ទរកថាឯកឧត្តម ទ្រីញ-រ៉ីញ

នៅទីអាសាន, ឯកឧត្តមទ្រីញ-រ៉ីញ រដ្ឋលេខាធិការក្រសួងធម្មការ
បានថ្លែងសុន្ទរកថា រៀបរាប់ចំពោះកិច្ចការដែលត្រូវបំពេញជាសារ-
ប្រយោជន៍ដល់ប្រទេសជាតិ ទឹងសារៈប្រយោជន៍រៀងពាល់រូប ។ សុន្ទរ-
កថានេះ យើងយកមកផ្សាយជូនពាំងស្រុងដែលមានសេចក្តីដូចត
ទៅនេះ ៖

សូមព្រះតេជៈជំកល់លើត្បូង
សូមព្រះពរជាគ្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត
សូមខ្ចីជ្រាប, ក្រោមល្អងធូលីព្រះបាទ ។

សូមថ្វាយបង្គំព្រះរតនត្តេរ:
សូមក្រាបបង្គំលុលទ្ធន់
សូមដំកបសហជីវិន
អស់លោក-អ្នកតាំងឡាយ
សូមទ្ធន់ជ្រាប, សូមជ្រាប ។

មន្ទីរពេទ្យបាលព្រះសង្ឃនេះ សមាគមគិលានសង្គ្រោះចាត់ចែងកសាងឡើងដោយកម្ចាំងសទ្ធាពុទ្ធបរិស័ទ តាំងបព្វជិតតាំងគ្រហស្ថ ក្នុងព្រះពុទ្ធអាណាចក្រតាំងមូល ដើម្បីទុកជាសេនាសន:សម្រាប់ព្យាបាលអាពាធព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ត្រូវតាមគន្ថធម្មវៃណ៍ ដែលថាភាយកភាយិកាជាអ្នកផ្គត់ផ្គង់ថ្នាំយ ៤ ចំពោះព្រះសង្ឃ ។ បច្ច័យ ៤ នេះជាមធ្យោបាយលៀងជីវិតព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ឲ្យប្រព្រឹត្តទៅស្រួលសមដូចជាពាក្យដែលលោកតាំងមូល បបួលគ្នានិយមថា ជីវិតាពខ្ពង់ខ្ពស់ ។ ពិតពលោកក្នុងបច្ចុប្បន្នកាលនេះ កំពុងខំប្រឹងកសាងការគ្រប់គ្រងជីវិតាពប្រជាជនលោកឲ្យរស់នៅដោយស្រួល ដោយការផ្តល់ឲ្យមាន:

១ – គ្រឿងស្វែរពាក់
២ – អាហារបរិភោគ
៣ – ទីលំនៅ
៤ – ឱសថគ្រែពេត

ភាំង ๔ ប្រការនេះ ឲ្យមានបរិបូណ៌យ៉ាំងណា ក្នុងពុទ្ធសាសនា ពាយកពាយិកាក៏មានការៈផ្គត់ផ្គង់បច្ច័យភាំង ๔ គឺ

๑ - ចីវរ

๒ - បិណ្ឌបាត

๓ - សេនាសនៈ

๔ - គិលានប្បច្ច័យ

ភាំង ๔ ប្រការនេះ ប្រសិនបើព្រះសង្ឃយ៉ាំងនោះដែរ ព្រោះមនុស្សលោកដែលនឹងរស់នៅបាន ក៏ដោយអាស្រ័យបច្ច័យភាំង ๔ នេះឯង, បើខ្វះខាតបច្ច័យណាមួយហើយ មនុស្សលោករស់នៅមិនបានៈ, ប្រៀបដូចជាបើមានតែគ្រឿងស្លៀកពាក់ - មិនមានអាហារ - ទីលំនៅ - ឱសថគ្រែគ្រេង មនុស្សនៅមិនបាន, មានតែគ្រឿងស្លៀកពាក់ និងអាហារ តែខ្វះខាតទីលំនៅឱសុថគ្រែគ្រេង មនុស្សនៅមិនបានដែរ, មានតែគ្រឿងស្លៀកពាក់-អាហារ-ទីលំនៅ គ្មានឱសថគ្រែគ្រេង មនុស្សនៅមិនបានទៀត ព្រោះមនុស្សមានរោគជាសត្រូវធំ សម្រាប់បំផ្លាញសេចក្តីសុខ បើមនុស្សមិនមានសុខភាពល្អហើយ, តើមនុស្សធ្វើសេចក្តីចំរើនឲ្យលោកដូចម្តេចបាន ដូចពុទ្ធភាសិតថា: ការមិនមានរោគ ហៅថា មានលាភធំ ។

តែការស្វែងរកនូវបច្ច័យភាំង ๔ មក ដើម្បីលៀងជីវិតនេះ មិនមែនតែសម្រាប់ឲ្យរស់នៅទេ ឲ្យមានគ្រឿងផ្គត់ជីវិតគ្រប់ភាំង ๔ ល្មមរស់នៅបានស្រួលហើយ ត្រូវបំពេញប្រយោជន៍ ប្រយោជន៍ខ្លួន និងប្រយោជន៍មនុស្សលោក ព្រមទាំងបំពេញគុណធម៌ដទៃទៀត មានសីលធម៌ជាដើម

ដើម្បីសេចក្តីសុខធំរួមជាមួយគ្នា គឺតសាធារណៈទៅជាអរិយជន បើនៅក្នុងសាសនាថា, អរិយជនមានច្រើនក្នុងប្រទេសណា ប្រទេសនោះហៅថាអរិយប្រទេស ។

មន្ទីរព្យាបាលព្រះសង្ឃនេះ តសាធារណៈសម្រាប់ផ្តល់បច្ច័យ ៤ បំពោះព្រះសង្ឃ ដើម្បីឲ្យព្រះសង្ឃរស់នៅសុខស្រួល មានអនាម័យល្អ ជាមានឧកាសរៀនសូត្រ បំពេញសមណធម៌ព្រហ្មចរិយធម៌ ទ្រទ្រង់គុណធម៌ដទៃទៀតច្រើនប្រការ ព្រមទាំងពន្លឺតព្រះពុទ្ធសាសនា ឲ្យផ្សាយទៅពេញសាកលលោក ឲ្យពិតពលោកបានទទួលគ្រែងរសជាតិសន្តិភាពពិតតាមពុទ្ធសាសនា ទើបជួយពួកខ្ញុំនៅប្រទេសជាមួយគ្នាឲ្យជាសម្ភាទិដ្ឋិ តាំងនៅក្នុងគុណធម៌ដ៏ខ្ពង់ខ្ពស់ ជាអរិយជន សមជាពលរដ្ឋមានវិន័យជាប្រសើរ ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ទូលព្រះបង្គំ ខ្ញុំបាទ សូមឆ្លៀតយកវាសនេះ ថ្លែងសេចក្តីត្រេកអរជាបំផុត បំពោះសមាគមគិលានសង្គ្រោះ ទ្រង់ឯកឧត្តម ព្រមទាំងពុទ្ធបរិស័ទទាំងឥស្រ ដែលរួមគ្នាយ៉ាងម៉ឺងម៉ាត់ ក្នុងការកសាងមន្ទីរព្យាបាលព្រះសង្ឃនេះឡើង, បំបែកឲ្យឃើញថា មានសេចក្តីឃ្លាតវាតមនោបាយព្រះពុទ្ធាភិបាល ដែលមានសម្តេច ព្រះឧបយុវោជជាប្រមុខ ក្រោមព្រះពុទ្ធាធិបតីភាពនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ព្រមទាំងសម្តេចព្រះមហាក្សត្រិយានីដែលតែងតែមានព្រះពុទ្ធបំណងជានិច្ចនៅក្នុងព្រះពុទ្ធហឫទ័យ ចង់បំបាត់

អាណាចក្រព្រះសង្ឃនឹងបំបាត់ពេភាព្យាធិប្រជាជនព្រះអង្គ ព្រោះជម្ងឺប្រជាជន គឺជម្ងឺព្រះអង្គ ។

មិនតែប៉ុណ្ណោះទេ មន្ទីរពេទ្យបាលព្រះសង្ឃនេះ ជាមេបុណ្យមួយដ៏ធំ សម្រាប់អ្នកប្រាថ្នាបុណ្យកើបយកបុណ្យ, សមដូចព្រះតម្រាស់ព្រះសម្ពុទ្ធថា អ្នកដែលពេទ្យបាលព្រះសង្ឃឈ្មោះថា ពេទ្យបាលតថាគត ។ សេចក្តីនេះ បញ្ជាក់ថា យើងបានចំរើនព្រះបរមសម្ពាសម្ពុទ្ធគុណ ១ គ្នា បានអានិសង្សច្រើនអនេកអនន្ត ត្រូវនឹងពុទ្ធដីកាមួយព្រះនេះថា អ្នកមានប្រាជ្ញា អ្នកឲ្យសេចក្តីសុខគេ ត្រូវបានសេចក្តីសុខមកវិញ ។

ទីបំផុត ខ្ញុំលព្រះបង្គំជាខ្ញុំ - ខ្ញុំព្រះករុណា ខ្ញុំលព្រះបង្គំ ខ្ញុំបាទ សូមអធិដ្ឋានគុណព្រះរ័ត្នត្រ័យ សូមទ្រង់ព្រះមេត្តាប្រោសអភិបាលថែរក្សាព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះទេយ្យវរាជ ទ្រង់ - ឯទត្តមអស់លោក ដែលមានកុសលចិត្តជួយកសាងមន្ទីរពេទ្យបាលព្រះសង្ឃនេះ ដោយកម្លាំងទ្រព្យ កម្លាំងកាយ សូមឲ្យបានសេចក្តីសុខសួស្តីសិរីវឌ្ឍន៍ ប្រាសចាកទុក្ខភេតភ័យគ្រប់ប្រការ សមតាមសេចក្តីប្រាថ្នាកុំបីឃ្លាត ។

លុះចប់សុន្ទរកថានៃឯកទត្តមទ្រង់ - ភ្ញាក់ហើយ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានស្តេចយាងទៅកាត់ខ្សែសំពត់បើកទ្វារមន្ទីរពេទ្យព្រះសង្ឃ ទឹងស្តេចទ្រង់បើកសំពត់ដែលចិទចាំងចាកផ្លាំងថ្ម រួចស្តេចយាងទតគ្រប់ជាន់, គ្រប់បន្ទប់ ដោយមានឧម៉ាទេសភូមុខមន្ត្រីតាមជង្ហែផង ។

ភាទិវង្គាយព្រះរាជទេស្សនានេះ, ទៅម៉ោង ១០,៩០ នាទី ព្រះមហាក្សត្រិយ៍ ចាន់ស្តេចយាងត្រឡប់មកគាន់ព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារហែអមព្រះអង្គដូចកាលស្តេចយាងទៅ ។

យើងសូមជំរាបថា ពិធីបុណ្យសម្ពោធមន្ទីរពេទ្យព្រះសង្ឃដែលចាន់ចាប់ផ្តើមធ្វើតាំងពីពេលព្រឹកថ្ងៃទី ២១ កុម្ភៈនេះ ចាន់បន្តរហូតដល់ម៉ោង ២៤ យប់ ដោយក្នុងពេលរាត្រីនោះ តុន្តុបរិស័ទចាន់និមន្តសម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត សង្ឃនាយកគណៈមហានិកាយ សំដែងធម៌ជាធម្មទាន ទើបបញ្ចាំងភាពយន្តផ្សាយជូនដល់តុន្តុបរិស័ទមើលជាការកំសាន្តផង ។

ចប់

គ្រួបជំនុំនិងទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ភាសិតសុភាសិត

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៨ លេខ ៦ ខែមិថុនា ព.ស. ២៤៩៩ គ.ស. ១៩៥៦

គ្រួសជាតិនិងទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ភាគ៥សាសនាយោ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា		
— ព្រះពុទ្ធសាសនាប្រទេសកម្ពុជា (ត-ចប់)	លោក ទៀង-តៃឈុន ប្រែ	៥០៣
— ប៉ញ្ញាកថា	ព្រះមហាឧត្តមវិជ្ជា ឈឹម-សាមី	៥១៣
— ប្រជុំធម៌ឧបាសក	ព្រះទេពសត្ថា កឹម-តូ	៥១៩
— ជាឥកថារឿងពុទ្ធរូបបុរាណ (តមក)	ឃុនអត្ថកោវិទ ជា-យ៉ូរ ប្រែ	៥២៧
ផ្នែកអក្សរសាស្ត្រ		
— បញ្ញាបរិយាយ	ព្រះឧបាលិវង្ស ស្សរ-ហាយ	៥៣៦
— ពេទ្យព្រះរាជា (តមក)	លោក សុិន-ហ៊ាន ប្រែ	៥៤៤
— រឿងសាមកុក (តមក)	ឧកញ៉ា នូ-ហន	៥៥២
— រឿងបល្ល័ង្កទិព្យ (តមក)	លោក ភ័ក-ប៊ុក ប្រែ	៥៦១
— រឿងសៅរ៍សោយ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម	៥៦៧
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ	លោក ជាប-ពិន	៥៧៨
កំណត់ទំនឹងប្រវត្តិការណ៍		
— ដំណើរទៅកាន់ប្រទេសភូមានៃប្រតិភូ៨រូប	ព្រះញាណវិរិយៈ ភិន-សាងុម	៥៨៨
— ដំណើរគណៈប្រតិភូខ្មែរ ទៅប្រជុំសន្និសីទ នៅពុទ្ធគយាប្រទេសឥណ្ឌា	លោក ជាប-ពិន	៥៩៨

មួយឆ្នាំមាន ១២ លេខ — ដំឡៃជាវ ៣០រ, ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE: *Page*

— Le Bouddhisme au Cambodge (suite et fin) . . . . . *Traduit par M. TIANG-TAY-CHHUN 503*

— Pannhākathā . . . . . *par Vénérable CHHIM-SAMEY 513*

— Les règles Bouddhiques des fidèles . . . . . *par Vénérable KEM-TO . . . 519*

— Les statues Bouddhiques primitives (suite) . . . . . *Traduit par M. CHEA-YOU . . 527*

PARTIE LITTÉRAIRE:

— Pannhāpariyay . . . . . *par Vénérable SO-HAY 536*

— Conte "Le Diamant du Raja" (suite) . . . . . *Traduit par M. SIN-HEAN . 544*

— Histoire de Samkok (suite) . . *par l'Okuha NOU-KAN 552*

— Les trente-deux récits du Trône (suite) . . . . . *Traduit par M. RAY-BOUC 561*

— Le "Sau-Soy" ou l'influence saturnienne (suite) . . . . . *par Vénérable PEUNG-PAM . . 567*

— Les activités de la Commission des Moeurs et Coutumes du Cambodge . . . . . *par M. CHAP-PIN 568*

NOTES ET CHRONIQUES:

— Voyage de la Commission religieuse Camdodgienne dn Birmanie . . . . . *par Vénérable VANN-SADUM 588*

— Voyage de la Délégation Cambodgienne à la conférence Bouddhique de Boddhagaya . *par M. CHAP-PIN 598*

Prix d'abonnement annuel (comprenant 12 numéros) 230$00

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា

ព្រះគ្រូសង្ឃសត្តា ប៊ុណ្យ-សុម្ពាជ ធម្មរាម:
សាស្ត្រាចារ្យនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅភ្នំពេញ,
សមាជិកផ្លើយឆ្ងងនៃសាលាថាភ៌ាងសែសប៊ែកបុងប្លូកាំប្រទេស,
សមាជិកនៃគណៈកម្មការវិប្បធម៌ខ្មែរ បានតែងជាភាសាថាភ៌ាង
លោក ទៀង-តៃ-ឈុន ក្រមការជើមខ្សែ ប្រែជាភាសាខ្មែរ
(ត-ចប់)

នៅក្នុងសាលានោះគ្រែតែបង្រៀនភាសាថាលី មានបង្រៀនចំណេះវិជ្ជាឯទៀតមួយពេលៗ ។ ព្រះសង្ឃដែលបានចំពេញចំណេះវិជ្ជា ចំនួន ៤ ឆ្នាំរួចហើយ ។ បានសញ្ញាប័ត្រសាលាថាលីជាន់ខ្ពស់នោះ មានចំនួនច្រើនពាន់អង្គទៅហើយ ។ សាលាថាលីជាន់ខ្ពស់នោះ ដែលមានសមណសិស្សចំនួន ៥០០ អង្គ, ដល់មកឆ្នាំនេះបានផ្លាស់ឈ្មោះជា "ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត" តាមព្រះរាជបញ្ជត្តិ ។ បន្ទាប់មកទៀត នៅក្នុង គ.ស. ១៨២៩ ព្រះរាជវង្សាគិចាលបានបង្កើតព្រះរាជបណ្ណាល័យ ហើយនឹងមន្ទីរពុទ្ធសាសនបណ្ឌិត្យ នៅក្នុង គ.ស. ១៨៣០ ដោយស្នាដៃនៃនាងកញ្ញា "ស. កាប៉ាលែស" ជាសមាជិកនៃសាលាថាភ៌ាងសែសបុងប្លូកាំប្រទេស ។ តមកទៀត បានបង្កើតមន្ទីរត្រួតដំនុំព្រះវិត្តបិដក ដែលមានព្រះសង្ឃអ្នកមានចំណេះវិជ្ជាយ៉ាងជាលេដ្ឋ ឲ្យបាប់ប្រែគ្នាភាសាថាលី មកជាភាសាខ្មែរ ។ ការប្រែព្រះវិត្តបិដកភាសាថាលីមកជាភាសា

ខ្មែរនោះ ចាប់ផ្តែរនៃយើងជាកជាមុន, ក្នុងការផ្តែរនេះមានយកសៀវភៅ
ចាលីអក្សរកូមា ទំនើសៀវភៅចាលីអក្សរសៀម ដែលគេចោះផ្សាយរួច
ហើយ មកប្រៀបធៀបនឹងគម្ពីរអក្សរខ្មែរផងដែរ ដើម្បីពិនិត្យផ្ទៀងផ្ទាត់
ឲ្យត្រឹមត្រូវម៉ត់ចត់ ហើយចោះពុម្ពផ្សាយក្នុងព្រះរាជអាណាចក្រគាំង
មូល ត្រមាំងផ្សាយទៅក្នុងប្រទេសជាំងឡាយខ្លះដែលកាន់ព្រះពុទ្ធ-
សាសនាដូចគ្នា ។

ដល់មកឆ្នាំ ១៩៣៣ គេបានបង្កើតសាលាចាលីឯកនៅវត្តទីក្រុង
ទំនើខែត្រក្រៅចំនួន ៤០០ សាលា ស្ទើរតែគ្រប់វត្ត ហើយមានសមណ-
សិស្សជាង ២ ០០០ អង្គ បានបំពេញចំណេះវិជ្ជាគ្រប់ ៣ ឆ្នាំ រួចបាន
ទទួលសញ្ញាប័ត្រសាលាចាលីឯង ។ សាលាចាលីឯងនោះបំរុងនឹង
ផ្លាស់ទៅជាសាលាបឋមសិក្សាចាលីវិញ ។

ក្រៅយបង្អស់គេបានបង្កើតសាលាធម្មវិន័យនៅគ្រប់វត្ត ក្នុងព្រះ
រាជអាណាចក្រកម្ពុជា ដើម្បីបង្រៀនតគ្គុសាមណេរតាំងពីសាស់តាំងក្មេង
ជាការចាំបាច់ ។

ក្នុងឆ្នាំ ១៩៥៥ គេបានឃើញគ្រឹះស្ថានមួយទៀតទ្រង់ទ្រាយធំនៅខាងមុខ
ព្រះបរមរាជវាំង ហៅថា "ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ" ដែល
គេបានសម្រេចនឹងបង្កើតតាំងពីឆ្នាំ ១៩៥៤ នោះមក ។ មហាវិទ្យាល័យ
ថ្មីនេះ នឹងបើកឲ្យតែនិស្សិតដែលមានសញ្ញាប័ត្រមធ្យមវិជ្ជាខាងព្រះពុទ្ធ-
សាសនា ឬ អ្នកដែលមានសញ្ញាប័ត្រដូចម្តេះស្មើគ្នា ទើបចូលរៀនបាន ។

ព្រះកុណាជាអម្ចាស់ជីវិតលើត្បូងជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។

ព្រះមហាក្សត្រ នរោត្តម - សីហនុ វរ្ម័ន ដែលសព្វថ្ងៃបានទទួលតំណែង
ជាសម្តេចព្រះឧបយុវរាជ បានដាក់ពាក្យសម្ពត្តិ ហើយថ្វាយពាក្យនោះ
ចំពោះព្រះវរោជបិតានឹងព្រះវរោជជននីនាថ ខ្ញុំស្នើយកពាក្យសម្ពត្តិគឺ
ព្រះអង្គមក ។ កាលសម្តេចខ្ញុំសោយពាក្យនៅឡើយ ខ្ញុំគ្មានអារម្មណ៍
អាល័យបានខ្ញុំយាងចុះពីព្រះពាក្យបល្ល័ង្ក ទៅបំពេញអគ្គិនេស្ក្រមអស់វារៈ ៣ ខែ គឺ ១ វស្សា ។ ខ្ញុំបានលើកទឹកចិត្តព្រះសង្ឃនឹងលើក
តម្កើងសាសនាឲ្យបានរុងរឿងឡើង ហើយថែមទាំងបំណាយព្រះពាក្យ-
ខ្ញុំឲ្យផ្ទាល់ព្រះអង្គ ដើម្បីកសាងសាលាខាងពុទ្ធចក្រនឹងខាងអាណា-
ចក្រទៅក្នុងព្រះពាក្យអាណាចក្រទាំងមូល ។ ពុទ្ធិកមហាវិទ្យាល័យដែល
បានថ្មីនេះមក ហើយនោះ ក៏ជាស្នាព្រះហស្តនៃព្រះអង្គជាដើមគំនិត
ព្រមទាំងខ្ញុំបានចូលព្រះពាក្យកសាងផង ទើបមហាវិទ្យាល័យនេះ
មានឈ្មោះថា "ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពាក្យ" ។

ការស្ថាបនានឹងសង្កេតការខាងលើទាំងប៉ុន្មាននេះ នាំឲ្យមានប្រយោជន៍
ដ៏ពិសេសដល់ព្រះពុទ្ធសាសនា ហើយនឹងនាំសមាជិកនៃគណៈសង្ឃឲ្យ
បានចំរើនចំណេះវិជ្ជាស្មើៗគ្នា ហើយនឹងឲ្យព្រះសង្ឃទាំងនោះកាន់ពុទ្ធ
បញ្ញត្តិត្រឹមត្រូវ តាមដែលព្រះបរមគ្រូនៃយើងសំដែងពុកមក ។ តាំងពី
ពេលនេះទៅ គណៈព្រះសង្ឃគ្មានខ្វែងគំនិតគ្នាពីរឿងពាក្យប្រៀនប្រដៅ
ឡើយ មានតែសេចក្តីស្រឡាញ់ និងចំរើនទៅអនាគតកាល ។

ក្រៅពីស្ថាបនាការ ដែលបានរៀបរាប់ខាងលើរួចមកហើយនោះ
មានបន្ថែមសមាគមពីរទៀត ហៅថា:

— សមាគមមិត្តសាលាបាលី;

— ពុទ្ធិកសមាគមពិភពលោក ។

សមាគមទី ១ សម្រាប់លើកទឹកចិត្តព្រះសង្ឃ ដើម្បីឲ្យរំលំពេញចំណេះវិជ្ជា ជាភាសាបាលី ភាសាជាតិឬក៏ភាសាបរទេស ។ ចំណែកខាងសមាគមទី ២ សម្រាប់ធ្វើការទាក់ទងពីរឿងព្រះពុទ្ធសាសនាក្នុងសកលលោក ។

ប្រជាជាតិខ្មែរធ្លាប់ធ្វើពិធីបុណ្យ ដែលត្រូវតាមព្រះពុទ្ធសាសនាចាំង ១២ ខែ ក្នុងមួយឆ្នាំ ។ ឯពិធីបុណ្យដែលមានឈ្មោះជាងគេនោះគឺ៖

១.— បុណ្យចូលឆ្នាំ ធ្លើនៅថ្ងៃ ១៣ - ១៤ - ១៥ ខែមេសា ។ នៅគ្រាសចូលឆ្នាំថ្មីនោះ គេមានធ្វើពិធីបុណ្យ "តូចក្នុងព្រឹប" ជាតំណាង "ព្រះចូឡាមណីចេតិយ" ដែលដំកល់ព្រះកេសានៃព្រះសម្ពុទ្ធកាលព្រះអង្គយាងចេញចាកមហាចក្កាសាទទៅទ្រង់ព្រះផ្នួស ។

២.— បុណ្យវិសាខបូជា ធ្លើក្នុងខែឧសភានៅក្នុងព្រះបរមរាជវាំង ហើយទីឯកន្លែងវត្តចាំងអស់ ក្នុងព្រះរាជអាណាចក្រកម្ពុជា ។ បុណ្យនេះជាបុណ្យឧបនៃកំណើតព្រះសម្ពុទ្ធ ដែលទ្រង់ប្រសូត, ទ្រង់ត្រាស់ដឹងនូវសម្មោធិញ្ញាណ ទ្រង់ចូលព្រះបរមនិព្វាន ។ ប្រទេសដទៃដែលកាន់លទ្ធិព្រះពុទ្ធសាសនាតែងធ្វើបុណ្យនេះដែរ ។

៣.— បុណ្យប្រត់ព្រះនង្គ័ល គេធ្លើនៅថ្ងៃ ៤ រោជ ខែវិសាខ (ឧសភា) នៅក្រុងភ្នំពេញ ។ បុណ្យនេះធ្លើតាមទម្លាប់ពីបុរាណ ដើម្បី

រុំព្រះកេសធាតុនៃព្រះបាទសុទ្ធោទនៈ ដែលត្រូវជាព្រះបរមពុទ្ធបិតា នៃព្រះសម្ពុទ្ធ កាលដែលទ្រង់នាំព្រះសិទ្ធត្ថៈកុមារទៅកាន់ពិធីបុណ្យច្រត់ ព្រះនង្គ័លនោះ ។

ក្នុងពិធីបុណ្យនោះ គេឃើញមានអ្នកតំណាងព្រះពុទ្ធម្នាក់ (ស្តេចមាយ) កាន់យាមនង្គ័ល ដែលមានលក្ខណៈជានិម្មិតរូប ហើយក្បួន ៣ ជុំ លើដីមួយកន្លែងដែលគេសន្មតជាព្រៃស្រែ ។ នៅខាងក្រោយស្តេចមាយនោះ មានស្ត្រីមួយនាក់ស្ទុះកាត់សំពត់សម្រាប់ពិធីបុណ្យ ដើរតាមមុខស្ត្រីឯទៀតដែលតាមហែហម ហើយសាបព្រោះកន្លែងដែលទើបទំនប់ក្បួនច្បាំ ។ ពិធីបុណ្យនេះជាសញ្ញានៃការភ្ជួរស្រែចម្ការនៅក្នុងព្រះពុទ្ធអាណាចក្រកម្ពុជាទាំងមូល ។

៤.— ប៉ុណ្ណេះបំប្លួសនាគ គេធ្វើនៅប្រទេសកម្ពុជា ក្នុងខែទាំងឡាយគ្រប់រដូវ លើកតែ ៣ ខែដែលចូលវស្សាចេញ តែចំណែកខាងព្រះពុទ្ធវង្សនុវង្ស ត្រាប់ធ្វើបុណ្យនេះមុនថ្ងៃចូលវស្សាមួយថ្ងៃ ។ បព្វជ្ជាបេក្ខៈខាងព្រះពុទ្ធវង្សនុវង្ស ទើបបព្វជ្ជាបេក្ខៈខាងគ្រួសារមន្ត្រី ដែលមានស័ក្តិរាស្ត្រសន្តស់ ហើយដែលសុំអនុញ្ញាតបួសនោះ ត្រាមអធិបតីភាពនៃព្រះកុរណាជាអម្ចាស់ដីតែលើតួន ត្រូវមានចំនួនតែ ១២ នាក់ឯ៉ង ច្រើនបំផុត ។ គេនិមន្តព្រះសង្ឃមកចំរើនព្រះបរិត្តចំពោះបព្វជ្ជាបេក្ខៈទាំងនោះនៅពេលល្ងាច ។ លុះព្រឹកឡើងនាគទាំងអស់ដើរជាក្បួនដង្ហែទៅវត្ត ។ ដោយហេតុថាព្រះសម្ពុទ្ធជាក្សត្រ ហើយទ្រង់ចេញពីជាតិក្សត្រនោះទៅ ដើម្បីស្រោចស្រង់សត្វលោក គួរតែក្បួនដង្ហែនាគនោះ

មានទំនងជាក្បួនដង្កែស្តេច បើប្រៀបធៀបជាអាចនឹងធ្វើបាន ។ នៅកន្លែងក្បួនដង្កែនោះ មានក្មេងនឹងអ្នកវាយស្គរ មានប្រុស-ស្រីកាន់ដើងពានប្រាក់ ដែលមានជាក់ស្តែង ប៉ុន្តែ ទឹងខ្ញុំនឹងជួប តុបតែងលំអដើរពីមុខនាគដែលស្មៀកពាក់ដូចព្រះអង្គម្ចាស់ពីដើម ហើយដែលជិះសេះមានចាំងភ្លឺយ៉ាងធំផង ។

បន្ទាប់មក នាគចាំងអស់ដើរចូលទៅក្នុងព្រះវិហារ ហើយអុជខ្ញែនទឹងជួប រួចក្រាបថ្វាយបង្គំព្រះពុទ្ធរូប ។ តពីនេះទៅនាគនោះដើរឆ្ពោះទៅមុខទៅបដ្ឋាយ៍ដែលមានព្រះសង្ឃចំនួន ២០ អង្គ ហើយក៏សុំបួស ។

៥.— ប៊ុណ្យប្រលឹសប្បា មានទៅប្រទេសកម្ពុជា ដូចជាប្រទេសដែលកាន់លទ្ធិព្រះពុទ្ធសាសនាដែរ ។ ព្រះសង្ឃត្រូវសម្រាកចំនួន ៣ ខែជាដំបូងក្នុងវត្តក្បែរ ។ នៅឧកាសបុណ្យនោះ ក្នុងវត្តនីមួយៗត្រូវមានអុជខ្ញែនវិស្សាដែលគេយកឈើមកធ្វើបំពង់លាបពណ៌ ទឹងតុបតែងលំអ ហើយគេចាក់ក្រមួនក្នុងបំពង់នោះដុំវិញប្រទេះ ។ ដួងណាខ្ញែនវិស្សានោះគេធ្វើពីក្រមួនសុទ្ធតែម្តង ហើយមានទំហំប៉ុនពីរជាប់កំពស់ព័រហត្ថ ។

នៅក្នុងព្រះបរមកដកាំង ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឬសមាដិកនៃព្រះពជវង្សានុវង្ស អុជខ្ញែនវិស្សា ៤ ដើមដោយៗឡាវ៉ែក ។ ខ្ញែនទី ១ អុជទុកក្នុងហោព្រះ ក្នុងព្រះបរមកដកាំង ។ ខ្ញែនទី ២ អុជក្នុងហោព្រះអដ្ឋកន្លែងទីនាំងទេវរាជនិច្ចយ ដែលមានកោដ្ឋព្រះធាតុនៃព្រះ

ពាជវង្សានុវង្ស ។ ខៀនទី ៣ អុជទុកក្នុងហោព្រះខ័នពាជ្យ ។ ខៀនទី ៤ អុជទុកនៅក្នុងព្រះវិហារព្រះកែវមរកត ។

ក្រៅពីនេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឆានត្រាស់បង្គាប់ឲ្យនាំខៀនវស្សាទៅដាក់វត្តនៅក្នុងទីក្រុង ទឹងវត្តជិតខាង ។ ចំនួនខៀនវស្សាព្រះពាជទ្រព្យចាំងអស់ ១៩ ដើម ។

មុនថ្ងៃចូលវស្សា គឺនៅថ្ងៃពេញបូណ៌មីខែអាសាធ ការអ៊ូអរតែងមាននៅគ្រប់វត្តចាំងអស់ ។ នៅពេលព្រលប់គេធ្វើពិធីដង្ហែខៀនវស្សាជាមួយទឹងសាជកសម្រាប់ព្រះសង្ឃស្រង់ទឹក ហើយទឹងបរិក្ខារផ្សេងៗផង ។

៦.— បុណ្យភ្ជុំបិណ្ឌ ធ្វើនៅគ្រប់វត្តចាំងអស់ចំនួន ១៥ ថ្ងៃ គឺចាប់តាំងពីថ្ងៃ ១ រោជដល់ថ្ងៃ ១៥ រោជ ខែភទ្របទ (កញ្ញា) ដើម្បីឧទ្ទិសចំពោះញាតិសន្តាន ដែលបានអនិច្ចកម្មបាត់ទៅហើយ ។

ព្រះបាទយសោវរ្ម័ន ដែលសោយរាជសម្បត្តិពី គ. ស. ៨៨៩ ដល់ ៩១០ (នៅអង្គរ) បានចារឹកទុកថា ព្រះអង្គបានប្រគេនចង្ហាន់រៀងរាល់ខែ ដល់ព្រះសង្ឃគង់នៅក្នុងកុដិជាច្រើន ដែលធំបានតសាង ដើម្បីឧទ្ទិសដល់មនុស្សស្លាប់ក្នុងចម្បាំង ទឹងព្រលឹងមនុស្សដែលគេចោះបង់ចោល ។

ក្រៅពីបុណ្យដែលបានរៀបរាប់ខាងលើនេះ មានបុណ្យផ្សេងៗឯទៀតៗ ជាច្រើន ដូចជាបុណ្យចេញវស្សា, បុណ្យកឋិន, បុណ្យសំពះព្រះខែ (អកអំបុក) ។ល។ បុណ្យទាំងនោះមានរបៀបធ្វើខុសគ្នាបន្តិចៗ ដោយមានបុណ្យខ្លះធ្វើតាមរបៀបសាសនាព្រាហ្មណ៍ តែការបញ្ចូល

ទម្លាប់សាសនាព្រាហ្មណ៍យ៉ាងនេះ មិនអាចនាំឲ្យផុយគ្នានឹងច្បាប់ព្រះសម្ពុទ្ធឡើយ ។

នៅប្រទេសកម្ពុជា សាសនាព្រះពុទ្ធបានរុងរឿងលូតលាស់យ៉ាងប្រសើរណាស់ ដោយគេបានកសាងវត្តខឹងសាហាថ្កាលីជាច្រើន នៅទីរួមខែត្រខ្លះក្នុងប្រទេសកម្ពុជាឯកពាជ្យ ។ តាំងពីយូរណាស់មកហើយ បុណ្យពុទ្ធាភិសេកខ្ពង់ (បុណ្យវិសាខបូជា) គេធ្វើជាដរាបនៅតែប៉ាវែវត្ត តែកាលពីខែតុលា គ.ស.១៩៥២ នៅពីក្រុងភ្នំពេញ គេបានរៀបចំធំបុណ្យនេះ ដើម្បីទទួលព្រះសារីរិកធាតុព្រះសម្ពុទ្ធ ទឹងព្រះអរហន្តធាតុនៃព្រះអគ្គសាវ័កទាំងពីរព្រះអង្គ គឺព្រះសារីបុត្រ ទឹងព្រះមោគ្គល្លាន ។ ពិធីបុណ្យនេះ គេធ្វើទៅតាមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទឹងសម្តេចសង្ឃនាយកទាំងពីរគណៈ ព្រមទាំងវរជនបរទេសដែលកាន់លទ្ធិព្រះពុទ្ធសាសនាដែរ ។ រួចពីនោះមក គេបានសង់ចេតិយមួយយ៉ាងខ្ពស់ត្រដឹម កណ្តាលក្រុងភ្នំពេញ ដើម្បីបញ្ចុះព្រះសារីរិកធាតុទឹងព្រះអរហន្តធាតុនោះ ទុកជាទីលឹកគោរពបូជាតទៅអនាគតកាល ។ ក្នុងរឿងនេះ យើងសូមបំភ្លឺដល់អ្នកអានថា បុណ្យសម្ពោធពុទ្ធសកពាជគម្រប់ ២.៥០០ ព្រះវស្សា ដែលធ្វើទៅក្នុងប្រទេសផ្សេងៗ មានកំណត់ពេលវេលាខុសពីគ្នា ដូចយ៉ាងនៅប្រទេសឥណ្ឌា, កោះសីលង្កាទឹងភូមា សម័យដែលត្រូវធ្វើបុណ្យនេះនៅដើមឆ្នាំមុន, តែនៅប្រទេសសៀម, កម្ពុជា, លាវ ទឹងយៀកណាម បុណ្យនេះគេធ្វើនៅចុងឆ្នាំក្រោយ ។ ហេតុដូច្នេះ បានជាកាលបរិច្ឆេទនោះខុស

តាមួយឆ្នាំ គឺប្រទេសឥណ្ឌា គោរសេរីលង្កាទឹងភូមា ត្រូវធ្វើពិធីបុណ្យ
នេះនៅថ្ងៃ ២៤ ឧសភា គ. ស. ១៩៥៦ ចំណែកប្រទេសអាស៊ីភាគ
អគ្នេយ៍ ដែលបានរៀបចំខាងលើរួចមកហើយនោះ ត្រូវធ្វើបុណ្យ
សម្ពោធពុទ្ធសកពជគម្រប់ ២.៥០០ ព្រះវស្សានៅថ្ងៃ ១៣ ឧសភា
គ. ស. ១៩៥៧ ។ យើងមានសេចក្តីស្តាយជាទីបំផុត ចំពោះការ
ដែលកំណត់ធ្វើបុណ្យខាងលើនេះខុសគ្នាមួយឆ្នាំដូច្នេះ, រឿងនេះបើ
តាមយោបល់យើងយល់ថា មានតែអ្នកជ្ញាខាងព្រះពុទ្ធសាសនានៅ
ប្រទេសខ្លះទេ ទើបវិនិច្ឆ័យបាន ។

ម្យ៉ាងទៀត យើងសូមរំលឹកថា នៅឧកាសពាក់កណ្តាលសកពជ
នៃព្រះពុទ្ធសាសនា យើងត្រូវធ្វើបុណ្យឧបនោកងទឹក្រងណា ដែលមាន
សង្ឃចេតិយបញ្ចុះព្រះសារីរិកធាតុព្រះពុទ្ធ ។ យើងសូមទទួលអំណរ
គុណដ៏ជ្រាលជ្រៅចំពោះសមាគម "មហាពោធិ" នៅប្រទេសឥណ្ឌា
ដែលបានអញ្ជើញមកជាកិត្តិយស ជួយឧបត្ថម្ភដល់ពិធីបុណ្យទទួលព្រះ
សារីរិកធាតុនេះឥឡូវ ๑๙๕๒ ។ ដើម្បីជាអនុស្សាវរីយ៍ចំពោ ព្រះសារីរិក-
ធាតុដែលបានស្តេចមកគាន់ប្រទេសកម្ពុជានោះ គេបានសាងព្រះចេតិយ
๑ យ៉ាងស្អាតល្អក្រងក្នុងភ្នំគោញ ហើយគេបម្រុងនឹងធ្វើបុណ្យសម្ពោធទុក
ជាទីគោរពបូជាតទៅអនាគត ។ យើងសង្ឃឹមថា គង់មានឧកាសណាមួយ
យើងនឹងបានទទួលព្រះសារីរិកធាតុជាពិសិដ្ឋអំពីប្រទេសឥណ្ឌា ឬកោះ
សេរីលង្កាឬក៏ប្រទេសភូមាមកបញ្ចុះក្នុងព្រះចេតិយនោះជាមិនខាន ។

នៅទីបំផុតនេះ សូមបញ្ចប់សេចក្តីថ្លែងការណ៍ខាងលើ ហើយសូមប្រសិទ្ធីពរចំពោះពិធីបុណ្យសម្ពោធពុទ្ធសកលជគម្រប់ ២.៥០០ ព្រះវស្សា ដែលជាគោលចារិកនៃព្រះពុទ្ធសាសនា ហើយដែលនាំឲ្យបានសេចក្តីសុខក្សេមក្សាន្តក្នុងអនាគតកាល ។

បុព្វណាសុភាសិត

១ - មនុស្សដែលស្វែងរកគោគ្ឃៈ ដោយល្បែងស៊ីសង

២ - មនុស្សដែលស្វែងរកកិត្តិយស ដោយជាក់ខ្លួនឲ្យអ្នកជាខែប្រើប្រាស់តាមត្រូវការ

៣ មនុស្សដែលស្វែងរកសេចក្តីសប្បាយ ដោយធ្វើជាសមយោចក

៤ - មនុស្សដែលប្រព្រឹត្តចំពោះមជីវិតដោយចោរកម្ម ។

បុគ្គលទាំង ៤ ពួកនេះ ជាមនុស្សពាលអាប់ឥតប្រាជ្ញ ត្រូវខ្ជួលខ្ជូវសេចក្តីវិនាសក្នុងអនាគតជាប្រាកដ ។

បញ្ញាកថា

ព្រះមហាធម្មសាមិ ឈឹម-សាមី រៀបរៀង

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

លំដាប់នេះ សូមសំដែងអំពីដើមកំណើតនៃបញ្ញា និងហេតុផលដែលនាំឲ្យកើតបញ្ញា ជាសេចក្តីសង្ខេបដូចមានតទៅនេះ:

ធម្មជាតិណាដែលសម្រាប់ដឹងដោយប្រការៈទាំងពួង ធម្មជាតិនោះហៅថា បញ្ញា ដូចមានវិគ្គហៈថា សព្វប្បការេន ជានាតីតិ បញ្ញា: ប្រែថា (ធម្មជាតិណា) ដឹងដោយប្រការសព្វគ្រប់ (ធម្មជាតិនោះ) ឈ្មោះថា បញ្ញា ។ បញ្ញានេះ បើពណ៌នាតាមគម្ពីរវិសុទ្ធិមគ្គ ត្រង់បញ្ញានិទ្ទេស យើញថាមានសេចក្តីពិស្តារជាលក្ខណៈពន្យល់ច្រើនណាស់ ហេតុនេះ សូមពណ៌នាចេះយកតែសេចក្តីណា ដែលមានខ្លឹមសារគួរដល់ការប្រតិបត្តិរបស់សាធុជន ។ ក្នុងសេចក្តីនេះ នឹងសូមពណ៌នាតែអំពីហេតុផល និងលក្ខណៈរបស់បញ្ញាដោយសេចក្តីសង្ខេប :

ហេតុដែលនាំឲ្យកើតបញ្ញាមាន ៨ យ៉ាង គឺ

១ — អាបរិយគារៅ	ការគោរពចំពោះអាចារ្យ
២ — បរិបុច្ឆកតា	ការឆ្លើយសេចក្តីសាកសួរ
៣ — ឱបរិតិ	ការវៀរចាកចោទ
៤ — សីលសំវរោ	ការសង្រួមក្នុងសីល

៥ - ពាហុសច្ចំ សេចក្តីចេះដឹងក្នុងផ្លូវលោកផ្លូវធម៌

៦ - វិរិយារម្ភោ ការព្យាយាមយ៉ាងតឹង

៧ - សតិ ការចងចាំច្រើន (ស្មារតី)

៨ - បញ្ញា ការដឹងការស្គាល់ដោយល្អ ។

សូមអធិប្បាយមួយម្តង ។ ដូចតទៅនេះ ៖

ការគោរពបំពោះអាចារ្យ គឺការយកចិត្តទុកដាក់ផ្គត់ផ្គង់ធ្វើបំរើបំពោះគ្រូអាចារ្យ ព្រោះថាបើសិស្សគោរពអាចារ្យ។ តែងទំបង្ហាត់បង្រៀនដល់សិស្ស ទាំងអនុគ្រោះពន្យល់សិស្សឲ្យបានចេះដឹងច្រើន ដែលជាហេតុឲ្យសិស្សកើតមានប្រាជ្ញា ។

ការធ្វើសេចក្តីសាកសួរ គឺការប្រតិបត្តិសិក្ខាស្ថាលំពោះលោកអ្នកចេះដឹងច្រើន ហើយបើឆ្ងល់ហេតុត្រង់ណាមួយ ត្រូវសាកសួរលោកដើម្បីផ្តិតយក ឬចម្ងល់យកចំណេះអំពីលោក ។

ការវៀរចាកបាប គឺការលះបង់អំពើអាក្រក់ឲ្យស្រឡះ ដើម្បីធ្វើចិត្តរបស់ខ្លួនឲ្យរង់ថ្លាស្អាតបរិសុទ្ធល្អ ដើបសេចក្តីធ្វៀរធ្លាសកើតមានឡើង ព្រោះមិនមានអំពើលាមកអាក្រក់ បញ្ញារមែងកើតឡើងបាន ។

ការសង្រួមក្នុងសីល គឺការរក្សាកាយ - វាចា - របស់ខ្លួនឲ្យតាំងនៅក្នុងសេចក្តីរៀបរយបរិសុទ្ធិ ម៉ត់ម៉ង ដើម្បីធ្វើឲ្យកើតមានសេចក្តី

អង់អាច មានឥទ្ធិឫទ្ធិកន្ធឹកច្រើនជុំវិញខ្លួន បញ្ជាមែងកើតឡើងដោយសេចក្តីភ្ញៀវភ្ញាន់ ។

សេចក្តីចេះដឹងក្នុងផ្លូវលោកផ្លូវធម៌ គឺការចេះស្តាប់ស្តាត់ឮឃ្នាតស្តាប់ពាក្យច្រើនពាក្យតន្យល់រឿយៗ ញឹកញាយៗ ដើម្បីឲ្យការចេះដឹងកើតមានក្នុងខ្លួនសព្ភាវៈរបស់ខ្លួនច្រើនឡើងៗ ។

ការព្យាយាមយ៉ាងតឹង គឺការចេះស្វាធ្យាយព្យាយាមស័ក្តា ឥតឲ្យព្យាយាមស្តាប់ត្រិះរិះគិតត្រាតែចូលចិត្តប្រាស់ណាស់មិនមានបន្ទុយបន្ទុយព្យាយាម ។

ការបងបាំប្រើន (ស្មារតី) គឺការតាំងស្មារតីបងចំពាំមាំមួនខ្ជាប់ខ្ជួនល្អជាដើម ។

ការដឹងឮស្តាល់ដោយល្អ គឺការស្តាល់ឮការចេះដឹងអ្វីពាំនាំពួនដោយល្អ គឺចេះអ្វីចេះច្បាស់ ដែលហៅថា "សុបញ្ញា" ឬ "សុវិជ្ជា" ។

បញ្ញានេះឯង បើសំដែងតាមលក្ខណៈ មានពីរយ៉ាងគឺ

๑ - ឆេទនលក្ខណបញ្ញា ប្រាជ្ញាមានកិរិយាកាត់ផ្តាច់ខ្លួនសេចក្តីសង្ស័យងឿងឆ្ងល់ចេញបានជាលក្ខណៈ ។

๒ - ឱភាសលក្ខណបញ្ញា ប្រាជ្ញាមានកិរិយាភ្លឺស្វាងអាចកំចាត់បង់ខ្លួមខ្លួលគ្រប់យ៉ាងមានអវិជ្ជាជាដើម ជាលក្ខណៈ ។

តអំពីនេះទៅ សូមសំដែងអំពីពន្ធុស្មើនៃប្រាជ្ញា ដូចតទៅនេះ:

ធម្មបញ្ញាសមាភា

"ពន្ធឹងាំងឡាយស្មើដោយពន្ធឹគឺជ្ញាមិនមានឡើយ" ។ ពន្ធឹងាំងឡាយក្នុងលោក មានពន្ធឹព្រះអាទិត្យ ព្រះចន្ទនិងពន្ធឹអគ្គិសនីជាដើម សម្រាប់តែភ្លឺតែកែកបស់ជនាន្តជនងាំងពួង ឲ្យយើញបានតែប្លែកផ្សេង ។ ប៉ុណ្ណោះ ពុំអាចនិងឲ្យយើញដល់ហេតុនិងផលងាំងពួងក្នុងលោកនេះនិងលោកខាងមុខបានឡើយ ។ ឯពន្ធឹគោលគឺបញ្ញាអាចដឹកនាំសន្តានចិត្តរបស់ជនងាំងពួងឲ្យយើញនូវហេតុនិងផលក្នុងលោកងាំងពីរបាន ។

ហេតុដូច្នោះ បញ្ញាទើបឈ្មោះថាជារតនៈរបស់ចិត្ត គឺជាពន្ធឹរបស់ចិត្ត អាចដឹកនាំចិត្តឲ្យពិចារណាយើញថា. របស់នេះជាហេតុនៃសេចក្តីសុខ. របស់នេះជាហេតុនៃសេចក្តីទុក្ខជាដើម ។ ឧទាហរណ៍ដូច ការប្រព្រឹត្តិសុចរិតគឺមត្តែវល្អ ជាហេតុនៃសេចក្តីសុខ; ការប្រព្រឹត្តិទុច្ចរិតអាក្រក់ ជាហេតុនៃសេចក្តីទុក្ខជាដើម ។ ពន្ធឹគឺបញ្ញានេះឯង អ្នកហ្លាជ្ញាងាំងឡាយសរសើរថា ជាពន្ធឹយ៉ាងឆ្នើម ជាងពន្ធឹដែលមានទៅក្នុងលោក ។

ក្នុងលោកយើងនេះ របស់ម៉ូសុទ្ធសឹងតែតមកអំពីហេតុ ឯហេតុនោះមានច្រើនយ៉ាងច្រើនប្រការណាស់ តែក្នុងទីនេះ ពោលតែហេតុ ២ យ៉ាង គឺហេតុនាំឲ្យថោកទាបនិងឲ្យទំលែកគោគសម្បុ ១, ហេតុដែលនាំឲ្យប្លុំប្លើងរុងរឿង នឹងនាំឲ្យបរិបូណ៌គោគសម្បុ ១ ។

អស់លោកអ្នកសប្បុរសងាំងឡាយសឹងជ្រាបមកហើយថា ការនាំឲ្យថោកទាប មកអំពីល្ងង់ខ្លៅជាហេតុ, ការល្ងង់ខ្លៅ មកពីការខ្វៃលប្រអូស មិនស្វះស្វែងប្រឹងប្រែងរកវៀនចំណេះវិជ្ជាសម្រាប់លោកជា

ហេតុ, ការនាំឲ្យទំលក់ក្រគោតសម្ប័ទ មកពីគ្មានចំណេះវិជ្ជាសម្រាប់លោកនឹងការខ្វៃលក្ខអូសគ្មានព្យាយាមជាហេតុ; ការនាំឲ្យក្តុំក្តើនរុនរឿន មកពីការមានចំណេះវិជ្ជាសម្រាប់លោកជាហេតុ; ការនាំឲ្យចរិបូណ៌ដោយគោតសម្បត្តិ មកពីការមានចំណេះវិជ្ជាសម្រាប់លោកជាហេតុផង ប្រកបដោយសេចក្តីព្យាយាមជាហេតុផង ។

ឯចំណេះវិជ្ជាសម្រាប់លោក នឹងគោតសម្ប័ទនោះ ជាហេតុនាំឲ្យសម្រេចប្រយោជន៍បានច្រើនប្រការណាស់ គួយ៉ាងដូចជាកងច្រវែងសន្ទូយ ។ ដែលមានសេចក្តីចំរើនដ៏ធំធូលាយ នឹងល្បីខ្ចរខ្ចាយទៅឯណោះបាននោះ ព្រោះគេមានចំណេះវិជ្ជាសម្រាប់លោក នឹងគោតសម្ប័ទ តេញចរិបូណ៌ហូរហៀរជាហេតុ ។

តាមដែលបានបរិយាយមកនេះ គួរយើញថា "ហេតុ" ជាដើមចមរបស់ផលគឺរបស់ដែលកើតមានឡើង; បើហេតុល្អ ផលដែលកើតឡើងក៏ល្អ; បើហេតុមិនល្អ ផលដែលកើតឡើងក៏មិនល្អ; បើហេតុមិនគាន់មាន ផលក៏មិនអាចកើតឡើងបាន ។ ហេតុជាពូជ ផលជាផ្លែ តើពូជយ៉ាងណា រំលាមានផ្លែក៏យ៉ាងនោះដែរ ។ ដូចមានពុទ្ធភាសិតថា:

យាទិសំ វិប្បតេ ពីជំ តាទិសំ លភតេ ផលំ

"បុគ្គលសាបព្រោះពូជយ៉ាងណា ដល់រំលាបានផលគឺផ្លែក៏រមែងបានយ៉ាងនោះវិញ" ។

ឯហេតុទាំងអស់នោះ អាស្រ័យបញ្ញាចក្ខុទើបមើលឃើញ មិនមែនអាស្រ័យមំសចក្ខុទើបមើលឃើញទេ; ឯក្នែកនុះ គ្រាន់តែនុះឲ្យ

យើញរូបប៉ុណ្ណោះ កាលយើញរូបហើយ ទើបចិត្តសុំៗទៅខ្លួលយកអំពីក្នុក ដើម្បីកត់សំគាល់ឲ្យដឹងថា រូបនេះមានវិញ្ញាណ - ឥតវិញ្ញាណ, ខ្មៅ - ស - ល្អ - អាក្រក់ជាដើម ហើយសោយអារម្មណ៍ផ្សេង ។ ទៅប៉ុន្តែនឹងអាចដឹងដល់ហេតុផលនៃរូបមានវិញ្ញាណ - ឥតវិញ្ញាណ ខ្មៅ - ស - ល្អ - អាក្រក់ជាដើមនោះ ថាមកអំពីហេតុយ៉ាងនេះយ៉ាងនោះពុំបានឡើយ; លុះតែបញ្ញា កើតមានឡើងក្នុងវេលាណា ទើបអាចដេញដោលឲ្យដឹងដល់ហេតុផលក្នុងវេលានេះបាន ។ ហេតុនោះហើយ ទ្រង់ជាអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធដាដើម តែងសរសើរថា បញ្ញាជីវី ជីវិតមាហុ សេដ្ឋិ "អ្នកដែលមានជីវិតរស់នៅដោយប្រាជ្ញា អ្នកប្រាជ្ញតែងថាជីវិតរបស់អ្នកនោះ ប្រសើរបំផុត (ក្នុងលោកនេះ) ។

ដូច្នេះ កាលបើបុគ្គលប្រឹងប្រែបនឹងធ្វើកិច្ចការអ្វីមួយ ដោយកម្លាំងចិត្តតែម្យ៉ាងនោះ មិនអាចនឹងកើតបានទេ; លុះតែប្រកបប្រាជ្ញផង ទើបធ្វើការនោះឲ្យសម្រេចប្រយោជន៍ដ៏ធំធេងបាន អាចឡើងទៅកាន់ឋានៈខ្ពស់ឧត្តមបាន ។

ធម្មទេសនា ដែលសំដែងមកនេះ ក៏ល្មមសមគួរនឹងបញ្ចប់ហើយ មុននឹងបញ្ចប់ សូមឲ្យជាតិ - សាសនា នឹងមហាក្សត្រ នៃទេមរជាតិយើងគាំងនៅក្នុងសេចក្តីសុខចំរើន សព្វប្រការអស់កាលជ័យរៀងទៅ ដោយអំណាចនៃធម្មទេសនានេះ ។

ប្រជុំធម៌ឧបាសក

ប្រស្នាសួរ-ឆ្លើយ

ព្រះទេពសត្ថា កឹម-គ្រីរ៉ូ ចន្ទមង្គលោ

ក្រុមដំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

អារម្ភកថា

បុព្វហេតុដែលនាំឲ្យខ្ញុំរៀបរៀង ប្រជុំធម៌ឧបាសក នេះម្ល៉ឹង ដោយសេចក្តីយល់ឃើញថា ឧបាសកឧបាសិកា ដែលជាអ្នកមានសទ្ធា រក្សាសីលតាមឋានៈតាមជាន់របស់ខ្លួន តុំសូវសម្បូរសៀវភៅជាច្បាប់ សម្រាប់សិក្សាគាន់ធឹងផ្សឹងផ្ទាត់នូវសីលរបស់ខ្លួន បើទុកជាមានខ្លះ ក៏មិនគាន់ធ្លួនល្មមដល់អ្នកត្រូវការសិក្សាដែរ ព្រោះហេតុនោះបានជាខ្ញុំខំ ព្យាយាមដកស្រង់នូវពួកធម៌សម្រាប់ឧបាសកឧបាសិកាប្រតិបត្តិ អំពីគម្ពីរផ្សេង ។ មករៀបរៀង កំណត់ឲ្យឈ្មោះថា ប្រជុំធម៌ឧបាសក ។

ប្រជុំធម៌ឧបាសកនេះ ខ្ញុំយល់ថាមានប្រយោជន៍យ៉ាងសំខាន់របស់ ឧបាសកឧបាសិកា ទុកដូចជាឋានៈសម្រាប់ដឹកតម្រង់ នូវការយកចិត្ត របស់អ្នករក្សាសីល ក៏បាន, ទុកដូចជាទុសឋសម្រាប់កំចាត់កោតគឺកិលេស របស់អ្នករក្សាសីល ក៏បាន, ទុកដូចជាគ្រូយ៉ាងវិសេស សម្រាប់ឲ្យ ចាក់ជាស់តឿនរំឭកឧបាសកឧបាសិកា ក៏បាន ប្រសិនបើមានសៀវភៅ នេះជាប់ដៃខ្លួន ។

ទីបំផុតនេះ សូមឱ្យពុទ្ធបរិស័ទ អ្នកសិក្សាធម៌នេះ បានដល់នូវសេចក្តីសុខសេចក្តីចំរើនជាកំយ្យាភាព. អស់កាលជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាត !

ថ្ងៃទី ៩ វិច្ឆិកា ២៤៩៥
១៩៥២

កិម តូវ

*
* *

១ – ឧបាសកវិធី

សួរ. គ្រហស្ថបែបណា ឈ្មោះថា ឧបាសក ព្រោះហេតុអ្វី ?

ឆ្លើយ. គ្រហស្ថអ្នកដល់នូវសរណៈទាំង ៣ (បើបុរស) ឈ្មោះថាឧបាសក (បើស្ត្រី) ឈ្មោះថា ឧបាសិកា, ដូចព្រះពុទ្ធដីកាដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះមហានាមថា "ម្នាលមហានាម ! គ្រហស្ថណា ដែលបានដល់នូវព្រះពុទ្ធ, ព្រះធម៌នឹងព្រះសង្ឃជាសរណៈ (ជាទីពឹង) គ្រហស្ថនោះ បាននាមថាឧបាសក ; ព្រោះហេតុដែលបានចូលទៅអង្គុយជិតព្រះរត្នត្រ័យ ។

ស. ពាក្យថាឧបាសក ប្រែថា ដូចម្តេច ? បានសេចក្តីយ៉ាងណា ?

ឆ. ប្រែថា "អ្នកចូលទៅអង្គុយជិតព្រះពុទ្ធព្រះធម៌ព្រះសង្ឃ"; បានសេចក្តីយ៉ាងនេះថា : បុគ្គលដែលចូលៈទៅអង្គុយជិតព្រះពុទ្ធព្រះធម៌ទឹងព្រះសង្ឃនោះ មិនមែនចូលទៅអង្គុយជិតជានិច្ចដោយរូបកាយទេ គឺលោកសង្គ្រោះយកនាមកាយជាប្រមាណ សូម្បីបុគ្គលនោះបិតនៅ

កន្លងទីឆ្ងាយក៏ដោយចុះ ឲ្យតែមានសទ្ធានចិត្តប្រតិព្ទជាប់ជោរទន់ទៅរកគុណព្រះត្រៃរ័ត្នជានិច្ច ឬចិត្តនោះទន់ទៅតោងយកគុណព្រះត្រៃរ័ត្នជាសរណៈអស់កាលជានិច្ច ; បុគ្គលនោះឈ្មោះថា ឧបាសក ។

២– សរណៈ:

ស. ពាក្យថា សរណៈ ប្រែថា ដូចម្តេច ?

ឧ. ប្រែថា ការពឹងអង្អែល ឬទីរលឹក ។

ស. បើកុំប្រែដូច្នោះ តើឯប្រែដូចម្តេចបានខ្លះទៀត ? ចូរអធិប្បាយ!

ឧ. ប្រែបានច្រើនយ៉ាង គឺប្រែថា "ជ្រកជ្រៀន, កំចាត់បង់, ដំដែកគោន ត្រឿងការពារ, ត្រឿងគ្រប់គ្រង, រក្សា" ជាដើម ។

អធិប្បាយថា: ពួកសត្វណា ដែលមានសទ្ធានចិត្តទោរទន់ទៅកន្លងគុណព្រះត្រៃរ័ត្នគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលឈ្មោះថាសរណៈ ។ នោះ អាចជ្រកជ្រៀនធ្វើឲ្យវិនាសនូវភ័យ សេចក្តីតក់ស្លុត សេចក្តីទុក្ខ ទុគ្គតិ និងកិលេសរបស់ពួកបុគ្គលនោះបាន ។

ម្យ៉ាងទៀត សរណៈនេះជាឈ្មោះនៃព្រះត្រៃរ័ត្ន ព្រោះថាព្រះពុទ្ធដែលកំចាត់បង់នូវភ័យរបស់ពួកសត្វ, ព្រះធម៌អាចបម្ងំពួកសត្វឲ្យផុតចាកកន្លែង (ផ្លូវឆ្ងាយដាច់ស្រយាល ឬផ្លូវលំបាក) គឺកត, ព្រះសង្ឃអាចធ្វើពួកសត្វឲ្យទទួលនូវផលដ៏ធំធូលាយបាន ។

ពាក្យថា សរណៈនេះ ប្រែបានច្រើនយ៉ាងក៏ពិតមែន ប៉ុន្តែសេចក្តីអធិប្បាយរបស់ពាក្យប្រែទាំងនោះ រួមមកបានសេចក្តីតែមួយ, គួរយ៉ាងដូចមនុស្សមានភេតហើយចូលទៅរកគេទ្យឲ្យព្យាបាល គេទ្យនោះឈ្មោះ

ថាជាអ្នកកំចាត់បង់នូវពេគកំបាន, ឈ្មោះថាជាទីពឹងរបស់អ្នកមានពេគកំបាន; ពុំនោះសោត មនុស្សសត្វត្រូវកំដៅថ្ងៃហើយចូលទៅជ្រកក្នុងម្លប់ឈើ ឬក្នុងផ្ទះ ម្លប់ឈើនឹងផ្ទះនោះ ឈ្មោះថាជាគំកំចាត់បង់នូវកំដៅថ្ងៃកំបាន, ឈ្មោះថាជាទីពឹងរបស់មនុស្សសត្វអ្នកត្រូវកំដៅថ្ងៃកំបានដូច្នេះជាដើមយ៉ាងណាមិញ; ចំណែកខាងព្រះរត្នត្រ័យ ឈ្មោះថាជាគ្រឿងកំចាត់បង់នូវភ័យនឹងសេចក្តីតក់ស្លុតជាដើមរបស់ពួកសត្វកំបាន, ឈ្មោះថាជាទីពឹងពំនាក់របស់ពួកសត្វកំបាន គឺយ៉ាងនោះដែរ ។

๓- សរណាគមន៍

ស. ពាក្យដែលថ្លាប់ហៅថា សរណាគមន៍ ។ នោះ ប្រែថា ដូចម្តេច? ចែកដោយអាការប៉ុន្មានយ៉ាង? អ្វីខ្លះ?

ឆ. ប្រែថា ការដល់នូវសរណៈ ចែកដោយអាការ ៤ យ៉ាង គឺ

๑- អត្តសន្និយ្យាតនៈ ๒- តប្បរាយនៈ

๓- សិស្សភារូបគមនៈ ๔- បាណិបាតៈ ។

ស. បណ្តាអាការទាំង ៤ យ៉ាង ដែលបានពន្យល់មកនេះ តើអាការមួយៗ មានសេចក្តីផ្សេងគ្នាយ៉ាងណាខ្លះ?

ឆ. មានសេចក្តីផ្សេងគ្នាយ៉ាងនេះគឺ

๑- អត្តសន្និយ្យាតនៈ ដល់នូវសរណៈ ដោយការប្រគល់ខ្លួនចំពោះព្រះរត្នត្រ័យ ដូចមានបាលីថា អជ្ជាទិ កត្វា អហំ អត្តានំ ពុទ្ធស្ស (ធម្មស្ស សង្ឃស្ស) និយ្យាទេមិ ខ្ញុំព្រះករុណា សូម

ប្រគល់ខ្លួនចំពោះព្រះពុទ្ធ (ព្រះធម៌ ព្រះសង្ឃ) ចាប់ដើមតាំងពីថ្ងៃនេះ
ទៅ ។

២– តប្បរាយនៈ ដល់ខ្ញុំវិសរណៈ ដោយការយកព្រះពុទ្ធ
ព្រះធម៌ ព្រះសង្ឃទាំងនោះឲ្យជាទីប្រតិត្តទៅកន្លងខាងមុខ ដូចមានបាលី
ថា អជ្ជាទឹ កត្វា អហំ ពុទ្ធបរាយនោ ធម្មបរាយនោ សង្ឃ-
បរាយនោ ឥតិ មំ ជានេបិ ខ្ញុំព្រះករុណា មានព្រះពុទ្ធប្រតិត្ត
ទៅកន្លងខាងមុខ មានព្រះធម៌ប្រតិត្តទៅកន្លងខាងមុខ មានព្រះសង្ឃ
ប្រតិត្តទៅកន្លងខាងមុខ សូមព្រះអង្គទ្រង់ចាំទុកនូវខ្ញុំព្រះករុណា ដូច្នេះបុះ
ចាប់ដើមតាំងពីថ្ងៃនេះទៅ ។

៣– សិស្សភ្រាវៈបគមនៈ ដល់ខ្ញុំវិសរណៈ ដោយការចុះចូល
ធ្វើជាសិស្សនៃព្រះត្តត្រ័យ ដូចមានបាលីថា អជ្ជាទឹ កត្វា អហំ
ពុទ្ធស្ស អន្តេវាសិកោ ធម្មស្ស សង្ឃស្សាតិ មំ ជានេបិ ខ្ញុំព្រះ
ករុណា សូមជាសិស្សនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមព្រះអង្គទ្រង់
ចាំទុកនូវខ្ញុំព្រះករុណា ដូច្នេះបុះ ចាប់ដើមតាំងពីថ្ងៃនេះទៅ ។

៤– បាណិបាតៈ ដល់ខ្ញុំវិសរណៈ ដោយការធ្វើសេចក្តី
គោរពយ៉ាងក្រៃលែង ដូចមានបាលីថា អជ្ជាទឹ កត្វា អភិវាទនំ
បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ពុទ្ធាទីនំយេវ តិណ្ណំ វត្ថុនំ
កវោមិ ឥតិ មំ ជានេបិ ខ្ញុំព្រះករុណា សូមធ្វើនូវការថ្វាយបង្គំដោយ

គោរព នូវការក្រោកឡើងទទួល នូវអញ្ជលិកម្ម នឹងសាមីចិកម្ម ចំពោះ វត្ថុដ៏ស័ក្តិសិទ្ធិទាំង ៣ មានព្រះពុទ្ធជាដើម សូមព្រះអង្គទ្រង់ចាំទុកនូវខ្ញុំ ព្រះករុណា ដូច្នេះចុះ ចាប់ដើមតាំងពីថ្ងៃនេះទៅ ។

ស. អាការទាំង ៤ យ៉ាង ដូចបានពោលមកនេះ បុគ្គលដែលបាន ដល់នូវសរណៈ លុះតែប្រកបគ្រប់ដោយអាការទាំង ៤ នោះ ទើបបាន ឈ្មោះថា ជាអ្នកជាប់សរណគមន៍ ឬ?

ឆ មិនមែនដូច្នោះទេ បុគ្គលដល់នូវសរណៈ ដោយអាការណា មួយក៏បានឈ្មោះថាជាអ្នកជាប់សរណគមន៍ដោយពិត ។

ស កាលជាន់ពុទ្ធសម័យ (សម័យដែលព្រះពុទ្ធកំពុងគង់ព្រះជន្ម នៅ) មានបុគ្គលណាខ្លះ បានដល់នូវសរណៈ ដោយអាការបែបណាខ្លះ? ចូរអធិប្បាយ!

ឆ. កាលជាន់ពុទ្ធសម័យ ព្រះមហាកស្សបត្ថេរ កាលលោកតាំង នៅក្នុងនាមជាបិប្ផលិមាណព បានដល់នូវព្រះពុទ្ធជាសរណៈ ដោយ ការចូលទៅសុំធ្វើជាសិស្ស ហៅថា សិស្សគារវូបគមនៈ ។

កាលអាឡវកយក្ខ (1) ចេញពីស្រុកមួយទៅកាន់ស្រុកមួយ ចេញពីបុរីមួយទៅកាន់បុរីមួយ ក៏តែងនមស្ការចំពោះព្រះពុទ្ធផង ព្រះ ធម៌ផង ព្រះសង្ឃផង ឈ្មោះថាដល់នូវសរណៈ ដោយការយកព្រះ ពុទ្ធ ព្រះធម៌ ព្រះសង្ឃ ប្រតិត្តទៅក្នុងខាងមុខ ហៅថា តប្បរាយនៈ ។

---

1 រឿងនេះ មានសេចក្តីពិស្តារក្នុងអាឡវកសូត្រ គម្ពីរសំយុត្តនិកាយ ។

កាលព្រាហ្មាយុព្រាហ្មណ៍ (១) គ្រោកចាកអាសនៈ ឆ្ពោះសំពត់ឧត្តរាសង្គ (សំពត់បាំងកាយ) ឱនស្មាម្ខាងក្រាបថ្វាយបង្គំទៀបព្រះបាទានៃព្រះដ៏មានព្រះភាគ ដាប់ព្រះបាទាព្រះអង្គដោយមាត់ទាំង ច្រាប់ដោយដៃទាំង ហើយបន្ទុំឈ្មោះរបស់ខ្លួនថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គឈ្មោះព្រាហ្មាយុព្រាហ្មណ៍ដូច្នេះជាដើម ឈ្មោះថា ដល់ខ្លួវសរណៈដោយការថ្វាយបង្គំដោយគោរព ហៅថា ឧបាសក ។

ស. ការថ្វាយបង្គំដោយគោរពដែលមិនកើតជាសរណគមន៍ តើមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

ឆ. មាន ៣ យ៉ាងគឺ ១— ញាតិបាណិបាត: បុគ្គលថ្វាយបង្គំដោយគិតថា ព្រះពុទ្ធជាញាតិរបស់លោកអ្នក ដូច្នេះក៏មិនកើតជាសរណគមន៍; ២— ភយបាណិបាត: បុគ្គលថ្វាយបង្គំដោយភ័យខ្លាចគិតថា ព្រះសមណគោតម ព្រះអង្គមានអានុភាពច្រើន ប៉ុនអម្បាលព្រះមហាក្សត្រិយ៍ម្ចាស់ផែនដីជា កាលបើលោកអ្នកមិនថ្វាយបង្គំ ទ្រង់ទិដ្ឋីនឹងធ្លុះសេចក្តីវិនាសដល់លោកអ្នកមិនខាន ហើយថ្វាយបង្គំទៅ ក៏មិនកើតជាសរណគមន៍ដែរ; ៣— អាចរិយបាណិបាត: បុគ្គលថ្វាយបង្គំដោយគិតថា ព្រះពុទ្ធជាអាចារ្យ កាលព្រះអង្គនៅជាពោធិសត្វបានបង្រៀនសិល្បៈដល់លោកអ្នក លុះព្រះអង្គបានត្រាស់ជាព្រះពុទ្ធទ្រង់បង្រៀនប្រដៅធម៌អាថ៌ដាក់លោកអ្នកទៀត ការថ្វាយបង្គំដោយគិតយ៉ាងនេះ ក៏មិនកើតជាសរណគមន៍ដែរ ។

---

១ មានសេចក្តីស្តារក្នុងព្រហ្មាយុសូត្រ គម្ពីរមជ្ឈិមនិកាយ ។

ស. ចុះថ្វាយបង្គំដោយគតិដូចម្តេច ទើបកើតជាសរណគមន៍បាន ?

ឧ. ថ្វាយបង្គំដោយគតិថា ព្រះភាគ្យជាខត្តិណោយ្យបុគ្គលប្រសើរបំផុតក្នុងលោក ដូច្នេះទើបកើតជាសរណគមន៍ ហៅថា ខត្តិណោយ្យ ភាណិភាគ: ។

៤– ប្រភេទរបស់សរណគមន៍

ស. ប្រភេទរបស់សរណគមន៍ចែកចេញជាប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ក្នុងសរណគមន៍មួយ ។ មានសេចក្តីផ្សេងគ្នាយ៉ាងណា ?

ឧ. ចែកចេញជា ២ យ៉ាងគឺ លោកុត្តរសរណគមន៍ ១ លោកិយ-សរណគមន៍ ១ ; មានសេចក្តីផ្សេងគ្នាយ៉ាងនេះ : សរណគមន៍របស់អរិយបុគ្គលដែលឃើញទូវសច្ច : ទាំង ៤ មានន័យជាអារម្មណ៍ អាចផ្តាច់បង់ទូវឧបក្កិលេសក្នុងខណៈនៃមគ្គ រមែងសម្រេចក្នុងព្រះរត្នត្រ័យបានទាំងអស់ នេះឈ្មោះថា លោកុត្តរសរណគមន៍ ។ ឯសរណគមន៍របស់បុថុជ្ជន ដែលមានពុទ្ធគុណជាដើម ជាអារម្មណ៍ គ្រាន់តែសង្កត់បន្ទោមទូវឧបក្កិលេសប៉ុណ្ណោះ តែមិនអាន់ការផ្តាច់ឧបក្កិលេសបានទៅឡើយ; ម្យ៉ាងទៀត ការបានទូវសទ្ធាមានសេចក្តីជឿជាក់ចំពោះព្រះរត្នត្រ័យមួយ, សម្មាទិដ្ឋិ មានសេចក្តីយល់ឃើញត្រូវដែលមានសទ្ធាជាមូលមួយ, ការធ្វើទិដ្ឋិឲ្យត្រឹមត្រង់ចំពោះបុញ្ញកិរិយាវត្ថុទាំង ១០ មួយ នេះឈ្មោះថា លោកិយសរណគមន៍ ។ (មានត)

ចាឋកកថារឿងពុទ្ធវង្សបុរាណ

ឃុនអត្ថកោវិទ ជា-យ៉ូរ៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែពាក្យស្បូតាវ៉ាំ ដំណាំងសាសនា ឆ្នាំទី ១ ច្បាប់ទី ៦ ភាសាថៃ

(ត្រឹមត)

ព្រោះហេតុដូច្នោះ កន្លងកាលដែលផ្ទាស់មកជាសម័យគុប្ត: គឺតមកពីសម័យគន្ធារៈ ក៏មកដល់សម័យអមរាវតី ប៉ាវព្រះពុទ្ធរូបនៅជាទំរង់ក្រែកគឺប៉ាវជ្រញអង្អាញ់ លុះមកដល់សម័យពាជវង្សគុប្ត: គេមិនចូលចិត្តប៉ាវជ្រញអង្អាញ់ គេធ្វើព្រះពុទ្ធរូបគ្រងប៉ាវស្តើង ឲ្យឃើញខ្លួនច្បាស់ ។ ព្រះពុទ្ធរូបរបស់ក្រែកៈនោះ សូម្បីជាស្នាដៃជាងជាតិក្រែកអ្នកសាងក៏ពិតតែគេអនុលោមតាមតម្រាវណ្ណៈច្រើនយ៉ាងដែរ ដូចពាក្យថា ឯណ្ណា លោមា ភមកន្តុវ ធ្វើព្រះឯណ្ណាលោមនៅរវាងព្រះភ្លុមោ ឯណ្ហាសសីសោ ព្រះកេសាដូចខ្លួនព្រះឯណ្ហ៊ីស (មកុដ) គេខើយធ្វើឲ្យមានព្រះមោលីខ្ទើង ។

លុះមកដល់សម័យគុប្ត: ជាសម័យដែលប្រទេសឥណ្ឌាមានសេចក្តីចំរើនរុងរឿង ដោយសារមានស្តេចផែនដី ១ ព្រះអង្គកន្លងព្រះវង្សនោះ ខ្លួនព្រះនាមថា ព្រះចន្ទគុប្ត: ទី ២ ខ្លួនមានអានុភាពជាពន្លឺកហើយជាស្តេចមួយ ដែលមានកន្លងនិទានរបស់ឥណ្ឌា ហៅថា ព្រះចន្ទវិក្រមាទិត្យ , កន្លងសម័យស្តេចអង្គនេះ ជាសម័យដែលល្បីល្បាញក្នុងឈ្មោះខាងសិល្បវិទ្យា មានកវីឯក ៩ នាក់ ហៅថា នវរតនកវី គាំង

សិល្បកម្មកំតើតឡើងយ៉ាងឋបរិបូណ៌ នៅតាមគុហាវង្គតំផ្សេងៗ គេកំបានសង់ព្រះពុទ្ធរូបទុកនៅខ្លះជាច្រើន ដែលមានឈ្មោះល្បីល្បាញជាងគេ គឺគុហាឈ្មោះអជន្តៈ ក្រៅយអំពីនោះ កំសឹងមានព្រះពុទ្ធរូបដែលមានជាយច័ពរតែម្ខាង ទើងមានជាយច័ពរទាំងសងខាង ជាព្រះសម័យប្រទានពរ សម័យប្រទានអភ័យ ទើងសម័យបឋមទេសនា ដែលមានគ្រូតាយដូចយើងហៅថា ព្រះពុទ្ធរូបសម័យគ្មារតីនោះឯង ដែលពីដើមយើងធ្លាប់ថា ព្រះពុទ្ធរូបសម័យនេះហើយ ដែលផ្សាយមកដល់ស្រុកយើងជាដំបូង ។ តាមតម្រាពុទ្ធចេតិយស្បាមរបស់សម្តេចក្រុមពញាតម្រង់ជាន្តុភាពថា ការប្រកាន់ចូលចិត្តផ្លូវច្បាះ កំជាការពិតម្យ៉ាងដែរតែដែលពិតម្យ៉ាងខ្លាំងនោះ យើងបានប្រទះឃើញព្រះពុទ្ធរូបសម័យអមរាវតី ក្នុងអាណាចក្រថៃច្រើនកន្លែង គឺមួយអង្គហើញនៅស្រុកពន៍ឥក (ផុងឥក), ១ អង្គខ្លាត ឃើញនៅខេត្តនគរពន, ឃើញនៅនគរបឋម (ណៈខនប៉ៈប៉ុំ) ក៏ច្រើនអង្គ, ដែលឯព្រះពុទ្ធរូបចោះពុម្ពក្នុងពិពិធកណ្ឌស្ថានខ្លះជាតិមានដល់ ១៦ អង្គ ខ្ញុំបានទូលសម្តេចក្រុមពញាតម្រង់ជាន្តុភាពថា ព្រះពុទ្ធរូបអមរាវតីនេះមានមកដល់ប្រទេសថៃហើយ គង់មានគេសាងក្នុងប្រទេសថៃស្រេចទៅហើយ ព្រោះមានស្នាដៃពួកស្រុកយើងធ្លាប់ច្រើនអង្គ ដូចព្រះពុទ្ធរូបរបស់ព្រះតុលការគោរពជាដើម ជាបែបអមរាវតីដោយពិត ហើយខ្ញុំបានយកទៅថ្វាយសម្តេចក្រុមព្រះពញាតម្រង់ជាន្តុភាពទត, ទ្រង់ពេញព្រះទ័យ តែមិនទ្រង់ទទួលថាត្រឹមត្រូវទេ គ្រាន់តែត្រាស់ថា បានប្រទះឃើញច្រើនជាការល្អគួរដែរ ។ ដំបូង

ខ្ញុំបានជឿតាមលោកអ្នកចាស់ជាន់មុនថា សូម្បីជាបែបអមរាវតីក៏ពិតមែន តែជាសម័យទ្វារវតី គេធ្វើតាមបែបអមរាវតី ។ តមកមានអ្នកភជការម្នាក់ជាតិចាកំណើសេស ជាកូលួយចាន់ហ្វាន់តណ្ហារក្សពិពិធតណ្ហាតី - មេត័ នៅប្រទេសចាកំណើចានចូលមកក្រុងថៃ ខ្ញុំបាននាំទៅមើលបុពណារាត្តនៅនៈរបឋម, កាលគេឃើញព្រះអមរាវតីហើយ គេសួរខ្ញុំថា ព្រះពុទ្ធរូបនេះគួរចាត់ជាព្រះសម័យណា ខ្ញុំប្រាប់ថាសម័យទ្វារវតី តែគេធ្វើតាមបែបអមរាវតី គេប្រាប់ខ្ញុំថា មិនមែនដូច្នោះទេ ជាព្រះអមរាវតីពិតប្រាកដ ព្រោះដូច្នោះគួរពួកយើងចូលចិត្តជាខ្លាំចំណែកខ្ញុំៗចូលចិត្តស៊ប់ណាស់ទៅហើយ ខ្ញុំបាននាំចាកំណើទៅមកមើលព្រះអមរាវតីចាំង ២ អង្គ តែងពិពិធតណ្ហាស្ថានដែលចានមកពីពន្ធឹកនឹនគរពេជ ខ្លឹងព្រះចោះពុម្ព ១៦ អង្គទៀត គេប្រាប់ខ្ញុំថា ជាព្រះសម័យអមរាវតីចាំងអស់ ។ ទ្រនេះជាហេតុឲ្យយើងជឿចានយ៉ាងប្រាកដថា ព្រះអមរាវតីបានមកដល់ប្រទេសថៃហើយ គេបានកសាងតៗគ្នាមកយ៉ាងជាក់ច្បាស់ ព្រោះដូច្នោះខ្ញុំបានតែងតម្រាប្រុប្រវត្តិព្រះពុទ្ធរូបជាន់ក្រោយៗមក បានបន្ថែមរឿងព្រះអមរាវតីចុះទៅក្នុងតម្រានោះទៀត, ចាំងនេះក៏ព្រោះតែតគ្រាផ្សឿងផ្សាត់ទៅបានលន្ធផលយ៉ាងល្អដូចពោលមកហើយ ។

តាំសម័យអមរាវតី ក៏មកដល់សម័យគុប្តៈ បានមកដល់ប្រទេសថៃក្នុងគ្រាដែលអាណាចក្រទ្វារវតីរុងរឿង ដែលយើងហៅថាព្រះសម័យទ្វារវតីរហូតដល់សព្វថ្ងៃនេះ ។ ពាក្យថា "ទ្វារវតី" ជាឈ្មោះអាណាចក្រ មានប្រាកដក្នុងសេចក្តីកត់ហេតុរបស់ចិនថា តាំងនៅក្នុងចន្លោះ

ប្រទេសកូរ៉ែមានទឹងប្រទេសខ្មែរ ចាន់ទទួលអារ្យធម៌មកពីឥណ្ឌា ។ ផ្លូវ
នៃការត្រួតត្រាស្រាវជ្រាវ ធ្វើឲ្យយើងចាន់ឃើញព្រះពុទ្ធរូប ដែលជាឥទ្ធិពលរបស់ឥណ្ឌាច្រើនណាស់, ដែលមានទៅក្នុងស្រុកនគរបឋម ហើយទឹងស្រុកជិតខាងគ្នានោះ ច្រើនតែជាព្រះពុទ្ធរូបសម័យគុប្តៈដូចព្រះដែលហៅថាពញាកុងពញាពាន ព្រះពីរទៅក្នុងវិហារវត្តភ្នំស្រុកនគរបឋម ទឹងព្រះដទៃៗទៀតជាច្រើន, ដែលយកមកតាំងច្បូងក្នុងទីនេះ ក៏មានព្រះគ្រាវតីជាច្រើនដែរ ។ ព្រះគ្រាវតីទៅប្រទេសយើង គឺព្រះបៃបឋឥណ្ឌាសម័យពាជវង្សគុប្តៈនោះឯង តែថាជាព្រះដែលសាងទៅស្រុកអាយ, អង្គខ្លះគេធ្វើល្អ ដូចព្រះពុទ្ធរូបដែលធ្វើទៅឥណ្ឌា, គេនិយាយថា ជាស្នាដៃជាងពួកអាចារ្យធ្វើ ឬជាស្នាដៃជាងឥណ្ឌាដែលចូលមកទៅក្នុងប្រទេសនេះក៏សឹងចាន់ ។ ព្រោះក្នុងវេលានោះគេជឿថាមានពួកឥណ្ឌាចូលមកទៅធ្វើជាគ្រូអាចារ្យច្រើនណាស់, តមកពួកអ្នកស្រុកធ្វើខ្លួនឯង ស្នាដៃទើបមិនត្រឹមត្រូវតាមភ្នាត ។ យើងទើបចែកព្រះសម័យគ្រាវតីចេញជា ២ ផ្នែក គឺដែលមានទម្រង់ដូចព្រះសម័យគុប្តៈពិតនោះ ១ ផ្នែក ដែលចូលចិត្តថាជាស្នាដៃជាងពួកអាចារ្យ ឬជាងឥណ្ឌាធ្វើខ្លួនឯង ទឹងស្នាដៃពួកអ្នកស្រុកធ្វើ ១ ផ្នែក ពួកលោកដែលជាអ្នករួបរួមព្រះពុទ្ធរូប ហើយជាអ្នកដំនាញក្នុងរឿងនោះអាចនឹងមើលចាន់គប់គ្នា ។

ឥឡូវនេះទឹងពោលពីការសិក្សា: ការសិក្សានោះយើងត្រូវមើលរបស់ធំៗ ដែលគេធ្វើជាគោលជាចារិក នៃសម័យដែលពោលមកហើយ

នោះ ដូចជាយើងនឹងមើលរូបពញាកុងពញាពាន ត្រូវចាំឲ្យបានថា គេធ្វើវង់ព្រះកត្តដូចម្តេច សរសៃព្រះកេសដូចម្តេច ព្រះហស្តយ៉ាងណា ចីវរយ៉ាងណា ខ្នងតង់ថែបណា ជាព្រះសម័យណា នេះជាវិធីសិក្សា ។ ឯការដែលយើងត្រូវសិក្សានោះដូច្នេះគឺ ត្រូវមើលរបស់ធំៗ ជាគួយ៉ាងមកហើយទើបមកមើលរបស់តូចៗ កាលយើងឃើញរបស់តូច ត្រូវសង្កេតឲ្យដឹងថា ដូចនឹងព្រះណា តាមដែលយើងធ្លាប់សិក្សាមកនោះ ហើយត្រូវចាំឲ្យបានយ៉ាងជាក់ច្បាស់ រួចតាំងចិត្តសង្កេតទាំងព្រះកេស, ព្រះមោលី, ព្រះខណ្ណាលោម ព្រះហស្ត, ព្រះបាទ, ចីវរ, ត្របកឈូក, សង្កេតអង្គធំហើយ ទើបមកសង្កេតអង្គតូច ដែលយើងបានចួបប្រទះគ្រប់កន្លែង; ដែលសិក្សារបៀបនេះហៅថាជាថ្នាក់ប្រតិបត្តិ ។

តពីសម័យទ្វារវតី ក៏មកដល់សម័យស្រីវិជ័យជាសម័យទី ២ ជាស្នាដៃរបស់ជាងនៃអាណាចក្រស្រីវិជ័យ ។ អាណាចក្រស្រីវិជ័យ តាំងពីជាន់ទៅក្នុងគោះសុមាត្រា ខាងទិសបស្ចិមនៃស្រុកចាំឡេមចាំង ។ ក្នុងសម័យនេះ បានផ្សាយវឌ្ឍនធម៌ឡើងមកដល់គោះមណ្ឌលរបស់ថៃ គឺស្រុកតះកួប៉ា ស្រុកខនរសីធម្មាជ ស្រុកដៃយា (នៃយ៉ា) ទឹងស្រុកវៀងស្រះ ។ ក្នុងស្រុកទាំងនេះ គេបានប្រទះឃើញបុរាណវត្ថុប៉ែកខាងព្រះពុទ្ធសាសនា ដូចយ៉ាងដែលប្រទះឃើញនៅគោះសុមាត្រា ទឹងគោះជ្វាជារច្រើន ។ ខនេះជាគោលចារឹកគ្រប់គ្រាន់ សរសេចក្តីឲ្យឃើញថា ព្រះពុទ្ធសាសនាប៉ែកខាងមហាយានបានផ្សាយមកខាងក្រៅទេសនេះ ក្នុងសម័យស្រីវិជ័យ ។ ព្រះពុទ្ធសាសនាមហាយាននេះ ជារឿងដែលយើង

ត្រូវតែដឹងដោយខាងមិនបាន ព្រោះហេតុថាមានព្រះពុទ្ធរូប ២ សម័យ គឺសម័យស្រាវដ័យ ទើងសម័យលពបុរ៉ ព្រោះដូច្នោះត្រូវតែពោលដល់ប្រវត្តិព្រះមហាយានបន្តិចបន្តួចផង គឺថាព្រះពុទ្ធរូបកងពុទ្ធសាសនាប៉ែកខាងមហាយាន កើតឡើងដោយការប្រណាំងគ្នា រវាងព្រះពុទ្ធសាសនាទើងសាសនាព្រាហ្មណ៍ ។ សាសនាព្រាហ្មណ៍ ទើងព្រះពុទ្ធសាសនានេះមានគតិស្រដៀងគ្នា គឺចាំងតែសាសនាប្រដៅឲ្យធ្វើកម្មដូចគ្នា តែអធិប្បាយប្រដៅផលរបស់កម្មផ្សេងគ្នា គឺព្រះពុទ្ធសាសនាប្រដៅឲ្យតើងខ្លួនឯងថាយើងធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ទើងបានល្អបានអាក្រក់ព្រោះខ្លួនឯង អ្នកដទៃគ្មានតែចំនុកបម្រុងប៉ុណ្ណោះ បើយើងធ្វើមិនល្អ អ្នកដទៃចំនុកបម្រុងក៏មិនបាន ។ ពាក្យចាំងនេះបូលក្នុងបទថា អត្តា ហិ អត្តនោ នាថោ ''ខ្លួនពឹងខ្លួន'' គឺព្រះពុទ្ធសាសនាប្រដៅឲ្យរៀកម្មផល ចំណែកសាសនាព្រាហ្មណ៍ប្រដៅថា ការដែលទើងបានល្អបានអាក្រក់ ឬបានសេចក្តីសុខទុក្ខនោះ ស្រេចទើងព្រះជាម្ចាស់ បើយើងបួងសួងបន់ស្រន់ឲ្យជាទីពេញចិត្ត ហើយព្រះអង្គក៏ផ្តួយបណ្តាលឲ្យយើងបានល្អ ឬបានសេចក្តីសុខ បើអ្នកណាធ្វើមិនឲ្យជាទីពេញចិត្តរបស់ព្រះជាម្ចាស់ ក៏ធ្វើឲ្យបានសេចក្តីទុក្ខ ; ព្រះពុទ្ធជាម្ចាស់ កាលស្តេចបូលនិព្វានទៅហើយនោះ ក៏គង់តែទៅតែព្រះធម៌ យើងមានតែព្រះធម៌ជាទីពឹង ព្រះធម៌មិនមានរូបកងខ្លួនឬណា មនុស្សល្ងង់អាចដឹងបញ្ញា សំឡឹងមើលមិនឃើញ ទើងមើលឃើញបានតែអ្នកដែលមានបញ្ញាប៉ុណ្ណោះ ព្រោះហេតុដែលមានអ្នកល្ងង់ច្រើនជាងអ្នកឈ្លាស ទើបបានអ្នកប្រដៅសាសនា

ព្រាហ្មណ៍ជាន់ក្រោយ គេដឹកនាំមនុស្សឲ្យចូលសាសនាគេបានយ៉ាងច្រើនរៃអែតលែង សាស្ត្រាចារ្យប៉ែកខាងព្រះពុទ្ធសាសនា យើញថាទឹងចាញ់ប្រៀបសាសនាព្រាហ្មណ៍ ទើបគិតចាត់វិធានការប៉ែកខាងព្រះពុទ្ធសាសនាឲ្យពិស្តារឡើង ដូចតែខែគោលដែលប្រកាន់ថា យេ បអតីតា សម្ពុទ្ធា យេ ច ពុទ្ធា អនាគតា ប្រែថា "ព្រះពុទ្ធអង្គមានមកហើយក្នុងកាលអតីត ក្នុងបច្ចុប្បន្នក៏មាន ហើយនឹងមានក្នុងអនាគតទៀត" ដូច្នេះ ពួកមហាយានយកបទនេះទៅតែងអធិប្បាយជាថ្មីទៀតថា ព្រះពុទ្ធជាម្ចាស់មានទៅខ្លួនឯកក្នុងទីទាំងពួង ហើយបែងគូមិព្រះពុទ្ធជាម្ចាស់ចេញជា ៣ ជាន់ គឺ

១— ព្រះសយម្ភូពុទ្ធ ព្រះពុទ្ធកើតត្រមទឹងដែនដី ហៅថា ព្រះអាទិពុទ្ធ,

២— ព្រះបច្ចេកពុទ្ធ ព្រះពុទ្ធកើតដោយអំណាចឈានសមាបត្តិរបស់ព្រះអាទិពុទ្ធនៅឯដីហានសួគ៌មាន ៥ អង្គ គឺ ព្រះវិរោចនៈ ១ ព្រះអក្សោភ្យៈ ១ ព្រះរតនសម្ភវៈ ១ ព្រះអមិតាភ ១ ព្រះអមោឃសិទ្ធ ១,

៣— ព្រះមានុស្សពុទ្ធ គឺព្រះពុទ្ធអង្គដែលចុះមកត្រាស់កងមនុស្សលោក (ព្រះពុទ្ធរបស់មនុស្ស) ។

ព្រះពុទ្ធ ៤ ពួកខាងដើមមិនដែលចុះមកពីហានសួគ៌ទេ, ដែលធ្លាប់ចុះមកតែពួកទី ៣ គឺព្រះមានុស្សពុទ្ធប៉ុណ្ណោះ ។

ក្រៅពីព្រះពុទ្ធទាំង ៣ កូមិនេះ នៅមានព្រះពោធិសត្វជាច្រើនអង្គ

ខ្លះតជាឧបជាតិក:របស់ព្រះធ្យានីពុទ្ធ តែដែលសំខាន់នោះមាន ៥ អង្គ ហៅថាធ្យានីពោធិសត្វ គឺ

១- ព្រះសមន្តភទ្រពោធិសត្វ អ្នករក្សាសាសនារបស់ព្រះកកុសន្ធ:;

២- ព្រះវជ្របាណីពោធិសត្វ អ្នករក្សាសាសនារបស់ព្រះកោនាគមន:;

៣- រតនបាណីពោធិសត្វ អ្នករក្សាសាសនាព្រះកស្សប:;

៤- ព្រះអវលោកិតេស្វរ: អ្នករក្សាសាសនាព្រះសិសាក្យមុនីគោតម;

៥- ព្រះវិស្វបាណីពោធិសត្វ អ្នករក្សាសាសនារបស់ព្រះអរិយមេត្តេយ្យនាអនាគត ។

តាមដែលពិតនោះព្រះពុទ្ធរូបរបស់មហាយានមិនមែនដូចខ្លះឡើយ គឺ

អង្គទី ១ ព្រះវៃរោចន:គឺព្រះសម័យបឋមទេសនានេះឯង, ព្រះមានុស្សីពុទ្ធរបស់ព្រះវៃរោចន: គឺព្រះកកុសន្ធ:;

អង្គទី ២ ព្រះអក្សោភ្យ: គឺព្រះសម័យមារវិជ័យ, ព្រះមានុស្សីពុទ្ធ:របស់ព្រះអក្សោភ្យ: គឺព្រះកោនាគមន:;

អង្គទី ៣ ព្រះរតនសម្ភវ: គឺព្រះសម័យបច្ចាទពរ, ព្រះមានុស្សីពុទ្ធ:របស់ព្រះរតនសម្ភវ: គឺព្រះកស្សប:;

អង្គទី ៤ ព្រះអមិតាភ: គឺព្រះសម័យសមាធិ, ព្រះមានុស្សីពុទ្ធ:

របស់ព្រះអមិតាភៈ គឺព្រះគោតម;

អដ្ឋកថា ៥ ព្រះអមោឃសិទ្ធ គឺព្រះសម្ព័យ្រទានអភ័យ, ព្រះមានុ-
ស្សពុទ្ធៈរបស់ព្រះអមោឃសិទ្ធ គឺព្រះអរិយមេត្តេយ្យ ដែលនឹងមកត្រាស់
នាអនាគត ។

តាមដែលពិតនោះ គេយកព្រះពុទ្ធរូបសម័យផ្សេង ។ ដែលរោល
មកហើយនោះទៅសម្មតិទ្បើង ដើម្បីប្រណាំងនឹងសាសនាព្រាហ្មណ៍
ហើយដើម្បីពន្យល់ជនានិកវាថា ព្រះពុទ្ធដែលបរិនិព្វានទៅហើយនោះ
ដូចព្រះទីបង្ករ ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ជាដើម រហូតដល់
ព្រះគោតម សុទ្ធតែជាព្រះមានុស្សពុទ្ធទាំងអស់ ដែលមាននៅនាឋានសួគ៌
សព្វថ្ងៃនេះ ក៏អាចយកជាទីពឹងបានដែរ ហើយបើទៅផែនដីយើងនេះ
កើតកលិយុគកលិយាម មានកើតចម្បាំងកំណាច់ជាដើម ព្រះអាទិពុទ្ធ
ក៏ឲ្យព្រះពោធិសត្វចុះមកជួយ ព្រោះព្រះពោធិសត្វជាតួការៈរបស់ព្រះ
អាទិពុទ្ធ នឹងព្រះធម្មាទិពុទ្ធ ជាអ្នកធ្វើការទាំងអស់ ក្នុងមនុស្សលោក
គឺជាអ្នកសាងលោក ព្រោះពុទ្ធសាសនាខាងមហាយានេះ មានការ
សាងលោក ដូចសាសនាព្រាហ្មណ៍ដែរ ហើយអ្នកដែលសាងលោកនោះ
គឺព្រះពោធិសត្វ; លោកសព្វថ្ងៃនេះ គេប្រកាន់ថាជាលោកទី ៤ គឺថាក្នុង
កប្បនេះ មានព្រះពុទ្ធ ៥ ព្រះអង្គ ដែលត្រាស់ទៅហើយ ៤ អង្គក្នុង
កាលឥឡូវនេះ, នៅក្នុងសម័យព្រះគោតម គឺអដ្ឋកថា ៤, លោកទី ៤ នេះព្រះ
ពោធិសត្វព្រះនាមអរិលោកិតេស្វរៈជាអ្នកសាង សម្រាប់ឲ្យព្រះអមិតាភៈ
គឺព្រះមានុស្សពុទ្ធគោតមជាអ្នកចុះមកត្រាស់ក្នុងលោក ។ (មានត)

ផ្នែកអក្សរសាស្ត្រ

បញ្ញាបរិយាយ

ព្រះឧបាលីវង្ស ស្សរ - ហាយ ក្រុមដំទុំព្រះត្រៃបិដក

រៀបរៀង

យើងជាជនជាតិខ្មែរបានទទួលយកព្រះពុទ្ធសាសនាមកសិក្សារៀនសូត្របានតាំងអស់កាលយូរវារង ២០ សតវត្សមកហើយ ។ ព្រះពុទ្ធសាសនាគេចារកក្នុងសាស្ត្រា (គម្ពីរ) នោះសុទ្ធតែជាភាសាមគធៈ ដែលហៅថា ភាសាបាលី ។ ព្រឹត្តិការណ៍របស់ភាសាខ្មែរយើង ដែលជាប់ពាក់ព័ន្ធដោយភាសាបាលី ទើង ភាសាសំស្ក្រឹតច្រើនពេកណាស់ សម្បើញចង្អាស់ថា វប្បធម៌ផ្នែកខាងអក្សរសាស្ត្រចស់ខ្មែរយើងបានកជាចេញមកអំពីភាសាបាលីនឹងសំស្ក្រឹត ដោយមានភាសាបាលីនឹងសំស្ក្រឹតជាប្រភព តំណាងដែនកើតនៃភាសាខ្មែរ ។

ព្រោះហេតុនោះ បានជាភាសាខ្មែរយើងលាយឡំដោយបាលី នឹងសំស្ក្រឹតជាចំនួនច្រើន ។ ពាក្យខ្មែរដែលប្រើនិយាយសព្វថ្ងៃនេះចំនួន ១០០ ម៉ាត់ មានពាក្យបាលីនឹងសំស្ក្រឹតលាយចូលប្រហែល ៥០ ម៉ាត់ ។ អ្នកដែលមិនបានរៀនវេយ្យាករណ៍បាលីនឹងសំស្ក្រឹតក្តី អ្នកដែលបានរៀនក្តី កាលបើត្រូវការនិយាយ ឬសរសេរពាក្យពេចន៍ណាមួយក៏សុទ្ធតែជាប់ពាក់ព័ន្ធដោយភាសាបាលី ឬសំស្ក្រឹតប្រហែល ។ គ្នា សូម្បីតែសាមីខ្លួនអ្នកនិយាយ ឬអ្នកសរសេរ ក៏ឥតដឹងថាជាភាសាបាលី ឬសំស្ក្រឹតសោះ ដោយហេតុតែជាប់ប្រើមកអស់កាលយូរ ដៀមដាំសឹប់សាំ

ណាស់ហើយ ដូចពាក្យថា "កាយ, ចិត្ត, រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ, សុខ, ទុក្ខ, ភោគ, ភ័យ, ច្រើនជាតិ, បុណ្យ, កេរ្តិ៍ឈ្មោះ ប៉ុណ្ណោះជាដើម សុទ្ធតែជាចាលីនឹងសំស្រ្តឹតពិតមែន ប៉ុន្តែអាចស្តាប់យកសេចក្តីបានតាំងអស់ឥតសង្ស័យឡើយ ។

ដំណើរដែលនាំឲ្យកើតសេចក្តីចេះដឹង យល់កិច្ចការខ្លួនទៅតាំងផ្លូវលោកតាំងផ្លូវធម៌ ហៅថា "បញ្ញាបរិយាយ" ឬហេតុដែលនាំឲ្យដុះដាលរីកគំនិត លូតលាស់ឡើងនៃការចេះដឹង ក៏ហៅថា "បញ្ញាបរិយាយ" ។ ការស្តាប់ដោយត្រចៀក, ការរៀនទន្ទេញដោយមាត់, ការមើលដោយភ្នែក ការដឹងហើយជញ្ជឹងគិតពិចារណាឯង ។ តាំងនេះសុទ្ធតែជាហេតុនៃការចេះដឹងទូទៅ ។ អក្សរសាស្ត្រ ឬ គម្ពីរដែលសម្រាប់រៀន សម្រាប់មើល ក៏ហៅថាជាគ្រឿងដ៏ប្រសើរសម្រាប់តាំងឲ្យចេះដឹង តាំងឲ្យយល់កិច្ចការគ្រប់យ៉ាង គឺថា ការចេះដឹងព្រោកប្រាជ្ញច្រើនតិចតាំងអស់ មានអក្សរសាស្ត្រជាហេតុ ។ មួយទៀតដំណើរចំនេះឬហេតុការណ៍ដែលគេផ្សំ ដើម្បីឲ្យកើតសេចក្តីចេះដឹង ឲ្យមានការយល់ច្បាស់ហ្មត់ចត់ ហៅថា "បញ្ញាបរិយាយ" ។

ការដឹងច្បាស់នូវហេតុការណ៍របស់លោក ឬរបស់សាសនាហៅថា "បញ្ញា" ។ ពាក្យថា "បញ្ញា" នេះជាភាសាចាលី ប៉ុន្តែយើងជាជនជាតិខ្មែរស្តាប់ចាំនយល់សេចក្តីស្ទើរតែគ្រប់គ្នា ។ ពាក្យថា "ប្រាជ្ញា" ជាភាសាសំស្រ្តឹត នេះក៏យើងយកមកប្រើច្រាស់ញឹកញាយ ដោយហេតុតែយើងស្តាប់បានដូចពាក្យថា បញ្ញា ដែរ ។

ហេតុដែលនាំឲ្យកើតមញ្ញាមាន ៦ យ៉ាង :

១ - អក្សរសាស្ត្រ ឬ គម្ពីរដីកា;

២ - ការរៀន ការស្តាប់;

៣- ការត្រិះរិះពិចារណា;

៤ - ការបំរើនឮ៎កឮយ;

៥ - ការមើលប្បាប់ប្រើន;

៦ - ការសាកសួរបំពោះលោកអ្នកបេះ ។

អធិប្បាយតទ្រឹកសេចក្តីចំពោះអត្ថបទមួយ ។

១ - អក្សរសាស្ត្រ ឬ គម្ពីរដីកា សំដៅយកក្បួនច្បាប់ គម្ពីរដីកា ដែលសំដែងអំពីអក្សរបស់ជាតិដែលនិយាយអំពីស្រៈ ព្យញ្ជនៈ ឬហៅថា វេយ្យាករណ៍របស់អក្សរដែលសម្រាប់ប្រើ សរសេរជាត់ពាក្យពេចន៍មានរបៀបតាមអក្ខរប្បវេទ ត្រូវតាមវិធីអក្ខរាវិរុទ្ធ ។ អក្សរសាស្ត្រដែលមានរបៀបរៀបរយល្អ, ដែលចំរើនទុនរឿនផ្សាយដល់ជនបរទេស ទៅបានក៏ព្រោះអាស្រ័យមនុស្សជាម្ចាស់ប្រទេស ជាអ្នកយកចិត្តទុកដាក់រៀបចំ, គោរពលើកតម្កើង, ស្រឡាញ់ក្នុងការសិក្សាអក្សរភាសារបស់ខ្លួន ។ អ្នកណាដែលលូនំខ្ជៀកក្នុងអក្សរជាតិរបស់ខ្លួន ដោយសេចក្តីធ្វេសប្រហែសក្តី ដោយសេចក្តីមើលងាយថាអក្សរជាតិរបស់ខ្លួនថោកទាបក្តី អ្នកនោះឈ្មោះថាជាអ្នកមិនគោរពកោតក្រែងចំពោះអក្សរសាស្ត្ររបស់ខ្លួន ឬឈ្មោះថាជាអ្នកប្រមាថមើលងាយអក្សរសាស្ត្ររបស់ខ្លួនដូច្នេះ

ក៏ជាន ។ អ្នកដែលសរសេរអក្សរបស់ជាតិដោយខ្ជិលច្រអូស មិនគិតអំពីអក្ខរ-វិរុទ្ធ គឺថាសរសេរតែឱ្យគ្រាន់តែចប់ពីដៃ មិនគិតពីខុសត្រូវ, អ្នកនេះយើងអាចសំគាល់ជាន់ថាខ្ពុកដូចជាអ្នកប្រមាថមើលងាយដល់អក្សរជាតិរបស់ខ្លួន ។ កាលបើគេហ៊ានប្រមាថមើលងាយអក្សរជាតិយ៉ាងនេះហើយ សូម្បីមនុស្សជាតិរបស់ខ្លួនក៏គេអាចប្រមាថមើលងាយដែរ គឺថា អ្នកណាមើលងាយអក្សរសាស្ត្ររបស់ជាតិ អ្នកនោះខ្ពុកដូចជាមើលងាយដល់ជាតិពាំងមូលរបស់ខ្លួនដូច្នេះក៏ជាន ។

អក្សរសាស្ត្ររបស់ជាតិ គួរយើងយកចិត្តទុកដាក់គោរពលើកតម្កើងជាងអក្សរសាស្ត្រជាតិដទៃ គួរស្រឡាញ់តេញចិត្តកន្តឹកការសរសេរក្តី កន្តឹកការមើលអានក្តីឱ្យជាន តែមត្រូវជាងអក្សរជាតិដទៃ ។ បើមិនយល់ មិនចេះកន្តឹងពាក្យណាមួយ ត្រូវពិនិត្យរកមើលវចនានុក្រម ឬបទានុក្រម, បើនៅតែមិនយល់ ត្រូវសាកសួរដៃញដោលរៀនចំពោះលោកអ្នកចេះដឹងតទៅទៀត ឱ្យគាល់តែយល់ចេះចាំជាស់លាស់ឡើង ទើបឈ្មោះថាជាអ្នកស្រឡាញ់អក្សរសាស្ត្ររបស់ខ្លួន ទាំងឈ្មោះថាជាអ្នកស្រឡាញ់ជាតិរបស់ខ្លួនដែរ ។ កាលបើអ្នកមិនស្រឡាញ់អក្សរសាស្ត្ររបស់ខ្លួនហើយ ក៏គួរឱ្យគេថាយ៉ាជាន់ថាជាអ្នកមិនស្រឡាញ់ជាតិធំដែរ ។

អក្សរសាស្ត្រនេះពិចារណាជាមូលដ្ឋានមួយដ៏ប្រសើរដែលជាហេតុនាំឱ្យកើតបញ្ញាស្មារតីបរិបូណ៌ បើកុំតែមានអក្សរសាស្ត្រ មនុស្សយើងមិនខុសពីសត្វប៉ុន្មានទេ ។ ករណីនេះឃើញថាបញ្ញា មានអក្សរសាស្ត្រជាប្រភព ដោយពិត ។

២— ការរៀន ការស្តាប់, ការនេះបានដល់ការសិក្សាដោយពិនិត្យមើលច្បាប់ខម្មាច់ផ្លូវលោកក្តីផ្លូវធម៌ក្តី ។ ស្តាប់មើលឲ្យញឹកញាយមិនខ្ជិលច្រអូសក្នុងការមើលសៀវភៅ ។ ការសិក្សាក្នុងផ្លូវលោក ឬក្នុងផ្លូវធម៌នេះ ពាក់ថាជាផែនការមួយសម្រាប់ពន្លឹសរុំយសន្ធានរបស់ខ្លួនឲ្យបានបណ្តូ ដើម្បីអប់រំឥន្ទ្រិយឲ្យល្អតៅ ។ ការរៀនឬការស្តាប់នេះជាការណីយកិច្ចដែលត្រូវបំពេញតាមវ័យខានមិនបាន តាមចំណាស់របស់ខ្លួន ដែលអាចបំពេញបាន ។ ការសិក្សានេះចាត់ជាអង្គការប្រចាំជីវិតរបស់មនុស្ស ពាក់ថាជាដំហានទី ១ របស់ប្រទេសជាតិ ដោយហេតុថាប្រទេសជាតិនីមួយ ។ ដែលអាចចំរើនរុងរឿងទៅបាននោះ ព្រោះអាស្រ័យការសិក្សាជាមូលហេតុ ។ ការសិក្សាក្នុងជាន់ដំបូង ត្រូវសិក្សាអក្សរសាស្ត្រ រួចទើបឡើងទៅរកថ្នាក់វិទ្យាសាស្ត្រ ឬវិជ្ជាថ្នាក់ខ្ពស់ ។ តទៅទៀត ដែលប្រទេសជាតិត្រូវការតាមកាលៈទេសៈ ។ ប្រទេសជាតិមានការសិក្សានេះជាពន្ធឹរស្មើ ។ ការសិក្សាជាផ្លូវធំធូលាយ នាំឲ្យមនុស្សមានភ្ញាក់ស្មារតីបរិបូណ៌ ឲ្យមានសមត្ថភាពត្រង់ត្រាន់ ។

ការស្តាប់នោះគោរពើស្តាប់ធម៌ទេសនាក្តី ស្តាប់សេចក្តីថ្លែងការណ៍ឬសន្ទិសីទក្តី សុទ្ធតែមានប្រយោជន៍ ដើម្បីបំពេញសតិបញ្ញា ។ ការស្តាប់នេះគាលបើស្តាប់ដោយគោរព ផ្ទៀងផ្តាត់ដោយម៉ត់ចត់ ត្រមាំង ។ ស្តាប់ស្តាប់ដោយញឹកញាយ សុទ្ធតែជាហេតុនាំឲ្យកើតប្រាជ្ញា ព្រោះលោកអ្នកសំដែង រមែងមានសេចក្តីយល់ហេតុការណ៍ច្បាស់ដោយកន្លែង ។ ជាងអ្នកស្តាប់ក៏មាន ថ្លែកសេចក្តីពីអ្នកស្តាប់ដែលភ្លាមចេះដឹង

ក៏មាន ។ ការសម្រាប់ស្តាប់នេះគុកថាជាហេតុមួយនាំឲ្យមានច្រើនជាជាដោយបានចម្លងយកសេចក្តីយល់ ឬជាកិច្ចប្តូរយោបល់អំពីការស្តាប់ ។

៣— ការត្រិះរិះពិចារណារកហេតុផល ការនេះគុកថាជារបស់ចាំបាច់មានតុំបាន ព្រោះថា រឿងរ៉ាវណាមួយ ឬហេតុការណ៍អ្វីក៏ដោយ ដែលប៉ះច្រៀងមកលើយើង ត្រូវតែចាប់យកហេតុការណ៍នោះ ។ មក ត្រិះរិះពិចារណាមើលសិនជាជាប ដើម្បីស្វាបស្ងួនឲ្យឃើញសមហេតុសមផល ទើបដឿយកជាការបាន មិនត្រូវចេះតែដឿដោយឥតត្រិះរិះពិចារណានោះឡើយ ។ ការត្រិះរិះពិចារណានេះ ជាផលដែលកើតមកអំពីការរៀនច្រើន ស្តាប់ច្រើន ពិតមែន ប៉ុន្តែលោកចាប់ថា ការត្រិះរិះនេះជាសម្ភារដ្ឋានៃបញ្ញា គឺថាជាទីកើតរបស់ឡើងនៃបញ្ញា ។

៤— ការបំរើឆន្ទៈកាយ : ពាក្យនេះចេញពីបាលីថា "ភាវនា" ដែលខ្មាំរមែរថា "ភាវ៉ែន" បានសេចក្តីថា ការរៀន, ខន្ធេញ, ម៉ើលច្បាប់, ស្វាធ្យាយន៍, ស្តាប់រឿយៗ មិនចោះបង់ មិនទម្លាក់ចោលខ្លួរឆ្លុះដែលល្អមានប្រយោជន៍ ។ ការណាមួយក្តី ណាមួយ ទោះបីសំបាកឬចន្លុតយ៉ាងណាក៏ដោយ តុំមែនលើសវិស័យរបស់មនុស្សឡើយ ។ កាលបើគេចាប់ធ្វើដោយព្យាយាមម៉ឺងម៉ាត់តស៊ូមិនឈប់ មិនលះបង់យូរ ។ ទៅ ឬបាកដជាថ្នឹកស្ទាត់យល់ច្បាស់លាស់តុំមាន ព្រោះហេតុនោះការចំរើនញឹកញយ គឺការធ្វើឬការរៀនជាដើមឲ្យច្រើនឡើងនេះឈ្មោះថាជាមគ្គុទ្ទេសមួយដ៏ប្រសើរ សម្រាប់ឲ្យកើតច្បាស្មាតី ។

៥- ការមើលច្បាប់ប្រើង : ពាក្យថា "ច្បាប់" នេះ ពុំបានសំដៅទៅតច្បាប់ត្រួតត្រាឬណ្ឌ ឬច្បាប់រដ្ឋប្បវេណីប៉ុណ្ណោះទេ តោះបីតម្លឹងដើរតា, សៀវភៅធម៌អាថ៌, សារពត៌មានឬទស្សនាវដ្តីណាមួយ ក៏ហៅថា "ច្បាប់ចាំងអស់" ។ ការមើលច្បាប់ច្រើនទុកជាមេរៀនមួយដែលអាចជួយយោងសតិបញ្ញាឲ្យមានបរិបូណ៌ឡើង ។ ការមើលធម៌អាថ៌ឬមើលសៀវភៅផ្សេងៗក្តី, មើលសារពត៌មានណាមួយក្តី តែបើទេសៈយើងសម័យបច្ចុប្បន្ននេះពុំពាន់សម្បូរ ព្រោះប្រជាជនមិនពាន់ស្រឡាញ់ពេញចិត្តតែការនេះនៅឡើយ ។

បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ជាមន្ទីរផ្តុកសៀវភៅច្បាប់ខ្មាប់អក្សរជាតិក៏មាន ជាអក្សរបរទេសក៏មាន ទុកសម្រាប់ឲ្យជនសាធារណៈមកមើល តាំងបណ្ណាល័យជាតិពាណិជ្យតែត្រូវតែកុងក្នុងពេញ ក៏មានសៀវភៅសម្រាប់ឲ្យមើលដូចគ្នាដែរ ប៉ុន្តែមិនសូវមានអ្នកទៅមើលច្រើនតុះតរសោះ ។ តែក្នុងថ្ងៃមួយៗ មានម្នាក់ឬពីរបីនាក់ទៅមើល ដួនកាលស្ងាត់ឈឹងមិនមានមនុស្សទៅមើលសោះក៏មាន មិនតុះតរដូចពេងល្ងេនពេងតុនទេ ឃើញថាចាញ់ពេងល្ងេនតុនឆ្ងាយណាស់, នៅក្នុងតប៉ាល់ក្នុងរថភ្លើង ឬក្នុងយន្តហោះរបស់ប្រទេសដែលមានវឌ្ឍនធម៌ មានទុតិយ-គតិ គេឃើញអ្នកជិះកាន់សៀវភៅឬសារពត៌មានមើលក្នុងយាននោះស្ទើរតែរាល់ដៃ មិនសូវមានអ្នកណាមួយទំនេរឥតមើលសៀវភៅទេ ។

នៅក្នុងតប៉ាល់ ក្នុងរថភ្លើងរបស់ប្រទេសយើង មានមនុស្សជិះទៅមកច្រើនតុះតរដូចគេដែរ ប៉ុន្តែពុំសូវមានអ្នកកាន់សៀវភៅមើលទេ ។

ការមើលច្បាប់ខម្ចាប់ច្រើន ជាគុណមួយធំក្នុលាយណាស់ នាំឲ្យចេះដឹងរឿងរ៉ាវ ជាព្រឹត្តិការណ៍ក្នុងសាកលលោក ដែលជាហេតុធ្វើខ្លួនយើងឲ្យមានខ្មីមសារ ញ៉ាំងខ្លួនយើងឲ្យឈ្លាសវៃទាំងផ្លូវលោកផ្លូវធម៌ មិនឲ្យខ្លួនយើងធ្លាក់ទៅជាមនុស្សឆ្កួង ឬមនុស្សឈ្លើយ ។ ការមើលច្បាប់ខម្ចាប់ច្រើន នាំឲ្យចំណេញការចេះដឹងយល់តិចការគ្រប់ចំពូក មិនខាតភ្នែកគាសដូចមើលល្ងោនមើលកុនឡើយ ។

៦— ការសាកសួរបំពោះលោកអ្នកបោះ, ការសាកសួរពាក់ថាជាការចាំបាច់មួយ ហើយខុកជាមេរៀន ដែលនាំឲ្យកើតច្បាស្ងាត់ថាចេះចាំយល់ការកក់ជ្រែវច្រើន ។ ក្នុងផ្លូវអក្សរសាស្ត្រក៏ ផ្លូវសាសនាក៏ការមើអ្នកណាខៅតុំខាន់ចេះតុំខាន់យល់ អ្នកនោះពោះបីមានហានៈខ្ពស់ខ្ពស់ដោយយសស័ក្តិប៉ុណ្ណាក៏ដោយ ត្រូវតែសាកសួរដេញដោលចំពោះលោកអ្នកចេះជាន់ខ្លួនដោយបំណងឲ្យចេះដឹង មិនត្រូវប្រកាន់ឫកពារ ឬអៀនខ្មាសទេ ។

វេលានេះប្រទេសកម្ពុជាយើងបានឯកភាពព្រមព្រៀងបរិបូណ៌ហើយ គួរយើងខ្មែរដឹងខ្លួនថាខ្លួនយើងរួចពីអាយ័តគេ មានឋានៈស្មើមុខនឹងជនជាតិប្រទេសឯកភាពក្នុងសកលលោកហើយ ដូច្នេះគួរយើងប្រឹងប្រែកបញ្ជាយាមបណ្តុះ បោតុងាំឲ្យកើតមានបញ្ញាទាំង ៦ ប្រការ នេះ ក្នុងខ្លួនឡើង ដើម្បីឲ្យសមនឹងប្រទេសយើងដែលឯកភាព កំពុងត្រូវការពេជនជាតិដែលមានចំណេះមានសមត្ថភាព ឲ្យទៅចំរើនប្រទេស ។

តៃនិត្រភេជា

លោក ស៊ីវ - ប៉ាវិង រៀបរៀបរៀង

លោក ឃ្លូរ - អ៊ីវ ពិនិត្យកែសម្រួល

(តមក)

លោកនិទ្ទេ ចាន់នោលពាក្យសុំទោសបិតាខ្ញុំ ហើយទទួលសារភាព ថា លោកមិនមានចេតនាទើបចាប់ទោសបិតាខ្ញុំទេ ព្រោះដែលលោកមកនោះ ដោយមានបំណងចង់ដឹងប្តូរប្រែរបស់លោកដែលជាមនុស្ស អាត្រក់កង់រឿងនេះប៉ុណ្ណោះ ព្រោះពេលដែលប្រជាប់ម្តង ចាន់ចាត់ទៅកន្លែងណា:ដែលលោកមិនទាន់ចាន់ទទួលម្តង អំពីវៃរបស់ប្តូរប្រែ ព្រោះវេលានោះលោកកំពុងឈឺធ្ងន់ ក្រោកមិនរួច លុះលោកជាសះស្បើយហើយក៏សួរកម្តង ប្តូរប្រែក៏នាំមកប្រគល់ឱ្យភ្លាម, កន្លែងណា: ទទួលម្តងមកពិនិត្យមើលវៅ លោកពុំឃើញពេលដែលប្រជាប់ម្តង; លោកសួរក, ប្តូរក៏ថ្លាប់ថា ខ្ញុំចាន់ទទួលមកត្រមាំងម្តង ទើប ពិនិត្យត្រួតត្រាមើលត្រឹមត្រូវហើយ កាលមកដល់ផ្ទះឃើញបិតាឈឺជាខ្លាំង ក៏នាំវៅដាក់ឱ្យកន្លែងបន្ទប់ដេកលើខ្នើខ្ញុំស្ងាត់កំប៉ាំងក្អែក ដោយនឹកថាគ្មាននរណាដឹងឡើយ តាំងអំពីពេលនោះមកមិនចាន់វៅចាប់ពាល់ទៀតសោះ ទាល់តែបិតាសួរក ទើបវៅនាំយកមកជូនលោក, អម្បាញ់មិញខ្ញុំមិនជឿឱ្យសំដីរបស់ប្តូរប្រែថានិយាយពិតត្រង់ លោកមានសេចក្តីត្រាធឹងជាខ្លាំង ចូលចិត្តថាប្តូរបស់លោកប្រពឹត្តខុសវិត នាំពេលដែ

ទៅលាក់ខ្លួនជាក្រែងជ គាលលោកនិយាយប្រាប់ថាតាខ្ញុំហើយ ក៏
ពោលពាក្យសុំទោស, បិតាខ្ញុំតបថា មិនប្រកាន់ទោសលោកទេ, តាំង
ពេលដែលបានជំនឿរឿងនេះ បិតាខ្ញុំសួរលោកថា បើយ៉ាងនេះតើនឹងធ្វើ
ដូចម្តេច ? លោកតបដោយសេចក្តីគួរអាណិតថា ខ្ញុំព្រមទទួលទោស
អំពីព្រះពាជា ខ្ញុំមិនអាចនឹងទៅរកពេជ្រពីណាបានទេ ទោះបីពេជ្រ
នោះមាន ក៏ខ្ញុំមិនអាចនឹងរកប្រាក់ទៅទិញគេបានឡើយ អមាត្យនិង
មានសេចក្តីទុក្ខខ្លាំងពេកក៏លាបិតាខ្ញុំទៅ បិតាខ្ញុំបានចេញដួងដំណើរនិង
អមាត្យ។ ដើរទៅដោយអាការយ្លងយ្លោង ដែលគួរអាណិតអាសូរ
សូម្បីបិតាខ្ញុំសូមឲ្យលោកឈប់បន្តិចសិន នឹងប្រើមនុស្សឲ្យយកវេរសែ
ជូនទៅ លោកក៏មិនព្រមសោះ" មាណពនិយាយមកដល់ត្រឹមនេះ
ក៏ឈប់មួយស្របក់ ហើយក្រែកក្បែរឆើយមុខមើលមេឃ, វេលានោះ
ជាពេលដែលព្រះអាទិត្យកំពុងលុបជ្រងំក្នុងព្រះសុមេរុ មានស្មៅស្រទន់ទៅ
លើផ្ទៃមេឃ ចោលស្រមោលទៅចំទាំងលោក ការឆេងឆឺតក៏ធ្វងបួលមក
យ៉ាងនាប់រហ័ស មាណពទើបបបួលជាលិតអមាត្យឡើងទៅលើផ្ទះថ្ម។

"ឈប់ ១ ស្របក់ចុះលោក ! សន្ធូនាគ្នាខាងលើស្រួលជាង ខ្ញុំ
ត្រេកអរនឹងបញ្ចេញនូវសេចក្តីតានតឹង ដែលមានមកយូរយារហើយនោះ
ចោលចេញខ្លះ" ។

មាណពនឹងអមាត្យ ទាំងគ្នាឡើងទៅសន្ធូនានៅកើយមុខ ត្រង់ទិស
ឧត្តរ សម្លឹងមើលទៅខាងក្រោមក៏ឃើញសួនច្របាំក្រងវេសាលីកំពុងហូរ
ត្រជាក់ សមគួរដល់ការអង្គុយមើល ដើម្បីបញ្ចេញ ឬបន្ថយនូវអារ

ម្នាក់វេបសម្លុតអ្នកសន្ទនាគ្នា ឮនយ៉ាងស្រួល, មាណាពរើបផ្តើមនិយាយ
តទៅ ៖

"ឥស្សរាធិតអាស្រមអមាត្យនន្ទិវិក្រែពេក, លោកឮនាំម្តងដែល
ឮថាសេចក្តីពេជ្រឡើងទៅថ្ងាយព្រះពេជ្រ ហើយគ្រាចូលរាយសេចក្តី
ដែលបុត្តប្រុសរបស់លោកទទួលមក រហូតដល់ឮនមកឱ្យដល់លោក
ខ្ញុំត ព្រះពេជ្រក៏ទ្រង់ព្រះពិរោធខ្លាំង ទ្រង់បញ្ជាឱ្យឃុំឃាំងនូវលោកនន្ទិ
ទ័ងបុត្តប្រុស ព្រោះទ្រង់មិនជឿថាជាសេចក្តីពិត ។ ការណ៍ដែលមិន
មានស្នាមគំនូសនៃការឮត់ពេជ្រសូន្យឈឹងនេះ ព្រះពេជ្រក៏ទ្រង់ព្រះ
ពេជ្រញាឱ្យស៊ើបអង្កេតឡើង តែទោះបីស៊ើបអង្កេតយ៉ាងណា អមាត្យ
នន្ទិក៏នៅតែនិយាយចាំពាក្យដដែលថា បុត្តប្រុសរបស់ខ្ញុំនឹងអ្នកទទួល
ទៅអំពីបិតាខ្ញុំ, លោកនន្ទិអមាត្យធ្វើយឱ្យការណ៍ទៅយូរស្មោះត្រង់
ដោយមិនបានចាប់ពីកន្លែងតិតថា តែងបុត្តប្រុសរបស់ខ្ញុំនឹងទទួលគ្រោះ
ថ្កាក់ណាទេ បុត្តប្រុសរបស់នន្ទិអមាត្យក៏និយាយរើនដំហរដូចគ្នាថាមិន
ឮនទៅចាប់ពាល់ម្តងនោះទៀតឡើយ កាលមកដល់ផ្ទះក៏ជាក់ខ្ញុំតលើខ្នង
ខ្លួនឯងបន្ទូបរបស់ខ្ញុំនតាំងចិត្តថាចាំបិតាសងជាសិន ទើបនឹងនាំយកទៅ
ប្រគល់ឱ្យក្នុងពេលដែលបិតាត្រឡប់ការ, ការស៊ើបអង្កេតមិនបាននគាលចាក
តស្តុតាងអ្វីសោះ សឹងតែមានទំដែលគួរឱ្យតិតថា នន្ទិអមាត្យជាមនុស្ស
ស្មោះត្រង់ឃ្លាយរយៈណាស់មកហើយ តាំងពីបាននទទួលការពារការ
ផែនដី មិនធ្លាប់ប្រព្រឹត្តខុសតែ ឬមានគំនិតអាក្រក់ក្នុងពេលណាម្តងទេ
បើប្រសិនលោកនេះជាអ្នកខុសតែមែន ម្តេចក៏មិនមានទីព្យសុតសុម្ភសម្ភារ

សប្បាយនឹងគេ ហេតុម្តេចមកមានគំនិតមិនស្មោះត្រង់នឹងព្រះពុទ្ធជាដើម ពេជ្រប្រដាប់ក្នុងដុតក្តីរីយចាស់ជាពហើយ; បុគ្គលប្រុសរបស់នឱ្យអមាត្យទៀត ក៏នៅកន្លែងតំណែងជាមហាឧបរាជ្យព្រះអង្គ មិនធ្លាប់ប្រព្រឹត្តអាក្រក់មកឡើយ មនុស្សនេះកម្រអ្នកណានឹងបើញថាជាអ្នកខុសត្រូវតែបាន តែដល់មានរឿងនេះឡើង ក៏មិនផុតអំពីការជាប់ពាក់ព័ន្ធក្នុងរឿងខាក់ខន់នឹងពេជ្រជាត់ក្នុងពេលនេះ, បណ្តាមនុស្សទាំង ៦ នាក់នេះមិនដឹងជាមនុស្សណាខុស ឬក៏ខុសទាំងពីរនាក់ ព្រោះហេតុនេះឯង ក្នុងទីបំផុត ព្រះពុទ្ធជាម្ចាស់ព្រះបញ្ជាឱ្យពិចារណាទោស នៃនឱ្យអមាត្យនឹងសុរពលមហាឧបរាជ្យព្រះអង្គជាការជាប់ខាត ដែលជាហេតុញ៉ាំងការលំបាកឱ្យកើតមានដល់ពួកនាម៉ឺន ជាអ្នកប្រឹក្សាក្នុងផ្លូវជាក់ទោស ព្រោះនាម៉ឺនទាំងនោះជាអ្នកស្និទ្ធស្នាលត្រមាំងជឹងអធ្យាស្រ័យល្អរបស់នឱ្យអមាត្យ តាំងអំពីបានទទួលធ្វើពុជការមកជាមួយគ្នា មិនធ្លាប់មានអ្នកណាអាក់អន់ចិត្តនឹងគាត់ជាហេតុឱ្យចងអាឃាតឡើយ, រឿងរបស់នឱ្យអមាត្យនេះនាម៉ឺនក៏បានដឹងគ្រប់គ្នា, ការពិចារណាជាក់ទោសទៀត ក៏ផុតនឹងវិនិច្ឆ័យបានព្រោះទាំងពីរនាក់មិនធ្វើយបដិសេធ ធ្វើយទទួលសារភាពត្រមែតឱ្យការណ៍ដែលរឹងជំហរគ្រប់ពេល, ដោយគុណធម៌ដ៏ខ្ពង់ខ្ពស់ដែលនឱ្យអមាត្យធ្លាប់ប្រព្រឹត្តមក ជាគ្រឿងជាស់តឿនចិត្តនាម៉ឺនទាំងឡាយ នាម៉ឺនទាំងនោះទើបបានទូលព្រះពុទ្ធជា សូមជាក់ទោសត្រមែតស្នានស្រាលៗ គឺឱ្យដកចេញចាកតំណែងទាំងឥពុកទាំងកូន, ឯការជាក់ទោសស្នានដទៃ ថ្វាយចំពោះព្រះពុទ្ធជាម្ចាស់វិនិច្ឆ័យដោយព្រះប្រាជ្ញាព្រះអង្គឯង" ។

កាលនំ ហើយមកដល់ត្រឹមនេះ មាណពក៏បែរមកខាងចុងលិតអមាត្យ ហើយសួរថា :

"លោកល្មមជាបជ្ញានទេថា ព្រះពុទ្ធជាខ្ញុំដាក់ទោសនទ្ធិអមាត្យ ទំនឹងគាហានឯកវេរបស់ព្រះអង្គស្ថានណា ?" ។

"ខ្ញុំយល់ឃើញស្របតាមការយល់ឃើញរបស់នាម៉ូនតាំងឡាយ" លោកអមាត្យតប ។

"មែនលោក, ខរណា ។ ក៏និយាយដូចលោកដែរ ព្រោះការដកចេញចាកយសទំនឹងតំណែងពុទ្ធការ កំដាទោសធ្ងន់ល្មមសមគួរសម្រាប់នទ្ធិអមាត្យហើយ តែនទ្ធិអមាត្យទំនឹងបុត្តប្រុសរបស់លោកជាអ្នកមានគ្រោះអាក្រក់ពន់ពេក ព្រោះជាមិនចាដាក់ទោសតែស្ថាន ១ ទេ ព្រះអង្គទំនឹងព្រះបញ្ជាឲ្យឃុំឃាំងក្នុងគុក ទាល់តែស៊ើបអង្កេតរកសេចក្តីពិតឃើញ ជាការខ្ជាខ្ជានយ៉ាងទម្ងន់ស្រាលបុគ្គលអ្នកមានសេចក្តីស្មោះត្រង់សុចរិត, អើលោក ! ខ្ញុំជ្ញាថ្នាទំនឹងសួរសេចក្តីឃល់អំពីលោក សួរលោកម្តងថ្ញាផ្ញាត្រឹមរឹងហើយ តែកន្លះលោមានសេចក្តីឃល់ឃើញខ្លះហើយលោកថ្ញាប់ខ្ញុំជាច្រើនថា នទ្ធិអមាត្យទំនឹងបុត្តប្រុសលោកជាអ្នកបរិសុទ្ធឬជាអ្នកទុច្ចរិត ? ។

កន្លះគេលព្រលប់មើលគ្នាឃើញស្ទុង ដែលមានពន្លឺព្រះច័ន្ទបញ្ចាំងចូលមកក្នុងបន្ទប់ អមាត្យចាលិតដកដង្ហើមញាប់ ។ បែបដូចជាមានអាការគិតខ្លាំង, មាណពទំរេតផ្អែកទៅលើភ្នាក់ដៃគៅអី ក្អែកសម្លឹងទៅមេឃឆ្ងាយ ត្រចៀកចាំស្តាប់សំដីរបស់ចាលិតអមាត្យ ដោយគុណ្ហីភាព ។

មិនមានសម្លេងណា ចូលមកចំណាយនូវសេចក្តីស្ងៀមស្ងាត់ក្នុងខណៈនេះ ក្រៅពីឮស្តាប់ដំនោរបក់មកត្រសៀកៗ ស្រូបយកក្លិនដែលប្លែកជាតិក្នុងក្រឡឹមមួយដង។ ក្លិនក្រអូបនោះជារបស់នាំឲ្យរីករាយចិត្ត; ជនទាំង ២ នាក់ ដែលបានស្រូបក្លិននោះហើយ អាចរសាយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទៅបានខ្លះ។

ចាលិតអមាត្យតបថា "ក្រណាស់ មាណព; ផ្ទុតបញ្ជារបស់ខ្ញុំ, ជាសេចក្តីកំចាំដែលលំបាកនឹងច្រាប់គ្នា សូម្បីតែនឹកគាត់ស្មានឬស្បែងតាយមើល ក៏មិនឃើញមានផ្លូវសោះ ដើម្បីនឹងដាក់ទោសថា កូនប្រុសរបស់លោកនឹងជាមនុស្សខ្លួចតែទៅ ក្រែងមានអ្នកដទៃនៅក្នុងផ្ទះលួចឬមនុស្សក្រៅផ្ទះមកលួច"។

"មិនមានទេលោក, អំពីមនុស្សក្នុងផ្ទះខ្ញុំមិនចាន់បានច្រាប់លោក, នឹងអមាត្យជាអ្នកសន្ទោស, ក្នុងផ្ទះរបស់លោកមានមនុស្សប៉ុន្មើម្នាក់ជាស្ត្រីផង, បន្ទប់ដែលបុត្តប្រុសរបស់លោកនៅ ហើយដែលនាំគេដេកទៅខុក ក៏មានកូនសោចាក់យ៉ាងមាំមួន ហើយជាបន្ទប់ជាន់លើមិនមានទ្វារណាឬរឿងចុះទៅធ្វើការកើតវាទៅទីនោះឡើយ"។

"បើដូច្នោះ មាណពឯងគ្មាច់ចាន់គិតខុកយ៉ាងដូចម្តេច?" ចាលិតអមាត្យសួរ។

"ខ្ញុំគាល់បញ្ជាហើយ មិនដឹងគិតយ៉ាងដូចម្តេចទេ ព្យាយាមគិតវាយបញ្ហាក្នុងរឿងនេះគ្រប់ផ្លូវអស់ហើយ ក៏មិនអាចនឹងដោះស្រាយតាម

គន្ធធ៌ណា។ ឯាន លោកឯានស្តាប់ខ្ញុំនិយាយហើយ ម្តេចតង់មិនអាចនឹង
យល់ឃើញឯាន តើឲ្យខ្ញុំយល់ឃើញដូចម្តេចកើត" មាណពតបវិញ ។

គួរអាណិតនន្ទិអមាត្យពន់ពេក ជាពណ្ណាស់ហើយមកត្រូវឃុំឃាំង,
ប៉ុន្តុប្រុសរបស់លោកជាគាហានឯក មិនគួរនឹងមានវែង គួរតែអាណិត
ឪពុករបស់ខ្លួន បើខ្លួនមិនខ្មាសក៏គួរសោកាខ្លួនថាខ្មាសតែម្នាក់ឯង ដើម្បី
សង្គ្រោះឪពុកឲ្យរួចពីទោសទុក្ខ, ថ្មើរនេះនន្ទិអមាត្យនឹងក្រែមក្រំចិត្ត
យ៉ាងណាទៅ? រួចមាណពពោលតទៅទៀត ៖

"មែន! នន្ទិអមាត្យជាអ្នកស្មោះត្រង់ ត្រូវក្រែមក្រំចិត្តជាខ្លាំង
ឯសុរពលជាប្តុប្រុសលោក គាលខ្ញុំទៅសួរនាំកងឃុំឃាំង ឯាន
និយាយប្រាប់ខ្ញុំថា ចង់ទទួលជាអ្នកខ្ចីតតែម្នាក់ឯងវែរ តែមិនអាចនឹង
ទទួលឯាន ព្រោះខ្លួនបរិសុទ្ធពិតៗ មិនមែនជាមិនមានសេចក្តីអាណិត
អាសូរឪពុកខោះទេ មិនតែប៉ុណ្ណោះ សុរពលឯានស្បថស្បែប្រាប់ខ្ញុំថា
ខ្លួនជាគាហានរក្សាពាក្យសម័ត្យជានិច្ច សេចក្តីស្មោះត្រង់ស្រឡាញ់កត្តិ
ចំពោះព្រះរាជាក៏ម៉ាំមួន; មុនដែលខ្ញុំនឹងលាត្រឡប់មកផ្ទះវិញ សុរពល
ចាប់ដៃខ្ញុំមានក្រសែភ្នែកហាក់ដូចជាចង់អង្វរខ្ញុំឲ្យជួយធុរៈអ៊ីម្ចុយ កាលខ្ញុំ
ញាក់មុខឲ្យសញ្ញាថាចង់និយាយអ៊ីនិយាយមកចុះ សុរពលក៏ពោលថា
គេមានប្អូនស្រីម្នាក់ ឥឡូវនេះគេនឹងឪពុកគេមិនដឹងថា ព្រះរាជានឹង
ឃុំឃាំងទុកយូរត្រឹមណាទេ បើខ្ញុំមិនរង្គើសអាណិតអាសូរគេនឹងបិតា
គេហើយ សូមជួយយកធុរៈមើលថែទាំប្អូនស្រីគេឲ្យផង ខ្ញុំមានចិត្ត
ជ្រះថ្លាដោយនឹកថាមិនជាត្រលំបាកអ្វីឡើយ, ទើបប្រាប់ថា ល្អើយចុ

សុវពលខ្ញុំនឹងយកចិត្តទុកដាក់មើលថែទាំប្អូនស្រីអ្នកឯង ដូចជាប្អូនរបស់ខ្ញុំ សុវពលត្រែកអានឹងខ្ញុំយ៉ាងវែលែង, ថ្ងៃនោះខ្ញុំបានសួរនាំតែសុវពលប៉ុណ្ណោះ ចំណែកនន្ទិអមាត្យមិនព្រមនិយាយអ្វីនឹងខ្ញុំសោះ អង្គុយត្រើយក្នុងទីយុំយាំង ខ្ញុំចូលទៅលាលោកៗគ្រាន់តែញាក់មុខប៉ុណ្ណោះ ខ្ញុំបានជំរាបលោកថា ខ្ញុំខ្លួលការៈជាអ្នលមើលថែទាំបុត្តស្រីរបស់លោក សូមលោកកុំព្រួយបារម្ភឡើយ ពេលនោះលោកបានថែរមុខមកសម្លឹងមើលខ្ញុំៗ មើលទៅឃើញលោកមានទឹកមុខរីករាយ ។

* * *

សេចក្តីស្រឡាញ់ពិតប្រាកដឬទេ ?

— ៤ —

ខ្ញុំត្រឡប់មកដល់ផ្ទះក្នុងវេលាល្ងាចណាស់ហើយ ប្រញាប់ទៅជម្រាបឲ្យបិតាខ្ញុំជ្រាបថា ខ្ញុំបានត្រឡប់មកពីសួរនាំនន្ទិអមាត្យនឹងសុវពល, បិតាខ្ញុំពេញចិត្តនឹងខ្ញុំដែលចេះប្រព្រឹត្តសមគួរក្នុងការទៅសួរនាំលោកនន្ទិអមាត្យដំនួសលោក, លោកនិយាយថា "ដែលកូនឯងបានធ្វើយ៉ាងនេះ លោកនន្ទិន៍ងឹងជឹងថាយើងមិនលះបង់ចោលលោក ក្នុងគ្រាមានវិបត្តិរកដល់ខ្លួនលោក" ហើយសាកសួរបន្តិចបន្តួចខ្លះទៀត ខ្ញុំក៏បានជំរាបតាត់ថា សុវពលផ្តាក់ផ្តើមប្អូនស្រីនឹងខ្ញុំ ឲ្យខ្ញុំជួយយកធុរៈមើលថែទាំដំនួសផង តើការណ៍នេះខ្ញុំគួរធ្វើដូចម្តេច សូមលោកឪពុកពន្យល់ខ្ញុំផង ។

(មានត)

កណ្ឌទី ២៤

ឧកញ៉ាវិបុលរាជសេនា ភូ - កាន ប្រែរៀបរៀង

(ខមក)

រឿងសាមកុកទុកជាឃ្លុងសាស្ត្រ
អ្នករាងវិជ្ជាសបើបានអាន
ធឹងបេះឧបាយកលបំណាន
ទាំងមានសង្ឃានស្នេហាជាតិ ។

គួនអ៊ូថា លោកមេវត្តនេះ ជាពួកម៉ាកនៅស្រុកខេសជាមួយនឹងយើង បែកគ្នាមកជាយូរហើយ ទើបនឹងបានមកជួបគ្នាថ្ងៃនេះបានជាត្រូវសោកស្តាយសុខទុក្ខខ្លះ ។ លោកគ្រូចិនកៅចេងក៏រៀបទឹកឆ្ងែឲ្យគួនអ៊ូផង ហើយចាក់ទឹកតែឲ្យគួនអ៊ូផឹក ។ គួនអ៊ូថាបងថ្ងៃខ្ញុំទាំង ២ នៅលើរថមុខវត្តឯណោះមិនបានផឹកផង ខ្ញុំនឹងផឹកមុនឆ្លើម្តេចបាន ។ លោកគ្រូចិនកៅចេងក៏យកទឹកតែនាំគួនអ៊ូចេញទៅឲ្យបងថ្ងៃលើរថផឹកទាំង ២ នាក់ លោករកនុកាសស្ងាត់ទឹងជ្រាបគួនអ៊ូពុំបាន ព្រោះពៀនហ៊ុយចេះតែតាមមើលបើទឹងនិយាយគ្រែងពៀនហ៊ុឮ ព្រោះពួកម៉ាកពៀនហ៊ុដើរទៅមកមិនដាច់ ។ លោកគ្រូចិនកៅចេងក៏យកចង្កឹលដៃ ចង្កឹលទៅត្រង់គ្រូបច្ចួនអ៊ូសៀត ហើយកំញាក់ក្អែកឲ្យដឹង ។ គួនអ៊ូក៏យល់សេចក្តីថា

ពៀនហ៊ុនធីងធ្វើអន្តរាយ ជាន់ជាបង្គាប់ថាហានឲ្យកាន់អាវុធតាមគួនអ៊ូ ៗ
លោកគ្រូចិនតៅចេងធីងគួនអ៊ូក៏ត្រឡប់ចូលទៅវត្តវិញ ។ ពៀនហ៊ុដំពប
គួនអ៊ូថា ខ្ញុំបាទឲ្យរៀបត្រយាជូនលោកព័ស្សារៀបខុកជាស្រែចហើយ
អញ្ជើញលោកចូលទៅខាងក្នុងចុះ ។

គួនអ៊ូបានស្តាប់ហើយក៏ឥតកោតញញើតឡើយ ចូលទៅអង្គុយ
ជាមួយនឹងពៀនហ៊ុ ឃើញពួកម៉ាកពៀនហ៊ុឈរតំរៀបគ្នា សុទ្ធតែ
សៀតគ្រប់លាក់បង្គប់កងអាវុ ឃើញជងលេចចេញមកខាងក្រៅ គួនអ៊ូ
ក៏សួរពៀនហ៊ុថា ដែលអ្នកអញ្ជើញយើងមកបរិភោគនេះជាល្អឬអាក្រក់ ?
ពៀនហ៊ុតក់ស្លុតក្នុងចិត្តញ័រខ្លួនអស់ពាំងខ្លួនមិនឆ្លើយថាអ្វីសោះ ។

គួនអ៊ូឃើញពៀនហ៊ុជាប់តំរុះដូច្នោះ ក៏ស្រែកគំហកថា អញគិត
ថាឯងជាមនុស្សល្អ អញក៏ធ្វើត្រង់ល្អចូលមក គួរឬឯងគិតប្រទូសក៏ឃ
ដល់អញ ? ពៀនហ៊ុឃើញគួនអ៊ូដឹងរឿងហើយក៏ស្រែកហៅថាហានថា
ពួកយើងចុះដៃជាប្រញាប់ ! ថាហានដែលឈរនោះមិនទាន់ទឹងកំរើក
ខ្លួន គួនអ៊ូសុះទៅកាប់ស្លាប់ជាច្រើនអ្នក ពៀនហ៊ុកំយណាស់សុះរត់ទៅ
ចូលក្នុងកំផ្ទៃ គួនអ៊ូចោលគ្រប់ពីដៃកន្ត្រាក់យកជាវដេញតាមទៅ ពៀន-
ហ៊ុឃើញគួនអ៊ូដេញជិតក៏យកកូនឃ្លុបត្រឡប់ចោលតម្រង់មកវិញ គួនអ៊ូ
យកជាវឆក់កូនឃ្លុបខ្ចាតចេញ ក៏កាប់ពៀនហ៊ុជាប់ពាក់កណ្តាលខ្លួន
ស្លាប់ ហើយត្រឡប់ក៏ទៅឯបងថ្លៃឃើញថាហានពៀនហ៊ុតំទ្ធជុំវិញជា
ច្រើន គួនអ៊ូក៏ដេញកាប់សម្លាប់ថាហានពាំងនោះបែកត្រាត់ទៅខ្លះ ស្លាប់
ពីការខ្លះ ហើយគួនអ៊ូក៏ចូលទៅចូលលោកគ្រូចិនតៅចេងថា គ្រានេះ

បើកុំតែលោកឲ្យដំណឹង ខ្ញុំ កំទឹងអន្តរាយដ៏វិត ។ លោកគ្រូចិនកៅចេង
ថា ខ្ញុំនាគាគាពទឹងមៅក្នុងវត្តនេះតៅ ពួកម៉ាកតៀនហ៊ុកំទឹងគុំគួនធ្វើ
អន្តរាយជាមិនខាន អាគ្មាកាពទឹងតៅរកវត្តឯទៀតទៅហើយ ។ គួនអ៊ូ
កំលាលោកគ្រូចិនកៅចេងចេញៅ ទាំរថបងថ្លៃទឹងតាហានតម្រង់តាម
ផ្លូវៅស្រុកអៀងយ៉ុង ។

ឯអង់សិកៅហ្គាយស្រុកអៀងយ៉ុង ដែលជាដន្លង់ទឹងហានហុក
ខោះ លុះឮដំណឹងថា គួនអ៊ូសម្លាប់ហានហុកស្លាប់ កំនិកគិតតែក្នុងចិត្ត
ថា "គួនអ៊ូនេះមានថ្លៃដៃខ្លាំងពូកែមែន បើទឹងចាប់យកខ្លួនចំពោះមុខមិន
ជានេ ត្រូវតែធ្វើកលឧបាយឲ្យគួនអ៊ូទុកចិត្តសិន ហើយសឹមចាប់សម្លាប់
ចេញ" គិតហើយក៏កេណ្ឌប្រមូលតាហាន ឲ្យៅស្កាត់ទៅតយតាមផ្លូវ
ជារ្រៃនតំបន់ កុំឲ្យគួនអ៊ូរត់រួចៅបាន លុះអង់សិកដឹងដំណឹងថា គួនអ៊ូ
មកដល់ស្រុកហើយ ក៏ឡើងសេះនាំតាហានចេញៅទទួលគួនអ៊ូ ដោយ
សុភាព ហើយសួរថា អ្នកមកនេះទឹងៅណា ? ។ គួនអ៊ូតបថា
យើងណាមហាឧបាជទឹងទាំបងថ្លៃៅរកឡៅពីឯស្រុកគីជីវ ។ អង់សិក
ថា អ្នកមកតាមនេះជាផ្លូវជាង់ស្រយ៉ាលខ្លាយណាស់ ពេលកំដីតយប់
ហើយ សូមអញ្ជើញអ្នកទឹងបងថ្លៃៅសំណាក់ក្នុងស្រុកនេះសិន ព្រឹក
ឡើងសឹមអញ្ជើញៅ ។ គួនអ៊ូបានស្តាប់អង់សិកទិយាយ ក៏មិនមាន
សេចក្តីសង្ស័យ ទើបឆ្លើយថា បើអ្នកអនុគ្រោះហើយ យើងក៏សំណាក់
នៅទីនេះ ១ យប់ចុះ ។ អង់សិកក៏នាំគួនអ៊ូទឹងគ្រួសាឡៅពី ចូលៅ
ក្នុងស្រុក ហើយចាត់ចែងទីដំណេកទឹងទីបរិភោគ ខណៈនោះអង់សិកក៏

ត្រឡប់មកឲ្យរៀបចំចំណីអាហារអោយញីញាតួនអ៊ូបរិភោគ មនុស្សបំរើក៏ទៅអញ្ជើញតួនអ៊ូ។ ក៏ទឹកតែកន្ធិចិត្តថា "ពៀនហ៊ីហៅយើងទៅបរិភោគអាហារ ក៏គិតច្រឡូសាយយើងម្តងហើយ ឥឡូវអង្គសិកឲ្យហៅយើងទៅបរិភោគម្តងទៀត ខ្លាចក្រែងធ្វើជាកលៗបាយដូចពៀនហ៊ីទៀតទេដឹង" តួនអ៊ូកទឹកកន្ធិខណៈនោះក៏ឲ្យពិការល់សង្ឃឹយ ទើបថ្លាប់ទៅមនុស្សបំរើនោះថា ដែលអង្គសិកឲ្យហៅយើងទៅទទួលទានអាហារនោះយើងមានសេចក្តីអរគុណច្រើនណាស់ តែថាបងថ្ងៃយើងជាស្រីគ្មាននរណាទៅតំជរសោះយើងនឹងទៅពុំបាន ។ មនុស្សបំរើនោះក៏វិលទៅថ្លាប់អង្គសិក។ ក៏ឲ្យលើកយកចំណីអាហារទៅជូនតួនអ៊ូដល់ទីកន្លែង តួនអ៊ូក៏ឲ្យយកសម្រាប់នោះជូនទៅឲ្យបងថ្ងៃពិសា ។ លុះពេលយប់តួនអ៊ូបង្គាប់ភាហានឲ្យនាំគ្នាដេក ឯខ្លួនតួនអ៊ូក៏ដោះក្រែសបេញអង្គុយអុជទៀនមើលសៀវភៅយាមក្បាបងថ្ងៃទៅខាងក្រៅ ។

អង្គសិកទើបបង្គាប់ហោប៉ាន់ថា ឥឡូវតួនអ៊ូរត់ពីមហាឧបរាជមកសម្លាប់ហាន់ហុកទៅហ្វាយស្រុកនឹងនាយគយលក្ខតាំង ២ នាក់ស្លាប់ទៅហើយ បើយើងនឹងព្រតចាប់យកខ្លួនបញ្ជូនទៅទីក្រុងវិញ តួនអ៊ូមានថ្លៃដៃខ្លាំងពូកែណាស់ ទោះបីយើងនឹងចាប់ខ្លួនបានតែតាហានយើងស្លាប់ជាច្រើននាក់មិនខាន ចាំយើងរិះគិតអានសម្លាប់តួនអ៊ូបេញកុងវិលាយប់នេះពេលយាម ៣ អ្នកឯងត្រូវលើកតាហាន ១ ពាន់ឲ្យកាន់ទ្រនឹងចំបើងម្នាក់មួយផាប់ ទៅឡោមព័ទ្ធទីកន្លែងដែលតួនអ៊ូសំណាក់ ហើយយកភ្លើងដុតព័ទ្ធជុំវិញទីនោះឲ្យតួនអ៊ូនឹងពួកម៉ាកស្លាប់តែម្តង បើកាលណា

ដុតភ្លើងនេះឱ្យដុតផ្ទាល់ជាសញ្ញាយើងនឹងលើកគាហានទៅដួយ ។ ហោ-ប៉ាន់ក៏លើកគាហាន ១ ពាន់ កាន់ទុសនឹងចំបើងគ្រប់ដៃ ទៅតវទុកដុំ វិញមិនសំណាក់គួនអ្វី តែទៅមិនទាន់ដុតភ្លើង ។

ហោប៉ាន់គ្រវែតក្នុងចិត្តថា "មនុស្សខានាក៏ឯពុលល្បីថា គួនអ្វី នេះជាមនុស្សខានថ្លីដៃខ្លាំងពូកែខាងសឹកសង្គ្រាមណាស់ យើងក៏មិន ដែលជួបប្រទះឃើញរូបកងសោះ បើដូច្នេះយើងចាំទៅលបមើលឱ្យ ឃើញច្បាស់សិន" គិតហើយហោប៉ាន់ក៏ចូលទៅសួរនាយទ្វារថា គួនអ្វី នៅឯណា ? នាយទ្វារឆ្លើយថា គួនអ្វីអង្គុយមើលសៀវភៅខាងក្នុង ក្រៅ ។ ហោប៉ាន់ក៏លបដើរចូលទៅឈរមើលឃើញគួនអ្វីអង្គុយមើល សៀវភៅលើតុអី ដៃម្ខាងច្បូតពុកមាត់ ។

ហោប៉ាន់ពិនិត្យមើលទាល់តែក្លេចស្មារតី ហើយស្រែកសរសើររូប នោមគួនអ្វីថា ល្អប្រពៃហួសខេតតា ។ គួនអ្វីឮសំឡេងក៏ភ្ញាក់ស្មារតី ភ័យណាស់ ស្រែកសួរទៅវិញថា នរណាចូលមកមានការអ្វី ? ហោប៉ាន់ ក៏ចូលទៅលុតជង្គង់គំនាប់ហើយដំរាបថា ខ្ញុំបាទឈ្មោះហោប៉ាន់នាយ គាហានអង់សិត ។ គួនអ្វីឮថា ឈ្មោះហោប៉ាន់ក៏នឹកចាំបាន ហើយសួរថា អ្នកឯងជាកូនហោហ្ម៊ីឬ ? ហោប៉ាន់ឆ្លើយថាបាទ ។ គួនអ្វីក៏យកសំបុត្រ ដែលហោហ្ម៊ីផ្ញើមកនោះ ហុចឱ្យទៅហោប៉ាន់ ។ ខណួលយកមកមើល ឃើញសេចក្តីថា "ហោហ្ម៊ីជាបិតា ផ្ញើសំបុត្រនេះមកដល់ហោប៉ាន់ជាកូន ឱ្យបានដឹង ដ្បិតគួនអ្វីនេះមានថ្លីដៃខ្លាំងពូកែណាស់ ខាំងចិត្តក៏ជាមនុស្ស កតញ្ញូខ្វៃត្រន់ទឹងផែនដី បើគួនអ្វីមកដល់ខែតបន់ណា ហើយហោប៉ាន់

ចាន់ដួបប្រទះក៏កុំឲ្យគិតប្រទូសរ៉ាយ តែវិតែរកឧបាយជួយខ្ទប់បំរុងគួនអូ ឲ្យបានចេញទៅដោយស្រួល ព្រោះតំណទៅឯមុខនឹងបានជាទីពឹងពំនាក់" ហោចាន់ជឿក្នុងសំបុត្រដូចោះក៏ភ័យស្លុតក្នុងចិត្ត ទើបបួលមកជិតគួនអ៊ូហើយឱបថា "ខ្ញុំចាមិនដឹងសោះជាឈ្មោះលោកល្អបវិសុទ្ធកុំអីដាវិតលោកនឹងក្បាលក្នុងទីនេះ ព្រោះអង់សិកគិតធ្វើប្រទូសរ៉ាយលោកឲ្យចាហានយកឧសនឹងចំបើងមកគរដុតក្តៅឲ្យលោកស្លាប់ ឥឡូវលោកបួរត្រៀមខ្លួនឲ្យកុងជាប្រញាប់ចុះ ខ្ញុំចាខនឹងទៅគិតឃាត់ហាមចាហានចាំងពួង ហើយនឹងហួសទៅបើកទ្វារស្រុកឲ្យលោកចេញទៅដោយស្រួល" និយាយហើយក៏លាចេញទៅចាត់ការមួយរំពេច ។

គួនអ៊ូបានឮហោចាន់ព័ណិនាប្រាប់សព្វសេចក្តី ក៏ភ័យតក់ស្លុតរន្ធត់ចិត្ត ចាំងមានសេចក្តីត្រេកអរគុណនឹងហោចាន់ពន់ប្រមាណណាស់ ទើបក្រោកឡើងពាក់ក្រសកាន់ដាវ ហើយអញ្ជើញបងថ្លៃឲ្យឡើងជិះរថឲ្យចាហានឃុំនាំចេញទៅមុខ គួនអ៊ូក៏ជិះសេះតាមពីក្រោយ លុះទៅដល់ឃើញទ្វារស្រុកចំហក៏មានអំណរណាស់ ទើបឲ្យចាហានបររថចេញផុតអំពីទ្វារក្រុងទៅ ។ ហោចាន់ឃើញគួនអ៊ូចេញហួសទៅហើយ ក៏វិលត្រឡប់មកប្រាប់ចាហានឲ្យដុតភ្លើងត្រៀបគ្នាឡើង ។ គួនអ៊ូចេញទៅចម្ងាយផ្លូវប្រមាណ ៣០ សិន (១.២០០ ម.) ត្រឡែកទៅឃើញភ្លើងនេះកណ្តាលស្រុកភ្លឺដូចថ្ងៃ ក៏ចូលចិត្តថាហោចាន់ធ្វើឧបាយលុបលាងសេចក្តីកុំឲ្យអ្នកផងដឹងតទៅខ្លួន ។

ឯអង់សិកបានឮសំឡេងជាវរហ៊ាយឃើញពន្លឺភ្លើងនេះឡើង ក៏លើក

តាហានស្រែកដល់ទីសំណាក់គួនអ៊ូ តាហានទាំងពួងស្រែកថា គួនអ៊ូរត់ពីកូនចេញរួចទៅហើយ ។ អង់សិកឮដូច្នោះ កំបរសេះនាំតាហានស្រួតតាមទៅដល់ត្រើស្រុក ហើយស្រែកថា គួនអ៊ូមានថ្លៃដៃទាំងពួកហេតុម្តេចក៏លបរត់ទៅមិនទៅចាំតដៃនឹងយើងសិន ។ គួនអ៊ូតបថា អញគ្មានធ្វើទុសអ្វីនឹងឯងសោះ ហេតុអ្វីឯងមកគិតប្រទូសក៏យអញ ។ អង់សិកឮដូច្នោះ ក៏ស្រែកតបថាអ្វីសោះ កំបរសេះកាន់លួនចូលចាំងនឹងគួនអ៊ូ។ ញាក់សេះពីយមកតទល់យកដាវគាត់លួនធ្លាក់ពីដៃអង់សឹក ហើយលើកដាវគាប់អង់សិកដាច់ញាក់កណ្តាលខ្នងស្លាប់នៅទីនោះ តាហានទាំងអស់ក៏រត់បែកខ្ចាត់ខ្ចាយអស់ទៅ ។ គួនអ៊ូបរសេះតាមបងថ្លៃទៅខ្លួត ក្នុងចិត្តនោះនឹកដល់គុណហោជាំន់មិនភ្លេច ។

ឯខ្លាអៀនចៅហ្វាយស្រុកតងគុនដឹងដំណឹងថា គួនអ៊ូរត់ពីមហាឧបាជហែកទំលាយគុយល្បាតមក ចានសម្ងាត់នាយគុយនឹងចៅហ្វាយស្រុកស្ទាប់ជាច្រើនតំបន់ ខ្លាអៀនក៏ប្រុំតាហានប្រហែល ៣០ នាក់ចេញមកចាំស្ទាត់ផ្លូវ ។ គួនអ៊ូឃើញខ្លាអៀនក៏សួរថា សព្វថ្ងៃនេះអ្នកនៅរក្សាស្រុកសុខសប្បាយទេឬ ? ខ្លាអៀនធ្វើយថា សុខសប្បាយជាទេ ចុះអ្នកមកនេះនឹងទៅណា ? ។ គួនអ៊ូតបថា យើងចានលាមហាឧបាជ ដើម្បីនឹងទៅរកខ្លាពីជាបងយើង ។ ខ្លាអៀនតបថា ខ្លាពីទៅអាស្រ័យនៅនឹងអ៊ូនសៀវ តែឥឡូវអ្នកសៀវនឹងមហាឧបាជធ្លើសឹកសង្គ្រាមនឹងគ្នា ខ្ញុំយល់ថា មហាឧបាជមិនមែនបើកឲ្យអ្នកទៅតាម

ស្រួលទេ ពុកជាអ្នកបានរត់មកដល់ទីនេះក៏ទំនឹងមិនផុតទៅបាន ព្រោះ
ហែហ្គុនទឹងជិនតីតាំងទ័ពនៅតំបន់ត្រើយខ្ទេហង៉ហោ ។

គួនអ៊ូតបថា ពីដើមមហាឧបរាជខ្លួលប្តេជ្ញាពុកទំនឹងយើង ឥឡូវ
យើងឮដំណឹងបងយើងហើយ យើងក៏ត្រូវចេញមកតាមសញ្ញា អ្នកបូរ
អាណិតជួយចាត់រកពូកចម្ងឹងជូនយើងទៅត្រើយម្ខាង ត្រង់កំពង់ខាងត្បូង
ឬខាងជើង ល្មមឲ្យផុតពីទ័ពហែហ្គុនចុះ ។ ឡៅអៀនថា ពូករបស់
យើងក៏មាននៅស្រាប់ តែដែលទំនឹងចម្ងឹងជូនអ្នកទៅ ទោសក៏ត្រូវមាន
ដល់យើង ។ គួនអ៊ូតបថា ស្រុកដែលអ្នករក្សានៅនេះក៏ជាស្រុកមុខ
គយ ខ្លួនយើងក៏ចាំបានយកអាសាសម្ងាប់ងាន់លៀង, ប៉ុន្តែវា ដែលជា
ពាហានឯកអ្វីនសៀវស្ងាប់ ហើយអ្នកទើបចាំបានសេចក្តីសប្បាយដោយសារ
យើងដែរ ហេតុម្តេចក៏ក្ងេចមិនគិតដល់គុណយើងផង គ្រាន់តែឲ្យចម្ងឹង
ជូនទៅប៉ុណ្ណោះមិនបាន" ហើយគួនអ៊ូមិនបានគិតញ៉ាញ៉ែត ទើបឲ្យ
ពាហានបររថបង្ហូសទៅដល់មាត់ទន្លេហង៉ហោ ។

ឯជិនតីដែលហែហ្គុនឲ្យឃុំពាហានមកតាំងបន្ទាយនៅតំបន់ ១ លុះ
ឮដំណឹងថា គួនអ៊ូនាំបងថ្លៃមកដល់មាត់ទន្លេហើយ ក៏ឡើងសេះលើក
ពាហានចេញពីបន្ទាយហើយក្តែងសួរថា នរណាហ៊ានដើរម្ងឹងមុខ
ទ័ពយើង មកនេះទឹងទៅណា ? គួនអ៊ូស្រែកតបថា យើងឈ្មោះគួនអ៊ូទឹង
សុំឆ្លងទៅត្រើយម្ខាង ដើម្បីទៅរកឡៅតីជាបងយើងនៅស្រុកខាងជើង ។
ជិនតីសួរថា មានសំបុត្រមហាឧបរាជបើកគយមកដែរឬទេ ? គួនអ៊ូ
ឆ្លើយថា យើងមិនមែនជាខ្ញុំកំដរស៊ីឈ្នួលត្រួតរបស់មហាឧបរាជកាលណា

ត្រូវការអ្វីទើសុំសំបុត្រនាំឲ្យវាល់ ។ ដំនូតវិស្រែកថា យើងជាពាហនៈ
វរណវែហាំខ្ញុំជាមេទ័ពបង្គាប់យើងមកនៅរក្សាទីនេះ មិនឲ្យនរណាដែល
មិនមានសំបុត្របើកគយមកនោះឆ្លងទៅមកបានទេ កុំថាតែមនុស្សដើរដី
ដូចយ៉ាងអ្នកឯងនេះឡើយ ទោះជាសត្វមានស្លាបហើរលើអាកាស
ក៏ទៅមិនរួចទើងដែរយើងឡើយ ។ គួនអ៊ូបានស្តាប់ដូច្នោះ ខឹងខ្លាំង
ណាស់ ធ្វើឃើញថា ដែលយើងមកនេះខ្លួនមិនបានឮដំណឹងល្បីឈ្មោះ
យើងខ្លះទេឬ? អ្នកដែលឃាត់ទាំងទើងយើង។ សម្លាប់ចោលជាច្រើន
នាក់មកហើយ ។ ជំនូតថា ដែលខ្លួនសម្លាប់បាននោះតែពាហនណា
ដែលគ្មានថ្លៃដៃ ឯមនុស្សយ៉ាងយើង អ្នកមិនធ្វើម្តេចបាន ។ គួនអ៊ូថា
ដែលខ្លួនអួតថាខ្លាំងពូកែនោះ បើប្រៀបទើងថ្លៃដៃនាន់លៀង, ប៉ុនធើវ
បានឬទេ? ជំនូតបានស្តាប់ក៏ខឹងណាស់ ទើបបរសេះពាំដាវចូលច្បាំង
ទើងគួនអ៊ូបាន១ភ្លែង គួនអ៊ូលើកដាវកាប់ត្រូវដំនូតដាច់តង្កាត់ពីលើសេះ
ស្លាប់ ពាហនពាំងអស់ក៏បែកបាក់ខ្ចាត់ខ្ចាយរត់ទៅ គួនអ៊ូក៏ស្រែកឃាត់
ពាហនដែលរត់នោះឲ្យឈប់ថា អ្នកពាំងពួងមិនបានធ្វើទុសអ្វីកុំគប្បីរត់
ខ្លាចយើងឡើយ យើងមិនបានធ្វើអន្តរាយអ្វីទេ ចូរដួយរកទូកចម្ងាយើង
ទៅត្រើយម្ខាងចុះ ។ ពាហនពាំងបានស្តាប់គួនអ៊ូស្រែកដូច្នេះ ក៏
បបួលគ្នាចាត់រកទូកចម្ងាដូនគួនអ៊ូទៅត្រើយម្ខាង ។

(មានត)

រៀបត្រួតតំណែ

លោកសមិន ម្ចាស់ផ្សារដើមៈតែង
លោកវ៉ាយ-ប៊ុក ក្រមការ ដើមខ្សែប្រៃរៀបរៀង

(តមក)

ទិទានផែរូបទេពធិម្មិតទី ២៣

(តមក)

ដល់ពេលដឹតមរណៈ នាយភាណាជនោះក៏បានពោលទៅកាន់បុត្រទាំង ៤ ថា "ខ្ញុំកូន, ក្រោយដែលបិតាធ្វើកាលកិរិយាទៅកាន់បរលោក កូនត្រូវតែរួបរួមសាមគ្គី កុំឈ្លោះទាស់ទែងគ្នា ។ ផលប្រយោជន៍ដែលបានមកពីគ្រួសារដែលសាមគ្គីគ្នាមានសារៈសំខាន់បំផុត គឺការដែលជួយគ្នាទៅវិញទៅមក, មនុស្ស បើខ្លះជាមានគ្នាច្រើនតែច ក៏គង់អាចបំពេញតិច្ចការដែលលំបាកឲ្យសម្រេចទៅបាន, ប្រៀបដូចជាសរសៃតំណជាតិរួបរួមប្រមូលជាបាច់ អាចការពារមិនឲ្យក្ងៀងហូរទៅទឹកបាន ; សរសៃតំណជាតិដែលនេះ បើបិតនៅពាក់ព័ន្ធ មិនអាចការពារខ្លួនទៅទឹកក្ងៀងបានទេ បើតាមសភាពផ្ទុយវិញ ទឹកក្ងៀងអាចធ្វើឲ្យស្ងាប់ខ្លួតំណជាតិបាន ។ ហេតុដូច្នេះ កូនត្រូវតែបិតនៅស្រុះស្រួលរួបរួមគ្នាជាសុខចុះ ។ បើដោតអាសនា ជំទាស់មិនឲ្យកូននៅរួបរួមគ្នាបានទេ បិតាបានតប់ថ្ងៃ ៤ នៅក្រោមបន្ទប់ដេកបិតា, ថ្ងៃនោះមានចាកអក្សរដាក់ឈ្មោះកូនឯង

តាំង ៤ នាក់, ដូច្នេះ បើអ្នកបានរកឃើញហើយ ចូរយកថ្លៃវានោះ តាមឈ្មោះសព្វ។ ខ្ញុំចុះ" ។ ក្រោយដែលបានផ្តាំកូនដូច្នេះហើយ នាយពាណិជក៏ធ្វើមរណកាលទៅ ។

ពីរបីថ្ងៃក្រោយមក កូនតាំងបីនោះឈ្មោះភាស់ខែង់គ្នា បែកបាក់គ្នា ហើយទៅកាយដីក្រៃមបន្ទប់ដេកអាពុក បានយកថ្លៃវាបស់ខ្លួនមក; នៅកង់ថ្លៃវាកូនច្បងមានដំ, កង់ថ្លៃវាកូនទីតិរមានឆ្ងួង, កង់ថ្លៃវា មានទម្រង់ដូចនាវានៃកូនទីបីមានជាក់ឆ្នឹង; កង់ថ្លៃវាកូនទីបួនមានជាក់ចំបើង ។ កូនប្រុសតាំងបួននាក់ មិនយល់ទូវចំណងរបស់បិតា ក៏បានចូលទៅសាកសួរបណ្ឌិតជាច្រើនអំពីរឿងនេះ តែគ្មានបណ្ឌិតណាម្នាក់អាចពន្យល់បំភ្លឺឱ្យជាក់ច្បាស់បានសោះឡើយ ។ កង់រយៈពេលជាច្រើនថ្ងៃ, ជនតាំងបួននាក់ក៏បិតនៅឯកឯងដ៏ពីគ្នា មានចិត្តព្រួយបារម្ភជាខ្លាំង ។

មានកាលមួយថ្ងៃ អ្នកតាំងបួននាក់បានចូលទៅកាន់ក្រុមព្រះពុទ្ធទីប្រឹក្សានៃព្រះចៅក្រុងវិត្ត ហើយសាកសួរសមាជិកអមព្រះអង្គ តែព្រះពុទ្ធទីប្រឹក្សាតាំងនោះ មិនអាចពន្យល់ឱ្យដឹងច្បាស់លាស់ថាតើថ្លៃវានោះមានន័យយ៉ាងណាសោះឡើយ ។

មានព្រាហ្មណ៍ពីរនាក់ទៅកង់ទន្លេបែតិស្ថាន មានប្អូនស្រីម្នាក់មេម៉ាយ, នាងនោះមានរូបឆោមលោមពណ៌ស្រស់ប្រឹមប្រិយ. នាងបានរួមសង្វាសជាមួយនឹងព្រះពុទ្ធរូបនៃស្តេចនាគ ដែលយាងចេញអំពីបាតាល ។ នាងក៏មានថ្លៃវានោះ ។ ព្រាហ្មណ៍តាំងពីរនាក់កាលបានឃើញប្អូនស្រីខ្លួនមានគតិ ក៏តើតមានសេចក្តីខ្វាសគេ ទើបដកខ្លួន

ថយទៅនៅកន្លែងមណ្ឌលមួយឆ្ងាយពីប្រទេស ។ ដល់ថ្ងៃក្រោយមកនាង
បានឆ្លងទន្លេ បានបុត្រប្រុសមួយសន្ធឹតថា សាលវាហនៈ (Sálávahana) ។
សាលវាហនៈ បិតនៅជាមួយមាតាឯគេហដ្ឋានឪយុសន្ធំឆ្នាំ ហើយ
បានឮដំណឹងអំពីរឿងថ្លៃកែវបួននោះ ក៏បានចូលទៅកាន់ទីប្រឹក្សាព្រះ
មហាក្សត្រិយ៍ឯនគរប្រតិស្ឋាន ពោលថា: "សូមអភ័យទោសព្រះពជ្ជទី
ប្រឹក្សា ! ខ្ញុំនឹងពន្យល់បំភ្លឺអំពីនិយថ្លៃកែវទាំងបួន" ។ ក្នុងពេលនេះព្រះ
ពជ្ជទីប្រឹក្សាក៏បានសុំឲ្យព្រះអង្គម្ចាស់ពន្យល់; ព្រះអង្គម្ចាស់សាលវាហនៈ
ក៏ពោលថា "អ្នកដែលមានថ្លៃកែវដាក់សុទ្ធតែដី ត្រូវបានកោតទុកថាជា
សង្ឃារមៈនឹងអសង្ឃារមៈ; អ្នកដែលមានថ្លៃកែវដាក់សុទ្ធតែធ្យូង ត្រូវបាន
លោហធាតុទាំងប្រាំបី គឺ មាស ប្រាក់ ទង់ដែង សំរឹទ្ធ ស្ពាន់
សំណ ដែក; អ្នកដែលមានថ្លៃកែវដាក់សុទ្ធតែឆ្អឹង ត្រូវបានដំរី សេះ
គោ ក្របី ពពែ ជ្រូក ទាសទាសី គឺសត្វទ្វេបាទនិងចតុប្បាទ;
អ្នកដែលមានថ្លៃកែវពេញទៅដោយចំបើង ត្រូវបានសម្បត្តិទាំងគ្រាប់ឈើ
គឺ ស្រូវ ថ្លៃ ស្រូវឆៃ តំណជាតិវែស (Vesce) សណ្តែកបាយ
ពពាយ ល្ង មូតារដ (Moutarde) ។ អ្នកទាំងបួនខាងដើមបានឮ
ព្រះអង្គម្ចាស់សាលវាហនៈកាត់សេចក្តីដូច្នោះ ក៏សប្បាយចិត្តគ្រប់ៗគ្នា,
បានត្រមេត្រងយកស្តើមតិកសព្វ ។ ខ្ញុំនេះហើយ ក៏បានទទួលនូវសេចក្តី
សុខជាកិយ្យាកាពតទៅ ។

ព្រះបាទវិក្រមាទិត្យទ្រង់ព្រះសណ្ប៉ាប់ឲ្យមតិមហាជនចំពោះការ
កាត់សេចក្តីខាងលើនេះ ទ្រង់ក៏ចាត់អមាត្យឲ្យទៅអញ្ជើញព្រះអង្គម្ចាស់

សាលវ៉ាហនៈឯនគរប្រតិស្ឋាន ។ តែព្រះអង្គម្ចាស់ស្តេចមិនបានយាងទៅតាមព្រះរាជតម្រាស់ទេ ទ្រង់មានព្រះបន្ទូលប្រាប់អមាត្យវិញថា. "តើមានប្រយោជន៍អ្វីត្រង់ការចូលទៅគាល់ព្រះបាទវិក្រមាទិត្យ? បើទ្រង់ត្រូវការជួបនឹងយើង ម្តេចក៏ទ្រង់មិនស្តេចយាងមកកាន់ទីនេះ" ។ អមាត្យក៏វិលទៅក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យ តាមបន្ទូលព្រះអង្គម្ចាស់សាលវ៉ាហនៈ ។ ព្រះបាទវិក្រមាទិត្យទ្រង់មានព្រះរាជហឫទ័យសន្សំយ៉ាងពន់ពេកចំពោះបន្ទូលព្រះអង្គម្ចាស់ដែលនៅវ័យក្មេង ហើយទ្រង់អន់ព្រះរាជហឫទ័យទ្រង់ក៏ស្តេចយាងទៅដោយនាំទ័ព ៤ កងទៅគាន់នគរប្រតិស្ឋាន ។ ក្នុងពេលនោះព្រះអង្គម្ចាស់សាលវ៉ាហនៈ ទ្រង់មិនបានស្តេចទៅគាល់ព្រះបាទវិក្រមាទិត្យទេ ដោយទ្រង់តតាំរតើបញ្ជាប់ញ័រសោះឡើយ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ព្រះក្រោធជាខ្លាំងក៏បានចាត់សេនាគាហានឲ្យទៅលោមព័ទ្ធនគរនោះ ទឹងដំណាក់ព្រះអង្គម្ចាស់សាលវ៉ាហនៈ ។ ដល់ព្រះអង្គម្ចាស់ទ្រង់ទតទៅឃើញដំណាក់ទ្រង់ ដែលព្រះបាទវិក្រមាទិត្យទ្រង់ចាត់កងយោធាឲ្យមកលោមព័ទ្ធជុំវិញដូច្នោះ, ទ្រង់ក៏បានអធិដ្ឋានវិញ្ញាទុកាពព្រះបិតាឲ្យបញ្ជូលដំរីតទៅកងអគ្គកាពដំរី, សេះ, គាហានដែលធ្វើពីដីឥដ្ឋ ហើយទ្រង់មានបន្ទូលឲ្យចូលទៅតយុទ្ធ ។ ក្នុងរយៈវេលាជារួចទៃថ្ងៃ, កងទ័ពព្រះអង្គម្ចាស់សាលវ៉ាហនៈទឹងកងទ័ពព្រះបាទវិក្រមាទិត្យ ក៏តស៊ូគ្នាដោយក្បួនសង្គ្រាមប្លែក ។ ។ ពុកជាយ៉ាងណាក៏ដោយ ព្រះតេជានុភាពព្រះបាទវិក្រមាទិត្យមិនអាចផ្តាញ់ទ្រាំកងទ័ពព្រះអង្គម្ចាស់សាលវ៉ាហនៈបានទេ ។

មានកាលមួយថ្ងៃ, ព្រះបិតានៃព្រះអង្គម្ចាស់សាលវាហនៈ, ព្រះ
រាជបុត្រស្តេចកុជង្គ្គនាគ ដែលទ្រង់គង់នៅនគរបាតាល ទ្រង់ស្តេចយាង
មកគាន់ទីនោះនៅពេលព្រលប់ ហើយក៏ទាំងឆន្ទាហានព្រះបាទវិក្រមា
ទិត្យ ធ្វើឲ្យល្ងីល្ងើដោយនុសថពុលនោះ. ហើយស្តេចយាងវិលទៅគាន់
នគរវិញ ។ ព្រះបាទវិក្រមាទិត្យ, ដល់ឃើញឆន្ទាហានរបស់ព្រះអង្គ
ល្ងីល្ងើដូច្នោះ, ទ្រង់បានសូត្រមន្តស្តេចនាគរាជ "វាសុកី" ដើម្បីនឹង
ធ្វើឲ្យឆន្ទាហានព្រះអង្គមានអាឧុគាពឡើងវិញ ដោយប្រោះទឹកអម្រឹត,
មហារាជ "វាសុកី" ពេញព្រះរាជហប្ញទ័យទ្រង់បានព្រះរាជទានទូវទឹក
អម្រឹតនោះទៅព្រះបាទវិក្រមាទិត្យ ហើយក៏កៀសព្រះអង្គឋាត់ទៅ ។
ព្រះបាទវិក្រមាទិត្យ ទ្រង់បានទឹកអម្រឹតនោះ ក៏ស្តេចយាងប្រញាប់
ប្រញាល់ទៅជួយឆន្ទាទ័ពព្រះអង្គ ។ តែដល់ស្តេចយាងបានពាក់កណ្តាល
ផ្លូវ ស្រាប់តែមានបុគ្គលពីរនាក់ដែលព្រះអង្គម្ចាស់សាលវាហនៈទ្រង់បាន
ចាត់មក, សូមមកសុំពីព្រះបាទវិក្រមាទិត្យ ទូវទឹកអម្រឹតនោះ ។ ព្រះ
បាទវិក្រមាទិត្យ ទ្រង់បានសន្យាថា ទ្រង់តែវតែព្រះរាជទានទូវបេះសំណាង
ដែលគេសុំព្រះអង្គ ។ ព្រោះហេតុដូច្នេះ ដើម្បីកុំឲ្យក្សត់ទូវកិច្ចសន្យា
នោះ, ទ្រង់ក៏បានព្រះរាជទានទូវទឹកអម្រឹតនេះទៅបុគ្គលពីរនាក់ ដែល
សុំព្រះអង្គ ។ កិត្តិយសជាពិតគឺមិនត្រូវបែកឡើតឡើយ ទ្រង់ពាក្យដែល
ពោល ។ មហារាជវិក្រមាទិត្យ កាលទ្រង់ធ្វើព្រះរាជដំណើរតែមួយ
ព្រះអង្គឯងតាមផ្លូវបាន ទ្រង់ព្រះតម្រិះដូចខាងលើ ។ ព្រះបាទវិក្រមា-
ទិត្យ ទ្រង់ព្រះតម្រិះតទៅទៀតថា: ពេលណាមនុស្សក្នុងកាត់សាគរគឺទុក្ខ

សោក ដែលលំបាកទឹងធ្ងន់ពន់ពេក ហើយបានធ្ងន់រួចដោយសារកម្លាំងគុណធម៌ ដែលបានមកពីការប្រព្រឹត្តិនូវកិច្ចការដោយកុសល, ពេលនោះគេទើបឃើញអានុភាពរបស់សាស្ត្រ: ។

កាលពេលនោះ ស្តេចនាគវាសូកីទ្រង់ស្តេចយាងពីនគរបាតាល បានបង្ហាញនូវភ្លៀងអម្រឹត ហើយធ្វើឲ្យពួកតាបានមហាភវិក្រមាទិត្យ ដឹងខ្លួនភ្ញាក់ស្មារតីឡើង ហើយទ្រង់យាងវិលត្រឡប់ទៅវិញ ។ កាលតាបានមហាភវិក្រមាទិត្យ ដូចជាមនុស្សភ្ញាក់ពីនិទ្រា បានបញ្ចេញនូវសព្ទសូរគឹកកងរំពងដូចធម្មតា ។ ព្រះបាទវិក្រមាទិត្យទ្រង់បានទតទៅឃើញកងតាបានបានដឹងស្មារតីគ្រប់ៗ គ្នា, ទ្រង់ស្តេចយាងជាមួយពួកតាបាន វិលត្រឡប់ទៅកាន់ព្រះនគរវិញ ។

រួចទេពនិម្មិតទីម្តែបី គ្រាប់បង្គំទូលព្រះមហាក្សត្រិយ៍ក្រោជ:ថែមទៀតថា: បើទ្រង់មានព្រះពាជបរិយា ដូចព្រះបាទវិក្រមាទិត្យថែបនេះ, ទ្រង់អាចគង់នៅលើបល្ល័ង្កទិព្យនេះបាន ។

ព្រះបាទក្រោជ:ទ្រង់ព្រះសណ្តាប់នូវរឿងរ៉ាវ ដែលរួចទេពនិម្មិតទីម្តែបីថ្វាយ ក៏ទ្រង់មិនបានទទួលនូវមុខតំណែងកងតាពេលនោះ ។

(មានត)

រឿងសៅរ៍សោយ

(សំសោរដាតក)

ព្រះមហាឧត្តមវិជ្ជា ជិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាជាលើរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមគម្រោយសាស្ត្រស្ងឹកវិត

តមកអំពីកម្ពុជសុរិយា លេខ ៩ ឆ្នាំ ១៩៥៥

សូមទោសអស់លោក-អ្នកអានទស្សនាវដ្តីនេះ, ការអាក់ខានមិនបានបុះរឿងនេះជាប់ជាលំដាប់មកនោះ មកអំពីលោកអ្នករៀបរៀងរឿងនេះ ត្រូវនិមន្តទៅបន្តវិជ្ជាឯប្រទេសថៃ ហើយលោកមិនបានបញ្ជូនរឿងខាងបុងនេះមកពុទ្ធសាសនបណ្ឌិត្យ ឲ្យទាន់ពេលវេលាដែលត្រូវបុះផ្សាយ ។

គួរតែសេនីយ អមាត្យមន្ត្រីគ្រប់ប្រាណ

បង្គំអវគាណ(១) ទើបបានជាការគប្បី ។

មើខ្លួលបង្គំ ថ្វាត់ថ្វាយប្រណម្យនវបតី

ក៏គ្មានសំរី មង្គលសួស្តីកើតបាន ។

មានតែរំងឹតតែ ធ្វើឲ្យបតិត្រកូត្រកក្ងាន្ត

អាប់ទន្ទឹងប្រាណ ព្រោះបានអ្នកពោសគាវ: ។

ជ្រួតហេតុព្រះអង្គ មានយសខ្ពស់ខ្ពង់វង្សស័ក្តិ

សមតែសៅរ៍ក មន្ត្រីកវីព្រាហ្មណា ។

ដែលឥតៈពោសទុក្ខ រងកម្មចាំគុកទុក្ខា

---

១ អវគារ ។

ថ្វាយថ្វាត់ក្សត្រា ខើបជាមង្គលដោតដំយ ។
ពេលនោះចក្រា បរមក្សត្រាកូវខ្ញុំយ
ទឹកកន្ត្រែព្រះដំយ មកមែតតស្តីឡើយហោង ។
ថាអ្នកនេះណា អង់អាចប្រាជ្ញាកន្ធង
មិនជាសមផង ខ្ញុំខ្ញងជាពង្សក្សត្រា ។
តាំងរូបភាពអគ្គ កំស្រស់ខ្ញីសខ្ចង់នាយា
ឆ្លៀវឆ្លាស់ណាស់ណា ចែងចេះដោះសាសេចក្តី ។
ចិន្តាជាស្រេច ខើបស្តេចបែរគេចស្រដី
សួរស្តៅទៅខ្ញុំ ថារ៉ុ ! មិងមកពីណា ? ។
កំបានជាមិង ធ្វើឫកវង់ភ្លឺដូខ្ញាំងក្លា
បេះសេះបេស្តា អំណាចអាជ្ញាអញនៃ ។
ហ៊ានបុះងូតទឹក គ្មានតាំងភ្ញាំងក្លឹកទឹកត័យ
កន្ធអាងមាំសម័យ ប្រដាប់សម្រាប់នគ្គា ។
ចូរអាសារសំពូ ទំយោយប្រាយប្រាប់ធាប់ប៉ា
មិងកូនអ្នកណា បានជាហ៊ានក្លាឥតប៉ី ។
ចមកពតបថា ថ្ងៃមួយនោះណាតាសី
នាំគ្នាហ្មាតខ្ញុំ ប៉ីចៅចក្រីយកទៅ ។
ជាក់ផ្តេតចោលស្មោះ មិនថ្វាយទឹកដោះឲ្យហូ
ហើយក៏រះចេញទៅ ពួនទៅកន្ធខ្ញីដរៃ ។
ព្រះចៅព្រះអគ្គ ពុំបានសោយស្រស់ឡើយនៃ

ឃ្លាន់ស្រែកពេកវៃក្រៃ ក្សត្រៃថ្លៃស្រែកយំពុំស្បើយ ។
ឯពួកស្រីស្នំ រាំទំសម្លុំកន្ទើយ
ពុំអើពើឡើយ បណ្តាយឲ្យយំឯកា ។
ខ្ញុំយល់ច្នោះហោង កំពៅត្រកងនគ្គា
នាំឃ្លាតយាត្រា តម្រង់ពៅត្រង់អាងវៃ ។
ជាក់ចៅសោកា ឲ្យស្រែងធាតនោះនៃ
កុមារអរវៃក្រៃ កំស្រែងអស់អង្គាកាយ ។
ទទេះលោតលេង កញ្ជ្រោកកញ្ជេងសប្បាយ
ទឹកសោតខ្លាត់ខ្លាយ មកត្រូវខ្លួកាយខ្ញុំខ្ញី ។
ខ្ញុំខ្លួលហេតុការណ៍ ដោយស្មោះអស់អាថសេចក្តី
សូមព្រះចក្រី ទ្រង់ជ្រាប់សេចក្តីនេះផង ។
ពេលនោះកូវន័យ កំទ្មេវត្តក្សត្រៃថ្លៃបាស់ប្បង
ឧង្គារសោសង ឋខ្លួលរឹងស្ងួងពៅថា ។
អើ ! រឿងតំណនេះ លើកលុបឈប់ស្ទះសិនក៏
យើងសួរមឹងថា គោត្រនាមនោះណាឈ្មោះអ្វី ?
មឹងកូនអ្នកណា ឋូលមកផ្ទាយើងខ្ញុំ
អស្ចារ្យអស់ក្តី ឥតប៉ិគោរពយើងឡើយ ។
មឹងហ៊ានរួមច្បាណ ឧឹងកូនកល្យាណត្រាណត្រើយ
បុត្រីយើងហើយ ត្រេដើយកន្ទើយសំដី ។
យង់ឃ្នង់ដង្ហដ្ឋ ពុំចេះដាក់តួគួរសម

ពុំថ្វាយបង្គំ ខ្ញុំយើងជាធំឡើយណា ។
ក្សត្រៃថ្ងៃសៅរ៍ ស្តាប់ហើយឆ្លើយទៅវិញថា
ខ្ញុំខ្លួលក្សត្រា តែនាមអាត្មាប៉ុណ្ណោះ ។
ឯគោត្រកូល ខ្ញុំពុំព្រមខ្លួលឡើយសោះ
តីខ្ញុំចំពោះ នាមឈ្មោះសៅរ៍កជា ។
ផ្ទាប់រុងរឿងក្តាត់ សោយភោជសម្បត្តិទៅនា
អនន្តភាព ទើបតែឃ្លាតឃ្លាមកហោង ។
កិន្នរ៍ក្តក្សត្រៃថ្ងៃ ព្រះអង្គខ្ញែកយកខ្លួន
ញ៉ាំដៃដើងផង ខ្ញុំបខ្ញាចអំណាចថ្លាម ។
ចុះចាកទីនាំង ព្រះរាជបល្ង័ង្គមកខ្ញុំ
ខុនក្រាបសំរើ ទៀបថ្វាយក្សត្រៃថ្ងៃហើយណា ។
លើតដៃប្រណម្យ ថ្វាត់ថ្វាយបង្គំខ្លួលថា
បពិត្រក្សត្រា ជាមហាក្សត្រក្លាហ៊ានក្រៃ ។
ខ្លួនខ្ញុំពុំបាន ដឹងជាក្សត្រកន្តឡើយនៃ
សូមខ្ញែងអភ័យ សន្តោសគោសតែវង្សឯក ។
ស្មានជាព្រះអង្គ ពុំមានពួជពង្សវង្ស
ចេះសូមក្សត្រា មេត្តាសន្តោសប្រោសប្រាណ ។
ត្រាស់ចប់ចមទៅ អញ្ជើញសំរៅអំណាច (១)
គង់បល្ង័ង្គថ្កាន ឯតួក្សត្រកន្តឯងណា ។

---

១ អរិពារ ។

ទ្រង់គន់ឱពាប តាមថ្នាក់សភាពអាត្មា
ស្រែចស្តេចសួរថា បពិត្រកូត្រាបាស់ច្បង ។
ម្តេចទ្រង់លះគាត់ ចោះបង់សម្បត្តិមកហោង
ដើរជាសដោយដង ផ្ទុលឆន្ទក្បៀតឯកា ។
ជ្រៀតជ្រកគោកយ៉ាក លំបិនលំបាកអាត្មា
សូមទ្រង់មេត្តា ប្រាប់ហេតុនោះណាផងនែ ។
ព្រះពោធិសត្វ អធិប្បាយថ្វាយថ្វាត់វែ ។
ថាខ្ញុំនេះនែ មិនផ្សឿសំដីហោក ។
ស្តេចត្រាស់អស់កល ទូលពិតឥតសល់ឡើយណា
រឿងដែលកូត្រា ទុក្ខាសន្ធំពុំស្បើយ ។
ដល់ពេលនេះទ្បី ឋានដប់ប្រាំបីខែហើយ
ឥតបានស្រាន្តស្បើយ ទុកល្ហែល្ហើយមួយថ្ងៃ ។
កិនវត្តនោះណា ស្តាប់មហាកូត្រាថ្លាថ្លៃ
សង្វែគពេកវៃក្រ កូចគិតអាណិតកូត្រា ។
ព្រះទ័យអន់អួល ទន្លឹះខ្សឹកខ្សួលទុក
ស្រក់ទឹកនេត្រា ពុំចេញវាចាស្រដី ។
ស្រែចស្តេចត្រាស់ថា ហៃអស់សេនាមន្ត្រី
ប្អូរធាប់ ។ ទ្បី ចាត់ការសង់ពដកេងរម្យ ។
រៀបចំប្រាសាទ ប្រសើរស្អាងស្អាតទុត្តម
ពួកវៃគ្រែចៀមចំ ទទួលបរមពជា ។

តាំងតួរតន្ត្រី ស្រែរៃខ្ទុយប៉ីរមនា
ភ្លេងចាមភ្លេងជ្វា គឹកគងរំពងខ្ទាំងក្តាត់ ។
រៀបស្រែចស្តេចតាំង ឲ្យយកកូស់ចាំងពោធិសត្វ
ទឹងនាងសុខត្តុ ទេវីវរ័តន៍ជាយា ។
ពលរេហ៍រៃដុំ សូរភ្លេងរងំរមនា
មន្ត្រីយោធា ដង្ហែក្បាអវតារ(១) ។
ទឹងនាងសុខត្តុ សោយរាជសម្បត្តិរដ្ឋហាន
អកំសេកក្សត្រកក្បាត្តុ លុះបាន ៧ ថ្ងៃណា ។
ត្រៃរឹងតកុធកណ្ណ គឺមកុដសុវណ្ណ, ខាន់ថ្ម,
ស្វេតច្ឆត្រសោតណា, ទឹងមហាសុពណ៌ិជាតុក៍រ័តន៍,
ភលីវជនី សម្រាប់នាទីមហាក្សត្រ
មន្ត្រីនាំថ្វាត់ ថ្វាយក្សត្រកូនទ័យថ្ងៃថ្វា ។
បង់គិច្ចស្រែចថ្វាត់ ព្រះចាទគំនូរតួក្សត្រា
ត្រាស់ប្រែសេនា ឲ្យឃ្លាតយាត្រាទៅខ្ញុំ ។
ស្វែងរកប្រញាប់ ប្រដាប់សម្រាប់ចក្រី
ដែលមនុស្សមប្រិយ ប្រញឹដណ្តើមយកទៅ ។
សេនាបតី ស្តាប់ហើយថយខ្ញុំពុំនៅ
ត្រឡប់សំដៅ ចៅក៏ឆ្ពោះទៅចាត់ចែង ។
បញ្ជូនក្លាក់ងារ ទឹងបរិតាខ្នះខ្នែង

---

១ អវតារ ។

រហ័សស្ទុះស្ទែង ខ្ញុំសព្វកន្លែងទិសា ។
ឯព្រៃសិរសៅរ៍ ផុតគ្រែអស់ក្តៅហើយណា
ប្រជាប់ប្រជា ដែលប្រែកន្លងនោះនៃ ។
កំប្រែកន្លង ដូចរដើមធម្មតាវិញ ។
អ្នកយកទីនៃ ឃើញតិតគិតតំយមហិមា ។
តុំហ៊ានលាក់ខ្ពុក ខ្លាចតរៀមមុខវេទនា
ទើបម្ចីលីណា ចេញចាកគ្រីហាដ៏ម្ពន ។
នាំគ្រឿងទំនិនោះ ប្រដូចថ្វាយបំពោះបច្ចស់ច្បង
ដើរដោយដុងដង បំណងតម្រង់ប្តី ។
តំមកជួបគ្នា នៅនាមាគ៌ាមួយខ្លី
ជួនជាសេនីយ ដែលលោកមន្ត្រីប្រើរៀ ។
ឃើញជាក់នេត្រា សួរដឹងហើយណាតុំនៅ
ចង់នាំយករៀ សំដៅលំនៅកំនត់ជ័យ ។
ព្រះបាទកិន្នរត្តុ ឃើញព្រមចមក្សត្រគ្រែគ្រងរៃគ
ទ្រង់ជាក់ពិន័យ ម្ចាត់ ។ រៃ ។ មួយពាន់ ។
តែពោធិសត្តូ សិរសៅរ៍តែន័យាត់ខាន់
ទ្រង់គ្រាស់រួសពន់ រំពាន់សំដែងថ្លែងថា ។
បពិត្រព្រះអង្គ សូមទ្រង់សន្តោសគោសា
កុំជាក់អាជ្ញា ដល់គ្នាឲ្យណា ព្រះអង្គ ។
ដែលទូលបង្គំ ជ្រប់មុខខុក្ខធំតុំបង់

វេទនាយូរលង់ សូមទ្រង់ជ្រាបក្នុងសន្ដាន ។
ថាព្រោះអំពើ ដែលខ្ញុំនេះធ្លាប់មកជ្ដាន
ទើបខ្ញុំត្រូវជ្ដាន ទុក្ខដ៏ពុំក្ស័ន្ដដល់ម្ដង ។
ទ្រង់ស្ងួមតម្កែង ទ្រង់ជ្ញាសង្ឃដោះលែងទៅហោង
កុំឃុំកុំចង អស់អ្នកវែសផង គ្រប់គ្នា ។
ត្រាស់ចប់នវបតី ទ្រៃសង្ឃការ៉ាលី
ទៅអាកាសនា ទិមន្ដសង្ឃជាប្រញាប់ ។
ទីដ៏នេនដ៏ទង់ ពីរត្ដដែលទ្រង់ជ្ញានធ្លាប់
ពីដងពាក់ប្រចាប់ មកជាឆាប់ៗ គ្រប់អង្គ ។
អមាត្យម្ចីម្នា នុនកបត្រាឋលា ត្រាច់ត្រង់
ឆ្ពោះចំតម្រង់ ទៅទិមន្ដសង្ឃសារកា ។
នាំគ្នាវេលាំ សំដៅទៅដល់ហ៊ីយណា
វត្ដារថក ទូលក្ដីប្រថ្នានោះហោង ។
កាលណោះអស់សង្ឃ ទិមន្ដត្រប់អង្គជាម្ចង
ចាំដងទំនោះផង ឆ្ពោះឆ្ពងតម្រង់សីមា ។
លុះជ្ញានទៅដល់ យង់យល់មណ្ឌលក្សត្រា
ទើបវៀបអាត្មា ម្ចីម្នាយាត្រាត្រប់ជ្ញាណ ។
ព្រះជ្ញាតក្សត្រៃថ្ង ទ្រង់ត្រេកពេកក្រៃប្រមាណ
នមស្ការស្រេចជ្ញាន ក្សត្រកក្ដាន្ដទ្រង់ជ្ញានត្រាស់វៃ ។
ឲ្យវៀបចង្ហាន់ ប្រគេនលោកធាន់ទីនៃ

ស្រែចថ្ងាត់ក្សត្រថ្ងៃ ដេស្តដ័យថ្ងាយត្រៃចីវរ ។
ដ៏ល្អបញ្ចង់ ព្រះសង្ឃគ្រប់អង្គគ្រែកអរ
ទទួលចីវរ សោមនស្សស្មោះសរអរក្តាត់ ។
ហើយសព្វនរបតី ទ្រង់ប្រើមន្ត្រីឲ្យចាត់
ជួសជុលសាងវត្ត ដែលទ្រង់ធ្លាប់គង់នោះថ្កាន ។
សាងកុដិ, សាលា, វិហារ, បដិមា ស្អាតស្អាន
ស្រែចថ្ងាត់ក្សត្រក្សាន្ត ទ្រង់ថ្វាយសង្ឃគង់នៅ ។
បំរុងរក្សា ឲ្យថ្កានសុខាតទៅ
ហើយព្រះបរមរៀ តម្រូវឲ្យនេនោះណា ។
លាសិក្ខមកថ្កាន ទ្រង់តាំងកងឋានបុត្រា
ស្រឡាញ់រក្សា ដូចជានុសព្រះអង្គ ។
យូរទៅបរមរៀ ហ្មង់សៅនឹកទៅស្រុកទ្រង់
នឹកធ្លាប់គង់ នឹកចតុរង្គសេនា ។
នឹកជនប្រុស-ស្រី នាហ្មឺនមន្ត្រីសេវកា
នឹកដល់កល្យាណ៍ អនន្តកនិដ្ឋាក្សត្រិយ ។
នុស្រស់មណី ! អនន្តទេវីពិសី
បងចាកបុរី ឃ្លាតស្រីក្សត្រីពុំជា ។
ម៉្លេះសមគោមទ្វៅ នាងសៅហ្មង់នៅកំព្រា
ដ្បិតបងឃ្លាតឃ្លា ឃ្លាតខ្លួនស្ងួនក្សាយូរហើយ ។
ម៉្លេះឆ្នើមថ្មីមថ្ងៃ សង្រៃឆ្ងល់ថ្ងៃឥតស្បើយ

ពុំដឹងរឿងឡើយ ថាបងបានស្បើយល្អើយខុសគ្នា ។
រួចរស់ដីវ៉ា គង់ពរវង្គាជាសុខ
ម្ដេះសមទ្រលុក កវីណាឥតណុកខុសគ្នី ។
តិតថ្លាត់ក្សត្រា ទើបប្រែសេនាមន្ត្រី
នាំសារចេត្រី ទៅថ្វាយមហេសីឯនាយ ។
មន្ត្រីតូចធំ ត្រាបថ្វាយបង្គំរឿងពយ
នាំគ្នាដាយ ទៅនគរនាយនោះខ្លី ។
លុះបានទៅដល់ យន់យល់ខំមលក្សត្រី
ទើបនុនសិរស៏ បង្គំស្រស់ស្រីឆ័តា ។
ថ្វាយសារចេត្រី ហើយទូលក្សត្រីថ្លៃថ្លា
បពិត្រធីតា ដ្បិតមហាក្សត្រាចប្រាស់ឫង ។
ជាព្រះស្វាមី នៃម្ចាស់ក្សត្រីខោរហោង
ប្រើយើងខ្ញុំផង ឲ្យចូលមកគាល់ក្សត្រី ។
មន្ត្រីស្ដីការ ទូលឆ្ពោះអស់អាថ៌សេចក្ដី
ក្សត្រីណានោះស្រស់ស្រី ព្រះទ័យអរវៃកកន្ធឹង ។
ទ្រង់ទតកាដសារ ទើបថ្កាប់រ៉ាវតលងង
ឲ្យរៀបធាប់ហោង គ្រប់កងយោធាជាធាប់ ។
សេនាបតី ទូលលាក្សត្រីត្រឡាប់
រៀបពលប្រញាប់ តែងគ្រឿងប្រដាប់គ្រប់ប្រាណ ។
គីពលដំរី រៃងឫទ្ធិតបីប្រៀបបាន

ណាន់ណែនដែនជាន ប្រមាណប្រាំមួយហ្មឺននាក់ ។
ពលសេះពេញពាស ពាក់មួកដែមាសជៀងជាក់
គ្រែវែស្បែកក័ពាក់ ប្រាំមួយហ្មឺននាក់ដូចគ្នា ។
តមកពលរថ ប្រាំមួយហ្មឺនគត់ឥតភា
នាំគ្នាមីមា លីណាឡើងលើរថា ។
រថនោះសឹងពាស ដោយស្បែកមាសស្បែកខ្លា
ចន្ទោលនោះណា ប្រជាប់ប្រដាប់ឆន់ជាយ ។
ពួកពលថ្មើរជើង ប្រជុំគ្នាឡើងរៀងពយ
ពុំមានពយមាយ ពីពលដល់នាយបញ្ជា ។
សុទ្ធសឹងហៅហាន ចំណានមុះមុតយុទ្ធនា
អាវុធាសោភា កាន់អាវុធាគ្រប់ដៃ ។
ពួកពលតាំង ៤ ជួបជុំគ្រួមក្បួនហើយនៃ
អមាត្យត្រៀតវៃ ទៅទូលស្រីថ្លៃវិញថា ។
បពិត្រក្សត្រី ! មន្ត្រីសេនិយសេនា
ចាត់រៀបត្រៀបត្រា តើឆន់ប្រាថ្នាការអ្វី ? ។
ព្រះនាងបញ្ជា ថាចូរនាំគ្នាឃ្លាតខ្លី
ទៅអចលបុរី ដើម្បីទទួលកជា ។
ដ្បិតអីព្រះអង្គ ស្តេចឆន់ទៅតង់ជន្លា
សំណាក់នៅនា អចលភាពនោះឯង ។

(មានត)

សេចក្តីកាត់នៃក្រុមដំណុំទំនៀមទម្លាប់ខ្មែរ

បរិយាយពីរចាំរបស់ខ្មែរ

លោក ប៊ាប៊-ពិធ រៀបរៀង

នៅចុងឆ្នាំ ១៩៥៣ ខ្ញុំបានបរិយាយតាងនាមក្រុមដំណុំទំនៀមទម្លាប់ខ្មែរម្តងហើយ អំពីនាដសិល្បៈ (សិល្បៈខាងកំ), តន្ត្រីសិល្បៈ (សិល្បៈខាងច្រៀង), តួរាំគ្គសិល្បៈ (សិល្បៈខាងតួរតន្ត្រី) ទំនងអំពីដើមកំណើតស្មោនជារចាំរបស់ខ្មែរ ដោយបានបញ្ជាក់ថា ស្មោនខ្មែរកើតមានឡើង តាំងពីរជ្ជកាលព្រះចាន់ជយវ៉ែនទី ២ គឺព្រះកេតុមាលា ជាមហាក្សត្រខ្មែរសោយរាជ្យដំបូងបំផុត នៅអង្គរ រវាងឆ្នាំ ៨០២ ដល់ ៨៦៩, តែនៅសល់រចាំខ្មែរជាច្រើនទៀតដែលតុំពាន់បានបរិយាយ ។

ក្នុងចំណោមរចាំដែលសល់នោះ ខ្ញុំសូមបរិយាយវេលានេះអំពីស្បែង ៩ យ៉ាង គឺ ១- ស្មោនខោល, ២- ស្មោនយន្ត, ៣- ណាំង ស្បែក ទំនងណាំងត្រលុង ៤- កន្ទែរ ៥- កំស្តែងខ្នោង ដើម្បីសំដែងឲ្យឃើញតួមគតិនៃរចាំដ៏ងនេះ ដែលជាអារ្យធម៌ជាតិគ្រឹងសំគាល់ទំនងជាក្បែកច្រមុះ របស់ខ្មែរជាតិ ហើយដែលជាភស្តុតាងអាចបង្ហាញសកលលោកឲ្យឃើញថា ជាតិខ្មែរមិនមែនជាជាតិថ្មីៗនេះទេ តែជាជាតិចាស់បុរាណមានអារ្យធម៌ជាមរតករបស់ខ្លួន ដោយមានឥរិយាបថសិល្បៈជាគ្រឹះស្ថានសិល្បៈរបស់ជាតិ ចម្រើនដល់កំពូលបំផុត តាំងពីព្រេងមកហើយ ។

រថាំ ៥ យ៉ាងនេះ សត្វថៃរថាំខ្លះសូន្យរូបអស់រលីងទៅហើយ នៅសល់តែឈ្មោះ ដើមិនកត់ត្រាទុកទេ តទៅមុខទើងសូន្យទាំងឈ្មោះទៅទៀតពុំខាន, ហេតុដូច្នេះ បានជាក្រុមជំទុំខំទៀមទម្លាប់ខ្មែរ ស្រាវជ្រាវរួបរួមកត់ត្រាក្សាទុកទាំងរថាំដែលបាត់បង់ ទាំងរថាំដែលនៅមានសត្វថៃជាឯកសារសម្រាប់ប្រទេសខ្មែរ ដូចរៀបរាប់ដោយសង្ខេបតទៅនេះ :

១– ល្ងែនខោល : ជាមហោស្រពព្រះរាជទ្រព្យសម្រាប់លេងក្នុងព្រះរាជពិធីផ្សេង ។ មានព្រះរាជពិធីតាំងតុបម្រែនព្រះជន្មជាដើម, ល្ងែននេះបានជាហៅថាល្ងែនខោល ព្រោះជាល្ងែនមានតួអ្នករថាំសុទ្ធតែប្រុស តាមកត់បញ្ជីនៃព្រះបរមរាជវាំងថា យ៉ាងច្រើនបំផុតមានដល់ ៦៥ នាក់ គឺ ៤ នាក់ជាមេល្ងែន, ២ នាក់ជាអ្នកពោល, ៥ នាក់ជាគ្រូល្ងែន, ៨ នាក់ជាអ្នកភ្លេង, ៩ នាក់ជានាយរោង, ២០ នាក់ជាស្មា, ១៩ នាក់ជាយក្ស, ៦ នាក់ជាតួក, រួមជា ៦៥ នាក់ ។

ល្ងែនវង់នេះ ឥតមានលេងរឿងដទៃក្រៅរឿងរាមកេរ្តិ៍ទេ, ខាងភ្លេងទៀតក៏ប្រើតែភ្លេងពិណពាទ្យមួយយ៉ាង ។ ឯគ្រឿងប្រដាប់សម្រាប់លេងមានច្រើនបែប ខាងតួកមុខ មានមុខយក្ស មុខស្មា ជាដើម, ខាងតួកមកុដ មានមកុដព្រះរាម មកុដព្រះលក្ខ្មណ៍ មកុដព្រះខាងសិតាជាដើម សត្វគ្រប់តាមរឿងរាមកេរ្តិ៍ ។

សត្វថៃនៅប្រទេសកម្ពុជាយើង ទីដែលមានក្រុមល្ងែននេះ គឺនៅឃុំពាមឧកញ៉ាមុង ស្រុកល្វាឯម ខែត្រកណ្តាល តាលើពាងដការត្រូវការលេងក្នុងព្រះរាជពិធីអ្វីតែងហៅក្រុមល្ងែននេះឲ្យមកលេងនៅមុខ

ព្រះបរមកដកំង ។ រីឯលេងនេះធ្លើរកេងមួយធំខ្ពស់ដើម្បីឲ្យអ្នកមើលយើញច្បាស់គ្រប់គ្នា ។

ក្រុមល្ខោននេះ ជាល្ខោនគ ព្រោះតួគអ្នកតំងាំងប្លុំគ្នាមិននិយាយរឿងខ្លួនឯងទេ ឲ្យក្បាច់កំនិយាយជួស តំពួកអ្នកតំគ្រាន់តែកំចាក់ក្បាច់តម្រូវទៅតាមរឿង ចង្ហាញអ្នកមើលឲ្យយ ល់តាមដំណើររឿងរបស់ខ្លួនប៉ុណ្ណោះ មានរូបអ្នកពោលដោយខ្លែកសម្រាប់តែពោលទៅតាមរឿងតាមច្បាក់ ឲ្យអ្នកមើលស្តាប់ដឹងរឿងប៉ាន ម៉ែនដូចល្ខោនខំនើមដែលពួកអ្នកតំគេតំងនគេនិយាយរឿងរបស់គេផ្ទាល់ខ្លួនឯងនោះឡើយ ។ ល្ខោនខោលជាមហោស្រពបុរាណសម្រាប់ជាតិរបស់ខ្មែរ មានលំនាំស្រដៀងគ្នា នឹងល្ខោនបុរាណរបស់ឥណ្ឌា ដែលគេតក្សាទុកជាមហោស្រពសម្រាប់ជាតិរបស់គេនោះដែរ ។ យើងពុំអាចដឹងច្បាស្រ្តល្ខោនខោលច្បាស់លាស់ទេ តែយើងអាចសន្និដ្ឋានថា ប្រហែលជាកើតមានឡើងក្នុងសតវត្សជាមួយគ្នានឹងល្ខោនធម្មតា ដែលយើងបានស្រាវជ្រាវបានពោលហើយពីខាងដើមថា "កើតមានឡើងតាំងពីរជ្ជកាលព្រះរេតុមាលា ជាព្រះមហាក្សត្រខ្មែរដំបូងបំផុតនៅអង្គរ រវាងគ្រីស្តសករាជ ៩០២ ដល់ ៩៦៩" នោះឯង ។ ខ្មែរយើងគួរតម្កល់ទុកមហោស្រពបុរាណរបស់យើង គួរសិក្សា គួរទស្សនា គួររក្សាទុកឲ្យបិតបាំងជាសម្បត្តិរបស់ខ្មែរយើង តទៅអនាគត តាំងគួររៀបចំចំពោះរបៀបការប្តូរក្បាច់ណាដែលមិនល្អឲ្យល្អ ដែលមិនស្អាតឲ្យស្អាត ដើម្បីដំកល់ទុកសម្រាប់បង្ហាញសកលលោកឲ្យយើញស្នាដៃនាជសិល្បៈខ្មែរ ឲ្យសមតាម

ប្រវត្តិសាស្ត្រដែលសកលលោកចាន់ដឹងថាខ្មែរធ្លាប់មានទាដសិល្បៈយ៉ាងជំនាញតាំងពីសម័យអង្គរហូតមក ។

២.— ល្ខោនយីគ្ឌ : វគ្គនេះ ចានដាហៅថា "ល្ខោនយន្ត" ពីព្រោះគេយកឈើស្រាល ។ មានលុសជាដើមមកឆ្លាក់ជារូបមនុស្ស យក្ស សត្វ ប៉ុន ។ កំភួនដៃ លាបថ្នាំពណ៌ធ្វើជារូបតំណាងរឿង សម្រាប់តាញខ្សែយន្តលេងតាមរឿង ជាមហាស្រទាប់ព្រះពន្ធទ្យសម្រាប់លេងក្នុងព្រះពន្ធពិធីផ្សេង ។ មានព្រះពន្ធពិធីជាគំរោកជាដើម មានតួអ្នកវគ្គនេះតែប្រុសដូចល្ខោនខោល ប្រមាណជា ១០ នាក់ អ្នកខ្លះជាអ្នកកាន់រូបតួឯក អ្នកខ្លះកាន់រូបនាង អ្នកខ្លះកាន់រូបនាយកេង អ្នកខ្លះកាន់រូបយក្ស ជាដើម ផ្ទាស់គ្នាតាមរឿង ។ ល្ខោនយន្តលេងក្នុងពិណពាទ្យដូចល្ខោនខោលដែរ តែល្ខោនយន្តមិនលេងរឿងកមក្តីជារឿងធំទេ, លេងតែរឿងតូច ។ ដូចរឿងព្រះដនមវង្ស រឿងសង្ខសិល្បជ័យជាដើម ។ ពេលលេងគេធ្វើពេងមួយធំ ហើយខាងក្នុងពេងនោះ គេចាំងរនាំងឈើឬរនាំងក្រណាត់ មានកំពស់ត្រឹមក្បាលដែលធ្វើអ្នកមើលឲ្យមើលពីក្រៅទៅ មិនឃើញមនុស្សអ្នកកាន់រូបឃើញតែរូបផ្សេង ។ ដែលពួកអ្នកវគ្គនៅខាងក្នុងគេតាញខ្សែយន្តឲ្យចាក់ក្បាច់យ៉ាងណា ។ តាមត្រូវការ ។ ល្ខោននេះក៏ជាល្ខោនតូចដូចល្ខោនខោលដែរ តែល្ខោនខោលអ្នកកំដោយខ្សែក អ្នកពោលដោយខ្សែក, ឯល្ខោនយន្តអ្នកតាញខ្សែយន្តរូបណាពោលរឿងរូបនោះខ្លួនឯង ។ ល្ខោននេះជាវគ្គមួយបុរាណរបស់ខ្មែរដែលមាន

ត្រឿងច្រៀងលេង ទំនងដំណើរលេងច្រវៀលគ្នាទំនងហ៊ីបុកណារបស់ចិន ដែលយើងធ្លាប់ឃើញគេមកលេងនៅប្រទេសយើង ។

អំពីបុកណាមានលេងតាំងស្មោនខោលតាំងស្មោនយន្ត តែគេឈប់លេងស្មោនយន្តនៅចុងរជ្ជកាលព្រះករុណាខត្តិយកោដ្ឋ, ឯស្មោនខោលនៅលេងរហូតដល់សព្វថ្ងៃ ។

៣— ណាំងស្បែក និង ណាំងទ្រលុង: ពាក្យថា "ណាំង" ក្នុងឈ្មោះរបាំនេះជាពាក្យសៀម ព្រោះគេហៅតាមសម័យដែលខ្មែរហើយទំនងសៀមមានទាដសិល្បៈតាក់ទងគ្នា, បើហៅតាមសំឡេងខ្មែរថា "របាំស្បែក" តែក្នុងទីនេះ សូមខុកតាមសំឡេងដែលអ្នកស្រុកធ្លាប់ហៅមកហើយ ។ របាំនេះជារបាំព្រះពជ្រឲ្យសម្រាប់លេងក្នុងព្រះពជពិធីនានា មានព្រះពជពិធីតាំងតុបម្រើនព្រះជន្មវស្សាព្រះករុណាជាអម្ចាស់ដីវិតលើត្បូងជាដើមយូរអង្វែងច្រើនរជ្ជកាលមកហើយ, រជ្ជកាលមុន ។ មានលេងតាំងណាំងស្បែកតាំងណាំងទ្រលុង ដល់មករជ្ជកាលព្រះករុណាព្រះចុលសម្តេចព្រះនរោត្តម · សីហនុ ទ្រង់ឲ្យផ្អាកលេងណាំងស្បែក ដើម្បីជួសជុលរូបដែលខូចឲ្យល្អសិនសឹមលេងឡើងវិញ ទ្រង់ឲ្យខុកតែណាំងទ្រលុងរហូតមកដល់សព្វថ្ងៃ ។

ណាំងស្បែក ហើយនិងណាំងទ្រលុង មានត្រឿងច្រៀងលេងនឹងរបៀបលេងច្រវៀលគ្នា គឺច្រៀងលេងគេយកស្បែកគោឬក្របីមកជាប់ខ្ទមជាក្បាច់ជារូបតំណាងតួផ្សេង ។ លាបម្រ័ក្សណ៍ខ្មៅ ។ ហើយគេយកមកលេងតាមរឿងដែលគេត្រូវការ មានរូបព្រះកម ព្រះលក្ខណ៍

ព្រះនាងសិតា ហនុម៉ាន ឬរូបព្រះជនវង្ស ព្រះនាងបទុមសុរិយា ព្រាហ្មណ៍កេសរជាដើម ក្នុងតែខាងណាំងស្បែកគេថ្មែរូបធំ ៗ មួយ ៗ ប៉ុនមនុស្សក្មេងដំទង់ ១ ផ្ទាំងមានរូប ១ ក៏មាន រូបច្រើនជាផ្ទាំងធំ ទំហំ ១ ព្យាមក៏មាន, ខាងណាំងក្រុងគេថ្មែរូបតូច ៗ មានទំហំតែត្រឹម ៤ ឬ ៥ ឆ្នាប់ កំពស់ ១ ចំអាមប៉ុណ្ណោះ ; មួយទៀតខាងណាំងស្បែកគេលេងតែរឿងធំ គឺរឿងរាមកេរ្តិ៍, ខាងណាំងក្រុងគេលេងតែរឿងតូច ៗ គឺរឿងព្រះជនវង្ស រឿងស័ង្ខសិល្បជ័យ និងរឿងព្រះបន្ទូលោរព ។ ណាំងស្បែកនិងណាំងក្រុង មានតួអ្នករចាំសុទ្ធតែប្រុស ៗ ដូចគ្នា, ណាំងស្បែកមានគ្នា ៣០ នាក់ សឹងមានមុខងារជាអ្នកបរណាំង (អ្នកបណ្តើរស្បែក) តែរឿងខ្លួន គឺអ្នកខ្លះបណ្តើររូបព្រះរាម អ្នកខ្លះបណ្តើររូបព្រះលក្ស្មណ៍ អ្នកខ្លះបណ្តើររូបព្រះនាងសិតា អ្នកខ្លះបណ្តើររូបហនុម៉ាន អ្នកខ្លះបណ្តើររូបតលស្វា អ្នកខ្លះបណ្តើររូបពពាណ៍ ជាដើម ។ ខាងណាំងស្បែកគេលេងក្នុងពិណពាទ្យ, ខាងណាំងក្រុងគេលេងក្នុងខ្លួនខែក មានគ្នា ៧ នាក់ គឺ ២ នាក់កាន់រូបស្បែក, ១ នាក់កាន់គងម៉ន់, ១ នាក់កាន់ឆាប, ២នាក់កាន់ក្រាប, ១ នាក់ទៀតជាភ្ងក ។

ខាងណាំងស្បែកខាងណាំងក្រុង គេបញ្ចាំងរូបស្បែកខ្មៅ ៗ លើស្បែសឲ្យខ្លុះឃើញជាងាកបបុះខ្លែង ជាដេក ដើរ ឈរ អង្គុយ ជាច្បាំងគ្នា ជាស្នេហា ជាទុក្ខព្រួយ ទៅតាមរឿងដូចគ្នា, ក្នុងតែណាំងស្បែកអ្នករចាំខាង ៣០ នាក់ ជាបរណាំងបណ្តើររូបបង្ហាញខ្លួនពីក្រៅស្បែ, ឯណាំងក្រុងមានអ្នករចាំតែ ២ នាក់ កាន់រូប ១ ម្នាក់ បំពាំង

ខ្លួនពីកូនស្បែប៉ុណ្ណោះ តែត្រូវគ្នាតែងណាំងស្បែកខ្លួនណាំងខ្លុងអ្នក បណ្តើរបូខ្លួនអ្នកកាន់រូបណាខ្លួយយកវឿងរូបនោះខ្លួនឯងដូចគ្នា ។

តាមដែលយើងបានសង្កេតស៊ើបសួរចាស់ទុំអ្នកចេះដឹងចំពោះវឿងនេះ បានការណ៍ថា ណាំងស្បែក អ្នកស្រុកហៅថា ណាំងស្បែក តាមធម្មតា ឥតមានវែកប្លែកទេ, ឯណាំងខ្លុង គេហៅថា ណាំងខ្លុងធង ថា អាយ៉ងធង, ដែលគេហៅថា អាយ៉ងនោះ ព្រោះមានជនម្នាក់ឈ្មោះ យ៉ង មានទីលំនៅនៅភូមិព្រែកតាឡុង ឃុំចាក់អង្រែ ស្រុកកណ្តាលស្ទឹង ខែត្រកណ្តាល គាត់ជាអ្នកណាំងខ្លុងយ៉ងដំនាញជាប់តែលេងណាំងខ្លុងក្នុងព្រះពុទ្ធសាសនា នៅបុណ្យរដូវកាលព្រះករុណាស៊ីសុវត្ថិកោដ្ឋ ដល់មករដូវកាលព្រះករុណាព្រះបាទសម្តេចនរោត្តមកោដ្ឋ អំណើរពីឈ្មោះយ៉ងនៅ អ្នកស្រុកជាប់ហៅណាំងខ្លុងថា "អាយ៉ង" រហូតដល់សព្វថ្ងៃ; ដូចឈ្មោះយ៉ែដែលមានទីលំនៅ ភូមិត្រពាំងតា ឃុំពងទឹក ស្រុកកំពង់ត្រាញ ខែត្រកណ្តាលជាអ្នកផ្តើមបង្កើតក្មេងនឹងបម្រែងមួយមានស្គរដើ ១ ខ្លែ ២ ឬ ៣ ក្អមយ ១ ក្រាប់ដៃ ១ ក្រាបសេន ១ ឈឹង ១ ម្ខុនគេបំផុតក្នុងរដូវកាលព្រះករុណាខត្តិយកោដ្ឋ ។ តាំងពីក្មេង, បម្រែងនេះកើតឡើង អ្នកស្រុកគាំងតួងនិយមរាប់អានណាស់ ដល់អំណើរពីឈ្មោះយ៉ែនៅ អ្នកស្រុកហៅក្រមក្មេងនេះថា "ក្មេងអាយ៉ែ, បម្រែងអាយ៉ែ" រហូតដល់សព្វថ្ងៃតាមឈ្មោះយ៉ែអ្នកផ្តើមដំបូង តែដូចកាលគេហៅថា "ក្មេងត្រពាំងតា" តាមឈ្មោះស្រុកដែលឈ្មោះយ៉ែជាអ្នកផ្តើមនោះនៅ ។

៤- កន្ត្រែរ: របាំនេះជារបាំរបស់អ្នកស្រុកតាមធម្មតា ជារបស់ពួកគាត់ចំពោះតែពេលណាដែលមានព្រះពួកពិធីផ្សេងៗ មានព្រះពួកពិធីពួកកសេកជាដើម ដែលពួកគាត់ត្រូវការហៅមកឲ្យលេងម្តងៗ។ របាំនេះ មានតួអ្នករបាំចំនួន ៥ នាក់ មានប្រុសមានស្រីលាយគ្នា គឺ

- ប្រុស ៣ នាក់ជាអ្នកភ្លេង ស្លៀកសំពត់បងកូនក្បាន ពាក់អាវបំពង់ខ្លី ម្នាក់កាន់គងវែង ១ វង់ ម្នាក់កាន់ខ្លែខ្នែ ម្នាក់កាន់ចាប៉ី ម្នាក់ទៀតកាន់គុយ សម្រាប់ពួយកូតដេញដុំជាបទភ្លេងប៉ុណ្ណោះ តម្រូវតាមបង្ហាក់រាំ;

- ស្រី ២ នាក់ជាអ្នករាំ ស្លៀកសំពត់ហួលសម្ពុយ ពាក់អាវបំពង់វែងព័ណ៌ឈៃតង បង់កសំយុង ក្បាលពាក់រវៃ ដៃឆ្វេងស្តាំកាន់ផ្ទឹតក្រជាស រាំតាមបង្ហាក់ភ្លេង។

៥- រាំស្នែងទន្សោង: របាំនេះ គេហៅឈ្មោះ ២ យ៉ាង គឺហៅថា «រាំស្នែងទន្សោង» តាមដែលមានពាក់ស្នែងទន្សោងក្បាលធំខ្លាំង ក៏ហៅ ហៅថា «បុកកំប្រុក» តាមដែលមានបុកកំប្រុកក៏បាន, មានតួអ្នករបាំចំនួន ១៦ នាក់ សុទ្ធតែប្រុសស្លៀកសំពត់បងកូនក្បាន ពាក់អាវបំពង់ខ្លី គឺ:

- ២ នាក់ជាអ្នកបើកបទឲ្យអ្នកឯទៀតបន្តរាំតាម;

- ២ នាក់កាន់ដងកំប្រុក ដែលមានសណ្ឋានដូចដងកញ្ជ្រោ សម្រាប់បុកតាមបង្ហាក់ភ្លេង.

- ២ នាក់កាន់ប៊ីពក.

– ២ នាក់កាន់ស្គរដី;

– ២ នាក់ពាក់ស្នែងខន្ធោងសម្រាប់ស្តេចចាំចាញ់;

– ២ នាក់ពាក់កន្ទុយក្លែកសម្រាប់ស្តេចចាំចាញ់;

– ២ នាក់ពាក់ក្បាលសេះ សម្រាប់កៀងខន្ធោង;

– ១ នាក់ស្លៀកពាក់ជាស្តេចខ្មែរដ៏ធ្ងន់ សម្រាប់ចាំចាញ់ខន្ធោងនឹងក្លែក;

– ១ នាក់ ហៅថា មេជាគ្រូ សម្រាប់បង្គក់ប្រសិទ្ធិឲ្យពួកអ្នកវាំដំបូងនឹងដើរនាំមុខហ្វូងក្នុងពេលចេញលេង ។

រជ្ជាំនេះ សព្វថ្ងៃគេឃើញមានតែនៅខែត្រតាខ្មៅសាត់ ។

រជ្ជាំតាំង ៥ មុខ ដូចរៀបរាប់មកខាងលើនេះ តាមដែលបានស៊ើបសួរមកបានការណ៍ថា សម័យបុរាណវេលាមានធ្វើព្រះពុទ្ធរូបធំៗ ជាផ្សេរការម្តងៗ មានព្រះពុទ្ធរូបជាតិសេកជាដើម ពុទ្ធការបានចាត់ឲ្យលេងជារឿងៗ នៅមុខព្រះបរមពុទ្ធរូបជាមួយនឹងល្បែង ៥ មុខទៀត គឺសួរព័ត៌មានយោលទោង ដាំដូង គុនដំបង ស្ទឹលតាំក្បាលស៊ី តម្រៀបគ្នាជាជួរឃ្លាតៗពីគ្នា តាមលំដាប់ជាការស្នែងក្របី ។ កណ្តាលហ្វូងល្បែងរជ្ជាំតាំងនោះ មានពេងដ៏តល់ស្គរ ១ ដែលមានគូរមុខពហូនៅលើស្បែកពាស ហៅថា "ស្គរជ័យ" សម្រាប់ឲ្យមនុស្សប្រុសម្នាក់ស្លៀកខោស្នាប់ក្លៅ ពាក់អាវផាយក្រហម ដួតក្បាលក្រហម កាន់អង្គុងចាំវាយឲ្យសញ្ញាដល់ល្បែងរជ្ជាំតាំងពួង ។ វេលាលេងម្តងៗ ពួកអ្នកល្បែងរជ្ជាំត្រង់មុខត្រៀមចាំស្តាប់សូរស្គរជ័យ, ពេលផ្តើមលេងអ្នកចាំវាយស្គរ

ជ័យក៏ដើមវាយឡើង ៣ អន្ទងរដ្ឋើល ។, ដល់អន្ទងទី ៣ ល្បែងរបាំ
គ្រប់ម្ខាងក៏ចាប់ដើមលេងឡើងតំណាលគ្នា, ដល់ពេលឈប់គេក៏តាំង
វាយស្គរជ័យ ៣ អន្ទងទៀត ឲ្យសញ្ញាឈប់ ។

និគមវិបឆ:

បទវសន្តតិលកា ពាក្យ ១៤

របាំបុរាណ របស់ជាតិខ្មែរ ជាគ្រឿងដួះ ប្រាប់ពេញលោក,
ថាខ្មែរមានជោគ មានអារ្យធម៌ ល្អប្រសើរ ពីព្រេងនាយ,
ថាខ្មែរជាជាតិ បរមបុរាណ ធ្លាប់មានយស ខ្ពស់ខ្ពុលាយ,
ប្តីប្តើងព្រោងព្រាយ ផ្សាយមហាអំណាច នៅអាស៊ី ទ្វីបនេះណា ។
ត្រូវថែរក្សាខ្មែរ តួរកម្លាថៃ របាំខ្មែរ ពីបុរាណ,
ឲ្យគង់វង្សបាន ជាចោះកាល ល្អត្រកាល យ៉ាងថ្លៃថ្លា,
សមតាមឫជខ្មែរ ដែលធ្លាប់ល្បីល្បាញ ខាងរបាំ ក្នុងលោក
ដោយមានក្តីនឹក ជាមហាក្សត្រា ស្ថាបនា ទុកតមក !

ចាប - ពិធ

កាលានុក្រមប្រវត្តិសាស្ត្រ

ដំណើរទៅកាន់ប្រទេសកូមា

នៃប្រតិភូ ៨ រូប

ព្រះញាណវីរៈ រ៉ាំង - សាឌុម ប្រមុខនៃគ្រែចិនក

រៀបរៀង

ដើម្បីទៅកាន់សន្និបាតកុងត្រូតរៈ នៃខណ្ឌសង្ឃាយនានៅប្រទេសកូមា នាថ្ងៃសុក្រទី ១៦ ធ្នូ ១៩៥៤ តាមសេចក្តីអញ្ជើញនៃរដ្ឋាភិបាលប្រទេសនេះ ពរដ្ឋាភិបាលប្រទេសកម្ពុជាបានចាត់ប្រតិភូ ៨ រូប គឺ

១– ព្រះគ្រូវិសុទ្ធមុនី ថ្ងាង - ស៊ីត វត្តទណ្ឌាលោម ជាប្រធាន

២– ព្រះចៅលដ្ឋសង្ឃវរ្ម ឥន្ទ - ក្តិម " ជាសមាជិក

៣– ព្រះចៅលដ្ឋធម្មយោសារក្តិត ហ៊ុយ អ៊ូច វត្តសាកវន ,,

៤– ព្រះមហា យ៉ញ - កែវ វត្តលង្កា ,,

៥– ព្រះញាណវីរៈ ង៉ន់ - សាឌុម វត្តខ្ទួនមណីភម ,,

៦– ព្រះគ្រូសិរិបញ្ញាមុនី ឌួ - យ៉ន វត្តបទុមវតី ,,

៧– ឧបាសកឧទេស - សារឿម វេយ្យាវច្ចករ សម្រាប់មហានិកាយ

៨– ឧបាសក រ៉ា - ប៊ុនយ៉ង់ ,, សម្រាប់ធម្មយុត្តិកនិកាយ ។

នៅថ្ងៃពុធ ទី ៧ ធ្នូ ១៩៥៥ ប្រតិភូទាំង ៨ រូបនេះ បានធ្វើដំណើរទៅតាមអាកាសយាន ចុះស្នាក់នៅក្រុងបាងកកប្រទេសថៃអស់ ៤ ក្តី ។

ថ្ងៃទី ១១ ធ្នូ បានបន្តដំណើរទៅដល់ក្រុងវ៉ាន់ប្រៃទេសកូមា ។ ពុទ្ធសាសនសភា បានចាត់ឲ្យស្នាក់នៅបន្ទប់លេខ ១៥ - ១៧ - ទីឯ ១៩ ជាន់ទី៣ នៃមហាកុដិមួយឈ្មោះ ឬឡូវ៉ែប៊ែ: ក្នុងចំណោមមហាកុដិចំនួនប្រាំមហាឫសាណាគុហា ។

ថ្ងៃ ១៦ ធ្នូ ព្រះសង្ឃជាប្រតិភូចំនួន ៦ រូប បានចូលក្នុងមហាឫសាណាគុហា ដើម្បីប្រជុំសន្និសីទនានា ជាមួយព្រះសង្ឃជាសន្និតិការកៈប្រមាណ ៦០០ រូប ។ ក្នុងវារៈនេះ ជាសម័យប្រជុំដែលត្រូវប្រតិភូប្រទេសថៃជាប្រធាន បានចាប់សន្និសីទនាអភិធម្មបិដក ត្រង់គម្ពីរបដ្ឋានរួចសន្និសីទនាសុត្តន្តបិដក ត្រង់គម្ពីរខុទ្ទកនិកាយ គឺខុទ្ទកបាឋ ១ ធម្មបទ ១ ឧទាន ១ ឥតិវុត្តក ១ សុត្តនិបាត ១ វិមានវត្ថុ ១ បេតវត្ថុ ១ ថេរគាថា ១ ថេរីគាថា ១ អបទាន ១ ចរិយាបិដក ១ និងនិទ្ទេស ១ ។ កាលសន្និសីទនាបានចាប់គម្ពីរនិទ្ទេសហើយ ក៏ប្រកាសបិទសម័យប្រជុំ ។ នៅសល់គម្ពីរ ៥ ឈ្មោះទៀត គឺ ជាតក ១ បដិសម្ភិទាមគ្គ ១ មិលិន្ទបញ្ហា ១ បដិសោភនេស ១ ខុទ្ទកប្បការណ៍ ១ ដែលកំពុងពិនិត្យផ្ទៀងផ្ទាត់ចោះតម្ព្ហ ហើយនឹងលើកកាន់សន្និសីទនាក្នុងវារៈសន្និបាតខាងក្រោយនេះ ។

សន្និតិវារៈនេះ មានថវិកាសល់ ៤ ខែ គឺបើកសម័យនៅថ្ងៃទី ១៦ ធ្នូ ១៩៥៩ បិទសម័យនៅថ្ងៃទី ១៦ កុម្ភៈ ១៩៥៦ ។ តាំងពីនោះមកពុទ្ធសាសនសភាបានផ្ញើនដំណើរ តួតព្រះសង្ឃីការកៈទៅមើលទីធ្លានមស្ការព្រះចេតិយដ្ឋានទាំងនោះ ដល់ថ្ងៃទី ២៦ កុម្ភៈ ទើបប្រតិភូប្រទេសកម្ពុជា បានឧកាសវិលត្រឡប់ពីប្រទេសកូមាវិញ ស្នាក់នៅប្រទេសថៃអស់ ៨ ៣ ថ្ងៃ

ហើយមកដល់ប្រទេសកម្ពុជា នៅថ្ងៃទី៥ មីនា ១៩៥៦ ដោយសុវត្ថិភាព។

ព្រឹត្តិការណ៍ថ្មីខ្លះនៅប្រទេសកូមា

១- វត្តជាទីសង្កាយនា

ប្រទេសកូមា មានប្រជាជនជាង ១៨ លាននាក់ប្រហែលប្រទេសថៃ មានការគ្រប់គ្រងតាមរបបប្រជាធិបតេយ្យសាធារណរដ្ឋ។ ដោយប្រទេសនេះរងគ្រោះយ៉ាងធ្ងន់ ព្រោះមហាសង្គ្រាមទីពីរដែលទើបរលត់ទៅនេះផង ទឹងដោយប្រជាជនកូមាដែលទើបត្រឡប់បានមកថ្មីៗ នេះមានដំហររឹងប៉ឹងបិតបៀតទៅផង ទើបប្រជាជនកូមា មានលោក អ៊ូ-ក៖អ៊ូ ប្រធានាធិបតី ទឹងលោក អ៊ូ-ន៊ូ នាយករដ្ឋមន្ត្រីជាដើម តែតែបញ្ជូលការស្អប់ខ្ពើមសង្គ្រាម ហើយស្រឡាញ់តេញចិត្ត ទំនាស់សន្តិភាពដោយមធ្យោបាយផ្សេង។

ដើម្បីជាមធ្យោបាយមួយយ៉ាងឯកកង់ការកសាងនោះ ក៏ស្រុះស្រួលបង្កើតសង្គីតិសភា ដែលមានពុទ្ធសាសនសភាជាបង្អែក បរិច្ចាគធនធានជាច្រើនកំពង់លានរូពីយ៍ សាងអាវាសពិសេស ១ ជារបស់ពុជការសម្រាប់ព្រះសង្ឃចតុទ្ទិសមិនចំពោះនិកាយ លើទីលូលធំលូលាយមួយកន្លែង ហៅ សិរិមង្គលបពតិ (ឥឡូវហៅ កបាអ៊ែ) ដែលពីដើមជាបម្ពារកៅស៊ូ តាំងនៅទិសខាងជើងក្រុងរង្គូន ចម្ងាយប្រហែល ៩ គីឡូម៉ែត្រ ពីព្រះចេតិយធំយ៉ាងស័ក្តិសិទ្ធិមួយហៅថា "សិរិដ្ឋិរ:" ដែលប្រតិស្ឋាននៅកណ្តាលក្រុងនេះ។

កន្លែងសន្និបាតនោះ គេបានសាងថាវត្តផ្សេងៗ មានដើមដូចតទៅនេះ:

១- គុហាថ្មមួយឈ្មោះធំ ហៅថា មហាបាសាណគុហា សម្រាប់ជាទីប្រជុំសង្គាយនានៃក្រុមព្រះបង្ឃជាសន្តិតិការកៈ ពាំនាងក្នុងប្រទេសពាំនាងក្រៅប្រទេស ដែលបានទទួលមកកាន់ប្រជុំ ។

២.- មហាកុដិបួនខ្នង ដែលមានឈ្មោះតាមទិសទាំងបួន សម្រាប់ជាទីស្នាក់អាស្រ័យនៃពួកព្រះសង្ឃជាសន្តិតិការកៈ និងពួកព្រះបាលិវិសោធកៈ ព្រមទាំងពួកសមណនិស្សិតផង ។

៣.- កត្តសាលា (ពេលចំអិនកត្តព) និងអាសនសាលា (ពេលឆាន់) ព្រមទាំងទីបរិវេណដ៏ធំលំទូលាយ ។

៤.- ព្រះចេតិយយ៉ាងពិសេស ប្រដាប់ដោយកំពូលទិបមាសមួយ ហៅលោកសន្តិ ដែលកន្លែងនោះជាទីប្រតិស្ឋានព្រះពុទ្ធរូបនិងព្រះសារីរិកធាតុ ។

៥.- ទ្បោសថាគារៈ (ពេលទ្បោសថ) ជាទីសង្ឃសន្និបាតធ្វើសង្ឃកម្មមួយខ្នងយ៉ាងធំធំលាយ មានកំពូលទិបមាសខ្ពស់ស្រោង ។

៦.. សណ្ឋាគារសម្រាប់ទទួលភ្ញៀវពីទីឆ្ងាយឬពីនានាប្រទេស...។

ឥឡូវនេះ កំពុងបន្ថែកសាងពាំងយប់ពាំងថ្ងៃ ទូរបណ្ណាល័យយ៉ាងសម្បើមអស្ចារ្យ ដើម្បីឲ្យសម្រេចពាន់ពីរមហាសន្និបាតលើកក្រោយនេះ ។

២- របៀបសង្គាយនា

កន្លែងសង្គាយនាលើកនេះ គេបានបង្កើតសន្តិតិសការ៉ាវ: មួយ

តាំងនៅក្រុងមន្តលេ ហើយមួយទៀតនៅក្រុងវង្គន សម្រាប់ជាទីប្រជុំពួកព្រះសង្ឃជាលិវិសោធក: ដែលគេនិមន្តមកពីខាងក្នុងប្រទេសទឹងក្រៅប្រទេស ដើម្បីពិនិត្យផ្ទៀងផ្ទាត់ដម្រះបាលីព្រះត្រៃបិដក ដែលមានស្រាប់ក្នុងប្រទេស គឺដែលនាំមកពីក្រៅប្រទេស មានប្រទេសលង្កាទឹងតម្ពុជាជាដើម កាលបានពិនិត្យផ្ទៀងផ្ទាត់ហើយ ទើបប្រគល់ឲ្យពុទ្ធសាសនសភាបោះពុម្ពជាច្បី តាំងពីព្រះនេះបិដកជាដើមទៅ ។ រួចហើយទើបតាំងវ: សន្និបាតនិមន្តព្រះសង្ឃជាសង្គីតិការក: ពីខាងក្នុងប្រទេសទឹងក្រៅប្រទេស មកប្រជុំជើកសម័យសង្គាយនា ។

ក្នុងសម័យសន្និបាតនីមួយ ។ មានព្រះសង្ឃជាសង្គីតិការក:ពប់រយខ្លះ ពប់តាន់ខ្លះ មិនកំណត់ ។ ប៉ើវ: សង្គាយនាកងសម័យណា មានថ្ងៃរវៀលខ្លី ដូចកងបឋមសន្និបាតទឹងចុងមសន្និបាត គឺមានត្រឹមដល់ពប់តាន់រូប ។ ប៉ើមានថ្ងៃរវៀលវែង ។ ដល់ទៅតិរវៀ ដូចកងចតុត្ថវ-សន្និបាតនេះ ឃើញមានតែ ៦០០ រូបប៉ុណ្ណោះ ព្រោះកិច្ចឧបត្ថម្ភព្រះសង្ឃសង្គីតិការក:តាំងនោះ ជាការជួនលើពុទ្ធសាសនសភាតាំងអស់ ។

ការសង្គាយនានេះ មិនជាការជួនអ្វីណាស់លើពួកព្រះសង្គីតិការក: ទេ ព្រោះបាលីដែលត្រូវលើកគាន់សង្គាយនា បានឧទ្ទេសការពិនិត្យផ្ទៀងផ្ទាត់ដម្រះចោះពុម្ពរួចស្រេចអំពីពួកព្រះបាលិវិសោធក:មកហើយ ។ ហេតុនេះនៅវេលាបើកសម័យសង្គាយនាម្តង ។ ក្នុងពេលរសៀលព្រះសង្គីតិការក:តាំងឡាយ គ្រាន់តែចាត់ព្រះថេរ:ពីរូប ឲ្យជាអ្នកសួរធ្វើយដោយត្រួសត្រាយបន្តិច ។ ជាបាលីខ្លះ ជាសម្រាយខ្លះ (ឲ្យសមដល់ពី

ប្រជុំដែលមានពួកព្រះសង្ឃខឹនពួកគ្រហស្ថមកដេរចាំស្តាប់ច្រើន) តាម
គោលព្រះពុទ្ធលិព្រះវិន័យមិនដក អស់រយៈចំនួនកន្លះម៉ោង (លើសខ្លះ
បន្តិចបន្តួច) ហើយបានដល់ត្រឹមណា, ព្រះសង្ឃនីតិការកៈចាំងឡាយ
ក៏ចាំគ្នាផ្តើមអានស្វាធ្យាយព្រះពុទ្ធលិ, ខ្លះមើលសៀវភៅ ខ្លះឲ្យតសូត្រ
មាត់ទេ ចាំងពីកចាំងរសៀលទៅដល់ត្រឹមណោះ គឺគ្រាន់តែធ្វើយក
ចំនួនតាមដែលបានធ្វើមកហើយ តួនអាហារថ្ងៃសម័យ ។ ពីកធ្វើតស់
រយៈ ២ ម៉ោង រសៀល ២ ម៉ោង (លើសខ្លះបន្តិចបន្តួច) ។ ធ្វើដូច្នេះកល់
ថ្ងៃ ឈប់តែថ្ងៃសីល ឬថ្ងៃបុណ្យតិរសេសមួយដងមួយកាលប៉ុណ្ណោះ ។

សង្គាយនាលើកនេះ ប្រទេសភូមា បានសន្មតថាជាឆដ្ឋសង្គាយនា
ព្រោះប្រទេសនេះទទួលស្គាល់តែសង្គាយនា ដែលបានធ្វើរួចមកហើយ
ដូចសាវតីមានបរទេសខ្លះបានសរសេរដូចតទៅនេះ :

សង្គាយនាលើកទី ១ ធ្វើទៅក្នុងពុទ្ធសករាជ ១ ឆ្នាំ ក្រោយពេលដែល
ព្រះពុទ្ធទ្រង់ចូលបរិនិព្វានបន្តិចទៅ ដោយបានទទួលព្រះពាក្យបញ្ជា
ពីព្រះបាទអជាតសត្រូវ ។

សង្គាយនាលើកទី ២ ធ្វើទៅក្នុងវស្សា ១ (ក្នុងរជ្ជកាលព្រះមហា-
វីរៈទ្រង់ប្រសូត) ក្នុងឆ្នាំ ៤៨៣ មុនគ្រិស្តសករាជ ក្រោមការណែនាំ
នៃព្រះបាទកាឡាសោករាជ ។

សង្គាយនាលើកទី ៣ ធ្វើទៅក្នុងពុទ្ធសករាជ ២១៨ ឆ្នាំ ៣០៨
មុនគ្រិស្តសករាជ ដោយមានព្រះបាទធម្មាសោក ជាអ្នកចាត់ចែង

អញ្ជើញសមាជិកចាំនួនប្រាយមកប្រជុំ ហើយបានបញ្ជូនបេសកជនជាច្រើននាក់ ទៅប្រទេសលង្កា ប្រទេសភូមា ដើម្បីទំនាក់ផ្សាយលទ្ធិព្រះពុទ្ធសាសនាទៅបូជាប្រទេស ។

សង្គាយនាលើកទី ៤ ធ្វើទៅប្រទេសលង្កា ។ ទៅក្នុងសង្គាយនានេះហើយ វិដលគេបានកត់ត្រាចម្លងអត្ថបទចាំនួនប្រាយ ពុកជាលើកដម្បូងបង្អស់ គឺនៅឆ្នាំ ២៩ - ១៣ មុនគ្រិស្តសករាជ ។

សង្គាយនាលើកទី ៥ ធ្វើទៅទីក្រុងមន្តលេ ក្នុងឆ្នាំ ១៨៧១ (១) ។ ទៅវេលានោះព្រះបាទមិនដូន - មិន (Mindon Min) បានទ្រង់ព្រះបញ្ជាឲ្យចារិកអត្ថបទដ៏សំខាន់នៃព្រះពុទ្ធសាសនា ទៅផ្ទាំងសិលាតែ ចំនួន ៧២៩ ផ្ទាំង ។ ផ្ទាំងសិលាចារិកនោះ បានផ្តល់ប្រយោជន៍យ៉ាងសម្បើមដល់អ្នកច្បាជដែលមកប្រជុំធ្វើ សង្គាយនាលើកទី ៦ (វិដលក្នុងឆ្នាំនេះ កំពុងធ្វើទៅក្រុងរ៉ង្គូន ក្នុងការណ៍ផ្សែងផ្សាត់ទំនងរៀបចំពុម្ពជាច្បាប់ឲ្យបានត្រឹមត្រូវល្អ នូវអត្ថបទព្រះវិន័យបិដក) ។

ការប្រជុំធ្វើសង្គាយនាលើកទី ៦ នេះ មានតិក្ខុសង្ឃជាតិភូមាចំនួនជាង ៥០០ រូប បានចាប់ធ្វើសហការជាមួយអ្នកច្បាជព្រះសង្ឃជាតិឥណ្ឌា,

---

១ សង្គាយនាក្រៅពីនេះ ដូចបានរួសង្គាយនា ក្នុងអរហន្តសម័យ នាក្រុងអនុរាធបុរីនៃលង្កាទ្វីប ក្នុងរជ្ជកាលព្រះបាទទេវានំប្បិយតិស្សៈក្តី សង្គាយនាដែលមានមកក្នុងប្រទេសភូមា នារជ្ជកាលមនុក្តី សង្គាយនា ដែលមានមកក្នុងប្រទេសថៃ នារជ្ជកាលណារ៉ាក្តី ទំនងរជ្ជកាលថៃក្តី សូម្បីជាសង្គាយនាខាងថៃវិញ ទំនងជារបស់រដ្ឋ តំប្រទេសភូមាគឺបានទទួលស្គាល់ជុះនាមក្នុងលំដាប់នេះទេ ប្រហែលជាទីប្រឌិយល់ឃើញថាពាក្យបដោយអង្គគ្រប់គ្រាន់ល្មមរាប់ថាជាសង្គាយនា ឬពុំសូវមានគុណប្រយោជន៍យ៉ាងណាដឹង ? ។

លង្កា , ថៃ , ខ្មែរនិងលាវ ។ល។ ដែលជួយធ្វើការដើម្បីចោះពុម្ពផ្សាយ
នូវព្រះពុទ្ធដីកាយ៉ាងត្រឹមត្រូវ ជាភាសាបាលី, កូមា, ឥណ្ឌា, ទេវនាគរី,
រ៉ូម៉ាំង និងភាសាអង់គ្លេស ក្នុងវិធានការដែលអាចធ្វើបាន ។

នេះគឺជាកិច្ចការមួយដ៏ប្រពៃនៃសាសនាធំជាសាកល ដែលព្រះ
សក្យមុនីបានចាប់បង្កើត អាចជួយស្រោចស្រង់អស់ពាន់ប្រជាជាតិឲ្យផុត
ចាកសង្គ្រាមដោយយកពុទ្ធមន្ត គឺអហិង្សានិងមេត្តាភាពមកប្រើ ។ ដូច្នេះ
ប្រទេសឥណ្ឌាមានប្រជាជនចំនួន ៣៦០ លាននាក់ បានត្រូវប្រឹងយ៉ាង
អស់ពីហឺងធ្វើសហការជាមួយប្រទេសកូមា និងប្រទេសឯទៀតដែលកាន់
ព្រះពុទ្ធសាសនាដែរ ដើម្បីជាប្រយោជន៍ដល់សាកលលោក ។

ជំណើរដ៏ល្អគួរគិត

ទៅវេលាមុនមហាសង្គ្រាមលើកទី ២ នេះ ពួកពុទ្ធសាសនិកជន
ក្នុងប្រទេសនានាហាក់ដូចជាអស់សង្ឃឹមសោះទៅហើយ ថាយើងនឹង
បានទៅមកវិញ ប្រជុំពិភាក្សាដោយស្មោះស្ម័គ្រ អំពីព្រះធម្មវិន័យរបស់
ព្រះសាស្តាយើង ដូចក្នុងឆ្នាំសង្គីតិកាលនេះឡើយ; ព្រោះសម័យនោះ
ប្រទេសខ្លះជាអាណានិគមរបស់គេ ហើយខ្លះទៀត នៅក្រោមអាណា-
ព្យាបាលរបស់គេ ។ សូម្បីប្រទេសខ្លះ ដែលទៅជាឯករាជ្យដូចបច្ចុប្បន្ន
ក៏គ្មានឥទ្ធិពលនឹងបំពេញការណ៍យកចិត្តចំពោះព្រះពុទ្ធសាសនា ឲ្យមាន
ការចាត់ទង់គ្នារវាងជនបរទេសបែបនេះបាន ។ ម្ល៉ោះហើយសូម្បីប្រទេស
កម្ពុជាយើងផ្តើមបង្កើតសមាគមណាមួយ ដើម្បីរួមកម្លាំងគ្នាលើកតម្កើង

ព្រះពុទ្ធសាសនា ការនោះក៏ពុំបានបំពេញគ្នានផ្លូវសង្ឃឹម ដូចពុទ្ធិក-
សមាគមដែលតាំងឡើងក្នុងប្រទេសតាំងពីយូរយៅសម័យនេះទេ ។

សម្តេចក្រុមព្រះវជិរញាណវង្ស អធិបតីពុទ្ធសាសនបណ្ឌិតសភាព្រះ
នាមសុធាសេ តែងមានព្រះបន្ទូលហើយព្រះបន្ទូលទៀត ចំពោះខ្ញុំ
(អ្នកសរសេរឿងនេះ) ថា:

"បើប្រទេសយើងឯកពាជ្យ យើងទំងន់រួមកម្លាំងគ្នាបង្កើតសមាគម
"បញ្ជូនអ្នកចេះដឹងទៅអប់រំវិញ្ញា ទឹងជិតឱ្យមើលបុរាណចេតិយដ្ឋាន
"ព្រមតាំងកិច្ចការប្រតិបត្តិខាងពុទ្ធសាសនាក្នុងប្រទេសនានា ហើយ
"ដើរសួរយកវិបបបទទម្លាប់ទំនៀមដែលល្អ។ មកបង្រៀនអប់រំដាតិ
"យើងឱ្យអនុវត្តតាម ។ បើធ្វើដូច្នេះបាន មិនយូរប៉ុន្មានប្រទេសយើងគង់
"សម្បូរអ្នកចាស្ត ដែលអាចចូលកាន់មហាសន្ធិបាតនានាប្រទេសខាង
"ពុទ្ធសាសនា ហើយញ៉ាំងសាសនាទំងប្រទេសយើងឱ្យមានកិត្តិយស
"ផ្សព្វផ្សាយទៅក្នុងសកលលោក ។ តែធ្វើម្តេច បើប្រទេសយើងទៅ
"ក្នុងទីមរបស់គេ កាលណាគេទំងើបឱ្យយើងធ្វើដូច្នេះបាន" ។

ដោយខ្ញុំធ្លាប់បានដឹងហេតុការណ៍ដូច្នេះ ដល់ខ្ញុំបានទៅយើញកិច្ច
ការពុទ្ធិកសមាគម (ដែលគេហៅថាពុទ្ធសាសនសមីតិ) ទំងការស្ថាបនា
អាវាសថ្មី ជាទីសង្ឃាយនា ព្រមតាំងកិច្ចការគណៈកម្មការថែទាំព្រះមហា-
ចេតិយដ្ឋាន របស់រដ្ឋកូមានោះ ខ្ញុំរីតតែជ្រះថ្លាក្នុងកិច្ចការនោះខ្លាំងឡើង
ហើយទឹកអាល្ហោះអាល័យសម្តេចព្រះបរមកដបិតាសុធាសេពន់ពេក ដ្បិត
ខ្ញុំបងឱ្យព្រះអង្គបានទ្រង់ជ្រាប ហើយទ្រង់អនុមោទនាវីរកាយចំពោះកិច្ច

ពុទ្ធសាសនាផង ព្រោះសព្វថ្ងៃកំពុងមានព្រឹត្តិការណ៍ដើរ
ទៅត្រូវចំចិដៅប្តូចំណុចព្រះទ័យព្រះអង្គហើយ ។

ឥឡូវនេះ កិច្ចការរបស់កូមាខាងពុទ្ធសាសនា មានចំនងដ៏ល្អណាស់
ក្នុងពិធីសាងសាមគ្គី ឲ្យបានជិតស្និទ្ធជាមួយនានាប្រទេសពុទ្ធសាសនិក
ទាំងខាងថេរវាទ ទាំងខាងអាចរិយវាទ ទីធ្វើការផ្សព្វផ្សាយព្រះពុទ្ធ-
សាសនាតាមទាំងកំតុំយស់ប្រទេសគេ ឲ្យប្លែកដៅក្នុងសកលលោក ។
កូមាបានចំណាយប្លែកសមាគមជាវដ៏សំខាន់ ។ នៅប្រទេសលង្កាខ្លះ
ប្រទេសឥណ្ឌាជាដើមខ្លះ សាងអាកាសសម្រាប់ព្រះសង្ឃកូមាទៅទៅ
ស្នាក់អាស្រ័យ ដើម្បីទស្សនាព្រះចេតិយដ្ឋានផង ដើម្បីអប់រំចំពេញវិជ្ជា
ខាងពុទ្ធសាសនា ទីធ្វើយព្រះពុទ្ធសាសនាជាដើមផង ។ តទៅ
យើងអាចជឿបានថា ដំណើរការរបស់ប្រទេសកូមនេះ ទីធ្វើអាចតាញ
ដំណើរការរបស់ប្រទេសយើង ឲ្យមានសភាពចុះសម្រុងគ្នាខ្លះមិនខាន
បើយើងឃើញច្បាស់ថា ដំណើរការនេះមានហេតុផលល្អមែន ។

ដំណើរគណៈប្រតិភូខ្មែរ

ទៅប្រជុំសន្និសីទនៅប្រទេសឥណ្ឌា

លោក ចាប-គិន រៀបរៀង

ព្រះពុទ្ធសាសនិកជនប្រទេសកម្ពុជា ជាទូទៅ ព្រះគ្រូសង្ឃសត្តាប៊ុណ្យ-សុម្ភាជ ជាប្រតិភូខ្មែរ ដោយមានសាមណេរ ស៊ីជន ហ៊ីល ជាតិអូស្ត្រាលី និងលោក គាន់-ចូហេង ជាវេយ្យាវច្ចករផង ទៅរួមប្រជុំសន្និសីទជាមួយនឹងគណៈកម្មាធិការទីប្រឹក្សាទៅពុទ្ធគយា ប្រទេសឥណ្ឌា កាលពីថ្ងៃទី ១៣ មីនា ព.ស. ២៤៩៩ គ.ស. ១៩៥៦ ។

សេចក្តីសង្ខេបកិច្ចសន្និសីទនោះ ដូចតទៅនេះ :

សមាជិកគណៈកម្មាធិការទីប្រឹក្សាស្តីពីប្រទេស ទឹងកូង ប្រទេសឥណ្ឌា ២២ រូប ដែលបានមកប្រជុំតែ ១៥ រូប បានចូលរួមប្រជុំនៅថ្ងៃទី ១៨ មីនា ១៩៥៦ ជា ២ លើក: លើកទី ១ នៅម៉ោង ១០ និង ៤៥ នាទីព្រឹក, លើកទី ២ នៅម៉ោង ១៤ រសៀល ។ កាលសមាជិកមកដួបជុំហើយ លោកពន្លឺស្ថាន អនុប្រធានាធិបតីប្រទេសឥណ្ឌា បានថ្លែងសារលិខិតបើកសម័យប្រជុំ ។ បន្ទាប់មកលោក ស.គ. មូតីជី តំណាងរដ្ឋាភិបាលឥណ្ឌា បានអានសេចក្តីកត់ការណ៍អំពីគោលសំខាន់ៗ របស់គណៈកម្មាធិការចាត់ចែងទីពុទ្ធគយាជូនពោលដោយសង្ខេបតទៅនេះ :

– អំពីដំណើរការដែលគណៈកម្មាធិការនេះ បានចាត់ចែងធ្វើមក

ជាបដល់ពុទ្ធគយាឆ្ងាត់មកនៅក្នុងកណ្តាប់ដៃគណៈកម្មាធិការនេះ តាំងថ្ងៃ
ពេញបូណ៌មីខែវិសាខ ១៨៥៣ ;

– អំពីចំនួនហិរញ្ញវត្ថុដែលបូជនីយវត្ថុ ទឹងទស្សនជនបានបូជា
ក្នុងមួយឆ្នាំៗ តាំងពីឆ្នាំ ១៨៥៣ - ៥៤-៥៥ មកទល់ទឹងខែកុម្ភៈ ១៨៥៦
ដោយកាត់ចំណាយចេញទៅនៅសល់ ១៦.៤៦៧ រូពីយ ៤៥ ;

– អំពីការរៀបចំវត្ថុពុទ្ធគយា ឲ្យមានបរិវេណខាងក្រៅធំទូលាយ
ទឹងជួសជុលព្រះមហាចេតិយពុទ្ធគយាត្រមាំងទីដុំវិញឲ្យបានល្អ ;

– អំពីការបែងចែកទីដីនៅពុទ្ធគយាឲ្យដល់រដ្ឋាភិបាលគ្រប់ប្រទេស
ពុទ្ធសាសនិកដែលត្រូវទុំបជួលដោយមានកំណត់កាលជាយូរ ដើម្បី
យកធ្វើវិហារ កុដិ បណ្ណាល័យ ទឹងសាលាសំណាក់រៀងខ្លួន.

– អំពីការរៀបចំពិធីបុណ្យសម្ពោធពុទ្ធសកពជគម្រប ២៥០០ ;

– អំពីការបំរែបំរួលធ្វើបុណ្យសម្ពោធពុទ្ធសកពជគម្រប ២៥០០ ។

ចំពោះបញ្ហាខាងក្រោយនេះ សមាជិកគ្រប់ប្រទេសបានមូលមតិ
ថា ទឹងត្រមត្រៀងគ្នាមកធ្វើបុណ្យនេះ នោះក្នុងខែវិច្ឆិកាវិញ ព្រោះខែ
នេះប្រទេសឥណ្ឌាមានអាកាសធាតុមិនក្តៅណាស់ដូចខែឧសភា ហើយ
មិនទាន់ចូលរដូវរងាផង តាំងត្រូវគ្នាទឹងសន្និសំពុទ្ធិកសមាគម
តិកតលោកនៅក្រុងកដ្ឋមណ្ឌទឹងលុម្ពិនីប្រទេសនេប៉ាល់ក្នុងថ្ងៃ ១០ ដល់
២០ វិច្ឆិកាផង ។

យោបល់នៃគណៈប្រតិភូខ្មែរ

ពុទ្ធគយាសព្វថ្ងៃ នៅក្នុងកណ្តាប់ដៃ អ្នកកាន់សាសនាហិណ្ឌូនៅ

ឡើយ, ហើយក្នុងសមាជិកគណៈកម្មាធិការចាត់ចែងទីពុទ្ធគយា ៩ រូប មានតែ ៤ រូបទេដែលជាពុទ្ធសាសនិក, ចាំឯគណៈកម្មាធិការទើប្រឹក្សាទៀតសោតក៏មានសមាជិកជាជាតិផ្សេងៗភាគច្រើន. ហេតុនេះគួរតែគ្រប់ប្រទេសពុទ្ធសាសនិក ចាត់អ្នកតំណាងឲ្យទៅគាន់ទីប្រជុំគ្រប់ពេលដែលប្រទេសផ្សេងៗត្រូវអញ្ជើញកុំខាន ដើម្បីឲ្យមានហេតុប្រសើរចំពោះសេចក្តីសម្រេចនីមួយៗ ដែលត្រូវជាប្រយោជន៍ចំពោះប្រទេសពុទ្ធសាសនិកទាំងមូល ។

ប្រទេសកម្ពុជាគួរតែសុំឲ្យបានទីជាមួយកន្លែង នៅមណ្ឌលពុទ្ធគយាដើម្បីសង់វិហារ កុដិ បណ្ណាល័យ សាលាសំណាក់ សម្រាប់ប្រទេសរបស់ខ្លួន ។

. . . . . .

គណៈប្រតិភូនេះ ត្រឡប់មកគាន់មាតុភូមិវិញ នៅថ្ងៃទី ៤ មេសា ១៩៥៦ ។